ក្រុមជំនុំវិន័យចារីតប្បញ្ញត្តិ
COMMISSION DES MŒURS & COUTUMES

ភគ្គិយសុត្តទេសនា


ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣០ លេខ ៤ ខែកញ្ញា
ព.ស. ២៥០១ គ.ស. ១៩៥៨
ភ្នំពេញ

ពិធីបុណ្យថ្វាយព្រះពរទំងថ្វាយព្រះរាជកុសលចំពោះ សម្តេចព្រះនរោត្តម សីហនុ ។

កាលពីថ្ងៃសុក្រទី ១៩ កញ្ញា ១៩៥៨ រដ្ឋសភានីតិក្រមច្រីក្សព្រះរាជអាណាចក្រ បានធ្វើបុណ្យថ្វាយព្រះពរ នីតិថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះនរោត្តមសីហនុ ព្រះបិតាឯករាជ្យជាតិដែលព្រះអង្គកំពុងបំពេញព្រះមហាបេសកកម្ម តាងនាមប្រជាជាតិខ្មែរ ក្នុងកិច្ចប្រជុំនៅមហាសន្និបាតនៃអង្គការសហប្រជាជាតិនោះ ដោយបាននិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ. សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រមទាំងព្រះសង្ឃភាំងពីរគណៈ មានចំនួន ៣៩ អង្គ មកចំរើនព្រះបរិត្ត ក្នុងមន្ទីរដ្ឋសភា ។ ចំរើនព្រះបរិត្តចប់ អាចារ្យបវារណាបច្ច័យ ៤ ចំពោះព្រះសង្ឃ តាមពុទ្ធានុញ្ញាត ។

ពិធីបុណ្យខេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ៩ នឹង ១៥ នាទីល្ងាច ។



ភ្នំពេញសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ធំងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ (តមក) ព្រះមហា ជាំង-ខាត់ រៀបរៀង	៧៥៥
	- សទ្ធម្មប្បជោត (តមក) ព្រះមហា អ៊ុក-អ័ន រៀបរៀង	៧៦៣
	- ពុទ្ធសាសនា ធៀបសាសនាដទៃ (តមក) របស់លោក ជា-យូ	៧៧៩
	- អត្តនោកម្មការណកថា ព្រះមហា អ៊ុក-អ៊ុន រៀបរៀង	៧៨៧
ផ្នែកអក្សរសាស្ត្រ		
	- រឿងទេវន្ធរបស់អម្រឹតក្សត្រីម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៨០៩
	- រឿងសាមកុក (តមក) ឧកញ៉ា នូ-ពន ប្រែ	៨១១
	- សភាសិតអភរប់ លោក ភ័យ-ប៊ុក ឯកស្រង់រៀបរៀង	៨២៣
	- រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន (តមក) លោក ភ័យ-ប៊ុក ប្រែរៀបរៀង	៨២៧
	- អធិប្បាយច្បាប់កៅ្ខ ការ ស្រី អ៊ូ រៀបរៀង	៨៣១
	- ប្រវត្តិវត្តវិហារសូរ លោក ជាប-ពិន រៀបរៀង	៨៣៥
ផ្នែកកំណត់ទឹងប្រវត្តិការណ៍		
	- ពត៌មានផ្សេង ៗ របស់ក្រសួងធម្មការ	៨៤៣
	- ពិធីទទួលព្រះត្រៃបិដកជាភាសាទីបេត	៨៤៦
	- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហាជាំង-ខាត់ រៀបរៀង	៨៥០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

-Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 755
-Saddhammappajota (suite) par Vén. *OUK-IN* 763
-Bouddhisme comparé (suite) par *M. CHEA-YOU* 779
-Attanokammakaranakatha par Vén. *OUK-IN* 787

PARTIE LITTERAIRE :

-Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 801
-Histoire de Samkok (suite) traduite par *M. NOU-KAN* . . 811
-Proverbes arabes par *M. RAY-BUC* 823
-Conte et Légende du Japon (suite) traduits par *M.RAY-BUC* 827
-Commentaire du Chbab kel-kal par *M. SREY-OU* . . . 831
-Historique de Vat Vihar-Suor par *M . CHAP-PIN* 835

NOTES ET CHRONIQUES :

-Chroniques du Ministère des Cultes 843
-Cérémonie de réception du Tripitaka en langue tibétaine 846
-Dictionnaire Sanskrit-Khmèr (suite) par Vén. *PANG-KHAT*. 85

Prix d'abonnement annuel (comprenant 12 numéros) : 230 r00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ឃឹង-ខាត់ រៀបរៀង

(តមក)

ទឹកដោះខាប់ ២៥ ឃដីក:, ក្បុរ ទង្គិ មួយមុខ ៣១ ឃដីក:, ទឹកឃ្មុំ ១៨ ឃដីក:, ទឹកកេសដ្ឋ:ផ្អែម(ទឹកលាយស្ករដូចស៊ីរ៉ូបឬទឹកអំពៅ)១៨ ឃដីក:, ប្រេងល្ង ២កុប្បុ: ១៥ឃដីក:, ខោពស្ត្រ (គ្រឿងស្លៀកពាក់) ១៨៨១ គូ ។ បូកវរួមមួយឆ្នាំអង្គរ២៨..០៤០ភារី, ១ព្រាណ:, ស្រូវ១១២.១៦១ ភារី ។ យកអាករមកពីស្រុក:

អង្គរ ៤.០៨៣ ភារីកា ១ ព្រាណ: ២ កុប្បុ:. ល្ង ១៨៣ ភារី ២ព្រាណ:៦ប្រស្ដ:; សំណែកដី២១០ភារី២ ព្រាណ: ១០ ប្រស្ដ:; ទឹកដោះខាប់ ៤០០ ឃដីក: ៨ ប្រស្ដ:; ទង្គិ៧ប្រស្ដ:៥០៧ឃដី ក្បុរ១ ប្រស្ដ:; ៥៨៦ឃដី:; ទឹកឃ្មុំ ៥ប្រស្ដ:៥៣៨ ឃដី; ទឹកកេសដ្ឋ:ផ្អែម៤៨០ឃដីក: ប្រេងល្ង ១៣ ប្រស្ដ:, ប្រេងតរុផល ៥ ប្រស្ដ: ៥ ឃដី ។

យកអាករមកពីផ្ទះអ្នកគម្បាញ ពីស្រុក ពីផ្សារ. . .

គ្រឿងស្លៀកពាក់ ចំនួន៤០.០៨៥ សម្រាប់; សំណុះឃ្មុំ ១៧ភារ:

១៨ តុលា, ៥ ឃដី ៨ បណ:; សំណ ៥១ ការ: ១៣ តុលា ១ កដ្ដិកា, សេះ ១ ពាស៊ី ២ ដំរី ២ ។

ព្រះពជ្រព្យនិធិទេយ្យទានពីអ្នកមានទ្រព្យនៅស្រុក៣.១៤០ស្រុក សម្រាប់ទុបត្ថម្ភគឺ ៖

បុរស ៤០០ នាក់, អធិការ (មហាវេរ) ១៨ អង្គ, អធិការរង (អនុវេរ) ២.៧៤០ អង្គ, បរិចារក: (អ្នកបំរើ) ២.២៣២ នាក់. រួមចំនួនបរិចារក៦១៥ នាក់ ជានាជកិច្ច (ស្រីស្នេហ)ផង, បូករួមចំនួនអស់ ១២.៦៤០ នាក់ រាប់ចំនួនអ្នកដែលដេកនៅក្នុងទីនេះផង, ស្ត្រីប្រុស ៦៦.៦២៩ នាក់ សម្រាប់បំរើវេរបូ, បូករួម ៧៩.២៦៩ នាក់ ព្រមចំនួនជាតិបូតាមនិធិចម្បា (កូមានិធិចាម). . . ។ មាសរបនាជាស្លាបូ ចានដើង . . . . . ២៨ ការ:, ៤ តុលា, ២ បាទ:, ៥ កដ្ដិកា: ប្រាក់: ២០ ការ:, ១៥ តុលា, ២ កដ្ដិកា. ២ បាទ:, ៤ បណ: តម្លៃ ៣៥ គ្រាប់, ផ្ទុតពីរប្រជាប់ដោយគជវង្ស: គជវង្ស ៤០.៦២០ គ្រាប់; រតនវត្ថុត្បូង គ្រប់មុខ ៤.៥៤០ គ្រាប់ . . . .; ស្លាន់ ១២០ ការ: ១៣ តុលា, ១ កដ្ដិ. ៥ បណ:; តែងសំណ ២.៣៣៨ ការ:, ១៧ តុលា; ខ្លះមាសមួយ ២៤ ការ:; ចានស្លាន់ ១ តុលា, ៦១៥ ការ:; សំណ ១០ កដ្ដិ. ៧ តុលា, ១៥ ការ:; សំណសុទ្ធ ៤៣៧ ការ: កន្លះតុលា; សំពត់ចិន ៤៦៧,

កម្រាលសូត្រ៩១២; ខ្សែ៩២៣ . . ; ប្រាសាទកំពូល (ព្រះស្ពឹបតូច?) ៣៩, ទីលំនៅធ្វើពីថ្ម៩៦៦, ទីលំនៅធ្វើពីឥដ្ឋ២៨៨, ស្រះ បឹង ទំនប់ ៧៦ព្យាម បណ្តោយ១.១៩០ព្យាម, ថ្មរៀបប្រការជុំវិញ២៧០២ ព្យាម, ធម្មាវី (តិក្ខុសង្ឃ)៤៣៨អង្គ ខ្លួសកត្តកាលំថ្ងៃក្នុងព្រះពជមន្ទីរ, អ្នកនៅជាមួយគ្រូ (សិស្ស?) ៨៧០នាក់, បូករួម ១.៤០៨នាក់ ។

ធ្វើបុណ្យវេចត្រ ពីថ្ងៃទី៨ទៅថ្ងៃពេញបូណ៌តាមប្រពៃណីព្រះជិនស្រី; ធ្វើបុណ្យតាមប្រពៃណីព្រះកតវតី (ប្រាជ្ញាចារមិនា?) ថ្ងៃ១៤ទឹង១៥កើត ហៃប្រទក្សិណព្រះកតវត (លោកេសូរ?) ព្រះកតវតី (ប្រាជ្ញាចារមិនា?) ទេពតាវីរ:, សក្តិនឹងទៅតាជាទៃទៀត; ក្បួនហៃ ទង់សុវណ្ណផ្កាលា, ខ្សែ . . . តួរឫតន្ត្រីឮសូរមុខគួរឲ្យរំកើបចិត្ត; អ្នកកាន់ស្រីប្រុស កុមារវៀនរាំឲ្យបានសុក្រឹត្យទាន់ការឲ្យបានទាន់ចរិយាល្អ, បូជាចំពោះព្រះគុណអង្គ ចំពោះទេពតា ១០០០ ចំពោះទៅតា ៦១៩ ដែលនៅពីនេះ: ខ្នុកបំរុងអ្នកប្រាជ្ញ; តិក្ខុ ព្រាហ្មណ៍ . . . ; គោតិកា៩១, កង៨៩, មាសឥបណ: (ទម្ងន់រួម); សំលៀកបំពាក់សម្រាប់ទេពតា ទឹងគ្រឿងស្លៀកពាក់អ្នកដទៃទៀត ១.១០៧ប្រដាប់, អាវក្រៀង៣, អាវពោមសត្វ២, អាវតួច ២៩, ឈ្នួតក្បាល២០, តុក្កុក១, ប្រអប់ដាក់ទឹកអប់៨៩, ខ្ទះ១, ពែងផឹកទឹក១០០; សំណរ.ប៦៦តុលា; ដំរីស្រលាំងនឹងសណ្តែកភៀងជាមួយគ្នា

៤គុណ, ១៦កដ្ដិការ; ទៀនក្រមួនធំ ១៦៥ . ៧៤៤ទៀនក្រមួន ១.៤០០ ការៈ, ៣៤គុណ; ម្ហូស្ងា, កម្រងផ្កា ។

អង្គរសម្រាប់ចំអិនថ្វាយទេវរូប: ៦៣០ភារ, ១៣ ប្រស្នៈ ជាយ: ១៦ ប្រស្នៈ; ល្ង ៣ ភារកន្ទុះ, ១១ ប្រស្នៈកន្ទុះ; សណ្តែកដី ៣ភារតា, ១ ទ្រោណៈ, ១ ប្រស្នៈកន្ទុះ; ទឹកដោះគោខាប់: ៤ ឃដី, ៥ ប្រស្នៈកន្ទុះ ទធ ៤ ឃដី, ១១ ប្រស្នៈ; ក្សីរៈ ៤ ប្រស្នៈ; ទឹកឃ្មុំ ៧ ឃដី; ទឹកកេសដ្ឋៈផ្អែម ៤ ឃដី, ១០ ប្រស្នៈ; តប៊ូរ ១ ថាខៈ, ៣ មាឍៈ, ៤ ពិម្ពៈ តុរ្សុស្កៈ (?) ១១ បណៈ; ឈើក្រអូប (?) ៨ បណៈ, ១ ថាខៈ ១ មាឍៈ; ជាតិហិង្គុលៈ ៤ ពិម្ពៈ; ចន្ទន៍ក្រឹស្នាៈ ២ កដ្ដិ, ៣ បណៈ, ៣ ថាដកៈ, តៃលកៈ (ភ្ញាញ់សត្វញើ? ឬដំរណើសសម្រាប់ធ្វើទឹកអប់) ១ បណៈ, ២ មាឍៈ, ៦ ពិម្ពៈ; ប្រេងល្ង ១ ប្រស្នៈ, ២ កុឌុវៈ; ខ្ទឹសស្ងួត: ២ ថាខៈ, ១០ កដ្ដិ; វត្ថុតំងនេះ តាំងពីគោកក្សាមក ត្រូវយកពីឃ្លាំងព្រះរាជទ្រព្យ ។

វត្ថុដែលត្រូវយកពីឃ្លាំងព្រះរាជទ្រព្យពាល់ឆ្នាំជូរឆ្នេះ ៖

អង្គរៈ; ២ ទ្រោណៈ; ៤៧០ ភារៈ; ល្ង; ២៦ភារៈ; ១ ទ្រោណៈ; ៤ ប្រស្នៈ, សណ្តែកដីៈ; ១ ទ្រោណៈ; ១០ ប្រស្នៈ; ៣៧ ភារតា; ទឹក-ដោះខាប់ ២៦ ឃដីៈ; ៩ ប្រស្នៈ; ទធ ៤ ប្រស្នៈ; ១ ឃដីតាៈ; ក្សីរៈ; ប្រេងជាធ្ងន់ៈ; ទឹកឃ្មុំៈ ៧ ប្រស្នៈ, ២១ ឃដីៈ; ទឹកកេសដ្ឋៈផ្អែមៈ; ១៦ ឃដី,

១ អាជ្ញា; ប្រៃឆ័ល; ១០ ប្រស្ត; ៣ ឃដី; ទេវពស្ត្រ (គ្រឿងស្លៀកពាក់) ២.៣៨៧ គូស សម្រាប់ទេវរូបនឹងគ្រឿងស្លៀកពាក់ដាក់ទេវតា; គ្រែនឹងអង្រឹង ស្នែង២៤, ពួក២០, មុង ៣៦; កម្រាលដេកចិនប្រកស្មៅ ២០,កម្រាលដេកព្រៃចិន ២៥; ក្រមួន ១ ការ; ១០ គុលា; មរិច; ៥ ប្រស្ត; ៣ក្រាណ; ២ ភារ; ចន្ទន៍ក្រឹស្ន ១ គុលា, ១២ កដ្ដី, ៣ ជាខ; ដំរស្រល់; ៣០ គុលា, ១៣ កដ្ដី; សណ្ដែកខ្មៅ; ១២ កដ្ដី, ១៥ គុលា; កប៊ូរ; ២ កដ្ដីកា, ៦ បណ; ភ្លុស្ត; (?) ១២ បណ, ១ កដ្ដី; ឈើ-ក្រអូប (?). ១០ បណ; ជាតិហិង្គុល; ២ កដ្ដី ៥ បណ; កងមាស១; គោតិក្ស ១, ប្រអប់មៀស ៣០ បណ; ប្រាក់; ៣០ ណប; ស្ពាន់; ៧ គុលា, ២ កដ្ដីកា; សំណ; ២ គុលា; ហ៊ាបចិន ៥០០; អំបិល; ៣២ ភារ, ៣ ក្រាណ; សំណខ្មៅ; ៣០ គុលា; សេះ ១ គោញី កបិលាប្រជាប់តាក់តែង ដោយគ្រឿងមាសត្រមាំងកូនគោផង ១; មានមន្ទីរពេទ្យ (អាពេគ្យសាលា) ១០២ នៅគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ។ ក្នុងមន្ទីរពេទ្យទាំងនេះ មានទេវរូប ៧៩៨ អង្គ ។ ត្រូវចំណាយអង្ករ ១១៧.២០០ ភារីកាសម្រាប់អ្នកជម្ងឺដែលដេកនៅក្នុងមន្ទីរពេទ្យ ។ ស្រុក ៨៣៨ ស្រុក បុរសស្ត្រី ៨១.៦៤០ នាក់ សម្រាប់ប្រចាំការក្នុងមន្ទីរពេទ្យនេះ ។

នេះបញ្ជីដែលត្រូវចំណាយកាលឆ្នាំពីឃ្លាំងព្រះពជទ្រព្យ:

ទ្រព្យសម្បត្តិ, គោកង្កា, កង: ១៦ បណ:, ២ ជាខ:, ៣ មាម:, គ្រឿងស្បៀកពាក់សម្រាប់ខែវប្រេ នឹងជាដៃទៀត ១.៦០០ សម្រាប់; បន្ទូន់ក្រឹស្ន: ១៤ បណ:, ៦ កដ្ឋី, ១ តុលា; ជ័រស្រល់: ៧ តុលា, , ៨ កដ្ឋី, ៤ បណ:; សណ្តែកខ្មៅ ៦ តុលា; ១១ កដ្ឋី, ១០ បណ:; ក្រមួន: ៦ តុលា, ៣ បណ:; ទឹកឃ្មុំ: ១១១ ឃដិកា, ៦២ ប្រស្ន:កន្ទុះ; កេសជ្ជ:ផ្អែម: ១២ ឃដិកា, ១២ ប្រស្ន:; ទធិ ១០ ឃដិ, ៩ ប្រស្ន:, ២ កុព្វ:; ល្ង: ៦២ ភារិកា, ១ ទ្រោ-ណ:; ជីប្ញី: ១៣ តុលា, ២ កដ្ឋិកា; ពាក់ធី, ជីប្ញី លំអង ឈើបុន្នាគ, គណិកា (?) មួយមុខៗ: ៧ បណ:, ១៣ កដ្ឋិកា; ជាតិផល (ផ្លែបន្ទូន់?) ៣.៤០៦; ក្បារ:(?) ជ័រណ៌ជាមួយគ្នា: ៥ កដ្ឋី, ១៤ បណ:; ក្រវាញពីរប្រភេទ: ៣ កដ្ឋី, ១ បណ:, ២ ជាខ, ៣ មាម; ស្ករ: ២ តុលា, ១៣ កដ្ឋី, ៨ បណ:; ខន្ធន្ធ្យ: (?) ២.៦៧០; សតបុស្ប: ១ តុលា, ៦ កដ្ឋី, ១២ បណ:; ធន្យ (ដើមឈើ ?) ១២តុលា, ១៦ កដ្ឋិកា ១៤ បណ:; តគរ (ដើមឈើ?) នឹងម្រេច ស្មៅគ្នា: ១៣ កដ្ឋី ៧បណ:; សម្ភែលិកា (ឈ្មោះក្រវាញមួយបែប): ១១ តុលា ៣ កដ្ឋី, ៧ បណ:; សម្ភបណ: (ឈ្មោះក្រវាញមួយបែប

ទៀត)៖ ១១ តុលា, ៣ កដ្ដិ, ៧ បណ។ ប្រចីរាល (ដើមឈើកូនក្រអូប) ១១ តុលា, ១៦ កដ្ដិតា៖ គ្រាប់រៃស្ពៃ ១ ទ្រោណ។ ១២ ប្រស្ដ។ បថ្យា-វចៈ?ពាំងអស់៖ ១១.៣៦០? ពារី? ១.០៦៨...; ក្រមួនទន់ធ្វើពីឫស ឈើ ១០ មុខ, មួយមុខៗចំនួន ៤៨.០០០;...; នឹងទុសថ្កែកោតផ្សេងៗ ទៀត ។ល។

រៀបចប់ពីបុញ្ញកិរិយាវត្ថុដែលទ្រង់បំពេញដ៏សម្បើមអស្ចារ្យយ៉ាងនេះហើយ ទ្រង់ទូន្មសព្រះពាជកុសលថ្វាយព្រះវរមាតាដោយគាថាជូរច្នះ

ភុវិន្ទិមានិ សុភគានតិមាតតភក្ខាវ្យាធតិប្រណិធិមេវមសៅភ្យតីន្ទ្រេ។
ឯកិគ្គចិត្តមមតៃកវិនាំតវាវ្ដេតារណាយកជតាំជនទីដ៏នតូម៏ ។ ។

"អំពើជាកុសលដែលទ្រង់ (ព្រះបាទជយវរ្ម័នទី៧) បានបំពេញដោយប្រពៃចំពោះព្រះវរពាជមាតា ដោយភក្ដីភាពយ៉ាងនេះហើយ ព្រះពាជាតាំងប្រណិធិថា "ដោយអំណាចបុញ្ញពលីនេះ សូមព្រះវរជនទីខ្ញុំដែលធ្វើរួចពាកមហាសាគរគឺតពាហើយ បានសម្រេចនូវភាពជាព្រះជិនស្រីកុំឃ្លាតឡើយ" ។ ១៤១ ។

ក្រោយសាងព្រះពាជវិហារមក ៥ ឆ្នាំក្ដុង ព.ស. ១៧៣៤ (គ.ស. ១១៩១) ទ្រង់សាងមហាប្រាសាទមួយទៀតឈ្មោះប្រាសាទ "ជយស្រី" ទូន្មសថ្វាយព្រះពុទ្ធសាសនា សព្វថ្ងៃហៅប្រាសាទព្រះខាន់ ដើម្បី

ជំគល់បដិមាករព្រះបាទធរណីន្ទ្រវរ្ម័ន ជាព្រះវរពោធិសត្វ
សត្វលោកស្បុះហើយថ្វាយព្រះនាមថា "ជយវរមេស្វរៈ" ។ នៅទិស
ខាងកើតក្នុងវាលំប្រាសាទព្រះខាន់នេះ ព្រះអង្គបានសាងប្រាសាទមួយមាន
សមញ្ញាថា «ពជ្រស្រី» សព្វថ្ងៃហៅប្រាសាទ"នាគព័ន្ធ" ។ នៅ
ចំកណ្តាលស្រះ ជាប្រាសាទតូចមួយមាននាគព័ន្ធពីក្រោមហើយមានស្រះ
៤ នៅគ្រប់ទិស ។ ស្រះនីមួយ ។ មានទុសម្រាប់បង្ហូរទឹកលាងជាបបចេញពីស្រះកណ្តាលដែលជាតួប្រាសាទនាគព័ន្ធ ។ ប្រាសាទ«ពជ្រ-
ស្រី» នេះ ជាកំពង់បុណ្យសម្រាប់លាងជាប ទាញយកលំអពីស្រះ
ទាំង៤ ទិស សាងដំណាងអនោតត្តស្រះនៅភ្នំព្រះសុមេរុពោធ (ភ្នំហិមាល-
យា) ដែលនិយាយថាមានកំពង់ ៤ ហូរចុះទៅកាន់ទិសទាំង ៤ តាមប្រ
ពៃណីប្រទេសឥណ្ឌា ហើយព្រះអង្គបានសាងបដិមារូបព្រះអង្គទុកជាអង្គព្រះ
ពុទ្ធគ្រូពោធិសាម "ព្រះកែវជ្រគុរុ វៃរូវ្រប្រភា" ដំគល់ទុកក្នុងប្រាសាទ
នេះផង សម្រាប់ជួយសង្គ្រោះសត្វលោកដែលមានជម្ងឺ ។ រូបសេះមួយ
ដែលមានចង្កាមមនុស្សគោង កំជាបដិមារូបព្រះអង្គដែរ មានន័យថា
"ព្រះអង្គដឹកជញ្ជូនសត្វលោកពីមហាសាគរ គឺវល្លិសង្សារវដ្តទៅត្រែតពោធិ
កាន់ទិសក្សេមក្សាន្តគឺព្រះនិព្វាន" ។ រឿងទាំងនេះ ដូចសិលាចារឹកនៅ
ប្រាសាទព្រះខាន់ដែលចារឹកទុកថា :-

(មានត)

សទ្ធម្មប្បជ្ជោត

(តចប់)

ព្រះមហា អ៊ុក-អ៊ីន រៀបរៀង

ភិក្ខុនីខន្ធកវណ្ណនាថា បើព្រះមានជោគមិនបញ្ជាគតុរុធម៌មុនភិក្ខុនីបួសទេ ព្រះសទ្ធម្មនឹងឋិតត្រឹម ៥០០ ឆ្នាំ បើបានបញ្ជាគុកមុន ព្រះសទ្ធម្មនឹងឋិតនៅ៥០០ឆ្នាំទៀត រួមជាមួយពាន់ឆ្នាំ ។ ព្រះសទ្ធម្មចែកជា ៣ ប្រភេទគឺ បរិយត្តិធម៌ បដិបត្តិធម៌ បដិវេធធម៌ ។ ព្រះសទ្ធម្មឋិតនៅ ៥០០០ឆ្នាំនោះ លោកកំណត់១០០០ឆ្នាំ ៥ ដង ដោយអំណាចនៃបុគ្គលសម្រេចបដិវេធធម៌ ៥ ថ្នាក់គឺ

- ១០០០ ឆ្នាំ ដោយអំណាច ព្រះខីណាស្រពចដ៏សម្មាសម្ពុទ្ធ
- " " សុក្ខវិបស្សកៈ
- " " អនាគាមិបុគ្គល
- " " សកទាគាមិបុគ្គល
- " " សោតាបន្នបុគ្គល ។

ព្រះសទ្ធម្ម គឺ បដិវេធធម៌ ឋិតនៅ៥០០០ឆ្នាំយ៉ាងនេះ ។ ព្រះបរិយត្តិធម៌ បដិបត្តិធម៌ជួបគ្នាដែរ ។ ឯភេទ (ភិក្ខុ) បើខុតជាបរិយត្តិអន្តរធានគឺឋិតនៅបានយូរ ។

ព្រះសទ្ធម្មនីធ សាបសូន្យដោយហេតុ៥យ៉ាងគឺ

១- ពួកភិក្ខុរៀនសុត្តន្តដែលខ្លួនរៀនខុស ដោយបទនីធព្យញ្ជនៈដែលរៀបរៀនខុស បទនីធព្យញ្ជនៈដែលរៀបរៀនខុស រមែងយល់សេចក្តីបានដោយក្រ ។

២- ពួកភិក្ខុជាអ្នកប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនបេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។

៣- ពួកភិក្ខុណា ជាអ្នកបេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ចង់ចាំនូវព្រះធម៌ (សុត្តន្ត) ចង់ចាំនូវព្រះវិន័យ ចង់ចាំមាតិកា, ពួកភិក្ខុពាំងនោះ មិនឲ្យភិក្ខុដទៃរៀនសុត្តន្តដោយគោរព លុះអស់ណើះឥតពីភិក្ខុពាំងនោះ សុត្តន្តក៏ជាប់ឫសមិនប្រតិស្ឋានទៅ ។

៤- ពួកភិក្ខុជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាកំពូលក្នុងវិវេក មិនប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសំរេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសំរេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់, ប្រជុំជនដែលកើតខាងក្រោយគឺ សទ្ធិវិហារិក អន្តេវាសិក តំយកតម្រាប់តាមភិក្ខុជាថេរៈពាំងនោះ ប្រជុំជនខាងក្រោយពាំងនោះ ក៏ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ។ល។

๙- សង្ឃវែកគ្នា, កាលបើសង្ឃវែកគ្នា, ការដេរគ្នានឹងគ្នាក៏មាន, ការប្រទេចផ្តាសាគ្នានឹងគ្នាក៏មាន, ការចោះចោកសំដីទៅរកគ្នានឹងគ្នាក៏មាន, ការលះបង់គ្នានឹងគ្នាក៏មាន, ពួកជនដែលមិនចាន់ជ្រះថ្លាក្នុងសង្ឃទាំងនោះក៏មិនមានសេចក្តីជ្រះថ្លា ដែលជ្រះថ្លាស្រាប់ក៏ងាកចិត្តលែងជ្រះថ្លាវិញ ។

ព្រះសទ្ធម្មនឹងឋិតនៅដោយហេតុ ๙ យ៉ាងដែលផ្សេងពីនេះ ។

ព្រះសទ្ធម្ម មិនមានបុគ្គលណាជាសត្រូវឲ្យសាបសូន្យបានទេ, បើពុទ្ធបរិស័ទមានសម្មាបដិបត្តិ ដរាបណា, ទំនឹងឋិតនៅដរាបនោះ ។ ដូចពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ទំនុកថ្នូរថា "ឥមេ ច កិក្ក សុភទ្ទ សម្មាបដិបត្តិ វិហរេយ្យុំ អសុញ្ញោ លោកោ អរហន្តេហិ ម្នាលសុភទ្ទ ឲ្យតែពួកភិក្ខុនេះមានសម្មាបដិបត្តិចុះ, លោកមិនសូន្យចាកអរហន្តទាំងឡាយទេ»។ នេះបង្ហើលឲ្យឃើញថា អាយុព្រះសទ្ធម្ម ពាក់ទងដោយសម្មាបដិបត្តិ ។ ប៉ុន្តែសម្មាបដិបត្តិ គោងមានបរិយត្តិជាមូល ។

๓- ពុទ្ធសកប្ទិបន:

ការកំណត់ពាក់អាយុកាលនៃសាសនាមួយៗ ចាប់ដើមអំពីថ្ងៃខែ ឆ្នាំដែលសាស្តាមួយៗកើតឡើង ឬបរិនិព្វាន, ស្ទាប់ ហៅថា "សក:ប្ទ-

សកពជ» ។ ការកំណត់ពាប់អាយុកាលព្រះពុទ្ធសាសនា ហៅថា "ពុទ្ធសកពជ" (ព.ស.) ។

ចំពោះពុទ្ធសាសនា, ការកំណត់ពាប់សកពជ គេពាប់ចាប់ដើមអំពីថ្ងៃពុធ១កេច ខែពិសាខ ឆ្នាំម្សាញ់ ជាថ្ងៃក្រោយពុទ្ធបរិនិព្វាន ។ ការពាប់នេះ គេកំណត់ពីថ្ងៃ១ កេចខែមួយ ទៅដល់ថ្ងៃ ១៥ កើតខែមួយជា១ខែ, ១២ខែ ជា១ឆ្នាំ គឺជា១សកពជ ។ សម័យពីដើមមិនមានពាក្យថា "សក: ឬសកពជ"ទេ, មានតែពាក្យថា «អំណើះ»; ប្រហែលជាសម័យមហានគរ ទើបមានពាក្យថា សកពជ ភ្ជាប់ជា "ពុទ្ធសកពជ" ។

ការតាំងពុទ្ធសកពជ កំណត់ពាប់នេះ អ្នកសរសេរសូមអាងរឿងដែលមានក្នុងពាហិរកថាមិលិន្ទប្បញ្ហាដែលព្រះពុទ្ធទ្រង់ព្យាករសាសនប្បតិដ្ឋានក្នុងបរិនិព្វានសម័យថា នាគាលតថាគតបរិនិព្វានហើយ កស្សប: រលឹកនូវពាក្យចំរូងចំពស របស់សុភទ្ទបួសចាស់ នឹងសង្គាយនាធម្មវិន័យដំរះពុទ្ធវចន: ។ ខាងមុខពីនោះ កន្លង៧១០ឆ្នាំ យស-កាកណ្ឌបុត្ត នឹងញាំញីពួកភិក្ខុវជ្ជិបុត្តក: ចុងធ្វើទុតិយសង្គីតិ ។ ខាងមុខពីនោះ កន្លង ៧ ២១៨ ឆ្នាំ, មោគ្គលីបុត្ត-តិស្សត្ថេរ នឹងចំណាយនូវវាទ:នៃពួកអន្យតិ្ថយនឹងធ្វើតតិយសង្គីតិ ។ កាលខាងមុខទៀត (២៣០) កិកុមហា-

មហិន្ទៈ នឹងប្រតិស្ថានសាសនាតថាគតក្នុងតាម្ពបណ្ណិទ្វីប (សិរីលង្កា) ។ ខាងមុខពីនោះ កន្លង៧ ៥០០ ឆ្នាំ អំពីបរិនិព្វាន នៃព្រះសម្មាសម្ពុទ្ធ, មានព្រះរាជាព្រះនាមមិលិន្ទៈ ញុំាញីពួកសមណព្រាហ្មណ៍ដោយបញ្ហាដ៏ល្អិត ក្នុងជម្ពុទីបតំាងសាកល ។ មានភិក្ខុមួយរូបនាមនាគសេន ចំលើយឆ្លងៈ របស់ព្រះរាជាបានញុំាងព្រះរាជាឲ្យរីករាយព្រះហឫទ័យដោយអានភូបមា ធ្វើឲ្យសាសនាមិនឲ្យមោះហួន នឹងប្រតិស្ថានជាបន្តប់ ៥០០០ ឆ្នាំ ។

ដូច្នេះ គួរសន្និដ្ឋានថា ការកំណត់រាប់អាយុកាលនៃពុទ្ធសាសនាមុនដំបូងគឺ ព្រះសម្មាសម្ពុទ្ធកំណត់ដោយព្រះអង្គឯង , ដល់ខាងក្រោយពួកសង្គីតិកាចារ្យកំណត់រាប់តាមដូច្នោះ តំាងពួកពុទ្ធបរិស័ទខាងក្រោយក៏កំណត់រាប់ដូច្នោះដែរ ។

ការតាំងកំណត់រាប់ពុទ្ធសករាជ ឬ សករាជឯទៀតៗ ជាប្រយោជន៍ដល់ការកំណត់កាល ចំណាំកាល នៃកម្មវិធីផ្សេងៗ នឹងប្រវត្តិសាស្ត្រ អាយុឆ្នាំ នៃមនុស្ស ជម្មជាតិ ស្ថាបនា ។

៤- បញ្ជីវត្ថុប្បតិដ្ឋាន

ព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ, ទ្រង់ប្រតិស្ថានវត្ថុ ៤ យ៉ាង គឺ

ក) បដិមា រូបស្នង់ព្រះអង្គ ;

ខ) ពោធិព្រឹក្ស ឈើជាទីត្រាស់ដឹង ;

គ) ស្ទូប ចេតិយបញ្ចុះព្រះសារីរិកធាតុ ;

ឃ) ជិនធាតុ ព្រះបរមធាតុព្រះជិនស្រី ;

ង) ធម្មក្ខន្ធ ៨៤.០០០ ព្រះត្រៃបិដក ។

ក) បដិមា

រូបស្នង់ព្រះពុទ្ធ ដែលគេគួរនឹងសំពត់ហៅថាព្រះបដិមា ។ គេសាងនឹងឈើ ឬលោហធាតុខ្លះ តាមពុទ្ធប្បវត្តិ ដើម្បីនមស្ការជាអារម្មណ៍របស់ចិត្ត ។ បដិមានេះ ហៅថា «ទេសចេតិយ» ។

ខ) ពោធិព្រឹក្ស

ឈើដែលគេចូលទៅដ្រកចាត់សេចក្តីត្រេកត្រអែកយកបាន ដកដង្កើមស្រួលហៅថា "អស្សត្ថព្រឹក្ស" ជាសហជាតធម៌របស់ព្រះសម្ពុទ្ធ ជាឈើដែលព្រះពុទ្ធគង់ចំរើនអានាបានសតិបានត្រាស់ពោធិញ្ញាណ ទើបហៅថា «ពោធិព្រឹក្ស» ។ អស្សត្ថព្រឹក្សនេះដែលយើងហៅថា «ដើមពោធិ» នៅប្រទេសយើង ។

គ) ស្ទូប

ចេតិយដែលគេសាងពងដូចគំនរស្រូវខ្លះ ដូចដំបូកខ្លះ ពងបួនជ្រុងជាមទៅលើខ្លះ សម្រាប់ដាក់បូជនីយវត្ថុ "ស្ទូប" ឬ "ថូប" ។ ស្ទូបនេះ

ជាន់ដល់តុំខ្ពស់ចេតិយ ๓ យ៉ាង គឺ

๑- បរិភោគចេតិយ ចេតិយដែលគេដំកល់ទុកសម្រាប់ប្រើប្រាស់មានជាត្រជាដើមរបស់ព្រះមានព្រះភាគ ។

๒- ជាតុចេតិយ សួចដែលគេបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ដែលប្រតិស្ឋានក្នុងជម្ពូទ្វីប ๘ កន្លែង គឺសួច ๑ នៅក្រុងពជគ្រឹះ, សួច ๑ នៅក្រុងអល្លកប្បៈ, សួច ๑ នៅរាមគ្រាម, សួច ๑ នៅក្រុងវេដ្ឋទីបកៈ, សួច ๑ នៅបាវេយ្យកៈក្នុងមល្លរដ្ឋដនបទ, សួចមួយនៅក្រុងកុសិនារ ។ សួចពីរទៀត គឺ សួច ๑ កំពស់ ๑๒ យោជន៍នៅព្រហ្មលោក, សួច๑គឺ ចូឡាមណិចេតិយនៅត្រៃត្រឹង្ស ។ ព.ស.๒๑๘, ព្រះបាទធម្មាសោក ទ្រង់ព្រះបញ្ជាឲ្យសាងចេតិយ ๘๔.๐๐๐ ក្នុងសាកលជម្ពូទ្វីប ។

๓- ធម្មចេតិយ ចេតិយដែលដំកល់ក្បួនលំនៃគតធម៌មានបដិច្ចសមុប្បាទជាដើម ដូចជាប្រាង្គប្រហោរក្រយសម្រាប់ដំកល់ព្រះត្រៃបិដក; ចេតិយមួយទៀត ហៅថា "បទចេតិយ" ជានដល់ស្នាមព្រះបាទ ๔ កន្លែងគឺ ๑- ស្នាមព្រះបាទលើផ្កាឈូកក្បែរស្ទឹងនម្មទា, ๒- ស្នាមព្រះបាទលើភ្នំសច្ចពន្ធ, ๓- ស្នាមព្រះបាទលើកំពូលភ្នំសុមនកូដ, ๔- ស្នាមព្រះបាទក្នុងរោនតបុរី ។ កន្លែងព្រះបាទ ๕ ទៀត គឺភ្នំសុវណ្ណមាលិក๑, សុវណ្ណបព្ភារ๑, ភ្នំសុមនកូដ๑, រោនតបុរី๑, ស្ទឹងនម្មទា๑ ។ ចេតិយ

ចែកជា ៣ ទៀតគឺ សារីរិកធាតុចេតិយ, បរិភោគចេតិយ, ឧទ្ទិសចេតិយគឺ បដិមាករ ។

ឃ) ជិនធាតុ

ព្រះសារីរិកធាតុប្រតិស្ថាននៅទីផ្សេង ។ គ្នា ចែកជា ៣ ផ្នែក គឺ ១) ព្រះធាតុមិនបែក ៧ អង្គ គឺព្រះទណ្ឌាសធាតុ (ឆ្នឹងថ្ងាស) ១, ព្រះទាឋាធាតុ (ចង្កឹមកែវ) ៤, ព្រះអក្ខកធាតុ (ឆ្នឹងជង្គាំបិត) ២ ។ ព្រះទាឋាធាតុស្តាំខាងលើនឹងព្រះអក្ខកធាតុស្តាំប្រតិស្ថានឯត្រៃត្រឹង្ស, ព្រះទាឋាធាតុស្តាំខាងក្រោមនៅសីហឡទ្វីប, ព្រះទាឋាធាតុឆ្វេងខាងលើនៅគន្ធាររដ្ឋ, ព្រះទាឋាធាតុឆ្វេងខាងក្រោមនៅនាគភពន, ព្រះអក្ខកធាតុឆ្វេងព្រមទាំងទុស្សធាតុ (សំពត់ស្រទាបចេញបួស) ឃដិការមហាព្រហ្មយកទៅប្រតិស្ថានឯព្រហ្មលោក ;

២) ព្រះធាតុបែកចេញមាន ៣ ភាគ គឺ ព្រះធាតុភាគធំទំហំប៉ុន ។ កំណាត់គ្រាប់សណ្តែកបាយមានពណ៌ដូចមាស រាល់បាន ៥ នាឡិ (ត្រែឡាក), ព្រះធាតុភាគកណ្តាលមានទំហំប៉ុន ។ កំណាត់គ្រាប់អង្កាមានពណ៌ដូចកែវផលិក រាល់បាន ៦ នាឡិ, ព្រះធាតុភាគតូចមានទំហំប៉ុន ។ គ្រាប់ស្ពៃមានពណ៌ដូចផ្កាពុល រាល់បាន ៤ នាឡិ ។ ព្រះធាតុទាំងនេះគេបញ្ចុះក្នុងសួបទាំង ៨ ក្នុងដម្ពទ្វីបតាលមុន,

៣) ព្រះខន្ធធាតុ ៤០, ព្រះកេសធាតុ, ព្រះលោមធាតុ នឹងព្រះនខ-ធាតុចាំងឡាយ ទៅតាចាំងឡាយនាំយកមួយអង្គ ។ ទៅតាន់បត្រាវឲ្យដាវ ។ ។ ឯព្រះកេសធាតុដែលព្រះអង្គកាត់ក្នុងកាលទ្រង់ព្រះផ្នួស ព្រះឥន្ទ្រនាំយកទៅប្រតិស្ឋានក្នុងចូឡាមណីចេតិយឯហានត្រៃត្រឹង្ស ។

ព.ស.២១៨, ព្រះបាទធម្មាសោកបានយកព្រះធាតុបញ្ចុះក្នុងចេតិយ ៨៤.០០០។ ព.ស.២៣០, ព្រះបាទទេវានំបិយតិស្សៈ បានបញ្ចុះព្រះអង្គក-ធាតុខាងលើ ដែលសុមនសាមណេរសុំអំពីព្រះឥន្ទ្រក្នុងសុបកងចូឡាភមឯលង្កាទ្វីប, ព្រះធាតុមួយចង្រ្កាត សុមនសាមណេរ សុំអំពីព្រះបាទអសោក ព្រះមហិន្ទត្ថេរដើរលាលើចេតិយគីរី, ។ សម័យព្រះបាទទុដ្ឋគាមណី-អភ័យ ព្រះនត្តាព្រះបាទទេវានំបិយតិស្សៈ បញ្ចុះព្រះធាតុចំនួន ១ ទោណក្នុងមហា ចេតិយ ។

ឆ) ធម្មក្ខន្ធ ៨៤.០០០

ព្រះបរិយត្តិធម៌ សោកកំណត់ជា ៣ គឺ សូត្រដែលមានអនុសន្ធិ ១ ជា ១ ធម្មក្ខន្ធ, សូត្រដែលមានអនុសន្ធិច្រើនត្រូវរាប់ធម្មក្ខន្ធដោយអំ-ណាចអនុសន្ធិចាំងនោះ; ក្នុងគាថាព័ន្ធចាំងឡាយ បញ្ញាប្បភេទជា ១ ធម្ម-ក្ខន្ធ, បញ្ញាវិសជ្ជនាជា ១ ធម្មក្ខន្ធ ។ ក្នុងអភិធម្ម, តិកទុកកាជន:មួយ ។, ចតុក្កកាជន:មួយ ។ ជា ១ ធម្មក្ខន្ធ ។ ក្នុងវិនយ, វិភង្គមាន, ខន្ធកៈមាន,

បទភាជនីយមាន, អន្តរាបត្តិមាន, អាបត្តិមាន, អនាបត្តិមាន, អតេកិច្ចៈមាន, សតេកិច្ចៈមាន, ។ ចំណែកមួយៗ គប្បីដឹងថាជា ๑ ធម្មក្ខន្ធ ๑ ។ រួបរួមអភិធម្មបិដកមាន ๘๔.๐๐๐ ធម្មក្ខន្ធ, វិនយបិដកមាន ๒๑.๐๐๐ ធម្មក្ខន្ធ, សុត្តន្តបិដកមាន ๒๑.๐๐๐ ធម្មក្ខន្ធ ។ ព្រះពុទ្ធវចនៈ ๘๔.๐๐๐ ធម្មក្ខន្ធយ៉ាងនេះ ។

๕- បញ្ហអន្តរជាន

ព្រះពុទ្ធសាសនា កាលនឹងសាបសូន្យ នឹងសាបសូន្យព្រោះអន្តរាយជាគុ ๕ យ៉ាង គឺ

ក)- បរិយត្តិអន្តរជាន សាបសូន្យព្រះបរិយត្តិ;

ខ)- បដិបត្តិអន្តរជាន សាបសូន្យបដិបត្តិ;

គ)- បដិវេធអន្តរជាន សាបសូន្យសេចក្តីត្រាស់ដឹង;

ឃ)- លិង្គអន្តរជាន សាបសូន្យភេទអ្នកបួស;

ង)- ធាតុអន្តរជាន សាបសូន្យព្រះសារីរិកធាតុ។

ក) បរិយត្តិអន្តរជាន

ព្រះបរិយត្តិនឹងសាបសូន្យយ៉ាងនេះ : កាលកន្លងទៅ ๑ តើតកលិយុគ, មនុស្សក្នុងសាកលលោកច្រាសចាកមនុស្សធម៌ ព្រោះចំហាយអយុត្តិធម៌ ធម្មជាតដែលជាទុបការមិនប្រព្រឹត្តទៅដោយប្រពៃ ដូចជា

ក្នុងនិងបង្អ្ហាមិនស្រួល ស្រួមិនសម្រេចផលជាដើម ។ ម្ល៉ោះហើយ ទាយកអ្នកផ្គត់ផ្គង់បច្ច័យសម្រាប់ការសិក្សាមិនអាចប្រគេនបច្ច័យដល់តក្កសង្ឃ ពួកតក្កលំបាកដោយបច្ច័យ មិនអាចសង្គ្រោះអន្តរាយសិក្ខាបរិយត្តិបាន ។ កាលកន្ទុងទៅ ។ តក្កមិនអាចទ្រទ្រង់អត្ថបាន ទ្រទ្រង់ធាន ត្រឹមបាលី ។ តទៅ, កាលកន្ទុងទៅ ។ តក្កមិនអាចទ្រទ្រង់បាលីទាំងអស់ ។ ដំបូង អតិធម្មបិដកសាបសូន្យ ។ ពីចុងមកមុនគឺ មហាបច្ចាន; តមក, យមក:, កថាវត្ថុ, បុគ្គលប្បញ្ញត្តិ, ធាតុកថា, វិភង្គ, ធម្មសង្គណី ។ តមក, សុត្តន្តបិដក សាបសូន្យ, អង្គុត្តរនិកាយសាបសូន្យចាប់ដើមអំពីឯកាទសក: ដល់ឯកក:; តមក, សំយុត្តនិកាយសាបសូន្យចាប់ដើមអំពីចក្កបេយ្យាល: ដល់ទុយតរណ:; តមក, មជ្ឈិមនិកាយសាបសូន្យចាប់ដើមអំពីឥន្ទ្រិយភាវន: ដល់មូលបរិយាយ:; តមក, ទីឃនិកាយសាបសូន្យចាប់ដើមអំពី ខសុត្តរ: ដល់ព្រហ្មជាល: ។ បុព្វាគាថាមួយក្តី ពីរក្តី បឋមៅអស់កាលវែងក៏ដោយ ក៏មិនអាចទ្រទ្រង់សាសនាបាន ដូចជាសព្ភិយបុព្វា អាឡវកបុព្វា កុដិកសព្វបុព្វសាសនា ។ តមក, ពួកលដ្ឋកតក្កទ្រទ្រង់វិនិច្ឆយ; ពួកតក្កប្រាថ្នាលាភ, កាលសុត្តន្តបិដកបឋមៅ ទ្រទ្រង់តែជាតកប៉ុណ្ណោះ ។ កាលកន្ទុងទៅ ។ តក្កមិនអាចទ្រទ្រង់ជាតក, វេស្សន្តរជាតកសាបសូន្យជាដំបូង; តមក, បណ្ណកជាតក

មហានាវជាតុក ដោយលំដាប់ប្រាសមក; អបណ្ណកជាតកសាបសូន្យទី
បំផុត ។ តិក្ខនៅទ្រទ្រង់នៃយ ។ កាលកន្ទងទៅ ។ នៃយសាប
សូន្យព្រះពុទ្ធមកមុនគឺ បវារ:, តមក, ទន្ធក:, តិក្ខនីតិង្គ, មហាវិតង្គ,
តិក្ខទ្រទ្រង់តែទោសថត្តន្ធក: ។ គាថា ៤ បទប្រព្រឹត្តក្នុងមនុស្ស
ជាតបណា, ជាតនោះ បវិយត្តិឈ្មោះថា មិនមានអន្តរធាន ។ កាលនោះ
ស្តេចដ្រះថ្វាយគេជាត់តហាបណ:មួយពាន់ក្នុងប្រអប់ជាត់លើតដំរី ឲ្យប្រកាស
ស្តែរស្តែរថា "អ្នកណាចេះគាថា ៤ បទដែលព្រះពុទ្ធទ្រង់សំដែង អ្នកនោះ
ចូរយកតហាបណ:មួយពាន់នេះចុះ" ។ កាលពាជបុរសប្រកាសស្តែរ ៣ ដង
មិនមានអ្នកណាទទួលយក, តំនាំយកថង់តេញដោយតហាបណ: ១ ពាន់
ចូលទៅកាន់ពាជត្រកូលវិញ ។ កាលនោះឯងហៅថាបវិយត្តិអន្តរធាន ។

១) បដិបត្តិអន្តរធាន

បដិបត្តិនឹងសាបសូន្យយ៉ាងនេះ: កាលកន្ទងទៅ ។ ពួកតិក្ខុមិនអាច
ញុំាងឈាន វិបស្សនា មគ្គផលឲ្យកើត, រក្សាតែចតុប្បារិសុទ្ធិសីល ។
កាលកន្ទងទៅ ។ ពួកតិក្ខុដល់នូវសេចក្តីបន្ទូរបន្តយថា "យើងរក្សាចតុ-
ប្បារិសុទ្ធិសីលផង ប្រកបរឿយ។ នូវប្រធានផង មិនអាចធ្វើឲ្យជាក់ច្បាស់
នូវមគ្គផលបាន, ឥឡូវនេះ អរិយធម្មប្បដិវេធធម៌មិនមាន" ហើយក៏
ល្មោកខ្ជិល មិនដាស់តឿនរំលឹកទៅវិញទៅមក មិនមានសង្វ័យ; តមក,

កំញាំញ៉ីខ្ចីតខ្ចីខ្ចីតសិក្ខាបទ ។ តាលកន្ទ្ធ៧ ។ តិក្ខុត្រូវអាបត្តិ
ចាបិត្តិយៈ ថុល្លច្ច័យ តពីនោះគ្រុកាបត្តិចាកដំតបិតនៅ ។ តាលបើពួក
តិក្ខុរក្សាចាកដំត ៤ មានមួយរយអង្គក្តី មួយពាន់អង្គក្តី, បដិបត្តិមិនពាន់
អន្តរាយទេ ។ លុះតែតិក្ខុក្រោយបង្អស់បែកធ្លាយសីលក្តី, អស់អាយុក្តី
បដិបត្តិឈ្មោះថា អន្តរាយ ។

ត) បដិវេធអន្តរាយ

បដិវេធៈ គឺអធិគមៈ បានដល់មគ្គ ៤, ផល ៤, បដិសម្ភិទា ៤, វិជ្ជា,
អភិញ្ញា ៦ ។ អធិគមៈសាបសូន្យអំពីបដិសម្ភិទាមកមុន ។ លុះសោតា-
បន្នបុគ្គលក្រោយបង្អស់អស់ជីវិត, អធិគមៈឈ្មោះថា អន្តរាយ ។

ឃ) លិង្គអន្តរាយ

តាលកន្ទ្ធ៧ ។, តារកាន់ចាត្រកាន់ចីវរ, បត់ លា ឈាន
ឈានទៅមុខ ឈានថយ មើលទៅមុខ មើលឆ្វេង ស្តាំ មិនសមរម្យ
តាមសមណសារុប្ប មិនជាទីជ្រះថ្លា ។ ពួកតិក្ខុដាក់ចាត្រត្រង់អគ្គពាហា
(ចុងដើមដៃ) ត្រាច់ទៅ ដូចនិគ្គន្ថសាវ្រមណីកាន់ចាត្រលាឈ្មោក ។
ប៉ុណ្ណោះ លិង្គនៅមិនពាន់អន្តរាយ ។ តាលកន្ទ្ធ៧ ។ ពួកតិក្ខុដាក់ចាត្រ
អំពីអគ្គពាហាយួរដោយដៃ ដោយសង្រែកត្រាច់ទៅ ។ តាលកន្ទ្ធ៧ ។
តិក្ខុមិនជ្រលក់ចីវរ តាត់សំពត់ធ្វើចីវរចោះតែក្រវិលពីខ្នុកប្បៈប៉ុណ្ណោះប្រើ
ប្រាស់ទៅ ។

តមក, ចោរតែក្រលៃ មិនធ្វើពិន្ទុកប្បៈ ។ តមក, មិនធ្វើចាំដ៏ពីរ
កាត់តែសំពត់ស្បៃកគ្រាច់ៗដូចបរិព្វាជក ។ កាលកន្លងៗពួកតិត្ថិគិត
ថា គ្មានប្រយោជន៍អ្វីដោយសំពត់ កំចង់ខ្លុកសាជកនឹងដៃខ្លះនឹងកន្ទុះ
ផ្សែមសក់ឲ្យខ្លីកខ្លះ ចិញ្ចឹមកូនប្រពន្ធធ្វើស្រែចិញ្ចឹមជីវិត ។ កាលនោះ
ជនណាឲ្យទក្ខិណាទានដល់ជនពួកនេះ ទក្ខិសចំពោះសង្ឃបានផលច្រើនៗ
ព្រះមានជោគត្រាស់សំដៅរឿងនេះថា “ម្នាលអានន្ទ ក្នុងកាលអង្វែង
ទៅអនាគតនឹងមានពួកគោត្រកូចឆកាសាវៈនឹងក ទ្រុស្តសីល មានធម៌
អាក្រក់, ពួកជនទើបឲ្យទានក្នុងគោត្រកូចំនោះ; ម្នាលអានន្ទ ក្នុងកាល
នោះ តថាគតពោលថា សង្ឃគាទក្ខិណាទាននោះ មានផលពាប់មិនបាន
ស្មានមិនត្រូវ” ។ តមក, កាលកន្លងទៅៗពួកជននោះនាំគ្នាធ្វើអំពើផ្សេងៗ
គិតថាការនេះនាំយើតយូរ យើងមានប្រយោជន៍អ្វីដោយវត្តនោះ ហើយកំ
ត្រាត់សំពត់កាសាវៈនោះចាលក្នុងព្រៃ ។ ក្នុងកាលនោះ លិង្គ ឈ្មោះ
ថា អន្តរធាន ។

ង) ជាតុអន្តរធាន

បរិនិព្វានមាន ៣ គឺ

- កិលេសបរិនិព្វាន មានហើយលើពោធិបល្ល័ង្ក ;
- ខន្ធបរិនិព្វាន មានហើយក្នុងក្រុងកុសិនារ ;

- ជាតុបរិនិព្វាន នឹងមានក្នុងកាលអនាគត ។

ជាតុបរិនិព្វាន, ព្រះជាតុពាំងឡាយកាលមិនបានសក្ការៈ ពាប់អាន
ក្នុងទីនោះ។ ក៏ទៅកាន់កន្លែងដែលបានសក្ការៈបូជាពាប់អាន ដោយកំលាំង
អធិដ្ឋានព្រះពុទ្ធពាំងឡាយ ។ កាលកន្លងទៅ ។ សក្ការៈបូជាពាប់អានមិន
មានសព្វហាន ។ ឮថា ក្នុងកាលសាសនារឿរោយ ព្រះជាតុពាំង
ឡាយទៅប្រជុំក្នុងតាម្ពបណ្ណិទ្វីប នឹងទៅកាន់មហាចេតិយ ចេញពីនោះ
ទៅកាន់រាជាយតនចេតិយក្នុងនាគទ្វីប ចេញពីនោះនឹងទៅកាន់មហាពោធិ
បល្ល័ង្ក ។ ព្រះជាតុពាំងឡាយនឹងមកអំពីនាគភពផង ទេវលោកផង
ព្រហ្មលោកផង ទៅកាន់ពោធិបល្ល័ង្កដែរ ។ ព្រះជាតុសូម្បីប៉ុនគ្រាប់ស្ពៃ
ក៏មិនវិនាសក្នុងចន្លោះ ។ ព្រះជាតុពាំងពាយ ប្រជុំនៅមហាពោធិបល្ល័ង្ក
កាន់យកនូវពុទ្ធរូបផ្ទឹមនឹងពុទ្ធសរីរៈដែលគង់ឰដ៏ពោធិមណ្ឌៈ; មហាបុរិស-
លក្ខណៈ ៣២, អនុព្យញ្ជនៈ ៨០ ; ពន្លឺផ្សាយចេញ ១ ព្យាមមានគ្រប់
ពាំងអស់ ។ លំដាប់នោះ. ព្រះជាតុពាំងឡាយនឹងធ្វើចាដិហារ្យបញ្ចេញ
ឆព្វណ្ណរំសីជួបក្នុងថ្ងៃយមកប្បាដិហារ្យ ។ រស្មីពាំងនោះនឹងផ្សាយទៅអស់
១ ម៉ឺនលោកធាតុ ។ ពួកមនុស្សមិនមានក្នុងទីនោះទេ ។ មានតែពួក
ទេវតា សន្និបាតក្នុង ១ ម៉ឺនចក្រវាឡ ធ្វើនូវការពោតាពធំជាងក្នុងថ្ងៃបរិ-
និព្វានៃព្រះទសពលថា "ព្រះទសពលបរិព្វានក្នុងថ្ងៃនេះ សាសនា

ន៏ឆន ថយក្នុងថ្ងៃនេះ, នេះជាបច្ចិមទស្សន៍ នៃពួកយើង" ។ លើក
លែងតែអនាគាមីទីណាសវៈ, ពួកទេវតាជ័សេសនឹងមិនអាចទ្រទ្រង់ដោយ
សកកាពបាន ។ លំដាប់នោះ តេជោជាតុតាំងឡើងអំពីជាតុសរីរៈ ញុំងឆ
សរីរៈនោះឲ្យដល់នូវអបណ្ណត្តិកភាព ។ អណ្តាតភ្លើងឡើងទៅដល់ព្រហ្ម-
លោក ។ បើព្រះជាតុនៅសល់ប៉ុនគ្រាប់ស្ពៃ អណ្តាតភ្លើងនៅ ។
កាលបើព្រះជាតុតាំងឡាយដល់នូវបរិយោសាន, អណ្តាតភ្លើងនឹងជាប់
សូន្យ ។ ព្រះជាតុតាំងឡាយសំដែងអានុភាពធំយ៉ាងនេះ ទើបបរិនិព្វាន ។

កាលនោះ ពួកទេវតា ដែលប្រជុំគ្នាច្បើសក្ការៈបូជាដោយគ្រឿងក្រអូប
ប្រែងផ្កាទិព្វនឹងតូរ្យតន្ត្រីទិព្វជាដើម ដូចក្នុងថ្ងៃព្រះពុទ្ធតាំងឡាយគង់នៅ
ធ្វើប្រទក្សិណថ្វាយបង្គំ ៣ ដងហើយពោលថា " បពិត្រព្រះមានជោគ
យើងតាំងឡាយនឹងបានឃើញព្រះពុទ្ធតាំងឡាយគ្រាស់ឯអនាគត " ។

បរិយត្តិអន្តរធាន ជាប្រធានៃអន្តរធានតាំង ៥ នេះ ព្រោះបរិយត្តិ
ជាប្រមាណនៃសាសនដ្ឋិតិ (ការទ្រទ្រង់ពុទ្ធសាសនា ។)

ចប់ ។

ពុទ្ធសាសនាដៀបសាសនាដទៃ

របស់

ឃុនអត្តកោវិទ ជា-ឃ្លូរ

ឃុនសុវត្តវេទ៍ ឃ្លូរ - អ៊ុង តំតំត្បកែសម្រួល

(តចប់)

ព្រះសង្ឃដែលបួសតាមលក្ខណៈ ៥ ប្រការនេះ ជាអ្នកអស់តង្វល់ កង្វល់តាមនៅក្រៅតែចតុបច្ច័យ ដែលខានមិនបានគឺ បង្អាន់បង្អែបាត ១ ចីវរ គ្រឿងស្លៀកដណ្តប់ ១, សេនាសនៈ ទីសំណាក់អាស្រ័យ ១, ភេសជ្ជៈ ថ្នាំការពារពេត ១ ។ ព្រះសង្ឃដែលមានលក្ខណៈដូចពោលមកនេះ ជាសង្ឃដែលគួរទំនុកបម្រុង ។

សង្ឃដែលមិនគួរទំនុកបម្រុង

លោកសង្ឃដែលមិនគួរទំនុកបម្រុងនោះគឺ សង្ឃដែលបួសដើម្បីអាជីព, បួសដើម្បីសម្រាកកាយ ឲ្យស្រួលមួយជាតិមួយគ្រា ឬបួសចៀសវាងកិច្ចការដែលខ្ជិលច្រអូស ។ មនុស្សខ្លះតែកាលឃើញថាការបួសជាផ្លូវងាយកស្តី ក៏តែតែនាំគ្នាមកបួសច្រើនឡើង ព្រះពុទ្ធសាសនាក៏តែតែសាបសូន្យថយចុះ ព្រោះសង្ឃពួកនេះមិនយកចិត្តទុកជាក់

ក្នុងជម្ងឺនេះ គឺតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ចាយតអ្នកចំនុកបម្រែង ព្រះសង្ឃពួកនេះ ដូចជួយធ្វើព្រះពុទ្ធសាសនាឲ្យអន្តរាយសាបសូន្យ ។

ផ្លូវជាគ្រឿងការពារព្រះពុទ្ធសាសនា មិនឲ្យសាបសូន្យ

ផ្លូវជាគ្រឿងការពារព្រះពុទ្ធសាសនាមិនឲ្យសាបសូន្យនោះ គឺកាលបើយើងឃើញថាសាសនានឹងសាបសូន្យ ដូចអាការដែលបានពោលមកហើយ បើយើងមានបំណងចង់ឲ្យព្រះពុទ្ធសាសនាចំរើន យើងត្រូវបួសដោយសទ្ធាជ្រះថ្លា ហើយប្រតិបត្តិឲ្យត្រង់តាមអដ្ឋង្គិកមគ្គ ពាំង ៨ បើអាចធ្វើឲ្យសម្រេចមគ្គផលបាន ក៏ធ្វើឲ្យពេញទំហឹង ដរាបដល់បានសម្រេច បើមិនអាចទេ ក៏ប្រតិបត្តិឲ្យត្រឹមត្រូវតាមធម៌វិន័យ តែកល់ខ្លួនឲ្យជាកល្យាណបុថុជ្ជន បើធ្វើដូច្នេះមិនបាន កុំបួសសោះល្អជាង ។ អ្នកចំនុកបម្រែងព្រះសង្ឃ ក៏ត្រូវជ្រើសរើសរកព្រះសង្ឃដែលគួរចំនុកបម្រែង ដើម្បីកាត់ផ្លូវជនពុំប្លែតែដែលចូលមកបួសបំផ្លាញសាសនាដោយតែតែប្រយោជន៍ផ្ទាល់ខ្លួន ។

យើងត្រូវចូលចិត្តថា ព្រះពុទ្ធសាសនានេះ ជាសាសនាដែលជនជាតិយើងកាន់តាប់តាន់មក បានដល់ពាំ ២៩០០ ឆ្នាំហើយ សព្វថ្ងៃនេះ យើងក៏នៅតែសិក្សា ព្រមទាំងប្រតិបត្តិយ៉ាងមាំមួន ប្រទេសយើង

ប្រៀបដូចបន្ទាយដ៏ធំនៃព្រះពុទ្ធសាសនា ព្រោះដូច្នោះ ទើបជានាទី
របស់យើង ដែលជាពួកពុទ្ធបរិស័ទ ត្រូវតស៊ូចាំជីវិតថែរក្សា នូវកម្ពុជរដ្ឋ
ឲ្យជារដ្ឋឯករាជ្យ ជានបិតៈថែរក្សាលអង្គរវត្ត ព្រះពុទ្ធសាសនាក៏នឹងរុង
រឿងដោយសារនោះផង ដើម្បីខុតជាកេរ្តិ៍មត៌កឲ្យកូនចៅរបស់យើង
តទៅឰដ៏អនាគតកាល ។

ការប្រតិបត្តិធម៌ធំងគោលធម៌ដែលគួរប្រតិបត្តិ

ការប្រតិបត្តិធម៌នឹងគោលធម៌ ដែលយើងគួរប្រតិបត្តិក្នុងទីនេះ
ពោលដោយសង្ខេប មាន ៤ យ៉ាង គឺ

๑- ការដល់ព្រះត្រៃសរណាគមន៍,

๒- ការប្រតិបត្តិសុចរិត ក្នុងត្រៃទ្វារ,

๓- ការដំកល់ខន្តីនៅក្នុងនិច្ចសីល,

๔- ការកំណត់ដឹងនូវអរិយសច្ច ๔ ។

ការដល់ព្រះត្រៃសរណាគមន៍

ការដល់ព្រះត្រៃសរណាគមន៍នោះ គឺជឹងគុណព្រះពុទ្ធ ព្រះធម
ព្រះសង្ឃថា:

๑- ព្រះពុទ្ធទ្រង់ត្រាស់ដឹង ដោយព្រះអង្គឯងមុនហើយ ប្រដៅ

អ្នកដទៃឲ្យដឹងតាមផង ។

๒- ព្រះធម៌គឺធម៌វិន័យ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

๓- ព្រះសង្ឃ គឺពួកសាវ័ក ដែលស្តាប់ពាក្យប្រដៅរបស់ព្រះពុទ្ធ ហើយប្រតិបត្តិតាមធម៌វិន័យ ទាំងប្រដៅអ្នកដទៃឲ្យប្រតិបត្តិតាមផង ។

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំង ๓ នេះ ហៅថា ព្រះរតនត្រ័យ យើងកាន់យកជាទីពឹងទីរលឹក ហៅថា ដល់ត្រៃសរណគមន៍ ។

ការប្រព្រឹត្តសុចរិតក្នុងត្រៃទ្វារ

ការប្រព្រឹត្តិសុចរិតក្នុងត្រៃទ្វារនោះគឺ ប្រព្រឹត្តសុចរិតដោយកាយ ๑ ដោយវាចា ๑ ដោយចិត្ត ๑ ។

ប្រព្រឹត្តសុចរិតដោយកាយនោះ គឺ

๑- វៀរចាកការសម្លាប់សត្វ,

๒- វៀរចាកការលួចទ្រព្យ,

๓- វៀរចាកការកន្ធត់ប្រពៃណី ។

ប្រព្រឹត្តសុចរិតដោយវាចានោះ គឺ

๑- វៀរចាកការនិយាយកុហក,

๒- វៀរចាកការនិយាយចាក់ដោត,

๓- វៀរចាកការនិយាយញុះញង់,

៤- អរិយវោហារនិយាយពាក្យឥតប្រយោជន៍ ។

ប្រព្រឹត្តសុបរិតដោយបិត្តនោះ គឺ

១- អរិយវោហារឈ្លោកចំពោះខ្លួនអ្នកដទៃ,

២ អរិយវោហារឆន់តំនុំចំពោះអ្នកដទៃ,

៣- ធ្វើចិត្តឲ្យឃើញត្រង់តាមសភាវធម៌ ។

ការជំកល់ខ្លួនទៅក្នុងធិប្ចសីល

ការជំកល់ខ្លួនទៅក្នុងធិប្ចសីលនោះ គឺ

១- អរិយវោហារសម្លាប់សត្វ,

២- អរិយវោហារលួចប្លន់ទ្រព្យគេ,

៣- អរិយវោហារកន្ធឆប្រពៃណី,

៤- អរិយវោហារនិយាយកុហក,

៥- អរិយវោហារក្រេបផឹកទឹកស្រវឹងនឹងមេរ៉ាយ ។

ការកំណាត់ជំងឺអរិយសច្ច ៤

ការកំណាត់ជំងឺអរិយសច្ច ៤ នោះគឺ កំណាត់ជំងឺទុក្ខ ១, កំណាត់ជំងឺហេតុជាទីកើតនៃទុក្ខ ១, កំណាត់ជំងឺការរំលត់ទុក្ខ ១, កំណាត់ជំងឺផ្លូវប្រតិបត្តិ

ដើម្បីរំលត់ទុក្ខ ១ ។

១- ទុក្ខ បានដល់សេចក្តីមិនសប្បាយកាយមិនសប្បាយចិត្ត ។

២- ហេតុជាទីកើតនៃទុក្ខ បានដល់តណ្ហា ៣ ប្រការ គឺកាមតណ្ហា សេចក្តីប្រាថ្នាក្នុងអារម្មណ៍ដែលគួរស្រឡាញ់ ១ ភវតណ្ហា សេចក្តីចង់មានចង់កើតជានេះជានោះ ១ វិភវតណ្ហា សេចក្តីមិនចង់មាន មិនចង់កើតជានេះជានោះ ១ ។

៣- ការរំលត់ទុក្ខ បានដល់ការរំលត់តណ្ហា ដែលពោលមកហើយនោះ ដោយអស់ដើន ។

៤- ផ្លូវប្រតិបត្តិដើម្បីរំលត់ទុក្ខ នោះមាន ៨ ប្រការគឺ បញ្ញាឃើញប្រពៃ ១ ត្រិះរិះប្រពៃ ១ ចរចាប្រពៃ ១ ធ្វើការងារប្រពៃ ១ ចិញ្ចឹមជីវិតប្រពៃ ១ ព្យាយាមប្រពៃ ១ តាំងស្មារតីប្រពៃ ១ តាំងចិត្តប្រពៃ ១ ។

ប្រយោជន៍នៃការប្រតិបត្តិសីលធម៌

ការប្រតិបត្តិសីលធម៌ដូចពោលមកហើយនេះ អ្នកប្រតិបត្តិតែងឃើញប្រយោជន៍ជាក់ច្បាស់ដោយខ្លួនឯង ដូចតទៅនេះ ៖

១- តែងបានទទួលសេចក្តីសុខផ្លូវចិត្ត ដោយជឹងចំពោះខ្លួនថា អាត្មាអញបានដំកល់ខ្លួនទុកក្នុងសីលធម៌ដ៏ប្រពៃ ។

២- ជាទីពុកចិត្តរបស់ម្នុសជាទៃ ពាំនប្រកបកិច្ចការអ្វី ។ តែងសម្រេចបានដោយស្រួល ព្រោះអ្នកដែលធ្វើការពាក់ព័ន្ធជាមួយគ្នានោះ មិនមានសេចក្តីរង្កៀសសង្ស័យ ; នេះជាកិច្ចដ៏សំខាន់ត្រៃលែង ។ ព្រោះការសម្ពន្ធរវាងបុគ្គលនឹងបុគ្គល គណៈនឹងគណៈ ជាតិនឹងជាតិ នឹងសម្ពន្ធបានយូរ ក៏ព្រោះមានសេចក្តីពុកចិត្តគ្នាទៅវិញទៅមក បើគ្មានសេចក្តីពុកចិត្តគ្នាទេ នឹងបងមេត្រីដល់គ្នានឹងគ្នា ឲ្យយឺនយូរពុំបានឡើយ ។ សេចក្តីពុកចិត្តគ្នានេះនឹងកើតឡើងបាន ព្រោះមានការប្រព្រឹត្តសុចរិត ពោលគឺតាំងខ្លួននៅក្នុងសីលធម៌នោះឯង ។

ប្រការ១ ទៀត ក្រៅពីមានប្រយោជន៍ចំពោះខ្លួនអ្នកប្រតិបត្តិហើយ ការប្រព្រឹត្តសីលធម៌នេះ អាចជាប្រយោជន៍ដល់ពួកគណៈ ឬដល់ប្រទេសជាតិ ព្រោះអ្នកប្រព្រឹត្តសីលធម៌ អាចដឹកនាំពួកជនឲ្យមានសាមគ្គីធម៌ ។ កាលជនពាំនឲ្យមានសាមគ្គីធម៌បរិបូណ៌ហើយ ក៏ជាកំឡាំងដល់ប្រទេសជាតិ ដែលយើងអាចនឹងរក្សាឥស្សរភាពឲ្យបានបឹតរឹងរឹតកាលឬពង្រីកឥស្សរភាពឲ្យបានខ្ជួលខ្ជាយ ក៏មកពីមានសាមគ្គីធម៌ ។ ការប្រព្រឹត្តសីលធម៌មានប្រយោជន៍ដូចពោលមកនេះ ទើបជាកិច្ចដែលយើងត្រូវតែប្រតិបត្តិ ដោយខានមិនបាន តើបើយើងនឹងធ្វើកិច្ចការអ្វីមួយ គួរធ្វើឲ្យត្រឹមត្រូវតាមគន្លងធម៌គន្លងច្បាប់ បើយើងនឹងតាំងច្បាប់អ្វីមួយត្រូវ

តាំងជាច្បាប់យុត្តិធម៌ កុំតាំងជាច្បាប់អយុត្តិធម៌ឡើយ ព្រោះច្បាប់ដែលតាំងជាយុត្តិធម៌ តែងឋិតនៅអស់កាលដ៏យូរ តាំងជាទីពាប់ចិត្តរបស់ជនពួកខ្លះ ច្បាប់ដែលតាំងជាអយុត្តិធម៌ តែងធ្លាប់វិនាសសាបសូន្យ តាំងមិនជាទីពាប់ចិត្តរបស់ជនានុជន ព្រោះដូច្នេះ យើងត្រូវប្រតិបត្តិធម៌ប្រតិបត្តិច្បាប់ ដើម្បីឲ្យបានប្រយោជន៍ដល់ខ្លួនយើង នឹងប្រទេសជាតិយើង បើយើងប្រព្រឹត្តធម៌ ធម៌ក៏នឹងរក្សាយើងឲ្យជ្រាលជាកកយន្តរាយតាំងពួនសមដូចព្រះពុទ្ធភាសិតថា ធម្មោ ហវេ រក្ខតិ ធម្មចារឹ "ធម៌នោះឯងតែងរក្សាអ្នកប្រព្រឹត្តធម៌ឲ្យបានសេចក្តីសុខសេចក្តីចំរើនគ្រប់ទីវាលត្រីកាល" ដូចបានអធិប្បាយមក ដោយប្រការដូច្នេះ ។

អត្តនោ កម្មករណាកថា

ព្រះមហាអ៊ុត-អ៊ីន រៀបរៀង

ឥមោ តសរ្ស កកវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តាលនេះជាតាលគួរពិណិនាអំពី អត្តនោ កម្មករណាកថា ការពោលអំពីការធ្វើនូវការងារបស់ខ្លួន ដើម្បីបំភ្លឺនូវមគ្គសម្រាប់ប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ដែលជាមគ្គកណ្តាលសម្រាប់អប់រំក្នុងពុទ្ធចក្រនឹងអាណាចក្រ ពាំងជាមធ្យោបាយដឹកនាំមនុស្សជាតិទូទៅឲ្យស្រឡាញ់សេចក្តីស្ងប់សម្រាប់ខ្លួននឹងអ្នកដទៃផង ។

មែនពិត ព្រះពុទ្ធសាសនា ជាធម្មជិបតេយ្យ ដឹកនាំសត្វតាមផ្លូវកណ្តាលមិនតឹងពេក-ធូរពេក ។ ព្រះពុទ្ធទេសន្តទ្រង់សំដែងពាំងប៉ុន្មានសុទ្ធតែជាអនុសាសនៈ ដឹកនាំសត្វទូទៅឥតរើសមុខ ឲ្យស្ងប់កាយ-វាចា-ចិត្ត ចាកអំពើជាអមនុស្សធម៌ឲ្យបានសុខគ្រោតគ្រាត កណ្តាលសុខុម ព័ន្ធយៅនាយ តាមផ្លូវពាំងពីរតំលោកនឹងធម៌ហូតនិព្វានសុខជាបំផុត ។ ព្រះពុទ្ធសាសនា ប្រកាសដឹកនាំសត្វឲ្យប្រកបការងារសម្រាប់ខ្លួន ដែលឥតទោសនាំមកនូវសុខចំរើន ប្រព្រឹត្តទៅមិនបៀតបៀន មិនបំផ្លេចបំផ្លាញសុខ ការសម្រេចសេរីភាព តាមផ្លូវកាយដ៏រឹត ធនធាន គ្រាមធម៌សច្ចៈ ស្មារតីមាំមួន រវាងគ្នានឹងគ្នា ប្រកបដោយព្រហ្មវិហារធម៌ ។ ព្រះពុទ្ធភាសិត

មួយបទដែលមានន័យសំដែងអំពីការប្រកបការងារបស់ខ្លួនគឺ

សីលទស្សនសម្បន្នំ ធម្មដ្ឋំ សច្ចវាទិនំ

អត្តនោ កម្ម កុព្វាំ តំ ជនោ កុរុតេ បិយំ (๑) ។

ជនទូទៅតែងស្រឡាញ់នូវបុគ្គល ដែលប្រកបដោយសីលនិងទស្សនៈបឋមនៅក្នុងធម៌ ពោលនូវសច្ចៈ ធ្វើនូវការងារសម្រាប់ខ្លួន ។

ព្រះពុទ្ធកាលនេះ សំដែងអំពីធម៌ដែលធ្វើបុគ្គលអ្នកប្រព្រឹត្តឲ្យជាទីស្រឡាញ់នៃលោកយមហាជន ជាបុគ្គលាធិដ្ឋាន ៥ បទគឺ

๑- សីលសម្បន្នៈ ដែលបរិបូរដោយសីល គឺមានសីល ៥, សីល៨, សីល ๑๐, សីល ๔;

๒- ទស្សនសម្បន្នៈ ដែលដល់ព្រមដោយទស្សនៈ គឺមានញាណយើញធម្មជាតិពិត ;

๓- ធម្មដ្ឋៈ ដែលឋិតក្នុងធម៌ គឺបានលោកុត្តរធម៌ ๙ ឬឋិតក្នុងធម្មវិនិច្ឆ័យ ;

๔- សច្ចវាទី ដែលពោលនូវសច្ចៈ គឺបាននូវសច្ចៈ ๔ ឬពោលវាចាពិតត្រង់ ;

๕- អត្តនោកម្មកុព្វាំ ដែលធ្វើនូវការងារសម្រាប់ខ្លួន គឺធ្វើតាមភារៈរបស់ខ្លួន ។

๑- ធម្មបទ ខុ. ចរិយាវគ្គ

បណ្តាធម៌ចាំង ៥ បទនោះ ត្រូវលើកយកតែបទទី ៥ មកពណ៌នា ដូចតទៅនេះ :

ពាក្យថា «ទំធ្វើនូវការងារសម្រាប់ខ្លួន» គឺទំប្រឹងប្រែងធ្វើនូវកិច្ចការដែលមានសម្រាប់ហាន: កេរ សង្គ្រមរបស់ខ្លួន ដែលខ្លួនត្រូវធ្វើ ប្រកបប្រព្រឹត្ត ដឹកនាំ សម្រេច គោរពប្រតិបត្តិដោយមុតមាំ មិនជាក់ធុរៈចោលមិនប្រមាទដើម្បីឲ្យបានផល ។

មែនពិត ក្នុងមនុស្សលោកនេះ មនុស្សដែលបានកើតមកក្នុងត្រកូល មានសម្បត្តិក្តី ឥតសម្បត្តិក្តី សុទ្ធតែជាមនុស្សក្រពាំងអស់ ព្រោះមនុស្សនេះឯងកាលដែលខ្លួនកើតមក មិនបានលេបកាន់យកចំណេះវិជ្ជាយសសក្តិទ្រព្យសម្បត្តិមកផងទេ កើតមកមានតែសរីរាវយវៈលាតទទេតែប៉ុណ្ណោះ ត្រឿនបរិហារបន្ទាប់មកជារបស់មាតាបិតាសុទ្ធសោធ; តែបណ្ឌិតមានព្រះពុទ្ធជាដើមពោលថា សត្វដែលបានកើតជាមនុស្ស ជាសត្វមានសម្បត្តិខ្ពង់ខ្ពស់ ព្រោះមានកំពូតិសេសជាងសត្តនិកាយឯទៀត ។ ដោយអត្ថកាពអាយតនៈនីដោយសេចក្តីដឹងពិសេស ចំពោះការចំរើនវិនាស; សេចក្តីដឹងពិសេសនេះហើយដែលញុំាងមនុស្សដែលកើតមកសុទ្ធតែត្រូវឲ្យចេះសិក្សាធ្វើការងារ ប្រតិបត្តិការងារ ដែលជាអណ្តូងនៃវិជ្ជាយសសក្តិទ្រព្យសម្បត្តិកេរ្តិ៍ឈ្មោះ សុខមនុស្ស សុខសួគ៌ សុខនិព្វានឥតកង្វល់ ។

មែនពិត, ទិដ្ឋធម្មិកលោក គឺលោកដែលយើងឃើញច្បាស់នឹងមំសចក្ខុ

នេះឯងជាលោកសម្រាប់ប្រារព្ធការងារ សាងការងារ បញ្ចប់ការងារតាម
ថ្នាក់នៃគោលបំណងរបស់អ្នកការងារ មិនមែនជាលោកសម្រាប់ចាំទទួល
សោយផល ដោយមិនចាំបាច់ធ្វើការងារ ប្រកបការងារតែម្ដងទេ ។ ព្រះ
ពុទ្ធជាអ្នកប្រាជ្ញខាងសន្តិភាពទ្រង់ស្ងាត់មុនគេក្នុងការប្រកបការងារសម្រាប់
ហានៈរបស់ព្រះអង្គ ដែលជាការងារមិនប៉ះពាល់ដល់សេចក្តីសម្រេចនឹងទំ
នើងគេមិនញ៉ាំងឲ្យខូចសេចក្តីសុខ_ចំរើននៃបវេនី ដរាបដល់ចប់ការងារ
របស់ព្រះអង្គ ក្នុងពេលដែលទ្រង់ត្រាស់ដឹងនូវធម៌ពិតជាធម៌ស្ងប់ ឥតវិហឹសា
សុទ្ធសាធផ្សាផង, មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់បំពេញការងារជាប្រយោជន៍
សត្វគឺពុទ្ធកិច្ច ៥ ទៀត ។ ពុទ្ធកិច្ចដែលជាប្រយោជន៍ធំបំផុតគឺការសំ
ដែងធម៌ណែនាំពន្យល់ប្រដៅសត្វ ឲ្យចំធ្វើការងារសុចរិតជាកុសលដែល
មិនបៀតបៀនខ្លួនឯងបុគ្គលដទៃ គឺទ្រង់ដឹកនាំឲ្យធ្វើការងារខាងផ្លូវសន្តិ
ភាពពាំងពីរខាង មិនមែនឲ្យធ្វើតែមួយខាងៗទេ ព្រោះព្រះអង្គមិនត្រូវ
ការជាក់ខ្លួនព្រះអង្គលើសត្វមួយៗ ព្រោះអគតិធម៌ទេ ក្នុងហានៈព្រះអង្គជា
ព្រះពុទ្ធ ព្រះអង្គគ្រាន់តែជាសាស្តាចារ្យ របស់មនុស្សទេពតាខ្លួនៗ ក្នុង
ត្រៃលោក ឥតរើសមុខប៉ុណ្ណោះ ។

ការងារដែលមានប្រចាំលោកមនុស្សនេះ ដែលមនុស្សអ្នកការងារ
ត្រូវតែធ្វើនឹងត្រូវតែរិះរក បង្កើតឲ្យមានឡើង មានច្រើនប្រភេទណាស់តែ
បើពោលដោយខ្លីជាគួរ ។ មានបីគឺ

ការងារគួរទី ๑

๑- រដ្ឋកម្ម ការងារសម្រាប់ព្រះរាជា ឬ អ្នករាជការ,

๒- រដ្ឋកម្ម ការងារសម្រាប់អ្នកដែន ឬ ពាស្ត្រ ។

រដ្ឋកម្ម

ចំណែកនៃដែនដីមួយផ្នែក។ ដែលមានមនុស្សនៅរួមជាមនុស្សព្រាសធំ មានប្រពៃណីសាសនាច្បាប់ របៀបគ្រប់គ្រងពេញលក្ខណៈ ហៅថាប្រទេសរដ្ឋ ឬដែន ។ ជនអ្នកនៅក្នុងដែនហៅថា ពលរដ្ឋ ។ បុគ្គលខ្ពស់ក្តីមានសេសជាតិគោរពសក្តារបូជានៃពលរដ្ឋ ហៅថាព្រះរាជា ឬព្រះមហាក្សត្រ ព្រះរាជាទ្រង់ញ៉ាំងពលរដ្ឋឲ្យក្សេមក្សាន្ត ដោយសង្គហធម៌និងសព្វជនបទធម៌ ។ ទ្រង់មានព្រះរាជការៈធ្ងន់បំផុតចំពោះអាយុជីវិតនៃប្រទេស។ ទ្រង់ប្រោសប្រាណឲ្យរឹងដែនចាត់ចែងអតិថិជនរដ្ឋ ។ តិច្ចការអតិថិជនរដ្ឋនេះ ជាតិច្ចមានខម្ងន់ចង្អៀតក្រៃបំផុត ព្រោះជាការមហាគ្រួសារមួយ ។ តិច្ចការនោះដែលជាប្រក្រតីធំ ។ មានជាអាទិ៍គឺ

- ការងារប្រព្រឹត្តទៅ ដើម្បីជីវភាពខ្ពង់ខ្ពស់សុខុមាលភាព,
- ការងារប្រព្រឹត្តទៅ ដើម្បីវឌ្ឍនភាពខាងវិជ្ជា,
- ការងារប្រព្រឹត្តទៅ ដើម្បីសុខភាពឥតរោគ,
- ការងារប្រព្រឹត្តទៅ ដើម្បីរៀបរយសុខសាន្ត

- ការងារប្រចាំក្តៅ ដើម្បី ឯកពាក្យសព្ទផ្សេង ។

ព្រះរាជាទ្រង់ប្រោសប្រាណឲ្យរាជនគ្រប់គ្រងរដ្ឋ ដោយព្រះពុទ្ធហេតុយ
ប្រកបដោយព្រហ្មវិហារធម៌ ទ្រង់ទុកពលរដ្ឋជាគ្រួសារតែមួយរបស់ព្រះអង្គ
ទ្រង់ព្យាយាមបំពេញព្រះពុទ្ធកម្ម ដើម្បីអធិបតេយ្យ សិទ្ធិ សេរីភាព សន្តិ-
ភាព ដល់ពលរដ្ឋជាកូនចៅជាទីស្នេហារបស់ព្រះអង្គ សូម្បីតែព្រះជន្មក៏
ទ្រង់អាចបូជាដល់មាតុភូមិ ព្រោះប្រយោជន៍សាធារណៈ ។

ព្រះមហាក្សត្រតាំងពីបឋមកល្បមក តែងតែជាទីគោរពបូជាស្នេហានៃ
ពលរដ្ឋ ។

រដ្ឋកិច្ច

ជនដែលនៅក្នុងដែនមានអធិបតេយ្យបរិបូណ៌ ហៅថាពលរដ្ឋ ។
ពលរដ្ឋដែលបានទទួលសុខ-ចំរើន អំពីអភិបាលរបស់ព្រះពុទ្ធហើយត្រូវ
ប្រតិបត្តិការងារសម្រាប់ខ្លួនឲ្យសមជាអ្នកមានវិន័យថ្លៃថ្នូរ ។ ការងារនោះ
មានជាអាទិ៍

- ជនសន្និដ្ឋិយ ការកសាងសន្សំជនធានទុក គឺការប្រតិប
អាដ៏រកម្មដោយកសិកម្មជាដើម សន្សំទ្រព្យទុកឲ្យមាន ។ ការសន្សំនឹង
ចាយវាយ ត្រូវតាមន័យនៃពាក្យសុភាសិតដ្ឋីថា :

អញ្ញធនំ ឧយ្យនិសា្ស ឧបចិតាធញ្ញ អាចយំ

มชฺฌิมา สมาหารา បណ្ឌិតោ យាមាវិសេ បណ្ឌិតនៅគ្រប់គ្រងផ្ទះសម្បែង ត្រូវមើលថែរក្សាបន្តក់ភ្នែកដែលអស់ មើលការពួនជំបួកនៃពួកសត្វកណ្តៀរ នឹងការដញ្ជាន់ចំកន្លែងនៃកម្រជាតិ ។

- ภณฺฑาคารกมฺม ការថ្វាយពលិកម្មដល់ព្រះរាជា ។ ប្រទេសពីនផ្នែកជាចាំបាច់លើពលរដ្ឋខាងធនធាន ។ ធនធានរបស់ពលរដ្ឋជារបស់ប្រទេស ។ តាលបើពលរដ្ឋមានសម្បត្តិគ្រប់ចាំងដប់ ប្រទេសមានមុខស្រស់ជានិច្ច ។ ដូច្នេះពលរដ្ឋត្រូវលែមួយចំណែកអំពីទ្រព្យ ដែលសន្សំបានបូជាដល់ប្រទេស ដើម្បីជាកំឡាំង ។

- ธมฺมปฏิปตฺติ ការប្រតិបត្តិតាមច្បាប់ គឺធ្វើតាមច្បាប់បញ្ញត្តិដោយមិនប្រព្រឹត្តកន្លងច្បាប់ដែលបញ្ញត្ត មានមិនឲ្យប្រព្រឹត្តអបាយមុខជាដើម ធ្វើតាមច្បាប់អនុញ្ញាត គឺប្រព្រឹត្តតាម កាន់តាមច្បាប់ដែលអនុញ្ញាតឲ្យធ្វើ ។

- ขุชฺชกมฺม ការងារត្រង់ គឺពលរដ្ឋសុតត្រង់ ខន់កូនដោយស្មានពីរយ៉ាងគឺ

ក- ខៀងត្រង់ សុភាពរៀបរយមានសុមីតភ្តិ ចំពោះព្រះរាជានឹងអ្នកពាក់ព័ន្ធ

ខ- ការគោរពគ្នា និយាយពាក្យពេចន៍ទៅកាន់គ្នា ចេះអត់ធ្មត់ទៅ-វិញទៅមក ។

ពលរដ្ឋ ដែលបានធ្វើការងារសម្រាប់ខ្លួនយ៉ាងនេះ ឈ្មោះថាបានបូជាកំលាំងកាយ-វាចា-ចិត្ត ថ្វាយព្រះរាជា ឈ្មោះថា ពលរដ្ឋស្មូតត្រង់ចំពោះព្រះរាជា ។

ការងារភ្លូទី ២

១- គហាដ្ឋកម្ម ការងារសម្រាប់អ្នកគ្រប់គ្រងផ្ទះ,

២- បព្វជិតកម្ម ការងារសម្រាប់អ្នកលះបង់ផ្ទះ (អ្នកបួស)។

គហាដ្ឋកម្ម

ពាក្យថា គហដ្ឋ ឬ គ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ បានសេចក្តីថា អ្នកឋិតនៅក្នុងការខ្វល់គឺតាមគុណ ; អ្នកឋិតក្នុងគ្រឿងចាក់គឺចំណងគឺប្រពន្ធកូនទ្រព្យសម្បត្តិ អ្នកឋិតនៅក្នុងសាំញ៉ាគឺការខ្វល់ក្នុងតិចួការផ្សាល់ខ្លួន តិចួការអ្នកដទៃ ក្នុងការចិញ្ចឹមគ្រួសារ, អ្នកឋិតក្នុងសេចក្តីច្រាច្បាគឺច្រាច្បា ប្រពន្ធកូន ទ្រព្យ ស្រុក ដែន លោកចាំងមូលៈអ្នកឋិតនៅក្នុងគ្រោះ គឺគ្រោះព្រោះខ្លួកកុប៉ាល់លិចខ្លួកលង់ រថយន្តក្លួកក្រឡាប់ ជាដើមៈអ្នកឋិតនៅក្នុងអន្តរាយគឺវិនាសសិរីញាណកទ្រព្យជាដើម អំពីចោរជាដើម, អ្នកឋិតនៅសឹង្គក្នុងសង្គ្រោះគឺសង្គ្រោះគ្រួសារខ្លួនអ្នកមានគុណទូបការ ញាតិមិត្រអ្នកចំលក្រសមណព្រាហ្មណ៍ ។ ការគ្រប់គ្រងផ្ទះរបស់គ្រហស្ថនេះ មិនងាយបំពេញឲ្យពេញបានទេ ព្រោះមានដំណើរដូចពោលមកហើយ ។ ខុកជាដូច្នោះ

ព្រះពុទ្ធជួយគ្រហស្ថដោយពន្យល់ឲ្យធ្វើការងារដោយឥតញាញ៊ីតធម្មជាតិ។

ការងារគ្រហស្ថដែលនឹងប្រព្រឹត្តទៅស្រួល ក្នុងបច្ចុប្បន្ននឹងបរលោក ត្រូវប្រកបដោយសម្បទា ៨ប្រការគឺ

๑- ឧដ្ឋានសម្បទា ការប្រកបដោយការខ្នះខ្នែងក្នុងការសន្សំទ្រព្យ ដោយកសិកម្ម, វណិជ្ជកម្ម, គោរក្ខកម្ម,ធនុសិល្បកម្ម, រាជបោរិសកម្ម, ឬ សិប្បៈដទៃ។ ; ការដំនាញមិនខ្ជិលក្នុងកិច្ចការនោះ។, ការប្រកបដោយឧបាយវីមំសាពិនិត្យមើលក្នុងការនោះ ។ ថាគួរធ្វើយ៉ាងនេះ គួរចាត់ចែងយ៉ាងនេះ ;

๒- អារក្ខសម្បទា ការប្រកបដោយការរក្សា គឺការបង្ខំនូវចិត្តទ្រព្យគ្រប់គ្រងខុកនូវគោគៈចាំងឡាយដែលខ្លួនបានដោយឧដ្ឋានៈ នឹងវីរិយៈសន្សំបានដោយកំលាំងដៃ បានដោយបែកញើសហូរញើស ប្រកបដោយធម៌ បានដោយធម៌ មិនឲ្យអន្តរាយដោយអ្នកមានឫទ្ធិ ចោរលួច ភ្លើង នេះ ទឹកសិច អ្នកទទួលមរតកមិនជាទីស្រឡាញ់ (អវជាតបុត្រ) នឹងហេតុផ្សេង។ មានអឌ្ឍមុខជាដើម ;

๓- កល្យាណមិត្តតា ភាពមានមិត្តល្អ គឺមានមិត្តដែលមានសទ្ធា, សីល, ចាគ, បញ្ញា ឈរ ចរចា សាកច្ឆា នឹងកល្យាណមិត្តនោះ រៀនតាមនូវសម្បទាចាំង ៤នោះ,

๔- สมชีวิตา การចិញ្ចឹមជីវិតល្មម គឺការចាយទ្រព្យចិញ្ចឹមជីវិត លៃតាមបរិមាណកោគៈថ្លឹងឲ្យស្មើ មិនខ្ពស់ពេក មិនតឹងតឹងពេក សមតាមជនខ្លួន,

๕- សទ្ធាសម្បទា ការដល់ព្រមដោយជំនឿ គឺការជឿចំពោះការត្រាស់ដឹងព្រះតថាគត,

๖- សីលសម្បទា ការដល់ព្រមដោយសីល គឺការលះបង់បញ្ហាវេរគឺកាន់សីល ๕,

๗- ចាគសម្បទា ការដល់ព្រមដោយចាគៈ គឺការលះកំណាញ់ បំពេញទានចាត់ចែងទាន,

๘- បញ្ញាសម្បទា ការដល់ព្រមដោយបញ្ញាគឺការដឹងច្បាស់ខ្លួវហេតុនៃទុក្ខនឹងអស់ទុក្ខ ។

គ្រហស្ថដែលមានតណ្ហាណាធម៌ បំពេញសម្បទាទាំង ๘នេះ ឈ្មោះថាបានធ្វើការងារសម្រាប់ខ្លួនពេញលក្ខណៈ ។

បព្វជិតកម្ម

ពាក្យថា បព្វជិត បានសេចក្តីថា បុគ្គលដែលលះបង់ចោលស្រឡះខ្លួយកាវាសធម៌ចូលទៅកាន់បព្វជ្ជាក្នុងសាសនា ជាបុគ្គលឥតពីរនៅម្នាក់ឯងគ្រប់គ្រងរយៈបួ ๔ ជាអ្នកធ្វើចម្បាំងនឹងសត្រូវគឺកិលេសរកប្រកបគេចអំពីមារគឺ

កិលេស ។ បពូជិតមានការងារផ្សេងអំពីគ្រហស្ថចាំផអស់ ។ ការងារ
បពូជិតគឺការប្រព្រឹត្តិវត្តប្រតិបត្តិអតិសមាចារ, បំពេញគន្ថធុរៈ, វិបស្សនាធុរៈ,
ការណែនាំពុទ្ធបរិស័ទជាគ្រហស្ថឲ្យស្គាល់ផ្លូវចំរើន-វិនាស ខ្លួនឲ្យប្រ
ព្រឹត្តសុចរិត ការច្រាប់ទុយរួចចាកទុក្ខតាមគន្ថធម៌ ។ ពោលដោយទុក្ខដ្ឋ
ការងារបពូជិត គឺការបំពេញនូវសិក្ខាបីគឺ អធិសីលសិក្ខា, អធិចិត្តសិក្ខា,
អធិបញ្ញាសិក្ខា ឲ្យពេញលេញ ។

បពូជិតដែលបានបំពេញនូវការងារបស់ខ្លួន តាមធម្មវិន័យហើយ
ឈ្មោះថាបានញ៉ាំងសុខឲ្យមានក្នុងលោក, ញ៉ាំងពុទ្ធសាសនាឲ្យឋិតថេរ
ព្រោះព្រះពុទ្ធសាសនាមានវិន័យជាឫស ។

ការងារគួរទី ៣

๑- ពុទ្ធកម្ម ការងារសម្រាប់ព្រះពុទ្ធ ;
๒- ពុទ្ធបរិសកម្ម ការងារសម្រាប់បរិស័ទព្រះពុទ្ធ ។

ពុទ្ធកម្ម

ព្រះពុទ្ធជាអ្នកច្រាច្រ- ក្បាត់រំលឹកក្នុងការបំពេញអំពើឥតព្យាបាទឥត
វិហឹសាមុនគេ ទ្រង់លះសុខមួយគ្រួសារភូចៅប្រតិបត្តិការងារដើម្បីការ-
ត្រាស់ដឹងធម៌ដរាបបានសម្រេចនូវទីបំផុតគឺការបានដូរអនុត្តរសម្មាសម្ពោ-
ធិញ្ញាណ ក្រោយការប្រព្រឹត្តិវត្តតឹងរឹង ๖ឆ្នាំ ។

លុះបានសម្រេចអត្តហិតប្រយោជន៍ហើយ ទ្រង់បំពេញបរហិត-ប្រយោជន៍ទៀត គឺទ្រង់បំពេញពុទ្ធកិច្ចប្រាំយ៉ាង ។ ពុទ្ធកិច្ចជាចម្បងគឺ-ការសម្តែងធម៌បញ្ញត្តិវិន័យទុកជាចក្ខុមួយទាងសន្តិភាពហៅថាពុទ្ធចក្ខុ ។ ពុទ្ធចក្ខុនេះមានធម្មវិន័យជាគោល មានបរិស័ទដែលមកពីវណ្ណៈទាំង ៤ ចូលមកជាអ្នកប្រតិបត្តិហៅថាពុទ្ធបរិស័ទ ។ ធម្មវិន័យចែកជាខុទ្ទកបិដក គឺការមិនឲ្យធ្វើអំពើអាក្រក់ ១, ការឲ្យបំពេញអំពើល្អ ១, ការឲ្យសំអាតចិត្តឲ្យ ១, ។ ចែកជាបិដកបីគឺ វិន័យបិដក ១, សុត្តន្តបិដក ១, អភិធម្ម-បិដក ១ ។

ព្រះពុទ្ធទ្រង់បំពេញការងារព្រះអគ្គចប់ ទ្រង់តែងតាំងសាសនាទុកជាចក្ខុសន្តិភាពសម្រាប់សត្វអនាគតអស់ ៥ វស្សាហើយទ្រង់និព្វានទៅ ។

ពុទ្ធបរិសកម្ម

វណ្ណៈទាំង ៤ ដែលចូលមកស្តាប់នូវព្រះពុទ្ធប្រព្រឹត្តតាមថ្នាក់បរិស័ទ ហៅថាពុទ្ធបរិស័ទ ។ ពុទ្ធបរិស័ទ ត្រូវប្រតិបត្តិតាមអនុសាសនៈព្រះពុទ្ធដោយកិច្ច ៤ យ៉ាងគឺ

១- បរិយត្តិ ការរៀន គឺការរៀនស្វាធ្យាយន៍ អានចាំនូវព្រះត្រៃ-បិដកជាការដឹងច្បាស់នូវអត្ថសេចក្តីសារបស់ព្រះពុទ្ធសាសនា ចាំតែនូវរបៀប ប្រតិបត្តិសព្វគ្រប់ ។ បើពុទ្ធបរិស័ទ មិនរៀន-អានព្រះត្រៃបិដកទេ ក៏មិនអាចដឹងដំរៅរបស់ពុទ្ធសាសនា ម្ល៉ោះហើយនាំឲ្យខូចតម្លៃព្រះពុទ្ធសា-

សនាទៅវិញ ។ ព្រោះថា ព្រះពុទ្ធសាសនាដែលនឹងបិតនៅលុះតែពុទ្ធ-
បរិស័ទគោរពដោយការរៀន-អានព្រះត្រៃបិដក ។ ត្រង់ប្រទេសពុទ្ធ-
សាសនិក គេចំផ្សាយពុទ្ធសាសនាដោយការរៀន-ចោះពុម្ពព្រះត្រៃបិដក
ដូចប្រទេសយើងដែរ ។ ការរៀន-អាន លុះតែមានព្រះត្រៃបិដក ។ ព្រះ
ត្រៃបិដកផ្សាយទៅបាន លុះតែពុទ្ធបរិស័ទចង់ត្រេបរស់ព្រះសទ្ធម្ម ហើយ
ចង់បានព្រះត្រៃបិដកទៅអាន ។ លុះតែពុទ្ធបរិស័ទចេះព្រះត្រៃបិដកខើប
ពុទ្ធសាសនា បិតនៅស្ថាពរ ។

២- ធម្មានុធម្មប្បដិបត្តិ ការប្រតិបត្តិធម៌តាមធម៌ ។ ការប្រតិបត្តិ
នេះបានដល់ការធ្វើតាមព្រះវរ ដែលទ្រង់ប្រដៅក្នុងព្រះត្រៃបិដកសព្វ
គ្រប់ ។ ការប្រតិបត្តិនេះ ដែលប្រព្រឹត្តទៅបានលុះតែចេះព្រះត្រៃបិដក ។
ព្រះត្រៃបិដកជាផ្លូវ , ប្រតិបត្តិជាដំណើរតាមផ្លូវ, ពុទ្ធបរិស័ទជាអ្នកដើរ ។
ការប្រតិបត្តិនេះរួមទៅបានដល់ការធ្វើតាមធម្មានុវិន័យ ដែលមានចែង
ប្បាស់ក្នុងព្រះត្រៃបិដកសព្វគ្រប់ ។

ព្រះពុទ្ធសាសនា នឹងបិតថេរលុះតែអាស្រ័យបរិយត្តិ នឹងបដិបត្តិ -
ការបំពេញគន្ថធុរៈ វិបស្សនាធុរៈ ដោយត្រឹមត្រូវ នៃពុទ្ធបរិស័ទ ។

ព្រះពុទ្ធមិនមែនប្រកាសសាសនា ដើម្បីបាត្រ-ថង់ យាមព្រះអង្គទេ
ទ្រង់បង្ហោញពុទ្ធទេស្សនៈនាំសត្វឲ្យធ្វើការងារសម្រាប់ខ្លួនដោយសុចរិត
តាមមាគ្គិកណ្ឌាល ៨ នឹងព្រហ្មវិហារធម៌ ដែលជាធម៌ស្ងួនលោក ។

ការងារទាំងបីគូនោះ ដែលនឹងសម្រេចបាន លុះតែអាស្រ័យធម៌ជាដំ-
ណួយ ๘ យ៉ាង គឺ

๑- ឧដ្ឋាន: ការខ្នះខ្នែងក្នុងការងារ ;

๒- សតិ ការចាំជាក់ក្នុងការងារ ;

๓- សុចិកម្ម: ការធ្វើការងារឲ្យស្អាត ;

๔- ឥរិយាបថសម្បជញ្ញ: ការពិនិត្យស្រេចទើបធ្វើ ;

๕- សញ្ញម: ការប្រយ័ត្នក្នុងការងារ ;

๖- ធម្មជីវ: ការរស់នៅតាមធម៌ ;

๗- អប្បមាទ: ការមិនបណ្តែតបណ្តោយ ;

๘- ឧទ្យោគ: ការខ្នះខ្នែងឥតខ្ជិលឡើយ ។

បុគ្គល, គ្រហស្ថ បព្វជិត, កាលបានប្រព្រឹត្តធ្វើកិច្ចការតាមហេតុ-
ខ្លួនហើយរមែងជាទីស្រឡាញ់ពេញចិត្តនៃជនទូទៅ ទាំងទេពនិមន្តុស្ស-
ទេព តែងតែយើញគោរពបូជាប្រទានផ្លែផ្កាជានិច្ច ។ អ្នកដែលធ្វើការងារ
សម្រាប់ខ្លួនមិនដូចប្រុះទុបសគ្គអន្តរាយទេ មានតែចំរើនវិជ្ជា យសសក្តិ
ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ អាយុ វណ្ណ: សុខ: ពល: បដិភាន: ។ ហេតុនេះ
អ្នកដែលត្រូវការសុខចំរើន គួរធ្វើតែការងារសម្រាប់ខ្លួនចុះ ។

ការពណ៌នាអំពី " អត្តនោ កម្មករណាកថា " និយាយ
អំពីតំណែងធ្វើនូវការងារសម្រាប់ខ្លួន " ចប់ប៉ុណ្ណេះឯង ។

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ភាសាភាសា)

(តមក)

លោក អម្ចឹតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម
លោក ប៉ាក-ថែម ពិនិត្យ

គន់ឃ្លាបន្តិច ទៅទើបសម្តេច វរាជពន្ធគា ទ្រង់គតិខ្មែរជប់ សម្តាប់បុត្រា
មួយទៀតសោតា ទ្រង់ន្ធូវនៃរល័ក្ខណ៍ ។ តាលប្រសូតមក ព្រះឥន្ទ្រស្តេច
យក ជន្ធូសរស័ក្តិ ពីសុទ្ធថ្ពើងថ្កល់ មកដល់ហើយដាក់ នៅដៃស្តេចដាក់
ហើយហិចហោះទៅ ។ ព្រះអយ្យកោតា ន្ធូវាស្ត្រប្រជា ដែលប្រជុំ-
នៅ នាក្នុងកំពូង ចាំងក្នុងចាំងក្រៅ សឹងស្មានដោយទៀ ថាកាន់
ចេញមក ។ តែក្សត្រទុក្ខម គន់គិតថាសម មានខេវតាយក ជួមក
ជាក់កាល សម្រាលចេញមក សមក្លូនពន្ធុក នេះមានសម្ភារ ។ ស្តេច
គិតនឹងព្រាហ្មណ៍ សន្ធគ្រះនាម រាជបុត្រសង្ឃារ ហៅសហស្សសារ
នាមករកុមារ តាមហេតុអស្ចារ្យ ហើយក្សត្រជៀស្តង់យ ។ ឲ្យរើស
មេនំ ហុតសិបបួនបំ ហៅបុត្រថ្មើមថ្ងៃ ឲ្យរើសកុមារី ប្រឹមប្រិយល្មម
ស្មៃ សឹងរូបប្រពៃ ត្រកូលព្រះវង្ស ។ បានមួយពាន់គត់ ថ្វាត់ថ្វាយ
រាជបុត្រ ចាំងពីព្រះអង្គ ហើយឲ្យរើសអស់ ក្លូនប្រុសចតុរង្គ មាត្យ

មានអគ្គាចារ្យ ចែងចេះសិល្បសាស្ត្រ ទ្វៀរធ្វើអស់អាថ៌ ឈ្មោះ
ហៅទិសា- ចារមេក្តីមែន។ ។ ចូរចៅទៅរៀន អស់ពាំងរបៀន ឲ្យ
ចេះស្ទាត់ក្បែន បើចាចេះចាំ មួនមាំមែនខែន ឲ្យមាសពីរសែន
ដំឡឹងទៅគេ ។ បុត្រពីរលើកក្តាំ ទុនបង្គំដាក់ លើព្រះសិរ ហើយ
ក្រាបប្រណិប័តន៍ លាក្បត្រពាំងទ្រូ រៀលពីងទៅឯ ច្រាន្តច្រាសទាន ។
រួសរៀបព្រះអគ្គ ចាប្តុះពីក្តង ដង្ហក់ដង្ហាម ភាន់ធ្លុសដ៏យ ប្រពៃ
ប្តើងប្តាន បរិវារគ្រប់ច្រាណ សឹងតាមហែទៅ ។ ឥតកិតកយា
ចេញចរលើលា លុះដល់ឋានក្រៅ ស្តេចយាត់បរិវារ បរិពារឲ្យទៅ
ស្តេងស្តេចយាងទៅ តែពីរអង្គា ។ ពស្ត្រភ្លឹកចារមើ រូបដសីហ៍
ចេញចាកគូហា ស្មោះឆ្ពោះសំដៅ ទៅតក្កសិលា ចូលព្រៃព្រឹក្សា
សុទ្ធសឹងសត្វដង ។ បក្សីធ្វើលធ្លាត់ យាសយំស្រែងាត់ ស្រង្វែត-
សៅហ្មង អម្រែគង្គាត់ រួតតែលេងលង កៀងគូគ្រសង ចូលព្រៃ
ពីងពួន ។ គោត្តគោសីង្ហ៍សីហ៍ ខ្មោងខ្មាក្របី រមាសមាំមួន រមាំង-
ប្រើសតែ ចោលព័ទ្ធពីងពួន ខ្លាចខ្លាលាក់ខ្លួន ខ្លះរកស៊ីស្មៅ ។ កុមារ
ប្រសើរ ធំតែផ្លែឈើ ទេះទំយាងទៅ ដោយកៀនគន្ធង ដែនដង-
ព្រៃស្រៅ ដរាបលំនៅ តក្កសិលា ។ រកអាចារ្យយល់ ចរចូល-
ទៅដល់ ទុនអគ្គវន្ទា ដម្រាបសូមរៀន រៀនសាស្ត្រា ឯអគ្គអាចារ្យ

ចានយង់យល់ជាក់ ។ រួចពន្លាលពេញ ចិត្តចាប់ស្រឡាញ់ ពាំន
ពីរស្មោះស្ម័គ្រ ដូចកូនអាត្មា សួរថាមៃអ្នក មាសមាននរលក្ខណ៍ មក
ពីឋានណា ។ ជាកូនព្រាហ្មណ៍ព្រឹទ្ធ ឬកូនបុរោហិត អាមាត្យសេនា
ឬចុបុត្រក្សត្រ គ្រងរដ្ឋភាព នគរនាមា នោះនាមឈ្មោះអ្វី ។
កុមារពីរពន្យល់ លុតលើកកំបង់ ជាក់លើសិរសី សារសន៍រំដឹងថ្លាត់ រីដ្ឋ-
ប្បវី នាមករស្មូស្តី តោសេយ្យនគរ ។ បិតាសោភ័ណ នាមព្រះទេវន្ធ
មហេសីបវរ ប្រសើរវរវង្ស ទ្រើសទ្រង់នាមករ សុវណ្ណកេសរ ជា-
ព្រះមាតា ។ ក្សត្រៃថ្ងៃពន្ធុក ច្រោសប្រើឲ្យមក. រកលោកអាចារ្យ
ច្រើណីសូមរៀន រៀនសាស្ត្រា បរិបូណ៌ច្បាស់ រំលឹងរំញឹងៗ ។
ព្រាហ្មណ៍ស្តាប់អរស្មោះ ឆ្លើយថាបើដ្ឋោះ ចូរចៅនិត្យនៅ អង្គុតញ-
ន្ធឹងច្រៀន រៀនពាក់ច្រៅ តាមចំណង់ៗ គន់គិតច្រាថ្នា ។ កុមារ-
ប្រសើរ ប្រណិបត្តន៍បំរើ សព្វពេលវេលា អាចារ្យច្រាប់ច្រៀន រៀន-
សាស្ត្រា តែមួយមាសា ចេះចាំមែនមែន ។ លង់សិល្បសត្តិសុទ្ធ
សោតសឹងធាប់ធុត ច្រាកដមែនៗ អាចារ្យប្រសិទ្ធ រឹងរិទ្ធីកូន ដូន-
មាសពីរសែន ដំឡឹងលាបវរ ។ ចូលក្នុងព្រៃច្រៅ ស្មោះឆ្ពោះសំដៅ
ឋានព្រះនគរ លាកលីលាលេង រង្គងរិលវរ ក្ងេចផ្លូវពានេចរ ជាន់-
ដើមដែលដើរ ។ វែះរិលមកត្រូវ ប្រទះលើផ្លូវ មួយមិញត្រង់លើ ឋាន-

មន្ត្រីក្នុង ថ្វាយជាបង្គោរ ។ លុះព្រះជន្មគ្រប់ បរិបូណ៌ឆ្នាំដប់ រីព្រះ
អនុជា ទ្រង់រូបល្អល្អះ គ្រចះថ្លៃថ្នូ ចម្រើនជន្មសា ប្រាំពីរឆ្នាំច្បាស់ ។
តែងនាំបង្គោរ នូវអស់បរិពារ ក្មេង។ ចាំងឡាយ លីលាតសេង
ដោយល្បែងសប្បាយ ថ្វាថ្លែងសរសោយ ភ្លាល់លេងបាញ់វង់ ។ សម្តេច្រ
សាគរ ស្តេចហាត់បាញ់សរ បានខាងតែត្រង់ សហស្សសរកុមារ
អនុជវៃឆ្ងាយ ព្រះទ័យនឹកចង់ ថ្លែងជាអ្នក។ ។ សោតសិងតែកើត
ដោយតេជៈណាត សរព្រះគោសីយ៍ ប្រពន្ធកុមារ បង្គោរប្រុសស្រី
ចិត្តចង់ស៊ីអ្វី សឹងសូមកុមារ ។ ស្តេចថ្លែងសរឲ្យ តើតបរិបូណ៌ដោយ
ចំណង់ប្រាថ្នា បើនឹងចង់ដុះ ដំនិះអស្សរោហ៍ តដេន្ទ្រថា ពាដសីហ៍តដ-
សីហ៍ ។ ខ្លួតអូតដុំពា រមាសភ្លេងខ្ញុ ចំណង់អ្វី។ ស្តេចតែងប្រាស
ប្រាណ ប្រពន្ធប្រក្រតី សប្បាយចាំងស្រី ចាំងប្រុសពាល់គ្នា ។លង់
លុះខៀងតិច ភៅខើបសម្តេច អយ្យគោអយ្យកា ដោយ។ ព្រះអគ្គ
ស្តេចទ្រង់ជព ក្សត្រិយព្រះជន្ម ភៅហានសួគ៌ភៅ ។ ក្សត្រីវៃឆ្ងាយ នូវ-
អគ្គព្រះពង្ស ព្រះពុទ្ធភៅ ពាស្រពេជវៃឆ្ងាយ ចាំងកូនចាំងស្រី សោត
សុទ្ធសឹងសៅ នឹងក្សត្រខ្មែហា ។

(ចប់ខ្សែ ៥ តែប៉ុណ្ណោះ) ។

នេះនៅស័ព្ទសារ សារសង់អស់តាថ អស់អត្តកំណត់ ហៅវៀ
ច្រាំមួយ តាមដាយន្ទូវបទ ន្ទូវបាទច្រាតដ ប្រកបសេចក្តី ។ កាល
ពោធិវង្ស ជុំអស់ចតុរង្គ មាត្យមុខមន្ត្រី ន្ទូវអស់ព្រាហ្មណ៍ព្រឹទ្ធ បុរោ-
ហិតតវី លើកសពព្រះបិ-តាន្ទូវមាតា ។ ហើយក្សត្រែថ្កល់ថ្កើង បូជា
ព្រះភ្លើង លើកសពសង្ការ បូជារួចស្រេច សម្តេចក្សត្រា រក្សាព្រះស្តេ
រង្គ ជាសុខលន់លង់ ។ មានមួយវេលា ស្តេចទ្រង់តិតថា ឧកូនពីរ
ពង្ស មានតែសរសើក្តី មួយនាក់គ្រប់អង្គ សោតសឹងខ្វៀលង់ គ្មាន
សិល្បសាស្ត្រផង ។ គួរឲ្យស្វែងស្វាក់ ដើរទៅរកអ្នក ច្រាជប្រុះ
កន្ទង ទឹងបានសូមរៀន រៀបសិល្បផង គ្រាន់រក្សាត្រង ពស្តេ
រង្គក្រែងក្រ ។ តិតស្រេចចមចៅ ត្រាស់ទ្រង់ឲ្យហៅ បុត្រែតួចវរ
លីលាខ្លែងដល់ មណ្ឌលកូនរ ថ្នាត់ថ្នាយតាយករ ស្តេចទ្រង់ត្រាស់-
ថា ។ ហៃស្ងួនវិសុទ្ធ ធម្មតាជាបុត្រ នៃក្សត្រែថ្កុំថ្កា លោកតែង
រកៀន រៀនសាស្ត្រា រក្សាតាយជា កើរប្រយោជន៍យូរ ។ ម៉ែ
ភ្លូវនេះ កូនស្ងួនពុំចេះ មានតែត្រឹមធ្ម មួយម្នាក់គ្រប់ខ្លួន ចូរស្ងួន-
តិតគូរ តិតគន់ទៅយូរ ក្រែងមានបើត្រ ។ ចូរទៅសូរសៃង លី-
លាលះលែង ប៉ុរវង្គចរ ចូលទៅតាន់ទ្រត ខ័ណ្ឌនានគរ មួយ-
នោះនាមករ ហៅតក្កសិលា ។ រស្រុកនោះឯង ពីព្រេងមកតែង

ហានអគ្គាចារ្យ ចែងចេះសិល្បសាស្ត្រ ទ្វៀរធ្វាស់អស់អាថ៌ ឈ្មោះ
ហៅទិសា- ចាមេក្ខមែន។ ។ ចូរចៅទៅរៀន អស់ពាំងរបៀន ឲ្យ
ចេះស្ទាត់ក្នែន បើចាចេះចាំ មួនមាំមែនខែន ឲ្យមាសពីរសែន
ដំឡឹងទៅគេ ។ បុត្រពីរវល៌ក្ខណ៌ ទុនបង្គិំដាក់ លើព្រះសិរ ហើយ
ត្រាបប្រណិប័តន៍ លាក្ស័ត្រពាំងទ្វេ វិលវាំងទៅឯ ប្រាង្គប្រាសាទហាន ។
រួសរៀបព្រះអង្គ ចរចុះពីក្នង ផ្លូវជតិមាន កាន់ធួសដ៏យ ប្រពៃ
ថ្កើងថ្កាន បរិវារគ្រប់ប្រាណ សឹងតាមហែទៅ ។ ឥតកិតកយា
ចេញចរលើលា លុះដល់ឋានក្រៅ ស្តេចយាត់បរិវារ បរិពារឲ្យនៅ
ស្តែងស្តេចយាងទៅ តែពីរអង្គា ។ ពស្ត្រភ្នំកចារមើ រូបជសីហ៌
ចេញចាកគូហា ស្មោះឆ្ពោះសំដៅ ទៅតក្កសិលា ចូលព្រៃព្រឹក្សា
សុទ្ធសឹងសក្ខជង ។ បក្សីធ្វើលធ្នាត់ យាសយំស្រងាត់ ស្រង្ងូត-
សៅហ្មង អម្រឹតង្គើត រួតតែលេងលង កៀងគូត្រសង ចូលព្រៃ
ពីងពួន ។ គោត្តគោសឹង្គសីហ៌ ខ្លោងខ្លាក្របី រមាសមាំមួន រមាំង-
ប្រើសតែ ចោលព័ទ្ធពីងពួន ខ្លាចខ្លាលាក់ខ្លួន ខ្លះកេស៊ីស្មៅ ។ តុមារ
ប្រសើរ ធ៌តែផ្លែឈើ ទះទំយាងទៅ ដោយកៀនគន្ធង ដែនដង-
ព្រៃស្រៅ ដរាបលំនៅ តក្កសិលា ។ កេអាចារ្យយល់ ចរចូល-
ទៅដល់ ទុនអគ្គវន្ទា ជម្រាបសួមរៀន របៀនសាស្ត្រា ឯអគ្គអាចារ្យ

ចានយ៉ាងយល់ជាក់ ។ រួចឯងពាលពេញ ចិត្តចាប់ស្រឡាញ់ ពាំង
ពីរស្មោះស្ម័គ្រ ដូចកូនអាត្មា សួរថាហៃអ្នក មាសមាននរល័ក្ខណ៍ មក
ពីឋានណា ។ ជាកូនព្រាហ្មណ៍ព្រឹទ្ធ ឬកូនបុរោហិត អាមាត្យសេនា
ឬចាបុត្រក្សត្រ គ្រងរដ្ឋការ នគរនាមា នោះនាមឈ្មោះអ្វី ។
កុមារពីរពង្ស លុតលើកតំបង់ ជាក់លើសិរសី សារសង់វិនិថ្នាត់ រវើរ-
បូរី នាមករសួស្តី តោសេយ្យនគរ ។ បិតាសោភ័ណ នាមព្រះទេវន្ទ
មហេសីបវរ ប្រសើរវរវង្ស ខ្ញុំសូមទ្រង់នាមករ សុវណ្ណកេសរ ជា-
ព្រះមាតា ។ ក្សត្រៃថ្លុងទូក ច្រោសប្រើឲ្យមក. រកលោកអាចារ្យ
ច្រើណីសូមរៀន រៀបនសាស្ត្រា បរិបូណ៌ប្រយោ វិលវិនិវិញៗ ។
ព្រាហ្មណ៍ស្តាប់អរស្មោះ ឆ្លើយថាបើឮោះ ចូរចៅនិគ្យនៅ អង្គុតញ-
ញនប្រឿន រៀបនពាក់ជ្រៅ តាមចំណង់ចៅ គន់គិតច្រាជ្ញ ។ កុមារ-
ប្រសើរ ប្រណិបត្តន៍បំរើ សព្វពេលវេលា អាចារ្យច្រាប់ប្រឿន រៀបន-
សាស្ត្រា តែមួយមាសា ចេះចាំមែនខែន ។ លង់សិល្បសត្តិសុទ្ធ
សោតសឹងធាប់ធុត ច្រាកដមែនៗ អាចារ្យប្រសិទ្ធ រឹងរិទ្ធិក្លែន ដូន-
មាសពីរសែន ដំឡឹងលាបរ ។ ចូលក្នុងព្រៃជ្រៅ ស្មោះឆ្ពោះសំដៅ
ឫទ្ធានព្រះនគរ លាកលីលាលេង រង្វង់រលីរវែ ក្អេចផ្លូវពានេចរ ជាន់-
ដើមដែលដើរ ។ វែះវិលមកត្រូវ ប្រទះលើផ្លូវ មួយមិញត្រង់លើ ឋាន-

ឥសីសិទ្ធ ទ្រង់ក្រឹត្យប្រសើរ ថ្ងៃនោះលោកដើរ ចរចូលទៅព្រៃ ។
កុមារយធ័យល់ ទីហានមណ្ឌល ព្រះឥសីថ្ងៃ ត្រេកអរបបួល គ្នាចូល-
អាស្រ័យ មួយឈើមួយឫ មុខអស្រមហាន ។

សុរិយាល្ងាចថ្ងៃ ព្រះឥសីសេយ្យ វិលវិធីវិញថ្កាន កុមារយល់
មហា ស័ណាវិញ្ញាណ ចរចូលព្រួញច្រាណ ថ្វាត់ថ្វាយវន្ទា ។ សួរថា
បពិត្រ ព្រះឥសីសិទ្ធិ ទ្រើសទ្រង់សីលា ព្រះអង្គមកគង់ នៅក្នុង-
ព្រឹក្សា ញ៉ាំឯសាន្តសុខា ឥតមានព្យាធិ ។ រមែងស្រាំធ្លុយ សុចក្ខាត
ក្អែបខ្លួយ អស់អម្រិតី ម្រិគាយធំឃ្លង ប៉ុនប៉ងយាយី ព្រះអង្គជាទី
ពុំឲ្យសុខសាន្ត ។ រីសត្វចាំងឡាយ នឹត្យនៅព្រៃគាយ ពិតពុំដែលឃើន មោះមកយាយី ព្រះមុនីវរញ្ញាណ ដោយតេជលោកឃាន ចំ-
រើនការនា ។ មួយសោតផ្លែឈើ សឹងមានគ្រាន់បើ គ្រាន់បរិភោគ្គា
ពុំសូវនឿយព្រួយ ឬមួយលោកតា ស្មែងរកអាហារ ក្រឹក្រពុំងាយ ។
ឥសីស្តែងស្តាប់ អស់អាថិសារសព្ទ ឆ្ងាស់ឆ្ងែយច្រាប់ច្រាយ
ហែរជកុមារ អាត្មានៅគាយ សាន្តសុខសប្បាយ ឥតអស់ពេគ ។
រីអម្រឹតផង សឹងគាចយធ័ឃ្លង ច្រើនក្រៃមហិមា តែពុំដែលមាន
អាចហានពាធា ដោយតេជសម្ភារ គុណព្រះភ្នែក្រៃ ។ ហែរជ
កុមារ រមែលផលា នៅគាយសព្វថ្ងៃ សោតសឹងតែមាន គ្រាន់

ចានអាស្រ័យ ពុំសូវក្រៃក្រៃ គ្រាន់បរិភោក្ត អ្នកចាំដីពីរដើរ អ្នក
មកមានបើ នឹងទៅឋានណា កុមារបង្គំ ថាខ្ញុំយាគ្រា ពីតក្តសិលា
នឹងទៅគោសេយ្យ ។ ឥសីឆ្លើយថា ចៅអើយចិត្តតា នេះអរពេកក្រៃ គន់
គិតពុំហាក់ ជាអ្នកជម្ងៃ ហាក់ដូចវិស័យ ជាសាច់សន្តាន ។ ចៅ-
អើយទឹកឃ្មុំ ផ្លែឈើខ្ញុំ តាសោតសឹងមាន រស់ជាតិពិសា ចៅតា
ក្រែងឃ្លាន ចូរចៅពីក្រោណ ចំអែតអង្គកាយ ។ ទឹកក្នងពិន្ទុ
ដែលយើងទៅដង មកពីស្ទឹងនាយ ចូរចៅទុតម ស្រង់ជម្រះកាយ
ឲ្យបានសប្បាយ បំបង់បរិឡាហ៍ ។

កុមារបង្គំ ខ្លួលថាយើងខ្ញុំ ខ្លួលពុទ្ធដីកា តែប្រគេនវិញ
បំពេញសទ្ធា ព្រះឥសីលា ស្មោះសរមេត្រី ។ សាកសួរវិញថា
ខ្ញោះតើនាមឋា ពាំងពីរឈ្មោះអ្វី អ្នកជាបុត្រក្សត្រៃ ឬមុខមន្ត្រី ព្រាហ្មណ៍
ក្រាដ្សសេដ្ឋី ពាដសេនានាយ ។ ហេតុអ្វីបានជា អ្នកចរយាគ្រា មក
មកដល់ឋានអាយ ឬមានបើចៅ ចូរចៅនិយាយ ដំណើរក្រាប់-
ក្រាយ ដោយខំនឹងត្រង់ ។

បពិត្រីស្រុក សម្តេចដនក ដនទីយើងគង់ ឈ្មោះហៅ
ពិជ័យ គោសេយ្យក្រៃក្រុង ព្រះនាមព្រះអង្គ ខេត្តបវរ ។ ព្រះ
វរមាតា ទ្រង់ព្រះនាមា សុវណ្ណកេសរ ខ្ញុំនាមវិសុទ្ធ សម្តេចក្រសាគរ

អនុជនាមករ សហស្សស្រះកុមារ ។ ស្តេចឲ្យទៅរៀន សិល្បសាស្ត្រវេទ ឯតក្កសិស្ស ស្រេចដូចបំណង លាអង្គអាចារ្យ ចរចេញយាត្រា រង្វើង ក្ងេចផ្លូវ ។ សូមប្រណីណែ ព្រៃត្រាសត្រាប់ប្រៃ ឲ្យបានត្រង់ត្រូវ ឥសីឆ្លើយស្មោះ បើប្លោះឥឡូវ ចូរចៅឈប់នៅ ព្រឹកសឹមចេរបរ ។ កុមារស្តេចឈប់ ផ្ទំនៅមួយយប់ លុះស្វាងទិនករ សោយផលចំណី ស្រេចឥសិលា នានាំមកឈរ ដល់ផ្លូវត្រាប់ថា ។

ចៅអើយទត្តរ នោះមានដុំថ្ម មួយធំសោះសា ជាតិជានតរ បវរសីមា យក្ខមួយនាមា កុជន្ធស្តេចយក្ខ ។ រីថ្មមួយដុំ នោះ-ឈ្មោះហៅកុំ កុជន្ធដឿងជាក់ ពាបប្រៀបពី ជាទីអស់យក្ខ អនេកអនន្តរ អនន្តប្រើនក្តីត ។ ឈើដុះលើកុំ នោះខ្ទៀងឆ្ងំ ស្រោងស្រោងប្រ-កំត ប្រកបផលា កុំបាច្បូលដំត ត្រែងក្រយដាំត នឹងដែយក្សា ។ គោសេយ្យពាជង្ឃាន នោះចំពូសាណ ក្លូវកុំបីបា ក្ងេចផ្លូវបែកបែរ ត្រាសប្រៃទៅណា កុមារសុគតា ចេរចរសំដៅ ។ សុរិយោស្វាចរថ្ងៃ បានដល់ដើមត្រែ មួយធំចូលទៅ សម្រាន្តកាយោ បន្ទោក្តីក្តៅ លំហើយដោយខ្លួន ព្រះពាយផាត់ផាយ ។ ព្រះរៀមអនុជា សេព-សោយផលា ផលផងពាំនឡាយ ធុំសឹងគន្ធរ កេសរខ្ចរខ្ចាយ ព្រ័ស ព្រមព្រះកាយ ប្រកបពលា ពួតែមាត់សគ្ន យាសយំស្រែងាំត់ កុដ្ឋព្រៃ-

ព្រឹក្សា ពីរពេន្ទ្រប្រាស់ប្រាណ សម្រាន្តកាយា ធ្វេសធ្វូលដ៏អ-គ្រាគ្រ-
តុំក្បាក្បាក់ ។


ស្ទេះនេះនឹងនៅ ថ្ងាវថ្ងូនតៅ ស្តេចកុដន្តយក្ខ មហាមហិ-
ទ្ធិវិទ្ធិសេដ្ឋស័ក្តិ អសុរន្ទ្រពជវ៌ក្ស អសុរយក្ស ។ កំនរវ៌ន៍ព័ទ្ធពិត ប្រាំ
ពីរជាន់ជិត ខឺយោពិស្តារ ប្រាសាទប្រសើរ ថ្កើនលើសិលា ម្តំជំ-
ជាតជា បុរីសុខសាន្ត ។ សន្ធ្នតនគរ នោះនាមករ កុដន្តពជហាន
អស់ពាំនរយោធ សេនាពហាន មារមិញមែនមាន លើសលែនពន្ធឹក ។
ក្រៀវក្រាខ្ទេះខ្ទាំន សព្វសិល្បប្បាស់ប្បាំន អាចឥតកាំនក្តឹក ឃ្លាឃ្លៀឃ្លៃ
ឃ្លោមគយឃ្លាំយប់ព្រឹក្ស ប្រុងប្រយ័ត្នសឹក ឥតឯធ្វេធ្វូស ។ រួមក្សត្រមន្ត្រវង្ស
សំបូណ៌សម្បត្តិ សមបុណ្យលែបលេស ប្រាសាទមណ្ឌប អង្គអព្ភុ-
នេស រូបក្នុនីវេសន៍ សម្តែចឥន្ទ្រា ។ សាវឡឹកស្រីស្នំ សុទ្ធសឹង
ស័ក្តិសម សោតសម្ភហុលា បំរើបរិបាល ន៍ចក្កាលសព្វត្រា ស្តេចយក្ខ-
សុខសា - ប្តាយចរិបូណ៌ស្កល់ ។ មានបុត្រីទ្រង់ រូបពន៍រវៃង្ស សក្តិ-
សមសួស្តីសល់ តក្រែផន់ប្រឹមប្រិយ សិរីមែល ស្រីក្នុងមណ្ឌល កុដន្ត-
ភ្នាន់ស្នើ ។ ឈ្មោះអសុរន្ទ្រោ ក្រែងយក្ខស្នេហា បុត្រីប្រសើរ ជន្ម-
ចូលសោឡស ស្រៀបស្រស់ស្តេចប្រើ ឲ្យនន៍ម្ចិតធ្លើ ប្រាសាទឲ្យគង់
ឯកអង្គក្សត្រី មានស្នំសាវស្រី បំរើបំរុង មានពាំនរខ្យាន ក្សែម-

ក្សត្តស្រេះស្រេង ប្រជាប់ឲ្យអគ្គ ព្រះពជធ៌តា ។ ពោះផ្ទឹមសម្បត្តិ សម្បូរពស្ត្រជ្ជ ផ្ទឹមអគ្គីផ្ទឹមអា-ទុកាពពលពន់ កុដន្តពជា មានតែមហា យក្សមួយនីកែយ ។ រជ្ជាជសីមា នៅលើបព្វតា ជាធំស្តិមស្តេ ឈ្មោះកុំសច្ចកន្តែ យក្ខសន្តតនៃ នាមហៅពិជ័យ សច្ចកន្តែ នគរ ។ យក្ខឈ្មោះសច្ចកណ្ឌ មន្ត្រីពលពាន់ ក្រាស់ក្រៃតែវរ នីរ-ណាយពោសទុក្ខ ជាស្តុទ្ធុប្បវ មានបុត្រាចរ-បូណ៌បុណ្យឯកអគ្គ ។ សោឡសត្រប់គ្រាន់ ឲ្យឈ្មោះសច្ចកណ្ឌ តតាមព្រះវង្ស ថ្កើងយស-ថ្កើងសក្តិ ស្តេចយក្ខពីរពង្ស ស្មើពលស្មើអគ្គ ស្មើបុណ្យចារមី ។ ពោះបាំងសឹងស្មើ យកគ្នាជាក្តើ អសុរន្ទ្រែចក្រី ឲ្យអស់សេនា នាំ-សារសេចក្តី ជាពជមេត្រី ទៅមកសព្វថ្ងាំ ។ កេរ្តិ៍កាលបរិសុទ្ធ ពុំ-ពាន់បានបុត្រ មុនមត់ផ្តាច់ផ្តាំ បន្ទូបន្ទោច ពាក្យពេចន៍ឲ្យចាំ ឲ្យជាចំ ណាំ ចំណងស្នេហា ។ បើអញនឹងកាណ ចានបុត្រប្រុសច្រណ យើងនឹងឲ្យវ៉ា យកគ្នាជាក្តើ ថាបើប្រែជា អញមានបុត្រា តាណ-មានបុត្រី ។ យើងឲ្យយកគ្នា ជាគូស្នេហា រក្សាពជ្ឈបូរី យក្ខពីរចាន មត់ សន្តតសំដី លុះពេជបុត្រ៉ កុដន្តធំហើយ ។ រិះរង់ពុំលេច ពុំឮពាក្យ ពេចន៍ ពាក្យពន្ធមកឡើយ សច្ចកំណួយក្សា ចានជាគោះតើយ គិត ថាមិត្រហើយ នឹងមានទៅណា ។ (មានត)

កណ្ដាទី ៣២

ឧកញ៉ាវិបុលភត្តិសេនា ជួ-ភឹង ប្រែរៀបរៀង

(តមក)



ភាំងតែឮគ្រោតគំនឹងឮទ្រុងរត់តែស្រុកសុងយ៉ុងក្នុងទាសនាមឺនមុខមន្ត្រី
មកគំនាប់ដោយឈ្មួញម៉ែតែសម្លាប់ ឮគ្រោតីទៅឆ្ងបសុម៉ាតែកដោ
ឮគ្រោតីបានភាន់ហុកមកវក្សាទុក រហូតដល់ឮគ្រោតីច្បាំងនឹងចោយិន ។

ខ្ញុំតែយល់ឃើញត្រូវកំឆ្លើយថា ដែលឪនគិតនេះគួរណាស់
ទៀវហ៊ុយដំកបថា លោកមានសេចក្តីសង្ស័យហើយកំកុំទៅឡើយ ។
ជូឡុងឆ្លើយថា បើលោកទៅស្រួលល្អជាង ខ្ញុំបានធ្វើលើកតាហាន
៣០០ ទៅជាមួយ ដើម្បីនឹងបានជួយការពារការក្សាលោក មិនឲ្យជាអន្តរ-

ពយ ។ ខ្ញុំតឹងខ្លួលតាមពាក្យដូច្នេះ លុះវេលាព្រឹកឡើង ខ្ញុំតឹងដឹងសេះតេតខ្ញុំ នាំដូច្នេះលើតថាហាន ៣០០. ហៅហាមថៅជាមួយ ដល់ស្រុកសុនយ៉ុន ។ ឯឈ្មួញដ៏ធំថា ខ្ញុំតឹមតក៏ធ្វើជាត្រេតអរពេះពយចេញទៅទទួល ដល់ទ្វារស្រុកហើយនាំចូលទៅ ខ្ញុំតឹ . ខ្ញុំបុន តំគំនាប់ខ្ញុំតឹ ។ ឃើញខ្ញុំតឹ ខ្ញុំបុនទៅទីនោះផង តំអស់សេចក្តីសន្យ ។ ខ្ញុំតឹតំចូលទៅអង្គុយខាងក្នុង ដូច្នេះនឹងថាហាន ៣០០ តំអង្គុយខ្ញុំមជុំវិញខ្ញុំតឹ និយាយដំរាបខ្ញុំតឹថា បិតាខ្ញុំបានឈឺទៀអញ្ជើញលោកមារមកទទួលគំនាប់នាម៉ឺនមន្ត្រី សោះតែថានឹងទទឹងខ្ញុំ-ប៉ៀវជាបិតាអ្នកមិនបាន ។

លុះវេលាព្រឹកឡើង ថៅហ្វាយស្រុកវៃត្រពោធំង ៩ មណ្ឌល ថៅហ្វាយស្រុកវៃត្រត្រី ចក្ស ៤២ មណ្ឌល ដែលជាចំណុះស្រុកតេងដីវ តំមកត្រួមគ្នា ក្នុងទីដំនុំនាម៉ឺនមុខមន្ត្រី ។ ណានោះឈ្មួញដ៏លបប្រឹក្សានឹងតេងអួតថា ខ្ញុំតឹនោះជាមនុស្សអត្រក់អភតញ្ញូ បើនឹង-បង្អង់ទុក ឲ្យនៅក្នុងស្រុកតេងដីវតទៅ អន្តរាយតំនឹងមានដល់យើងទាំងអស់គ្នាជាប្រាកដ ថ្ងៃនេះបានចំណាប់ហើយ យើងត្រូវចាប់ខ្ញុំតឹសំឡាប់ចេញ ស្រុកយើងទើបនឹងរួចផុតពីភ័យអន្តរាយ ។ តេងអួតតបថា មនុស្សទាំងពួងឮសឿថា ខ្ញុំតឹជាមនុស្សសុចរិតពិតត្រង់ណាស់ -

ដែលអ្នកមកគិតនឹងសម្លាប់ចេញនោះ នាម៉ឺនមុខមន្ត្រីនឹងបណ្តាពស្តេ
ចាំនពួននឹងមានគរហានិន្នាដល់អ្នក ។ ឈួម៉ែកូនប្រាប់ថា ការនេះមិនមែន
យើងនឹងរំលងធ្វើឯងនឹងទេ ទ្បៅប៉ៀរលបបង្គាប់ឲ្យយើងធ្វើ នឹងខ្លាចគេនិន្នា
ធ្វើអ្វី ? គេងអួតថា បើទ្បៅប៉ៀរបង្គាប់ឲ្យធ្វើមែនក៏ធ្វើទៅចុះ តែដែលនឹង
ធ្វើការនោះ ត្រូវរិះគិតពាត់ចែងការឲ្យមាំមួនល្អ ឈួម៉ែតបថា ការ-
ចាំងឡាយយើងបានត្រៀមខ្មុកជាស្រេចហើយនៅទីភ្នំឥសានត្រង់ព្រៃទិស
បូពានោះ ខ្ញុំឲ្យឈ្លួហោជាប្អូនលើកទាហានទៅចាំស្កាត់ដែរ ព្រៃខាងទិស
ទក្ខិណ ខ្ញុំក៏ឲ្យឈ្លួហ៊ុនលើកទាហានទៅចាំស្កាត់ទៀត នៅខាងតែខាង
ទិសបស្ចិមនោះ ព្រោះទ្បៅពីយើញមានស្តីនគាន់ខ្លាចាំងមាំណាស់

ទោះបីទ្បៅពីនឹងរះរត់ទៅខាងទិសនោះ ក៏ឆ្ងល់ចិត្តទៅមិនរួច ។ គេង
អួតបថា ដែលអ្នកវៀបដើងការខ្មុកនោះក៏ល្អណាស់ តែខ្ញុំបារម្ភព្រោះ
មានជួទ្បុងទាហានឯកបស់ទ្បៅពីមកជាមួយ ឯជួទ្បុងនោះមានថ្លឹងខ្លាំង
ពូកែណាស់ នៅតែប្រហែងទ្បៅពី មិនទៅណាឆ្ងាយ ត្រែងយើងធ្វើការ
នេះមិនបានរហូតទេដឹង ? ។ ឈួម៉ែតបថា អ្នកកុំព្រួយជាខ្មុកឡើយ យើង
បានកេណ្ឌទាហាន ៥០០ ឲ្យពួនបង្កប់នៅខាងក្រៅ ១ ផង ។ គេងអួតថា
ឲ្យបង្កាប់ប៉ុនផង នឹងអង្គុយឲ្យជានាយកងប្រចាំបំរើទាហាននឹងនាម៉ឺន
មុខមន្ត្រីខាងក្រៅ ហើយឲ្យហៅខ្លួនជួទ្បុងនឹងទាហានទ្បៅពីចេញទៅ

ស៊ីលឿនខាងត្រៃ នៅខាងក្នុងយើងនឹងបានធ្វើការចាប់ខ្លួនឡៅពីបាន យ៉ាងស្រួល ឈ្មួយ៉ាយល់ឃើញ កំបង្គាប់ឲ្យប៊ុនផេងនឹងអង្អុយធ្វើតាម ពាក្យគេអ្នកបង្គាប់ ។

លុះបានពេលពេលហើយ ឈ្មួយ៉ាឲ្យអញ្ជើញឡៅពីចេញទៅទួលនាម្ចាស់មុខមន្ត្រី ។ ចាំឯពួងក៏ធ្វើសេចក្តីគោរពគំនាប់ឡៅពី តាមទម្លាប់ខំនៀម ។ ឡៅពីទួលគំនាប់ហើយក៏ប្រគាសរំលឹកប្រដៅតាមផ្លូវពាដកាវ គឺឲ្យនាម្ចាស់ទ្បាំពាដកាវចាំងឡាយទិតខំយកចិត្តទុកដាក់រក្សាសេចក្តីសុខអាណាប្រជានុកស្រុកនឹងការពាដកាវឲ្យចំរើន តាមបុកណាពាដប្រវៃណីដាលំដាប់តទៅបណ្តាទ្បាំពាដកាវចាំងឡាយគ្រប់ទួលស្តាប់ឱវាទដោយគោរព ហើយក៏នាំគ្នាបរិភោគភោជនាហារ ។ ដូច្នេះក៏កាន់គ្រប់ឈរក្សាឡៅពីពីក្រោយប៊ុនផេងនឹងអង្អុយក៏ចូលទៅនិយាយនឹងដូច្នេះឲ្យចេញទៅបរិភោគអាហារខាងត្រៃជាមួយនឹងពួកទាម្ចាស់តួចនឹងតាហាន ដូច្នេះក៏ធ្វើព្រងើយបែបមិនឮមិនចាន់ចេញទៅ ។ ឡៅពីឮហើយក៏ប្រាប់ដូច្នេះឲ្យចេញទៅបរិភោគនឹងគេចុះ ដូច្នេះមិនអាចទទឹងនឹងឡៅពីក៏ដើរចេញទៅស៊ីលឿនខាងត្រៃ ឈ្មួយ៉ាឃើញបានចំណាប់ស្រួល ក៏ចេញមកនាំតាហាន៩០ ដែលបង្គាប់នោះ លបរាយគ្នាវៀនចូលទៅចាំមើលតស៊ូការ បើឃើញឡៅពីស្រវឹងស្រាវេលាណា ឲ្យនាំគ្នាចាប់សម្លាប់ចេញវេលានោះ ។

ខណៈនោះ អ៊ីដៀជឺនថា ឈ្មួញគិតប្រពុំសព្រាយខ្លៅពី តំធ្វើជាចូលទៅចាត់ស្រាគំនាប់ខ្លៅពី ហើយចោលក្អែកសំឡឹងខ្លៅពីឲ្យដឹងខ្លួន ហើយក្អែងនិយាយនឹងខ្លៅពីថាក្តៅណាស់ សូមឲ្យលោកចូលទៅដោះអាវចេញមួយជាន់ចុះ ខ្លោពីដឹងតស់ស្គាល់តំរិយោតំធ្វើជាគ្រោកចូលទៅខាងក្នុងជាមួយនឹងអ៊ីដៀ ។ រួចប្រាប់ខ្លៅពីថា ឈ្មួញគិតសម្លាប់ឥឡូវហើយ ខាងក្រៅសុទ្ធតែចាហានគាន់អាវុធគ្រប់ដៃស្អាត់គ្រប់ផ្លូវ តិសឯតើតឯដើនឯត្បូង នៅបន្ទោះតែតិសឯលិច បើលោកនឹងរត់ ឲ្យរត់ចេញទៅតិសឯលិចទើបរួច ។

ខ្លៅពីបានស្តាប់ដូច្នោះ តំស្ងួតស្ងួនស្ងោរតែតំយណាស់ តំលបបើកទ្វារចេញទៅតាមផ្លូវខាងក្រោយ ហើយស្រាយយកសេះតេតខ្លៅឡើងជិះបំផាយចេញទៅតែម្នាក់ឯង ដល់ទ្វារស្រុកខាងទិសបស្ចិម នាយទ្វារតំសួរខ្លៅពីថា លោកនឹងទៅណា ? ខ្លៅពីតំមិនឆ្លើយ ទំបរសេះផុតទ្វារចេញទៅក្រៅ ឯនាយទ្វារឃើញអាការបែកដូច្នោះ តំចូលទៅដំណឹងឈ្មួញ ឈ្មួញឮដូច្នោះតំឡើនសេះនាំចាហានស្រួតតាមខ្លៅពីទៅ ខ្លៅពីតស់ទៅចម្ងាយផ្លូវ ប្រហែល ៣០ សិន (១២០០ម) ដល់ស្ទឹងតាន់ខេ ស្ទឹងនោះទំហំទទឹងប្រហែល ១០ ព្យាម (៤០ម) ជម្រៅប្រហែលគ្នា ខ្លៅពីមិនដឹងនឹងតិតធ្វើទៅត្រង់ណាបាន តំញាក់សេះថយមកក្រោយបំណង

នឹងវេតនៃខ្លួនឆ្កួត ខ្ញុំលក្រៃឡតមកក្រោយឃើញវាហានឡើងលើដេញ
ប្រកិតតាមទៀតជាច្រើន ទៀតពីព័ត៌ស្មូតនន្តត់ចិត្តគិតថា គ្រានេះដឹងតែ
យើងនឹងដល់នូវសេចក្តីស្លាប់ហើយ ទៀតពីតំស្រែកយំហើយបរសេះ
លោតចុះទៅក្នុងស្ទឹង ដើងមុខសេះនោះតំជាន់លើខ្នងដូចគេតវណ្តែតល្មើន
ទៅ អាវនឹងទៅដែលស្ទៀតពាក់ក៏ខ្ទិតជាក ទៀតពីតំយកតែសេរ៉ាយសេះ
នោះជាច្រើនរំពាត់ហើយស្រែកថា ថ្ងៃនេះតេកទៀតឯងនឹងចំផ្លាញម្ចាស់
ហើយឬ? ស្មដូតពាក្យសេះនោះ តំលោតតក្រញ្ជោលទៅបានប្រហែល
៦ ឬម ៧ ឬមដល់ខ្ទឹកពក់ ។ ទៀតពីតំបរឡើងបង្គំទៅលើច្រាំងបាន
មានសេចក្តីត្រេកអរជាទីបំផុត ។បមាដូចយល់សប្តិឃើញថាបានឡើង
ទៅឋានសួគ៌ ក្រៃឡតមើលមកក្រោយឃើញឈ្មួញលើតទាហានមកដល់
មាត់ច្រាំងត្រើយម្ខាង ឈ្មួញធ្លីជាស្រែកសួរទៀតពីថា ហេតុម្តេចលោក
មិនតិសាក្រយា តំបរសេះមកនឹងទៅណា?។ ទៀតពីតបថា អញនឹងឯងមិន
មានរឿងអ្វីឲ្យខុសចាស់គ្នាសោះ ហេតុម្តេចបានជាឯងតិតប្រទុសក្រាយ
អញ?។ ឈ្មួញថ្លើយថា ខ្ញុំមិនមែនតិតធ្វើអ្វីលោកទេ ហេតុម្តេចលោកមក
ធ្វើគំនិតស្រាលដូច្នេះ លោកដឿស្តាប់តែពាក្យគេញុះញង់ ហើយឈ្មួញ
តំលើកធ្នូទៀតបាញ់ទៀតពី ទៀតពីយើញដូច្នោះតំនឹកខ្លាច ទើបបំផាយ
សេះរត់ចេញទៅទិសបស្ចឹម ។ ឈ្មួញឃើញទៀតពីរត់ចេញទៅតំមិនបាន

ធ្នូនតាម ថែរមកនិយាយនឹងខ្ញុំដែនថា ដែលខ្ញុំពីរត់ធ្នូនស្នឹងទៅគ្រានេះ ប្រហែលខេត្តាដួយនាំធ្នូនខឹកទៅទៀតហើយ ហើយកំញាក់សេះនាំខ្លួនវិលមកកន្លែងកំពែងស្រុកវិញ ។

ឯដួងឡូនកាលកំពុងបរិភោគអាហារនោះ ឃានឡូនាមឹនមុខមន្ត្រីតាំងតួនតាក់ផ្តើលតឹងតឹងតំរង់ចូលទៅមើល លុះមឹនយើញខ្ញុំពីតឹងស្មុកស្មាះតើត្រឡប់វិលមកវិញ ក្តុមនុស្សតាំងតួនក្នុងខ្លួនទាំងអោះនិយាយគ្នាថា ខ្ញុំពីរត់ទៅតាមផ្លូវទិសខាងលិចទៅហើយ ឈ្លួមឹបានលើកអាហានតាមទៅដួងឡូនតំឡើនសេះនាំខ្លួនហាន ៣០០ ស្រួតតាមទៅ ចេញពួរខាងលិចខ្លួលប្រទះនឹងឈ្លួមត្រឡប់មកដល់តាក់តណ្តាលផ្លូវ ដួងឡូនតឹសួរថា ខ្ញុំពីទៅហ្វាយយើងទៅឯណាបានដួបអ្នក ? ឈ្លួមឹថា ខ្ញុំពីចេញពីស្រុកបាក់ទៅហើយ នឹងទៅឯណាមិនបានដួបទេ ឯដួងឡូនអោះដាមនុស្សចិត្តធ្ងន់ធ្ងរមិនបាននិយាយថាអ្វីសោះ បរសេះស្រួតទៅដល់មាត់ស្នឹងតាន់ទេ មើលទៅមិនយើញមានខ្មែនដែលឈ្មួមនឹងធ្នូនទៅបាន តំញាក់សេះវិលត្រឡប់ទៅហៅឈ្លួមឹឈប់ហើយសួរថា តើដើមខ្ញុំពីប៉ើរឡេញទៅហ្វាយយើងមកខ្លួលតំនាប់នាមឹនមុខមន្ត្រីតាំងតួស ហេតុម្តេចបានដាខ្លួនលើកអាហានដេញទៅហ្វាយយើងដូច្នេះ ? ។ ឈ្លួមឹតបថា បណ្តាទៅហ្វាយស្រុកតូច-ធំ ដែលចូលមកបរិភោគអាហារតំនៅទាំងអស់គ្នា យើង

នាំចាហានមកការពារក្សាសេចក្តីអន្តរាយ បំណងនឹងមិនឲ្យសត្រូវបៀត
បៀនស្រុកតេន៍ជាវ ដូច្នេះថាខ្លួនគិតធ្វើការយ៉ាងម្តេច យើងក៏យល់ថាខ្លួន
ប៉ងនឹងប្រទូស្តកាយឡៅពី លុះយើងសាកសួរ ខ្លួនយកសេចក្តីឯទៀតមក
តែប្តាប្តានឹងលុបលាងឲ្យបាត់ ។ ឈ្លបតបថា យើងដឹងថាឡៅពីគេបាត់
មកពីក្នុងទីប្រជុំជារប្រាកដ បានជាតាមមកវាកខ្លួនតែមិនជួបប្រទះ ដូច្នេះ
ស្តាប់ហើយក៏នៅតែសង្ស័យ ទើបញាក់សេរីលៅដល់មាត់ស្ទឹង ហើយ
ពិចារណាមើលឃើញស្នាមដើងសេះឡើងពីទឹកទៅត្រើយម្ខាងដល់មាត់
ច្រាំងលើ ដូច្នេះក៏តែងតែឆ្ងល់សង្ស័យក្នុងចិត្តថា ស្ទឹងនេះជ្រៅហើយជំ
ណាស់ ឡៅពីនឹងឆ្លងបានឬ? លុះពីគ្រោះមើលខាងត្រើយខាងណោះ
ក៏ឃើញស្នាមដើងសេះជាន់តប់ទៅក្នុងតក់ចុះទៅ រកសំគាល់មិនឮស់
ក៏ញាក់ថយសេះមកវិញនឹងសួរឈ្លបម៉ឲ្យបានសេចក្តី ទទួលឈ្លបបួលទៅ
ក្នុងតំពែងស្រុកបាត់ ហើយក៏ឲ្យចាប់អ្នកចាំទ្វារទិសខាងលិចមកសួរពិចា-
រណាថា ខ្លួនបានឃើញឡៅពីមកតាមទ្វារផ្លូវនេះឬទេ? បើមិនប្រាប់តាម
ត្រង់ទេ អញនឹងឲ្យវាយឲ្យរៀបស្លាប់ នាយទ្វារខ្លាចញ័រអស់ពាំនឹងខ្លួនក៏ប្រាប់
ថា យើញឡៅពីតែចេញមកតាមទ្វារនេះតែម្នាក់ឯង ដូច្នេះបានឮដូច្នោះ
ក៏ឧទានឈ្លបម៉ លុះនឹងក៏បួលទៅតាមនឹងឈ្លបដល់ក្នុងតំពែងស្រុក ក៏ឧទាន
ត្រែង ព្រោះជាខ្លាចផ្លែតចង្អុល ទើបបរសេះនាំចាហានត្រឡប់ទៅស្រុក
ស៊ុនសៀវិញ ។

ឯខ្ញុំពីដំនះសេះរត់ទៅតាមផ្លូវទៀសបស្ងួម មិនបានដឹងផ្លូវមាគ៌ាធំធៅទៅណា ក៏ទឹកភ្នែកមនស្សត្រូចចិត្តថា ខ្លួនអញអើយ បានសេចក្តីលំបាកវេទនាអីម្ល៉ះ តែថាមកទៅមានសេចក្តីសង្ស័យបន្តិច ព្រោះស្ទឹងតាន់ទេ នោះធំហើយជ្រៅ ៩ ព្យាម ឬ ១០ ព្យាម ហេតុម្តេចបានជា សេះនេះលោតឆ្លងតែម្តង ពីត្រើយខាងណោមេកត្រើយខាងណោះបានដល់ទឹកពាក់ប្រហែលមានទេឦាដួយ ទុបត្ថម្ភក៏អញទេដឹង ទើបមិនមានអន្តរាយ លុះបរសេះទៅដល់ដែនស្រុកឡាំចៀង ដួនជាពេលល្ងាច ឃើញក្មេងម្នាក់ជិះក្របី ផ្តុំប៊ីបមកត្រង់មុខ ខ្ញុំពីជកដង្ហើមធំហើយថា យើងនេះប្រកបទៅដោយសេចក្តីទុក្ខលំបាកក្រៃពេក ចំរៀកអីតែក្មេងឃ្វាលក្របីវាសប្បាយជាងយើងទៅទៀត ខ្ញុំពីក៏ឈប់សេះស្តាប់សូរប៊ី ដើម្បីនឹងឲ្យរសាយសេចក្តីទុក្ខវេទនាក្មេងឃ្វាលក្របីក៏ឈប់ផ្តុំប៊ីប្រឡែតម៉ែលរបខ្ញុំពីសព្វគ្រប់ ឃើញខ្ពស់ធំស្ទឹកត្រចៀកយារដល់ស្មា ប្លែកជាងមនុស្សទាំងពួង ក្មេងនោះក៏សួរថា លោកនេះឈ្មោះខ្ញុំពីឬ ? ដែលបានដួយក្រាបក្រាមពួកចោរដួតក្បាលលឿងគ្រាខៀវកុក ។

ខ្ញុំពីឮដូច្នោះក៏មានសេចក្តីសង្ស័យ ទើបសួរថា ខ្លួនឯងក្មេងប៉ុណ្ណោះហេតុម្តេច ក៏ដឹងស្គាល់ខ្លួនយើងថាដួយក្រាបក្រាមពួកចោរដួតក្បាលលឿងគ្រាខៀវកុកនោះ ? ក្មេងនោះក៏ឆ្លើយថា អាយុខ្ញុំបាទនៅក្មេងមែន

មិនបានស្គាល់លោកទេ តែថាគ្រូប្រដៅឲ្យរៀនសំបុត្រមាននៅម្នាក់ ឯពួកម៉ាកគ្រូខ្ញុំបាទនោះមានច្រើន កាលណានឹងមកលេងនឹងគ្រូខ្ញុំបាទ រមែងដំណាលសរសើរដល់ឈ្មោះខ្លៅពីថា ប្រកបទៅដោយលក្ខណៈដ៏ល្អ ថាខ្លៅពីនោះខ្ពស់ប្រហែល ៦ ហត្ថ ត្រចៀកធំយារដល់ស្មា ដៃវែងដល់ក្បាលជង្គង់ ក្អែកក្រឡែកទាំងយើញស្មើកត្រចៀកខ្លួនឯង ហើយទំនាយថាមានសតិបញ្ញា តទៅមុខថានឹងមានបុណ្យ ឥឡូវខ្ញុំបាទមកយើញលោក លោកឡើពីមែនឬ ? ។ ខ្លៅពីក៏សួរក្មេងនោះវិញថា អាចារ្យរបស់នាងឯង ដែលចេញឈ្មោះយើងនោះឈ្មោះអ្វី ? ។ ក្មេងនោះឆ្លើយថា គ្រូខ្ញុំបាទឈ្មោះសុមាតេតនោ ។ ខ្លៅពីសួរថា កើនរបស់គ្រូនាងឯងឈ្មោះអ្វីខ្លះ ? ។ ក្មេងនោះឆ្លើយថា កើនគ្រូខ្ញុំបាទ ២ នាក់ ម្នាក់ឈ្មោះចាំងតេតកុង អាយុចាស់ជាងគ្រូខ្ញុំបាទ ១០ ឆ្នាំ ម្នាក់ទៀតឈ្មោះថាហាចាំងថង់ ក្មេងជាងគ្រូខ្ញុំបាទ ៥ ឆ្នាំ មានសតិបញ្ញាវង្វៃណាស់ សុមាតេតនោស្រឡាញ់ណាស់ហៅថាប្អូន មានឹងក្មួយចាំងពីនាក់នេះនៅស្រុកសុងយ៉ុងជាប់ទៅមកពាប់អានគ្នា និយាយសរសើរពីខ្លៅពីជារឿយ ។ ។

ខ្លៅពីបានឮដូច្នោះក៏សួរថា ឥឡូវអាចារ្យនាងឯងនៅឯណា ? ។ ក្មេងនោះបន្ទូលប្រាប់ថា អាចារ្យខ្ញុំបាទនៅត្រង់នោះ មើលទៅយើញព្រៃឈើចង្កឹះ ផ្លូវពីនេះទៅប្រហែល ៤០ សិន (៨០០ម) ។ ខ្លៅពីថា ខ្ញុន

យើងឈ្មោះឡៅតីមែនហើយ ទំនងជាបានឃើញអាចារ្យនោះ នាងឯង
ប្រហែលយើងទៅសន្ទនាទំនងគ្រូនោះបន្តិចបានឬទេ ? ។ ក្មេងនោះតំនាំឡៅតី
ទៅ លុះទៅដល់ទ្វារផ្ទះសុមាតេតធោនោះ តំបានឮសំឡេងពិណដែល
សុមាតេតធោដេញពីរោះណាស់ ។ ឡៅតីតំនិយាយហាមក្មេង
នោះថា កុំគាលនាំសេចក្តីទៅដំរាបឲ្យអាចារ្យដឹងសិនបុះ ឲ្យអាចារ្យ
ដេញពិណស្តាប់ឲ្យសប្បាយចិត្តសិន រួចសឹមចូលទៅ ឡៅតីតំឈប់ស្តាប់
មួយស្របក់ ។

ឯសុមាតេតធោ លុះដេញពិណហើយតំក្រោកដើរចេញមកត្រៅទើបថា
ពេលថ្ងៃនេះ យើងដេញពិណក្បោះក្បាយដោយខ្វៃពិណស្រួលបួលប្រ
ហែលមានមនុស្សមានសតិបញ្ញា មកលបលួចស្តាប់ទេដឹង ? ។ ក្មេងឃ្លាល
ក្រែបីឃើញសុមាតេតធោដើរចេញមក តំប្រាប់ឡៅតីថា នេះហើយគឺសុមា
តេតធោជាអាចារ្យរបស់ខ្ញុំចុង ។ ឡៅតីឃើញសុមាតេតធោប្រកបទៅ
ដោយរូបភាពស្អាតបាតល្អ ត្រមាំងតិរោមារយោទល្អន់ល្អាសសមមម្យគួរ
ជាអាចារ្យ តំមានសេចក្តីគ្រេកអរណាស់ តំនុនគំនាប់តាមប្រវៃណី ឯសុ-
មាតេតធោក្រែឡេកឃើញឡៅតីគំនាប់ តំពិគ្រោះមើលឃើញអាវនឹងខោ
ទឹកដោកតំសួរថា អ្នកនេះមានបុណ្យវាសនាច្រើនណាស់ តំយមកដល់
ខ្លួនហើយតំរត់យកខ្លួនរួចបាន ។ ឡៅតីបានស្តាប់ដូច្នោះ តំប្លែកក្នុងចិត

ទើបគិតថា ហេតុដូចម្តេចបានជាសុមាតេកធោដ៏ធំហេតុផលដូច្នេះ ។

ខណៈនោះ ក្មេងឃ្វាលក្របីក៏ដាក់បសុមាតេកធោថា រូបនេះគឺឈ្មោះ ខ្ញុំពី ឲ្យខ្ញុំបាននាំខ្លួនមកជួបនឹងលោកសូមគំនាប់ស្គាល់ ។ សុមាតេក ធោឮដូច្នោះក៏អញ្ជើញឡើពីឲ្យឡើងទៅលើផ្ទះបួលទៅទានលែងក្នុងរៀប ចំទីឲ្យអង្គុយហើយក៏សួរថា ខ្លួនអ្នកនេះមកពីណា ? ។ ឡើពីដាក់បថា ខ្ញុំ បាទដើរមកលេង ឃើញក្តូមិហានរបស់លោកសប្បាយយក៏ឆ្មើងចូលមក គំនាប់ ជាបុណ្យកំពរបស់ខ្ញុំបាទ បានមកជួបនឹងលោកក្នុងថ្ងៃនេះ ខ្ញុំបាន មានសេចក្តីត្រេកអរជាខ្លាំងបំផុត ។ សុមាតេកធោឮដូច្នោះក៏និយាយថា អ្នក កុំបាច់តូចយើងធ្វើអ្វី យើងជាមនុស្សហើយ ត្រានេះគឺអ្នកតត់ក៏យមកជា ប្រាកដ ។ ឡើពីបានស្តាប់ហើយ ក៏អធិប្បាយយ៉ាយប់រឿងរ៉ាវប្រាប់សុមា- តេកធោតាមដំណើរត្រង់ឲ្យស្តាប់គ្រប់ប្រការ ។ សុមាតេកធោនិយាយថា ខ្ញុំបានឮគេនិយាយល្បីល្បាញមកតាំងពីដើមថា ខ្លួនអ្នកមានដម្រិះប្រាជ្ញា ឆ្លាតនឹងគំនិតវែងឆ្ងាយ ឆ្លាតវែងណាស់ ឆ្លាតវែងណាប្រៀបស្មើក៏ពុំបាន ហេតុម្តេចក៏បានជា តាំងខ្លួនមិនជាប់ ។ ឡើពីថា ខ្លួនខ្ញុំបាទសព្វថ្ងៃនេះវាសនាតិចណាស់ ពាំនឹង ជតាពាសីក៏អន់អំបុអកត្តូពន់ពេក ទើបមានតែសេចក្តីព្រួយលំបាក មិន ស្រាកស្រាន្តសោះ ។ សុមាតេកធោថា ដែលអ្នកថាបុណ្យវាសនា តិចបញ្ជាមកឆ្ងើជាខ្លាំងមិនបាន ។

(មានត)

លោកវ៉ាយ-ប៊ុក ជាកវីស្រង់ហើយ រៀបរៀង

១- កុំឲ្យអាក់ខានធ្វើសេចក្តីល្អចំពោះបុគ្គលម្នាក់ ។ អ្នកណាមិនព្រមធ្វើសេចក្តីល្អ អ្នកនោះច្រើនជួបប្រទះនឹងសេចក្តីទុក្ខលំបាកគ្រប់យ៉ាង ។

២- អ្នកណាដែលធ្វើសេចក្តីល្អ, អ្នកនោះនឹងបានរង្វាន់ក្នុងថ្ងៃណាមួយមិនខាន ។

៣- អកតញ្ញូតាធម៌ជាធម៌ដែលត្រូវចៀសវាងឲ្យឆ្ងាយ កុំឲ្យជិត ។

៤- កាលណាសច្ចធម៌ចូលមកដល់ សកាពកុហកកក្លែតំរែតំរង់ចេញទៅ ព្រោះថា សកាពកុហកកក្លែតជាស្រមោលនៃសច្ចធម៌ ។

៥- វត្តុដែលមកដល់ ច្រើនមានសកាពលាមកជាងវត្តុដែលចេញទៅ ។

៦- ក្រោយដែលបានក្រែបនូវសេជាតិសប្បាយ ត្រែកត្រែអាលក្នុងអាមិស គ្មានសល់អ្វីឡើយ នៅសល់តែការសន្ទនាទៅវិញទៅមក រវាងមនុស្សស្រីប្រុស ដែលអង្គុយសេពសុភជាមួយគ្នា ។

៧- បើគ្មានកំឡាំងល្មមរក្សាសេចក្តីស្អាតកំចាំងបានទេ ស្ងាប់ទៅជាការប្រសើរ ។

๘- កោតក្រែងធ្វើឲ្យចម្រើនដល់សេដ្ឋី តែធ្វើឲ្យមានទុក្ខលំបាកគ្រប់យ៉ាង ដល់អ្នកជ្រមុជទៅក្នុងសេចក្តីស្នេហា ។

๙- មាយាប្រុសច្រើនជាងមាយាស្រី ។

๑๐- សេចក្តីស្លាប់ស្រួលងាយខ្លួល ជាងសេចក្តីខ្មាសគេ ។

๑๑- សត្វទាំងអស់ត្រូវក្រែបន្ទូវទុជាវេនសេចក្តីស្លាប់ ។

๑๒- ការប្រព្រឹត្តិប្រតិបត្តិតាមមាយាស្រី នាំឲ្យបុរសមានគាតព្វកិច្ចជួនបំផុត ។

๑๓- ស៊ូនៅ តម្លាក់ឯង កុំឲ្យតែនៅរួមជាមួយនឹងអ្នកកាចសាហាវ ។

๑๔- ធ្វើសេចក្តីល្អចំពោះអ្នកដែលធ្វើសេចក្តីអាក្រក់នឹងអ្នកឯង ។

๑๕- ចូរឯងដឿចំពោះតែវត្តុដែលឯងឃើញ ដោយមំសចក្ខុ ចូរឯងកុំសោកស្តាយចំពោះរឿងក៏ដោយ ដែលមានពីអតីតកាល ។

๑๖- ក្រោយដែលខ្ញុំកើតបានន្ទូវត្តុនីមួយ ។ ខ្ញុំមិនកើតស្មាមគំនួសនៃវត្តុនោះទេ ។

๑๗- បើខ្ញុំធ្វើឲ្យចៃដន្យចិត្តមួន ។ តាមកាល ហេតុដូចម្តេច កំខ្ញុំមិនយកប្រាជ្ញាមកគិតគូរពិចារណាសិក្សា ក្នុងពេលដែលខ្លួនខ្ញុំរស់នៅ ។

๑๘- ឯងមិនដឹងទេថា អ្នកណាដឹកអន្ទង អ្នកនោះមុខជាភ្ជាក់ក្នុងអន្ទងថ្ងៃណាមួយមិនខាន ។

១៩- ចិត្តមានសភាពរហ័សជាដើរវៀងទៀត ។

២០- ការដែកគ្នាទៅវិញទៅមក មានរឿងរ៉ាវបែកមែកជាដើរ ច្រើនប្រការ ។

២១- បើសុភមង្គលចូលមកស្ថិតនៅលើបុគ្គលណា ទ្រព្យសម្បត្តិនឹងចូលមកក្នុងបុគ្គលនោះមិនខាន ។

២២- បើអ្នកណាចោះបង់ចោលបេះបេរបស់ខ្លួន ជោគវាសនានឹងរត់ចោលអ្នកនោះមិនខាន ។

២៣- នំប៉័ងដែលនឹងមានទ្រង់ទ្រាយមូលល្អ ហើយត្រូវគេយកមកជូនបរិភោគ បានចំពោះតែអ្នកណា ដែលបានព្យាយាមប្រឹងប្រែងធ្វើការងារគ្រប់ចំពូក ។

២៤- ត្រូវតែចៅហ្វាយនាយមានចិត្តសប្បុរសនឹងភាសាសីរបស់ខ្លួន ត្រូវតែឲ្យរង្វាន់ចែកចាយមួយពេលមួយខណៈ ប្រាក់ខែបើកឲ្យបានគ្រប់គ្រាន់ តែបើភាសាសីនោះមានកោតទ្រព្យអ្វី ចៅហ្វាយនាយមិនត្រូវចង់បានទេ ។

២៥- បើតំណក់ពេលវេលាដល់ហើយ គ្មានអ្នកណាបន្ថយតំណក់ឬពន្យារកាលតំណក់ ទៅថ្ងៃមុខបានឡើយ ។

២៦- ដំរីតូចអស់ បើទុកថាស្ថិតនៅយូរយ៉ាងណាក៏ដោយ ក៏ត្រូវ

តែទៅដល់កំណត់ពេលវេលា ដែលដំរីតនោះត្រូវលត់រលាយជាមិនខាន ។

២៧- មិនដែលមានអ្នកនិពន្ធណាសរសៃរៀបរៀងដែលទេ, តែស្នាដៃសរសេរ ស្នាមគំនូសសរសេរនោះ នឹងស្ថិតនៅជាអនន្តកាល ។

២៨- គ្មានអ្នកពោលពាក្យមួយម៉ាត់ ដោយគ្មានអ្នកស្តាប់ទេ តែមានអ្នកស្តាប់ដែរតាំងស្តាប់ ។

២៩- កុំឲ្យសែ្វងរកនូវតែដែលឯងមិនស្គាល់, គេនឹងសួរឯងចំពោះតែតែដែលឯងឮដោយត្រចៀក ឃើញដោយភ្នែក ដឹងដោយចិត្តប៉ុណ្ណោះ ។

៣០- សម្បត្តិទ្រព្យនឹងកូនជារតនៈនៃដីវាគាត្មកនេះ ។

៣១- បើអ្នកណាទិញសេចក្តីខុសគាន់ច្រឡំ ដើម្បីដឹកនាំខ្លួនឯង, ដំរីតម្នាក់នោះមិនមានប្រយោជន៍ទេ, ហើយគេខុកអ្នកនោះថា គ្មានអ្នកណាដឹកនាំទេ ។

៣២- អ្នកឆ្កួត, ខ្វាក់, ខ្លួនអ្នកមិនអាចរកទ្រព្យសម្បត្តិបានឡើយ, បើខុកជាសំដែងសេចក្តីសោកស្តាយ ក៏ជាការឥតប្រយោជន៍ ។

៣៣- ផ្នែកបន្ទាមួយភ្នែក អាចធ្វើឲ្យបុគ្គលមើលមិនឃើញ: ដល់ផ្នែកបន្ទានោះភ្ជាប់ពីមុខខ្លួន, បុគ្គលនោះត្រាច់ទៅកាន់ទីដ៏ខៃតាមពន្លឺនោះបាន បើកាលណាដល់ពេលដ៏តុំវិញខ្លួន បុគ្គលនោះក៏ឈប់ដើរ ។

(មានត)

រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន

លោក រ៉ាយ - ប៊ុក ប្រែរៀបរៀង

(តមក)

អ៊ុំសៀម៉ាគ្រូនិងព្រះនាងទ្រង់ក៏កាន់ព្រះហស្តគ្នាចូលទៅក្នុងព្រះបន្ទប់ ដែលមានជញ្ជាំងធ្វើពីប្រាក់ មានតុទូមានពណ៌ភ្លឺច្រកាត់ ។ គឺនៅទីនោះឯង ដែលព្រះអគ្គមហាសេត្រី នឹងអ៊ុំសៀម៉ាគ្រូបាននាំគ្នានៅជាសុខសប្បាយជានិរន្តរ៍តរៀងទៅ ។

នៅព្រះបរមកដរាំងនៃព្រះអាទិទេពមហាសាគរ អ៊ុំសៀម៉ាគ្រូបានត្រែបន្ទូរសុកមង្គលដ៏ប្រសើរថ្លៃថ្លាពន់ពេក ។ សុកមង្គលនោះមិនមែនមានសភាពឥតកតរល្អក់នោះទេ ការព្រួយចិត្តនឹងការដកដង្ហើមធំស្ពាយគ្រោយលាយឡំជាមួយផង ។

អ៊ុំសៀម៉ាគ្រូក៏ពោលចំពោះខ្លួន ដោយខ្លួនឯងថា :

« ប្រហែលជាបិតាមាតាអញព្រួយចិត្តយ៉ាងណាទៅ ដោយលោកមិនដឹងជាក់ច្បាស់ថា កូនសំឡាញ់របស់លោកទៅទីណា ? បើបិតាមាតាអញដឹងថា ជីវភាពរបស់អញនៅទីនេះ សុខស្រួលជាអនេកប្បការ លោកសប្បាយចិត្តពន់ពេក ។ សេចក្តីសប្បាយដែលគ្មានក្នុងពេលនេះ

គឺការគិតថា បិតាមាតាអញមិនបានចូលមករួបរួមសប្បាយជាមួយនឹងអញ ប៉ុណ្ណោះ . . . ។ តើពេលវេលាដែលអញនឹងស្ថិតនៅក្នុងព្រះបរមពុទ្ធរាជនៃព្រះអាទិទេពមហាសាគរប៉ុន្មានទៅ ? ប្រហែលជា ២ ឆ្នាំ ៣ ឆ្នាំ នៅទីនេះ គ្មានវេជ្ជវិវេឆនៈទេ ជាការងាយនឹងបួតលេខមើល ។ រវាង ២ ឬ ៣ ឆ្នាំ ដែលស្ថិតនៅដោយថប់ព្រួយចាម្តេ ជារវាងដែលយូរពន់ពេក . . . អញនឹងមិនអាចរង់ទុក្ខទាំងនេះបានឡើយ អញនឹងទៅសូមព្រះទេពីអញឲ្យព្រះនាងអនុញ្ញាតឲ្យអញវិលត្រឡប់ទៅគាន់បិតាមាតាបាន ៤-៥ ថ្ងៃសិន ។ ដល់អញជូនពិតមានបិតាមាតាជ្រោបសព្វគ្រប់ សឹមអញវិលត្រឡប់មកគាន់ទីនេះវិញ ។

អ៊ុំសៀមាភ្លៃ កំពុងទៅថ្វាយបង្គំណាងរបស់ខ្លួនឲ្យទេពីជ្រោប ។ ព្រះនាងទ្រង់ទើបនឹងស្គាល់ទុក្ខជាបឋម ។ ដោយទ្រង់ឃ្លាតពីព្រះស្វាមី ព្រះនាងក៏ទ្រង់ព្រះកន្សែង ព្រះកន្ត្រៃជោកជាំដោយទឹកនេត្រា ។

អ៊ុំសៀមាភ្លៃ រកទុយដើម្បីបំបាត់នូវសេចក្តីព្រួយចិត្តរបស់នាង ហើយមានបន្ទូលទៅគាន់ព្រះនាងថា : បងសូមសន្យាថា នឹងវិលត្រឡប់មករកប្អូនវិញដោយរហ័សធាប់មិនហ៊ានខាន . . . ។ កាលបើយើញជាក់ស្តែងថា យើងសប្បាយពន់ពេកនៅទីនេះ ម្តេចក៏បងមិនប្រញាប់ប្រញាល់មកគាន់ទីនេះ ដែលប្រកបដោយសុភមង្គលប្រសើរជ្រុះ ។

អាសាន ព្រះនាងទ្រង់មានបន្ទូលថា " ខ្ញុំមិនអាចយាត់ព្រះបង្គំរួចព្រោះជាការណីយកិច្ចរបស់ព្រះបង្គំខានមិនបាន . . . ។ តែខ្ញុំត្រូវបំផុត ខ្ញុំត្រូវណាស់ ខ្ញុំត្រូវតែយើងលែងបានជួបគ្នាហើយ ។ តែមានមធ្យោបាយមួយយ៉ាង ដែលអាចធ្វើកុំឲ្យយើងឃ្លាតគ្នាយូរពេក ។ ខ្ញុំនឹងជូនព្រះបង្គំនូវគេនវត្ថុមួយ ដែលនឹងអាចជួយឲ្យព្រះបង្គំរំលែកត្រឡប់មកកាន់ខ្ញុំវិញ កាលណាព្រះបង្គំមានចិត្តចំណង់មាំមួន " ។

ព្រះនាងទ្រង់បានថ្វាយទៅព្រះស្វាមីនូវប្រអប់លាបអាចម៍ល័ក្ខដែលមានខ្សែក្រមួយចង្អឹតជាប់ (គេបានដំណាលថានៅព្រះវិហារគណៈគឺ ព្រះសង្ឃបានរក្សាទុកនូវប្រអប់ នឹងជូនសន្ទូចរបស់អ៊ុរសៀម៉ាគារ៉ូ) ។

ព្រះនាងទ្រង់មានបន្ទូលទៅកាន់ព្រះស្វាមីថា សូមព្រះបង្គំស្តេចយកប្រអប់នេះទៅចុះ ទ្រង់កុំធ្វើឲ្យបាត់ ។ ហាមកុំឲ្យទ្រង់បើកប្រអប់នេះរំសោះឡើយ បើទុកជាមានបំណងខ្លាំងក្លាយ៉ាងណា ក៏កុំបើកឲ្យសោះ ។ បើទ្រង់បើកប្រអប់នេះ ទ្រង់នឹងមិនអាចរំលែកត្រឡប់មកកាន់ពីនេះបានឡើយ ទ្រង់លែងឃើញមុខខ្ញុំម្ចាស់ហើយ ។

ព្រះនាងទ្រង់ស្រក់ទឹកនេត្រា យកព្រះកូសាដូត ។

អ៊ុរសៀម៉ាគារ៉ូទ្រង់តបទៅព្រះនាងវិញថា : កុំបួងព្រួយនឹងបង្គំអ្វី បង្គំសូមប្រកាសជាទីឡាវភៃថា បង្គំមិនបានស្រាយខ្សែក្រដែលបង្គំប្រអប់នេះ

ហ៊ានទិញសំលៀកបំពាក់ជាដើមឲ្យសមរម្យទេ ឈ្មោះថា កំណាញ់ស្រាកម្រា ជាហេតុឲ្យអាប់កេរ្តិ៍ឈ្មោះ នាំឲ្យគេមើលងាយ ។ ពាក្យណែនាំដូចរឿងមៅស្ងួតក្នុងសៀវភៅធម្មក្រិត្យស្រាប់ ។

១២- រក្សាខ្លួនឲ្យរុងរឿង - រឿងទុត្តុង្គទុត្តមខ្ញុស់ ប្រដាប់ដោយសំត្តិយស ខ្លួនជាធំឲ្យបៃផ្លួន ។

អធិប្បាយ- ធម្មតាមនុស្ស ត្រូវតែរក្សាខ្លួន រៀបចំខ្លួន ធ្វើខ្លួនឲ្យខ្ពង់ខ្ពស់, ឲ្យថ្លៃថ្នូរ គឺត្រូវឲ្យមានសណ្តាប់ធ្នាប់ រៀបចូកពាក់ឲ្យសមរម្យ ស្លៀកពាក់ឲ្យស្អាត កាលបើបានឡើងស័ក្តិយសជាធំ ជាមេបាគេហើយ ត្រូវមើលថែរក្សាខ្លួនអ្នកនៅក្រោមបង្គាប់ ឲ្យបានសុខស្រួល មិនសង្កត់សង្កិនអ្នកគួប ដោយលំអៀងតាមអគតិធម៌នោះឡើយ ។

១៣- ឱ្យទាំងៗ[1] ស្មោះ កុំអាឡោះអាល័យស្ងួនទ្រព្យនេះធឹងនាំខ្លួន ទៅបរលោកពុំសោះស្ងួន ។

អធិប្បាយ- កាលបើឲ្យទានគឺឲ្យទ្រព្យរបស់អ្វី ។ ពោះបីតិចក្តីច្រើនក្តី ថោកក្តី ថ្លៃក្តី ដល់ស្ងួមយាយចក, អ្នកកំសត់ទុគ៌ត ឬឲ្យដល់សមណ-ព្រាហ្មណ៍ ត្រូវឲ្យដោយចិត្តស្មោះចំពោះ ទើបបានបុណ្យបានកុសល-ច្រើន កុំឲ្យទានទៅហើយ មានសេចក្តីអាឡោះអាល័យ, ស្តាយដោយ

១- សាស្ត្រាខ្លះថា ឲ្យទានតាំងចិត្តស្មោះ . . . ។

បង់យកមកវិញនោះ មិនប្រសើរទេ ទ្រព្យដែលបានបរិច្ចាគទៅហើយនោះ ទុកជាសេរ្ចាំង ទុកជាយានដំនិះដឹកនាំខ្លួនយើងទៅបរលោក មិនមែនឲ្យទានទៅហើយសោះសូន្យ គ្មានផលនោះទេ ។ ការឲ្យទានពិតជាមានផលានិសង្សច្រើនទៅក្នុងបរលោក ។

១៤- ទ្រព្យធនទោះបៅកប្លែ កុំដាក់ដៃឲ្យតែក្លួន
ស្លូវអស់ទាំងបងប្អូន អ្នកដទៃរក្សាបាង ។

អធិប្បាយ- ទ្រព្យសម្បត្តិ ទោះថាកក្តី ប្លែក្តី ត្រូវត្រួតត្រាមើលដោយខ្លួនឯងផង មិនត្រូវទុកចិត្តស្រេចលើកូនចៅ ឬញាតិសន្តានណាមួយ ឲ្យថែរក្សាយកជាការអស់ហើយនោះទេ, ធម្មតា កូនចៅ ឬញាតិសន្តានមើលមិនសព្វគ្រប់ទេ ឬដួនកាល មានបន្ទុំបំបាត់យកស៊ីចាយខ្លះមិនខាន ។

១៥- ទុកបិត្តុំឲ្យ[1] ដាក់ ស្មើភ្នែកខ្វាក់ទាំងសងខាង
ឲ្យក្លួនគង់មើលតាង ស្មើភ្នែកម្ខាងពុំពេញពីរ ។

អធិប្បាយ- យើងមានទ្រព្យសម្បត្តិច្រើន ហើយប្រគល់ទុកជាក់ ឲ្យកម្មករមើលថែទាំដំនួសទាំងស្រុង មុខជាមិនគត់មត់ទេ ធម្មតាកម្មករមើលមិនយ៉ាងសព្វទេ លោកប្រៀបថាដូចភ្នែកខ្វាក់ទាំងពីរ, ធម្មតា

១- សាស្ត្រខ្លះថា ទុកចិត្តុំមើលដាក់ . . . ។

មនុស្សខ្វាក់ភ្នែកសង្ឃាង មើលអ្វីមិនឃើញទេ គ្រាន់តែស្មាន ។ ព្រោះ
មិនប្រាកដជាក់លាក់ទេ ឲ្យកម្មករមើលជួសក៏ជួញដែរ ។ បើប្រគល់
ឲ្យកូនមើលថែរក្សាគ្រាន់បើជាងកម្មករបន្តិច លោកប្រៀបដូចមនុស្សខ្វាក់
ភ្នែកតែមួយ នៅភ្នែកមួយគ្រាន់នឹងមើលបានខ្លះដែរ តែពុំស្មើនឹងភ្នែកពីរទេ
ជម្មតា កូនតែងដឹងបាតគន់ខ្លះ តែមិនដល់នឹងខ្លួនឯងដែរ ។

១៦- ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយបង្កើតកេរ
សំអាតអស់សរិល កុំឲ្យមានក្តីនិន្ទា ។

អធិប្បាយ_ ទោះបីធ្វើកិច្ចការអ្វីផងទាំងពួង ដូចជាធ្វើផ្ទះក្តី តុ:ខ្ពក្តី
គ្រាញស្អី ចង្អេរជាដើមក្តី ត្រូវតែធ្វើឲ្យហើយ ត្រូវធ្វើឲ្យម៉ត់ចត់ កុំធ្វើ
ការងារអ្វី បណ្តាក់ពេលថា ចាំថ្ងៃក្រោយ, ខែក្រោយ, ឆ្នាំក្រោយសឹម
បន្តើយ ត្រូវធ្វើឲ្យពាល់តែហើយស្រេច ត្រូវសំអាតផ្ទៃតផ្ទង់ការនោះ កុំ
ធ្វើខ្ជិលឲ្យតែរួចពីដៃ កុំឲ្យមានកេរអាក្រក់ទៅថ្ងៃក្រោយ កុំឲ្យអ្នកផងគេ
តិះដៀលថា អ្នកនេះធ្វើការប៉ុណ្ណឹងមិនឲ្យហើយ ធ្វើការនេះខ្ជិលណាស់
ដូច្នេះជាដើម ។

១៧- ជំណោកដេកជាខ្នាត ឲ្យសំអាតសំអាងជា
ទើបទេព្តារក្សា បំរើនសុខស្រីសួស្តី ។

(មានត)

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

ប្រវត្តិវត្តព្រះវិហារស្ងួរ

ស្រុកទ្រាំងកណ្តាល

ខេត្តកណ្តាល

លោក ចាប-ពិន រៀបរៀង

វត្តព្រះវិហារស្ងួរ ជាបូជនីយដ្ឋានដ៏សក្តិសិទ្ធិ ១ ក្នុងចំណោមវត្តនាមស្ទើរតែពេញប្រទេសកម្ពុជា តាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្នកាលនេះ អ្នកផងសឹងបានជ្រាបជាច្រើន ។ ក្នុង ១ ឆ្នាំ ។ តែងមានមហាជនពាក់ព័ន្ធនាក់ទៅបូជាបៃតន់ផ្សេង ។ សូម្បីព្រះពជា ព្រះពជវង្សានុវង្ស នាហ្នឹនសព្វមុខមន្ត្រីក៏តែងទ្រង់ស្តេចយាង, អញ្ជើញទៅបូជាបួងសួងដែរ ។

មុននឹងបរិយាយ ពីប្រវត្តិនៃវត្តព្រះវិហារស្ងួរនោះ សូមបញ្ជាក់នូវសព្ទថា ព្រះវិហារស្ងួរ ឲ្យជាក់ច្បាស់សិន ។

ពាក្យថា ព្រះវិហារស្ងួរ បែកជា ២ បទ គឺ ព្រះវិហារ ១ បទ ស្ងួរ ១ បទ ។ ក៏ពាក្យថា ព្រះវិហារ មិនចាប់អធិប្បាយទេ ព្រោះជាពាក្យងាយដែលអ្នកផងគ្នាបាប់ជ្រាបហើយ ថា ព្រះវិហារ គឺវត្តជាទីគង់នៅរបស់ព្រះសង្ឃ ឧទ្ទិសព្រះពុទ្ធរូប ។ សូមអធិប្បាយតែពាក្យ ថា ស្ងួរ ១

បទ ព្រោះពាក្យនេះជាពាក្យអាថិតំបាំងបន្តិច ។

ពាក្យថា សួរ មាន ៣ បែប :

បែបទី ១ ពាក្យថា សួរ គ្មានអក្សរអ្វីប្រកបមុខទេ ជាកិរិយាស័ព្ទ
តាសាខ្មែរ ដូចសួរស្តាន សួរសួ សួរព្រឹត្រ ។ ល ។

បែបទី ២ ពាក្យថា សួរ មានអក្សរ រ ប្រកបមុខ ជាកិរិយាស័ព្ទ
តាសាខ្មែរ ដូចសួរឲ្យគេធ្វើយ ។ ល ។

បែបទី ៣ ពាក្យថា សួគ៌ មានអក្សរ គ ជាកំរបាទប្រកបមុខ
ជានាមស័ព្ទតាសាសំស្ក្រឹតក្តាយ ដូចឋានសួគ៌ ។ ល ។

ឯពាក្យថា " សួរ " ក្នុងទីនេះជាឈ្មោះបេស់ព្រះវិហារ ១ នៅក្នុង
ស្រុកឦចត់តណ្តាល ខែត្រកណ្តាល បើសរសេរពាក្យនេះត្រូវជាក់ រ មុខសួ
អានថា ព្រះវិហារសួរ ព្រោះព្រះវិហារនេះ មានដើមកំណើតជាព្រះពជ-
ទ្រព្យ ដែលព្រះពជាទ្រង់សាងឡើង ពុកជាអនុស្សាវរីយ៍ ត្រង់ទីដែល
តាគេហៅតែនទ្រង់សួរ ដូចចែងពុកក្នុងប្រវត្តិនៃព្រះវិហារនោះតទៅនេះ ៖

តាមរបាក្យត្រដែលមានចារឹកពុកមកក្នុងព្រះពជវង្សវតារប្រទេស
កម្ពុជា ថា វត្តព្រះវិហារសួរ កើតឡើងក្នុងរជ្ជកាលទី ១៩ នៃរជ្ជកាល
ព្រះបាទបញ្ញាចាំក្រុង ជាព្រះចៅប្រទេសកម្ពុជាតង់នៅនគរវត្ត ក្នុងពុទ្ធស-
កពជ ១៩៧២ គ្រិស្តសកពជវង្ស ១០២៨ ឬ ២៩ ព្រះអង្គបានផ្តើមកសាង

ពុកជាអនុស្សាវរីយ៍រំលឹកដល់ពេលដែលព្រះអង្គរត់ទ័ពជាមួយតាគហេ ។

រឿងនេះមានដំណាលថា :

កាលដែលព្រះបាទចក្រពត្រ ព្រះចៅប្រទេសកម្ពុជា រដ្ឋកាលទី១៦ ទ្រង់ព្រះនាមវិគ្គតទៅ មានបុរសម្នាក់ឈ្មោះដំបងត្រញឹងមានវិជ្ជាខ្លាំងពូកែបាន សោយរាជ្យជារដ្ឋកាលទី ១៧ ឡើង បង្គាប់ឲ្យធ្វើគតព្រះពជវង្សពុទ្ធ្យ ។

កាលនោះ, មានព្រះម្នាងម្នាក់ទ្រង់ព្រះគភ៌ពុំបានគ្រប់ខែ។ កៀសខ្លួនទៅជារាស្ត្រសាមញ្ញចេញទៅស្រុកក្រៅ នៅសំណាក់ជាមួយតាគហេ នឹងយាយលាក់ ជាស្វាមីភរិយា ។ លុះព្រះគភ៌គ្រប់ ១០ខែ ក៏សម្ភពព្រះពជបុត្រា ១ ព្រះអង្គ ប្រកបដោយព្រះលក្ខណៈល្អ មានលាយល័ក្ខ-ណ៍គងចក្រនៅបាតព្រះហស្តនឹងបាតព្រះបាទ ។ តាគហេនឹងយាយលាក់ស្រឡាញ់ណាស់ថ្នមដូចកូនបង្កើត ។ ថ្ងៃ ១ តាយាយនឹងព្រះម្នាងទៅច្រូតស្រែ បាននាំកព្រះពជកុមារគ្រោមម្ងប់ឈើ ១ ។ លុះតំរៅថ្ងៃចាំងមកត្រូវព្រះពជកុមារ មានសត្វបក្សី ១ មកគាងស្លាបក្រូងចាំងពីលើមិនឲ្យត្រូវថ្ងៃ តាគហេក៏យកគ់ទៅមើល បក្សីនោះហើរចាកគ់ទៅ ។ តាគហេសរសើរថា មានបុណ្យអស្ចារ្យណាស់ ក៏ថ្វាយព្រះនាមថា "បក្សីចាំក្រូង" ។

តមក, កាលព្រះបាទព្រហ្មកិល (ពញាក្រែក) រដ្ឋកាលទី ១៨

ទ្រង់សោយរាជ្យទៀនទ្រង់បានជ្រាបទំនាយតាមពួកហោរាថាយ៉ូយ៉ាថា មានអ្នកមានបុណ្យកើតក្នុងត្រកូលក្សត្រិបានព្រះជន្ម ៧ ឆ្នាំហើយគឿន ខ្លួនជាពស្ត្រនៅក្នុងព្រះពាជអាណាចក្រនេះ អ្នកមានបុណ្យនោះមានកង ចក្រនៅជាតដៃជាតដើង ទ្រង់កំឡែងកក្នុង ។ អាយុ ៧ ឆ្នាំ ដៃលមាន ក្នុងព្រះនគរទាំងប៉ុន្មានមកផ្តិតដៃលើមេម៉ាក្នុងចង្អេរដើម្បីទ្រង់ឧតកងចក្រ ។ គាតហែកយកំពបក្សីចាំក្រុងរត់ចេញ ។ ព្រះពាជាទ្រង់ចាត់ឲ្យលើកកងទ័ព តាមចាប់ ។

ហេតុតែបុណ្យចារមីបក្សីចាំក្រុង កងទ័ពដេញតាមពុំទាន់រកពុំ ឃើញ ។ គាតហេបញ្ជិះបក្សីចាំក្រុងលើស្មា ដើរគាត់ព្រៃទៅផ្ទះ ដល់ ហើយគាត់ទូលបក្សីចាំក្រុងថា "ចាតង់នៅទីនេះចុះ ចាំតាទៅគឿងគោ បញ្ចូលគ្រោលសិន" ហើយគាត់ចោលដំបងដេញគោ ដំបងចាត់ក្នុងទឹក អូរតពុំឃើញ ចានជាអូរនោះមានឈ្មោះថា "អូរដំបង" ទៃត្រចាត់ដំបង សព្វថ្ងៃនេះ ។

បន្ទាប់ពីនេះ, គាតហេពបក្សីចាំក្រុងតត់គាត់ព្រៃទៅដល់ខ្លួល ១ ហានដើមរលួសមួយត្រៃឈ្ម កំឈប់សម្រាកដេកនៅទីនោះ ចានជាទី នោះហៅថា "តូមិរលួស" នៅក្នុងស្រុកសូទ្រនិគម ទៃត្រសៀមហសព្វ ថ្ងៃនេះ ។

លុះព្រឹកឡើងវត់ដោះពីទីនោះ ចូលទៅក្នុងព្រៃប្រទះនឹងព្រៃ ១ មានពីកខាន់ផ្លូវ គាត់ហោបានយើញក្មេងម្នាក់ឈ្មោះដើរក្រែងដំរីខ្លួកស្លូបត្រកំឲ្យចម្លង បានជាជាប់ឈ្មោះទីនោះថា "ភូមិដើរក្រែង ស្រុកដើរក្រែង" នៅក្នុងខែត្រសៀមរាបសព្វថ្ងៃនេះ ។

ក្រោយពីនោះ, វត់មកដល់ភ្នំ ១ ជួបនឹងតាម្នាក់ឈ្មោះម៉ឹង តាម៉ឹងសួរ តាគហេថា "តានាំចៅទៅឯណា" តាគហេប្រាប់ថា ខ្ញុំមានតាសន្ទុមានទុក្ខ ធំណាស់ អត់ពំនឹងស្បៀងអាហារផង តាម៉ឹងឲ្យពួនចាំនៅភ្នំនោះ ខ្លួនតាត់ទៅយកអាហារមកឲ្យបរិភោគ ហើយឲ្យជាស្បៀងទៅតាមផ្លូវផង បានជាភ្នំនោះឈ្មោះថា "ភ្នំតាសន្ទុទុក្ខ" ដែលក្លាយមកជាភ្នំសន្ទុក ក្នុងស្រុកសន្ទុក ខែត្រកំពង់ធំ សព្វថ្ងៃនេះ ។

តពីនេះ, តាគហោនឹងបក្សីចាំក្រុង ដោយសារខ្លួកគេធ្លងតាត់ទីតំនាបទឹកមកដល់ខែត្រដើងព្រៃ កងទ័ពលើកតាមមកដិតពាន់ តាគហោក៏នាំបក្សីចាំក្រុងវេះពួនក្នុងព្រៃ ១ នៅវេលាយប់ព្រៃនោះមានមូសច្រើន បក្សីចាំក្រុងបួងសួងថា "បើខ្ញុំមានបុណ្យសូមកុំឲ្យមានមូសក្នុងទីនេះ" ។ ដោយអានុភាពព្រះពជកុមារ មូសក៏ចាត់អស់ទៅ ទើបទីនោះមានឈ្មោះថា "ខ្លួសគហោ" នៅក្នុងតំបន់តាកោង ស្រុកមុខកំពូល ខែត្រកណ្តាល សព្វថ្ងៃនេះ ។

លុះព្រឹកឡើង តាគហេកំនាំបក្សីចាំក្រូង រត់ទៅទៀត ដល់មាត់ទន្លេមេគង្គ ប្រឹងនឹងធ្វូងទៅត្រើយខាងត្បូង តែកេរ្តិ៍ធ្វូងគ្មាន បក្សីចាំក្រូងផ្សែបារម៉ាថា "បើខ្ញុំត្រូវហ៊ុនសោយរាជ្យ ហើយបានទំនុកបម្រុង ពុទ្ធសាសនាមែន សូមឲ្យដើមកោងៅត្រើយខាងដើងកោងទៅ ដើមល្វាទៅត្រើយត្បូងទេរមក" ។ ដើមឈើទាំងពីរនោះក៏កោងទៅទេរមកដូចប្រណិធាន ។

តាគហេ កំពប់បក្សីចាំក្រូងធ្វូងតាមដើមឈើទាំង ២ នោះរួចទៅ ដើមឈើទាំងពីរក៏ងើបឡើងដូចដើមវិញ ទើបពីត្រើយខាងដើងមានឈ្មោះថា "រកាកោង" នៅក្នុងស្រុកមុខកំពូល ខែត្រកណ្តាល, ពីត្រើយខាងត្បូងហៅថា "ល្វាទេរ" នៅក្នុងស្រុកស្រីសុន្ទរ ខែត្រកំពង់ចាម សព្វថ្ងៃនេះ ។

លុះតាគហេ នាំរត់ទៅត្រើយខាងត្បូងដល់ទួល ១ ប្រុបន្តែបីដងបានកាប់មែកថ្ងៃជោគធ្វើសម្រាប់សម្រាប់ស្រាប់សម្រាកកម្ចាំងទៅពីនោះ បក្សីចាំក្រូងក៏និក្រាលក់ក្រោមម្លប់សម្រាប់នោះ ។ កំពុងតែលក់ស្រួលស្រាប់តែមានហ្វូងសត្វតាជក់នោលខុងជាច្រើន ដែលចុះរកស៊ីក្នុងបឹងនោះ ក៏ផ្តើលអ៊ូឡើងព្ធសន្ធឹកភ្នំង តាគហេឮសត្វនោះស្ងាត់ថាកងទ័ព ក៏ស្ទុះទៅតើនព្រះរាជកុមារសួរថា "នែទៅឮសូរអ្វីភ្នំងម្ល៉ះ ?" ។ ព្រះរាជកុមារ

តើនឡើងភ័យណាស់ស្មានថាកងទ័ព កំសុះឡើងមែកដៃ ដែលជោគ
ផ្ញើសម្រាប់នោះ ឈរមើលគ្រប់ទិសមិនឃើញកងទ័ព ឃើញតែសត្វហើរ
ដេរជាស កំបាត់ភ័យទៅវិញ ។ មែកដៃនោះរស់នៅរៀងពបដរាបមក
នៅខាងត្បូងវត្តព្រះវិហារស្ពរ សព្វថ្ងៃនេះ ។ គាត់មានាំបក្សីចាំក្រុង
រត់ធ្លងទន្ទេរដោយខ្លួកទៅត្រើយខាងលិច ទៅពួននៅគុហាភ្នំប្រសិទ្ធិ ខែត្រ
សំរោងទងថាស់ ដែលជាស្រុកពញាឮ ខែត្រកណ្តាល សព្វថ្ងៃនេះ ។
កងទ័ពតាមទៅបៀតបៀនពុំបាន ឡើយ ។

លុះព្រះបាទ ព្រហ្មកិល (ពញាក្រែក) សោយរាជ្យបាន ២០ឆ្នាំ
ទ្រង់ព្រះទិវង្គតទៅ នាហ្មឺនសព្វមុខមន្ត្រីដឹងថា បក្សីចាំក្រុងព្រះរាជ
កុមារមានបុណ្យអស្ចារ្យគង់នៅភ្នំប្រសិទ្ធិ កំអញ្ជើញទ្រង់មកសោយរាជ-
សម្បត្តិតទៅ ។

តាលបក្សីចាំក្រុងពជកុមារបានសោយរាជ្យឡើងទ្រង់តាំងតាគេហ
ទីឯយាយលាក់ ជាព្រះអយ្យកោ អយ្យិកាជាមិ ។ ទ្រង់ឲ្យសាងប្រា-
សាទ ១ ត្រង់ទីដែលឃើញទង់ដំយវែងលៃលៃរបស់កងទ័ពដែលលើកដេញ
តាមជាដំបូង ហៅថា "ប្រាសាទលៃលៃ" ។ ទ្រង់ឲ្យសាងប្រាសាទ ១
ត្រង់តាគេហថា "ចុតងសិន" ហៅថា "ប្រាសាទចុតងសិ" ដែលភ្លាយ
មកជា "ប្រាសាទចុតង" នៅខែត្រសៀមរាប សព្វថ្ងៃនេះ ។ ទ្រង់

ឲ្យសាងប្រាសាទ ១ ទៀតនៅក្រោលគោរបស់គាត់ហៅ ហៅថា "ប្រាសាទបាគោ" នៅខែត្រសៀមរាប សព្វថ្ងៃនេះ ។ ទ្រង់ឲ្យសាងព្រះវិហារ ១ និងព្រះពុទ្ធបាទ ១ នៅភ្នំអាសន្នខ្ពស់ ឲ្យតាមុំនជាចៅហ្វាយស្រុកអង្គរក្នុងទីនោះ ។

ទ្រង់ឲ្យសាងព្រះវិហារ ១ ដំកល់ព្រះពុទ្ធបដិមាករ ១ ព្រះអង្គ ត្រង់ទីដែលជាតមែកដ្រែធ្វើសម្រាប់តំទីដែលគាត់ហៅតើនទ្រង់សួរពីសួរសំដួងហួនសុស្នាន់ថាកន្លែងនោះ ហៅថា "វត្តព្រះវិហារសួរ" ទើបជាប់មានឈ្មោះថា "វត្តព្រះវិហារសួរ" ជាបូជនីយដ្ឋានដ៏ស័ក្តិសិទ្ធិដរាបមកដល់សព្វថ្ងៃនេះ ។

ឯគាត់ហៅ នឹងយាយលាក់នោះលុះចាស់ជរាទួលមរណភាពតាមលំដាប់គ្នាទៅ, ព្រះរាជាទ្រង់ឲ្យធ្វើបុណ្យរំលាយសព ហើយទ្រង់ឲ្យយកជាតុគាត់ហៅទៅបញ្ចុះនៅទីដែលផ្សែងមិនឲ្យមានមួស ទើបទីនោះមានឈ្មោះថា "ទួលគាហៅ" នៅតំបន់រកាកោង ស្រុកមុខកំពូល ខែត្រកណ្តាល សព្វថ្ងៃនេះ ។ ជាតុយាយលាក់ ទ្រង់ឲ្យយកទៅបញ្ចុះនៅប្រាសាទបាគោ ឯខែត្រសៀមរាប ព្រោះភូមិនោះជាទីភូមិរបស់គាត់នៅ ។

ចប់ប្រវត្តិវត្តព្រះវិហារសួរត្រឹមប៉ុណ្ណេះ ។

ពត៌មានដ្ឋាន ។ របស់ក្រសួងធម្មការ

លោកស្រី – អ៊ូ ថ្លែងតាមវិទ្យុជាតិ

នៅថ្ងៃទី ២៣ សីហា ១៩៥៨

ការផ្សាយរបស់អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា

ការសិក្សាខាងព្រះពុទ្ធសាសនា ដែលហៅថាពុទ្ធិកសិក្សា គាន់តែមានដំណើរដឿនលឿនទៅមុខហើយ ។ នៅគ្រប់វត្តអារាមក្នុងព្រះរាជអាណាចក្រ សុទ្ធតែមានសាលាធម្មវិន័យ សម្រាប់កុំសាមណេររៀនសូត្រតាមសេចក្តីត្រូវការ ដើម្បីអប់រំដឹកាពឲ្យសមរម្យជាពុទ្ធិកបព្វជិត ក្នុងព្រះពុទ្ធសាសនា ។ ក្រៅពីសាលាធម្មវិន័យ មានវត្តចំនួន ៩៧៩ វត្ត ដែលមានសាលាពុទ្ធិកបឋមសិក្សា ដែលតាំឡើងដោយអគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា ព្រមទាំងរដ្ឋមន្ត្រីក្រសួងធម្មការ សម្រាប់ឲ្យកុំសាមណេរដែលមានបំណងក្នុងការសិក្សា ឲ្យបានចេះដឹងជ្រៅជ្រះ ក្នុងច្បាប់ព្រះពុទ្ធសាសនាថែមទៀតទៀត ។ ហើយសព្វថ្ងៃនេះ មានវត្តជាច្រើនទៀត ដែលកំពុងសុំតាំងសាលាពុទ្ធិកបឋមសិក្សា ។ ក្នុងរៃប្តិ្ចកា ឆ្នាំ

១៩៥៧ មានសមណសិស្សចំនួន ២.៣០០ រូបដែលប្រឡងបានជាប់
វិញ្ញាបនប័ត្រសាលាពុទ្ធិកបឋមសិក្សា ។ នៅខែកុម្ភៈ ១៩៥៨ មានសម-
ណសិស្សចំនួន ២០.៨៩ រូប ដែលបានសុំបុះឈ្មោះចូលប្រឡងប្រជែង
យកកន្លែងរៀននៅពុទ្ធិកវិទ្យាល័យព្រះសុកម្រិត ។ ចំណែកខាងពុទ្ធិក-
វិទ្យាល័យព្រះសុកម្រិតសព្វថ្ងៃនេះ មានសមណនិស្សិត ៦៥០ រូបកំពុង
សិក្សារៀនសូត្រនៅផ្ទាំងផ្លូវធម៌និងផ្លូវលោក តាមលំដាប់ថ្នាក់ពីចាបៗខ្ពស់
ដោយសេចក្តីរៀបរយយ៉ាងថ្លៃថ្លា ។ សព្វថ្ងៃនេះពុទ្ធិកវិទ្យាល័យ មាន
តែមួយកំពីតមែន ប៉ុន្តែសមណនិស្សិត ដែលបានប្រឡងជាប់សញ្ញា-
ប័ត្រមានចំនួនច្រើនណាស់ហើយ ។ ព្រះពជរដ្ឋាភិបាល ដែលមានព្រះ
ករុណាជាអម្ចាស់ដ៏វិសេសលើត្បូងជាប្រមុខ បានបង្កើតឲ្យមានមហាវិទ្យាល័យ
មួយ ហៅថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជ ជាមហាវិទ្យាល័យ
សម្រាប់បន្តការសិក្សាបណ្តុះពូជជាវ នៃចំណេះវិជ្ជាជាន់ខ្ពស់ របស់ពួក
សមណនិស្សិត ដែលបានសិក្សានៅពុទ្ធិកវិទ្យាល័យគ្រប់ ៤ ឆ្នាំហើយ
ហើយបានប្រឡងជាប់សញ្ញាប័ត្ររបស់វិទ្យាល័យនោះ ។ ការសិក្សាក្នុង
ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជ នឹងបើកបង្រៀននៅឆ្នាំ ១៩៥៩ មុខ
នេះ ។ សាលាពុទ្ធិកបឋមសិក្សាទូទៅក្នុងព្រះពជអាណាចក្រក្តី ពុទ្ធិកវិទ្យា-
ល័យព្រះសុកម្រិតក្តី ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជក្តី មានគោល
បំណងដូចគ្នា ដូចតទៅនេះគឺ

១- ដើម្បីឲ្យព្រះសង្ឃពុទ្ធសាសនិកជាតិខ្មែរយើង បានចេះដឹងនូវវិជ្ជាផ្សេង ។ ពាំងពាន់ផ្លូវសាសនា ពាំងពាន់ផ្លូវលោក ឲ្យបានជ្រៅជ្រះខ្ពង់ខ្ពស់ឡើង ឲ្យសមតាមសម័យនិយម ព្រោះព្រះសង្ឃជាបង្អែកមួយយ៉ាងមាំរបស់ពលរដ្ឋភាគច្រើនក្នុងប្រទេស ពាន់ផ្លូវដឹកនាំទៅរកប្រយោជន៍ល្អ។

២- កាលបើព្រះសង្ឃជាតិខ្មែរយើង មានការចេះដឹងមាំមួនហើយ នឹងអាចជួយដឹកនាំប្រជាពលរដ្ឋក្នុងប្រទេស ឲ្យបានចេះដឹងផ្លូវលោក ផ្លូវធម៌ដោយងាយ ហើយមិនតែប៉ុណ្ណោះ លោកអាចជួយធ្វើឲ្យព្រះពុទ្ធសាសនា បានចំរើនរុងរឿងតទៅអនាគតផងទៀត ។

៣ ក្នុងបណ្តាព្រះសង្ឃពាន់នោះ បើមានភិក្ខុ សាមណេរអង្គខ្លះមិនអាចនឹងទ្រាំនៅក្នុងកេរដាបព្វជិតបាន ហើយសឹកទៅជាគ្រហស្ថ ក៏នឹងបានទៅជាពលរដ្ឋខ្មែរមួយរូប ដែលមានចំណេះចេះដឹងផ្លូវលោក ផ្លូវធម៌ សមដល់ឋានៈនៃប្រទេសកម្ពុជាឯកពេជ្យ នឹងប្រទេសគាន់ព្រះពុទ្ធសាសនា ។

ពិធីទទួលព្រះត្រៃបិដកជាភាសាទីបេត

នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ស្រ៊ែ-អ៊ូ រៀបរៀង

កាលពីថ្ងៃទី ២១ ស៊ីហា ១៩៥៨ ម៉ោង ៩ ព្រឹក នៅពុទ្ធសាស-
នបណ្ឌិត្យ ក្រសួងធម្មការ មានធ្វើពិធីទទួលព្រះត្រៃបិដកភាសាទីបេត
ចំនួន១៣១ ក្បាល ជាអំណោយរបស់ឯកឧត្តមកេនហ្សូ ម៉ាត់ស៊ុយ សមា-
ជិកវរជ្ជសភា ធនធជាអតីតរដ្ឋមន្ត្រីប្រទេសជប៉ុន ដែលឯកឧត្តមឯកអគ្គរាជទូត
ប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា បានប្រគល់ជូនមកក្រសួងធម្មការដើម្បី
បង្គ្រប់ជា ១ ចប់ ជាយគតិតាំងសៀវភៅ ដែលឯកឧត្តម ឯកអគ្គរាជទូត
បានប្រគល់ពីលើកមុនចំនួន ២០ ក្បាលនោះផង បូករួមជា ១៥១ ក្បាល ។

ឯវាសមណៈ វរជន ដែលបាននិមន្ត-អញ្ជើញមកជួបជុំក្នុងពិធីនោះ
គេសង្កេតឃើញ :

ផ្នែកខាងព្រះសង្ឃ : សម្តេចព្រះសង្ឃនាយកតំណាងព្រះ
ពោធិវង្សហួត-គាត ពជាគណៈ ហាននុក្រម ក្រុមដំនុំព្រះត្រៃបិដក ។

ផ្នែកខាងគ្រហស្ថ : លោកអ៊ុច-រ៉ឺន អនុរដ្ឋលេខាធិការក្រសួងធម្ម-
ការ លោក អ៊ុក-ឈុំនាយកការិយាល័យក្រសួងធម្មការ លោក ប៊ុនចាន់
ប៉ូធ៌ អគ្គលេខាធិការក្រសួងការបរទេស លោក កឹងតុន ចាងហ្វាងនៃការ
សិក្សាទុតិយភូមិនិងឧត្តមភូមិ ដំណាងលោករដ្ឋលេខាធិការក្រសួងសិក្សា-
ធិការ លោក សម-ញ៉ា ណប្រធានក្រុមប្រឹក្សាព្រះពុទ្ធអាណាចក្រ លោក

មីនារសី អតីតរដ្ឋមន្ត្រីក្រសួងធម្មការ ទទឹងបុគ្គលិកក្រសួងធម្មការ ក្រុមពុទ្ធ-
សាសនបណ្ឌិត្យ-ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត -ពុទ្ធិកមហាវិទ្យាល័យព្រះ
សីហនុរាជ-អគ្គាធិការដ្ឋានពុទ្ធិកសិក្សា ។

ម៉ោង ៨ ទឹង ៣០នាទី ឯកឧត្តមយ៉ាស៊ុយ៉ូកា ឯកអគ្គរាជទូតប្រទេស
ជប៉ុនប្រចាំប្រទេសកម្ពុជាបានអញ្ជើញមកដល់ ម៉ោង ៩ ឯកឧត្តមបាន
ថ្វាយសុន្ទរកថាមួយ ពណ៌នាអំពីចិត្តសោមនស្សនៃលោកកេនហ្ស៊ូម៉ាត់សុភ-
សមាជិករដ្ឋសភាទទឹងអតីតរដ្ឋមន្ត្រីប្រទេសជប៉ុន ចំពោះការធ្វើអំណោយ
ព្រះត្រៃបិដកជាភាសាខ្មែរ ចាត់លើកមុន លើកក្រោយ ចំនួន ១៥១
ក្បាល ដែលបានប្រគល់ជូនមកពាក់ព័ន្ធកិច្ចការប្រទេសកម្ពុជា ។

លុះចប់សុន្ទរកថាហើយ ទើបឯកឧត្តមបានលើកព្រះត្រៃបិដក ១ ក្បាល
ជានិមិត្តរូបនៃព្រះត្រៃបិដក ១៣១ ក្បាល ជូនមកលោកអ៊ុច-វ៉ែន អនុរដ្ឋ-
លេខាធិការក្រសួងធម្មការ ។

លំដាប់តមក លោកអ៊ុច-វ៉ែនអនុរដ្ឋលេខាធិការក្រសួងធម្មការ បាន
ថ្វាយសុន្ទរកថាមួយជាភាសាខ្មែរដូចតទៅនេះ :

សម្តេច !

ឯកឧត្តម !

ព្រះថេរានុត្ថេរៈទាំងឡាយ !

លោក-អ្នកនាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយជាដំបូងបង្អស់នូវតេជញ្ញាតាធម៌យ៉ាងជ្រាលជ្រៅ

ចំពោះសម្តេចតំណពីព្រះអង្គ ព្រមទាំងសូមសំដែងនូវអំណរគុណចំពោះព្រះថេរានុត្ថេរៈនឹងអស់លោក-អ្នកតំណាយ ដែលបាននិមន្តនឹងអញ្ជើញមកកាន់ទីនេះ ដើម្បីញុំាងពិធីទទួលព្រះត្រៃបិដកនេះ ឲ្យបានជាទុក្ខាកែវ ឯកទត្តម ឯកអគ្គពាជទូត !

គឺជាកិត្តិយសដ៏ប្រសើរបស់ខ្ញុំ នឹងជាកិច្ចដ៏សោមនស្សពន់ពេកដោយថ្ងៃនេះ ខ្ញុំបានទទួលជាលើកទី ២ នូវការៈជាអធិបតីនៃពិធីទទួលព្រះត្រៃបិដក ការក្រោយបង្អស់ ជាការសាទរចេតនាដែលឯកទត្តមនឹងប្រគល់ជូនចំពោះពុទ្ធសាសនបណ្ឌិត្យ ជាអំណោយពីលោកកេនហ្យូម៉ាត់សុប៉ា សមាជិកវដ្ឋសភានឹងអតីតវដ្ឋមន្ត្រីប្រទេសជប៉ុន ។

ព្រះត្រៃបិដកមានចំនួន១៣១ ក្បាលនេះ ដោយគិតចាំងសៀវភៅចំនួន ២០ ក្បាល ដែលឯកទត្តមបានប្រគល់ពីលើកមុនផង ត្រូវបំពេញ នូវសម្ភារៈមហាភាពដ៏ទុក្ខទត្តមនៃព្រះត្រៃបិដកជាការសាទរចេតដែលវិជ្ជាស្ថានសម្រាប់ការសិក្សាព្រះត្រៃបិដក ការសាទរចេត នៅប្រទេសជប៉ុនបានចាប់ពុម្ពផ្សាយ ឯកទត្តម !

ការរៀបចំពិធីប្រគល់សៀវភៅនេះជាន់មុន ខ្ញុំបានបញ្ជាក់ឯកទត្តមរួចហើយ អំពីសារៈសំខាន់នៃគម្ពីរព្រះត្រៃបិដកនេះ ព្រមទាំងបានជំរាបអំពីប្រយោជន៍ដល់ពួកពុទ្ធមាមកជន នូវសម្ភារៈមហាភាពនៃក្នុងច្បាប់ព្រះពុទ្ធសាសនា ដែលមានសភាពសម្បើមអស្ចារ្យនេះ ។ ខ្ញុំសូមរំលឹកនឹងសូមបញ្ជាក់នៅថ្ងៃនេះម្តងទៀតថា យើងនឹងរក្សាទុកជាវត្ថុដ៏ថ្លៃថ្លាយ៉ាង

ក្រៃលែង នូវគម្ពីរព្រះត្រៃបិដកជាភាសាទីបេត៍នេះ ដែលជាលទ្ធផលនៃ
កិច្ចការរបស់ពួកមហាបណ្ឌិត ក្នុងប្រទេសរបស់ឯកឧត្តម ដែលខ្ញុំសូម
គោតសរសើរ ជាយ៉ាងជ្រាលជ្រៅក្នុងពេលនោះ ។

សារវត្ថុដ៏ប្រសើរបំផុត ដែលមានដីវភាពខ្ពង់ខ្ពស់ចំពោះរូបនិយមនឹង
សតិប្បជ្ជានេះ សម្រាប់យកមកបំពេញបណ្ណាល័យរបស់យើង ដែលមាន
ពួកអ្នកស្រាវជ្រាវជាបព្វជិតនឹងគ្រហស្ថជាតិខ្មែរនឹងបរទេស ព្រមទាំង
និស្សិតដែលមានចិត្តចង់សិក្សាគ្រប់ ។ គ្នា តែងចូលមកអានរកវិនសូត្រ
រាល់ ។ ថ្ងៃ ។ មិនតែប៉ុណ្ណោះសារវត្ថុនេះ អាចចងភ្ជាប់នូវចំណងមិត្តភាពរវាង
ប្រទេសដប៉ុន នឹងព្រះរាជអាណាចក្រកម្ពុជាឲ្យកាន់តែមាំមួនឡើងថែមទៀត
ក្នុងនាមនៃរដ្ឋាភិបាលប្រទេសកម្ពុជា ក្នុងនាមនៃពួកពុទ្ធសាសនិក-
ជនខ្មែរ នឹងក្នុងនាមផ្ទាល់របស់ខ្ញុំ ខ្ញុំសូមថ្លែងនូវគុណភាពមិ ជាយ៉ាង
ជ្រាលជ្រៅម្តងទៀតជាអវសាន ចំពោះការិការទានវិទ្យាសាស្ត្រ នយោ-
បាយ នឹងសាសនា ដែលឯកឧត្តមនឹងប្រជាពស្ត្រដប៉ុន បានបំពេញចំពោះ
ប្រជាពស្ត្រខ្មែរ ហើយខ្ញុំសូមឯកឧត្តមបញ្ជូនទៅលោកគេនហ្ស៊ូម៉ាត់សុភី
នឹងរដ្ឋាភិបាលប្រទេសដប៉ុន នូវបដិការគុណយ៉ាងជ្រាលជ្រៅរបស់ខ្ញុំ ។

បន្ទាប់មក លោកអ៊ុក-ឈុំនាយកការិយាល័យក្រសួងធម្មការបាន
ថ្លែងសុន្ទរកថា ជាភាសាបារាំង ជាសេចក្តីប្រែពីសុន្ទរកថាជាភាសាខ្មែរ ។

លុះចប់សុន្ទរកថាហើយ ទើបព្រះសង្ឃសូត្រធម្មដូនពរសំពះសាធុការ
ដោយបរិយាកាសប្រកបដោយសេចក្តីរីករាយ ។

(តមក)

ព្រះមហា ប៉ាំង-ខាត់ រៀបរៀង

អបកិត គុ. នែលមិនញាប់ញ័រ, ម៉ាំមួន ។

អបក្រ គុ. នែលមិនមានកង់ ។

អបក្សុស៑ អបក្ឃុស្ត្រ, គុ. នែលមិនមានចក្ខុ, ខ្វាក់ ។ **អចក្សុវិយ** នុំ, ធម្មជាត នែលមិនមែនជាវិស័យនៃចក្ខុ; គុ. នែលមិនមែនទៅក្នុងវិស័យនៃចក្ខុ (នែលជុតពីវង់ងៃនៃចក្ខុ) ។

អបណ្ឌ គុ. នែលមិនកាច, សុភាព, ស្លូត ។

អបត្យ គុ. នែលមិនឈ្លាស ។

អបទ្ធ គុ. នែលមិនមែនជាខ្ទឹមចន្ទន៍ ។

អបន្ត្រូស្យ គុ. នែលមិនមែនជាព្រះចន្ទ្រទឹងព្រះអាទិត្យ ។

អបបល គុ. នែលមិនឃ្លេងឃ្លោង ។

អបរ នែលមិនរំភើប, ទំងធំង ។

(មានត)

ពិធីបុណ្យដាក់បាត្រក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ

ប្រគេនជោគជ័យសិរីសួស្តី ចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស

ដើម្បីប្រគេនជោគជ័យសិរីសួស្តីចំពោះព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-ភាត ចាន់ ហ្វាន់ពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ដែលទទួលគ្រោះថ្នាក់ដោយរថយន្ត ក្នុងវេលាធ្វើដំណើរទៅស្រុកទន្លុង្គ នៅថ្ងៃទី ៣០ សីហា ១៩៥៨ ដែលបាននិមន្តទៅព្យាបាល នៅមន្ទីរពេទ្យព្រះកេតុ-មាលាក្រុងភ្នំពេញ ដល់បានជួរស្រាល ហើយនិមន្តមកកុដិវិញ នៅថ្ងៃទី ១៣ កញ្ញា ១៩៥៨ នោះ, គណៈកម្មការវត្តនឹងសិស្សានុសិស្ស បានធ្វើបុណ្យដាក់បាត្រគឺ

-ថ្ងៃសៅរ៍ ១៤ កញ្ញា ១៩៥៨ ម៉ោង ១៩ យប់ ចំរើនបរិត្ត-ទេសនា,

-ថ្ងៃអាទិត្យ ១៥ ខែ ដែល ម៉ោង ៩ ភន្លះព្រឹក ជាក់បាតព្រះសង្ឃ ចំនួន ១៤០ អង្គ ក្រោមអធិបតីភាព នៃសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយក គណៈមហានិកាយ ។

ពិធីបុណ្យនេះ បានចប់សព្វគ្រប់ នៅវេលាម៉ោង ១០ ភន្លះព្រឹក ។

អត្ថបទនិយាយ

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ១០ ខែតុលា

ព.ស. ២៥០១ គ.ស. ១៩៥៨

ភ្នំពេញ

វិធីលើកជហ្វាដំកល់លើគ្រឹះស្ថានប្តី

កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ១៩៩៨ ពីម៉ោង ៧ ដល់ម៉ោង ៩ កន្លះព្រឹក មានធ្វើពិធីលើកជហ្វាដំកល់លើគ្រឹះស្ថានថ្មីមួយខ្នងនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំងពីរ ព្រះអង្គ ទីឥស្សរជនជាន់ខ្ពស់ច្រើនរូប មានលោក ផ្ង-ព្រឿង រដ្ឋមន្ត្រី នឹងលោក អ៊ុច-វ៉ែន អនុរដ្ឋលេខាធិការ ក្រសួងធម្មការជាដើម ។

ពិធីនេះ មានជាក់ជហ្វា ១ ចំកណ្តាលទីធ្លារៀបគ្រឿងពលិការចំ-ពោះមុខសម្ភារៈគ្រឿងជាង មានណារ ដែកឈូសជាដើម ជារបៀបខ្មែរ១បែប ចិន១បែប តាមប្រពៃណីជាង ថ្វាយព្រះពិស្ណុការ ព្រោះជាងធ្វើសំណង់នោះ មានខ្មែរ មានចិន ។

លោជបូជាក្បៀវកិត្តិយស ព្រះតេជព្រះគុណព្រះពោធិវ័ង្សវ៉ែង សង្ឃថាដោយព្រះតិស្សទេវ រៀបរាប់អំពីការស្ថាបនាគ្រឹះស្ថានថ្មីនេះ ដ៏ពីរោះក្បោះក្បាយ ។ បន្ទាប់ពីសង្ឃថានោះមក, ពួកជាងបានផ្តើមសូត្រអញ្ជើញ ក្រុងពាលីតាមទំនៀមជាងថា:

ឯមៈ បឋមុត្តភេ ច ប៊ុញ្ញិយំ អគ្គនេយ្យេ ច វេវតោ
ឧត្តិណោ កស្សបោ ពុទ្ធោ និរតិយេ សុមង្គលោ
បច្ឆិមេ ពុទ្ធសិខី ច ញាយព្យេ ច មេធង្ករោ

តទៅក្រោយទាំងពុង



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ (តមក)	ព្រះមហា ជាំង-ខាត់ រៀបរៀង	៨៥១
- ចិត្តនឹកនាំលោក	ព្រះព្រះពុទ្ធវង្ស កែម-តូរ រៀបរៀង	៨៦៣
- ការឧបត្ថម្ភពុទ្ធសាសនា	ព្រះមហា ឈឹម-ទង រៀបរៀង	៨៧៥
- ទាន ៤ យ៉ាងនិងពរ ៨ ប្រការ	ព្រះញាណកោសល ញាណ-ឈឺន រៀបរៀង	៨៨៣
ផ្នែកអក្សរសាស្ត្រ		
- រឿងទេវន្តរបស់អម្រឹតក្សត្រីម៉ុក (តមក)	លោក ញ៉ុក-ថែម ពិនិត្យ	៨៩៣
- រឿងសាមកុក (តមក)	ឧកញ៉ា នួ-ពន ប្រែ	៩០៩
- សុភាសិតអភប់ (តមក)	លោក វ៉ាយ-ប៊ុក ឯកស្រង់រៀបរៀង	៩១៥
- រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន (តមក)	លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង	៩១៩
- អធិប្បាយច្បាប់កេរ្តិ៍កាល (តមក)	លោក ស្រ៊ី-អ៊ូ រៀបរៀង	៩២៣
ផ្នែកកំណត់ទីន្ន៍ប្រវត្តិការណ៍		
- ប្រវត្តិនៃទស្សនាវដ្តី	កម្ពុជសុរិយា លោកយូរ-អ៊ុន រៀបរៀង	៩៣៣
- គុណនៃព្រះត្រៃបិដក	លោកស្រ៊ី-អ៊ូ រៀបរៀង	៩៤០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហាជាំង-ខាត់ រៀបរៀង	៩៤៦

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជាវ ២៣០រ៉ៀល

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

— Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 851
— La volonté mène le monde par Vén. *KEM-TO* . . . 867
— La manière de protéger le Bouddhisme par Vén. *CHHIM-NONG* 875
— Les quatre pratiques de la charité par Vén. *NHEAN - CHHŒUN* 883

PARTIE LITTERAIRE :

— Histoire de Devanda de *M. MOK* (suite) revue et corrigée par *M. NHOK-THEM* 893
— Histoire de Sam-Kok (suite) traduite par *M. NOU-KAN* 909
— Proverbes arabes (suite) par *M. RAY-BUC* 915
— Contes et légendes du Japon (suite) traduites par *M. RAY-BUC* . . . 919
— Commentaire du chbab kel kal par *M. SERY-OU* (suite) 923

NOTES ET CHRONIQUES :

— Notes sur la Revue "Kambujasuriya" par *M. YOU-OUN* 933
— La Définition du Tripitaka par *M. SREY-OU* 940
— Dictionnaire Sanskrit khmèr (suite) par Vén *PANG-KHAT* 946

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ជួង-ខាត់ រៀបរៀង

(តមក)

សុវុចិវិរចិតាយា ភូមហិច្ឆាសម្ភូតប្រតិសុតតកេតុគ្រីជយគ្រីតវយាមិ
ទបលកនកមាលាវញ្ជិតាយាំគ្រីយាពវ្យាវ្យធិតជយតជាតាទគិមេហេនីន្ទ្រះ ។

អម្ពោជពគាញ្ជិតគាតកុម្ភប្រាសាទកាសារុណិតាម្ពុវាតិ
វិក្រាជតេ កាតិវិការិតសរ្វក្តហ្រាទសាកតិមុទូហំ យ ។
យាសាន្តរេ តិថិជលែកពតិជាតាកិពម៌ បុលិនំបពត្ថិ្រ មិ
សំសរ្គតិនាំ ក្សាលិតបាបបង្កិំ វហិត្រភូតន្តរណាំ កវាវ្ជ ។

«ន្រនំ (ព្រះបាទជយវរ្ម័នទី៧)បានសាងស្រះពង្សស្រី (នាគព័ន្ធ)
ទុកដូចតញ្ចាក់ក្តីដោយតែវទបលនឹងកម្រងផ្កាមាសទុកក្នុងប្រាសាទជ័យស្រី
(ព្រះខាន់) ប្រាកដដូចក្នុងព្រះកេសាដែលបូជនដោយសិល្បៈយ៉ាងប្រពៃ
នៃព្រះអគ្គមហេសី ដែលគាត់តែងវិចិត្រមុខគួរឲ្យរែកយ ។ ១៖៨ ។

«ស្រះពង្សស្រីនេះ មានទឹកថ្លាយង់យល់ដី ធ្លុះស្រមោលនៃពន្ធ
ប្រាសាទមាសនឹងពណ៌ផ្កាឈូកត្រហម ហោលពន្ធឹក្តីប្រាលឆ្លុះផ្លូវ ប្រា-

តជាដូចជាស្រះឈាមដែលព្រះជាទេតាតិ: (ស្តេចនៃចម្ប៉ា) ធ្វើឲ្យហូរ
ល្ហាប (ក្នុងចម្ប៉ាធំ) ។ ១៦៩ ។

នៅតណ្តាលស្រះពាជស្រីនោះ មានតំពធ៌បុណ្យសម្រាប់ឈាន
ចាបមួយ គាញ្ញយតលំអស្រស់មកពីស្រះ (គ្រប់ទិសទាំង៤) ជាតំពធ៌
បុណ្យសម្រាប់ឈាងផុតគឺចាបនៃជនណាដែលបានបួលទៅ ជាសំពៅ
កេត្រាដឹកជញ្ជូនសត្វលោក តាត់ធ្វើសមុទ្រមហាសាគរឲ្យចេញចាកត្រៃ
តព (ទៅកាន់អមតមហានិព្វាន) ។ ១៧០ ។

ទ្រង់បានសាងប្រាសាទច្រើនកន្លែងទៀត សម្រាប់ដំកល់ព្រះពុទ្ធ
បដិមាកនាម «ព្រះជយពុទ្ធមហានាថ» ដើម្បីជោះទុក្ខសត្វលោក ។
គេឃានរកឃើញព្រះពុទ្ធរូបបែបនេះ នៅលពបុរី សុពណ្ណបុរី រាជបុរី
ពេត្រាបុរី មឿងសិង្ហ (ក្នុងដីសៀមសព្វថ្ងៃនេះ) ។

សិលាចារឹកនៅប្រាសាទព្រះខាន់ មានខ្លឹមដូចសិលាចារឹកនៅ
ប្រាសាទតាព្រហ្មដែរ ខុសគ្នាបន្តិចបន្តួច តែជាស្នាព្រះហស្តព្រះរាជបុត្រ
ព្រះអង្គមួយអង្គផ្សេងទៀតព្រះនាម "ព្រះវីរកុមារ" ។ ព្រះវីរកុមារ
ព្រះវីរកុមារនេះ ព្រះនាមព្រះនាង "រាជេន្ទ្រទេវី" ជាអគ្គមហេសីទី១ ។
សិលាចារឹកនេះ បរិដ្ឋេមនមស្ការព្រះរតនត្រ័យដូចសិលាចារឹកនៅប្រា-
សាទតាព្រហ្ម រៀបរាប់ពីព្រះរាជវង្ស សរសើរប្រាជ្ញាព្រះបាទជយវរ្ម័នទី៧

ហើយរៀបរាប់ពីបញ្ជីវត្ថុអាហារគោជន ដែលត្រូវប្រើប្រាស់ក្នុងវត្តព្រះខាន់នេះ ។ ខ្ញុំជូតស្រង់សេចក្តីខ្លះមកទុកក្នុងនេះ ។ ត្រង់កសាងប្រាសាទព្រះខាន់ សិលាចារឹកនេះចែងទុកថា :

យត្រូវ្ចំច្រុងរាម្ចំដយត្រើយំ ហោ ដប្រោ យុធិ វ្យធិត តត្រប្បីន្តចាឡាម៊ា
ហោមាម្ចុដោបលវ៉ាញ្ចិតកូមិកាតា ទិត្ថាធុនាបិ រុធិរវ៉ៃយោ វិកាត៕

ព្រះកជាអង្គណា (ព្រះបាទជយវរ៌ន្ទ្រទី៧) ច្បាំងមានជ័យក្នុងសង្គ្រាមត្រង់ទីឋានណា ព្រះកជាអង្គនោះ កសាងបុរីមានឈ្មោះថា «ជ័យស្រី» ត្រង់ទីឋានដែលឈាមនៃសត្រូវដក់នៅនោះ ជាកូមិភាគមានតេនវត្ថុនឹងផ្កាឈូកមាសចាំងរស្មីធ្វើជីឲ្យមានពណ៌ត្រហមភ្លឺច្រាលរន្ធាលរហូតមកដល់កាលឥឡូវនេះ ប្រាកដហាក់ដូចគេយកឈាមនៃសត្រូវទៅលាបៗ ៣៦។

ត្រង់បានសាងបដិមាកព្រះវរកជបិតាជាតួអង្គពោធិសត្វលោកេស្វរៈថ្វាយព្រះនាមថា «ជយវរមេស្វរៈ» ដំណាលទុកក្នុងប្រាសាទជ័យស្រីនេះក្នុង ព.ស.១៧៣៤ (គ.ស.១១៩១) ព្រមទាំងបានកសាងព្រះពុទ្ធរូបជាច្រើនទៀតច្រើនអនេក ហើយទំនុកបំរុងដោយបច្ចយ ៤ ច្រើនអនេកអនន្តទៀត ។

នេះបញ្ជីវត្ថុដែលថ្វាយដល់ទៅរូបពាល់ថ្ងៃ មានពោធិសត្វលោកេស្វរៈជាដើមទៅវត្តព្រះខាន់គឺ :

អង្ករ: ៧៥ ខារ៉ែគា, កន្ទុះគ្រាណ: ; ល្ង: ១ ខារ៉ែគា, ៩ ប្រស្ន:, ២ កុទុ:; សណ្តែកពងមាស: ២ គ្រាណ:, ៤ ប្រស្ន:, ៤ កុទុ:, ទឹកដោះខាប់: ១យដីគា, ១៣ ប្រស្ន:, ខជ: ១យដីគា, ១៤ ប្រស្ន:, ២ កុទុ: ក្បរ:, ២៩ ប្រស្ន:, ២ កុទុ:, ទឹកឃ្មុំ ២១ ប្រស្ន:; ទឹកតេសដ្ឋ:ផ្អែម: ១៩ ប្រស្ន:; ប្រេងល្ង: ៦ ប្រស្ន:, ៣ កុទុ:; ប្រេងផ្លែឈើ: ២ ប្រស្ន:, ២ កុទុ: ព្រមទាំងគ្រឿងប្រដាប់ប្លង ។ បន្ថែមផ្លែឈើមិនពប់ក្នុងពីនេះទេ ។ សំពត់សាក្សាតសនីងក្រហម ៦៤៩ ជាប់សម្រាប់សំលៀកបំពាក់ទេវតា ព្រមទាំងសម្រាប់គ្រែដេក នីងកម្រាល: សំពត់ព្រៃចិនស្តើងសម្រាប់ការពារសត្វល្អិតដែលកេមព្រះហ្មទេវរូបដូចលោតកេស្ង:នីងទេវតាដទៃទៀតជាដើម ។

បញ្ជីចំណាយសម្រាប់បុគ្គលិក សាស្ត្រាចារ្យ. និសិត:

អង្ករ: ២២ ខារ៉ែ, ២ គ្រាណ: ១៤ ប្រស្ន: ។ ចំនួនអង្ករនេះរួមទាំងអង្ករសម្រាប់សេវាទេវតាផង ពាលថ្ងៃឡើងដល់: ៩៧ ខារ៉ែ, ៣ គ្រាណ:, ៦ ប្រស្ន: ។

នេះបញ្ជីសម្រាប់ថ្ងៃបុណ្យទី ៥, ទី ៨, ទី ១២, ទី ១៤, ទី ១៥, ពាលបក្ស, បុណ្យចូលឆ្នាំ (សង្ក្រាន្ត) ព្រមទាំងថ្ងៃបុណ្យ ១៨ ផង ។ បើបូករួមបុទំណាយទាំងនេះជាមួយគ្នាក្នុងមួយឆ្នាំ ។ នីងមានចំនួនដូច្នេះ:

អង្ករធុនល្អ: ៥.៣៨៦ ខារ: ១០ ប្រស្ដ: ; ល្អ: ៧៤ ខាវគា, ៣ ត្រណា:, ៤ កុឌុវ:; សណ្ដែកពងមាស: ៧៥ ខាវគា, ២ ត្រណា: ១៣ ប្រស្ដ:, ២ កុឌុវ, ទឹកដោះខាប់: ៧៥ យដគា, ៨ ប្រស្ដ:, ខធ: ៦៨ យដគា, ១ អាឈក:, ៤ កុឌុវ:; ក្សីរ: ៧៨ យដគា, ៧ ប្រស្ដ:, ៤ កុឌុវ:; ទឹកឃ្មុ: ៧៥ យដគា, ១ ប្រស្ដ:, ទឹកកេសដូវផ្អែម: ៦០ យដគា, ៤ ប្រស្ដ:, ៤ កុឌុវ:, ប្រេងល្ង: ៥៧ យដគា, ១០ ប្រស្ដ:, ប្រេងផ្លែឈើសម្រាប់វិធីបូជាទេវតា: ១៣ យដគា, ៤ ប្រស្ដ: ។ បើបូកបញ្ចូលគ្នាសម្រាប់សេវាទេពតាមួយឆ្នាំ ៗ ផង ត្រូវប្រើវត្ថុតាំងនេះជាខ្នាតគុណ ។

នេះបញ្ជីវត្ថុជាតាកវបានមកពីស្រុក :

ស្រូវ: ១៤៦.៥៨១ ខារ: អង្ករដែលបានមកពីស្រុកស្រាង្គ, ពីវាមាយ, ព័ផ្ស:, ខ្នងទីផ្សារ ៗ ទៀត : ៧.៨៤៨ ខារ: ល្ង: ៤៣៣ខារ: សណ្ដែកពងមាស ៤៤២ ខារ, ៣ ត្រណា:, ទឹកដោះខាប់: ៥៤៥ យដគា, ៧ ប្រស្ដ:កន្លះ ខធ: ៧៧៨ យដ, ១០ ប្រស្ដ:; ក្សីរ: ៦៣៩, ៦ ប្រស្ដ:; ទឹកឃ្មុ: ៤៥៤ យដគា, ៥ ប្រស្ដ:; ទឹកកេសដូវផ្អែម: ៤៥១ យដគា, ៥ ប្រស្ដ:; ប្រេងល្ង: ៣១៤ យដ, ៣ ប្រស្ដ:; ប្រេងឈើ: ១១៨ យដ, ៨ ប្រស្ដ:; គ្រឿងស្សៀកពាក់សម្រាប់ទេវតា ធំធាត់គ្រឿងស្សៀកពាក់ដទៃទៀត ៤២ ៦៨២ គូ: តុស្ដ: ១ គុណ, ៤២ បណ:

ដីស្រែ៖ ១ ការៈ, ២ តុលា, ១៣ កដ្ឋិតា; ឈើក្រឹស្ណា ១ ការៈ, ៣ តុលា, ១៣ កដ្ឋិតា; ក្រមួន: ១០០ ការៈ; ២ តុលា, ២១ កដ្ឋិតាកន្លះ, ៣ពែ ៤៣, ព្រាប ៣៥០; មានក្មេកនឹងព្រាបហារិតាលជាច្រើនទៀត, ព្រះពជ្ឈានឹងអ្នកមានទ្រព្យនៅស្រុកបានបួងា: ៥.៣២៤ ស្រុក; បុរសស្ត្រីបួកគ្នា: ៨៧.៨៤០ នាក់ ក្នុងចំនួននេះ មានជនជាប្រមុខ ៤៤៤ នាក់; សេវក, ៤០០៦; បរិចារិកា: ២.២៨៨ នាក់ រួមទាំងស្រីស្នេហ ១០០០ នាក់ផង; មានអ្នកធ្វើពិធីបួងា: ៤៧.៨៣៦ នាក់ទៀត ។

នេះបញ្ជីវត្ថុដែលត្រូវយកពីឃ្លាំងព្រះពជ្ឈាលំផ្ទាំ៖

អដ្ឋ: ១.៣២៨ ភារ ២ ទ្រោណ; សណ្តែកពង្គសៈ ៥៧ភារ, ៣ ទ្រោណ; ល្ង: ២៨ ភារ, ៣ ទ្រោណ; ៤ ប្រស្ថ; ទឹកដោះខាប់ ២៣ ឃដិកា, ៦ ប្រស្ថ; ទធិ ៣០ឃដិកា, ៨ប្រស្ថ; ម្ទុកុវ; ក្រវៃ ៣១ឃដិ; ៤ប្រស្ថ; ទឹកឃ្មុំ ៣៨៦ឃដិ; ៦ប្រស្ថ; ២កុឌុវ; ទឹកកេសដ្ឋផ្លែម ១៦ឃដិកា; ៦ប្រស្ថ; ២កុឌុវ; ប្រេងល្ង ៦ឃដិកា, ៤ប្រស្ថ; សំលៀកបំពាក់ទេវតានឹងដទៃទៀត ៣.៧១២ គូ; គ្រែ ១៣, មុងគ្រែចន ៣២; ពូក ២២; ពូកចនធ្វើពីស្បៅ ២; ម្រេចៈ ១ ភារកា ១២ប្រស្ថ; ក្រមួន: ២ការៈ, ២តុលា, ១១កដ្ឋិតាកន្លះ; អំបិល ៤ ភារ, ១០ ទ្រោណ; ចន្ទន៍ក្រឹស្ណា: ១ការៈ; ៥តុលា; ដីស្រែ: ១ ការៈ;

ពាក្យលា . . . , ឈើក្រឹស្ន: ១ការ:: ៦តុលា កប៉ូវាក កដ្ដី . . . មាម: . . . , ៦កដ្ដីគា, ១០បណា:: ចេសសូត្រ ពាកដ្ដី . . . , កន៏ន៏ដ៏គោ តិក្ស៎មាស: ៤មាម:: ៣ចាខ:: ១៤ . . . ; ប្រអប់, ប៉ាន់ចំពួយ . . . ៨បណា:: ៣ចាខ:: . . . ៨តំម្លក:: ចានស្ពាន់: ១តុលា . . . , កដ្ដីគា . . . ; . . . ៥កដ្ដីគា, ៤តុលា, ៥បណា:: ប្រអប់ចន៏ន៏៤០: គោញីក្រហមប្រផែះ មានក្រចកដើន៏ន៏ដ៏ស្ដួចទិញមាសន៏ដ៏សំពត់ត្រប១: សេះពណ៌៤, ជ័រ៤, ៣ស៊ី៤: ក្របីញី៤ វត្តប៊ុណ្ណះត្រូវព្រះពជា ប្រញ្ញ ៗ

វត្តជាវិការ:នៃមាស: ប្រាសាខ ៤៥.៣ (ស្លួច?) ន៏ដ៏ត្តៃផ្សេង ទៀត ៗ ចានដើន៏ (ជាវិការនៃមាស) ន៏ដ៏ត្រឿន៏ប្រជាប់ (ជាវិការ នៃមាស) ជាខទៀត: ១៨.១៦០ ៗ ចំនួនមាសសម្រាប់កសាន៏ត្រឿន ប្រជាប់: ៣០០ការ:, ១៤តុលា, ៣កដ្ដីគា, ១៤បណា:: ១ចាខ:: ៤មាម:: ៤តំម្លក:: ប្រាក់: ១៣៧ការ: ៤កដ្ដីគា: វេន: ៣៥.៨៣៧គ្រាប់ គឺពេជ្រ, កែវពៃឌូរ្យ: មុក្តា: គដ១១៤.៣០០គ្រាប់, ស្ពាន់: ៧.៣ការ:: ១តុលា: ៣កដ្ដី: សម្រឹទ្ធ: ១៦.១១០ការ:: ៤តុលា, ១កដ្ដី: ១០បណា:: ចានមាស៤០០ការ:: ៣តុលា, ៣កដ្ដី: សំណ: ៨០០ការ:: ៤តុលា, ៥កដ្ដី: សំណសុទ្ធ: ៤៤៤ការ:: ដែក: ៤៦០ការ:: ៤តុលា, ៣កដ្ដី: ស្លួចមានជាន់ទាំន៏អស់: ១០៤:

សំណង់ថ្ម ៤៨៥ ក្រុម, ប្រាក់រង្វាយក្រៀម: ២.២៣៨ ក្រាម; ៥ កន្ទៃ ២.០៧៥ ក្រាម . . . ; . . . ផ្លូវថ្នល់ក្រៀមគ្រប់កន្ទៃ; បន្ទប់ចាំងអស់ ៤៣៤; អធ្យាស្រ័យ (សាស្ត្រាចារ្យ) ១ នាក់, ទុតិយាស្រ័យ (សាស្ត្រាចារ្យរង) ១៥ នាក់ . . . ; ធម្មជាតិបស់លធម្មកាណកយោគី . . . . ចាំងអស់ នេះចំនួន ៣០៨ នាក់ ។ ចំណែកព្រាហ្មណ៍ការន់សាសនាព្រះឥស្សរមាន ៣៤ . . . . ។ បូករួមចំនួនមនុស្សដែលនៅខាងក្នុងព័ទ្ធជាន់ . . . . ។

ព្រះបាទជយវរ្ម័នទី ៧ បានកសាងព្រះសុគតស្រីវីរសត្តិ ហើយតម្កល់ទុកក្នុងទីនេះ ។ ទ្រង់បានកសាងព្រះសុគតស្រីពជបតីស្វរៈ, ជយមង្គលាថ ចូឌាមណី តម្កល់ទុកក្នុងស្រុកសិតជា ។ ទ្រង់បានតម្កល់ទុកព្រះគន្ធ-គ្រឹយនៅស្រីជយន្តបុរៈ, វិទ្យុបតិត, មទិលបុរៈ, ស្រីជយពជធានី, ស្រី-ជយន្តនគរី, ជយសិង្ហវតី; ស្រីជយវីរវតី, លវោទយបុរៈ; សុវណ៌ិបុរៈ, សម្ភកបដ្ដនៈ, ជយាពជបុរី, ស្រីជយសិង្ហបុរី, ស្រីជយវជ្របុរី, ស្រី-ជយស្ដម្ភបុរី, ស្រីជយពជគិរី, ស្រីជយវីរបុរី, ស្រីជយវជ្រវតី, ស្រីជយ-ក្ដីរបុរី, ស្រីជយក្សេមបុរី, ស្រីវិជយាទិត្យបុរី, ស្រីជយសិង្ហគ្រាម, មធ្យម-គ្រាមកៈ, សមវន្ទ្រគ្រាម, ស្រីជយបុរី, វិហារពេត្តរកៈ, បូរ៉ាវ៉ាស, និង កន្លែងទៀតសរុប ៤៣ ទៀត ។ ទ្រង់កសាងព្រះជយពុទ្ធមហានាថនិង មន្ទីរស្រង់ (ស្មានៈ) ១០ នៅឆ្នាស្រះយសោធរៈ ។ ទ្រង់បានកសាង

សាលាសំណាក់ តាមថ្នល់ពីក្រុងយសោធរបុរៈទៅរាជធានីចម្ប៉ា ៥៧ សាលា ។ ពីក្រុងយសោធរបុរៈទៅពិមាយ ១៧ សាលា ។ ពីក្រុងយសោធរបុរៈទៅក្រុងជយវតី តទៅជយសិង្ហវតី តទៅជយវីរវតី តទៅជយរាជគិរីតាមថ្នល់ ១៤ សាលា ។ សាលា ១ នៅក្រុងស្រីសូរ្យបពិត ១ នៅក្រុងស្រីវិជយាទិត្យបុរៈ, ១ នៅក្រុងកល្យាណសិទ្ធិកៈ, រួមចំនួន ១២១ សាលា ។

បញ្ជីរាយនាមព្រះពុទ្ធរូបធ្វើពីមាសប្រាក់សំរិទ្ធិថ្វាយច្រើនអង្គ . . .

ចូលរួមព្រមចំនឹងព្រះយមព្រះកាលផង នៅគ្រប់ខេត្តចំនួន ២០.៤០០ អង្គ ។ ចំណែកគោជនាហារគ្រឿងបូជាទៅតា នឹងគ្រឿងទំនុកចំរុងបុគ្គលិកដែលនៅជាមួយអធ្យាស្រ័យ នឹងនិស្សិតចាំងអស់ដូច្នេះ :

ស្រូវ: ១៨៣.១៩០ ខារិកា; អង្ករ: ៤.៥៣៣ ខារិកា, សណ្តែកជាមាស: ២.៤២៣ ខារ; ល្ង: ២.៥៤៥ ខារ; ទឹកដោះខាប់: ១.៦៦៤ ឃដី, ១០ ប្រស្ថ:, ២កុម្ភ:; ទធិនឹងគ្រឿង: ១.៧៦៦ ឃដី, ៣ប្រស្ថ:មួយមុខ; ទឹកឃ្មុំនឹងទឹកកេសដូងផ្អែម: ១.៦៤៣ ឃដី, ៦ប្រស្ថ:មួយមុខ; ប្រេងល្ង: ៥១៤ ឃដី, ២ប្រស្ថ: ប្រេងផ្លែឈើ: ២៣៦ ឃដី, ៤ប្រស្ថ: កន្ទុះ; ជ័រស្រល់: ២ ភារ:; ៥តុលា, ២កដ្ឋិកា, ១០បណ:, ឈើក្រឹស្ណ: មានខមូនដូចគ្នា; បន្ទះក្រឹស្ណ: ១ភារ:; ១តុលា, ១កដ្ឋិ, ១៨បណ:, កប៊ូរ: ១តុលា, ១កដ្ឋិ កន្ទុះ, ៥បណ:; ឈើតរុស្ក: ៤តុលា, ១៤កដ្ឋិកា

ញបណា:: ក្រមួន: ៣.២០០ការ:, ៣កដ្ដ, ១០បណា: គ្រឿងស្បៃក
ពាក់សម្រាប់ទៅតា ៧៥.៥២៥ ប្រដាប់ . . . , គ្រែ: ១.៦៦៦ ។
ព្រះរាជាព្រះរាជទានជាមួយអ្នកមានសព្ទាដទៃទៀត ៨.១៧៦ ស្រុក ។
មានបុរសស្រីជាទាសទាសី ២០៨.៥៣២ នាក់, បណ្ដាជនចំនួនខ្លះ
អត់រែក្ស ៤២៣ នាក់, កម្មករ ៦.៤៦៥ នាក់, ស្រី ៤.៣៣២ នាក់
រួមចំនួនស្រីសុទ្ធ ១.៦៦២ នាក់ផង ។

មាសសម្រាប់បទនាជាប្រាសាទ (ស្លឹបរ) នឹងវត្ថុផ្សេងៗទៀត
ជូបថាននជើងមូល នឹងគ្រឿងប្រើប្រាស់: ១៣៨ ការ: ១៤ កដ្ដិកា:
ប្រាក់: ១២១ ការ:, ១៤ កដ្ដិកា, ១១ បណា:: ស្ពាន់: ៣៤៣ ការ::
១ គុលា, ១ កដ្ដិកា, ៥ បណា:: សម្រឹទ្ធ: ៥. ៦០ ការ::
២ គុលា : ២ កដ្ដ: ថានមាស: ២០០ ការ:: ១ កដ្ដ, ១៦ បណា::
សំណ: ១៤ ការ:, ២ គុលា, ៤ កដ្ដិកា; សំណសុទ្ធ: ១.២០០
ការ:: ៥ គុលា: ដែក: ២.០០០ ការ:, ៧ គុលា, ៦ កដ្ដ:
រតនវត្ថុ ពេជ្រកែវពៃទូរ្យ ទឹម: ៨៧.៣២៨ គ្រាប់: គង:
១៦៩.២២២គ្រាប់: ប្រាសាទ (ស្លឹប?) ៥១៤: ក្រុមសំណង់ឥដ្ឋ
២.០៦ : ប្រាការ (កំពែង) ៤៦.៤៩០ ព្យាម: ដុំវិញតាងទឹក
៤៤.៦៤៨ព្យាម: ដុំវិញស្រះមានស្រះជយតដាក:ជារដើម: ៩៣ ៥០៧
ព្យាម: បន្ទប់: ១.៥១២: បុរសទៅជាមួយនិស្សែត: ២.៩៩៩ នាក់ ។

ក្នុងវិទ្ធផល្គុនពាល់ឆ្នាំ ព្រះពុទ្ធរូបចាំឆ្លាយដូចមានពាយព្រះនាម ខាងក្រោមត្រូវដង្ហែមកជំកល់ក្នុងទីនេះ (ប្រាសាទព្រះខាន់) គឺព្រះមុនីន្ទ្រៈ (ខាងកើត) ១អង្គ; ព្រះស្រីដយពាដចូរាមណី ១ អង្គ; ព្រះដយពុទ្ធមហា-នាថ ២៥ អង្គនៅ ២៥ ប្រទេស; ព្រះសុគតស្រីវីរសក្តិ១អង្គ; ព្រះសុគតពិមាយ១អង្គ; ព្រះកក្រេស្សរៈ១អង្គ; ព្រះបមេស្សរៈ១អង្គ;ព្រះបថុ-ម្មសៃលេស្សរៈ ១ អង្គ រួម ១២៦ ព្រះអង្គ ត្រូមចាំឆ្លាយគាជាបរិវារផង ។

គ្រឿងប្រដាប់ទំនុកបំរុងទេពតាចាំឆ្លាយនេះដែលត្រូវយកពីឃ្លាំង ព្រះពជ្រៃក្នុងទុកាសបុណ្យវិទ្ធផល្គុននេះ :

មាស: ៤ បាល:, ២កដ្ដី; ប្រាក់: ១៤កដ្ដី; សំណាស: ៤តុលា; គ្រឿងប្រដាប់ស្វែកពាក់ទេវតា ២៥៩ គូ; អង្គរៈ ១០០ ទាវតា; គ្រឿងក្រអូប: ១៤៣ ប្រអប់; ទឹកដោះខាប់ ទឹកឃ្មុំ, ទឹកកេសដ្ឋ: ផ្លែម: ១ឃដ្ដី; ១០ ប្រស្ន: ក្នុងមួយមុខ ។; ក្រមួនឃ្មុំ: ១តុលា, ៥ កដ្ដីតា; ដីរស្រស់, ឈើក្រឹស្ន: ៥ តុលា ក្នុងមួយមុខ ។; ទឹងនីងក្បែរ: ១ឃដ៏តា, ១០ប្រស្ន:ក្នុងមួយមុខ ។ ។

ព្រាហ្មណ៍ចាំឆ្លាយ មានព្រាហ្មណ៍ឈ្មោះស្រីសូរ្យកង្គជាដើម, ព្រះពជាវៃដរៈ (ជ្ជា). ព្រះពជាវៃយវៃនៈ (យួន) ព្រះពជាចាំង ពីរអង្គវៃចាម, ស្តេចយាងមកធ្វើពិធីស្នាន: ពិធីស្រង់ (ព្រះទឹកៈ) ព្រះពុទ្ធរូបដោយកក្តីពល់ ។ ថ្ងៃ ។

ក្នុងការទបត្តម្ភព្រះវិហារ «ជ័យស្រី» នេះ មានប្រុសស្ត្រីរួមទាំងជនជាតិ ចាម យួន ចូកាម (ចាគាន=កូមា) និងរ្យន[1] (Ryan) ផង មានចំនួន ៣០៦.៣៧២ នាក់ ស្រុកចំនួន ១៣.៤០០ ស្រុក, អង្គរជាគ្រឿងពុទ្ធបូជា ៤០០.១៦៦ ភារៈ។ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់បានបំពេញមហាកុសលទុំសថ្វាយព្រះពុទ្ធសាសនាដ៏អស្ចារ្យក្រៃលែង មិនទុនថយជាងព្រះបាទធម្មាសោកមហារាជប្រាកដដូច្នេះហើយ ព្រះរាជបុត្រស្រីវីរកុមារគ្រាស់សរសើរព្រះអង្គទុកក្នុងគាថា ១៦៧ ថា "សព្វបើព្រានព្រៃឈ្មោះអដៃតេន្ទ្រៈ គ្រាន់តែបានថ្វាយគ្គារមួយបន្តុះ ម្តេចទៅតើតបានតាពជាធំឈ្មោះ «តៃរៅសុរៈ»" ក្នុងឋានសួគ៌ទៅហើយ ចំណង់បើព្រះរាជាអង្គនេះ ដែលបានបូជាដោយអើពើចំពោះព្រះពុទ្ធ ចំពោះទេវតា ចំពោះព្រាហ្មណ៍ ចំពោះតាបស ដោយតគ្រាសន្តៈ ដោយប្រាសាទមាសតែរមណីនីធីភ្ញុកប្រាកដយ៉ាងនេះ (នឹងបានផលានិសង្សដែលម្ល៉ៅទៅទៀត?)។ ទីបំផុត ព្រះរាជកុមារចារបញ្ចប់សេចក្តីថា ៖

កត្តា ប្រកប្តសុកតានម្មិតានវជ្រមថ៌ាយ សោនៃបតិនិទិលាសុកាជាមិ-
កវ្វំស្តិមានិកុតលានិ បតិប្រកប្តកត្តា វិតេមត ឥតិ ប្រនិធីតាភេ។
បុណ្យវរមីកិរុកយាវរណាន្ធតាពនប្រជ្ញាកិរត្តិមីសវៃរីនិហត្យ សព្វៈ។

១- ជនជាតិ រ្យន នេះ មិនដឹងប្រាកដជាជាតិអ្វី, លោកលីនែសយល់ថា ប្រហែលជា ជា "ភមញ ពំមន ឬ ប៊ើញន" ។

វេធ បពនធគតាំកដតាំ កវាខ្វុត្តារណាយដគតាញ្ញនគោ មទីយ: ॥

"លុះបានបំពេញកុសលដ៏ច្រើនពាប់មិនអស់កល់ថ្ងៃ ជាប្រយោជន៍ដល់សត្វលោកយ៉ាងនេះហើយ ព្រះបាទជយវរ្ម័នទី ៧ ទ្រង់បានបំពេញព្រះរាជកុសលថ្វាយព្រះវរាជបិតា (ព្រះបាទធរណីន្ទ្រវរ្ម័ន) ដោយភក្តីភាពយ៉ាងវិសេសវិសាលថែមទៀត ហើយទ្រង់តាំងប្រនិធិទុំសព្រះរាជកុសលថ្វាយថា ។ ๑๗๑ ។

សូមអំណាចបុញ្ញាពសីដ៏ច្រើន ដែលផ្សាយចេញទៅតាមស្មើប្រាជ្ញា (ទ្រង់ទបត្ថម្ភគ្រូសិស្សក្នុងការសិក្សា) នឹងព្រះអាទិត្យ (ទ្រង់កសាងកំពូលប្រាសាទទំពូមាសក្នុងព្រាលរន្ធាល) កំចាត់បង់នូវមោហន្ធការដែលបិទបាំង (នូវបុញ្ញាពសីដែលព្រះវរបិតាខ្ញុំបានបំពេញ ទាំងពីរប្រការខាងលើនេះ) កាលថ្ងៃ ហើយសូមព្រះវរាជបិតាខ្ញុំបានសម្រេចពោធិញ្ញាណដែលជនជាតិពុំទាន់បាន ដើម្បីនឹងចម្ងងសត្វលោកឲ្យឆ្លងចាកមហាសាគរគឺត្រៃតភព (ទៅកាន់ត្រើយត្រាណអមតមហានិញ្ញានកុំបីខាន) ។ ๑๗๒ ។

ជាងៃពីនេះ ព្រះបាទជយវរ្ម័នទ្រង់បានកសាងថ្កល់ធំពីមហានគរទៅប្រទេសចម្ប (វៀតណាម) ដល់ក្រុងជាងពង (ចាណ្ឌវង្គ:) ឬក្រុងវិជយវៃត្រប៉ិញឌិញ (Binh-dinh) ទៅក្រុងពិមាយ (សៀម) ។ តាមថ្កល់ធំនេះ ទ្រង់បានសាង "សាលាសំណាក់មានក្តីង" ๑๒๑ សាលា, មួយៗចម្ងាយពីគ្នា ប្រហែល ๑๙ គីឡូម៉ែត្រ, ពីមហានគរទៅដល់ចម្ប

មាន ๔๗ សាលា, នៅក្នុងដីស្រុ ๑ ត្រមាំងមន្ទីរពេទ្យ ๑๐๒ (អាគារ-សាលា)ផង ។ មានសិលាចារឹកមួយ ។ នៅត្រង់មន្ទីរពេទ្យ ។ សិលា-ចារឹកនេះ រៀបរាប់ពីការឧបត្ថម្ភក្នុងមន្ទីរពេទ្យមានគ្រូពេទ្យ មានគិលានុ-បដ្ឋាក គិលានុបដ្ឋាយិកា ។ល។ ក្រោមអធិបតីភាពព្រះសុគត គឺគ្រូពេទ្យ ឈ្មោះ "ជៃយជយវរ្ម័ន ព្រះបរមសុគត" នឹងបុត្រព្រះជនស្រីពីរព្រះអង្គទៀតគឺ សូរ្យវៃរោចន:នឹងចន្ទ្រវៃរោចន: ។ ជនវណ្ណ:ចាំង ๔ ទៅព្យាបាលរោគនៅ មន្ទីរពេទ្យបានជួចគ្នា ។ បុគ្គលិកធ្វើការមាន: គ្រូពេទ្យ ๒ នាក់ គ្រូ ពេទ្យរង ๓ នាក់: ប្រុស ๑, ស្រី ๒ (មន្ត្រីសុខាភិបាល); ឱសថបាល (អ្នករក្សាឃ្លាំង) ๒ នាក់; បាចក: (អ្នកគ្រួ) ๒ នាក់; យជ្ញហារី (អ្នក បូជា) ๒ នាក់; អាគារសាលាសំរាប់ (គិលានុបដ្ឋាក) ๑๔ នាក់, ស្រី ๘ នាក់ ពីរនាក់សម្រាប់បុគអង្គរ ។ ក្រៅពីនេះ រៀបរាប់ពីអាហារ ភោជនទីឆ្ងាសៃសដ្ឋ:តែរោគ ។

កិច្ចការចាំងនេះ សំដែងឲ្យឃើញថា ព្រះបាទជយវរ្ម័នទី ๗ ទ្រង់ ប្រកបដោយព្រះមហាករុណាគុណដ៏ធំក្រៃលែង ដូចសិលាចារឹកនេះ ពោលបញ្ជាក់ថា :

ពុទ្ធា សុគតាតិ ប្បថ្ថំ មត្វាមរណទុបតាមិ។
មត្វាណាមមរត្តាយ យោ ទិតុច្ចជាមតម្ ॥ ๑๐ ॥
ប្ប ប្ប
បុប្ប្យ តតិ តតិតត្ប យោ តតោ វមិ។
ប្ប ប្ប

ภวสงฺขารนิสฺสชฺชี กตฺตา ตฺริยุคเสวโก: ॥ ๑๑ ॥

ชีตาสงฺเคหิ ปาปิโม สิรึ ตฺรีกุฬนาฬิณี।

ปมาเต นิรเย ปาเต ปาเปหิ ยมปุปฺผลีตก: ॥ ๑๒ ॥

เอวมาสุเหวเคยฺย- (สุ สุวเค) เสา วุฏฺฐภิมิ।

ภวฺหุ:วา หิ ตถาคโต หุ:วา หุ:วาปิ นาคุน: ॥ ๑๓ ॥

"ข้าแต่ (พระบาทยวุ้นที่ ๗) ผู้ประเสริฐ ข้าพเจ้าขอถวายบังคมแด่พระองค์ ผู้ที่ข้าพเจ้าได้กราบทูลไว้ก่อนแล้วว่า ขอพระองค์ทรงโปรดประทานพระวโรกาสแก่ข้าพเจ้าด้วยเถิด

"ទ្រង់ខ្វាចផ្សាវក្រៃលែង ចំពោះពេកនៃជនអ្នកមានពាធកាយ ប្រជាជនព្រះអង្គ) ជាងព្រះអាពាធផ្ទាល់ព្រះអង្គ ព្រោះថា ទុក្ខកាស្ត្រ ជាទុក្ខនៃអ្នកគ្រប់គ្រង (គឺព្រះរាជា) ចាំងឡាយ តាំមែនចំពោះទុក្ខផ្ទាល់ ព្រះរាកាយព្រះអង្គឡើយ ។ ๑๓ ។

ទីបំផុត ទ្រង់តាំងចិត្តប្រកបដោយមេត្តាដ៏ជ្រាលជ្រៅ ហើយទ្រង់ តាំងប្រណិធីថា "សូមឲ្យខ្ញុំបានចម្ងន់សព្វសត្វតាំងអស់ដែលលិចលង់នៅ ក្នុងសាគរវេលវដ្តសង្សារគឺត្រៃតពនេះ (ទៅជាក់ដល់ត្រើយត្រាណអមត- មហានិព្វាន) ដោយតេជកុសលដែលខ្ញុំបានសាងនេះកុំបីខានឡើយ ,, ។

ក្នុងបច្ចុប្បន្នកាល ព្រះអង្គទ្រង់សាងប្រាសាទជ័យន ទុំសម្ងាយ ព្រះពុទ្ធសាសនានៅចំមជ្ឈមណ្ឌលព្រះមហានគរលើកជំភើងព្រះកិត្តិយស ដើម្បីដំកល់ព្រះបដិមាកព្រះអង្គដែលទុកជាតួអង្គ "ពុទ្ធពាជ" ជំនួសអង្គ "ទេវពាជ" (លិង្គមាស) ពីបូព៌ាណាកាល មិនតែប៉ុណ្ណោះទេ សូម្បីពោធិសត្វ លោកេស្វរៈសមន្តមុខដែលនៅគ្រប់កំពូលប្រាង្គប្រាង្គ បែរព្រះកត្តញ្ញូញ្ញឹម ទៅគ្រប់ទិសទាំង ៤ ក៏ទុកជាតួអង្គទ្រង់ដែរ ។ សិលាចារឹកនៅប្រាសាទ ជ័យនថ្ងៃឯបញ្ជាក់ថា ប្រាសាទនេះ ជាមជ្ឈមណ្ឌលការគោរពសកល ទេពបូជានៃព្រះពាជវង្សានុវង្សនៃធានាទេត្តទាំងដែនសីមានៃប្រទេស

(មានត)

បិត្តដឹកនាំលោក

ព្រះពុទ្ធឯង កែម-តូរ រៀបរៀង

ចិត្តេន នីយតិ លោកោ[1]

លោកត្រូវបិត្តដឹកនាំ

អត្ថបទនេះ មានអត្ថាធិប្បាយជា ៣ បទ គឺអំពីលោក ១ បទ ចិត្ត ១ បទ អាការដឹកនាំ ១ បទ ដូចតទៅនេះ

លោកគឺអ្វី ?

សភាវៈ ដែលតតើតមានឡើងហើយ មិនតាំងនៅដោយខៀងខាត់ តែងតែបែរឈឺមមុខទៅរកសេចក្តីវិនាសបាត់បង់ សូឡៃទៅវិញ ក្នុងពេលណាមួយ ហៅថា លោក ។ មានច្រើនជាអនេក ប៉ុន្តែបើបំប្រញចុះមកមានត្រឹមតែ ៣ គឺសង្ខារលោក ១ សត្តលោក ១ ឱកាសលោក ១ ។

រូបធម៌ទំនងអរូបធម៌ចាំងឡាយដែលតើតឡើង ដូចជាពួកសត្វចាំងអស់ដែលមានអត្តភាពតាំងនៅបានដោយសារអាហារក្តី នាមទំនងរូបក្តី វេទនា ៣ យ៉ាង មានសុខវេទនាជាដើមក្តី អាហារ ៤ យ៉ាងមានកវឡិង្ការាហារជាដើមក្តី អាយតនៈខាងក្នុង ៦ មានចក្ខាយតនៈជាដើមក្តី វិញ្ញាណ-

---

១- ធម្មបទ ខុទ្ទកនិកាយ ។

ដ្ឋិតិ ៧ មានឧបាទត្តកាយ ឧបាទត្តសញ្ញី (ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាក៏ផ្សេងគ្នា) ជាដើមក្តី លោកធម៌ ៨ យ៉ាង មានលាភៈនិងអលាភៈជាដើមក្តី សត្តាវាសៈ ៩ យ៉ាង មានវិញ្ញាណដ្ឋិតិ ៧ ជាដើមក្តី អាយតនៈ ១២ មានចក្ខាយតនៈនិងរូបាយតនៈជាដើមក្តី ធាតុ ១៨ យ៉ាង មានចក្ខុធាតុជាដើមក្តីប៉ុណ្ណោះជាដើម ហៅថា សង្ខារលោក ប្រែថា លោក គឺសង្ខារដែលជានាទីវាងតាក់តែងឲ្យចំរើន-ឲ្យវិនាស ។

ពួកមនុស្ស ទាំងបុរស ទាំងស្ត្រី ទោះមានបុណ្យ ឬឥតបុណ្យ មានកិលេសឬឥតកិលេស, មានប្រាជ្ញាឬឥតប្រាជ្ញា, ល្អឬអាក្រក់ក្តី ពួកអមនុស្ស មានទេវតា, មារ, ព្រហ្ម, យក្សនិងគន្ធព្វជាដើមក្តី តែងអាស្រ័យនៅក្នុងលោកទាំងបី ។ ប្រែកន្លះសត្វទាំងអស់នេះ រួមមកតែពាក្យមួយហៅថា សត្តលោក ប្រែថា លោក គឺពួកសត្វ ។

លោកទាំងមូលដូចជាកន្ទរសម្រាប់រនៃទ្រុត្រួតគ្នា គឺឲ្យលំទ្រំតែទ្រុដីៗ ទ្រុទុច្ចាទិដ្ឋកសង្ខារ គឺសង្ខារដែលមានវិញ្ញាណមានមនុស្សសត្វជាដើម ធំងអនុច្ចាទិដ្ឋកសង្ខារ គឺសង្ខារដែលឥតវិញ្ញាណមានរុក្ខជាតិ, តិណជាតិ ធំងភ្នំថ្មជាដើម ឬសំដៅយកដែនចក្រវាឡទាំងមូល ឬក៏សំដៅយកទុតាសដែលព្រះកាតិត្យ ធំងព្រះចន្ទដើរបំភ្លឺលោកអស់ទីត្រឹមណាទីត្រឹម នាំហៅថា ទុតាសលោក ប្រែថា លោក គឺទុតាស ។ ពាក្យថា លោកនេះ ទេមរដនយើងប្រើនន័យមកប់អានថាជាពាក្យថ្លូថ្លា ពាក្យគួរ

សម សម្រាប់ប្រើហៅមនុស្សអ្នកមានបុណ្យយសស័ក្តិអំណាច ឬហៅ
ព្រះសង្ឃខ្លះ តែបើតាមពិត ពាក្យថា លោកនេះ ជាពាក្យសាធារណៈ
អាចហៅបានគ្រប់សត្វនិងសង្ខារទាំងអស់ ។ អ្នកប្រាជ្ញខាងធម្មសាស្ត្រ
មានព្រះពុទ្ធជាដើម តែងប្រមូលយកសង្ខារទាំងមានវិញ្ញាណ ទាំងឥត
វិញ្ញាណ ហៅថា លោក ព្រោះយល់ថាលោកនេះ ដែលកកើតឡើង
ជារូបកាយហើយ មិនដែលតាំងនៅទៀងទាត់ទេ រមែងតែបម្រែបម្រួលក្នុងខាង
ដើម ប្រែប្រួលក្នុងវាងកណ្តាល ហើយត្រូវបាត់បង់ទៅវិញទៅទីបំផុត ។

ន័យមួយទៀត ពាក្យដែលយើងនិយមប្រើហៅឈ្មោះសត្វ នឹង
សង្ខារសព្វថ្ងៃនេះ ដូចពាក្យហៅថា មនុស្ស សត្វ ប្រុស ស្រី ឈើ ក្នុង
ថ្ម ។ល។ សុទ្ធតែជាពាក្យលោកវោហារទាំងអស់ គឺជាសំដីនិយាយហៅ
ដោយការសន្មតទៅតាមគេទេ លក្ខណៈ អាការ លំនាំរបស់សត្វនិង
សង្ខារ ដែលផ្សេងគ្នាប៉ុណ្ណោះ មិនមែនជាសំដីពិតទៅតាមផ្លូវបរមត្ថ-
សាស្ត្រទេ, បើនិយាយហៅតាមផ្លូវបរមត្ថសាស្ត្រវិញ ទើបជាពាក្យពិត ។
បើយើងត្រូវការរៀនសេចក្តីពិតក្នុងរឿងនេះ ត្រូវយកមនុស្សម្នាក់មកឲ្យ
នៅក្នុងទីចំពោះមុខ ហើយយើងពិចារណាវែកញែកពាក្យដែលគេហៅថា
មនុស្សនោះមុខជានឹងរកពុំឃើញឡើយ គឺឃើញតែធាតុដី ធាតុទឹក ធាតុ
ភ្លើង ធាតុខ្យល់ ទាំងអស់, បើដូច្នេះ តើពាក្យថា មនុស្សប្រុសស្រី នៅ
ត្រង់ណា ? ឯសង្ខារទាំងពួងក៏ដូច្នោះដែរ ។ តាហរណ៍ដូចពាក្យដែលយើង

ហៅថាផ្ទះ ថាសាលា បើយើងពិចារណាវែងវែងទៅយើញតែសសរ
ជ្រុង ជាន បង្គន់ ដែរណែន ។ល។ មានឈ្មោះដោយច្រើន ។ ពីគ្នាចាំង
រស់ បើដូច្នេះតើពាក្យថាផ្ទះ ថាសាលា នោះនៅត្រង់ណា ? ហេតុនោះ
ពាក្យថាមនុស្សស្លូតស្រីប្រុសផ្ទះសាលា ។ល។ ជាពាក្យហៅដោយសន្មតិ
តាមលោកវោហារ មិនមែនពាក្យពិតតាមផ្លូវបរមត្ថសាស្ត្រទេ ។
ព្រោះនាគុដែលមានឈ្មោះគេហៅដោយពាក្យជាលោកវោហារក្តី ដោយ
ពាក្យបរមត្ថក្តី រួមមកហៅថា លោក ។ ដូចគ្នាចាំងអស់ ។

ព្រោះហេតុនោះ លោកចាំង ៣ ដូចបានពណ៌នាមកក្នុងខាងលើ
គឺសង្ខារលោក ជាអ្នកកាន់តំណែងខាងបង្កបង្កើតសត្តលោកនឹងតុសា-
លោក, តុសាលោកដែលកើតឡើងដោយអំណាចសង្ខារលោកនោះ
ជាអ្នកកាន់តំណែងខាងស្តុយទ្រុសត្តលោក ឬជាលំនៅនៃសត្តលោក ។
ដែលកើតឡើងតាស្រ័យសង្ខារលោក នឹងតុសាលោកជាបង្អែកហើយ
ទើបញ៉ាំងជីវិតាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមលោកនិយម ។ ឯលោក
ដែលប៉ះប៉ូនឥតលើកយកមកនិយាយក្នុងផ្នែកអត្ថបទនេះ សំដៅយក
សត្តលោក គឺប្រជារាស្ត្រទូទៅគ្រប់ប្រភេទ ។ ប្រជារាស្ត្រដែលបានទទួល
អំណោយរបស់តំរើ គឺសេចក្តីល្អ តាក្រត់, សុខទុក្ខ, បុណ្យបាប,
គុណទោស, ទុស្សត្រូវជាដើម តាស្រ័យនូវចិត្តជាប្រធាន ។

បិដ្ឋគីរ្ស៎

បណ្តាពួកសត្វទាំងអស់ក្នុងលោកនេះ មិនមានពួកសត្វណាមួយ ប្រសើរជាងមនុស្ស, ក្នុងគ្រាន់តាយរបស់មនុស្សទាំងមូល មិនមានធម្ម-ជាតអ្វីប្រសើរជាងចិត្ត ។ ធម្មជាតជានាមធម៌មួយយ៉ាងដែលសម្រេច ទាងការគិត គឺហៅយរូប (បេះដូង) ដែលជាបន្ទប់មួយមានទឹកដក់នៅ អាចបញ្ចេញចំហាយគឺសេចក្តីដឹង សេចក្តីត្រិះរិះផ្សេង ។ ជាទីតាំងឲ្យកើត វិញ្ញាណនឹងសតិបញ្ញាដែលអាចធ្វើឲ្យរូបកាយមានចលនា (តម្រើក) គ្រប់ គ្រងយោបថទាំងបានហៅថា ចិត្ត ។ ចិត្តនេះគឺជាវិញ្ញាណហ្នឹងឯងដែលវិចិត្រ ដោយភូមិវិត្ត អារម្មណ៍នឹងកិរិយាជាដើម បិតនៅក្នុងមហាភូតរូបគឺគ្រាន់ តាយរបស់មនុស្ស, ឥតមានសរីរៈខ្លួនប្រាណពណ៌សម្បុរសណ្ឋានទ្រង់ ទ្រាយអ្វីជាគ្រឿងប្រាកដសោះទេ ប៉ុន្តែជាធម្មជាតសំខាន់បំផុត អាចនឹង គិតត្រិះរិះរាវរក ឬទទួលយកអារម្មណ៍ផ្សេង ។ មានរូបារម្មណ៍ជាដើម បាន, អាចសូនគ្រាចំទៅតែម្នាក់ឯងគាន់ទីដឹងតទីឆ្ងាយបាន ដោយដំណើរ ជីវហ័សត្រៃលេងគ្មានអ្វីប្រៀបប្រដូច, យើងនិយមយល់ថា បណ្តារបស់ ដែលមានក្នុងលោក គ្មានរបស់អ្វីលឿនវហ័សត្រៃលេងជាងគម្នាំងអគ្គិសនី ទេ សំខុនគម្នាំងអគ្គិសនីនេះលឿនវហ័សក៏ពិតមែន ប៉ុន្តែនៅមិនទាន់ស្មើ នឹងសំខុនរបស់ចិត្តឡើយ, ចិត្តនេះមានលឿនវហ័សត្រៃលេងជាងគម្នាំង

អត្ថិសនីទៅទៀត ។ បិត្តនេះ បើតាមប្រក្រតីដើមដែលមិនមានទុបក្កិលេសអ្វីធ្វើឲ្យកែវរវេ, មានពន្លឺថ្លាស្អាតល្អណាស់ ពាំនាំចាប់ធ្វើឥន្ទ្រិយគឺចក្ខាយពាំនាំមូល មានចីតមុខ សាច់ឈាម ពណ៌សម្បុរជាដើមរបស់ខ្លួនឲ្យភ្លឺថ្លាស្រស់បស់ផងដែរ, តួយ៉ាងដូចកូនក្មេងដែលនៅតូច ។ ជាបណាតិលេសគ្រឿងសៅហ្មងអាក្រក់ មិនទាន់ដុះចំរើនកើតមានឡើងក្នុងសន្តានចិត្តរបស់វាទេ ជាបនោះ សាច់ឈាមសម្បុរបស់ក្មេងនោះ ឃើញនៅភ្លឺថ្លាស្អាតស្រស់បស់ល្អ ព្រោះចិត្តថ្លាស្អាតនោះឯងជាហេតុ ឫដូចបុគ្គលដែលបានសម្រេចគុណវិសេសជាន់ខ្ពស់ លោកមានចីតមុខសាច់ឈាមឡើងថ្លាស្អាតស្រស់បស់ល្អជាងតាលនៅជាបុប្ផជន, រឿងនេះយើងមិនបានឃើញផ្ទាល់ដោយចក្ខុទេ តែបានដឹងតាមសេចក្តីតំណាលក្នុងគម្ពីរផ្សេង ។ ថា បុគ្គលដែលប្រតិបត្តិអប់រំដុះខាត់ចិត្តឲ្យស្អាតចាកតិលេសគឺ ពគ: ទោស: មោហ: គ្រឿងសៅហ្មងអស់ពីសន្តានចិត្តហើយ ចិត្តរបស់លោកតំណើនឡើងភ្លឺថ្លាស្អាត ពាំនាំសាច់ឈាមសម្បុរកាយរបស់លោកតំណើនភ្លឺថ្លាស្អាតផងដែរ ពាំនាំឥន្ទ្រិយរបស់លោកសោតទៀត តំស្រគត់ស្រគំរមែរមល្អ គួរឲ្យអ្នកដែលបានជួបប្រទះឃើញលោកមានសេចក្តីជ្រះថ្លាវិកែលែង ។

បិត្តនេះ ជាធម្មជាតភ្លឺថ្លាស្អាតល្អពិតមែន ប៉ុន្តែដែលទៅជាងងឹតស្រអាប់ចាត់ពន្លឺថ្លាស្អាតទៅវិញនោះ តំណាលដោយអំណាចទុបក្កិលេសមានរាគៈជ្ឈា

ន៏ឯងមានសម្បុរដ៏ជោគ ប្លែកមកគ្រប់សង្កត់រូបរឹតញាំញីជានិច្ច ធ្វើឲ្យទៅជាចិត្តវិបរិតប្រែប្រួលខុសអំពីប្រក្រតីដែរ ទាំងសាច់ឈាមសម្បុរបស់បុគ្គលនោះសោតទៀត ក៏ទៅជាត្រោតត្រោតស្រអាប់អាក្រក់ទៅតាមផងដែរ ដូចបុគ្គលដែលកំពុងមានចិត្តសោមនស្ស សាច់ឈាមសម្បុរបស់បុគ្គលនោះ ក៏ឡើងភ្លឺថ្លាល្អ ឯបុគ្គលដែលកំពុងមានចិត្តទោមនស្ស សាច់ឈាមសម្បុរបស់បុគ្គលនោះ ក៏ប្រែជាត្រោតត្រោតជាស្រអាប់អាក្រក់ទៅតាមដែរ ព្រោះតែចិត្តដែលថ្លាស្អាតនឹងចិត្តដែលសៅហ្មងនោះឯងជាហេតុ ។

អាការរបស់ចិត្ត

ចិត្តជាធម្មជាតក្រៀចក្រឡុចពិបាករក្សាជាទីបំផុត ជាងរបស់អ្វី ៗ ទាំងអស់ ព្រោះចិត្តនេះ មានតណ្ហាមាយាចេញទៅជាអាការច្រើនយ៉ាង ។ ក្នុងទីនេះ សូមអធិប្បាយដោយសង្ខេបចំពោះតែអាការរបស់ចិត្ត ៤ យ៉ាង គឺចិត្តនេះតែងត្រាច់ស្ទុះស្ទាត់ធ្លាវរវាមកវរកអារម្មណ៍ដែលមិនធ្លាប់មានឬអារម្មណ៍ដែលមាននៅក្នុងអនាគតខាងមុខ ៗ នោះ ១ ចិត្តនេះតែងអន្ទះសារធ្លាក់ទៅមកជានិច្ច មិនចេះនៅនឹងស្ងៀម ទាំងជំណើរដែលស្ទុះចេញទៅនោះសោតទៀតក៏ទៅតែម្ចាស់ ឯង មានសំឡុះលឿនហ័សក្រៃលែងគ្មានអ្វីប្រៀបដូចបាន ១ ចិត្តដែលស្ទុះស្ទាត់ទៅមកដោយហ័ស

ស្មែនរកអារម្មណ៍ក្នុងទិសផ្សេង ។ នោះ តំមន្ត្រាតដដល់មំសចក្ខុរបស់ខ្លួនឬរបស់អ្នកដទៃ ១ ចិត្តនេះតែងត្រេតសប្បំភរម្រាកអាស្រ័យនៅក្នុងគុហា គឺមហាកូតរួបបួន ១ ។

ចិត្តនេះ ជាធម្មជាតល្អិតធ្លាយ៉ាងក្រៃលែង ពាំងកើត ពាំងរលត់ តំហ័សហួសវិស័យនឹងប្រដូច នឹងឃើញបាន ពាំងការខ្ជាន់ឈ្លានរក្សាចិត្ត នោះឲ្យតាំងនៅនឹងជាប្រក្រតី កំក្រណាស់ លុះតែអ្នកប្រាជ្ញខាងចិត្ត-សាស្ត្រ ធ្លាប់សិក្សាអប់រំ ធ្លាប់រិះគិតពិនិត្យពិចារណាខាងផ្លូវចិត្ត ទើបអាចឃុំគ្រងរក្សាការពារចិត្ត ឲ្យតាំងនៅនឹងតាមបំណងខ្លួនបាន សមដូចព្រះពុទ្ធកាសិតក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា :

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ

ចិត្តនេះ ជាធម្មជាតល្អិតធ្លាណាស់ ផុតវិស័យបុគ្គលនឹងឃើញបានដោយងាយ តែងធ្លាក់ចុះទៅក្នុងអារម្មណ៍ណាមួយតាមចំណង់របស់ខ្លួនដោយឥតបើគិត ឥតដឹងប្រមាណខ្លួន គឺមិនដឹងថាដែលត្រូវបាន នឹងថាដែលមិនត្រូវបាន, មិនដឹងថាដែលគួរ នឹងថាដែលមិនគួរ, មិនចេះគិតលៃមើលជាតិ គោត្រ ត្រកូល នឹងវ័យរបស់ខ្លួនឬរបស់អ្នកដទៃទេ ចេះតែតស៊ូលដ្រកមមកទៅសព្វកន្លែងឥតមានចន្លោះត្រង់ណាឡើយ ។

(មានត)

ព្រះមហា ឈឹម-ឆង រៀបរៀង

ចំរំ តំដួតុ សាសនំ

សូមឲ្យព្រះពុទ្ធសាសនា ទ្រង់នៅជាស្ថាពរ អស់កាលយូរ !

សុភាសិតខ្មែរនេះ ដូចគ្នានឹងពាក្យសម្រាប់សូត្របន់ សូត្របួងសួងដែរ តែវិធីធ្វើ ដើម្បីជួយទ្រទ្រង់ ជួយរក្សាព្រះពុទ្ធសាសនានោះតើ ត្រូវធ្វើដូចម្តេច ? ។

បញ្ហានេះ ព្រះសង្គីតិកាចារ្យចាំនឡាយ លោកពិចារណាឃើញច្បាស់មកហើយ ហើយចាំនឡានប្រជុំព្រះថេរានុត្ថេរៈ ដំនុំដំរះព្រះធម្មវិន័យឲ្យបានត្រឹមត្រូវតាមព្រះពុទ្ធវចនៈ ចាត់ឲ្យជាវគ្គ ជាកង ជាពួកខ្មែត មូលមតិគ្នាយ៉ាងណាហើយ ក៏នាំគ្នាសូត្រស្មូធ្យាយព្រះពុទ្ធវចនៈនោះ ។ ព្រមគ្នាម្តងខ្មែត ហៅថា សង្គីតិ នេះជាវិធីមួយ ដែលជួយទ្រទ្រង់ជួយរក្សាព្រះពុទ្ធសាសនា ឲ្យបានទ្រង់នៅជាស្ថាពរ អស់កាលយូរលង់ ។

ពាក្យថា សង្គីតិ ឬ សង្គាយនា នេះ ប្រែថាសូត្រព្រមគ្នា ប៉ុន្តែវេលាជាដំបូង ពុំទាន់មានចារជាអក្សរទៅទៀយទេ រីឯទ្រទ្រង់

រីឯរក្សាព្រះពុទ្ធសាសនាវិលានោះ សុទ្ធតែទន្ទេញឲ្យចាំមាត់ សូត្រ
ដោយមាត់ទទេ បានពាន់អស់គ្នា រីឯនេះឡើមកយូរហើយ កាលព្រះពុទ្ធ
ទ្រង់ព្រះជន្មនៅឡើយ ព្រះសារីបុត្រក៏បានធ្វើជាទូតហារណ៍មកហើយ
ដែរ ដូចមានរឿងរ៉ាវនិទានមកថា:

ថ្ងៃមួយ ព្រះពុទ្ធជាម្ចាស់ ទ្រង់ស្តេចយាងព្រះចាកភៅដែនមល្ល:
លុះដល់នគរបាវ៉ា ជាភជធានីនៃដែននោះឯង ពួកស្តេចមល្ល: ទ្រង់
ជ្រាបដំណឹងនោះហើយ ទ្រង់បានអាភធនាទិមន្តព្រះដ៏មានបុណ្យជាម្ចាស់
ដើម្បីសូមព្រះអង្គទ្រង់យាងភៅប្រថាប់នៅឯមន្ទីរសណ្ឋាគារ គឺទីស្តីការ
ភជការដែលទើបស្ថាបនាហើយថ្មីៗ ព្រះអង្គទទួលព្រះភជនិមន្តហើយទ្រង់
ស្តេចយាងភៅប្រថាប់នៅទីនោះឯង បានពាន់ទ្រង់ត្រាស់សំដែងធម
ប្រោសប្រាណ ដល់ស្តេចមល្ល:យ៉ាងវិចិត្រពិស្តារ ដល់ពេលយប់យាន់
ទៀតផង ទើបទ្រង់បញ្ចប់ធម៌ ។ ចំណែកស្តេចមល្ល:នោះសោត ក៏ទ្រង់
ព្រះសណ្តាប់ដោយគោរព ដរាបដល់ចប់តុំមានប្រមាទសោះឡើយ ។ ទើប
ក្រាបថ្វាយបង្គំលាយាងត្រឡប់ភៅវិញ ។ ខណៈនោះ ព្រះសម្ចាសម្ពុទ្ធ
ទ្រង់ពិចារណាឃើញថា វេលានេះ បណ្តាភិក្ខុសង្ឃដែលតាមភៅបាមព
ព្រះអង្គភៅក្នុងទីនោះ តុំពាន់ផ្ទុយសឹងនៅឡើយ ទើបត្រាស់បង្គាប់
ឲ្យ ព្រះសារីបុត្រសំដែងធម្មីកថាដល់ភិក្ខុពាន់នោះ បន្តិចភៅទៀត

ព្រះសារីបុត្រ លុះទទួលព្រះពុទ្ធដីកាដែលត្រាស់បង្គាប់មកដូច្នេះ ហើយ ក៏ផ្តើមពាក្យប្រារព្ធដល់រឿងនន្ទនាជបុត្រ ជាសាស្តាចារ្យ ម្នាក់ជាមុនដំបូង ។

នន្ទនាជបុត្រ[1] ដែលព្រះសារីបុត្រប្រារព្ធដល់នោះឯង ដែលជាអ្នកតាំងសាសនាដេនឬដេនស្ន ក្នុងប្រទេសឥណ្ឌៀ ដំនាន់ព្រះពុទ្ធជាម្ចាស់របស់យើងនេះដែរ លោកកើតក្នុងនគរវេសាលី ដល់អាយុបាន ៤០ឆ្នាំ លោកបានបំពេញវត្ត ហើយគ្រាចំពៅប្រៀនប្រដៅជនាទុជន ក្នុងដែនមគធៈនឹងវេទេហៈ ឲ្យនិយមកប់អាន កាន់តាមលទ្ធិរបស់គាត់ ដូចប្រាកដមកថា វេលានោះ មានមនុស្សនិយមកប់អាន កាន់សាសនាដេន ឬដេនិស្តប្រហែលជា ៩មុឺន ៨០០០ នាក់ដែរ លុះដល់ចាស់ជាមានរោគាពាធមកបៀតបៀន ក៏ធ្វើមរណកាលកន្លងបង់ទៅ នៅទីត្រុងបាវ៉ា ដែនមល្លរដ្ឋ តែដែនជាមួយគ្នានឹងដែនដែលព្រះពុទ្ធទ្រង់បរិនិព្វាននោះឯង ផ្សែងតែទីត្រុងប៉ុណ្ណោះ ចំណែកឯវោ តែពាក្យប្រៀនប្រដៅរបស់គាត់នោះសោត ដែលជាគោលធំៗ ក៏ប្រហែលគ្នានឹងពាក្យប្រៀនប្រដៅខាងព្រះពុទ្ធសាសនាខ្លះដែរ តែដែលខុសគ្នាក៏មានច្រើនដូចយ៉ាងទំនៀមទម្លាប់អ្នកបួស ក្នុងសាសនានោះ គ្មានអនុញ្ញាតឲ្យស្លៀកដណ្តប់បិទបាំងកាយសោះដូច្នេះហើយ ដែលសិក្ខានុសិស្សជា

១- នន្ទនាជបុត្រនឹងមហារីនាជបុត្រប្រហែលជាឈ្មោះរបស់មនុស្សតែម្នាក់ទេ ។

សាវ័កបេសក់គាត់ទៅក្រោយ តែប្រែលទ្ធិជាថ្មីទៀត ។

កំហុស ដែលកើតមកពីការកែលទ្ធិនោះ លោកសំដែងមកថា លុះនិគន្ថនាដបុត្រនោះ ស្លាប់បង់ទៅហើយ មិនយូរប៉ុន្មាន សិស្ស-នុសិស្សរបស់គាត់ ក៏កើតហេតុទាស់ទែងទ្វេនគំនិតគ្នាទៀត ពីរឿងតែប្រែលទ្ធិនោះឯង ដាច់បដល់បែកគ្នាជាពួកជាក្រុមទៀត ក្រុមណាដែលភ្ជាប់វិស្សាសៈរាប់អាននឹងសង្ឃ ក៏បានយករឿងមកដំណាលប្រាប់ដល់សង្ឃថែមទៀត ហេតុការណ៍ខើបបានខ្ចរខ្ចាយសាយសព្វទៅដោយហ៊ាស ព្រះសារីបុត្រនិងានរឿងនិគន្ថនាដបុត្រ នឹងសាវ័កបេសក់គាត់ ជាទៀបណ៌រួចហើយ មកផ្តៀងសង្ឃវិញថា សង្ឃ យើងកុំធ្វើដូច្នោះ ព្រោះធម្ម-វិន័យព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង ទ្រង់បញ្ញត្តទុកមកសព្វគ្រប់ហើយ ល្អ-បរិសុទ្ធគ្រប់ប្រការ, លុះផ្តៀងសង្ឃយ៉ាងនេះរួចហើយ ព្រះសារីបុត្រ ក៏ផ្តើមនូវធម្មទេសនា រួបរួមធម៌គ្រប់ប្រការ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងរួចមកហើយ ឲ្យបណ្តាកិក្ខុសង្ឃទាំងនោះបានស្តាប់ម្តងទៀត ជាវគ្គ, ជាកង់ជាពួក។ តាំងពីពួកទី ១ មានធម៌ ១ · ដល់ពួកទី ១០ មានធម៌ ១០. ជាដើម។ ហើយប្រៀនប្រដៅឲ្យទន្ទេញឲ្យចាំស្តាត់ ឲ្យសូត្រដោយមាត់ទៅត្រមគ្នាជាទាងក្រោយ លុះចប់ធម្មទេសនាហើយ ខណៈនោះ ព្រះពុទ្ធទ្រង់ប្រទានពរសព្វសាធុការបីដង មិនតែប៉ុណ្ណោះ បានទាំងទ្រង់ត្រាស់សរសើរទៀតថា ព្រះសារីបុត្រ បានសំដែងធម្ម-

បរិយាយល្អហើយ ប្រពៃហើយគ្រប់ប្រការ គួរតែក្តុបរសៃបដិបត្តិតាម
ចុះ ប្រយោជន៍នឹងបានដួយច្រើនដំ ដួយរក្សាព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនា ដូចវិសជ្ជនាមកដូច្នេះ កំតំធម្មវិន័យនេះឯង
គ្មានផ្សេងគ្នាឡើយ តែធម្មវិន័យនេះ ដល់មកក្នុងសម័យសង្គាយនា រួម
ជាព្រះត្រៃបិដកវិញ ត្រូវចែកចេញជា ៣ ប្រការ គឺវិនយបិដក សុត្តន្ត-
បិដក នឹងអភិធម្មបិដក ។ ដែលត្រូវចែកយ៉ាងនោះ ពីព្រោះព្រះអរ-
ហន្តខីណាស្រពាំងឡាយ ចំនួន ៥០០ អង្គ មានព្រះមហាកស្សបជា
ប្រធាន ប្រាថ្នានឹងឲ្យព្រះពុទ្ធសាសនាច្រើនៅជាស្ពាតរ អស់កាល
យូរនោះឯង ផ្សេងតែមូលហេតុដែលត្រូវប្រារព្ធដល់ប៉ុណ្ណោះ ព្រះសារី-
បុត្រ ប្រារព្ធដល់រឿងនិគន្ថនាដបុត្រ សុគតទៅហើយ សិស្សានុសិស្ស
ជាសាវ័កនៅក្រោយ តំតើតហេតុថាស់ខែងវែងគំនិតគ្នាឡើង ពីរឿង
សាសនាដេន ឬដេនិស្ម ចំណែកព្រះអរហន្តខីណាស្រព ប្រារព្ធដល់
រឿងដែលសុភទ្ទកក្តុបួសថាស់ ពោលពាក្យជាបដិបក្ខប្រទូស្តពាយនឹងព្រះ
ពុទ្ធសាសនានេះឯង ជាមូលហេតុដែលត្រូវឲ្យរួបរួមធម្មវិន័យបូលគ្នា
ព្រះត្រៃបិដក ។ ហើយការរួបរួមវិន័យគ្រានោះទៀតសោត នឹងថា
ធ្វើតាមព្រះសារីបុត្រដែលធ្វើមុនមកមុនហើយក៏សមដែរ ព្រោះវិធីធ្វើដូចគ្នា
សេចក្តីប្រាថ្នាក៏ដូចគ្នា សូម្បីវិធីច្រើនឹងវិធីរក្សា តំនៅតែច្រើនឹង

រក្សាដោយមុខជាបដិសេធ តុំចាន់មានចារជាអក្សរនៅឡើយទេ ទើបតែមកដល់ព្រះពុទ្ធសករាជ ៤៣៣ ឆ្នាំ ទើបបានមានចារជាអក្សរដំតល់ទុកមក រឿងនេះ លោកសំដែងមកថា :

កាលណា ព្រះបាទវដ្ដគាមិនី ដែលបានសោយរាជ្យក្នុងប្រទេសលង្កាព្រមទាំងព្រះសង្ឃត្រកាន់ត្រៃ:ទាំង៣ប្លាយ ឮបានប្រារព្ធដល់រឿងព្រះពុទ្ធសាសនាថា ព្រះពុទ្ធវចនៈគ្រប់ប្រការ ព្រះសង្ឃទាំងពួង បានជួយទ្រទ្រង់ ជួយរក្សាតៗមក ដោយមុខជាបដិសេធតែម្យ៉ាង គឺទន្ទេញឲ្យចាំមាត់ ហើយសូត្រដោយមាត់ទេព្រោះគ្មានជាទាន់ត្រាយ ព្រះពុទ្ធសាសនាទើបប្រាកដមានមកដល់សព្វថ្ងៃនេះ តែតទៅអនាគតទៀត ការទ្រទ្រង់នឹងការរក្សាដោយវិធីយ៉ាងនេះ គង់ប្រព្រឹត្តទៅពុំបានសារឡើយ បើដូច្នេះ ព្រះពុទ្ធសាសនានៅប្រទេសយើងនេះ គង់តែសាបសូន្យទៅវិញជាមិនខាន យល់ឮស្រាប់យ៉ាងនេះហើយ ទើបមូលមតិគ្នា រួមជាគណៈមួយ ជួយចារព្រះត្រៃបិដកជាភាសាអក្សរ ទាំងបាលី ទាំងអដ្ឋកថា ជាក់ក្នុងស្លឹករឹត ដំកល់ទុកមកក្នុងវត្តមហាវិហារ ប្រទេសលង្កា ហើយសូត្រតាក្យបួងសួងថា សូមឲ្យព្រះពុទ្ធសាសនា ទ្រទ្រង់នៅជាស្ថាពរ ឲ្យបានគ្រប់ ៥០០០ ឆ្នាំរៀមទៀត, នេះជាវិធីជួយទ្រទ្រង់ ជួយរក្សាព្រះពុទ្ធសាសនានៅប្រទេសលង្កា ។ ចុះប្រទេសកម្ពុជាយើងវិញ តើធ្វើទ្រទ្រង់ តើធ្វើរក្សាសាសនា ដោយវិធីយ៉ាងណាដែរ ?

ប្រទេសកម្ពុជាយើងនេះ អ្នកប្រទេស ក៏កាន់ព្រះពុទ្ធសាសនា ដូចប្រទេសលង្កាដែរ មិនខុសខ្សែយជាងប្រទេសលង្កានោះសោះឡើយ ហើយអ្នកប្រាជ្ញជាន់ចាស់របស់យើងខ្មែតសោត ក៏បានចារព្រះត្រៃបិដក ទាំងបាលីទាំងអដ្ឋកថា ជាក់ក្នុងស្លឹករឹត ដំកល់ទុកមកក៏មានច្រើនដែរ ប៉ុន្តែពុំបានសាយសព្វគ្រប់តំបន់ គ្រប់វត្តអារាមនៅឡើយ បើដូច្នេះ តទៅអនាគត ព្រះពុទ្ធសាសនានៅប្រទេសយើងនេះគង់តែអូនថយទៅវិញជាមិនខាន ព្រោះក្រែងព្រះពុទ្ធសាសនាទីងអូនថយយ៉ាងនេះហើយព្រះករុណាជាអម្ចាស់ជីវិត ដែលទ្រង់ព្រះអង្គជាសាសនូបត្ថម្ភក៍ ទើបទ្រង់អនុញ្ញាតឲ្យក្រុមដំទុំព្រះត្រៃបិដក នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ចាត់ការចោះពុម្ពព្រះត្រៃបិដកជាប្រញាប់ ប្រយោជន៍ទីងបានផ្សាយឲ្យសាយសព្វគ្រប់វត្តអារាមដង ដួយទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យមានព្រះជន្មវស្សា ៥០០០ ឆ្នាំដង ។

ដូច្នេះ សូមសាធុជនទាំងឡាយ ទាំងគ្រហស្ថ ទាំងបព្វជិត គប្បីកសាង ដួយទបត្ថម្ភគាំទ្រព្រះត្រៃបិដករបស់យើង ដើម្បីយកទៅដំកល់ទុក សម្រាប់វត្តសម្រាប់ភូមិឋានរបស់ខ្លួន ទីងបានជាប្រយោជន៍សម្រាប់សិក្សារៀនសូត្រខ្លះ សម្រាប់សក្ការៈបូជានមស្ការថ្វាយបង្គំខ្លះ បើមាន

សម្តែងធ្វើយ៉ាងនេះបាន កំណាកាប្រសើរណាស់ ព្រោះថា បុគ្គលណា
ប្រាថ្នាតសាងព្រះត្រៃបិដក បុគ្គលនោះ ឈ្មោះថាបានជួយទ្រទ្រង់ ជួយ
រក្សាព្រះពុទ្ធសាសនាឲ្យមានព្រះជន្មវស្សា ៥០០០ឆ្នាំផង សមនឹងពាក្យ
ដែលយើងសូត្រថា «បិតំ តិដ្ឋតុ សាសនំ» ដូច្នេះដែរផង ។



ព្រះញាណកោសល ញាណ-ឈឺន រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព ។

បន្ទាប់អំពីនេះ សូមដកស្រង់យកទាន ៤ យ៉ាង គឺអាគន្តុកទាន១ គមិកទាន ១ គិលានទាន ១ គិលានុបដ្ឋាកទាន ១ មកសំដែង ។

ទានទាំងនេះ មាននៅក្នុងចំណោមគាលទានសូត្រខ្លះ ក្នុងចំណោមពរប្រាំបីប្រការ របស់នាងវិសាខាមិគារមាតាខ្លះ ដូចពណ៌នាតទៅនេះ :

ចំពោះគាលទានសូត្រ មានសេចក្តីថា ទានដែលមាន ឧកាស អាចធ្វើបានមួយជនមួយកាល លោកហៅថា "គាលទាន" ប្រែថា "ទាននៅពេលវេលាដែលគួរឲ្យមួយជនមួយកាល" គឺយូរ ។ ទើបមានម្តង លោកសង្គ្រោះយកកត្តុ ៤ យ៉ាងគឺ អាគន្តុកកត្តុ (កត្តុដែលគេប្រគេនដល់តុកូទើបមកដល់ថ្មី) ១, គមិកកត្តុ (កត្តុដែលគេប្រគេនដល់តុកូអ្នកមានដំណើរចេញទៅ)១, គិលានកត្តុ (កត្តុដែលគេប្រគេនដល់តុកូអ្នកមានជម្ងឺ) ១, គិលានុបដ្ឋាកកត្តុ (កត្តុដែលគេប្រគេនដល់តុកូអ្នកបម្រើ

ជម្ងឺ) ១, នវកកត្ត (កត្តដែលនៅថ្មីៗថ្មង) ១; មានទាហរណ៍ថា គេធ្វើស្រែមួយឆ្នាំមុន ហើយគេអាចធ្វើតទុកាស ធ្វើបានបានច្រើនដង កប់ចាប់ដើមពីស្រូវនៅក្នុងស្រែ គឺគ្រាន់តែស្រូវមានបង្កើមភ្លាម គេកាច់យកបង្កើមស្រូវនោះមកបុកកិនជាទឹកដោះ ឬជាមៀរធ្វើយាគូ ធ្វើស្ករគាំងម៉ែ ដើម្បីធ្វើទានពីដម្បងជាបដល់ស្រូវខុំ គេប្រួត បញ្ជាន់បុកបែនដង្ហាន ជាក់ជង្រុកជាទីបំផុត ។

ទានពាំងនេះ ហៅថា អគ្គទាន ឬនវទាន ដូច្នេះវិញក៏បាន ប៉ុន្តែទីនេះ មិនមានបំណង នឹងសំដែងតាលទានសូត្រឲ្យពិស្តារទេ ។

២ ចំពោះពរ ៨ ប្រការរបស់នាងវិសាខាមិគារមាតា មានសេចក្តីថា :

សម័យមួយ ព្រះមានព្រះភាគស្តេចប្រថាប់នៅក្រុងសាវត្ថី គួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រឡប់មកគាន់ចារិកក្រុងសាវត្ថីវិញ ទ្រង់គង់នៅវត្តព្រះជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ខៀបក្រុងសាវត្ថី ។ លុះនោះ នាងវិសាខាបានចូលគាល់ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ លុះអង្គុយស៊ប់ហើយ ទើបព្រះមានព្រះភាគ ទ្រង់ពន្យល់នាងវិសាខា ឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា លុះចប់ហើយ នាងក៏ក្រាបបង្គំទូលថា

"បពិត្រព្រះមានព្រះភាគដ៏ចំរើន សូមព្រះអង្គជាមួយនឹងភិក្ខុសង្ឃ

ទ្រង់ខ្ញុំលួសកគ្គរបស់ខ្ញុំម្ចាស់ក្នុងថ្ងៃស្អែកឲ្យបាន" ។ ព្រះមានព្រះភាគក៏ទ្រង់ខ្ញុំលួសនិមន្ត ដោយតុណ្ហីភាព ។

លុះដល់ថ្ងៃស្អែក នាងវិសាខាបានតាក់តែងខាទនីយភោជនីយាហារឲ្យឆ្អែនត្រប់គ្រាន់ហើយ ក៏បញ្ជាទាសីម្នាក់ឲ្យទៅក្រាបបង្គំទូលកគ្គកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ! វេលានេះជាកាលគួរហើយ កគ្គសម្រេចត្រប់គ្រាន់ហើយ ។ ទាសីនោះបានទៅកាន់អារាមតាមបញ្ជា ក៏បានឃើញពួកភិក្ខុកំពុងស្រង់ទឹកលង់កាយទេ ដោយអាកប្បកិរិយាពុំគប្បីជាសមណៈ ។ ទាសីនោះក៏ត្រឡប់មកជំរាបនាងវិសាខាវិញថា "បពិត្រអ្នកម្ចាស់ ! ក្នុងអារាមនោះគ្មានភិក្ខុទេ មានសុទ្ធតែអាជីវក កំពុងងូតទឹកអាក្រាតកាយ សូមអ្នកម្ចាស់ជ្រាប" ។

នាងវិសាខាលុះបានស្តាប់ពាក្យទាសីដំរាបដូច្នោះហើយ នាងក៏តើតមានសេចក្តីរង្កៀសសង្ឃាប់សញ្ជឹងមួយស្របក់ ទើបប្រើទាសីឲ្យទៅក្រាបបង្គំទូលកគ្គកាល ចំពោះព្រះមានព្រះភាគទៀត អស់វារៈ ៣ ដង ។ នៅបុនក្រោយបង្អស់ ទាសីនោះក្រាបបង្គំទូលថា " បពិត្រព្រះសុគតដ៏ចំរើន វេលានេះជាកាលគួរហើយ កគ្គសម្រេចហើយ" ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុមកហើយមានព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ ចូរអ្នករៀបចំចាត្រទឹងចីវរចុះ ព្រោះដល់ពេលចង្ហាន់

ហើយ " ។ ពួកតិត្ថិយទូលព្រះពុទ្ធដីកាថា "ព្រះគុណាព្រះអង្គ" ។

ចំណែកព្រះមានព្រះភាគទ្រង់ប្រដាប់ជាត្រៃទីវរួចហើយ ទ្រង់បំបាត់ព្រះអង្គ អំពីវត្តដេតពនដោយឫទ្ធិ ស្តេចទៅប្រតិស្ឋានទៀបក្បែងទ្វាររបស់នាងវិសាខាដោយឆាប់រហ័ស ស្តេចទៅគង់លើពុទ្ធាសនៈដែលគេតាក់តែងថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ នាងវិសាខាមានចិត្តរីករាយយ៉ាងខ្លាំង ទើបចាត់បាចនាងទាសីយកោជនីយាហារ អង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលែងទទួលទៀតរួចហើយ ទាំងអង្គុយក្នុងទីសមគួរ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់ចង់សុំពរ ៨ ប្រការអំពីសំណាក់ព្រះអង្គ សូមព្រះអង្គទ្រង់ប្រោសប្រទានដល់ខ្ញុំម្ចាស់ ។ ព្រះសម្មុទ្ធទ្រង់ត្រាស់សួរថា តើនាងសុំពរដូចម្តេចខ្លះ ? ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពរណាដែលគួរ ដែលឥតមានទោស ខ្ញុំម្ចាស់សូមពរនោះ ដូចថ្វាយសេចក្តីតទៅនេះ :

๑ - ខ្ញុំម្ចាស់ត្រូវការប្រគេនសំពត់សម្រាប់ស្រង់ទឹកភ្លៀង ,

๒ ប្រគេនកត្តដល់ភិក្ខុអ្នកទើបមកដល់ថ្មី ,

๓- ប្រគេនកត្តដល់ភិក្ខុអ្នកធ្វើដំណើរចេញទៅ ,

๔ - ប្រគេនកត្តដល់ភិក្ខុអ្នកមានជម្ងឺ ,

๕ - ប្រគេនកត្តដល់ភិក្ខុអ្នកបម្រើជម្ងឺ ,

๖ - ប្រគេនថ្នាំតែរោគដល់តិក្ខុអ្នកមានជម្ងឺ ,

๗ ប្រគេនធុរយាគូដល់ព្រះសង្ឃ ,

๘ - ប្រគេនសំពត់សម្រាប់ស្រង់ទឹកដល់តិក្ខុនីសង្ឃ ។

ភរតាំង๘ប្រការនេះ ខ្ញុំម្ចាស់សូមអនុវត្តដាបដល់អស់ដីវិត ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់សួរថា នាងឃើញអំណាចប្រយោជន៍ដូចម្តេច ទ្បានជាសុំពរ ๘ ប្រការអំពីសំណាក់តថាគត ។ នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំម្ចាស់យល់ឃើញថា តិក្ខុស្រង់ទឹកវៃដ៏ការយ៉ាងនេះ ជាកិរិយាពុំគប្បីដល់សមណភាព ជាការគួរខ្ពើមព្រោះហេតុនោះ ទ្បានជាខ្ញុំម្ចាស់ត្រូវការប្រគេនវស្ត្រកសាដក ដល់ព្រះសង្ឃដាបដល់អស់ដីវិត នេះជាពរទី ๑ ។ ខ្ញុំម្ចាស់យល់ឃើញថា តិក្ខុជាអាគន្តុកៈទើបមកដល់ថ្មី មិនទាន់ឈ្មោសក្នុងផ្លូវ មិនទាន់ឈ្មោសក្នុងទីគោចរ លំបាកនឹងគ្រាច់ភៅបិណ្ឌបាត លុះបានទាន់អាគន្តុកភត្តរបស់ខ្ញុំម្ចាស់ហើយ មុខជានឹងឈ្មោសក្នុងផ្លូវ ឈ្មោសក្នុងទីគោចរ មិនលំបាកក្នុងការគ្រាច់ភៅបិណ្ឌបាតទៀត ព្រោះហេតុនោះ ទ្បានជាខ្ញុំម្ចាស់ត្រូវការប្រគេនអាគន្តុកភត្ត ដល់ព្រះសង្ឃដាបដល់អស់ដីវិត នេះជាពរគំរប់២ ។ ខ្ញុំម្ចាស់យល់ឃើញថា តិក្ខុអ្នករង្វាំដំណើរ បើវៃលៃតែសូន្យរកភត្តសម្រាប់ខ្លួន មុខជានឹងបែកខ្ញែកចាកគ្នាគ្នា អ្នកភៅជាមួយ ឬនឹងយឺតយូរខ្លុសកាលបរិច្ឆេទ ដែលខ្លួនមានបំណងភៅតាន់ប្រទេសណា ក៏នឹង

ទៅដល់ប្រទេសនោះខុសពេលវេលា នាំឲ្យលំបាកនឹងទៅតាន់ប្រទេសថ្លាយ លុះតែកុម្មអ្នកធ្វើដំណើរនោះ បានធាន់តម៉ាកកត្តរបស់ខ្ញុំម្ចាស់ហើយមុខ ជានឹងមិនបែកខ្ញែកចាកកត្តីភ្លាទេ ឬបើចង់ទៅតាន់ប្រទេសណា នឹងបានដល់ប្រទេសនោះ មិនខុសកាលវេលា ដូចពាណិនាហើយនោះទេ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនតម៉ាកកត្តដល់ព្រះសង្ឃជាបដល់អស់ជីវិត នេះជាពាក្យប្រមាញ ។ ខ្ញុំម្ចាស់យល់ឃើញថា កិច្ចអ្នកមានជម្ងឺ កាលបើមិនបានគោជនជាទីសប្បាយទេ ជម្ងឺនឹងតែចំរើនខ្លាំង នឹងធ្វើឲ្យដល់មរណកាលក៏សឹងមាន លុះកិច្ចនោះបានធាន់តិលានកត្តរបស់ខ្ញុំម្ចាស់ហើយ ជម្ងឺក៏មិនចម្រើន នឹងមិនដល់នូវមរណភាពទេ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនតិលានកត្ត ដល់ព្រះសង្ឃជាបដល់អស់ជីវិត នេះជាពាក្យប្រមាញ ។ ខ្ញុំម្ចាស់យល់ឃើញថា កិច្ចអ្នកបម្រើជម្ងឺ កាលបើវៀតែនឹងស្វែងរកកត្តសម្រាប់ខ្លួនហើយ មុខជានឹងនាំយកកត្តមកឲ្យកិច្ចឈឺកន្លះវេលាថ្ងៃពេកនាំឲ្យហួសពេល ធ្វើឲ្យកិច្ចឈឺជាប់ចង្ការ បណ្តាលឲ្យជម្ងឺកាន់តែចម្រើនខ្លាំង លុះកិច្ចអ្នកបម្រើនោះបានធាន់តិលានុបដ្ឋាកកត្តរបស់ខ្ញុំម្ចាស់ហើយ មុខជានឹងបាននាំយកកត្តមកឲ្យកិច្ចឈឺកន្លះកាលគួរ មិនធ្វើឲ្យកិច្ចឈឺជាប់ចង្ការខ្លាំងឡើយ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនតិលានុបដ្ឋាកកត្តដល់ព្រះសង្ឃជាបដល់អស់ជីវិត នេះជាពាក្យប្រមាញ ។ ខ្ញុំម្ចាស់យល់ឃើញថា

តិក្ខុអ្នកមានជម្ងឺពោះស្រាលក្តី ធ្ងន់ក្តី បើមិនបានកេសដ្ឋៈជាទីសប្បាយទេ នោះជម្ងឺនឹងតែចម្រើនឡើង នឹងធ្វើឲ្យដល់មរណភាពក៏សឹងមានលុះតិក្ខុនោះបានធាន់ បានប្រើប្រាស់តិលានកេសដ្ឋៈរបស់ខ្ញុំម្ចាស់ហើយ ជម្ងឺក៏មិនចម្រើននឹងមិនធ្វើឲ្យដល់មរណភាពទេ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនតិលានកេសដ្ឋៈ ដល់ព្រះសង្ឃដរាបដល់អស់ជីវិត នេះជាពរគំរប់ ៦ ។

ខ្ញុំម្ចាស់យល់ឃើញថា គានិសង្សយោគូមាន ១០ យ៉ាងដែលព្រះសម្ពុទ្ធទ្រង់សំដែងហើយ ទ្រង់អនុញ្ញាតហើយ ដល់តិក្ខុពាំងឡាយ ដូចមានតម្កើងថា តាយកអ្នកឲ្យទានមបរ រមែងបាននូវអាយុវែង ១, បាននូវពណ៌សម្បុរក្អៀវថ្លា ១, បាននូវសេចក្តីសុខស្រួលកាយស្រួលចិត្ត ១, បាននូវកម្លាំងកាយកម្លាំងប្រាជ្ញា ១, បាននូវការស្មាត់ដំនាញ ១, ឯអ្នកដែលបានឲ្យទានបបរ រមែងបានតាំងឃ្លានបាយ ១, បានស្រែកចឹក ១, ឃ្លាំងក្នុងពោះវៀនតូចធំប្រព្រឹត្តទៅស្រួល ១, បំពង់សរសៃនឹងពោះវៀនបានស្អាតបរិសុទ្ធ ១, អាហារចាស់ដែលសេសសល់ អាចរលួយទ្រុឌទ្រោមដោយល្អ ។ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនបបរ ដល់ព្រះសង្ឃដរាបដល់អស់ជីវិត នេះជាពរគម្រប់ ៧ ។

ខ្ញុំម្ចាស់យល់ឃើញថា តិក្ខុនីស្រន់ចឹកលែងតាយរាល ជាមួយនឹងស្រីពេស្យា ជាកិរិយាពុំគប្បីដល់ស្ត្រីគេនិមន្តៈ ដោយគ្នា

ខ្ញុំម ។ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់ត្រូវការប្រគេនទេតសាជក ដល់តិក្ខិនសង្ឃ ជាបដល់អស់ដីវិត នេះជាពរគម្រប់ ๘ ។

ឯុះនាងវិសាខា ក្រាបបង្គំទូលសុំពរចំនួន ๘ ប្រការ ព្រមចំនួនសេចក្តីអធិប្បាយ អំពីផលប្រយោជន៍នីមួយៗនៃពរនោះ ចប់ហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលនាងវិសាខា ល្អហើយ ល្អហើយ បើដូច្នោះ តថាគតអនុញ្ញាតឲ្យដល់នាង ។ ទើបទ្រង់ធ្វើអនុមោទនា ដោយគាថានេះថា ៖

យា អន្នបានំ ទទតី បមោទិតា
សីលូបបន្នា សុគតស្ស សាវិកា
ទាតុ ទានំ អភិកុយ្យ មច្ចរំ
សោវគ្គិកំ សោភនុទំ សុខាវហំ
ទិព្ពំ ពលំ សា លភតេ ច អាយុំ
អាគម្ម មគ្គំ វិរជំ អនង្គណំ
សា បុញ្ញភាមា សុខិនី អនាមយា
សគ្គមិ ភាយមិ ចិរំ បមោទតីតិ ។

ស្ត្រីណាជាអ្នកឲ្យបាយទឹក មានចិត្តរីករាយមានសីលបរិបូណ៌ជាសាវិការបស់ព្រះសុគត អ្នកគ្រប់សង្កត់នូវសេចក្តីកំណាញ់បានហើយឲ្យនូវទាន ស្ត្រីនោះឯង តែងបាននូវផល គឺអារម្មណ៍ជាប្រសើរជាយ

ប្រពៃមានរូបជារដើម ចានបន្ទោបង់នូវសោក នាំមកនូវសេចក្តីសុខមាន
កម្លាំងនឹងអាយុជាដើម្បី ស្តេចនោះឈ្មោះថាប្រាថ្នានូវបុណ្យ អ្នកមានសេចក្តី
សុខ ឥតមានទុក្ខ តែងរីករាយក្នុងស្ថានសួគ៌អស់កាលជាយូរអង្វែងព្រោះអា
ស្រ័យនូវមគ្គចិត្តដ៏ប្រសើរក្រៃលែង ជាចិត្តមិនមានកិលេស ។ រួចហើយទ្រង់
អនុញ្ញាតថា "អ្នធុជាតាមិ ភិក្ខវេ វិស្សជ្ជេសាធីតិ" ប៉ុណ្ណេះជារដើម ។

ពុទ្ធានុញ្ញាតនេះហើយដែលពុទ្ធបរិស័ទបានប្រកាន់ខ្ជាប់ថា
"ជាមត៌កវិសេសសម្រាប់បំពេញទាន" ហើយបានអនុវត្តតៗគ្នាមក
ដរាបដល់សព្វថ្ងៃ ។ អត្ថបទពាំងពីរនេះក្នុងកាលទានសូត្រ ទើបពរ
៨ ប្រការ ដែលចន្លោះពៅលើកត្តពាំង ៤ យ៉ាង មានអាគន្តុកកត្ត
ជាអាទិ៍ ដូចបានពណ៌នាពីខាងដើមនេះ មិនមែនគ្រាន់តែជាចំណុចនៃ
មន្តីរពេទ្យព្រះសង្ឃពុទ្ធសាសនិកប៉ុណ្ណោះទេ សឹងតាក់ទងនៅជាបវេណី
ធម៌សាធារណៈ: សម្រាប់ពុទ្ធបរិស័ទក្នុងសាសនមណ្ឌលពាំងមូលធងដែរ
ព្រោះអ្នកមានសទ្ធាមុះមុត រមែងគាប់អធ្យាស្រ័យនូវកត្តពាំងខោះពុំរួញរា
សោះឡើយ ហើយអ្នកមានសទ្ធាតែងតែលះជនធានបណ្តុះពូជបុណ្យ
ស្តើរតែគ្រប់ឈ្មោះកត្តពាំង ១៤ មិនសូវមានសេសសល់កត្តណាមួយទេ ។
សូម្បីអ្នកបំពេញបុណ្យច្រើនដល់ម្ល៉ោះ គង់នៅខ្វះខាតមិនទាន់បាន
គ្រប់គ្រាន់ដល់ចំណុចនៃការបុណ្យនោះ ។ ឡើយ ដ្បិតនៅមាន
អធ្យាស្រ័យ ធ្វើមានតែនឹងបង់គ្នាហកបុគ្គល ដែលមានឧបការៈ តាម

ភ្ជាប់ស្គាល់ពាប់តេគ្នា ហើយដែលមានសមត្ថភាពធំដុំ មានសុខភាព
ពន្លឹកាយពេញលេញ ជាអ្នកសម្បូណ៌ស្តុកស្តម្ភស្រាប់ ។ ឯបដិគ្គា-
ហកបុគ្គលទ័លក្រអោមរហាម ឈឺថ្កាត់ឆ្អើងខ្លួនវេទនា ដោយពេត
ផ្សេង ។ ឬ ជនដកតំព្រាអនាថាឥតមានទីពឹងផ្អែកនោះ គេពុំសូវប្រាថ្នា
ធ្វើទេ បើពោះបីធ្វើក៏ស្តួចស្តើងណាស់ គឺថាប្រែនតែធ្វើទានសំដៅ
មនុស្សជានា គ្មានផលអ្វី ពុំសូវដែលឲ្យទានសំដៅអ្នកឈឺនោះឡើយ ។

ការធ្វើទានមានសភាពដូចនេះ ប្រសើរមែនហើយ ប៉ុន្តែនៅមាន
ព្រះពុទ្ធដីកាមួយអន្លើទៀត ព្រះអគ្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ
បុគ្គលណាបម្រើតថាគត បុគ្គលនោះគួរបំរើភិក្ខុឈឺដែរ[1] ។

ព្រះពុទ្ធដីកានេះ បង្ហាញឲ្យយើញថា ភិក្ខុឈឺមានឋានៈស្មើ
នឹងព្រះអគ្គ ។ ការធ្វើទានចំពោះភិក្ខុឈឺក្តី ការបម្រើភិក្ខុឈឺក្តី ទុក
ដូចបានធ្វើទាន បានបម្រើចំពោះព្រះពុទ្ធជាម្ចាស់ដោយពិត ។

មួយទៀត ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ពោះទុបដ្ឋាយ អាចារ្យ
អន្តេវាសិក សិទ្ធិវិហារិក ដែលលោកអគ្គណាមួយមានជម្ងឺ ត្រូវអ្នក
ដែលជានា នៅបម្រើដរាបដល់បានជាសះស្បើយ ។

ហេតុដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ប៉ុណ្ណោះហើយ បានជានាងវិសា
ខាមហាឧបាសិកា តើតសទ្ធាជ្រះថ្លាអត់ទ្រាំពុំបាន ទើបក្រាបបង្គំទូលសុំពរ
ចំនួន ៨ ប្រការ ដូចបាននាំមកសំដែងហើយដោយសង្ខេបនេះឯង ។

(១ យោ ភិក្ខវេ មំ ឧបដ្ឋេហេយ្យ សោ គិលានំ ឧបដ្ឋេហេយ្យ ។ នេះជាពុទ្ធដីកាមកក្នុងចីវរ-
ក្ខន្ធកៈ ទំព័រ ១៤៨ ភាគ-៨ ។

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ភាសាភាគ្យ)

(តមក)

លោក អម្ពុតក្យត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថែម ពិនិត្យ

តាប់តាលនាថ្ងៃ កុមារថ្ងាថ្ងៃ ចេរចរយាត្រា មកផ្ទំអាស្រ័យ ក្រោម
ផ្ទៃសាខា លក់លន់ធ្លេសស្មារ-តីដោយនឿយណាស់ ។

កុដន្តយក្សចង់ សេនផ្ទៃស្រេចទ្រង់ គ្រប់គ្រឿងប្រាលប្រាស់
លីលាឯកអង្គ ទ្រើសទ្រង់សហ័ស តាប់តាស់ស៊ីវែស បង្អាក់តោក្តា ។
ដំណើរនៃវ័យ ពានផ្ទៃល្អិតផ្ទៃ ពន្ធឹកមហិមា អស់អង្គម្រឹគ ក្លាំង-
ក្លឹកយក្សា រួតរត់ចូលអា-ស្រ័យស្រប់ជ្រុលជ្រក ។ ខេរខ្ចីឯះខំ ដេញ
ជិតជាលដំ វេះវៃល់ទៅមក ឈានឈោងស្ទុះស្ទាត់ ស្ទុះស្ទាត់វ៉ះរក
ចាប់ចាក់យួរយក ប្លាទបរិភោគក័ក្ខ ។ ឈប់ឈរចំអើត ចំទើតងើយ-
ងើត មៀងមើលបញ្ជាក់ យក្ខយលកុមារ ទ្វេហាវរលីក្ខណ៍ ដោយ-
សែងចន្ត្រែជាក់ អរឯងប៉ូមប្លាម ។ ហេតុយប់ងងឹត លបលួនចូលដិត
ក្រាបខើបងើមងាំម គយគន់ផ្ទង់ផ្ទៀង ប្រុបប្រៀងខ្មាមាម លម៉ាម-
លាម លបមើលជាក់ ។ តក់ទ្រង់តក់ស្មា ឧអញស្មានជា ខ្សែ

ខ្លាយអបល័ក្ខណ៍ ប៉ុនប៉ងនឹងចាប់ សម្ងាប់ជាកគ្ន ជាតិព្ទអញជាក់
អញចម្ដងណោះ ។ ពានពេលល្ងាច្ចុះ ទើបមកប្រទះ ប្រពៃនជូរច្ចុះ
មកពីណាមក កំណូដល់ម្ទេះ មិនគឺពាស្ត្រីនេះ សមជាបុត្រស្ដេច ។ ទើប
តបនល័ក្ខណ៍ តែធ្នូមួយម្នាក់ អង់អាចត្រែកត្រែច សំអាងវែមន្ត
ទិព្ទតនលើសលេច លើសលុះសម្រេច ត្រើយត្រៃវែងផង ។ តួចតិច
សមប្អូន រួបពងសុទ្ធសួន ជំនោះសមបង អញនឹងយកទៅ លំនៅឲ្យ
ត្រង់ បុត្រីស្នេហ៍ស្នង ជាគូស្នេហា ។ យកតែបងទៅ អាណិត
ប្អូនទៅ ក្រែងក្រោកសោក រូតរះកេបង វែងវង់ខុក្ខា មានកូនតាវ៉ា
នឹងឲ្យចាំដរខ្ញុ ។ នឹងឲ្យជូរច្ចុះ យល់ជាមិនបេះ ស្រឡាញ់ស្រីខ្ញ
គួរយកចាំងខ្ញុ ទៅតាមតែ ប៉ុត្រីស្នាលស្នេ- ហាហើយតាមចិត្ត ។
ពោះយក្ខសច្ចភ័ណ្ឌ ក្រែវក្រែងទឹងខាន់ គេកាត់មកត់មិត្ត មែនមិនប៉ុណ្ណោះ
ទៀងពោះពិដត សង្គ្រាមអញឥត ពារញ្ជប្រញ្ជាណ ។ ស្រេចសូត្រ
អាគម ទិព្ទមន្តសន្តុំ បែរបៀតបីបាន ចាំងពីរពន្យារ ចាំងសរ
ធ្នូបាន ហិចហោះទៅឋាន ប្រាសាទរចនា ។ ដល់ជាក់សម្ដុត- សាគរ
វិសុទ្ធ ផ្ដុំផ្ដើមធាតា យក្ខរៀបបន្ទុំ បរមេសយ្យនា ជាក់អនុជា ឲ្យផ្ដុំ
ខាងត្រៃ ។ ឈរឈប់សម្រិត សម្រប់ពីនិត រំពៃជួនថៃ គន់តាយ
ផ្ដុំផ្ដើម ស័ក្តិសមស្នាលស្នេហ៍ អរឥតផ្ដើមផ្ដូរ ស្ទើបសរសើរថា ។ ខ

ហេតុកពួបុណ្យ កពួបុត្រស្ងួនតន់ ស្ងួនតួចតូចតូជា តូពូជាធ៌ស្រែលស្រី ចានប្តីថ្លៃថ្លា ស្រាប់ស្រែចយកួយា- ត្រាត្រែចហារហៅ ។ អស់ស្ងំស្នេហា មកដល់ត្រាស់ថា ចូរហានប្រែ៧ ជាតជាស្ងំមនុស្ស ចាំនអស់និតិ្យនៅ ទីចាំនក្នុងត្រៃ កុំឲ្យសល់ម្នាក់ ។ ដ្បិតអញយកមនុស្ស មកជាកូនប្រុស ត្រែនតយភ្ញាចយក្ស ផ្តាំស្រែចចមចៅ ស្តេចចៅតំណាក់ យាធ៌យាសដល់ជាក់ ច្រាសព្រះអគ្គីផ្ទុំ ។ ស្ងំស្ងួនចាំនអស់ សឹនប្រែជាមនុស្ស ខ្លះតូចខ្លះធំ ខ្លះធាត់ខ្លះស្គម ស្មាក់ស្មមស័ក្តិសម ខ្លះដេកខ្លះចាំ យាមតាមនាឡិកា ។

កាលណោះសមុទ្រ- សាគរវិសុទ្ធ ប្រែព្រះកាយា មមើពុំភ្ញាក់ តនឹតាក់ហត្ថា លើនាធ៌ស្មានជា អនុជស្នេហ៍ស្ងួន ។

នាធ៌នាជបុត្រយក្ខ ប្រែច្រាណក្ងាក់ រន្ធត់ភ័យតិត រំលៀកអគ្គីច្រាណ ពុំចានតន់តិត តន់តាយពិនិត្យ រូតរាត់ចេញទៅ ។ រកស្ងំជំនិត ចំណាំខុតចិត្ត ដឹនតារកត់ច្រៅ យល់ស្ងំពេញពាស ដេរជាសណែនទៅ សោតសឹនប្រែ៧ ជាមនុស្សាសាធ ។ ខ្លះដេកសេលកប ខ្លះក្រោកខ្លះក្រោប ថ្ងាត់ថ្ងាយអតិវាទ អស់ឯតតិតតេច មិនជាប់មិនខាត តិតថាច្រាសាទ នេះហានឧណា ។ ច្រាន្តច្រាសាទ នេះ អញរកអញរ៉ះ អញរំពឹនថា ជាហានអគ្គីអញ ម្តេចមិញស្រិត្តា តិក្ខាយជាតិជា មនុស្សាដូច្នេះ ។ ប្តូតម្រែត់យក ខ្លួនយ៉ាតមក តម្ម

អើយអ្វីម្ល៉ះ ព្រាត់ពីនេះនឹង ពាក់ពីឯណេះ មានមកដូច្នេះ នឹងទៅ
ឯណា ។ ឲ្យស្គាល់ចានម្ចាក់ នឹងសួរឲ្យដាក់ សព្វសោះសង្កា នាង
នាងគន់គិត រឹងគិតមួយសា នឹកនឹងហើយហា សួរសោតអល់
ឯក ។

ក្សត្រីណាស្នំដ៏និត យង់យល់ចរិត នៃនាងនាងប្លែក ស្រពោន
ស្រពន់ អៀនអន់សង្វេគ រោពអល់ឯក ឲ្យជាចង់សើច ។ ជញ្ជឹង
ទៅសព្វ ១៖ខ្លះខ្លះ អាចអត់សំណើច ធ្វើហាក់តើតខ្ពុក ជាក់មុខ
ត្រដើច តើពោលពាក្យតើច បញ្ជៀសផ្តងថា ។ ខ្ញុំនសព្វកាល
ម្ចាស់រៃនស្នេហ៍ស្នាល ស្តេចមកគាលណា យល់ហើយស្រស់ស្រាយ
រោះរាយចរចា នេះមិនដឹងជា ខ្ញុំនមានទោសអ្វី ។ មកហើយអល់
ឯក ទ:ចុះឡែក ទុអង្គីក្តី ហាក់អន់មិនដឹង អន់នឹងខ្ញុំស្រី ឬមួយ
ម្ចាស់ថ្មី ឲ្យអន់ចិត្តា ។ បើម្ចាស់ប្រុសគ្មាន ឲ្យអន់ត្រាន់បាន ដៀង
ជួយជោះសា បើម្ចាស់ប្រុសឆ្គង មានហ្នឹងផងគ្នា មិនដឹងប្រាប់
ឯណាជួយបាន ។ ដូចគេមើលមេឃ ឃើញផ្ទាយពន់ពេក ពេកពន់
ប្រមាណ ប្រមើលហើយគិត ផុតចិត្តផុតជ្ញាន នឹងពឹងមិនបាន មួយមិន
ស្ងួនផង ។

នាងឮសំដី ស្គាល់ជាសាវស្រី ដំនិតស្នេហ៍ស្នង គិតថាអញ

ស្មាន គេគ្មានដឹងផង បើដោយពាក្យបង គេដឹងពាល់គ្នា ។ ពាំង
អៀនពាំងអរ រត់ទៅកៀកក បំទមាត់ត្រាស់ថា ប្អូនបានខឹងផង
ឆ្ងល់បងតាលណា ហើយប្អូនបានជា អ្វីផងអង្គាល់ ។ បងអើយប្អូនក្លាក់
ពីលក់ដោយងាក់ ដៃដល់តើមពាល់ ពិតពុំដឹងជា ព័ណ៌ាដឹងស្គាល់
រុតរត់មកពាល់ នៅនោះរកបង ។ ហេតុម្តេចពាល់គ្នា សោតសឹងប្រែ
ជា រូបស្ងំមនុស្សផង កុំបងលាក់លាយ នំយាយលេងលង បួរប្រាប់
ប្អូនម្តង ជំណើរហេតុអ្វី ។ ពីលៀនទូលថា ដ្បិតព្រះបិតា ក្រែងព្រះ
ស្វាមី អ្នកមាសវរលក្ខណ៍ ខ្ជាចយកកូនី ឲ្យប្រែជាស្រី មនុស្សនៅ
រក្សា ។

នាងស្តាប់ពាក្យពិត ត្រឹព្រួចចាប់ចិត្ត តើតក្តួចស្នេហា ប្រែ
ប្រួយដាត់ផ្សះ សាក់សួរទៅថា ស្តេចយកពីណា នាមនោះឈ្មោះ
អ្វី ។

ពិលៀនឆ្លើយថា បងដឹងតាលណា ទូលទៅក្រែងឥតឮ ឡូវសោតពុំ
សម ដូចគំនិតស្រី ស្តាយកុំឆ្លើយថ្វី សោះមានទោសា ។

នានាដបែរបៀន បំទមាត់ពីលៀន ញឹមញែមចរចា អញស្អប់
ចិត្តនឹង ធាប់ខឹងណាស់ណា លេសឹងលេញជា តែចក្តួចពុំបាន ។ កុំបង
លាក់លង ដួយគិតប្អូនផង ឆ្លើយម្តេចនឹងបាន ឲ្យគួរនឹងច្បាប់ ទន្ទាប់បួរណា
គួរឲ្យប្អូនខាន ឬគួរឲ្យទៅ ។

ពាលៀងឆ្លើយថា អញ្ជើញទៅជា កុំខានឡើយ ក្រែងព្រះបិតា ក្រោធាយោរយៅ មួយសោតស្រៅ ឥតជ្រាបពតិមាន ។

នាងនាដស្នេហ៍ស្មើ ប្អូនអៀនម្ល៉ះតើ ឥតទៅម្តេចបាន ពាលៀងស្តាប់ហើយ ផ្ទាស់ឆ្លើយវិញថា អញ្ជើញកុំខាន នៅនេះមិនជា ។ ទម្ល៉ះសមឥតឥន្ទ្រិយ ព្រះម៉ែយខ្ចោចផ្សារ ផ្សារមកកប់ក្តួច ថ្មីថ្នូរស្នេហា អញ្ជើញរួសព័ កុំគិតផ្សារផ្សែង ។

នាងស្តាប់ពាក្យកើច អរអត់សំណើច អន់អៀនទំប្រជ្រែ ទៅហើយដូចខេ រ៉ះរកាធំ ខន់ពាំងអស់អង្គាគិតក្តីខ្លាស ។ ស្ទើរទៅស្ទើរនៅ លង់លុះដល់ទៅ ខែនពិភូមាលមាស យង់យល់រូបទ្រង់ ព្រះអង្គសេយ្យាសន៍ តាយោនុតាស ថ្ងាថ្ងៃថ្លើងភ្លាន ។ មានចិត្តស្មាលស្នេហាហើយថយថៃ អង្គអៀនព្រឺព្រាណ ព្រឺព្រួចប្រិយប្រិម សន្យឹមបៀតបាន បៀតបែរប្រុបប្រាណ ប្រុបប្រុសផ្ងំផ្ងឹម ។

នឹកៗផ្អូកៗ ពិតពុំលន់លក់ សម្ងាត់សម្ងំ សម្លៀមសួនឡើងរំពឹងសុខុម ចិត្តចង់ជឹងជំ-ណើរនៃកុមារ ។

កុមារនិរទុក្ខ ភ្ញាក្ញាក់ចាកលក់ បែរបើកនេត្រា យល់ប្រាសាទមណី ពិភពក្រៃឡា បន្ទំសុវណ្ណា ដោយប្រពីបផង ។ តិតថាពីថ្ងៃ

អញដេកគ្រោមជ្រៃ តែប្អូនឆ្ងល់បង ទុខីមណ្ឌល គួរឆ្ងល់កន្ទួង ឬ
ខេពត្រប់គ្រង ជ្រៃជ្រោមអាណិត ។ ប្រែជាប្រាសាទ ប្រសើរស្អាង
ស្អាត ឲ្យអញដេកដិត ហើយបែរយល់នាង ផ្ទំខាងខៀបដិត សញ្ញា
ក្នុងចិត្ត ថាអង្គអនុជា ។ បែរទៅម្ខាងយល់ អនុជនិមិល ជាត់ចិន្តា
ថា ប្អូនអញខាងណោះ ចុះនោះនរណា ឆ្ងល់ហើយម្ដេចមា តើនខើប
ទ្រង់ធ្ងួ ។ ហត្ថម្ខាងវល៌ក្ខណ៍ ចាប់ជើតសូកក្រែ ដែលនាងខខូរ សន្សឹម
តិចៗ ស្ដែងស្ដេចខតយូរ ជ្រាបដោយវិញ្ញា វិញ្ញាណសញ្ញា ។ ជ្រួត
ជ្រាបដៀងជាត់ ជាស្រីវរល៌ក្ខណ៍ កួចតើតស្នេហា គិតថាឧប្អូន តែវ
កួននរណា ហេតុម្ដេចបានជា មកផ្ទំនឹងបង ។ ឧអញឆ្ងល់ក្ដិត ឬខេព
និម្មិត ឲ្យអញគ្រប់គ្រង នូវបុត្រនាគា គ្រុងាយកួងផង ឬមេស្នេហ៍ស្នង
បុត្រស្ដេចមនុស្សា ។ ខេត្តាតយក ប្អូនឆ្ងឹងអញមក ឲ្យបរិបូណ៌ជា
គូគួរនៃបនិត្យ ស្នាលស្ងួនស្នេហា ឧអញហៅមហា តព៌ាលើសសព្វ
ជង ។ គួរអញឲ្យបាន នាងនោះរួមបាន ខើបដឹងដើមខង ខោះតើតវល់
តាមកល់នេះម្ដេង ជាប្រុសកន្ទួង លែងចប្បាំងម្ដេចបាន ។ គិត
ស្រេចបីបម បីបានថ្នាត់ថ្នម នាងនាដកល្យាណ ថៃថើបព្រះខាត់ នាង
ជាត់នាងច្រាន ចង់ជ្រាបជាហ៊ាន ឬពាក្យខ្ញៀ ។

នាងខិតចុះចេញ ឆ្ងើជាអម្ដេញ តម្រាមថាខៅ នៃអ្នកប្រុស
ច្រាជ្ញ អង់អាចសៅដៅ ស្មានជាលំនៅ សូន្យខេប្អរ៉ូ ។ ខ្ញុំជាបុត្រ

យក្ខ ធើរិទ្ធិសក្តិ លើសលើលោកិយ លោកឲ្យយោជា សេនាសេនី ចាំដុំប្រក្រតី ត្រូវែលក្សា ។ ខ្ញុំគិតអាណិត អាសូរដើរិត ក្រែងលុះមរណា កុំរំខានទៅ ស្តេចទៅវិញជា ដោយពាក្យខ្ញុំថា ទើបរស់ជន្មពិត ។

សមុទ្រសាគរ ធ្វើយថាបងអរ (នឹងប្អូនវរមិត្រ) ខ្លាចខ្លួនបងក្សីយ មាសវិថូរបើចិត្ត ដូច្នេះមាសមិត្រ គ្រាន់ផ្ញើខ្លួនបាន ។ ប្អូនអើយ ធម្មជាត ជាប្រុសសីហនាទ ធើរិទ្ធិថ្កើងថ្កាន ដូចបងបើកិយ ខ្លាចក្សីយ ច្រាសច្រាណ តាលណានឹងហ៊ាន រុតពនរកទៅ ។ មួយហ៊ានមាសមេ ពុំស្ងាត់សូន្យទេ ដាំងហើយប្អូនៅ លោកឲ្យសេនី យោធាចាំនៅ ត្រូវែលមកទៅ ចោមដុំក្សា ។ ដូចប្រុសដទៃ នរណានឹងកិយ ហ៊ានមកស្ងួនក្សា នេះពាន់លើបង កន្ធឹងនានា អាចហ៊ានពុះពារ មកដល់ប្អូនស្រី ។ គួរតែមាសមិត្រ មាសមេពេញចិត្ត ដ្បិតយល់ថាមើ លើសលើលោកផង យកបងជាប្តី គួរគាប់តាអ្វី បែរបណ្តោញទៅ ។

នាងនាដស្តែងស្តាប់ ព្រះសូរសោរសំឡូ កុមារចមទៅ នាងជ្រួតជ្រាបជា ច្រាជ្រាជ្រះជ្រៅ ខំទូលតបទៅ បពិត្រពុជា ។ អញខ្ញុំបានមត៌ ប៉ានមានសន្ធត ផ្តែផ្តាំប្តេជ្ញា ម្តេចក្សត្រិយ៍ថ្កើងថ្កាន អាចហ៊ានពុះពារមកតែដោយសារ ដំណើរហេតុអ្វី ។

ព្រះរាជកុមារ បន្ទូលត្រាស់ថា ម្នៃស្នងប្រិមប្រិយ បងពុំមកឯង គឺព្រោះជាតិ បងនឹងអ្នកស្រី ជាគូផងគ្នា ។ បងដេកក្នុងព្រៃ ក្រោមដើមព្រះព្រៃ នាយប់សន្ធ្យា ស្រាប់តែភ្ញាក់ឃើញ មណ្ឌលសុវណ្ណា យល់ទាំងអ្នកទាំ ស្រេចស្រាប់តែម្ដង ។ ហេតុនោះបងអាង ដែលផលសំណាង ខ្ញុំចអ្វីមាសបង ពោះព្រះបិតា ត្រាជាកន្ទុង បងឯងបង រង ពោសទុក្ខតាងចៅ ។ នាងនាងធ្វើយដោះ ក្រែងពុំជូរថ្នោះ ភ័យហើយស្ដេចទៅ តែកុំត្រែទុក្ខម ចោលខ្ញុំឲ្យនៅ អសោចអសាកើតកង្កៀនិន្នា ។

កុមារធ្វើយត្រៀត ធ្វើយធ្នូងទៅទៀត ម្នៃអ្នកស្នេហា កុំអ្នកមាសថ្ងៃ សង្ឃឹយចិន្តា ត្រែងបងកយា រត់ចោលទេពី ។ ប្អូនអើយ បើក្ងឹត បើភ្នំងក្ងកសឹត រូតរត់ចោលទី លោកពុំពប់អាន ហៅមានវិន្ធី ហៅប្រុសសាកញី កំណើតតិរច្ឆាន ។ អម្បាលបងឬ នឹងព្រៃញ នឹងព្រឹ រូតរត់ចោលឋាន នាងនាងស្លាប់ហើយ ផ្ទាស់ធ្វើយវិជ្ជាន បពិត្រទ្រង់មាន បន្ទូលនេះសម ។ មែនហើយព្រះទ័យ ព្រោះពុំមានភ័យ ថាម៉ិនចោលខ្ញុំ កុមារធ្វើយផ្ទាស់ ម្នៃមាសទុក្ខម បើបងពិតពុំ ជានស្នងថ្ងៃថ្ងា ។ ភ័យផងឥតដល់ ធ្វើម្ដេចនឹងឃើញ វិន្ធីចេស្ដា បើប្អូនអន្ទុកូល ម៉ិត្រមូលស្នេហា មានភ័យកាលណា គង់ប្អូនឃើញទេ ។ បើភ័យផងផុន នោះហើយជាបុណ្យ បងនឹងមាសស្នេហ៍ កុំអ្នកមាសម៉ិត្រ

គន់គិតគេចវៃ បងពុំបណ្តែ បណ្តោយតាមឡើយ ។ គ្រាស់ស្រែចពុំ
លង់ ទិតទាងទុបអគ្គ ព្រះប្អូនគ្រាណាត្រើយ ពីរពង្សទ្តម ផ្តុំមធុរមែ
ខ្ញើយ ប្រកៀកប្រកើយ ប្រកបស្នេហា ។ ទាំងពីរពង្សក្សត្រ
ក្រសែមប្រជិតខ្ទ សាន្តសោមនស្សា ៗ ថៅមកស្មោះស័ក្តិ ឥតអាក់-
ចិន្តា ឥតអៀនព្រះហា-ទ័យទាំងពីរពង្ស ។ ទើបពាដកុមារ ថ្នាក់ថ្នម
សួរថា ហៃស្តេនវរង្ស ស្រុកនេះឈ្មោះអ្វី ប្អូនស្រីនួវអគ្គ បិតាស្តេច
ទ្រង់ ព្រះនាមឈ្មោះអ្វី ។

នាងនាដទូលថា វរីព្រះបិតា អញខ្ញុំចក្រី ទ្រង់នាមសោភ័ណ
កុដន្តធិបតី ប្រសើរជាឥ-សូរលើយក្សា ។ ស្រុកនេះឈ្មោះចោះ អញ
ខ្ញុំនេះឈ្មោះ អសុរិន្ទ្រា ជាបុត្រព្រះអគ្គ សូមទ្រង់មេត្តា ប្រោសវរិញ
ជោយនា ដំណើរពានេចរ ។

កុមារធ្វើយស្មោះ ប្អូនអើយបងឈ្មោះ សមុទ្រសាគរ អនុជ
នាមហៅ ថៅសហស្សសែរ បិតានាមករ ទៅនួថ្វាថៃ ។ វរីព្រះនគរ
ប្រសើរបវរ ឈ្មោះហៅកោសេយ្យ បិតាច្បាស់ច្បង ប្រើបងនេះនៃ នួវ
អនុជថៃ ថៅតក្កសិលា ។ បងរៀនសិល្បសព្វ វិលវិនត្រឡប់ រង្គឆ
មាតា ដើរថៅប្រទះ ព្រះឥសីលា លោកមានមេត្តា ប្រោសប្រាប់
ផ្លូវព្រៃ ។ បងដើរលុះយប់ នាំបងប្អូនឈប់ ដេកត្រាមដើមថ្លៃ ស្រាប់

វែមកយល់ មណ្ឌលចិត្តថ្ងៃ យល់មិត្រមាសមែ បងពុំដឹងច្រាណ ។

នាងខូលវិនិថា បពិត្របិតា ធ្លាជក្ស័ត្រែក្សត្ត ស្តែងស្តេចទៅ
ព្រៃ រៀលវែរយើញបាន ក្ស័ត្រែពីរអង្គប្រាណ មកចាំងសន្ធឹ ។

ក្សត្រាក្សត្រី ជ្រាបសព្វសេចក្តី សែនសោមនស្ស តតក៍យតត
តិត ស្នាលស្និទ្ធស្នេហា ស្គាល់លើក្រឡា ព្រះបន្ទំទៅ ។

រីព្រះអនុជា ស្តែងស្តេចនិព្រា តើនឡើងចមរៅ យងំយល់ពិមាន
ទីហានលំនៅ ប្រាសាទមាសផ្ទៅ ធ្លាក់ក្នងចិត្តា ។ រំពឹងគិតស្ទៀម បែរ
រកព្រះរៀម យល់ស្តេចនិព្រា លើខែនមាសផ្ទង់ ទំងអង្គុធីតា ស្ទៀម
គុំចរចា ប្រាសផ្ទំវិញទៅ ។

លុះព្រេងសុរិយា ស្តេចយកតូបិតា ឲ្យហៅនាងទៅ សួរនាមព្រះ
អង្គ សួរពាក្យពេងរ្យទៅ នាងខូលដោយទូរ ដំណើរដើមទង ។

តុជន្តយក្ស គ្រែតអរមហិមា ហៅមន្ត្រីឫទ្ធ ប្រើឲ្យប្រាម
ប្រាប់ បង្គាប់យកតូផង ឲ្យប្រែខ្លួនផ្តង ជាមនុស្សសុទ្ធ ឲ្យនិម្មិតប្រា-
សាទមួយសុវណ្ណា ប្រពានសមុទ្រ-សាគរកុមារ បរិវារសឹងសុទ្ធ ជា
មនុស្សថ្វាយបុ-ត្រីនូវសុណិសា ។ និម្មិតប្រាសាទ មណីមួយស្អាងស្អាត
មានស្នំស្នេហា សម្រាប់ថ្វាយបវ-សហាស្សសែកុមារ ក្រុងយក្ខស្នេហា
ដួចបុត្រព្រះអង្គ ។ ប្រសើរគ្រប់ក្សត្ត ប្រដូចតិមាន ព្រះត់ន្ត្រស្តេច
តង់ នន្ទវនទេវាន មានវាំងស្រែស្រង់ តាមតែនឹងចិត្ត ត្រសាល

សប្បាយ ។ ទោះមនុស្សច្រេចរេ មកពីនគរ បរទេសឋានឆ្ងាយ សឹងតុំ
ជិតជា យក្សាប្រែក្សាយ សឹងតន់តិតហ្នាយ ជាឋានមនុស្ស ។ កុមារ
ពីរព្រោណ ថេរបិតសុខសាន្ត ក្នុងតិតបិតា បីដូចស្តេចបាន បិតឋានសួគ៌
តាំងពីកុមារ សឹងសុខសប្បាយ ។ តែធនាំអនុជា នូវអស់បរិពារ បរិ-
វារតាំងឡាយ ទៅលេងទន្យាន តំសាន្តព្រះកាយ ប្តូរថ្តើងពណ្តាយ ឥត
ព្រួយចិត្តា ។ លង់លុះខែត ខៀតទៅសហស្សសរ កុមារអនុជា
ផ្ញើសម្លក្តក្តនឹក រលឹកមាតា នូវមហាក្ស័ត្រជា ឥសូរចមទៅ ។ ទើប
ទូលដង្ហា សូមទ្រង់មេត្តា នាំអញទៅ បង្គំមាតា បិតាចមទៅ ជ្រឹត
យើងមកនៅ នេះយូរមហិមា ។

សម្តេចសាគរ ឆ្ងាស់ឆ្ងើយអង្វរ ហៃស្នេហ្នេហា ចាំពីរបីខែ
ខៀតទេស្នេក្តា សិមបងយាត្រា ដូនប្អូនមាសទៅ ។ សម្តេចសាគរ
លួងលោមអង្វរ ឃាត់ព្រះប្អូនទៅ ព្រោះហេតុកុមារ បានជាយោនៅ
ពិតតុំចង់ទៅ ចាកចោលឃ្លាតឃ្លា ។ នាំលេងទន្យាន ឲ្យត្រេមឲ្យក្សាន្ត
ឲ្យភ្លេចចិត្តា លុះហួសអំពី ពីរបីមាសា ចូលទៅវិញ្ញា ទូលតឿនបាទ
បង ។ លួងលោមថាតែ ចាំពីរបីខែ ទោះជាច្រើនដង យល់ព្រះអនុ-
ជា តក្រែសៅហ្មង ឲ្យបរិវារផង នាំលេងសព្វគ្រា ។

ទើងថ្ងៃដំណើរ ស្តេចយកក្តមួយក្តើ កុដន្តយក្ស ឈ្មោះសច្ច-
ត័ណ្ឌយក្ស សិទ្ធិស័ក្តិមហិមា ចានកដបុត្រា មួយឈ្មោះសច្ចត័ណ្ឌ ។

រីករាយក្សេមក្សាន្ត នៅលើបពិត្រ មួយធំពេកពន់ រុងរឿងឧត្តម ឈ្មោះក្នុង
សច្ចកណ្ឌ ពាលយក្ខអនន្ត អនេកសែនគោដ ។ ឮថាកុដន្ត ឲ្យបុត្រ
តន់ ទៅកុមារសោត ហេតុចិត្តប្តូរា ឥច្ឆាធុតនោត ធុរៈធរក្រៃ
ក្រោធ រន្ធត់គិតថា ។ កាលដើមសន្ធត ឧដ្ឋគ្នាច្រោកដ ឋានផ្សំផ្គុំគ្នា ឥន្ទ្រវ
ម្ភេចប្រៃ ឲ្យឯធ៌កា ទៅមនុស្សម្តេចវ៉ា ធ្វើតាមចិត្តចង់ ។ អញនឹង
លើកខ័ព ទៅឧឲ្យស្ងាប់ ចាំងអស់ពូជពង្ស គិតស្រេចខ្វល់ខ្វាយ ក្នុង-
ពាលចតុរង្គ សឹងយក្ខសឹងចង់ ប្រយុទ្ធជាញាដ័យ ។ សឹងមានអាវុធ
ឲ្យអានមុតៗ កាន់គ្រប់ដោយដៃ ខែលខ័នគោម៉ា ធ្នូសរស័ក្តិថ្លៃ
សំសៃវិដ័យ ស្មាស្មលំពែង ។ ដែកដោលជាវ៉ែ ជាវ៉ែលកដ៏ត ក្រ
ចាដែកស្តែង លើកលីន៏រកិត កាំបិតស្មៀតស្មែង ក្រម៉ៃលំពែង ដំពុះ
ខុងខួន ។ សូលីមូលស័ក្តិ ក្រឹះក្រោះដែកជាក់ គ្រប់ដោយរឿងខ្លួន
ខ្លះគង់អាព័ទ្ធ ធំធាត់មាំមួន ក្រលេកក្រលួន ក្អែកប៉ុនផ្លែដូង ។ ប្រែ
ប្រាណខ្លួនឡៅ ក្រឡេកមើលទៅ ក្អែកសភាតខ្ញង ខ្លះឡាំងឡៅ
មើលទៅដូចឆ្ងង ជាសដុះរោមទ្រូង សំបើមសំបា ។ ខ្លះខ្លួនខៀវ
ខាត់ ដូចព្រះឥន្ទ្រកំស្ត្រៃ ខ្លះសោភា ខ្លះលឿងខ្លះនួន ខ្លះខ្លួនដូចជា
ពិណព្រះសុរិយា ព្រះចន្ទ្រប្រសើរ ។ បណ្តាពណ៌មាន ទៅក្នុងក្រែ
ហាន យក្ខទំម៉ិតធ្ងើ គ្រប់ៗ ដូចអ្នក ឆ្នោទ្វាក់រូបឈើ ផែផាត់ថ្នាំលើ
ពិចិត្រចនា ។ ខ្លះប្រែរឹងថ្នាត់ សរសាជាសក្ខ ខ្លួនជាយក្ខា ក្បាល

ជារប្រើសត្រាយ ខ្ញុំក្តាយជាខ្ញា ខ្ញុះក្បាលសីហា ខ្ញុំជាអស្សតរ ។
ពលយក្ខសីនតែ តាឡាប្រាណប្រែ សត្វសត្តុកងជរ-ណីនេះឥតខ្ញុះ
ម្ខោម្ខះអួតអរ អួតអាងតាងក បន្ទឹត្តធ្លាយ ។ ក្បាលមៀមភ្នាតក្អែក
ផ្សែងៗផ្ទែកៗ ដោយពួកនិកាយ និតរ៉ែង អគ្គិសេនានាយ សោតសីង
ប្រែក្តាយ រូបរូបត្តា ។ ខ្ញុះដំរាជសីហ៍ ដំរះគោក្របី ដំរះមាសខ្ញា
ដំរះគោសង្ខ្ញុត ដំរះអួតដំរះលា ខ្ញុះដំរះអស្សពាហ៍ តែរះគោតគីលេន ។
ខ្ញុះដំរះលៀងកា ខ្ញុះដំរុំពា សឹងជាតំធំក្បែន សាក់សំនឹងខ្ញុន ម៉ាំមួន
មែនៗ អនេកសល់សែន សឹងមានចេស្តា ។ អួតៗគ្រែងៗ លាន់
ពួសំឡេង ញ៉ែរពាំងពសុធា ខ្ញុនខ្ពស់ធំជួន បីបួនប្រាំគា-រុតវែងខ្ញុនជា
បួនប្រាំយោជន៍យល់ ។ លុះបានជាគជ័យ ស្តេចទ្រង់អរក្រៃ ឲ្យបុត្រ
និមិល ចេញជាអាណា ត្រួតត្រាវេហ៍ពល សច្ចកណ្ឌថ្កើងថ្កល់ គង់
គជន្ទ្រោ ។ ពលយក្ខច្រើនក្រៃ សែនអសង្ខ្យេយ្យ តាំងហោរខ្ញៀវភ្ញា
កក្រើកខ្ចាខ្ចរ ញាប់ញ័រភាសុធា គោះគងជយា លើកពលចេញចរ ។
ដោយតេជពលមារ សែងសុរិយោគា អ័ព្ទអន្ធការ ល្អឹតល្អន់ព្រឹក្ស
ព្រៃ ខន់ដ័យសែតស ខ្ទៀវច្រាលលៀងប្រ- តិតដិតលើគ្នា ។ អស់
គ្រឿងសហស្ស ប្រទើសប្រទាស់ ក្រវីងជា ធំងធំងាស ខ្ទុះធ្លាស់
សោះសា ផ្ទែកៗ ដូចជា ផ្ទែកបន្ទោរពៅ ។ បរចូលចោមព័ទ្ធ
តុដន្តរម្យរដ្ឋ ដិតជុំក្រាសរ៉ាស់ ក្បាលមៀមភ្នាតស្រែក សម្រែកពួរពៅ

សំបើមដូចនៅ ចូលចាប់ចូលចឹត ។ ពលយក្ខសឹងស្រែក បន្ទុំសម្រែក បំភ្លូកបំភ្លឹក កំរេកំរើរ បន្ទុំពន្ធឹក តិតៗ នឹកៗ ស្ទើរចាប់នឹងដៃ ។

កុដន្តយក្ខយល់ សេនាពួកពល មារមកក្រាសក្រៃ ឥតព្រឺភេមមួយ ទ្រង់ព្រួយព្រះទ័យ តែនឹងបុត្រថ្លៃ ក្រែងខ្លាចយក្ស ។ ស្តេចឲ្យអាមាត្យ កំនត់ព្រាសាទ បុត្រទាំងទ្វេហា សឹងជាប់ខាន់ទាំង កំឆាំងកៅវគា មានពលសេនា សេនីចោមចាំ ។

រឯសច្ចកំណ្ហ ស្តេចចោមខេត្តខ័ណ្ឌ ដឹតដុំមួនមាំ បរិបូណ៌ស្រែច ស្រាប់ ស្តែងស្តេចឲ្យនាំ សារសំពួបណ្តាំ ទៅថ្វាយព្រាប់ប្រាយ ។ បើខ្លាចចេស្តា ចូលទុលដីតា ទឹងក្បាលមកថ្វាយ ប្រសិនបើមិង ពារឹងស្តែស្តាយ សមទឹងអន្តរាយ ជីវិតពុំរួច ។ អញទឹងផ្តាច់ឫ ស្រុកមិងឲ្យមរណ៍ មិនឲ្យគង់ពូជ កុដន្តយក្ខស្តាប់ សារសំពួជាក់ព្រួច ព្រះហទ័យដូច អគ្គីឆេះឆាប ។ គ្រាស់រីយសេនា ចូររៀបយោធាឫ រៀបពលកងទ័ព ឆាប់ ។ ឱ្យ ។ មន្ត្រីងងស្តាប់ ទទួលបង្គាប់ ចេញរៀបចតុរង្គ ។ សឹងប្រែកាឡា ដូចពលយោធា សច្ចកណ្ហយក្ខយង់ រៀបស្រេចរួសរាន់ កុដន្តយក្ខខង់ រដីរត្តដង់ លើកចេញពុំផ្សង ។

រីពីកុមារ យល់គេកំងឺព្រា ចិត្តបង្អួចចង ឮសំពួសន្ធឹក ពន្ធឹកអឺងកង ឥតក្លឹកប៉ុនល្អង សួរព្រះមហេសី ។ សំពួអ្នសួនក្តា ស្តេចឲ្យ

បិទទ្វារ បង្អួចហេតុអ្វី នាងទូលវិនិយ្ឆ័ត បពិត្រចក្រី សូរសព្ទសេនី
:សនាពលរេហ៍ ។ ស្តេចសង្ខត័ណ្ឌជា ក្មេងធំបិតា សម្ងាញ់ស្មាលស្នេហ៍
បានសូមអញ្ជុំ ផ្សំធំកូនគេ ឥឡូវស្តេចប្រែ ឲ្យមកក្សត្រា ។
បានជាគេខឹង លើកពលមកទីង សម្ងាប់ពលគ្នា ត្រែងត៍ត្រែធាង
ខួបខ្វាចយក្សា បានជាបិតា ឲ្យរាំងទ្វារចង ។

សមុទ្រសាគរ ស្តាប់ហ៍យត្រែកអរ ត្រាស់ហៅស្ងួនត្រង ចង
អ្នកឯងអាច ពុំខ្វាចប៉ុនល្អង ឲ្យធ្វើមកបង ទៅជួយបិតា ។ នាងថ្វាយធ្នូសរ
ស្រេចស្តេចចេរចេរ ព្រមព្រះអនុជា បរិវារសឹងតែ ហៅ។ យាត្រា ដួចពាជ-
សីហា ឥតតិតឥតត្រែង ។ ពួកពលយក្សា យង់យល់កុមារ សោតសឹង
ស្ងប់ស្ងៀង ទៅចាន់បិតា វន្ទាទូលថ្វៃង សារសុំសំដែង នូវគេជចេស្តា ។

កុដន្តយក្ខទុប ថ្កាត់ថ្មក្រសោប ត្រាស់ហៅស្ងួនក្ងា កុំចាត្រួយ
ខ្លៃយ ត្រាស់ហើយយក្សា ពពីកុមារ មកទុកច្រាសាខ ។ ស្រេច
ស្តេចយក្សា រិលវិនយាត្រា ខឿនទៅខ្ញុំឃ្នាត កុមារពុំនៅ តាមទៅ
អាក់ខ ទីខៀបព្រះបា-ទាទូលស្រដី ។

បពិត្រយើងខ្ញុំ ពាំងពីរពិតពុំ ខ្វាចប៉ុនកេសី កុំថាប៉ុណ្ណោះ
នោះខោះយោប៍ លើសនេះរយក្តី ក៏និរ័យកិត ។

(មានត)

ឧកញ៉ាវិបុលរាជសេដ្ឋ ឆ្លូ-កិច្ច ប្រែរៀបរៀង

(តមក)

រឿងសាមគ្គីកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាស បើបានអាន
ធឹងបេះទុយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ទៀតតាបថា ឯទីប្រឹក្សារបស់ខ្ញុំបាទក៏មានដែរ គឺស៊ុនខៀន ប៊ីគុកនឹងកាន់យ៉ាង ចាំង ៣ នាក់នេះ សុទ្ធតែជាមនុស្សគួរទុកចិត្តមកពីដើមឯគួនអ៊ូនឹងខៀវហ៊ុយ ដូច្នេះ ចាំង ៣ នាក់នេះក៏ជាសេនាឯកដែរ ធ្លាប់សុចរិតពិតត្រង់នឹងខ្ញុំបាទ ដូចបងប្អូនរួមទរ ១ ជាមួយគ្នា តែហាក់ថាបុណ្យខ្ញុំបាទគ្មាន ទើបតាំងខ្លួននៅមិនជាប់ដូច្នេះ ។ សុមាតេកនោធ្វើយថា ឯស៊ុនខៀន ; ប៊ីគុកនឹងកាន់យ៉ាងនោះអ្នកមកពាប់ថា មានតម្រិះប្រាជ្ញាជាទីប្រឹក្សាផងនោះមិនបានទេ អ្នកចាំង ៣ នាក់នេះ គ្រាន់តែជាមនុស្សច្រេះអក្សរ

សំបុត្រតត់ហ្មាយ នឹងខ្មាប់ខំរៀមពីដើមប៉ុណ្ណោះ ទោះមឹងប្រាស្រ័យ
តម្រិះរៃគិតផ្សាស់ប្តូរ ក្នុងការសឹកសង្រ្គាមមិនបានទេ ទោះបីមឹងមានខ្លួនក៏ដូចជាមិនមាន ឯគួនអ្វី, ខ្លៀវហ៊ុយ, ដូឡុង ក៏គ្រាន់តែមានថ្វីដៃខ្លាំងពូកែអង់អាច អាចតឹងពលយោធា ម៉ឺន_សែនបានមែន តែថាបើគ្មានអ្នកចេះចាត់ការរៃប្រើប្រាស់ឲ្យស្គាល់ឪក្រែវិជ្ជាយុទ្ធសាស្ត្រ ក៏មិនអាចសម្រេចទៅតាមថ្វីដៃបាន ។ ឡៅពីតបថា លោកមានប្រសាសន៍នោះត្រូវណាស់ហើយ ព្រោះសព្វថ្ងៃនេះខ្ញុំបាទក៏ទំនើបស្មើរស្មេះស្មេងរកមនុស្ស ដែលល្អមានតម្រិះប្រាជ្ញានោះណាស់ដែរ ដើម្បីឧឹងបានជួយទប្បកិច្ចកុំឲ្យតបុំរុងតទៅ តែថាឧឹងខ្ញុំគាល់ឧឹងរៃរកមិនបានដូចចិត្តប្រាថ្នា ។ សុមាតេតធោមិយាយថា បុពណាលោកពោលទុកពីដើមមកថា ១០ នាក់ត្រូវរកអ្នកខ្លាំងពូកែម្នាក់ឲ្យបាន, ១០០ នាក់ត្រូវជ្រើសរើសរកអ្នកមានតម្រិះប្រាជ្ញាឲ្យបានម្នាក់ ឯមនុស្សពាលឧឹងតួងក៏មានទៅជាច្រើនណាស់ បើប្រសិនជាអ្នកត្រូវការឧឹងប្រាថ្នារកអ្នកមានតម្រិះប្រាជ្ញានោះ ក៏គង់ឧឹងបានដូចសេចក្តីប្រាថ្នា ។ ឡៅពីតបថា លោកមានប្រសាសន៍នោះត្រូវស្តាប់ណាស់ តែថាខ្ញុំបាទមានតម្រិះរៃគិតតិចតម្រៃដែលឧឹងពីគ្រោះរកយើញ សូមលោកអនុគ្រោះបំភ្លឺណែនាំឲ្យខ្ញុំបាទដឹងផងចុះ ទោះបីមនុស្សនោះនៅឆ្ងាយដាច់ភ្នំណា ក៏ឧឹងតាំងចិត្តគិតយាត្រាស្វះស្វែងទៅរក ។

សុមាតេតធោឆ្លើយថា អ្នកដែលមានតម្រិះប្រាជ្ញានោះ ក៏មាននៅ

មិនសូវឆ្ងាយដូចប៉ុន្មានទេ បើអ្នកមានសេចក្តីប្រាថ្នាទំនឹងសមាគមផង ក៏ចូរទស្សាពិព្យាយាម សូរសែងទៅរកគង់តែនឹងជួបប្រទះ ។ ឝ្លៅពីថា មនុស្សល្អដែលមានតម្រិះប្រាជ្ញានោះទៅទិសដំបន់ឯណា ខ្ញុំបាទនៅមិនទាន់ដឹង ។ សុមាតែកធ្វើថា តើហុកឡុងទំនឹងហុងស៊ូ ៦ នាក់នេះ បើបានយកមកទុកជាទីប្រឹក្សាផង សូម្បីតែម្នាក់ណាមួយ ក៏អាចនឹងរៃគិតប្រាប់ប្រាមសត្រូវផែនដីឲ្យស្ងប់ពាំងអស់បាន ។ ឝ្លៅពីតបថា ដែលលោកមានប្រសាសន៍ថា ហុកឡុង, ហុងស៊ូនោះ ខ្ញុំបាទមិនយល់ថាឈ្មោះអ្វីសោះ ។ សុមាតែកធ្វើស្តាប់ហើយក៏ទះដៃសើចថាល្អហើយ ឝ្លៅពីក៏ដឹកដៃដែកសួរទៅទៀតថា លោកចូរអនុគ្រោះប្រាប់ឲ្យខ្ញុំបានដឹងផងចុះ ។ សុមាតែកធ្វើថា ពេលថ្ងៃនេះក៏ជួនដាយប់ទៅហើយ បើអ្នកបង្អែបង្អង់នៅមួយយប់សិន ត្រឹកស្អែកខ្ញុំនឹងប្រាប់ឈ្មោះឲ្យដឹង ហើយក៏ឲ្យកូនសិស្សទទួលយកសេះរបស់ឝ្លៅពី នាំទៅចងខាងក្រៅផ្ទះ ហើយឲ្យរៀបអាហារឲ្យឝ្លៅពីបរិភោគ រួចក៏រៀបទីនិទ្រាឲ្យឝ្លៅពីឈប់ស្រាយដំណេក ។ ឝ្លៅពីក៏ចូលទៅកន្លែងដំណេក ប្រាសខ្លួនដេកទៅលើខ្នើយឲ្យគិតរំពឹងដល់ពាក្យសុមាតែកធ្វើប្រាប់សេចក្តីមិនឲ្យច្បាស់ ក៏ចេះតែរវិតរវែកដេកមិនលក់ដល់ពេលយាមមួយ ឮមាត់មនុស្សម្នាគោះទ្វារហៅពីក្រៅ ឲ្យបើកទ្វារ ហើយមនុស្សនោះចូលទៅរកសុមាតែកធ្វើនៅខាងក្នុង ។ សុមាតែកធ្វើសួរថា អ្នកមកមានការអ្វី ? ឈីស៊ីតនាប់ហើយប្រាប់ថា ខ្ញុំថាមកនេះមានសេចក្តី

ប្រាថ្នាដើម្បីសន្ទនានឹងលោក ព្រោះខ្ញុំបានឮគេនិយាយថា ឧត្តរមាណពនោះ មានចិត្តល្អធ្ងន់ធ្ងរ ឈ្លាសវៃក្នុងការសន្ទនា ជាអ្នកមានតម្រិះប្រាជ្ញា ដើម្បីបត្តម្ភថែរក្សាមនុស្សឲ្យបានចំរើនត្រប់ប្រការ មិនបានសេពគប់នឹងមនុស្សទុច្ចរិត ខ្ញុំក៏គិតទស្សាហ៍សូរែស្វែងរកតប្រាថ្នា នឹងចូលធ្វើការដើម្បីនឹងឧត្តរមាណពនោះ ខ្ញុំនៅនៅសំណាក់នឹងឧត្តរមាណពតែម្នាក់ឯង តែមិនសមសេចក្តីដែលបានឮមកនោះសោះ ពោះបើនឹងប្រែមនុស្សដែលមានតម្រិះប្រាជ្ញាសោត ក៏មិនស្គាល់ច្បាស់ការដែលនឹងបង្គាប់បញ្ជា សូម្បីនឹងពោលតំបាត់មនុស្សឲ្យចាលឲ្យប្រាសចាកចេញក៏ពុំបាន ខ្ញុំឃើញថាសន្ដានចិត្តឧត្តរមាណពនោះ ប្រព្រឹត្តការពាំនាំពួនមិនបានដោយប្រយោជន៍ បានជាខ្ញុំគេចដោះខ្លួនចេញមកវិញ ។

សុមាតែកនោះបានស្តាប់តំបាំ ថាខ្លួនអ្នកជាមនុស្សមានសតិបញ្ញា គួរតែនឹងស្វែងរកធ្វើការពាក់ព័ន្ធនឹងអ្នក ដែលមានចិត្តល្អ ធ្ងន់ធ្ងរ ឈ្លាសវៃក្នុងការគប់មនុស្សល្អ សព្វថ្ងៃនេះអ្នកដែលមានតម្រិះប្រាជ្ញាជ្រៅធ្ងន់ឈ្លាសតំមានប្រកបដោយនឹងក្នុងអ្នកហេតុម្តេច ទើបមិនពិគ្រោះមើលឲ្យដាច់ថា ឧត្តរមាណពនោះល្អឬអាក្រក់ឲ្យជាក់ច្បាស់មិនសឹមចូលទៅនៅផង ។ ឈើស៊ីធ្វើយ៉ាងនោះ លោកមានប្រសាសន៍នេះត្រូវណាស់ហើយ ខណៈកាលឈើស៊ីចូលទៅសន្ទនាគ្នានឹងសុមាតែកនោះនោះ ឧត្តរមាណពនៅស្តាប់ឮសំដីតំគ្រោតឡើងក៏ស្តាប់បង់សព្វសេចក្តី តំគិតតែក្នុងចិត្តថា ដែលសុមាតែកនោះប្រាប់ពីថ្ងៃថា មនុស្សដែលមានតម្រិះប្រាជ្ញានៅ មិនសូវឆ្ងាយណាស់ដូចណាស់

នោះ ប្រហែលជាអ្នកនេះទេដឹង? សំគាល់ក្នុងចិត្តដូច្នេះហើយក៏អានសេចក្តី
ត្រែតអរណាស់ លុះខឹងចេញមកសួរនាថង ក្នុងគោលបំណងនោះអារម្មណ៍
ខ្លាចចិត្តសុមាតែតនោ ។

លុះវេលាព្រឹកឡើង ទ្បៀតីសួរសុមាតែតនោ ។ ច្រាប់ទ្បៀតីថាអ្នក
ដែលមកចរចាយប់មិញនោះជាគ្រឿនសំឡាញ់កប់អានរបស់យើង ។ ទ្បៀ
តីថា ធ្លើម្តេចខ្ញុំបានឮឯងបានយើញស្គាល់ខ្លួនផង លោកចូរអនុគ្រោះឲ្យ
បានមកជួបសន្ទនាបន្តិចបានឬទេ ? ។ សុមាតែតនោច្រាប់ថា គេទៅវិញតី
យប់មិញទៅហើយ ។ ទ្បៀតីសួរថា អ្នកនោះឯងឈ្មោះអ្វី ? សុមាតែត -
នោ ស្តាប់ហើយក៏សើចថាល្អហើយ ។ ទ្បៀតីថា ដែលលោកឮឯងអាណិត
ខ្ញុំបាទច្រាប់ឈ្មោះឲ្យដឹងក៏ចូរច្រាប់មកចុះ តើហុកឡង់ហុងស៊ីនោះជាឈ្មោះ
អ្នកឯណាសោត? សុមាតែតនោក៏សើចថាល្អហើយ ។ ទ្បៀតីយើញថាសុ -
មាតែតនោមិនព្រមច្រាប់ឈ្មោះ ឲ្យច្បាស់ចេះតែសើចដូច្នោះ ក៏ថាសព្វថ្ងៃ
នេះខ្ញុំបាទមានសេចក្តីច្រាថ្នាឥឡឹងខ្លាំងបំរុងផងដែ ព្រះចៅហៀនតេឲ្យបាន
សេចក្តីសុខ ក៏នៅមិនទាន់ឃុនសម្រេច បើឃុនប្រកបដូចលោកមានប្រ -
សាសន៍ តើដួបប្រទះនឹងអ្នកមានតម្រិះប្រាជ្ញាណាទីមួយ យកទៅឆ្លើយជាទី
ប្រឹក្សា ដួយរៃគិតការពាំងពួង យើញថាផងដែព្រះចៅហៀនតេនឹងចំរើន
សូមអញ្ជើញលោកទៅដួយធ្លើការពារការជាមួយនឹងខ្ញុំបាទចុះដើម្បីនឹងបាន
ដួយអនុគ្រោះព្រះចៅហៀនតេផង ។ សុមាតែតនោឆ្លើយថា ខ្លួនយើងជា

ជាតិអ្នកស្រែចំការទៅស្រុកគ្រៅមានសតិបញ្ញាតិចណាស់ បើនឹងធ្វើពាណិជ្ជ-
ការជាមួយនឹងអ្នកនោះយើញថាមិនបាន ឯអ្នកមានតម្រិះប្រាជ្ញាលើស
ជាងយើងនោះក៏នៅមាន ចូរអ្នកទំនុះស្នងទស្សាហ៍ទៅកុះ ។

ក្នុងខណៈដែលសុមាតែកនោ នឹងឡៅពីកំពុងសន្ទនាគ្នានៅទីនោះ
ដូឡុងក៏នាំពាហានប្រហែល ១០០ នាក់ ស្ទុងមកជាប់តាមឡៅពីចូលទៅ
សំទៀងពាហានក៏តិតកងំពង ។ ឡៅពីក៏ស្ទុតចិត្តគ្រោតចេញទៅមើល
យើញដូឡុងនាំមុខ ក៏មានសោមនស្សក្នុងចិត្តពន់ប្រមាណណាស់ ដូឡុង
យើញឡៅពីក៏លោតចុះពីលើសេះ ចូលទៅគំនាប់ឡៅពី ហើយក៏ពាណិ-
នារឿងដែលស្ទុះស្ទងតាមកនោះ ឲ្យឡៅពីស្តាប់គ្រប់ប្រការ ហើយថា
សូមឲ្យលោកតិតប្រញាប់ត្រឡប់ទៅស្រុកសុំនអៀចុះ ខ្លួចសត្រូវនឹង
ទៅធ្វើប្រទូស្តរ៉ាយឯក្រោយ ។ ឡៅពីបានស្តាប់ក៏ចូលទៅលាសុមាតែក
ធោហើយក៏ឡើងសេះចេញទៅជាមួយនឹងដូឡុង ទៅចម្ងាយពីភូមិនោះប្រ
ហែល ៦០ សិន (៩០០ ម.) ខ្លួលដួបប្រទះនឹងគួនអ្ងិ, ឡៃហ៊ុយ
លើកពាហានតាមមក ។

(មានត)

លោកវ៉ាយ-ប៊ុក ជាកវីដ៏ហើយ រៀបរៀង

(តមក)

៣៤_ កុំឲ្យយកសម្បៀកបំពាក់នៃការខុសគាន់ច្រឡំទៅស្រោបសច្ចធម៌ សេចក្តីពិតណា ដែលខ្លួនបានដឹងហើយ, មិនត្រូវលាក់បិទបាំងទេ ។

៣៥_ ចូរអ្នកសូត្រធម៌ តាមកាលវេលា, ចូរធ្វើអំណោយ, ចូរទុនក្បាលគោរពជាមួយនឹងអ្នកចាំឆ្លាយដែលទុនក្បាលនោះ ។

៣៦_ ចូរអ្នកយកខ្ពើមឆ្អើមការសូត្រធម៌ឲ្យដួយអកុសលអ្នក ពិតមែនតែខ្ពើមឆ្អើមការសូត្រធម៌ជាការលំបាកនឹងធ្វើ ។

៣៧_ អ្នកណាដែលទិញជីវិតសម័យបច្ចុប្បន្ន ដោយយកជីវិតអនាគតជាតម្លៃ ជាបដែលអ្នកនោះបានធ្វើមិនមែនស្រាលទេ, ហើយអ្នកនោះគ្មានអ្នកណាជួយទេ ។

៣៨_ ភាពល្អសូត្រធ្ងន់នឹងការអត់ទន្ទឹងពាសប្រសើរជាងការឲ្យទានដោយធ្វើខុសលំបាកដល់អ្នកសុំ ។

៣៩_ មនុស្សភាំងឆ្លាយយល់ថា រស់នៅប្រសើរក្នុងលោក ចំពោះជីវភាពនៃមនុស្សដែលសប្បាយត្រេកត្រអាលនឹងស្ត្រី, បុត្រា បុត្រី, គំនរ

ទ្រព្យសម្បត្តិមាសប្រាក់, សេះជាតិធំ, ហ្វូងបសុសត្វ, នឹងស្រែចម្ការ ។

៤០- ចំពោះអ្នកណាដែលបំពេញតំណែងទាំងឡាយគ្មានតម្លៃនៅក្នុងលោកនេះ នឹងលោកខាងមុខទេ អ្នកនោះកុំសង្ឃឹមថា ឲ្យគេជួយ ។

៤១- អ្នកនិយាយនឹងមាត់ តែចិត្តដោយខ្លួន ។

៤២- ដំរីភាពនៅក្នុងលោកនេះ ប្រកបដោយទុក្ខលំបាកគ្រប់យ៉ាង ។

៤៣- កុំឲ្យគិតថា អ្នកណាដែលមានមនោសញ្ចេតនាសប្បុរិយចំពោះការដែលខ្លួនបានធ្វើ ហើយចង់ឲ្យគេសរសើរខ្លួន ចំពោះកិច្ចការដែលខ្លួនមិនបានបំពេញ អ្នកនោះនឹងបានសេចក្តីសុខ នឹងផុតពីទុក្ខភោសភ័យ ។

៤៤- អ្នកកាចពាលទុច្ចរិត គ្មានអ្នកណាជួយទេ ។

៤៥- ចូរអ្នកកាន់ខ្លួន, ចូរអ្នកគ្រប់គ្រងដោយខ្លួន ។

៤៦- ចូរអ្នកឲ្យកោតទ្រព្យនៅក្នុងកំព្រា: កុំអ្នកឲ្យវត្តអាក្រក់ថា ប្លន់យកវត្តល្អ: កុំឲ្យបំផ្លាញទ្រព្យវត្ត ដោយទ្រព្យរបស់អ្នក ។

៤៧- កុំឲ្យផ្ទៀកោតទ្រព្យរបស់អ្នកនឹងពួកពាលទុច្ចរិត ។

៤៨- កុំឯងរកវៀនឈ្លោះប្រកែកនឹងអ្នកដែលកាន់ច្រឡំខ្លួនឯង ។

៤៩- អ្នកដែលប្រព្រឹត្តអាក្រក់ អ្នកនោះនឹងបានផ្សាន់អាក្រក់ ។

៥០- បើឯងសន្ធឹងដៃមកកាន់ខ្ញុំ ដើម្បីសម្លាប់ខ្ញុំ។ មិនសន្ធឹងដៃខ្ញុំទៅកាន់ឯង ដើម្បីសម្លាប់ឯងទេ ។

៥១- កុំឲ្យអ្នកសាកសួរកន្ទរវាត្ ដែលគេបង្ហាញឲ្យអ្នកដែលបណ្តាលឲ្យមានទុក្ខទោសភ័យ ។

៥២- ចូរឯងឃើញទេ មើលអ្នកនេះពោលពាក្យកុហកតែខ្លួនឯង ហើយពាក្យដែលពោលនេះវាត់ផ្ទាយពីខ្លួនគាត់ ។

៥៣- ការរស់នៅក្នុងពិភពលោក ជាល្បែងតំសាន្ត ។

៥៤- អ្នកណាដែលមានសទ្ធាជឿជាក់ ហើយមិនឲ្យសទ្ធានោះធ្លាក់ទៅក្នុងកណ្តាប់ដៃអយុត្តិធម៌, អ្នកនោះនឹងបានសេចក្តីសុខ, នឹងមានគេដឹកនាំទៅរកសេចក្តីសុខ ។

៥៥- ចូរឲ្យគ្នាសើចបន្តិចសិន, ពីព្រោះគ្រាយំច្រើនជង់ហើយ នេះគឺជារង្វាន់ដ៏ប្រសើរ ។

៥៦- អ្នកនេះពេញចិត្តស្ថិតនៅជាមួយនឹងអ្នកខាងឡាយដែលនៅក្រោយគេ ។

៥៧- ត្រាមួយចោះចំហរយវត្ថុរបស់ខ្លួន ។ មិនយល់សោះឡើយ ។

៥៨- ចំពោះអ្នកដែលធ្វើសេចក្តីល្អ សភាពល្អខាងសីលធម៌តម្រើន; ផង់ធុលីដីដែលធ្វើឲ្យប្រឡាក់មុខ, ការអៀនខ្មាស់គ្មានគ្របមុខ, អ្នកនោះ មិនឲ្យគេឃើញបានឡើយ ។

៥៩- អ្នកណាដែលធ្វើសេចក្តីអាក្រក់ អ្នកនោះនឹងបានខូចខ្លួនឯ

សេចក្តីអាក្រក់, ហើយសេចក្តីឮៗសន្ធឹងស្រោចជាងកាយអ្នកនោះបញ្ចេញ
ឲ្យគេឃើញមិនខាន ។

៦០- ដីវាលនៅក្នុងពិភពលោកនេះ បើប្រៀបធៀបនឹងដីវាលនៃ
បរលោក ដូចជាការទទួលផលិតផល ចំពោះអ្នកទទួលដួលដី ពីអ្នក
កម្មសិទ្ធដី ។

៦១- កំពាលអ្នកមួយម៉ាត់ ប្រៀបដូចជារុក្ខជាតិល្អមួយដើម ដែល
មានឫសចាក់ជ្រៅមាំមួនខ្លាំងនឹងដី ធន់ទៅនឹងការដុះស្រោង
ស្រាងទៀតលើមេឃ ។

៦២- កំពាអាក្រក់មួយម៉ាត់ ប្រៀបដូចជារុក្ខជាតិ អាក្រក់មួយដើម
ដែលគេដកចេញពីលើដី : គ្មានកន្លែងនឹងនួនទេ ចំពោះរុក្ខជាតិនេះ
ដែលគេកំណត់ខុតជាស្រេច ។

៦៣- គ្មានប្រជាពស្ត្រណាអាចធ្វើកាលវិលាឲ្យបានធាប់ហ័ស ឬ
បង្អង់ឲ្យយឺតយូរបាន ។

៦៤- បើអ្នកធ្វើសេចក្តីល្អ បានសេចក្តីល្អចំពោះខ្លួនដោយខ្លួនឯង បើ
អ្នកឯងប្រព្រឹត្តការអាក្រក់ បានការអាក្រក់ចំពោះខ្លួនដោយខ្លួនឯង ។

៦៥- អ្នកណាឲ្យគេដឹកនាំ អ្នកនោះគឺឲ្យគេដឹកនាំចំពោះខ្លួនដោយ
ខ្លួនឯង ។

(មានត)

រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន

លោក រ៉ាយ - ប៊ុក ប្រែរៀបរៀង

(តមក)

បុរសមិនស្គាល់អ្វីសោះឡើយ ស្គាល់តែក្តុតូច ។ ទឹងស័ព្ទសូរ
ខ្ចីតជ្រៅហូរគាត់ភូមិ ។ គេហដ្ឋានចាំងប៉ុន្មានសុទ្ធតែប្រក្រនិត្រាយ
ចាំងអស់ មានគេហដ្ឋានខ្លះធំជាងមុន ខ្លះទើបទឹងជួសជុលថ្មី ។ មានស្រែ
ខ្លះមិនដូចពីកាលមុន ចំណែកឯព្រះវិហារដែលស្ថិតនៅពីដើមឯមាត់
សមុទ្រ ឥឡូវនេះ គេសាងជាថ្មីនៅលើភ្នំ ។ នៅដីតគេហដ្ឋាន
បិតាមាតាអ៊ីសៀម៉ាតារ៉ូ មានព្រៃស្រល់ដុះដុំវិញ ។

អ្នកត្រាច់តាមផ្លូវក្រឡេកមើលអ្នកនេសាទដោយចិត្តធ្ងន់ ។
ពីដើមបុរសស្គាល់អ្នកស្រុកស្ទើរចាំងអស់ ឥឡូវនេះមុខចាំងអស់បុរសមិន
ស្គាល់ទៅវិញ ។ ក្នុងពេលនោះ, ស្រាប់តែមានតាចាស់មួយកាន់ឈើ
ច្រត់អញ្ជើញមកដល់ទីនេះ ។ បុរសគិតក្នុងចិត្តថា តាចាស់នេះប្រ
ហែលជ្រាបនូវតិមាសព្វគ្រប់ អំពីរឿងភូមិនេះ ។

គិតក្នុងចិត្តហើយក៏ចូលទៅដិតតាចាស់ហើយពោលថា: ខ្ញុំបាទ
លោកតាអត់ទោស សូមលោកតាប្រាប់ខ្ញុំ តើគ្រួសារអ៊ីសៀម៉ាតារ៉ូទៅ
ទីណាលោកតា ? ។

តាចាស់ក៏តបមកបុរសវិញថា: អ្នកពោលយ៉ាងណា អ៊ុំរស្សីមា៉តារ៉ូ ម្តេច អ៊ុំរស្សីមា៉តារ៉ូ? ។

បុរសស្មានថា តាចាស់ចូងក៏ស្រែកយ៉ាងខ្លាំងថា: អ៊ុំរស្សីមា៉តារ៉ូ អ៊ុំរស្សីមា៉តារ៉ូ! តើគ្រួសារអ៊ុំរស្សីមា៉តារ៉ូ នៅឯណា លោកតា? ។

តាចាស់ក៏តបថា: "អ្នកឯងឆ្កួតឬ? ឬអ្នកឯងមកពីណា, បានជាមិនដឹងរឿងនេះ, អ៊ុំរស្សីមា៉តារ៉ូ អ្នកឯងមិនដឹងថាជានាមនៃអ្នកនេសាទម្នាក់ដែលលង់ទឹកស្លាប់តាំងពី ៤ សតវត្ស នៅក្នុងសមុទ្រនេះ ហើយដែលគេរកសាកសពនឹងខ្លួនមិនឃើញ អ៊ុំរស្សីមា៉តារ៉ូ គេបានធ្វើចេតិយនៅថ្មបង្គួនមួយ ថ្មបង្គួនដែលគេលែងតប់សពតាំងពី ៩០ ឆ្នាំមក ។ អ្នកឯងអាចទៅទស្សនាបាននូវចេតិយនោះ ។ ម្តេចក៏ឯងមិនដឹងនូវពត៌មានតាំងនេះ បានជាអ្នកឯងសួរថា តើគ្រួសារអ៊ុំរស្សីមា៉តារ៉ូនៅឯណា? ។

តាចាស់ក៏គ្រវីក្បាលធ្វើទឹកមុខញញឹមញញែមហើយដើរទៅ ។

អ៊ុំរស្សីមា៉តារ៉ូក៏បានគ្រាប់ទៅតាន់ថ្មបង្គួនចាស់ ហើយក៏បានទៅឃើញចេតិយដែលតម្កល់សពបរស់ខ្លួន, សពបិតា, មាតា នឹងបងប្អូនញាតិសន្តាន ។ សំលាដែលធ្វើចេតិយនោះ មានស្មៅដុះព័ទ្ធជុំវិញហើយចាស់ណាស់ មិនអាចនឹងអានអក្សរដែលចារឹកនាមឈ្មោះបាន ។

បុរសគិតក្នុងចិត្តខ្លួនប្រហែលជាយល់សប្តិ តែយល់សប្តិនេះមិនអាចនឹងដឹងហេតុផលសព្វគ្រប់ ។ បុរសបានគាន់ខ្ជាប់ប្រអប់តូចនោះនៅដៃ, ប្រអប់ដែលព្រះនាងជាបុត្រីស្តេចកុដន្ធនាគបានឲ្យ ។

បុរសពោលចំពោះខ្លួនឯងថា: អ្នកណាអាចដឹងបានថា ប្រហែលជាប្រអប់ពិសិដ្ឋតូចនេះឯង ដែលធ្វើឲ្យប្រែប្រួលទេសភាព ដុំវិញខ្លួនអញ? ឬប្រហែលជាប្រអប់ពិសិដ្ឋតូចនេះ ដែលជាមូលដ្ឋាននៃការដោះស្រាយឲ្យជាក់ច្បាស់នូវសភាពប្រែប្រួលទាំងនេះ..។ បើអញបើកប្រអប់នេះគឺវាយ៉ាងណាទៅ អញបានសន្យានឹងទេពីអញថា អញមិនស្រាយខ្សែសូត្រដែលចងមុខប្រអប់នេះសោះឡើយ តែអញនឹងធ្វើចំណងនេះឲ្យដូចព្រះនាងធ្វើឲ្យបេះបិទ កុំឲ្យព្រះនាងទ្រង់សង្ស័យសោះឡើយ; ហើយព្រះនាងលែងនឿងគួលអ្វីឡើយ, អើ ត្រូវតែអញយល់ជាក់ច្បាស់នូវទេសភាពដែលមានមកប្លែក។ ដុំវិញខ្លួនអញហើយអញនឹងយល់នូវទេសភាពនេះបាន លុះត្រាតែអញបានបើកប្រអប់តូចនេះ ។

ពោលដូច្នេះ បុរសក៏ស្រាយខ្សែសូត្រដែលចងមាត់ប្រអប់ បើកប្រអប់នោះឡើង ស្រាប់តែមានចំហាយ ដូចពពកមានពណ៌សហុយ ចេញពីក្នុងប្រអប់រត់ចេញទៅខាងក្រៅ ចំពោះទៅកាន់កោះដ៏ឆ្ងាយនាដែលស្តេចកុដន្ធនាគទ្រង់គង់នៅ, មានតែប៉ុណ្ណោះក្នុងប្រអប់តូចនោះ ។

ក្នុងខណៈពេលដែលអ៊ុំស្រីម៉ាតាប្រកែកយល់ដាក់ច្បាស់ថា តាវដែលធ្វើនោះមិនសមរម្យ
សោះ មិនគួរនឹងធ្វើ... ព្រោះថា តាំងពីថ្ងៃដែលបើកប្រអប់នោះបុរសនោះ
លែងបានវិលត្រឡប់ទៅកព្រះនាងវិញហើយ លែងបានត្រេបខ្លួនជាសស
សុខដុំរមនានៃការស្នឹតនៅជាមួយនឹងព្រះនាងដូចពីកាលមុនហើយ....

បុរសក៏ខ្លួញយំ , យំហើយយំទៀត.... ។

ក្នុងមួយរំពេច ស្រាប់តែលោហិតនៃបុរសទៅជាកកនៅក្នុងសរសៃ
ហូរមិនរួច អាយុរៈទៅជាត្រឹមត្រូវតិសក់ទៅជាស ធ្មេញបាត់ជ្លក់អស់
កំប្លុងអន់ថយតាមលំដាប់, បុរសក៏ដួលទៅលើដែនដី បួនសតវត្សដែល
បុរសបានរស់នៅឯព្រះបរមរាជវាំង ស្តេចកុដន្ធនាគ ឬ ព្រះអាទិទេពមហា
សាគរ ដូចជាត្រូវសង្កត់ទៅលើខ្នងអ៊ុំស្រីម៉ាតារួច ក៏ទៅជាចាស់ដងត្រាំ
ត្រា លែងបានស្ថិតទៅជាយុវនភាពបានតាំងពីនោះមក ។ អ៊ុំស្រីម៉ាតារួ
ក៏ខ្លួលមរណភាពក្នុងពេលនោះទៅ ។

អធិប្បាយបច្ចាប់កែរ៉ែកាល

ស្រី - អ៊ូ រៀបរៀង

(តមក)

អធិប្បាយ_. ទឹកនៃ្ទសម្រាប់ដេកជាប្រក្រតី ដេកជានិច្ច ដូចគ្រែពួក ខ្នើយកន្ទេល មុន ត្រូវរៀបចំឲ្យត្រឹមត្រូវ ចោកគក់ជ្រលក់លាងសំអាតជានិច្ច ទើបខេ្ចាដួយបីចាប់ថែរក្សា ដួយចំរុនចំរើនជាគជ័យ សេចក្តីសុខនឹងសិរីសួស្តី ។

១៨- គ្រឹះហោឲ្យធ្ងិតធ្ងៃង់ កុំឲ្យធែងធ៉ុយធុលី
ជម្រែបំ[1]បោសជាំ ឲ្យ៉ែតប្បាងកើតសុខា ។

អធិប្បាយ_. ផ្ទះសម្បែងត្រូវរៀបចំឲ្យស្អាត ឲ្យមានរបៀបត្រូវបោសផង់ធុល បោសសំបុកឥងពាង ជ្រែងភ្លើង ធ្វើឲ្យស្រឡះស្រឡំ តាំងភូមិហាន ត្រូវដំរះស្មៅ ពង្រាបដី ឲ្យរាបស្មើល្អ កុំឲ្យស្មៅដុះព្រុលព្រុប កុំឲ្យមានជ្រាំ មានសំអុយ ត្រូវថែទាំឲ្យត្រូវតាមច្បាប់អនាម័យ ជាហេតុមិនឲ្យកើតរោគផ្សេង ។ ទើបកើតសេចក្តីសុខកាយសប្បាយចិត្តជានិច្ច ។

១៩- អ្នកញ្ជូលទុកឲ្យគង់ ប្រាក់ក្នុងបីដង់ទុកឲ្យជា

១-សាស្ត្រាខ្លះថា ជម្រះជាជោសធំ ។

ប្រើខ្ញុំមើលបិត្តូវ៉ា[1] ទោះកាបជាមើលឲ្យស្លៃង ។

អធិប្បាយ_. គ្រឿងប្រដាប់ប្រើប្រាស់ផងទាំងពួង ត្រូវរក្សាឲ្យគង់សុម្បីម្តុលចេស តែគេត្រូវរក្សាទុកឲ្យគង់កុំឲ្យបាត់ញឹកញាយពេក ! ប្រាក់គាសដែលបានចូលថង់ ចូលទូរ ចូលហិបហើយ ត្រូវប្រយ័ត្នឲ្យគង់វង់ កុំយកចាយវាយកញ្ឆេះតញ្ជាយពេក, មានតម្នាក់ ត្រូវពិនិត្យមើលចិត្តគំនិតកិរិយា មារយាទរបស់វាឲ្យដឹងថា វាចិត្តទិលខូច ឬចិត្តស្លូតត្រង់ ត្រូវសង្កេតមើលឲ្យដាក់ច្បាស់ ។

២០- សារពើរួសរៀនរិះ ឲ្យបាំបេះៗបាំបែង
បង់គាប់ប្រើស្ទះស្លៃង រកៀនរិះសារពើក្តី ។

អធិប្បាយ_. កិច្ចការ ឬវិជ្ជាទាំងពួង ត្រូវហ៊ាសរួសរាន់ រកៀនសូត្រឲ្យចេះដឹងសព្វគ្រប់ កុំបណ្តោយខ្ជិនទុកឲ្យល្ងង់ខ្លៅ បើយើងចង់បានបុណ្យស័ក្តិឲ្យប្រសើរខ្ពង់ខ្ពស់ ត្រូវតែស្ទះស្ទើរកៀនវិជ្ជាទាំងពួងឲ្យបានក្តៅឈ្នោះល្អ គឺប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ឲ្យបាន ទើបខ្ជិនយើងគាប់គួរឲ្យនឹងបុណ្យស័ក្តិបាន ។

២១- សប្បុរសពេកបាញ់ធង ឥតទុំដងបាញ់ពីឡើយ

១_. សាស្ត្រាខ្ទះថា ប្រើខ្ញុំមើលមុខវា ។

ប្រពន្ធល្អប្រើនចាញ់ប្តី ពាក្យប្រើនភូតចាញ់អាត្មា ។

អធិប្បាយ- ពាក្យថា " សប្បុរសពេកចាញ់ធន " គឺបុគ្គលមានចិត្តអូលាយជ្រុលពេក ចាយធំហួសកំណត់, ហួសព្រំដែន មិនគួរឲ្យកំឲ្យគេដែរ ប្រៀបដូចអ្នកដឹកសុរា បើតាមតំរាំនដឹកដោយខ្នងឯង អស់ចំនួនតែ ១ ពែង ឬ ១ កែវ កំលុមគ្រាន់ហើយ ប៉ុន្តែមិនដូច្នោះ ឲ្យតែឃើញអ្នកណា ដើរមកដល់ ចេះតែចាក់ស្រាឲ្យស្មើរតែគ្រប់គ្នា, មនុស្សចាយជ្រុលពេក ហួសកំណត់ ដូចអ្នកដឹកស្រាដូច្នេះ ឈ្មោះថា ចាញ់-ទ្រព្យធន គឺខាតទ្រព្យសម្បត្តិ ។ តាំងនៅមិនបាន ចេះតែវិនាសទៅរាល់ ។ ថ្ងៃ ។

ពាក្យថា នាទុជ្ឈនចាញ់ពីឫទ្ធិយ គឺមនុស្សទុជ្ជន មានចិត្តទ្រឹស្តស្ងួរ មានចិត្តរបឹងរឹងរូស, មនុស្សគោចអាក្រក់ តាំងខាតកាពជាធំ គឺគ្មានអំណាច គ្មានអានុភាព មិនបានធ្វើធំ, មិនបានធ្វើជានាយចៅហ្វាយគេទេ ឬថា តាំងវិនាសខ្លួនក៏បាន ។

ពាក្យថា ប្រពន្ធល្អ ប្រើនចាញ់ប្តី ។ ល្អមាន ២ យ៉ាង គឺល្អដោយរូបសម្បត្តិ ១, ល្អដោយគុណសម្បត្តិ ១ ។

ពាក្យថា ចាញ់ប្តី គឺចាញ់នៃប្តី, ហត់ឧឡាយនៃប្តី ជានិសេចក្តីថា ប្តីចាញ់, ប្តីហត់ឧឡាយជាដើម ។ ប្រពន្ធល្អតាំងពីរបៃបនេះ ពោះល្អ

បែបណាក៏ដោយ ច្រើនតែប្តីចាញ់ជាជាងប ដូចសេចក្តីអធិប្បាយតទៅនេះ :

ប្រពន្ធល្អដោយរូបសម្បត្តិ :

បុរសបុគ្គលខ្លះ បានប្រពន្ធមានរូបឆោមលោមពណ៌ល្អ ស្អាតស្រស់ប្រឹមប្រិយ ហើយមានវ័យនៅក្មេង ប្តីច្រើនតែថ្នមប្រពន្ធ មិនសូវឲ្យប្រពន្ធធ្វើការងារអ្វីទេ ច្រើនតែចេញធ្វើការដំនួសប្រពន្ធទាំងអស់, ទំប្រឹងធ្វើការងារឯកាលផង ការងារក្នុងផ្ទះផង ផ្គាប់ចិត្តប្រពន្ធ តាមសេចក្តីស្នេហាដែលកើតអំពីជម្ងឺជាតិបណ្តាលចិត្ត, ដំរុញចិត្ត, ជាស់តឿនចិត្ត ឲ្យទំតស៊ូនឹងការងារគ្រប់ចំពូក មិនគិតថា ត្រូជាក់-ក្តៅទេ ត្រូនឹងភាសិត ๑ បទ ថា "ធង់អ្វីមិនស្មើធង់ធំឯប្រពន្ធប្រើ" តាមសេចក្តីស្នេហាប្រើ តែគេថាប្រពន្ធប្រើ ដូចគាថូដតព្រាហ្មណ៍ បាននាងអមិត្តតា មានរូបល្អចំណាប់មកធ្វើជាប្រពន្ធ គាត់ចេញទៅធ្វើការងារ សូរសែងរកទ្រព្យយកមកផ្គាប់ចិត្តនាងអមិត្តតា មិនឲ្យនាងអមិត្តតាលំបាក ស៊ូលំបាកនឿយហត់តែម្នាក់ឯង ហេតុនេះបានជាថា ប្រពន្ធល្អច្រើនចាញ់នៃប្តី ។

ប្រពន្ធល្អដោយគុណសម្បត្តិ :

បុរសបុគ្គលខ្លះ បានប្រពន្ធប្រកបដោយលក្ខណៈស្រី, ជាស្ត្រីមានសុភាពរាបសា ចេះធម៌អាថ៌ សុចរិតស្មូតត្រង់ កាន់ត្រឹត្យស្រី, ប្រព្រឹត្ត

តាមច្បាប់ស្រី ។ ចំណែកឯប្តីជាមនុស្សវិលខ្លួច មិនគាន់ច្បាប់ប្រុសទេ តែងដើរស៊ីផឹក ចាយវាយខ្ជះខ្ជាយ រហូតដល់ចំពាក់ប្រាក់គាស់អ្នកដទៃ គាលបើម្ចាស់របស់គេមកតឹងការដល់ផ្ទះ ប្រពន្ធដឹងថាប្តី ចំពាក់គេហើយ ក៏យកប្រាក់សងគេគ្រប់ចំនួន មិនរករឿងហេតុឈ្លោះតបតនឹងប្តីទេ គាន់ខ្លាប់ខ្លួវសណ្តាប់ធ្នាប់ជាប្រពន្ធដរាប, ប្តីនៅតែប្រព្រឹត្តអំពើអាក្រក់ថោកទាបជាញយៗ មកទៀត, ប្រពន្ធក៏មិនស្តីបន្ទោសថាអ្វីឡើយ មិនយូរប៉ុន្មាន ប្តីនោះស្រាប់តែក្បាត់ខ្លួន ដឹងខ្លួនថា អាគ្នាអញជាប្រុសជាប្តីគេ មិនគួរបើមកប្រព្រឹត្តអំពើលាមក នាំឲ្យថោកទាបដល់ប្រពន្ធដឹងសោះ ព្រោះប្រពន្ធមានចរិយាល្អបែបនេះមិនងាយរកបានទេ ប្តីនោះក៏ចុះចាញ់លែងហ៊ានប្រព្រឹត្តអំពើថោកទាបតទៅទៀត ត្រឡប់តាំងខ្លួនជាអ្នកត្រឹមត្រូវ ទំរកស៊ីយ៉ាងម៉ឺងម៉ាត់ ទៅជាមនុស្សមានជនជានបរិបូណ៌គោតខ្ចាប ប្រពន្ធជាដរាប ។

ពាក្យថា " ពាក្យប្រើនភ្លូតចាញ់អាត្មា " គឺមនុស្សពោលពាក្យមិនពិត ច្រើននិយាយកុហក គាលបើគេដឹងច្បាស់ថា ជាមនុស្សកុហកហើយ នឹងទៅពឹងពាក់អ្វីគេ ក៏គេមិនឲ្យ គេមិនជឿ គេលែងទុកចិត្ត គ្មានអ្នកណាចូលចិត្តប្រាស្រ័យតិចតួចអ្វីៗឡើយ, ខូចខ្លួន ព្រោះតែនិយាយភូតកុហក បានជាថា ពាក្យប្រើនភ្លូត ចាញ់អាត្មា ។

២២- ឈើផ្លែប្រើនចាញ់ស្វឹក ត្រីប្រើនទឹកល្អក់ពុំជា
ទ្រព្យប្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះគិត ។

អធិប្បាយ_. ឈើចាំនឲ្យ កាលបើដល់រដូវផ្លែ ក៏បញ្ចេញផ្លែ
ស្មោកស្វក់, គេត្រឡែកមើលទៅ ឃើញផ្លែស្អកស្គាស់ រយោនរយោន
មិនសូវឃើញស្វឹកទេ ឈ្មោះថា ស្វឹកចាញ់ផ្លែ អន់អានុភាពជាងផ្លែ ផ្លែ
គេបញ្ចេញមុខជាង ឈ្មោះថា ឈើមានផ្លែច្រើន ស្វឹកអន់ថយជាង ឬក៏
គេឃើញផ្លែច្រើន គេឡើងទៅបេះ គេកាច់ស្វឹក កាច់មែក ក៏ឈ្មោះ_
ថា ស្វឹកចាញ់ផ្លែ ។ ទឹកគួកត្រីពាំងបឹងបួរក៏ដោយ តែមានត្រីច្រើនហើយ
ត្រីពាំងនោះ ហែលហិចដេញចាប់ចំណីអាហារ ស្ទុះចុះស្ទុះឡើង បណ្តាល
ឲ្យល្អក់, ឬក៏គេឃើញត្រីច្រើន គេចុះទៅនេសាទយកត្រី ក៏នាំឲ្យទឹក
ល្អក់ដែរ។ អ្នកមានទ្រព្យសម្បត្តិច្រើនបរិបូណ៌ ក៏នាំឲ្យនឿយព្រួយនឹងថែរក្សា
ឲ្យសព្វគ្រប់ណាស់ដែរ ប៉ុន្តែ មិនលំបាកគំនិតប៉ុន្មានទេ ។ ឯអ្នកមាន
ទ្រព្យតិច ឬអ្នកគ្មានទ្រព្យ ជាហេតុនាំឲ្យទាញតុំគំនិត គិតអ្វីមិនលេច
ទេ ព្រោះសេចក្តីខ្វល់ក្រ នាំឲ្យរួញគំនិត មិនឲ្យធើបមុខរួច, ការ_
ខ្វល់ទ្រព្យសម្បត្តិ ជាទុក្ខយ៉ាងធំរបស់មនុស្ស ។

២៣- ដើកយប់កុំជំអក់ ឲ្យលង់លក់ក្រៅសុបរិត
ទុំណាមានគំនិត គួរឲ្យគិតប្រណីវា ។

អធិប្បាយ_. ពេលយប់ យើងត្រូវដេក កុំដំអក់ខំរន់ បើឮសូរ-
ស័ព្ទអ្វីប្លែក ត្រូវគ្រោតទៅមើលឲ្យដឹងជាក់ ក្រែងមានចោរចូលមកលប
លួច ឬក្រែងមានកយន្តពាយផ្សែង។ កើតទៀង ត្រូវមានស្មារតី ប្រុងប្រ-
យ័ត្នជានិច្ច កុំដេកឲ្យលក់ហួសខ្នាត ហួសកំរិតទៀយ ។ កម្មតវដែលមាន
គំនិតមារយាទត្រឹមត្រូវ គួរដួយសង្រ្គោះដោយផ្តល់ប្រយោជន៍ឲ្យបានសម
រម្យតាមការគួរ ។

២៤- បងទូកបោះបង្គៀល រក្សា[1]ថ្នៀលព្រួយប្លែ
ការខ្សល់ៗ កាច[2]ជា ក្រែងពាន១ពារបោកបែកបាត់[3] ។

អធិប្បាយ_ត្រង់បទថា បងទូកបោះបង្គៀល គឺយើងមានទូក ឬសំពៅ
កាលបើត្រូវចតឈប់នៅមាត់ភ្នំធំ គប្បីបោះបង្គៀលយកព្រួយប្រក់ បង
ក្រៀកឲ្យជាប់មាំមួន កុំឲ្យខ្សល់ព្យុះខ្សល់ដំនោរ បក់បោកផាត់អណ្តែតត្រូ
សែតទៅបាត់ ។ ត្រង់បទថា រក្សាថ្នៀលព្រួយប្លែ គឺទូកមានថ្នៀលព្រួ
យប្លែរួចហើយ ត្រូវរៀបចាំខុកជាក់ថ្នៀលព្រួយប្លែ ឲ្យត្រឹមត្រូវ ក្រែងមាន
អន្តរាយ ដោយចោរលួចបន្ទុយកបាត់ ។

២៥-រៀនរិះសារពើពីី ទោះស្រដីមានពាក្យស័ព្ទ[4]

១-សាស្ត្រាខ្លះថា រិះរកថ្នៀលព្រួយប្លែ បានសេចក្តីថា ទូកខ្លោះមិនមានថ្នៀលព្រួយប្លែទេ។
២-សាស្ត្រាខ្លះថាខ្សល់កាចពុំដែរ ។ ៣- សាស្ត្រាខ្លះថា ក្រែងពាក្យរបោកបែកបាក់ ។
៤-សាស្ត្រាខ្លះថា ទោះស្រដីពាក្យស័ព្ទ ។

បាំក្បួនបាំឲ្យស្អាត់ កុំអៀនប្រៀនសមពាក្យពោល ។

អធិប្បាយ ការរៀនសូត្រចេះដឹងត្រូវដឹងជាចាំឆ្លងតួន ត្រូវត្រិះរិះឲ្យមិត្តចត់ កាលបើនិយាយស្តីក៏ត្រូវនិយាយថ្លែងតាមសេចក្តីពិត មិនត្រូវនិយាយ បញ្ឆោតបញ្ឆាលកូតកុហកឡើយ, បើរៀនបានចេះដឹងតាមគម្រោងណា ឬ តាមគម្ពីរដើរកាណា ត្រូវចាំឲ្យពិតប្រាកដតាមក្បួនតម្រាឬគម្ពីរដើរកានោះ ឲ្យស្អាត់មែនទែន កាលបើមានគេសួរឬគេអញ្ជើញឲ្យអធិប្បាយអំពីបញ្ហាអ្វីមួយត្រូវអធិប្បាយដោះស្រាយ ដោយក្បោះក្បាយ មិនត្រូវអើមអៀម ឡែះឡោះឡែយ កាលបើយើងធ្វើយដោះស្រាយដោយអើមអៀនខ្មែមប្លំ សមគេនឹងពោលតិះដៀលបន្ទុះបង្អាប់ ជាហេតុនាំឲ្យខ្មាសគេ ក្នុងកណ្តាលប្រជុំជន ។ ឬបើត្រូវប្រឡងយកបុណ្យស័ក្តិ កាលយើងធ្វើយមិនរួច ឈ្មោះថា ធ្លាក់ មិនជាប់លេខ។ ទានបានបុណ្យស័ក្តិ ព្រោះចាំមិនច្រាកដ ចាំមិនស្អាត់ ។

២៦- ការក្រែកុំគិតងាយ ការសម្ងាយជាកម្រោល
សន្សឹមកុំបំបោល ក្រែងពុំដល់ដួចប្រាជ្ញា ។

អធិប្បាយ-. ត្រង់បទថា ការក្រែកុំគិតងាយ គឺកិច្ចការចាំឆ្លងយ ដែលធំៗ ពិបាក ហៅថា ការក្រែ។ នេះគេចាប់ធ្វើឡើង ត្រូវតែប្រុងប្រយ័ត្នជានិច្ច មិនត្រូវមើលងាយការថា ការនេះស្រួលទេ ងាយទេ ដូច្នេះឡើយ ប្រៀប

ដូចការធ្វើផ្ទះ គេត្រូវប្រយ័ត្នខ្ចាចរលំ ខ្ចាចខ្រេក ខ្ចាចស្រុតនាំឲ្យអន្តរាយ ត្រូវធ្វើប្រយ័ត្ន គឺត្រូវបុកឫសឲ្យមាំមួន ដាក់ឃ្នាបរនងឲ្យរឹងប៉ឹងជាដើម មិនត្រូវធ្វើឲ្យតែរួចពីដៃទេ ឈ្មោះថា ការក្រមុំគិតងាយ ។ ត្រង់បទថា ការ-

សម្ងាយជាកម្រោល សន្សឹមកុំបំបោល ក្រែងពុំដល់ដួចប្រាថ្នា

គឺការផងតាំងពួន, ការសាមញ្ញ ហៅថា ការសម្ងាយ ។ សុខ្ខសីនៅតាំងស្រុង នៅតាំងកម្រោល តាំងជុំ តាំងមូល គេត្រូវចំបែកច្រៀកជាផ្នែកដាក្រម ដោយសន្សឹមៗមិនត្រូវដម្រុលបង្ខំឲ្យស្រេចក្តាមទេ ប្រៀបដូចឈើហ៊ុបមួយដើមនៅតាំងកម្រោល ៤ ជ្រុង គេត្រូវគោរ ច្រៀកដោយណាឲ្យបែកជាបួនៗ ហើយឈូសរំលីងធ្វើជាគុះខ្ទៅតាដើម, ការធ្វើនោះគេធ្វើដោយផ្ចិតផ្ចង់ដោយសម្រួល ទើបការងារនោះប្រព្រឹត្តទៅបានល្អស្អាត កាលបើយើងធ្វើដោយប្រញាប់ប្រញាល់តួងតាងទៅ ជួនជាបាក់បែកខូចការ នាំឲ្យមិនបានសម្រេចដូចប្រាថ្នាបានជាលោកថា ការសម្ងាយជាកម្រោល

សន្សឹមកុំបំបោល ក្រែងពុំដល់ដួចប្រាថ្នា ។

២៣- រៀនរិះរួសរាំង ធ្វើស្រែប្រាំងស្រែវស្សា

ធ្វើស្រែមានបំណាស ធ្វើបំការបានរបង ។

អធិប្បាយ - ត្រូវរៀនត្រិះរិះ ថែទាំទ្រព្យគ្រប់ដំណក ឲ្យគង់នៅឋិតថេរបានល្អ បើមិនរៀនហាត់ចិត្តឲ្យចេះរក្សាទ្រព្យសម្បត្តិទេ ទ្រព្យនោះនឹង

លត់លោយអស់ទៅមិនខាន ។ ត្រូវធ្វើស្រែកន្លះមួយឆ្នាំឲ្យបានពីរដង គឺ
រដូវប្រាំងម្តង រដូវវស្សាម្តង ។ ការធ្វើស្រែមួយៗ ត្រូវលើកភ្ជួ លើកទំនប់
ឃាត់ទឹកទុកក្សោសន្ទូង សំណាប ត្រូវធ្វើបន្ទាយ ធ្វើផលមាគ សម្រាប់
បង្ហូរបន្ទឹមទឹក កុំឲ្យជន់លិចសន្ទូង ។ ត្រូវធ្វើចំការជាំពោតសណ្តែក ត្រ
ឡាច តាសក់ជាដើម គប្បីធ្វើរបងព័ទ្ធជុំវិញ កុំឲ្យសត្វធាតុចូលទៅលុក
លុយផង ឲ្យជិត ពំប្រទល់ចំការយើង ឧដ៏ចំការគេផង ការពារកុំឲ្យ
មានរឿងក្តាសវែងគ្នា ។

២៨- ផ្លែរឿបកុំបាបង់ ផ្លែរណាត្រង់កុំជើរហោង
ជើរដោយផ្លែគន្ធង តម្រាយអ្នកចាស់បុរាណ ។

អធិប្បាយ-- សុភាសិតបទនេះ អ្នកប្រាជ្ញសម័យព្រេងនាយប្រដៅទុកមក
សម្រាប់ជនប្រុសស្រីតើតជាន់ក្រោយ ក្រែងមានតើតរឿងក្តីក្តាំ ធម្មតារឿង
ក្តីច្រើនតែក្លែងចោទប្រកាន់មួលបង្កាច់គ្នា ឲ្យតែបានឈ្នះ ដូចយ៉ាងគេ
ចោទថា យើងលួចទ្រព្យរបស់គេ ចំណែកខ្លួនយើងត្រង់សោះ មិនមែន
លួចគេទេ ប៉ុន្តែ យើងមិនចេះធ្វើយដោះខ្លួន ច្រើនឱយាយត្រង់ៗ មិនចេះ
និយាយវៃឆ្លៀវដោយអាងហេតុផល ឬ អាងសាក្សីជួនតុលាការឲ្យជ្រាប
បានផង ត្រឡប់ទៅជាយើងមានពិរុទ្ធទៅវិញ ត្រូវនឹងពាក្យចាស់បុរាណ
ថា "ស្លូតស្ងាប់រឿងមានតែព្រួ អាយុយឺនយូរ"

(មានត)

ផ្នែកការសិក្សាទំនើបប្រៀបធៀប

ប្រវត្តិនៃទស្សនាវដ្តី កម្ពុជសុរិយា

លោក យ៉ូរ-អ៊ុង រៀបរៀង

ពុទ្ធបរិស័ទទាំងឡាយ !

ក្នុងកាលនេះ ខ្ញុំនឹងពណ៌នាអំពីប្រវត្តិនៃទស្សនាវដ្តី កម្ពុជសុរិយា នៃពុទ្ធសាសនបណ្ឌិត្យ ដោយសេចក្តីសង្ខេប តែមុនបង្អស់ សូមពណ៌នាអំពីពាក្យថា ទស្សនាវដ្តី និងពាក្យថា កម្ពុជសុរិយា ។

អ្វីហៅថា ទស្សនាវដ្តី កម្ពុជសុរិយា ?

ទស្សនាវដ្តី ជាពាក្យបាលី ប្រែថា "ដំណើរវិលនៃការមើល" គឺការមើលឬអានវិលទៅតាមពេលកំណត់ ដែលនឹងចេញឲ្យមើលឲ្យអានជួចកំណត់រៀងរាល់ខែ ឬ មួយខែនឹងចេញ ១ លេខឲ្យមើល យ៉ាងនេះហៅថា ទស្សនាវដ្តី ។ ឯនដល់សៀវភៅដែលគេបោះពុម្ពចម្រុះអត្ថបទចេញផ្សាយឲ្យមើលគ្នាតាមលេខ ពីលេខ ១ ទៅលេខ ២ ពីលេខ ២ ទៅលេខ ៣ ជាដើម បើអត្ថបទណាវែង គេរំលែកចុះក្នុងសៀវភៅលេខ ១ខ្លះ លេខ ២ខ្លះ លេខ ៣ ខ្លះ ឲ្យចាប់តែចប់អត្ថបទនោះ ។ ទស្សនាវដ្តីនេះ មាន

អាការចេញផ្សាយ ប្រហែលគ្មានធំសារពាត៌មាន ប្លែកគ្នាតែត្រង់ទស្សនាវដ្តី
គេចធំជាសៀវភៅ ឯសារពណ៌មានគេមិនចធំប៉ុណ្ណោះ ។

កម្ពុជសុរិយា ជាពាក្យភាសាលីប្រែថា ព្រះអាទិត្យកម្ពុជា ។ ពាក្យ
នេះជាឈ្មោះនៃទស្សនាវដ្តី របស់មន្ទីរព្រះពុទ្ធបណ្ណាល័យកម្ពុជា ដែល
ឥឡូវនេះ ប្រែឈ្មោះមកជា មន្ទីរពុទ្ធសាសនបណ្ឌិត្យ ជាវិជ្ជាស្ថាន
សម្រាប់ពង្រីកពាន៏សាសនាទំនើបអក្សរសាស្ត្រ ។

ការសន្មតិឈ្មោះទស្សនាវដ្តីថា កម្ពុជសុរិយានោះ ដោយ
លោកអ្នកបង្កើត មានសេចក្តីយល់ឃើញថា ប្រទេសកម្ពុជា ចាប់
ពីពេលដែលមានទស្សនាវដ្តីនេះចេញផ្សាយ តាមមុខការពាន៏ជួយបំភ្លឺ
ពន្យល់គតិលោកគតិធម៌ ពុកដូចជាមានព្រះអាទិត្យមួយរះបញ្ចាំងផ
ស្ទើភ្លឺត្រចះ ហើយបណ្តាជនជាតិខ្មែរ កំពុងតើតមានច្រឡំភ្លឺស្វាន
ក្នុងផ្លូវលោក ផ្លូវធម៌ ដោយសារបានអានទស្សនាវដ្តីនេះ ។

ទស្សនាវដ្តីនេះមានប្រវត្តិយ៉ាងណាមានគោលបំណងដូចម្តេច?

ក្នុងប្រទេសកម្ពុជា កាលពីមុន គ.ស. ១៩៦៥ នៅឡើយ
មិនទាន់មានការចោះពុម្ពសៀវភៅ ជាផ្លូវលោកផ្លូវធម៌ ផ្សាយបំភ្លឺ
ដល់បណ្តាជនទេ ។ នៅសម័យនោះ ប្រទេសកម្ពុជាពុកដូចជានៅ
ក្នុងទីងងឹត គ្មានពន្លឺព្រះអាទិត្យ ចែងចាំងចូលដល់សោះ ។ លុះមក

ដល់ គ.ស. ១៩២៩ ពាជវង្ឆាកិច្ចលបានបង្កើតឲ្យមានមន្ទីរព្រះពាជបណ្ណាល័យកម្ពុជា គឺមន្ទីរពុទ្ធសាសនបណ្ឌិត្យ សព្វថ្ងៃនេះ ដើម្បីតម្កល់ក្ប្លែន តម្រា តម្ពរ សាស្ត្រាទឹងសៀវភៅផ្សេង ។ ពុតសម្រាប់សាធារណជន ចូលទៅរៀន ទៅអាន ឬ ខ្ចីយកទៅសិក្សាឯលំនៅឋានរបស់ខ្លួនបានតាមចិត្ត ។ តាលតើតមានមន្ទីរនេះហើយ ទើបមន្ទីរនេះចាត់ការបង្កើតនូវទស្សនាវដ្តី កម្ពុជសុរិយា ចោះពុម្ពផ្សាយចេញពាលំ១ ព្រមទាំងបានចោះពុម្ពសៀវភៅ ជាគតិធម៌ថែមទៀត ចំពោះតែសៀវភៅណា ដែលពុទ្ធបរិស័ទត្រូវការណាស់ ដូចសៀវភៅ ចាតិមោក្ខសង្ឃេប សាមណេរវិន័យ តិហិបដិបត្តិជាដើម ។

ទស្សនាវដ្តី កម្ពុជសុរិយា ដែលបានបង្កើតឲ្យមានឡើងនេះ ដោយមានគោលបំណងមួយ ត្រាលបំភ្លឺប្រជាជាតិខ្មែរ ឲ្យមានប្រាជ្ញាឈ្លាសយល់ក្តីស្មាង ក្នុងគតិលោកគតិធម៌ តាមគ្រាន់ការណ៍ដូចតទៅនេះ :

១- ចុះផ្សាយប្រចាំខែ នូវអត្ថបទខាងពុទ្ធសាសនា ដែលមានក្នុងគម្ពីរសូត្រតែស្រាប់ ព្រមទាំងដំណឹងជាគតិលោកគតិធម៌ ដែលមានសារប្រយោជន៍ដល់សាធារណជន ។

២- ចុះផ្សាយប្រចាំខែ នូវអត្ថបទផ្នែកអក្សរសាស្ត្រ ដែលបាន

និពន្ធឡើងដោយស្នាដៃដ៏ជំនាញ នៃបុគ្គលិកក្រុមនេះ ឬ ក៏ពួកគាត់ពីគ្រប់ទិសបាននិពន្ធ ហើយផ្ញើមកឲ្យព្រះរាជបណ្ណាល័យចុះផ្សាយ ។

៣- ចុះផ្សាយនូវប្រវត្តិការណ៍ នឹងដំណឹងផ្សេងៗ ជាពិសេស ឬ ជាផ្លូវការដែលទាក់ទងនឹងសាសនា ឬក៏ចុះផ្សាយនូវសកម្មភាពរួមៗ របស់ក្រុមនេះដែលបានធ្វើ ។

ព្រោះហេតុមានគោលបំណងយ៉ាងនេះហើយ ទើបទស្សនាវដ្តីកម្ពុជសុរិយា កាលពីសម័យដំបូងនោះ បញ្ចេញពន្លឺខាងគតិធម៌ច្រើនជាងគតិលោក ។ ទោះបីដូច្នោះ ក៏ដីវភាពនឹងការប្រព្រឹត្តទៅនៃកម្ពុជសុរិយា ចេះតែចំរើនឡើងជាលំដាប់ មិនដែលរលត់រលាយទៅ ។

ចាប់តាំងពី គ.ស. ១៩២៨ មក ព្រះរាជបណ្ណាល័យកម្ពុជា បានកែប្រែត្រឡប់ជាចុះផ្សាយអត្ថបទ ខាងគតិលោកច្រើនជាងគតិធម៌វិញ ដោយអាងថា សៀវភៅគតិធម៌មានបោះពុម្ពផ្សាយច្រើនហើយ ចំណែកសៀវភៅ ខាងគតិលោកបោះពុម្ពផ្សាយតិចគួរបស្ពុចស្តើងណាស់ មួយទៀត ដោយអនុលោមតាមមតិនៃអ្នកអានភាគច្រើន ដែលចូលចិត្តខាងគតិលោក ។

ប្រវត្តិទស្សនាវដ្តី កម្ពុជសុរិយា តាមដែលបានរៀបរាប់ដោយ

សង្ខេបមកនេះ ល្មមជាបច្ចាន់ថា តាំងពីទស្សនាវដ្តីនេះចាប់កំណើត រហូតមកដល់ឆ្នាំ ១៩៩៨ នេះ ត្រូវជា ៣០ ឆ្នាំហើយ ។ ក្នុងរយៈវេលា ៣០ ឆ្នាំ ដែលកន្លងទៅហើយនោះ កម្ពុជសុរិយាពុំដែលមានការអាក់ខាន ឬបាត់ឈ្មោះទេ នៅតែមានពលានុកាពាធិបុគ្គលជាជាងរៀងមក អាចបំពេញតួនាទី ជួយបំភ្លឺ ជួយពន្យល់ពុទ្ធសាសនិកជនជាតិខ្មែរ ឲ្យយល់ប្រវត្តិការណ៍សាសនា ឲ្យលះអាក្រក់ កាន់ល្អតាមគន្លងធម៌ បានច្រើនជាអនេក ហេតុនោះហើយបានជា កម្ពុជសុរិយាតែងទទួលលទ្ធផលល្អ គឺសេចក្តីសរសើរអំពីសំណាក់ទស្សនិកអ្នកអានតាំងពីក្មេង ជារឿយៗ ។

ទស្សនាវដ្តីនេះ មានប្រយោជន៍យ៉ាងណា ?

ពុទ្ធបរិស័ទតាំងពីក្មេង !

ដូច ព្រះតេជព្រះគុណ ធម្មានន្ទ-អ្នកបានជ្រាបស្រាប់ហើយថា ក្នុងសម័យនេះ គ្រប់អាវុប្រទេសតាំងពីក្មេង ក្នុងលោកទោះប្រទេសធំក្តី តូចក្តី តែងមានទស្សនាវដ្តីជាច្រើនណាស់ គឺទស្សនាវដ្តីចេញប្រចាំសប្តាហ៍ក៏មាន ចេញប្រចាំខែក៏មាន ចេញប្រចាំឆ្នាំក៏មាន ហើយដែលចេញពាល់សប្តាហ៍ ពាល់ខែ ពាល់ឆ្នាំនោះ មិនមែនមានតែមួយម៉ាត់ ។ ដូចទស្សនាវដ្តី នៅប្រទេសយើង

ទេ គឺមានច្រើនឈ្មោះទស្សនាវដ្តី ។ ដែលទៅជាមានទស្សនាវដ្តីច្រើនយ៉ាងនេះ ក៏ដោយអាស្រ័យជនជាតិក្នុងប្រទេសចាំងនោះ ពេញចិត្តក្នុងការសិក្សាច្រើន ដែលជាហេតុឲ្យនិយមបួលចិត្តអានច្រើន ។ ជនជាតិចាំងនោះក៏ដុះដាលចំរើនឡើង ដោយចរិយាល្អនឹងកោតទ្រព្យជាលំដាប់រាល់ថ្ងៃ ដោយសារផ្លូវគំនិតផ្លូវប្រាជ្ញា ដែលកើតអំពីការអានន្ទូវទស្សនាវដ្តី ដូចជាកម្លាំងមួយផង ។

ដោយយើញនៅប្រទេសគេ មានអ្នកអានច្រើនណាស់ យ៉ាងនេះហើយទើបក្រុមពុទ្ធសាសនបណ្ឌិតឲ្យ តែងទុនឹងមើលក្រែងប្អូនរួមជាតិដោយនឹកកង់ចិត្តថា ឆ្នើរម្តេចហ្ន៎ ឲ្យជនជាតិយើងចេះឆ្លើយដំណើរគំនិតចាស់ចោលចេញ ប្រែគំនិតថ្មីវិញ ពេញចិត្តក្នុងការសិក្សានឹងការអានន្ទូវទស្សនាវដ្តីឲ្យបានច្រើនរូប ជាលំដាប់រាល់ឆ្នាំឡើង កុំឲ្យចាញ់ប្រៀបជនជាតិដទៃ ។

ប្រសិនបើ ជនជាតិយើងបួលចិត្តអានច្រើនរូបហើយទស្សនាវដ្តីកនប្រទេសយើង ក៏ទឹងកើតមានច្រើនឡើងដែរ ហើយកម្មដសុរិយាក៏ទឹងបានទស្សនាវដ្តីនោះ ។ ជាគ្នា ដើម្បីរួមកម្លាំងជួយបំភ្លឺផ្លូវជាតិ ឲ្យដើរទៅរកសេចក្តីចំរើន ដោយមិនលំបាកដូចមានគោលតែមួយទេ ។

យូរផ្នាំមកហើយ ក្រុមពុទ្ធសាសនបណ្ឌិតឲ្យ បានយកចិត្តទុកជាក់

ស្ថិតស្ថានលំអកម្ពុជសុរិយា ចាំខ្ញុំលបដំសណ្ការៈចំពោះជនរួមជាតិអ្នកអាន ដោយអត្ថបទ ៣ ផ្នែកគឺផ្នែកសាសនា១ ផ្នែកអក្សរសាស្ត្រ ១ ផ្នែកប្រវត្តិការណ៍១ ដែលជាអត្ថបទសំរែតសម្រាំង តម្រូវតាមអធ្យាស្រ័យលោកអ្នកអាន ។ ដោយលទ្ធផលនៃការខំសំរែតសម្រាំងអត្ថបទនោះ ក្រុមពុទ្ធ-សាសនបណ្ឌិត្យ បានយើញ ព្រះតេជព្រះគុណ នឹងអស់លោក-អ្នក ដែលបានចុះនាមជាវិយកទៅអាន ក៏មានច្រើនរួបដែរហើយ ដែលយើងសង្ឃឹមថាមិនលះបង់ចោលកម្ពុជសុរិយា នឹងចេះតែបន្តព្យាយាមជាវជាជាបទៅ ក្រុមពុទ្ធសាសនបណ្ឌិត្យ សូមសរសើរគុណ ព្រះតេជព្រះគុណ នឹងអស់លោក អ្នកពាំនោះ ខុតជាមុន ។

ចំណែក ព្រះតេជព្រះគុណ នឹងអស់លោក-អ្នក ដែលពុំបានចុះនាមជាវ យើងសង្ឃឹមថា គង់នឹងបំពេញ ចំណង់ក្នុងការសិក្សាអាន ឲ្យបានច្រើនរួបឡើង ហើយផ្ញើនាម ទៅចុះជាវិយកមកអានដើម្បីជាជំនួយសតិបញ្ញារបស់ព្រះតេជព្រះគុណនឹងរបស់លោក-អ្នក ។

ព្រោះកម្ពុជសុរិយា ១២ ក្បាល ក្នុង ១ ឆ្នាំជំទៀជាវជាប្រាក់ ២៣០ រៀលនោះ យើងស្មានថា ពុំស្មើនឹងតម្លៃសតិបញ្ញា ដែលកើតអំពីការអានទស្សនាវដ្តី កម្ពុជសុរិយាឡើយ ។

គុណនៃព្រះត្រៃបិដក

ស្រី-អ៊ូ រៀបរៀង

ព្រះត្រៃបិដក មានគុណល្អសំខាន់ដូចម្តេចខ្លះ ឬបានជាពុទ្ធិកជនពាំនាំគ្នាជឿជាក់អានច្រើនម្ល៉េះ ?

គុណនៃព្រះត្រៃបិដកនោះ មិនអាចនឹងពណ៌នា ឲ្យសព្វគ្រប់បាន, សូមពណ៌នាយ៉ាងសង្ខេបដូចតទៅ :

ព្រះវិន័យបិដក ជាគម្ពីរមានគុណប្រយោជន៍សំខាន់ ខាងហ្វឹកហ្វឺនបង្ហាត់បង្រៀនអ្នកប្រតិបត្តិតាម មិនឲ្យមានសេចក្តីឃ្មើលឃ្មុលដោយកាយវាចា គឺធ្វើកាយវាចាឲ្យមានសណ្តាប់ធ្នាប់រៀបរយល្អ, ព្រោះពុទ្ធបរិស័ទពាំនាំគ្នា ដែលចូលមកកាន់ព្រះពុទ្ធសាសនា តែងមានអធ្យាស្រ័យផ្សេងៗ គ្នា អ្នកខ្លះមានអធ្យាស្រ័យគ្រោតគ្រាត អ្នកខ្លះមានអធ្យាស្រ័យសុភាពរាបសារល្អ អ្នកខ្លះមានកំឡាំងកាយច្រើន អ្នកខ្លះមានកំឡាំងកាយតិចខ្លាំងខ្សោយ, ម្ល៉ោះហើយ អ្នកមានអធ្យាស្រ័យអាក្រក់មានកំឡាំងច្រើន តែងតែប្រព្រឹត្តរំលោភម៉ឺលជាយអ្នកខ្លាំងខ្សោយ ប៉ុន្តែមានព្រះវិន័យជាគ្រឿងទប់ទាន់ប្រៀនប្រដៅឲ្យមានរបៀបរៀបរយ ប្រៀបដូចអម្បោះ ប្តេចសរោតក្រក់ផ្តាំដែលចេះមកពីគុម្ពផ្សេងៗ គ្នា ឲ្យមានជារបៀប ឆាកងួន ជាតម្រងល្អម៉ើលដូច្នោះ ។

ព្រះវិន័យបិដក ចាត់ជា «អាណាវេសនា» ការសំដែងបំភ្លឺនូវអំណាច នូវច្បាប់បញ្ញត្ត ។

ព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងនូវបទបញ្ញត្តមានកំរិត ទ្រង់តែងតាំងអាជ្ញា ទ្រង់បញ្ញត្ត ចាត់ជាសិក្ខាបទ ដែលមានក្នុងបាតិមោក្ខ មានចំនួន ២២៧ សិក្ខាបទ ។ បទបញ្ញត្តនេះសោត ក៏មានអានុភាពជាប់ប៉ិតថេរជាស្ថាពរ រហូតមកដល់សព្វថ្ងៃនេះ ។

ព្រះសុត្តន្តបិដក ជាគម្ពីរមានគុណប្រយោជន៍សំខាន់ខាងធ្វើអ្នកប្រតិបត្តិតាម ឲ្យមានអធ្យាស្រ័យស្ងួតត្រង់ ល្អប្រពៃឡើង ធ្វើឲ្យមានសទ្ធាលូតលាស់ដុះដាល ចង់ធ្វើទានជាលំដាប់ទៅទៀត ។

ព្រះសុត្តន្តបិដក ចាត់ជា "វោហារវេសនា" ការសំដែងវោហារ ការសំដែងធម៌អធិប្បាយបញ្ចេញវោហារ ឲ្យខ្លាយងាយស្តាប់ ងាយយល់ ។

ព្រះសក្យមុនីបរមគ្រូ ទ្រង់ឈ្វាស់វៃក្នុងពាក្យសំដី ទ្រង់ប្រាន់សំដែងពាក្យណាៗក ពាក្យនោះតែងប្រាកដ ឥតប្រែប្រួល ហើយមិនចាប់បង្ខិំឲ្យនរណាមួយដើរតាមទេ ក៏មានតែដើរតាមៗឯងដោយស្រួលតោះបើមនុស្ស ឬទេព្តាណាមួយ កាលបើបានស្តាប់ធម៌ដែលព្រះសម្ពុទ្ធសំដែងហើយ ក៏តែងសេចក្តីជ្រះថ្លាដើរតាម ហើយបានសម្រេចមគ្គផលដោយរួសរាន់ ។

ព្រះអភិធម្មបិដក ជាគម្ពីរមានគុណប្រយោជន៍សំខាន់ខាងធ្វើអ្នក
ប្រតិបត្តិតាម ឲ្យស្គាល់លក្ខណៈនៃសភាវធម៌ ហើយអាចធ្វើឲ្យមានចិត្ត
ឃ្លាតចាកសេចក្តីសៅហ្មងគ្រប់យ៉ាងបាន ។

ព្រះអភិធម្មបិដក ចាត់ជា "បរមត្ថទេសនា" ការសំដែងនូវធម៌
មានអត្ថដ៏ឧត្តម ឬមានអត្ថដ៏ជ្រាលជ្រៅ ។

ព្រះតថាគតមុនី ទ្រង់ឈ្វេងយល់ក្នុងសេចក្តីល្អិតជ្រាលជ្រៅ ទ្រង់ជា
កំពូលមនុស្ស ទ្រង់បានជ្រាបច្បាស់នូវធម៌ដែលមានអាថដ៏ឧត្តម មានអាថដ៏
ជ្រាលជ្រៅក្រៃលែង ហើយទ្រង់លើកយកអាថនៃធម៌នោះ ។ មកសំ
ដែងបង្ហាញ ពន្យល់ ដល់អ្នកស្តាប់ ។ អ្នកស្តាប់ពាំនោះ ក៏អាច
យល់ច្បាស់លាស់បានដោយងាយ ។

ពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធ ដែលឲ្យឈ្មោះថា ព្រះ
ត្រៃបិដក ជាពាក្យបរិបូណ៌ដោយគុណ គឺសេចក្តីល្អវិសេសណាស់ បើនឹង
យកតម្លៃផែនដីក្នុងដែនលោកពាំនមួលមកផ្គុំគ្នា ក៏មិនស្មើនឹងតម្លៃព្រះត្រៃ
បិដកនេះឡើយ ព្រោះផែនក្រឡាមហាប្រឹថពី គ្រាន់តែជាទីពាំនាក់អាស្រ័យ
នៃពួកសត្វប៉ុណ្ណោះ តែមិនអាចធ្វើសត្វណាមួយឲ្យរួចចាក់ទុក្ខពាំនឡាយ
មានជាតិទុក្ខជាដើមបាន ។

ឯព្រះត្រៃបិដក អាចធ្វើអ្នកប្រតិបត្តិតាមឲ្យរួចស្រឡះ ពាក់ពុំកួ
ចាំងពួងបាន ។ ព្រោះហេតុដូច្នេះ បានជាលោកពាប់ថា ព្រះត្រៃបិដកនេះ
ជាវត្ថុដ៏ស័ក្តិសិទ្ធលើសវត្ថុដទៃ ។ ដែលមានក្នុងលោក ។

ព្រះត្រៃបិដក មានគុណដូចបរិយាយមកនេះ បានជាពុទ្ធិកជនចាំង
ឡាយនាំគ្នាដឿកប់អាន តាំងពីបុពណារហូតមកដល់សព្វថ្ងៃនេះ ។

ធម៌វិន័យដែលបិតនៅ ក្នុងព្រះត្រៃបិដកនេះ លោកសន្មតនាមតាម
សាសនាវហារ ថា "ព្រះពុទ្ធសាសនា" ។ ព្រះពុទ្ធសាសនានេះ មុន
ដំបូងបំផុត ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ទេសនាប្រដៅបញ្ចវគ្គិយភិក្ខុ ក្នុង
ព្រៃឥសិបតនមិគទាយវ័ន ខៀបក្រុងពារាណសី ៖ តពីនោះមកទ្រង់ត្រាច់
ទេសនាប្រដៅមហាជនតែក្នុងមជ្ឈិមប្រទេស (ប្រទេសឥណ្ឌាសព្វថ្ងៃ
នេះ) អស់រយៈកាល ៤៥ វស្សា ហើយទ្រង់បរិនិព្វានទៅ ។ ដែល
ព្រះពុទ្ធសាសនា បានផ្សាយទូទៅក្នុងប្រទេសនានា ក្រៅពីមជ្ឈិមប្រទេស
នោះ ក៏ព្រោះអាស្រ័យនឹងព្រះសង្ឃសាវ័ក ជាអ្នកជួយផ្សាយបន្តិម ទើប
បានជាមានមនុស្សអ្នកដឿជ្រះថ្លា នាំគ្នារៀនសូត្រប្រតិបត្តិតាម នឹង
ប្រឿនប្រដៅគ្នាត ។ មក កាន់តែច្រើនឡើង ។ ដរាបមកដល់សព្វថ្ងៃ
នេះ ស្ទើរតែគ្រប់ប្រទេសក្នុងពិភពលោក ។

អានិសង្សនៃការទុបត្ថម្ភព្រះត្រៃបិដក

ពុទ្ធបរិស័ទពាំនងឮយ ដែលមានសទ្ធាជឿជាក់ស្មោះចំពោះព្រះពុទ្ធ-សាសនា គួរបណ្តុះសទ្ធា ឧធ្ទិសចក្តីជ្រះថ្លាឲ្យរឹងរឹតតែខ្លាំងឡើង ហើយជួយអនុមោទនាត្រេកអរតាមកិច្ចការដ៏ទុតម ដែលពុទ្ធសាសនបណ្ឌិតឫកំពុងចាត់ការបោះពុម្ពព្រះត្រៃបិដក ក្នុងសម័យបច្ចុប្បន្ននេះ ក្រែមការទុបត្ថម្ភនៃព្រះរាជរដ្ឋាភិបាល គួរប្រញាប់ប្រញាល់ជាវ គួរទំមើល-ទំស្តាប់-ទំរៀនទ្ធេញ, ទំចំណាំឲ្យចាំស្អាត់, ទំពិចារណាឲ្យយល់ធម៌វិន័យ ក្នុងព្រះត្រៃបិដក ដោយច្បាស់លាស់ ហើយទំប្រតិបត្តិតាម ឲ្យដល់កម្រិតរបស់ធម្មវិន័យនោះ ។ មុខជាឧធ្ទិសបានផលានិសង្សសមគួរតាមវាសនារៀង ។ ខ្លួន ។

សាធុជនអ្នកបានអនុមោទនា ហើយបានជួយទុបត្ថម្ភក្នុងការធ្វើសង្គាយនាព្រះត្រៃបិដកនេះ រមែងបានផលានិសង្សច្រើនជាអនេក ។ សេសក្តីនេះមិនអាចនឹងបរិយាយឲ្យសព្វគ្រប់បានឡើយ គ្រាន់តែពាញរឿងមកប្រាប់ឲ្យបានជាគោល ដោយសង្ខេប ដូចតទៅ :

រឿងព្រះបាទអជាតសត្រូវមហារាជ

ព្រះបាទអជាតសត្រូវមហារាជ កាលនៅជាព្រះរាជកុមារ បានសេព-

គប់នឹងខ្លួនខ្លួន ក៏ក្លាត់ព្រះទ័យទៅពិឃាតព្រះបាទពិម្ពិសារៈ ជាព្រះបរម-
រាជបិតា របស់ព្រះអង្គ ដើម្បីយកពរជសម្បត្តិសោយ" តាមពាសបិតុ-
ឃាតនេះ គួរណាស់តែធ្លាក់ទៅសោយទុក្ខ ក្នុងអវីចិមហានរក អស់មួយ
កប្ប។ ប៉ុន្តែដោយអំណាចផល ដែលទ្រង់បានជួយទំនុកបម្រុងក្នុងការ
ធ្វើបឋមសង្គាយនា មកជួយគាំទ្រ ព្រះអង្គក៏មិនធ្លាក់ទៅរងទុក្ខក្នុងអវីចិម-
ហានរកនោះឡើយ ទៅសោយទុក្ខតែត្រឹមលោហកុម្ភីនរកវិញ, លុះរួច
ពីនរកនោះហើយ នឹងបានឡើងទៅសោយទិព្វសម្បត្តិ ក្នុងស្ថានសួគ៌
ជាសុខក្សេមក្សាន្ត ។



ឧត្តរេ សិរីសក្យមុនី ចេវ ឦសានេ បញ្ច ពុទ្ធា នមាមិហំ

យើងខ្ញុំបង្គំវន្ទ សូមពារស្តេចក្រុងពារាណសី ឥសូរកំពូលទីបា ប្រកបទូវលាភសោភា ជាតិខ្ញុំបានពេលា (រៀបលើកដហ្វាដងគ្នា) ។ ខ្ញុំរៀបអស់កោដនាហារ ប្រសើរជាតិជាស្អាងស្អាត បិទប្រាក់មួយចុង ដោតដមពាងគួឆ្ងេងស្ទាំ រៀបចាំអញ្ជើញអ្នកហោង សូមអ្នកយាគ្រាហោះផ្សង ដល់ហានយើងហោង អញ្ជើញអ្នកសេពសោយ ពោះខ្ញុំធ្វើការមុនគ្រោយ ក្រែងក្ងេច ក្រែងក្ងោយ កុំបីយកពោសា ។ សោយស្រេចស្តេចចរយាគ្រា ទុកពរដយាឲ្យខ្ញុំគ្រប់ប្រាណ សូមឲ្យបានសុខសាន្តដូចក្តីប៉ុនប៉ងប្រាថ្នា ហេតុនេះយើងខ្ញុំគ្រប់គ្នា រៀបថ្វាយបូជាអ្នកស្រេចហោង ។

ហើយពួកភ្លេងកំប្រគំភ្លេងសាធុការ ឲ្យស័ព្ទសាធុការពារ ៣ បទរួចធ្វើពិធីតួចអំបោះមង្គលទីធ្លោះព្រំសុគន្ធវារីលើដហ្វា ហើយពាក្យលើកដហ្វាឡើងភ្ជាប់ទីត្រឹះស្ថានថ្មី រួចប្រគំភ្លេង ៣ បទទៀត ឲ្យស័ព្ទសាធុការពារ ព្រះសង្ឃសូត្រធម៌ដយន្តោ ៣ ចប់ ប្រសិទ្ធិពរជ័យ ។

ពិធីនេះបានធ្វើចប់សព្ទគ្រប់នៅវេលាម៉ោង ៩ កន្លះព្រឹក ។

(តមក)

ព្រះមហា ប៉ាង--ខាត់ រៀបរៀង

អបវរ គុ. ដែលមិនមែនឧបុងដេ, ប្រសើរ ។ – *វយស* នបុំ. យុវដែន ។

អបវិត នបុំ. អចរិត, ការិយាវៀរមិនបរិភោគ ។

អបល គុ. ដែលមិនកម្រើក, ទំងថ្កល់, មាំមួន។ នបុំ. ភ្នំ; ឈ្មោះបងថ្ងៃ ទី៩ខែភទ្របទ ។

អចលា ស្ត្រី. ផែនដី ។ – *ភូមិ* ស្ត្រី. ផែនដី ។ – *ភិទ* បុំ. សត្វកោកំលះ ឬ ភាភេ ។ – *ទ្ធ* បុំ. ឈ្មោះអ្នកឥតធន ។ *អចលាធិប* បុំ. "ស្តេចនៃភ្នំ" ភ្នំហិមាល័យ ។ *អចលេន្ទ្រ* ឬ *អចលេស្វរ* បុំ. ឈ្មោះភ្នំហិមាល័យ ។

អបលន នបុំ. ការិយាមិនកម្រើក ។

អបាតុមិស្ស គុ. ដែលមិនមានពាំដឹងាតុមិស្ស ។

អបាបល, អបាបលយ នបុំ. ការិយាមិនកម្រើក, សេចក្តីទំងនួន ។

(មានត)

ភ្នំពេញសង្ឃនិយា

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ១១ ខែវិច្ឆិកា

ព.ស. ២៥០១ គ.ស. ១៩៥៨

ភ្នំពេញ

ដំណាំងទស្សនាចរនៃរបៀបរៀបចំធ្វើកសៀវភៅ
របស់ពុទ្ធសាសនបណ្ឌិត្យ

សូមប្រគេន សូមដួនដំណាងដល់ពួកពុទ្ធបរិស័ទចាំឯបពុទ្ធដែត ចាំឯ
គ្រហស្ថ នៅខែត្រក្រៅ សូមជ្រាប ។

ដ្បិតរថយន្តផ្សព្វសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យមានចេញដំណើរ
ទៅប្រតិបត្តិការ ប្រស្រ័យជាក់ខាង នឹងជាសៀវភៅធម៌អាថ៌ផ្សេងៗ ផ្តាល់
ដល់ពីប្រជុំជនទីវត្តអារាមនានា ក្នុងខែត្រចាំឯអស់ ចាប់តាំងពីចុងខែមករា
ឆ្នាំ ១៩៥៩ នេះតទៅ ។

ទស្សនាចរនេះនឹងចាប់ផ្តើមក្នុងខែត្រ ៣ ជាមុនគឺ
ខែត្រកំពង់ស្ពឺ កំពត-ខឹងខែត្រតាកែវ រួចហើយនឹងបន្តដំណើរទៅក្នុង
ខែត្រដទៃទៀត មានខែត្រកំពង់ឆ្នាំង-ពោធិ៍សាត់-ចុងដំបងជាដើម ជារំ
ជាប់លាប់ដោយតៗទៅទៀត ។

ដូច្នេះ សូមអស់លោក-អ្នកពុទ្ធមាមកជនចាំឯទាំងឡាយនៅ
ដែលមានបំណងរកសៀវភៅធម៌អាថ៌រៀនសូត្រ សូមអញ្ជើ
សៀវភៅផ្សេងៗពីរថយន្តនោះតាមត្រូវការ ។



ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា ធំងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជើរឿង	ទំព័រ
- ប្រវត្តិពុទ្ធសាសនា នៅប្រទេសខ្មែរ (តមក)	ព្រះមហា ប៉ាង-ខាត់ រៀបរៀង	៨៤៧
- ចិត្តធំកនាំលោក (តមក)	ព្រះពុទ្ធវង្ស កាម-គូរ រៀបរៀង	៨៥៧
- អត្តជាតសុខកថា	ព្រះមហា អ៊ុក-អ៊ុន រៀបរៀង	៨៦៨
ផ្នែកអក្សរសាស្ត្រ		
- រឿងទេន្លេរបស់អម្រឹតក្សត្រីម៉ុក (តចប់)	លោក ញ៉ុក-ថែម រិទ្ធិត្យ	៨៧៨
- រឿងសាមកុក (តមក)	ឧកញ៉ា នួ-កន ប្រែ	៨៨៥
- សុភាសិតអាវប់ (តចប់)	លោក ភ័យ-ប៊ុក ជំនស្រែង់រៀបរៀង	១០១៨
- អធិប្បាយឮឮ ប់កៅ្ត ភាស (តចប់)	លោក ស្រ៊-អ៊ូ រៀបរៀង	១០២១
- ដើមកំណើតរឿងរាមកៅ្ត	លោក ចាប-គិន រៀបរៀង	១០២៧
ផ្នែកកំណត់ទំនៃប្រវត្តិការណ៍		
- ប្រវត្តិការណ៍ ធំងសកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ		១០៣៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហាប៉ាង-ខាត់ រៀបរៀង	១០៤២

មួយឆ្នាំមាន ១២ សៀវភៅ ធំឡុងជា ២៣០០

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

— Histoire du Bouddhisme au Cambodge (suite) par Vén. *PANG-KHAT* 947
— La volonté mène le monde (suite et fin) par Vén. *KEM-TO* 957
— Atthajatasukhakatha par Vén. *OUK-IN* 969

PARTIE LITTERAIRE :

— Histoire de Devanda de *M. MOK* (suite et fin) revue et corrigée par *M. NHOK-THEM* 979
— Histoire de Sam-Kok (suite) traduite par *M.NOU-KAN* 995
— Proverbes arabes (suite et fin) par *M. RAY-BUC* . 1019
— Commentaire du chbab kel kal (suite et fin) par *M. SERY-OU* 1021
— Origine du Ramayana par *M. CHAP-PIN* 1027

NOTES ET CHRONIQUES :

— Les Activités de l'Institut Bouddhique 1037
— Dictionnaire Sanskrit khmèr (suite) par Vén *PANG-KHAT* 1042

Prix d'abonnement annuel (comprenant 12 numéros) : 230 r 00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ជាំង-ខាត់ រៀបរៀង

(តមក)

គឺព្រះមហានគរដែលមានប្រាការ ១២គ.ម. ដុំវិញមានក្នុងជាមជ្ឈមណ្ឌលខុក ជាតួសកលលោកសន្និវាស ឯប្រាសាទបាយ័នខុកជាតួព្រះពុទ្ធអាណាចក្រ (ប្រាង្គកណ្តាលខ្ពស់ជាពុទ្ធានី ប្រាង្គទៅដុំវិញជាទានាខេត្ត) ជាសញ្ញាលក្ខណៈតាំងពីមនុស្សលោកនឹងទៅលោកទៅនាឋានគ្រាមនេះ ។

ក្នុងរជ្ជកាលព្រះអង្គ មានព្រឹត្តិការណ៍មួយចំឡែក គួរតស់សំគាល់ គឺទ្រង់បានបញ្ជូនព្រះរាជបុត្រទៅសិក្សាវិជ្ជាព្រះពុទ្ធសាសនា ហើយបព្វជ្ជា(១) នៅវត្តមហាវិហារនាគោះសិរីលង្កា ។ តាមពង្សាវតារគូមានិយាយថា "មានសាមណេរមនុស្សមួយអង្គឈ្មោះ ធបតៈ អាយុ ២០ ឆ្នាំ ចេញទៅរៀនទៅគោះសិរីលង្កា ១០ ឆ្នាំ ហើយត្រឡប់មកកាន់ប្រទេសកូមាវិញ ពី ព.ស. ១.៧៣៣ ជាមួយនឹងភិក្ខុឯទៀត ៤ អង្គ មួយអង្គនាមតាមលិន្ទៈជាព្រះរាជបុត្រនៃព្រះមហាក្សត្រប្រទេសកម្ពុជា" ។ តែក្នុងតាមលិន្ទៈនេះ

១- បុស្សង្ឃៈ ។

ប្រាកដជាព្រះពាជបុត្រព្រះចាន់ដយវ៉ែនទី ៧ ហើយ ។ សេចក្តីមានប៉ុណ្ណេះ ជាដើមដែលនាំឲ្យអ្នកប្រាជ្ញពន្យល់ថា: "តិក្ខតាមលិន្ទៈ ជាព្រះពាជបុត្រនៃព្រះចាន់ដយវ៉ែនទី ៧ នេះហើយ ដែលនាំពុទ្ធសាសនាថេរវាទលង្កាវង្សចូលមកផ្សាយក្នុងប្រទេសកម្ពុជាមុនដំបូងបង្អស់ក្នុងពន្ធភ្នាគារខ្មែរ" ។ តែសេចក្តីនេះ ខ្ញុំយល់ថា ពុទ្ធសាសនាថេរវាទក្តី សាសនាព្រាហ្មណ៍ក្តី ពុទ្ធសាសនាលទ្ធិមហាយានដែលចូលមកដំនាន់ក្រោយក្តី គាំងតែពីឯានមកប្រតិស្ឋាននៅលើទឹកដីកម្ពុជាហើយ មិនសាបសូន្យឆាត់បង់ចោកក្នុងកាលណាមួយទេ នៅជាមួយគ្នារៀងរហូតមក ឯតិក្ខតាមលិន្ទៈដែលអ្នកប្រាជ្ញទាំងឡាយយល់ថា "ទើបនឹងនាំពុទ្ធសាសនាថេរវាទមកបណ្តុះបណ្តាលនេះ" គ្រាន់តែជាការចាត់ទុកផ្លាស់ប្តូរវប្បធម៌មួយចំណែកតាមប្រវត្តិពណ៌ពុទ្ធសាសនាតែប៉ុណ្ណោះទេ ដូចជាព្រឹត្តិការណ៍ដែលមានក្នុងបច្ចុប្បន្នកាលនេះដែរ ។

ក្រោយរដ្ឋកាលព្រះចាន់ដយវ៉ែនទី ៧ ទៅ ព្រះពាជាសោយរាជ្យជាតំណត្រកូលត្រួបមកតាន់សាសនាព្រាហ្មណ៍វិញ សាសនាព្រាហ្មណ៍រុងរឿងចំនើនក្រោយបំផុតក្នុងទៀត ។ ឯពុទ្ធសាសនាថេរវាទ ដែលមិនសូវលេចឡើងចោះសម្ងួនទើបគេមកអស់កាលយូរហើយនោះ ក៏ចំរើនខ្លាំងណាស់ដែរក្នុងសម័យនេះ ។ លោក ចៀវ តា-កួន ជាពាជទូតព្រះចៅ

ក្រុងចិន ដែលបានមកគាន់មហានគរនៃប្រទេសខ្មែរក្នុង ព.ស. ១៨៣៩ (គ.ស. ១៤៩៦) បានធ្វើសេចក្តីពិពណ៌នាមកដូច្នេះថា "ឃើញមានតិក្ខុគោរព្រះកេស ប្រដាប់ត្រៃចីវរពណ៌លឿង ត្រង់ចីវរធ្វើនស្មាឆ្វេង នៅស្មាស្តាំទទេរ ដើរដើនទទេ វិហារប្រក់ក្បឿង ក្នុងវិហារមានបាឡាតីព្រះ= ព្រះពុទ្ធរូបសក្យមុនី ព្រពុទ្ធរូបនៅក្នុងវិហារធ្វើពីសម្រឹទ្ធ មិនមានដួងស្តេរទេ ធានត្រីសាច់ មិនធានសុកទេ ធានមួយថ្ងៃតែម្តង ក្នុងវត្តអារាមមិនមានផ្ទះបាយទេ តិក្ខុសាមណេរនិមន្តបិណ្ឌបាតសូត្រធម៌ តម្លើដើតាចារជាក់ស្តឹកតែ ព្រះពាជាទ្រង់ពិគ្រោះកិច្ចការធំៗ ទើតិក្ខុសង្ឃ មិនមានតិក្ខុនិទេ" ។ សេចក្តីពិពណ៌លោក ចៀវ តា-កួន នេះ សំដែងឲ្យឃើញច្បាស់ថា ពុទ្ធសាសនាថេរវាទលូតលាស់ដុះដាលចំរើនបរិបូណ៌ត្រៃលែង ហើយបានទទួលស្តាល់ពីព្រះពាជានិងមុខមន្ត្រីរហូតដល់ប្រជាជនខ្មែរ ។

ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ នេះ ប្រទេសខ្មែរចំរើនរុងរឿងដល់ថ្នាក់ខ្ពស់ផុត សមដូចសេចក្តីពិពណ៌ លោក ចៀវ-តា-កួន ថា "តាំង-ប៊ូ-ចេ គឺតម្កល់ជាចំរើនរុងរឿងណាស់, មហានគរ(យសោធរបុរៈក្នុងពាក្យព្រះបាទជយវរ្ម័នទី ៧) គឺអង្គរធំសព្វថ្ងៃនេះ មានកូនំជុំវិញ មានប្រាការ, មានគោបុរៈ ៥ មានលានបង្ហាន់ដែនាគ មានប្រាសាទមាស (បាយ័ន)

ជាមជ្ឈមណ្ឌលមហាន៍គរ, មានប្រាសាទស្ពាន់ (ប៉ាពួន), មួយសែសៅ
ខាងដើង ជាព្រះពន់រាំង ។ ខាងក្រៅប្រាការ នៅខាងត្បូងមាន
ប្រាសាទលូបាន់ (កុំប៉ាខែង) ចេតិយលូបាន់ (អង្គរវត្ត) ។ល។ ។

ព្រះបាទស្រីន្ទ្រវរ្ម័ន ទ្បើងសោយរាជ្យនៅក្រុងយសោធរបុរៈក្នុង
ព.ស. ១៨៣៩ (គ.ស. ១១៩៦) ។ ព្រះអង្គទ្រង់ជ្រះថ្លាក្នុងបវរ
ពុទ្ធសាសនាប្រសើរមួយអង្គដែរ បានថ្វាយគ្រាមមួយសម្រាប់តសាងវត្ត
អារាមទុំសថ្វាយព្រះពុទ្ធសាសនា ក្រោយមកទំនងជាទ្រង់ជាក់ពាក្យ
ថ្វាយព្រះពាជបុត្រហើយចេញសាងអភិនិស្ក្រមណ៍ ។ ក្នុងពាក្យព្រះអង្គ
តើតមានសំលេចរឹកប៉ាលីមុនជំបូងបង្អស់ក្នុងប្រវត្តិពុទ្ធសាសនាថេរវាទនៅ
ប្រទេសកម្ពុជា ។ ខ្ញុំស្រង់យកពាក្យអស់មកទុកក្នុងទីនេះជាអនុស្សាវរីយ៍
ដល់ពុទ្ធសាសនិកជនទូទៅ ។

សេចក្តីបម្លែង

វិសុទ្ធមិសុទ្ធានំ សុទ្ធិសម្បាបកញ្ចិនំ ।
ធម្មញ្ញាយសង្ឃញ្ច សតតំ សិរសា នមេ ॥ ១ ॥
សិរីសិរិន្ទ្រវម្មាទ្យ- កូបេសោ គុណកូសណោ ।
យសោធរបុរេ អាសិ មជ្ឈិន្ទុយមិន្ទុនា ॥ ២ ॥
ន កត្តុយមចន្ទមិហ អសិន្ទីតារកានុតេ ।

ยาเมตีเต ทุปาทเก ॥ ๓ ॥
มหาเวเสฺส ฉัมเตา ।
คามเมตมต มุต ॥ ๔ ॥
ลกฺขี ฆาม จุปาสิกา ।
ฆฆาลงฺการปาลกา ॥ ๕ ॥
วิหารมิฆ สา ปุน ।
จนาเปนฺตี ตเตาปรำ ॥ ๖ ॥
ภูปาธิปตเปสิตา ।
ตาสิตาสาทิเก อต ॥ ๗ ॥
ทิตมยฺหเคามกำ ।
นยฺเคฺคคามกญฺเม ॥ ๘ ॥
สมนฺตทฺวิสาสุ จ ।
ภูปาธิปติ ฉมฺปิกา ॥ ๙ ॥
คามเกฺขตฺตมนฺตเร ।
ยาฉคานมตาปยิ ॥ ๑๐ ॥

วรวิหารมฺหิ ตถเย
สิรีสิรินฺทมาลิสฺส
สิรีสิรินฺทวตน-
สิรีมาลินีวตน-
สทฺธาทิคุณสมฺปนฺนา
เปสิตา เตน การเกา
ปริจฺฉา ตฺวาตญฺจ
ปนฺนคิยมปนฺนมิหิ
พุทฺธปูชญฺจาปเปา
วิกุลตฺถลคามญฺจ
ตาลีสตฺถลคามญฺจ
ตานฺตานฺตา เขตฺตสีมาโย
พุทฺธปูชาย ตาทิสิ
สิรีสิรินฺทวตน-
อชฺฌปนฺนินิ เขตฺตานิ

เสจกฺกีปฺปโย

"ขฺสูมนมสฺการจำเพาะพระชินสรีมหาสุทฺธ ដែលផ្តល់នូវសេចក្តី

បរិសុទ្ធជាលំដាប់មិនបរិសុទ្ធពាំងឡាយផង ចំពោះព្រះធម៌ផង ចំពោះព្រះសង្ឃផង ដោយសិរីសោភ័ព្វផង អស់កាលម៉ាន់ជាច់ ។ ១ ។

"ព្រះរាជាអង្គនេះ ប្រដាប់ព្រះអង្គដោយគុណសម្បត្តិ (គ្រប់ប្រការ) ទ្រង់ព្រះនាមព្រះបាទសិរីសិរិន្ទ្រវម្ម: បានទៀនសោយរាជ្យក្នុងឆ្នាំសោធរបុរ: ក្នុងឆ្នាំឥន្ទ (១), យម: (២), ឥន្ទ (១), មង្គល (៨) =១២៩៨[1] សក: ។ ២ ។

"ក្នុងឆ្នាំ ចន្ទ (១), យម: (២), អគ្គិ (៣), នភ: (០) =១២៣០[2] សក: ប្រកបដោយអស្សនីនក្ខត្តឫក្ស រវាង: ២ បាទ គ្រោយយាមទី ៣ កន្លងហើយ ។ ៣ ។

"ព្រះរាជាឃ្លាយសិរីសិរិន្ទ្រតនគ្រាមនេះ ចំពោះព្រះមហាថេរជាអ្នកប្រាជ្ញ ព្រះនាមសិរីសិរិន្ទ្រមោលិ ដោយសេចក្តីគោរព ។ ៤ ។

"ព្រះនាងទេវាសិតាព្រះនាមសិរីមោលិនីលក្ខី មានគុណធម៌មានសទ្ធាជាដើម ជាអ្នករក្សាខ្លួនព្រះរាជាលង្កា ។ ៥ ។

"ព្រះនាងទេវាសិតាអង្គនេះ គឺព្រះរាជាអង្គនោះ ត្រាស់បង្គាប់ឲ្យចាត់បែងគសាង ព្រះវិហារនៅសិរីសិរិន្ទ្រតនគ្រាមនេះ ព្រមទាំងឲ្យដីកគូទឹងស្រះថមទៀត ។ ៦ ។

1- ១២៩៨ សក: + ៧៨ = ១៣៨៦ គ.ស. + ៥៤៣ = ១៨៣៩ ព.ស.-

2- ១២៣០ សក: + ៧៨ = ១៣០៨ គ.ស. + ៥៤៣ = ១៨៥១ ព.ស. ។

" ក្នុងឆ្នាំ ចន្ទ[1] (១), យមៈ (៤) អគ្គិ (៣), ចន្ទ (១)ព្រះនាងទេចាសិកាអង្គនេះ បានដាំកល់ព្រះពុទ្ធរូបមួយអង្គតាមព្រះពាជ បញ្ជា ព្រមទាំងថ្វាយវត្តទាំង៤ឆ្ងាយមានពាសាពាសីជាដើម ។ ៧ ។

"គ្រាមទាំង៤ឆ្ងាយនេះគឺ វាកុលគ្រាម ១ , គ្រាមឈ្មោះទំពាំ ១, តាល័សគ្គលគ្រាម ១ , នទ្យាគ្គគ្រាម ១ ។ ៨ ។

"ព្រះភូបាធិបតីប្រកបដោយធម៌ ទ្រង់គ្រាស់ឲ្យចងខេត្តសីមា (ឲ្យ-គូវផនទី) ដុំវិញគ្រប់ទិស ហើយថ្វាយជាពុទ្ធបូជា ។ ៩ ។

"នៅក្នុងសំរិទ្ធវត្តនគ្រាមនេះ ទ្រង់មានព្រះពាជបញ្ជាឲ្យចែកខេត្តទាំង៤ឆ្ងាយ ៨ ទៀតដល់យាជកៈ (កិត្តុអកបូជា)ទាំង៤ឆ្ងាយ ។ ១០ ។

ចំណេរចិរកាលតមក ព្រះពុទ្ធសាសនាថេរវេទចំរើនរុងរឿងជាលំដាប់ ។ តពីរដ្ឋកាលព្រះបាទស្រីន្ទ្រវ៉ែនមក រវាងពាក់កណ្តាលពុទ្ធសត-វត្សទី ១៨ (គ្រិស្តសតវត្សទី ១៤) ប្រទេសកម្ពុជាមានគ្រោះថ្នាក់ធំ ចុះរោយ រឿរបន្តិចម្តងៗរៀងមក ដោយសារចម្បាំងទាក់ទងដល់មិនមានដាច់ សិលា-ចារឹកតំណាលពីពាជវង្សតៗមកមិនសូវមាន ពត៌មានតាវត៌ប្តូរណាមាំងប៉ុន្មាន ដែលមានមកហើយ ក៏អក្ខរជាន ចាត់បង់ទៅវិញតាមកាលវេលា រហូត មកដល់រដ្ឋកាលព្រះបាទពញាយ៉ត ពាក់កណ្តាលពុទ្ធសតវត្សទី ២០

(រៀងពី ស. ១៨៧៥ គ.ស. ១៨៣១) ។ ព្រះពុទ្ធពញាយ័តអង្គនេះ លះបង់មហានគរមកតាំងនៅបាសាន (ស្រីសន្ធរ) ហើយតមកតាំងនៅក្រុងចតុម្មុខ (ក្រុងកំពេញ) សព្វថ្ងៃនេះ ។

សម័យបច្ចុប្បន្ន - ពុទ្ធសតវត្សទី ២០ ទៅទី ២៥ (ព.ស. ១៨៧៥-២៥០០) គ្រិស្តសតវត្សទី ១៩ ទៅទី ២០ (ព.ស. ១៤៣១-១៨៥៧) ក្រោយសម័យមហានគរមក ព្រះពុទ្ធសាសនាថេរវាទប្រតិស្ឋានលើផែនដីខ្មែរជាប់ស៊ប់ឥតប្រែប្រួល ចាត់ថ្នាសគល់មាំជាស្តាពរវៀងរហូតមកដល់បច្ចុប្បន្នកាលនេះ ឯសាសនាព្រាហ្មណ៍មិនពុទ្ធសាសនាមហាយានមិនសូវមានសាវ័កកំសាបសូន្យបន្តិចម្តងៗ រហូតដល់អវសាន ចាត់ឈ្មោះចោះសម្លេងសូន្យឈឹង នៅសល់តែបុរាណដ្ឋានជាតំណែលដែរជាសាក្សីភេញប្រទេស ។

ព្រះពុទ្ធសាសនាថេរវាទឡើងគាន់សេចក្តីចំរើន យកវត្តសាសនាព្រាហ្មណ៍មកធ្វើជាវត្តពុទ្ធសាសនាវិញ ចាត់សិវលិង្គនៅលើស្មាន-ព្រាណីទៅ លេចឃើញព្រះពុទ្ធរូបដំកល់នៅលើស្មានព្រាណីដំនួសវិញ ។ មានវត្តច្រើនណាស់ដែលតាំងនៅលើកន្លែងវត្តសាសនាព្រាហ្មណ៍ឈ្មោះនៅជាឈ្មោះវត្តសាសនាព្រាហ្មណ៍ថា អង្គ, តាំង, ក្រាំង, រលាំង, ចា ដូចជា អង្គព្រះលិង, តាំងគោក, ក្រាំងស្វាយ, រលាំងកែន, ចាជាយ

ជាដែល តែតួវត្តសព្វថ្ងៃជាពុទ្ធសាសនា ។ វត្តណាមួយដែលតាំងនៅលើវត្តសាសនាព្រាហ្មណ៍ វត្តនោះមិនមែននៅសល់តែឈ្មោះទេ នៅមានសល់ពាំងស្នាមដំណែលសាសនាព្រាហ្មណ៍ គឺហានកែលាសជាដើម នៅព្រះវិសូរទៀតផង ។ ឯទំនៀមប្រពៃណីឬពិធីផ្សេងៗ ដែលលាយឡំដោយលទ្ធិសាសនាព្រាហ្មណ៍ទន្ទឹងពុទ្ធសាសនាមហាយាន ក៏កើតទៅជាទំនៀមប្រពៃណីស្រុកខេសជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ក្នុងព្រះបរមរាជវាំង ព្រះរាជពិធីផ្សេងៗ ដែលមានមកពីបុរាណកាលចំនួន ២.០០០ ឆ្នាំមកហើយ ក៏នៅមានតាមប្រពៃណីដើមដដែល ។ សព្វថ្ងៃនេះ មើលទៅឃើញតែវត្តអារាម កុដិវិហារសាលាដំហើយដោយកំពូលតាងឃ្វាយច្រូងច្រាង កិក្ខុសាមណេរគ្រងចីពរពណ៌លឿង សព្វទីកន្លែងពាសពេញព្រះរាជអាណាចក្រ បានជាគេតែងមានពាក្យអ្នកបរទេសខ្លះគេហៅប្រទេសយើងថា "ប្រទេសកិក្ខុសង្ឃ" ។

ពុទ្ធសាសនាទឹងប្រជាជនខ្មែរ:- ក្នុងសម័យតាប់ទន ប្រជាជនខ្មែរពាំងប្រទេសបានជួបប្រទះសេចក្តីទុក្ខវេទនាខ្លាំងបំផុត ថមថយកម្លាំងទន្ទឹងសាធសេចក្តីចំរើនដូចសម័យត្រង់នាយពុំបាន តែទោះបីជាត់ចុះដុនជាបប៉ុណ្ណាក៏ដោយ ប្រជាជនខ្មែរដែលបានស្គាល់សេដាតិព្រះធម៌ថ្លៃវិសេសហើយ ទុបសាសនានេះជាប់ទន្ទឹងខ្លួនចុះតបក សូស្មាប់មិន

ព្រមលះបង់ចោល ។ បុណ្យទទួលព្រះបរមសារីរធាតុនឹងព្រះអរហន្ត-
ធាតុព្រះសារីបុត្តនឹងព្រះមហាមោគ្គល្លានពីខែ តុលា ព.ស. ២៤៩៤ ជា
ពស្តុតាងឲ្យឃើញច្បាស់ថា ប្រជាជនខ្មែរពាំងប្រទេសមានចិត្តភក្តីចំពោះ
ព្រះពុទ្ធសាសនាស្រាប់ហើយ ។ ពុទ្ធសាសនាថេរវាទដែលធ្លាប់មាន
មកពីសម័យត្រៃនាយស្រាប់ ក៏ជ្រួតជ្រាបរហ័សចូលទៅដល់ចិត្តថ្មើម
ប្រជាជនគ្រប់ជាន់គ្រប់ថ្នាក់ ហើយធ្លាក់ជាប់មិនមានឥទ្ធិពលអ្វីមួយមកគាស់
រំលើងបានឡើយ ។ អស់លោកអ្នកនាំប្រទេសខ្មែរ ព្រះមហាក្សត្រ មន្ត្រី
តួបំផុត ដែលបានយល់តម្លៃពុទ្ធសាសនាថាមានផលប្រយោជន៍ មានហេតុ
ផលគ្រប់គ្រាន់ល្មមនាំខ្លួនទៅកាន់សេចក្តីសុខក្សេមក្សាន្តបាន ក៏ព្រមលះ
បង់សាសនាដទៃចោលអស់ទៅជ្រើសសម្រាំងយកតែពុទ្ធសាសនាថេរវាទ
មួយប៉ុណ្ណោះ ពុតជាសម្តែងវប្បធម៌ប្រចាំប្រទេសខ្មែរហូតដល់មកបច្ចុប្បន្ន
កាលនេះ ។ ក្នុងសម័យអាប់ឧនប្រជាជនខ្មែរបានពុទ្ធសាសនានេះហើយ
ជាសរណៈដ៏ត្តមខ្ពង់ខ្ពស់ជួយសម្រាលលំហៀរសេចក្តីទុក្ខ ដោយដឿតម្ង
ផលច្បាស់លាស់ថា «ដើម្អ បានម្អ ដើម្អអាត្រក់ បានអាត្រក់» ហើយ
ខ្លួនឯងប្រឹងប្រែងប្រដៅកូនចៅនៅឯក្រោយឲ្យខំតស៊ូឯសេចក្តីល្អ ដើម្បីតស៊ូ
អនាគតឲ្យបានរុងរឿងដូចសម័យត្រៃនាយវិញ ទោះជាលំបាក
យ៉ាងណា ក៏ពេញចិត្តរួមសុខទុក្ខជាមួយពុទ្ធសាសនា ពាល់តែកើតទៅជា
សុភាសិតប្រចាំជាតិថា «ស្លឹស្លាប់ទៅតាប់ រសជាតិកុំបីបាត់» ។ (មានត)

បិត្តជំកនាំលោក

ព្រះពុទ្ធឃោស ភិម-តូរ រៀបរៀង

(តមក)

ប៉ុគ្គលអន្ធពាលមិនអាចរក្សាចិត្តរបស់ខ្លួនបានទេ រមែងជាល់ខ្លួវសេចក្តីវិនាសព្រោះតែធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃចិត្ត ឯបណ្ឌិតមិនធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃចិត្តទេ គឺលោកធ្វើចិត្តឲ្យលុះក្នុងអំណាចនៃខ្លួនវិញ ទើបរក្សាចិត្តបែបនោះបាន ព្រោះថា ចិត្តដែលគេគ្រប់គ្រងឲ្យនៅក្នុងអំណាចនៃខ្លួនបានហើយ រមែងនាំសុខមកប្រគល់ឲ្យ ។

គួរធ្វើចិត្តឲ្យលុះក្នុងអំណាចខ្លួន

ពិតមែន, ចិត្តនេះជាធម្មជាតតែងតម្រើកញាប់ញ័រ ឃ្លេនឃ្លោន ស្ទុះស្ទារឆ្ងាត្សុលដ្រសៅរសៅរសៃកាគារម្មណ៍មានរូបជាដើម ពិបាកនឹងរក្សា ពិបាកនឹងហាមឃាត់ពត់តម្រង់ឲ្យត្រង់ឬឲ្យស្ងប់ស្ងៀមសូម្បីតែមួយស្របក់ក៏មិនងាយនឹងធ្វើបាន, ដូចកូនក្មេងដែលនៅតូច។ មិនអាចនឹងធ្វើវាឲ្យនៅស្ងៀម តែកុងឥរិយាបថមួយ។ បាន, ពុំនោះសោត ដូចគោល្អើកស៊ីសំណាបសំខ្ចីនៅក្នុងចំបន្លែតគាន់ដោយសំណាបសំខ្ចី ពិបាកម្ចាស់នឹងការពារឲ្យនៅនឹងតែកន្លែងមួយបាន ក៏ដូច្នោះដែរ ។ ប៉ុន្តែ ចិត្តនេះ បើទុកជាពិបាកនឹងថែរក្សាដូចពាក្យខាងមកហើយនោះក៏ដោយ គង់តែមាន

បណ្ដិតអាចដើម្បីចិត្តឲ្យល្អុះល្អិនអំណាចនៃខ្លួនដោយគ្រឿងពត់ផ្សេង ។ ដរាបដល់ត្រង់ស្រួលទៅបាន ប្រៀបដូចជាដែត្រួញ យកឈើឬឫស្សីមួយកំណាត់ មកបកសំបកមកពុះលួសហើយ លាបទឹកថ្នាយឬប្រេងឲ្យជោកហើយយកទៅពេលឆ្ពោះលើរដើកភ្លើងឲ្យរន់សាច់ ហើយយកទៅសិកក្នុងឃ្នាបគាបពត់តម្រង់ឲ្យល្អមិនឲ្យមានរឿចកោង ឲ្យគួរដល់ការប្រាញ់ សូម្បីប្រាញ់ពេមសត្វដែលជារបស់ល្អិតឆ្មារ ក៏អាចប្រាញ់បាន ល្អុះធ្វើបានការហើយ ក៏យកសិល្បៈនោះទៅសំដែងបង្ហាញចំពោះព្រះមហាក្សត្រិយ៍នឹងភជមហាមាត្យទ្រង់ជ្រាបថា ខ្លួនជាអ្នកប្រាញ់មានថ្នូរដៃស្ទាត់ជំនាញមែន ក៏រមែងបានលាភសក្ការៈព្រមទាំងសេចក្ដីរាប់អានជាច្រើន សេចក្ដីនេះឧបមាយ៉ាងណា បុគ្គលអ្នកមានប្រាជ្ញារមែងចាប់យកចិត្តដែលមានសភាពដូច្នោះមកបកសំបកគឺកិលេសដ៏គ្រោតគ្រាតឲ្យប្រាសចាកសន្ដាន ដោយអំណាចធុតង្គ ហើយលាបទឹកថ្នាយឬប្រេងគឺសទ្ធា (ជំនឿ) រួចយកទៅពេលភ្លើងគឺវិរិយៈ (សេចក្ដីព្យាយាម) ដែលប្រកបក្នុងកាយនឹងចិត្ត ហើយទៅសិកគាបក្នុងឃ្នាប គឺ សមថកម្មដ្ឋាននឹងវិបស្សនាកម្មដ្ឋាន ពត់តម្រង់ឲ្យទៅជាចិត្តត្រង់ មិនឲ្យមានរឿចកោងមិនឲ្យមានពុតកំណាច ល្អុះពត់សម្រួលបានការហើយ ក៏ផ្ដងចិត្តឡើងរំពឹងពិចារណាសង្ខារទាំងអស់ដោយញាណឲ្យភាល់តែឃើញថាជាត្រៃលក្ខណ៍ពិត។ ហើយចំបែកទំលាយគំនរអវិជ្ជា

សេចក្តីឆន្ទៈគ្រាន់តែទៅ ដើម្បីកន្លងទុក្ខ ឲ្យផុតចេញចាកសន្តានចិត្តហើយ ពាក្យថាតណ្ហាវិសេស គឺដែលអាចនាំ ឲ្យតាំងនៅក្នុងកណ្តាប់ដៃរបស់ខ្លួនបានហើយ រមែងបានដល់នូវភាពជាអគ្គទក្ខិណេយ្យបុគ្គលប្រសើរក្នុងលោក ជាអ្នកគួរដល់ការគោរពនឹងសមានគារវៈរបស់ទេវតានឹងមនុស្សទាំងឡាយទូទៅ តំមានឧបមេយ្យដូច្នេះឯង ។ ព្រោះហេតុនោះ ធម្មតាចិត្តកាលបើរឭកអំពីការសេពគប់បណ្ឌិត រឭកអំពីការសិក្សាអប់រំឬមិនមានសមថធម៌ជាឃ្លាបជាវីពំនាក់ទេ តែងតែឃ្លេងឃ្លោង ត្រឡប់ក្លាយទៅក្នុងផ្លូវធ្វេងនាំឲ្យខូចខុសគន្លងធម៌ក៏មាន តែងរវើរាយបម្រាស់នៅលៀលទៅតាមអារម្មណ៍ផ្សេងៗខុសទំនងក៏មាន តែងតែអន្ទះសាធ្វើការប៉ុលប៉ុបជានិច្ច ឥតដែលចេះនៅនឹងស្ងប់ស្ងៀមម្តងណាឡើយ ចិត្តនេះលោកប្រៀបថា មានអាការដូចផ្ទៃត្រឡាចដែលគេដាក់លើខ្នងរុះឬដូចបង្គាលដែលគេចោះលើគំនរអង្កាម, ពុំនោះសោតដូចអាការរបស់ស្វាឬកូនក្មេងតូច ដូច្នេះឯង ។

បំណង់របស់ចិត្ត

បំណង់របស់ចិត្ត បំពោះអារម្មណ៍ខាងក្នុងឬខាងក្រៅមិនមានពីបំផុតចប់ទេ ចិត្តនេះតែងស្រេកឃ្លានជានិច្ចចំពោះអាហារ គឺអកុសលធម៌ទាំងពួង បណ្តាលអកុសលធម៌ទាំងអស់ មានទីវរណធម៌ ៥ ជាដើម ជាអ-

ហារបស់ចិត្តខាងអក្រក់, ចំណែកខាងកុសលធម៌មានបុញ្ញកិរិយាវត្ថុ ៣ នឹងសតិប្បដ្ឋាន ៤ ជាដើមជាអាហារបស់ចិត្តខាងល្អ ដូចគ្នានឹងកោជនាហារសម្រាប់រូបកាយដែរ ។ ប៉ុន្តែធម្មតាចិត្តរបស់មនុស្សបុថុជ្ជន ច្រើនតែមានចំណូលល្មោភធ្ងន់ទៅខាងវត្ថុកាមនឹងកិលេសកាម ដោយមិនចាប់បន្ទុំ ព្រោះតាមពាំនោះជាកំណើតជាលំនៅរបស់ចិត្តដែលភ្ជាប់តែប្រស្រ័យមកស្រាប់, បើគេចាប់ពាក្យចិត្តនោះលើកជាក់ក្តីធម៌ដែលជាប្រតិបក្ខនឹងតាមនោះគាល ណា, ចិត្តនេះក៏ក្រាញមិនចង់នៅទេ តែងតែបម្រះនៀលស្ទុះទៅរកតាមគុណជាលំនៅរបស់ខ្លួនជាដែលវិញ គាលនោះ, ដូចពួកសត្វរាជាតិមានត្រីជាដើម ជាសត្វកើតក្នុងទឹក មានទឹកជាលំនៅ កាលបើគេចាប់លើកស្រង៉ាក់ឡើងផុតពីទឹកមកជាក់លើគោក, ត្រីនោះតែងបម្រះនៀលបែរមុខទៅរកទឹកវិញ ព្រោះអ្វី ? ព្រោះទឹកនោះ ជាកំណើត ជាលំនៅរបស់ត្រី ក៏ភ្ជាប់ប្រស្រ័យមកស្រាប់ ឬដូចពួកទីឃជាតិមានពស់ជាដើម ធម្មតាពស់តែងចូលចិត្តនៅត្រង់ទីកៀនគោះទីចង្អៀត ទីដែលមានព្រៃស៊ុបច្រុប បើទុកជាគេចាប់វាយកមកជាក់ឲ្យនៅទីវាលទីស្រឡះ ពស់នោះមិនពេញចិត្ត មិនដឹងនៅទេ តែងតែជាកវេលូនគ្រឡុសសុលរុកទៅរកទីកៀនគោះ ទីស៊ុបច្រុបនោះវិញព្រោះទីកៀនគោះទីស៊ុបច្រុបនោះជាលំនៅ ជាកំណើតរបស់ពស់ ជាទីដែល

វាធ្វាប់ជ្រែក ធ្លាប់ប្រស្រ័យជាប់ក្នុងចិត្តតាំងពីកំណើតមក ជាហេតុនាំឲ្យ
ពស់នោះមិនជាចង់អាល័យ សេចក្តីប្រៀបធៀងនេះយ៉ាងណាមិញ; ធម្មតា
ចិត្តរបស់មនុស្ស សូម្បីកំពុងធ្វើការអ្វីក្តី គិតពីរឿងអ្វីក្តី និយាយសំណេះ
សំណាលពីរឿងផ្សេង ។ ក្តី ច្រៀងពិគុកកំប្លែងក្តី សូម្បីប៉ះទង្គិចនឹងអ្វី
មួយហើយភ្ញាក់ផ្អើលសមាត់ក្តី ច្រើនតែធ្លាប់ឆ្ងន់រំលងសសៀរទៅរកតែគ្រឿងកាម
ជាប់ស្អិតតែនឹងគ្រឿងកាម ផ្រេកសម្ងំទៅតែក្នុងគ្រឿងកាមបើពុំដាច់ចិត្តនោះឲ្យងាកឃ្លាតចេញពីគ្រឿងកាមនោះមក ដោយ
ពេលខ្លះ ។ ក៏មិនបានយូរប៉ុន្មានដែរ គង់តែស្ទុះបម្រះនាំលផ្រេក
សម្ងំជេកគ្រាំទៅក្នុងគ្រឿងកាមនោះដដែលវិញមិនជាច់អាល័យ, ព្រោះ
ហេតុអ្វី? ព្រោះកំណើតរបស់មនុស្សតែតមកអំពីតាម ធ្លាប់ជេកគ្រាំទៅ
ក្នុងកាម មានកាមជាចំណី មានកាមជាលំទៅ ក៏យ៉ាងនោះដែរ ព្រោះ
ហេតុនោះ ចានជាការខ្លាំនចិត្តឲ្យលះចំណង់ក្នុងកាមចេញបានដោយ
កម្រពេកណាស់ លុះតែបណ្ឌិតអ្នកមានប្រាជ្ញាធ្លាប់ស្គាល់តសមាយា
បស់ចិត្តដោយជាក់ច្បាស់ ទើបអាចប្រើប្រាជ្ញាខ្លាំនប្រឿនប្រដៅពត់
តម្រង់ចិត្តឲ្យមានបែបបទទៅបាន ។

លោកត្រូវបិទ្ធដឹកនាំដូចម្តេច?

ពាក្យក្នុងមាតិកានេះ ត្រូវបែងជា ៣ បទ គឺលោក ១ បទ ចិត្ត ១

បទ ដឹកនាំ ๑ បទ ๆ ត្រង់ពាក្យថា "លោក" នឹងពាក្យថា "ចិត្ត" បានអធិប្បាយខ្លះមកហើយ នៅតែពាក្យថា "ដឹកនាំ" ពុំទាន់អធិប្បាយ សូមអធិប្បាយដោយសង្ខេបដូចតទៅនេះ :

បិត្តនាំសត្តលោក

មនុស្សម្នាក់ៗដែលនៅក្នុងទ្រឹស្តីលោក ហៅថា "សត្តលោក" មានចិត្តជានាមធម៌ដ៏ត្រកាលគ្រប់គ្រង សម្រាប់ដឹកនាំកាយជារូបធម៌ឲ្យប្រព្រឹត្តទៅដោយអាការផ្សេងៗមានអាការថោក ថ្លៃ ថាប ខ្ពស់ ទូប ជាអាក្រក់ ល្អជាដើម ។ ខាងអាការថោក ថាប ទូប អាក្រក់ មានដឹកនាំឲ្យខ្ជិលច្រអូស មិនឲ្យរៀនសូត្រ មិនឲ្យធ្វើការងារជាប្រយោជន៍ផ្សេងៗ ព្រមទាំងដឹកនាំឲ្យប្រព្រឹត្តអាក្រក់ផ្សេងៗ មានសម្លាប់លួចប្លន់ជាដើមទៀតផង បួនគាលដឹកនាំជ្រុលជល់ទៅសម្លាប់មាតាបិតារបស់ខ្លួនក៏មាន (ព្រោះអស្រ័យលោភៈ ទោសៈ មោហៈ) ។ ខាងអាការថ្លៃ ខ្ពស់ ជា ល្អ មានដឹកនាំឲ្យទស្សាហ៍រៀនសូត្រវិជ្ជាការផ្សះផ្សាលោកផ្សះធម៌ ឲ្យធ្វើការងារជាប្រយោជន៍ដល់ខ្លួននឹងប្រទេសជាតិ ឲ្យធ្វើទានរក្សាសីលជាដើម រហូតដល់ដឹកនាំឲ្យចម្រើនធម៌លះកិលេសឲ្យបានសម្រេចមគ្គផលនិព្វានជាទីបំផុត (ព្រោះអស្រ័យ អលោភៈ អទោសៈ អមោហៈ) ។ រួមសេចក្តីថា សត្តលោកនឹងបានសុខឬទុក្ខ ក្នុងលោកនេះ នឹងទៀងសូត្រ ឬចុះនរក

ក្នុងលោកខាងមុខ ឬក៏នឹងសម្រេចព្រះនិព្វានជាទីបំផុតលោកឃាន កំ
ព្រោះតែចិត្តដឹកនាំ ។

ឧទាហរណ៍ក្នុងសម័យពុទ្ធកាល ចំពោះអ្នកដែលលុះតាមអំណាច
ចិត្តដឹកនាំប្រកបដោយអាសាថោក ទាប ខ្ជូច អាក្រក់ ដូចទៅវត្តដែលបួស
តាមព្រះសម្មាសម្ពុទ្ធ ប៉ុន្តែត្រឡប់ជាញ៉ាយាមសម្លាប់ព្រះអង្គដោយៗឃាយ
ផ្សេងៗ មានប្រមេ លឫពីលើកំគិដ្ឋកូដម្ងាក់លើព្រះអង្គធ្វើព្រះពុទ្ធឃាតឲ្យ
ព្រុតឥន្ទ្រព្រះលោហិតដែលហៅថា ធ្វើពុទ្ធលោហិតុប្បាទ ជាអនន្តរិយកម្ម
លុះស្លាប់ទៅៗ កើតក្នុងអវិចីមហានរក នឹងដូចព្រះបាទអជាតសត្រូវដែល
សេពគប់នឹងទេវទត្តបានធ្វើឃាតព្រះបាទពិម្ពិសារជាព្រះបិតា លុះទ្រង់
អស់ព្រះជន្មទៅៗកើតក្នុងលោហកុម្ភីនរក ។ ចាំងអ្នកដែលលុះតាម
អំណាចចិត្តដឹកនាំប្រកបដោយអាសាវិថ្ងន់ ជា ល្អ ក្នុងសម័យពុទ្ធកាល
ដែលជាសម័យចិត្តនិយម គឺសម័យដែលមនុស្សព្រមអានការហាត់ពត់ចិត្ត
ជាធំ គេញ៉ាយាមហ្វឹកហ្វឺនចិត្តឲ្យដល់កម្រិតជាចិត្តន្តស់ឯក. ចិត្តដែលគេ
ហ្វឹកហ្វឺនល្អហើយអាចឲ្យគេបានសម្រេចមគ្គផលដល់ថ្នាក់ន្តស់បំផុត គឺ
សម្រេចអរហត្តបដិសម្ភិទា ជាព្រះខីណាស្រពប្រកបដោយឫទ្ធិដូចព្រះ
មហាមោគ្គល្លានជាឧត្តិយសាវ័កនៃព្រះសម្ពុទ្ធជាដើម ។ ចិត្តជាធម្មជាត
ដ៏ត្រកាលអាចបង្វិលសត្តលោកឲ្យវិលទៅរកសេចក្តីចម្រើនក៏មាន ទៅរក

សេចក្តីវិនាសកំមាន ដូចពណ៌នាមកដោយសង្ខេបនេះ ។

ព្រោះហេតុនេះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនា ដូចន័យដែលតាំងខុទ្ទកជាមាតិកាខាងដើមបំផុតថា "ចិត្តេន នីយតិ លោកោ លោកត្រូវចិត្តដឹកនាំ" គឺថា "ចិត្តដឹកនាំសត្តលោក" ន៎ុះឯង ។

បិត្តដឹកនាំឧកាសលោក

ចក្រវាឲមួយៗ ដែលជាទីប្រជុំធាតុធាតុមានដីទឹកភ្លើងខ្យល់ជាដើម ជាលំនៅរបស់សត្តលោកហៅថា "ឧកាសលោក" ជាលោកមួយៗពុំមានចិត្តគ្រប់គ្រង តែងទន់ខ្សោរទៅតាមចិត្តគំនិតរបស់សត្តលោក គេចង់ដឹកនាំចង់បង្វិលឲ្យទៅជាយ៉ាងណា ក៏ចេះតែទន់ទៅតាមគេយ៉ាងនោះ ដូចក្រមួនត្រូវកំដៅ ចេះតែវិលដូចកង្ហារត្រូវខ្យល់ គឺស្រេចតែចិត្តគេត្រូវគាស, បានសេចក្តីថាឧកាសលោក គឺផែនទឹកផែនដី ស្រុកទេសក្នុងកាលជាអតីតក្តី បច្ចុប្បន្នក្តី អនាគតក្តី ទំនឹងបានចម្រើនឬបាត់វិនាសដូចម្តេចៗ ក៏ស្រេចតែចិត្តគំនិតរបស់ពលរដ្ឋនៃប្រទេសនោះៗ គេចាត់ចែង, ទុកាហរណ៍ដូចក្នុងសម័យបច្ចុប្បន្ននេះ ដែលជាសម័យសម្ភារនិយម គឺសម័យមនុស្សប្រកបអានគ្រឿងសម្ភារៈដ៏ប្រណីតៗ បើគេចូលចិត្តវត្ថុណា គេក៏ខំគិតរកឲ្យបានផ្លូវវិទ្យាសាស្ត្រ ហើយគេប្រឌិតធ្វើវត្ថុនោះឲ្យបានដើម្បីជាគ្រឿងប្រើប្រាស់គ្រឿងបរិភោគគ្រឿងមើលគ្រឿងស្តាប់ ច្រើន

មុខ ច្រើនបែប ជាអនេកវាប់មិនអស់ ដូចគ្រឿងចក្រ គ្រឿងយន្ត មានរថយន្ត រ៉ឺម៉ូ រ៉ឺម៉ូទុនស្សន៍ជាដើម សម្រាប់មនុស្សប្រើប្រាស់តាមត្រូវការជាសាធារណៈទូទៅ ។

និយាយដោយខ្លី សម័យបច្ចុប្បន្ននេះ គេអាចធ្វើលោហធាតុគ្រឿងធ្ងន់ៗជាស្រាលឲ្យហោះហើរដើរនាផ្ទៃអាកាស លើផែនដី លើផ្ទៃទឹក ឲ្យមុជក្រែកដីក្រែកទឹក ដឹកនាំសម្ភារៈនឹងមនុស្សច្រើននាក់ ឲ្យធ្វើគមនាគមន៍ជុំវិញលោកបាន ។ល។ ជំនួសសម័យពុទ្ធកាលដែលមានមនុស្សចេះហោះហើរដើរនាអាកាសផ្តាល់ខ្លួនមួយរូប ។

បើយើងយកព្រឹត្តិការណ៍របស់មនុស្សសម័យពុទ្ធកាលមកដំណាលប្រាប់មនុស្សសម័យបច្ចុប្បន្នថា "សម័យពុទ្ធកាល លោកដែលបានហ៊ឹកហ៊ឺនចិត្តដល់កម្រិតជាចិត្តខ្ពស់ឯក លោកចេះហោះ". ហើយបើមនុស្សបច្ចុប្បន្នគេមិនជឿព្រោះគេមិនបានឃើញជាក់ទឹងភ្នែកគេ នោះយើងគប្បីសួរបញ្ជាក់គេវិញថា "ប្រសិនបើយើងកើតក្នុងសម័យពុទ្ធកាលដែលពេលនោះជាសម័យចិត្តនិយមដែកមិនទាន់ចេះហោះនៅឡើយ ហើយបើពេលនោះមានអ្នកណាគេប្រាប់ថា ដល់មកសម័យយើងនេះដែកចេះហោះហើរដើរឯអាកាសបាន តើយើងជឿគេទេ?" ថាយើងមិនជឿដែរព្រោះយើងមិនបានឃើញទឹងភ្នែក ; ប៉ុន្តែដល់មកសម័យនេះយើងបាន

ឃើញនឹងភ្នែក យើងក៏ជឿថា មានដែរបេះហោះមែន ព្រោះជាសម័យ
សម្ភារនិយម ចិត្តរបស់មនុស្សសម័យនេះគេរិះគិតដល់កំរិតមែនទែន
ទៅ គេអាចប្រឌិតឲ្យដែរបេះហោះហើរដើរនាអាកាសដ្រែកចឹកដ្រែកដំបាន
ជាច្រើនដង ។

ដូច្នេះ យើងគប្បីយល់ថាសម័យណាក៏ដោយឲ្យតែចិត្តសត្តលោក
ដឹកនាំទៅយ៉ាងណា, ទុកាសលោកក៏ទន់ទៅតាមគេយ៉ាងនោះ ។

ព្រោះហេតុនេះ ទើបគួរចាត់លោកជា ២ សម័យ :

ទី ១ សម័យចិត្តនិយម ;

ទី ២ សម័យសម្ភារនិយម ។

សម័យសម្ភារនិយម ចាត់ជាប្រើនយ៉ាងទៅទៀត ជាអាទិ៍ គឺ

ក) សម័យថ្ម ជានពាសម័យដែលមនុស្សលោកនិយមកាប់គាន
គ្រឿងសម្ភារៈផ្សេងៗដែលធ្វើដោយថ្ម គេយកថ្មធ្វើគ្រឿងប្រើប្រាស់
របស់ណាកើតដោយថ្មគេសំគាល់ថាជារបស់ល្អវិសេស (សម័យនេះ
ប្រាសាទថ្មនគរវត្តខ្ញុំយើងបានទទួលកិត្តិយសពីសាកលលោកថាជាវត្ត
អស្ចារ្យទី ៧ នៃវត្តអស្ចារ្យក្នុងសាកលលោក) ;

ខ) សម័យកៅស៊ូ ជានពាសម័យដែលមនុស្សលោកនិយមកាប់គាន
គ្រឿងសម្ភារៈប្រើប្រាស់ផ្សេងៗ ដែលធ្វើដោយដំរកៅស៊ូគេយកដំរកៅស៊ូ

ធ្វើគ្រឿងប្រើប្រាស់ របស់ណាកើតពីដែរកៅស៊ូគេសំគាល់ថាជារបស់ល្អ វិសេស ។ កាលបើមនុស្សលោកនិយមដូច្នេះ ពួកអ្នកវិទ្យាសាស្ត្រក៏ប្រណាំងប្រជែងគ្នា ធ្វើប្រដាប់ប្រើប្រាស់ដោយជាតិកៅស៊ូឲ្យកើតខ្មែនថែមទាំងគេយកកៅស៊ូធ្វើជាសាច់សំពត់១ បែបហៅ "ឡាន" ជាដើម សម្រាប់ធ្វើជាគ្រឿងស្បែកពាក់គ្រឿងប្រើប្រាស់ផ្សេង។ ដែលអាចចេញមុខជាសម័យមួយបាន ហៅថា "សម័យនឡាន" ក្នុងបច្ចុប្បន្ននេះ ;

គ) សម័យបរមាណូ បានទាំងសម័យដែលមនុស្សលោកនិយមរាប់អានគ្រឿងប្រើប្រាស់ផ្សេង។ ដែលធ្វើដោយផ្សំជាតុជាតិបរមាណូថាជាវត្ថុវិសេសហើយជាវត្ថុដែលអាចប្រព្រឹត្តទៅបានទាំងការគុំសាងលោក ទាំងការបំផ្លាញលោក ។

បច្ចុប្បន្ននេះ ពិភពលោកឃ្លាតចេញវាកសម័យថ្មី ចេរមកជាសម័យកៅស៊ូ ឬសម័យនឡាន និងសម័យបរមាណូវិញ, ព្រឹត្តិការណ៍នៃសម័យទាំងនេះ កំពុងតែប្រណាំងប្រជែងគ្នាពេញទំហឹងដោយអ្នកវិទ្យាសាស្ត្រ គ្រោះគិតប្រឌិតធ្វើឲ្យប្លែក។ ឡើងច្រើនបែបច្រើនយ៉ាងណាស់មិនឈប់ឈរបើរាប់ ។ យើងមិនអាចទាយថា ទៅអនាគតតើព្រឹត្តិការណ៍ពិភពលោកនឹងអាចប្រែក្លាយទៅជាសម័យអ្វីទៀតនៅឡើយទេ តែគេអាចសន្និដ្ឋានជាឯកច្ឆន្ទថា ព្រឹត្តិការណ៍ពិភពលោកខាងសម័យណាក៏ដោយ សុទ្ធតែ

ស្រេចលើចិត្តានុភាពរបស់មនុស្សពាំងអស់ ។

ចិត្តអាចបង្ខិលលោកឲ្យទៅជាលោកសង្គ្រាមច្បាំងសម្លាប់គ្នាក៏បាន ដូចសម័យសង្គ្រាមលោកលើកទី ១ និងទី ២ កន្លងទៅហើយ. ឲ្យទៅជាលោកសន្តិភាពស្ងប់ច្បាំងក៏បាន ប្រសិនបើសត្តលោកគេត្រូវការចម្រើនចិត្តភាវនាផ្លូវនេះមែនទែន. សព្វថ្ងៃប្រទេសជាច្រើនក្នុងអាស៊ីទូបគេបាននាំគ្នាញ៉ាំងបញ្ញាសីលា (សីល ៥) តាមលំនាំព្រះពុទ្ធសាសនាឲ្យមានដំហានឈានទៅខាងមុខខ្លះហើយ. ដើម្បីទប់ទល់កុំឲ្យកើតសង្គ្រាមលោកលើកទី ៣ តទៅ ព្រោះគេនឿយណាយស្អប់ខ្ពើមសង្គ្រាម គឺថា គេប្រាថ្នាគេព្យាយាមបង្ខិលលោកឲ្យវិលឃ្លាតចាកលោកសង្គ្រាម ទៅជាលោកសន្តិភាពឲ្យចាស់តែបាន ។

ព្រោះហេតុតែចិត្តជាធម្មជាតមានអានុភាពដូច្នេះបានជាព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ត្រាស់ដូចន័យដែលបានស្រង់យកមកអាំងខុកជាមាតិកាខាងដើមបំផុតថា «ចិត្តេន នីយតិ លោកោ លោកត្រូវចិត្តដឹកនាំ» ដូចពណ៌នាមកនេះ ។

រួមសេចក្តីថា ស្រេចលើចិត្តរបស់មនុស្សគេត្រូវការចាប់អង្រួន ឬបង្ខិលលោកទៅយ៉ាងណា លោកក៏រញ្ជួយ ឬវិលទៅតាមគេយ៉ាងនោះឥតប្រែតែកបានសោះឡើយ ។

ចិត្តដឹកនាំលោក ចប់ដោយសង្ខេប ។

អត្ថជាតសុត្តកថា

"ការពោលអំពីកិច្ចត្រូវការ ធ៌មអ្នកជួយឲ្យបានសុខ"

ព្រះមហា អ៊ុក-អ៊ីង រៀបរៀង

ក្នុងលោកនេះ អ្វីមួយ ដែលកើតឡើងដោយមិនមានកិច្ចត្រូវការ ពុំមានទេ ។ កិច្ចត្រូវការបង្អាប់ឲ្យកើតសត្វវត្ថុ ដែលទបតរណ៍សម្រាប់ មនុស្ស នៅលើសកលលោកឥតខ្វះចន្លោះ ។ ប៉ុន្តែ កិច្ចត្រូវការសាង សត្វវត្ថុបានហើយ ច្រើនតែគ្មាយទៅជានាំដុត ឲ្យក្តៅពោលពាល បំផ្ទុច បំផ្លាញបៀតបៀនខ្លួនឯងផង អ្នកជិតផងទៅវិញ ព្រោះប្រព្រឹត្តទៅក្នុង អំណាចនៃមិច្ឆាវិតក្កៈ ៣ គឺ

១- កាមវិតក្កៈ សេចក្តីត្រិះរិះទៅតាមអារម្មណ៍ជាត្រូវចំណង់ ។

២- ព្យាបាទវិតក្កៈ សេចក្តីត្រិះរិះ ក្នុងការបំផ្លាញ ។

៣. វិហឹសាវិតក្កៈ សេចក្តីត្រិះរិះ ក្នុងការបៀតបៀន ។

ព្រោះដំណើរនេះលោកធ៌មគ្មាយទៅជា ក្តៅធ, ខឹក, ឲ្យល់, ឆេះប្រល័យ រំលាយកំចាត់កំចាយខ្លួនឯង ក្នុងកាលណាមួយដោយពិត ។

កិច្ចត្រូវការមួយ ដែលមានប្រចាំលោកគឺ

ជាតិ ការកើតនៃខន្ធក្នុងសត្តនិកាយនោះៗ,

ជរា ការទ្រុឌទ្រោមនៃខន្ធ,

ឈ្មោះ ការឈឺចាប់នៃខន្ធ ,

មរណៈ ការបែកធ្លាយនៃខន្ធ ។

ជាប្រភពនៃកិច្ចត្រូវការឯទៀត ។ ដែលជាដំនួយ ជាឧបករណ៍ ។ ពាក្យនេះបានជាថា កិច្ចត្រូវការ ព្រោះជាធុរៈរវល់បណ្តាចំរបស់លោក ដែលត្រូវការគេឲ្យជួយយ៉ាងបន្ទាន់ ។ ។ កិច្ចត្រូវការនេះជាហេតុនាំឲ្យព្រះពុទ្ធត្រាស់ឡើងក្នុងលោក ក្នុងអំណាចនៃសម្មាវិតក្កៈ ៣ គឺ

๑- នេក្ខម្មវិតក្កៈ សេចក្តីត្រិះរិះក្នុងការចេញចាកកាម,

๒ អព្យាបាទវិតក្កៈ សេចក្តីត្រិះរិះក្នុងការមិនបំផ្ងិចបំផ្ងាញ,

๓- អវិហឹសាវិតក្កៈ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ។

ព្រោះដំណើរនេះ លោកនឹងប្រព្រឹត្តទៅ ឥតក្តៅក្រហាយ សុខសួបំសាន្តត្រាណ ។

ព្រះពុទ្ធកាលទ្រង់ត្រាស់ទៅនឹងក្នុងលោក, ទ្រង់សម្រេចកិច្ចត្រូវការនោះដោយព្រះអង្គឯងស្រេច ទើបទ្រង់ដួយពួកសត្វឲ្យសម្រេចផង ដោយមធ្យមមាគ្គដែលប្រព្រឹត្តទៅ ឥតឲ្យក្តៅក្រហាយ ឥតបំផ្ងិចបំផ្ងាញ ឥតបៀតបៀន ឥតឲ្យកើតទុក្ខទោមនស្ស សោកសៅ, មិនចាំបាច់ប្រើអាវុធ សស្ត្រា-ដំបង: មិនចាំបាច់ចាប់ចង, មិនចាំបាច់ធ្វើកម្មករណៈ (ពិធីធ្វើទោសដល់អ្នកមានទោស) ។

ព្រះពុទ្ធ ទ្រង់តែងតែគិតឲ្យសត្វមើលមុខគ្នាត្រង់ ដោយព្រហ្មវិហារធម៌ ដួនទ្រង់ទតឃើញពួកសត្វឋិតនៅក្នុងមនុស្សធម៌ហួសហេតុពេក ទ្រង់ត្រិះរិះនឹងជួយសត្វ ដោយការគ្រប់គ្រងដោយធម៌ ដោយមហាករុណា ដើម្បីជួយសត្វដែលមានកិច្ចត្រូវការឲ្យបានសុខ ព្រោះព្រះអង្គជាអ្នកជួយសត្វ ។

ព្រះពុទ្ធកាសិតមួយឃ្លាទៀតថា ក្នុងធម្មបទនាគវគ្គ ដែលព្រះអង្គសំដែងបញ្ជាក់ខ្លួនវិការុញ្ញភាពដ៏ខ្ពស់ឈរបស់ព្រះអង្គ ក្នុងការជួយលោកដោយត្រង់ ។ ដែលមានអត្ថន័យ សំដែងអំពីកិច្ចត្រូវការនឹងអ្នកជួយឲ្យបានស្រួលក្នុងកិច្ចនោះគឺ

អត្ថម្ហិ ជាតម្ហិ សុខា សហាយា

កាលមានកិច្ចត្រូវការ សំឡាញ់ក្លាជួយឲ្យសុខ ។

ពាក្យថា អត្ថ ប្រែថា "ផល, ប្រយោជន៍, សេចក្តីត្រូវការ; សេចក្តីនៃសព្ទ, សេចក្តី, សេចក្តីអធិប្បាយ; សេចក្តីចំរើន, វត្ថុ, រឿងរ៉ាវ ទ្រព្យសម្បត្តិ, ប្រយោជន៍កំរៃ, ទំសាងលិច (អស្តង្គត) កិច្ចត្រូវការ, ធុរៈ, វេល់, ហេតុការណ៍, ហេតុ, ដំណើរ, សេចក្តីនាំស, អស់, រឿងហេតុ, ក្តី," ។ ក្នុងទីនេះ អត្ថ សំដៅយក កិច្ចត្រូវការ ជាដើម ។

ពាក្យថា សហាយ បានសេចក្តីថា សំឡាញ់, គូកន, គ្នាគ្នា, មិត្ត, អ្នកប្រព្រឹត្តទៅជាមួយគ្នា, អ្នករួមសុខទុក្ខជាមួយគ្នា, អ្នកជួយគ្នា ។

វិញទៅមក, អ្នកទៅជាមួយគ្នា, អ្នកមានធន:ត្រូវគ្នា, អ្នកមានចិត្តស្មើគ្នា អ្នកអត់កំហុសគួច-ដំទៅវិញទៅមក ។

សំឡាញ់ចែកតាមកេទមានពីរគឺ សំឡាញ់ជាគ្រហស្ថ ១, សំឡាញ់ជាបព្វជិត ១ ។ ចែកតាមសំមួន្នភាពមានពីរគឺ ទិដ្ឋបុព្វសហាយ:សំឡាញ់ធ្លាប់ឃើញគ្នា ១, អទិដ្ឋបុព្វសហាយ: សំឡាញ់មិនធ្លាប់បានឃើញគ្នា ១។ (សូមមើលសិគាលសុត្ត) ។

អត្ថ: ដែលសំដៅយក "កិច្ចត្រូវការ" ជាដើម ក្នុងទីនេះ ព្រោះកើតមានឡើង ត្រូវការរកមិត្តសំឡាញ់អ្នកជនឲ្យជួយធ្វើ ជួយសំរេច ជួយរម្ងាប់ ជួយការពារ ទើបសម្រេចបាន ។ អ្នកដែលជួយខ្នះខ្នែងយកចិត្តទុកដាក់ក្នុងកិច្ចនោះ ។ ពាល់តែបានការ ឈ្មោះថា សំឡាញ់ជួយឲ្យបានសុខ ។

កិច្ចត្រូវការមានច្រើន បំប្រួញតាមកេទបុគ្គលទៅត្រឹម ២ យ៉ាង គឺ

១- កិច្ចាំនោ អត្ថោ កិច្ចត្រូវការ សម្រាប់គ្រហស្ថ,

២- បព្វជិតស អត្ថោ កិច្ចត្រូវការ សម្រាប់បព្វជិត ។

កិច្ចត្រូវការសម្រាប់គ្រហស្ថ:

គ្រហស្ថគឺអ្នកគ្រប់គ្រងផ្ទះ មានបុត្តភរិយា ធនធានជាកម្មសិទ្ធិរបស់ខ្លួន ។ កិច្ចត្រូវការសម្រាប់គ្រហស្ថ មានច្រើនដំពូក រួបរួមទៅត្រឹម៣ យ៉ាង គឺ

๑- កិច្ចត្រូវការដែលត្រូវសំរេច ចានដល់តំសិតម្ន, ពាណិជ្ជកម្ម ការសង់គេហស្ថាន, អាពាហ៍ពិពាហ៍, ការធ្វើដំណើរទៅ, ការរៀនសូត្រ, កិច្ច បំបួស, កិច្ចបំពេញកុសល; វិជ្ជាដ៏វែកម្ន ។

๒- រឿងហេតុដែលត្រូវការពារ ចានដល់ការរំលោភ, ការដេះដាន់ ការមើលងាយ, ការបំបាក, ការដកហូតយកទ្រព្យសម្បត្តិ ស្រែចំការ ប្រពន្ធកូន ពាហនៈ ស្រុកប្រទេស អំណាច យសសក្តិ ឋានន្តរ, ការ បៀតបៀន ធ្វើទុក្ខបុកម្នេញ, ការចោទប្រកាន់, ការពោលបង្កាច់, ការ ចាប់កំហុស ដែលមិនមាន មិនពិត អំពីសំណាក់នៃពួកអ្នដែលមាន កំលាំង; ការសាបសូន្យអន្តរាយគោគទ្រព្យ ព្រោះទឹកលិច, ភ្លើងឆេះ, ចោរប្លន់, ពួកជនមានអំណាច, ពួកជនសំអប់, វេយ្យាវច្ចក្រឡាប់ជាដើម; ការស្វាប់នៃសកូនប្រពន្ធញាតិជាទីពឹង ព្រោះព្យាយាមនៃសត្រូវគុំគួន បងពៀរព្យាបាទ, ព្រោះអន្តរាយតាមផ្លូវទឹក-គោក អាកាស, ព្រោះរោគា- ពាធ, ព្រោះមនុស្សបៀតបៀន, ព្រោះទុក្ខអត់ឃ្យាយ, ព្រោះចម្បាំង ។

๓- កិច្ចត្រូវការដែលត្រូវសាង ចានដល់ការសង់សាលារៀន វិទ្យា- ល័យ អនុវិទ្យាល័យ មហាវិទ្យាល័យ, ការសង់មន្ទីរពេទ្យ, ការស្ថាបនា រោងការងារ, ការសង់ទប់ករណ៍ការពារនគរ, ការសាងក្រុង, ការសង់ ផ្សារ, ការដីកស្រែ-អណ្តូង ការលើកថ្នល់-ទំនប់ទឹក, ការសង់ស្ពាន, ការសង់កំពង់ដំនូញជារដើម ។

កិច្ចត្រូវការសម្រាប់បព្វជិត:

បព្វជិត គឺបុគ្គលដែលលះចង់នូវហ៊ានកេទនូវកង្វល់ក្នុងផ្ទះចាំងអស់ចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនា ដែលឥតកង្វល់ក្នុងផ្ទះ ទ្រទ្រង់នូវទត្តមកេវ ។ លោកមានអាជីវៈប្លែកអំពីគ្រហស្ថ តែបដិពទ្ធនឹងគ្រហស្ថដោយបច្ចយ ៤ ។ លោកមានការណីយកិច្ចចាត់ចងតាមគន្ធនៃធម្មវិន័យចាំងអស់ ។ លោកមានកិច្ចត្រូវការប្រព្រឹត្តទៅតាមធម្មវិន័យដែរ។ កិច្ចត្រូវការសម្រាប់បព្វជិត បំប្រួញមកត្រឹម ៣ យ៉ាងគឺ

១- កិច្ចត្រូវការដែលត្រូវសំរេច ចានដល់ការធ្វើចីវរ, ការកសាងសេនាសនៈ កុដិ សាលាឧបោសថាគារ, ការកសាងបរិយត្តិសាលា, ការកសាងមន្ទីរសមណវិបស្សនា ទីចង្រ្កម, ការរុះរើធ្វើជាថ្មី. ការជួសជុលនូវសេនាសនៈ ដែលចាស់ខ្ទេចខ្ទ្រោម, ការធ្វើសង្ឃកម្មណីយកិច្ច ដែលជាកិច្ចមានពុំបាន ។

២- រឿងហេតុដែលត្រូវសម្លាប់ ចានដល់អធិករណ៍; ជំលោះវិបត្តិ, ចំរើនចាស្ទក្នុងធម្មវិន័យ, សេចក្តីអផ្សុកចំពោះព្រហ្មចរិយៈ, សេចក្តីសង្ស័យការចោទរំលំ, ការកំចាត់គុណ. ការវង្វេងសតិ, អន្តរាយដល់ជីវិត,អន្តរាយដល់ព្រហ្មចរិយធម៌ ព្រោះសត្រូវសេក្ខសាហាវ, ស្ត្រី; ពេគាពាធ ។

៣- កិច្ចត្រូវការដែលត្រូវបំពេញ ចានដល់ការបំពេញនូវធុរៈពីរ

ក្នុងសាសនាគឺតន្ត្រធុរៈ ចាន់ដល់ការរៀនព្រះបរិយត្តិធម៌ ដែលត្រូវការដោយបច្ច័យ, សិក្ខាបករណ៍, ទីអាស្រ័យនៅ, សាលារៀន, អាចារ្យបង្រៀន, ក្សួនច្បាប់វិបស្សនាធុរៈ ចាន់ដល់ការលើកចិត្តតាន់វិបស្សនាបញ្ញា តាមត្រៃលក្ខណ៍ដោយធ្វើអាសវៈឲ្យអស់ជាទីបំផុត ដែលត្រូវការដោយអាចារ្យអ្នកប្រាប់កម្មដ្ឋានគួរហាណាវិធី ដោយសប្បាយ ។

តិចត្រូវការតាំងពីរតេនេះ, កាលបើគឺតមានហើយ, តែងតែត្រូវការរកអ្នកដទៃឲ្យជួយធ្វើជួយសំរេច, ជួយការពារ, ជួយជោះស្រាយ, ជួយអះអាង, ជួយធនធាន, ជួយកំលាំង, ជួយគិត, ជួយបន្ទំស្រាល ជួយបំពេញ, ជួយសាង, ជួយបង្កើត, ជួយរម្ងាប់ ។

មិត្តសំឡាញ់តាំងពីរតេនគឺគ្រហស្ថនឹងបព្វជិត គប្បីជួយអ្នកមានតិចត្រូវការ ដោយដំនួយ ២ យ៉ាងគឺ

១ ការជួយដោយអាមិសៈ ចាន់ដល់សំលៀកបំពាក់ មាសប្រាក់ ភោជនៈ ស្រូវអង្ករ, ទព្វសម្ភារៈ សម្រាប់សំណង់, សម្រាប់ការពារ, សម្រាប់សិក្សា អនាម័យ, បច្ចយ ៤ ។

២- ការជួយដោយធម៌ ចាន់ដល់ការជួយដោយចំណេះ គំនិតបញ្ញាជោះស្រាយការពារ រម្ងាប់តាមផ្លូវច្បាប់ ផ្លូវវិន័យ, ការជួយពន្យល់សេចក្តី, ការជួយឲ្យដំណើរ, សំដែងធម៌បន្ទោបង់នូវសេចក្តីទុក្ខព្រួយ ។

មិត្តសំឡាញ់ ដែលបានជួយញុំាងកិច្ចនោះ ។ ឲ្យសំរេច ឲ្យស្រួលសម្រាប់ឲ្យតើតទៀង ដោយដំនួយទាំងពីរនេះ ឈ្មោះថា ញុំាងសុខចំរើនឲ្យតើតមានដល់អ្នកដែលមានកិច្ចត្រូវការ ដោយពិតប្រាកដ ។

លោកតែងតែត្រូវការដោយដំនួយទាំងពីរនេះជានិច្ច តាមមាគ៌ានៃសប្បុរិសធម៌ ។ ក្នុងរឿងជួយនេះ, ព្រះសម្ពុទ្ធទ្រង់ជាអ្នកជួយលោកតាមពុទ្ធធម៌ដ៏បរិសុទ្ធ បំផុតឥតលុះអគតិ ឥតសំឡឹងកំរៃ ឥតបន្ទុំអ្វីទេ តែទ្រង់មិនជានាអះអាងថា " ព្រះអង្គជួយខ្លួលយកបាបអំពីលោក " ទេ ព្រោះបាបជាអំពើលាមក ដែលព្រះអង្គឯងលះបង់អស់ហើយ ថែមទាំងហ្វាប់មិនឲ្យធ្វើ ប្រព្រឹត្ត គិតទៀតផង ។

សម្រាប់បព្វជិត ដែលទៅជាតព្រះអង្គជាធំបរិស័ទឯទៀត, ព្រះអង្គទ្រង់ជាក់ត្រាំរ៉ៃយឲ្យតឹងរឹងបរិសុទ្ធផ្លូវផងនឹងជាធំគេដែរ ហើយទ្រង់ជួយស្រោចស្រង់ច្រើនជាងគេបន្តិច ព្រោះថា បរិស័ទឆ្ងាយអាចដំនួសព្រះអង្គបាន ក្នុងកិច្ចប្រកាសសាសនា ។ ទ្រង់ជួយឲ្យប្រព្រឹត្តធម្មវិន័យ, ជួយដោយបច្ច័យ ៤ ដោយពាក្យចាលគិលានភិក្ខុ ដូចគិលានុបដ្ឋាកដែរ ។

គិលានភិក្ខុ និង គិលានុបដ្ឋាកភិក្ខុ :

បណ្តាកិច្ចត្រូវការទាំងអស់ ដែលតែងតែមានដល់បុគ្គលពួកៅ ហើយគេចមិនរួចគឺពេត ។ ពេតជាសភាវៈតើតក្នុងកាយ, មិនជាទីប្រាថ្នា. មិនជាទីត្រូវការ, មិនជាទីពេញចិត្តនៃមនុស្ស ហើយដែលមនុស្ស

ត្រូវតែការពារជានិច្ច មានចាំដ៏ក្រសួងសាធារណសុខាភិបាល សម្រាប់ចាត់ចែងការពារផង, តែមនុស្សតែងតែឃាននូវរោគនោះ ព្រោះរបស់សំបុកនៃរោគចាំដ៏អស់ ។

រោគមានច្រើនប្រការ, មានសម្គាល់ផ្សេង ។ គ្នា, ខ្លះបណ្តាលអំពីអាហារមិនគ្រប់គ្រាន់_មិនរលួយ, ខ្លះអំពីឥរិយាបថ, ខ្លះអំពីរដូវ, ខ្លះអំពីទីប្រជុំ, ខ្លះអំពីព្យាយាម, ខ្លះអំពីកំដៅ, ខ្លះអំពីបរិភោគហួសប្រមាណ, មិនដឹងប្រមាណ ខ្លះបណ្តាលអំពីកម្មវិបាក ។ រោគដែលបណ្តាលអំពីកម្មវិបាកនេះ ជារោគដែលវេជ្ជបណ្ឌិតមិនអាចព្យាបាលបានព្រោះថា រោគកើតអំពីផលរបស់អកុសលកម្ម ដែលខ្លួនអ្នកឈឺធ្វើអំពីបុព្វជាតិ ។

រោគជាអាការៈចាក់ដោត ធ្វើឲ្យកើតទុក្ខវេទនា តួសរីរកាយគ្រប់ឥរិយាបថ ។ រោគជាសត្រូវដិតរបស់កាយ, ធ្វើឲ្យតំលាំងកាយ បញ្ញាខ្សោយ, សៅសម្បុរ, ស្តាំងស្តម, ខូចព្យាយាម, អាយុខ្លី, វ័យចាស់ជាជិតទៅគាន់ទីជិតនៃមរណៈ ។ រោគជាទុបសគ្គធំបំផុតរបស់មនុស្សស្តុកដំណើរ, បង្ខាតលាភ, បង្កិនសម្បត្តិដែលមាន នឹងដែលមិនទាន់មាន, មិនឲ្យបានទូរវិជ្ជា, យសសក្តិ, សុខចំរើន សប្បាយរីករាយតាមអារម្មណ៍របស់លោក នឹងអារម្មណ៍របស់ធម៌ ។

បព្វជិតជាអ្នកព្យាបាលរោគខាងផ្លូវចិត្តគឺ កិលេសតាមធម្មវិន័យ កំពុងតែមានហើយ ប៉ុន្តែថា លោកត្រូវព្យាបាលរោគខាងកាយដែរ ។ ដូច្នេះដើម្បីសួលដល់ព្រហ្មចរិយៈ, បព្វជិត ត្រូវការកេសជ្ជៈ ឧស្ថ, អ្នកព្យាបាល, គិលានសាលាដែរ, តែសេចក្តីត្រូវការនេះ បដិពន្ធនឹងអ្នកផ្តត់ផ្តង់ ។

ព្រះសម្ពុទ្ធ ទ្រង់ដួយកក្តួលមុនគេ ។ ព្រះអង្គទ្រង់ដូចជាវេជ្ជបណ្ឌិតមួយរូបខាងផ្លូវចិត្ត ទ្រង់ពិសោធរោគគឺកិលេសដោយញាណ កាត់វះដោយបញ្ញាជាក់ជម្ងឺឧស្ថ តម្រូវតាមចរិតអធ្យាស្រ័យនិស្ស័យអាការៈរបស់សត្វឲ្យជាសះស្បើយ ផ្តោះកន្ទួតពពួកទៅកាន់ទីឥតរោគគឺនិព្វាន ។ ព្រះអង្គមិនមែនទ្រង់តែតែរោគខាងផ្លូវចិត្តទេ ទ្រង់តែខាងផ្លូវកាយណាស់ដែរ ព្រោះកាយជាគ្រោងរបស់ចិត្ត ជាគុហារបស់ចិត្ត ។ ព្រោះហេតុនេះព្រះអង្គទ្រង់អនុញ្ញាតឲ្យមានកេសជ្ជៈ, ឲ្យមានគិលានសាលា, ឲ្យមានអ្នកព្យាបាលរោគ ។ កេសជ្ជភ្នួកៈចែងថា ពួកភិក្ខុ, កាលដែលព្រះអង្គមិនទាន់អនុញ្ញាតកេសជ្ជៈ, តើតរោគរបងសម ព្រោះអាហារមិនត្រប់គ្រាន់ ព្រោះទុរុបច្ចយទី ៤ នោះ. អង្គុះផ្ទាប់ជាសុខុមាលជាតិ ធន់មិនបាន កំលាំងកាយក៏មាន, អង្គុះខុនខុកស្ងោរទ្រទ្រង់អាត្មាមិនបានក៏មាន; អង្គុះសុគតក៏មាន ។

(មានត)

ផ្នែកអក្សរសាស្ត្រ

រឿងនេវន្ត (ភាគភាគ)

(តចប់)

លោក អម្ពុតក្សត្រីម៉ុក រៀបរៀង ក្នុងរាជ្យព្រះពុទ្ធាព្រះជាទេសម្តេចព្រះនរោត្តម
លោក ញ៉ុក-ថែម ពិនិត្យ

កុដន្តស្តាប់ហើយ ឆ្លើយថាសូនអើយ អាពុកដឹពិត គឺមោះតែថា
បិតាគន់គិត ដឹតអ្នកក្មេងក្តិត ពុំធ្លាប់ធ្វើការ ។
កុមារបង្គំ ទូលថាស្តេចកុំ ព្រួយព្រះចិត្តា បំណាច់ព្រះអង្គ
ស្តេចទ្រង់មេត្តា ដូចរាជបុត្រា បង្កើតពីប្រាណ ។ រឯយក្ខនោះ
លើកមកពីព្រោះ តែខ្ញុំមកបាន ជាព្រះសុណិសា ព្រះមហាក្សត្រក្សាន្ត
មួយសោតស្តេចមាន ព្រះគុណធ្ងន់ក្រៃ ។ រាជបុត្រទង់វង រមែងតែង-
ស្នង ព្រះបិតាថ្កៅ ដំណើរពូជពង្ស មានសង្រ្គាមជ័យ តែងនឹងស្នងដៃ
ព្រះវរបិតា ។ ពុំគួរនឹងនៅ ឲ្យព្រះអង្គខ្ចៅ ចំរ៉ាងឯងច្នេះណា បើ
គ្មានខុរស ប្រាណប្រាសមិនថា ស្មុមមហាក្សត្រា ចរចេញរាជ ។
យក្ខស្តាប់បុត្រា ត្រេកត្រង់គិតថា អះកូនចាំងពីរ នេះមិញ-
ហាវហាន សមមានវិជ្ជី ដើមតែកើ ពុំព្រួញរួញរា ។ គិតហើយ
ថើបសិរ រាជបុត្រទាំងពីរ ត្រេកអរមហិមា បញ្ជូនលើយាន សូរកាន

យាត្រា ពាហានយកក្បា ហៅៗភ្ញាន់ភ្ញាប់ ។ ស្តេចទុកឲ្យនៅ លើ-
បង្គុយក្រៅ ស្តេចចេញតទ័ព តទល់ស្រែវាលស្រែក សម្រែកសន្ធាប់
រត្រែតំបូលពាប់ ពៅមកកាន់គ្នា ។

* ព្រះចុងកុដន្ត ព្រះចុងសច្ចកំណ្ឌ ពះកាយន្ទវាលា ជាល់-
តប់ខេត្តក ពៅមកគន់ការ ជាល់ដំហគ្នា រោកត់ពាយ ។ ពានក្តំល្អិតក្តំ
សិលាគូចធំ របើកភ្នាត់ភ្នាយ ឈើព្រៃជុលជាប់ ខ្លឹខ្លេចពាត់ពាយ
សន្ធឹកពាសភ្នាយ ពាល់សួគ៌មណ្ឌល ។ កក្រើកចត្រាវ៉ា ដោយតេជពល
ពោល រីពលន្ទវាល យកក្ងយដំបូលយុទ្ធ ប្រយុទ្ធតទល់ តតាំងតំហល់
តំហែងហ៊ាសហារ ។ ប្រដេញប្រដំ ជាញដែងដ៍ជយទំ ប្រកាប់ប្រការ
ស្មើចិត្តស្មើដៃ ស្មើដ៍យចេស្តា ស្មើអង្គស្មើអា _ នុភាពសឹងស្មើ ។

សមុទ្រសាគរ ពៅសហស្សសរ ពីរពង្សតែងលើ បន្ទាយយង់
យល់ ពួកពល់សឹងស្មើ បិតាប្រសើរ សឹងស្មើចេស្តា ។ សមុទ្រ
សាគរ ស្តែងស្តេចថ្លែងសរ ត្រូវត្រែងទក សច្ចកំណ្ឌក្សិណត្ថ័យ ប្រល័-
យជន្មា សហស្សសរកុមារ ថ្លែងសរពៀតៗ ។ ក្មួយជាខាតា
ច្រើនពៃក្រមហ៊ាមា ចងយក្ងយោរយៅ រនាបវនៃល រវែលនិត្យនៅ ក្អែក
សក្អែកឡៅ កិតក៍យតក្តមា ។ ពាំងសច្ចកំណ្ឌបុត្រ កិតក៍យរន្ធត់ ពាំង
ពួកយោធ ថ្វាត់ថ្វាយបង្គំ សូមសុំពោសា សុំដីពជន្មា សុំជាខ្ញុំនៅ ។

កុដន្តយក្ខយល់ ទ្រង់ត្រែកអរសល់ ទុបបុត្រចមរៅ ថើបថៃពាង៥ នាំ
បរិពារៅ កាន់ទីលំនៅ ប្រាសាទរចនា ។ មាត្យមុខមត្រី យក្ស-
យក្សី សឹង៥សោមនស្យា ចំរើនវុឌ្ឍីពរ វិទ្ធីវរិន្ទការ វុឌ្ឍីជន្មា សរសើរ
ជារមឺ ។ ក្យាណយក្ខវិសុទ្ធ អភិសេកសមុទ្រ សាគរធិបតី នូវអសុ-
រិន្ទ្រា ជាតិជាមហេសី ឲ្យត្រង៥បុរី នាថ្ងៃនោះឯង ។ រីពលយក្ខយុទ្ធ
នូវសច្ចតិណ្ឌបុត្រ ស្តែង៥ស្តេចឲ្យលែង ឲ្យនាំសពៅ លំនៅតាតតែង
ព្រះមេរុជាតិចែង លើកសពសង្ការ ។

តាំង៥ពីកាលណោះ បុរីរដ្ឋនោះ តែង៥នាំសួយសារ មកថ្វាយ-
កុដន្ត ខែត្រខណ្ឌសីមា សព្វៗឆ្នាំជា សណ្តាប់ពាក្យនៅ ។ សមុទ្រ
សាគរ នូវអង្គសហស្សសរ ស្តែង៥ស្តេចនិត្យនៅ ក្សេមក្សាន្តជាសុខ
ឥតទុក្ខហ្នង៥សៅ យប់មួយនោះចៅ សហស្សសរកុមារ ។ ក្អកនឹក
ដល់ស្រុក ជននីជនក លុះព្រាង៥សុរិយា ហោង៥ព្រះចាទៅ លំនៅ
ដេដ្ឋា ដល់ហើយវន្ទា ទៀង៥ទូលអភិប្រាយ ។

បពិត្រយើង៥យា -ត្រាចោលបិតា មាតាឯនាយ ម្ល៉ះសមជា-
ទុក្ខ ពុំសុខសប្បាយ គិតយើង៥នៅអាយ បិតបាត់យូរលង់ ។ គិត
គួរនានាំ ភ្នាក់ទៅបង្គំ ក្សត្រតាំង៥ពីពេញ្ញ ស្តេចស្តាប់អនុជា ក្សត្រា
វរវង្ស គេញត្រេះ៥យទ្រង់ នាំអនុជទៅ ។ ដល់ហើយថ្វាត់ថ្វាយ

បត់បង្គិចតាយ យក្ខយន៍ចមរៅ ខ្ញុលថាយើនខ្ញុំ សូមសុំលាទៅ ទៅ
ហានលំទៅ មាតាបិតា ។ ដ្បិតយើនពីរពន្យ មកចោលព្រះអង្គ
ជាយូរមហិមា ម្ល៉ះស្តេចសមនឹន ខ្ញុំនឹមាតិ ជាទុក្ខភ្នែចផ្សា ។ព
ហ្មិនសៅ ។

យក្ខស្តាប់ឆ្លើយថា បើកូនស្ងួនក្ងា ខំនឹវិលលំទៅ អាពុក
ត្រែតអរ ចង់ចរដួនទៅ ចង់ស្គាល់លំទៅ មាតាបិតា ។ យើនទៅ
ព្រមអ្នក ត្រាស់ហើយក្រុងយក្ខ ឲ្យរៀបសេនា-
មាត្យមុខមន្ត្រី សេនីយោធា តដរថអស្សាហ៍ ខំតរខំតាយ ។ សឹនឲ្យប្រែអង្គ
ជាទៅបុត្រ ទ្រង់នូវគ្រឿនធើតធាយ កាន់ខន់កាន់ធ័ត្រ តែវត្តរៀនពាយ
ដូចទេពសួគ៌នាយ ចុះចាកសួគ៌ ។ ក៏ប្រាក់ក៏មាស ក៏តែវធ្លុះធ្មាស
ត្រៀបដោយហត្ថា បានបួកដ្បៅកដាក់ ស្តេចយក្ខយាត្រា. បុត្រប៊ី-
អង្គា សឹនឡើតនឹយាន ។ គោះតនឹវាយស្គរ លើតពលចេរចរ
ចេញចាកពាជធ្លាន ហេតុដោយពលា យក្ខាហ៊ោហាន តែថ្ងៃ ៣ ចាន
ដល់ដែនកោសេយ្យ ។

ទើបពីរកុមារ ឲ្យដ្ឋើរដសារ ចូលទៅក្រុងត្រៃ ទូលព្រះបិតា
មាតាថ្ងៃថ្ងៃ ដោយនូវសម័យ សារសព្ទទៅថា សមុទ្រសាគរ អញ
ទៀថ្ងាយវែ មាតាបិតា ដ្បិតកាលអញទៀ បង្គំគ្រាបលា នាំព្រះអនុ-

ជា ទៅរៀនសិល្បៈសេយ្យ ។ រំលងវិញមកបាន ជាយោរួមហាន បាន ជាយូរក្រៃ ឥឡូវនាំនាង នូវអនុជប្ញៃ ត្រឡប់រំលងវៃ មកថ្វាយបង្គំ ពាំងកុដន្តយក្ស រើរឿងខ្លីៗក្តី ជាបាក្មេកខ្ញុំ ចង់ស្គាល់ព្រះមហា ក្សត្រាទត្តម មកមួយនឹងខ្ញុំ សូមជ្រាបសេចក្តី ។

ព្រះបាទខេរុន្ធ សម្តេចសុរិណ្ណ កេសរក្សត្រី បានទ្រង់សណ្តាប់ សារសព្ទសេចក្តី ព្រះអរឥតបី ថ្លែងថ្លឹងទបមា ។ ប្រើទូតរំងាត់ អញ្ជើញយក្ខក្សត្រ បុត្របីអង្គា ចូលរំលងចូល ទៀងចូលយក្សា នូវព្រះបុត្រា ពាំងពីរព្រះអង្គ ត្រាយទូតរំលៅ ទៅទូចមរចៅ ស្តែងស្តេចឲ្យសង់ កោងពាដសេនា យោធាពលពង្ស រួចរៀបចំរុង ពលពាលបុត្រា ។

កុមារវរិល្ខណ៍ នូវអង្គស្តេចយក្ខ លើកពលយោធា ចូលក្នុងបុរី ប្រុសស្រីនានា យល់យក្ខស្រឹង្គារ នូវយក្ខសេនី ។ ស្មានជាទេវតា នូវទេពកញ្ញា ដង្កែគោសីយ៍ ចុះចាកពិមាន ទិព្វហានសួគស្រី ពុំដឹងសេចក្តី ជាតិជាយក្ស ។ លុះដឹងស្គាល់ជាក់ ជាម្ចាស់ទើបភ្លាក់ បង្គំពាល់គ្នា សារសើរធោឡា ទុម្ខស់ថ្លៃថ្លា បានសឹងទេវតា ដង្កែឲ្យលង្ហៅ ។ ស្តែងស្តេចដល់ទ្វារ បញ្ជាប់បរិពារ សេនានិត្យនៅ ព្រមស្តុបរិស័ទ បួនកំសត្រចូលទៅ ដល់ពោងរត្ន-

ផ្ទៅ ខេរន្ទក្សត្រា ។ បុះមកដឹកដៃ យកទូឲ្យគង់ឮ ឃើញឆ្លាចមាន
ពាំនពីព្រះអង្គ ស្តេចទ្រង់រន្ធា ទៅមកគាន់គ្នា ស្មោះសរត្រេកត្រង់
បីបុត្រទត្តម ថ្លាត់ថ្លាយបង្គំ ក្សត្រពាំនពីរពង្ស សុវណ្ណកេសរ ត្រេក
អរទុបអង្គ អសុរន្ទ្រទ្រង់ សាគសួរប្រស្រ័យ ។ ទៃហ្ន៎នស្នេហា
អ្នកមកបានគ្នា សំគ្តិសមប្រពៃ ម្តាយអរឥតឯ ជ្រួមផ្ទេរទបមេយ្យ
ដូចអ្នកមាសថ្លៃ ចេញចាកទុពក ។ ចូរស្ងួនធោមធាយ អ្នកទុកខ្ញុំន
ម្តាយ ជាតិជាមាតា ម្តាយនឹងទុកកូន ខ្ញុំមខ្ញុនថ្លៃថ្លា បទដ្ឋិត-
មាតា មិនមានបុត្រី ។

ក្សត្រគ្រប់ព្រះអង្គ សំណេះត្រេកទ្រង់ ស្មោះសរប្រុមប្រុយ
សួរសព្វទុក្ខសោក នូវកេតព្យាធ៍ បុកណាបុរី បរមរង្គា ។ ច្រាប់
សព្វទៅមក សោតសឹងសាទរ ពោធីស្តេចថា មហាក្សត្រិសុខ
យកបុត្រប្រសា ទៅគ្រងភាព ប្តូមួយទុកនៅ ។ ស្តេចយកក្តួធ្លើយ
ស្នង បពិត្រច្បាស់ច្បង់ ខ្ញុំឥតក្ងួនទៅ ឯអង្គអញ្ជើ ចង់សុំយក
ទៅ ទុកអមុជនៅ នឹងក្សត្រទ្រង់ល័ក្ខណ៍ ។

ពោធីធ្លើយថា តាមព្រះចិត្តា ខ្ញុំអានឹងអ្នក មានចំត្តស្នេហា
បុត្រាខ្ញុំហាក់ បុត្រក្សត្រវរល័ក្ខណ៍ បង្កើតពីអង្គ ។ ស្រេចពោធី-
សត្វ រៀបប្រាសាទត្ន ថ្វាយស្តេចយកទុយង់ ស្តេចយកចមៅ តង់

នៅអម្ចង់ ខែបឹត្រះអង្គ លាក្ស័ត្រុបវរ ។ នាំបុត្រចាំងពីរ ទៅថ្កូនឆានី ដោយសុខសាទរ ក្រោយនោះសម្តេច សារពេជ្ជកូដរ អតិសេកស-ហស្សសារ ជាទេបពជ ។ តិតការស្នំស្នង ក្ស័ត្រថ្ងៃច្បាស់ច្បង រ័ករ៉ោស្ត្រ ប្រជា ជាសុខពេកពន់ កុដន្តភាក តែងនឹងនាំសារ ទៅមកពុំខាន ។

ចំណោរលុះលង់ តិចទៅត្រះពន្ធ្យ ពោធីស្តេចបាន បុត្រីឯក អង្គ រូបទ្រង់កល្យាណ នឹងនាងនោះមាន ព័ណ៌ពិតដូចមាស ។ រស្មីផ្សាយចេញ ពន្លាយដុំវិញ ភ្លឺផ្កេកផ្ទុំទ្វាស សោភាសោភ័ណ ខន់ភ្លឺល្អន់ល្អាស ដូចជាឆឹកាស សុវណ្ណរចនា ។ ហេតុព័ណ៌ ដូច្នោះ ពោធីឲ្យឈ្មោះ សុវណ្ណបុប្ផា អតីតេកាលៃ បុព្វហិសា សេដ្ឋីធីតា សីលសម្បទី ។ កាលដើមនាងកើត ឃោនយកតំណើត ជាកូនសេដ្ឋី តែងរក្សាសីល ពុំខ្វិលប្រក្រតី (បញ្ចអដ្ឋមី) អាចឲ្យឋ-វិសុទ្ធ ។ នាងយល់រូបឈើ មួយមិញគេធ្វើ ជារូបព្រះពុទ្ធ តែពុំ-ច្បានចំខ មាសពិតឈើសុទ្ធ អរទុនលំអុត លើកហត្ថវន្ទា ។ មានចិត្ត ថ្វាជ្រះ ហើយគិតសាងព្រះ ច្បានលាបលនជា ថ្នោងថ្លឹបខមាស ទុកាស ជ្រះថ្លា ធ្វើចាំងវិហារ បូជាធានធ្ងន ។ ដោយតេជផលសីល ល្អ ល្អះស្រស់ស្រៀល រស្មីផង ផ្ទុះផ្ទាសព្រោងព្រាយ ពីកាយឥតហ្មង ល្អ

ឥតមនុស្សផង នឹងប្រៀបផ្ទឹមស្មើ ។ ព្រោះដលបានបំពេ មាសព្រះពុទ្ធពិត
បិតាប្រសើរ នូវព្រះមាតា ប្រជាជនមើល សោតសឹងសរសើរ បុណ្យចា-
រមើតា ។ ក្សត្រចាំងពីរអង្គ ស្តេចនៅលន់លង់ តែចៅជាព បៀត
បំណាត្រូវ ស្តេចស្តូវតេសា រង្គើខ្លា នេត្រនោះស្រាំង ស្តែងស្តេច
ផ្លៀងផ្លែក តែតកើតសង្វែគ ខ្ទះខ្ទរបំ រួបអើយមិនទៀង (តែងល្ហែង
អនិច្ចំ) ទៀងតែមរណៈ នាំរួបទៅ ។ តែតហើយត្រាស់ថា ហៃ-
ប្អូនស្ងួនភ្ងា ខ្ញុំនបងនឹងចៅ ចាស់ជាហើយ ស្ងួនអើយនឹងនៅ
នៅនេះនឹកចៅ សូន្យសោះអសារ ។ បើបងនឹងស្លាប់ បានបួសគួរគាប់
ប្រសើរថ្លៃថ្លា បងសូមលាចៅ ទៅនៅហេមវ៉ា បួសសាងសីលជា
ឥសីសីលសេយ្យ ។ ថាបើចិត្តចៅ ចិត្តបងនឹងតាមទៅ នៅនេះមាសមែ
មាសមានចិន្តា ស្នេហាអាល័យ រាជបុត្រថ្នើមថ្លៃ ចូរនាងនៅហោង ។

នាងទូលវិងវៃថា បពិត្រក្សត្រា ខ្ញុំសូមទៅផង បំរើព្រះបាទ
នរនាថច្បាស់ច្បង សិរសោភប់រង ទទួលបាទ ។ ពីរពង្សទ្រង់គិត
ព្រើសត្រមចូលចិត្ត ប្រគល់រាជ្យរាជបុត្រាត្ន ហើយក្សត្រលាកល
រាជវង្សពង្សា សេនាមន្ត្រី ។ បុត្រីបុត្រា រាជវង្សពង្សា រាស្ត្រចាស
ប្រុសស្រី បុរោហិតព្រឹទ្ធ សេនាសេនី អាមាត្យមន្ត្រី ចតុរង្គរហ៍-
ពល ។ សឹងយំរត់តាម ទឹកភ្នែករហាម ជាទុក្ខសោកសល់ ស្តេ

ហាមប្រាមយាត់ ហើយក្សត្រនិមិល ពាំនពីរស្តេចដល់ ព្រៃព្រះហម-
ពាន្ត ។ បួសជាឥសី សាន៍សីលប្រក្រតី ជ្ញានបញ្ចកិញ្ញាណ អដ្ឋសមា
បត្តិយានូវឈាន អស់អាយុជាន ទៅហានព្រហ្ម ។ ក្សត្រីថ្លាថ្លៃ
សោយសោកអាល័យ ពោធីសត្តា លន់លុះពាល់ក្សីយ នៅព្រៃព្រឹក្ស
ទៅកើតសួគ៌ា ក្សេមក្សាន្តសុខសម ។

នេះនឹងថ្លែងទៅ បុត្រីវត្ថុនៅ បុរីវជ្ជមឃ្ស ជន្មដួបសោឡស
ស្រៀបស្រស់ស័ក្តិសម ស័ក្តិសួនទត្តម ដួចទេពកញ្ញា ។ រីរូបនាង
នោះ ក្តុលេចសាយសុះ សាយសព្វទិសា គ្រប់ក្សត្រនៅក្តុង ប្រ
ឡុងលោកា សោតសឹងស្នេហា ចូលចិត្តចង់ចាន ។ ស្តេចមួយរយម្លៃ-
មួយសឹងមានមៃ-ត្រីត្រួតពាហិន សេនាពលពង្ស ចតុរង្គគ្នាហាន មួយ
អង្គមែនមាន សែសិបអង្គា ។ លើកអស់ពលក្រៃ ចោមក្រងគោសេ-
យ្យ មាន:មានោ បីជាន់ដុំដិត សឹងចិត្តពាលោ តាំងំពតាំងហោ
ស្តីរវៃកពសុធា ។ លន់លុះយោមយប់ ហើយអុជគោមគុប កកាន
គ្រប់គ្នា ភ្លើងភ្លឺធុំធ្លាស អាកាសវៃហាស៍ ដាលដួចសុរិយា សែងសូ-
រ្យវង្សីយ៍ ស្តេចផងដួបគ្នា ហើយសួរគ្នាថា អ្នកលើកមកថ្មី ច្រាប់គ្នា
ចាមក ចាប់យកបុរី យើងនឹងខ្លាចអ្វី ឥតនឹងខ្លែង ។ ពីដើមមិនថា
ឱចមហាក្សត្រា ដ្បិតស្តេចមានបុណ្យ ឥឡូវក្សីណាក្សីយ ប្រល័យ

ជីពជន្ម យើនធ្វើឲ្យអ-ន្តរធានបុរី ។ អស់អង្គក្សត្រា ពុំច្រាបំគ្នាថា
ចង់បានក្សត្រី ច្រាបំប្រែជួញ្ចោះ ក្សត្រីណានោះសេនី សេនាមន្ត្រី ពាស្ត្រ
ក្នុងគន្លរ ។ យល់ពលពាសពេញ ចោមចាប់ជុំវិញ តតៃយវីកវរ រដោ
រដើប ខៀបខើបសហស្សសរ ស្តេចឲ្យពាយស្គរ ប្រែច្រាបំច្រាមថា ។
កុំភ័យកុំតិត កុំកោតកុំតិត កុំរួញកុំក កុំជោះកុំជាល កុំអាលកុំតា
សន្យឹមហៅគ្នា លេងក្តេងក្តាត់ផង ។ អ្នកខ្លះឲ្យនាំ គ្នាលេងឲ្យកំ
ជ្រួចប្រឿងអឺងកង ឲ្យពួកកំដរ ឮស័ព្ទសូរផង យើនលេងយើនលង
មើលគំនិតគេ ។ មនុស្សផងទីទៃ ស្តាប់ហើយកុំភ័យ កុំតិតសឹងតែ
លេងលែងតាំងឡាយ សប្បាយឥតឯ គន់គិតរិះរេ ខ្លាចសង្គ្រាមដ៏យ ។
អស់ស្តេចសាមល្អ ឮសូរស័ព្ទដល់ គន់គិតសង្ស័យ យើនចោមរាជ្យម្ស
ជិតដុំគ្រាស់ក្រៃ ម្តេចមិនមានភ័យ ប្រឹងលេងសប្បាយ ។ ខ្លះថាជួច
ត្រី នៅក្នុងស្រះស្រី ទូរហោនឆ្ងាយ ពុំដែលយល់មនុស្ស ចរចាប់ក-
កាយ ឆ្ងាប់នៅសប្បាយ ពុំជឹងខ្លួនស្លាប់ ។ ខ្លះថាជួចព្រាយ នៅស្ងៀ
ព្រៃឆ្ងាយ គេពុំដែលចាប់ យល់ព្រានដើរដេត ពុំគិតខ្លួនស្លាប់ ដើរបួល
ប្រញាប់ ពុំជឹងមរណា ។ ស្តេចខ្លះថាតេះ ក្រែងគេចែងចេះ ទុបាយ
ច្រាជ្រា ប៉ះញ្ជោតឲ្យជុង ឲ្យលង់អាត្មា គេបែបការឱ្យ ក្រឡាស់ឲ្យលំ
ច្រ ។ ទើបអាមាត្យឆ្លាក់ ថាបើចង់ជាក់ ចាំមញ្ជាឱ្យល ដោយកលគំ

ខ្ញុំគិតរំរក៌ សួរអ្នកនគរ ទើបដឹងសេចក្តី ។ ក៏ត្រង់គន់គិត
ព្រើសត្រមចូលចិត្ត ទៀងទើបមន្ត្រី កែងខ្លួនធ្វើហាក់ ដូចអ្នកបុរី
ចូលទៅស្រដី ឧដ្ឋអ្នកព្ធារថា ។ ឥឡូវនេះគេ លើកអស់ពលរេហ៌
មកចោមភាក ម្តេចម្ចាស់យើងពុំ ក្លួចភ្ញុំយោធា ចរចេញពំនក តាំង
ពីតន៌ព ។

ក៏ណោះនាយព្ធារ ស្មានគ្នាឯងគ្នា ថ្ងាថ្ងែងច្រាយច្រាប់ បាន
ជាព្រះអង្គ ពុំច្រង់បង្គាប់ ឲ្យរៀបកងទ័ព ទៅទប់តទល់ ។ ព្រោះ
ស្តេចគិតថា ម្ចៅ។ នាំគ្នា មកឲ្យវេល់ ឲ្យស្ងាប់អស់ពស្ត្រ ព្រាត់
ច្រាសមណ្ឌល ក៏តើតកង្វល់ អំពីខ្លួនឯង ។ ហើយស្តេចគិតថា អស់
រស្ត្រប្រជា មានផ្ទះសម្បែង មានកូនមានចៅ និត្យនៅនាយតែង គន់
គិតចម្បែង បិទបង់គ្នាវ ។ បន្តិចរត់ទៅ ចោលឯងឲ្យនៅ ច្បាំងនឹង
នរណា ពស្ត្ររត់ទៅតង់ តែអង្គអាត្មា ទំនើងក្បត្រា ឲ្យចាប់ចងវាយ ។
ស្តេចគិតព្នោះឯង ឲ្យច្រៀងលេងល្បែង មហោស្រពពាំងឡាយ មន្ត្រី
ស្តាប់ដាក់ ធ្វើហាក់រួសរាយ លីលាលាក់កាយ វិលវឹងទៅទ័ព ។

ខូលអស់ក្បត្រា ដូចពាក្យអ្នកព្ធារ និយាយច្រាយច្រាប់ គ្រប់
ប្រការគ្រប់ច្ង អស់ស្តេចផងស្តាប់ ក្រែវក្រោធបង្គាប់ អស់ពលផងគ្នា ។
ចូរចោមពង្រេច បន្ទាយឲ្យខ្ជួច ចូរចាប់យកវ៉ា ឲ្យបានពាំងរស់ ហើយ

អស់គ្នីគ្នា នាំមកប្រសាទ ឥឡូវនាប់ៗ ។ អស់អង្គមន្ត្រី សឹងជិះជាំរ
តឿនអស់ពលទ័ព លលាំលលោ តាំងរហែកុលាប់ ឮលាន់សន្ធាប់
សន្ធឹកមហិមា ។ ចូលចាក់ពង្រែប បន្ទាយមួយរំពេច ទើបអស់សេនា
ខាងឯសហស្សសារ ថ្វាយវែងគ្នា ក្រួញក្រាបទូលថា បពិត្រក្សត្រៃថ្ងៃ ។

ឥឡូវទំលាយ បន្ទាយក្រៅគ្នាយ ពស្ត្រផងតតស៊ាយ សូមទ្រង់
លើកពល ទៅទល់ជាញជ័យ កុមារថ្វាថ្ងៃ បន្ទូលឃាត់ថា ។ កុំគាល
លើកទៅ ចូរស្បើមឈប់នៅ បង្ហុំមើលក់ ក្បិណានោះពលពង្ស
អស់អង្គក្សត្រា ទំលាយសេមា ចាក់បានប៉ជាន់ ។ ក្បិណានោះសេនា
ខាងកដុមារ ហត្ថាតតាន់ គ្រប់គ្រឿងសហស្សសារ ប្រចាក់ណែនណាន់
ណែននៅតាប់តាន់ លើតាគបន្ទាយ ។ ចាក់ឡាប់ត្រួសក្តៅ ជះជាំរ
ចំទៅ ត្រូវដាំរខ្លាយ ពោះតំរូបខ្លាច ពុំគាចទំលាយ ជាន់មនុស្ស
ចាំងឡាយ វិនាសសូន្យស្មាប់ ។

ក្បិណានោះសហស្សសារ ឮស័ព្ទពីតារ ទ្រហឹងតឹងតាប់ ព្រះ
តចាប់ធ្នូ ព្រះកៅណ្ឌជាប់ ព្រះតាយប្រជាប់ គ្រប់គ្រឿងចេញចរ ។
បិតលើបន្ទាយ យល់ស្តេចចាំងឡាយ តឿនពលនិការ ឲ្យចូលទំលាយ
បន្ទាយភ្លូវ ស្តេចដំទៅឆ្ងែសារ ស័ក្តិសោតថ្វាថ្ងៃឆ ។ តើតជាសិង្ហសី

ហ៍ ជាខ្លាដំរី រមាសពស់ស្វែង ទាំចាក់ចង់ចឹក ពន្លឺតគួរស្រែង ពល
ផងគោតក្រែង បុណ្យចារមីតា ។ ខ្លះតវ៉ាចរស់ ចោលទ្រព្យរបស់
ខ្លះក្រាយជន្មា ខ្លះត្រូវចំណង នាគចង់ហត្ថា អស់អង្គក្សត្រា សឹងត្រូវ
ចំណង ។ ស្តេចផងតិតក័យ ភ្ញៅភ្ញាចខ្លួនក្រាយ អង្វរអង្វន សូម
ទោសាសុំ ជាខ្ញុំក្រោមល្អង ធុលីច្បាស់ច្បង ឲ្យរស់ជន្ម ។ កុមារ
ប្រាណប្រោស ប្រណីអត់ទោស ឲ្យធ្វើសីមា ពាំងបីជាន់ស្រេច
ហើយស្តេចមេត្តា ឲ្យរំលែកកាយ ទីនៃគ្រប់កាយ ។ ពីនោះសព្វថ្នាំ
តែងតែនំនាំ សួយសារមកថ្វាយ កុមារនិពុ្ធ ជាសុខសប្បាយ មន្ត្រី
ពាំឡាយ ព្រាហ្មណ៍ព្រឹទ្ធិការ ។ ដំនុំគតគ្នា ផ្សុំព្រះអនុជា ឯក
អគ្គមហេសី រៀបអភិសេក ជាឯកជាឥ_សូរចាលបុរី ស្នងព្រះបិតា ។
ស្តេចសោយសម្បត្តិ សម្បូរពស្ត្រវដ្ឋ លង់លុះដាច មានបុត្រាមួយ
ស្តេចឲ្យសេនា រើសពាជធីតា នៃក្សត្រជាខៃ ។ មកអភិសេក លើក
ឡើងជាឯក អគ្គមហេសី សោយរាជ្យគ្រប់គ្រង ស្មាប់ស្នងជៀស្ងប់យ
ចរចេញាទៅព្រៃ តែពីរអង្គ្រាណ ។ បួសជាឥសី សាងសីលអស្ចឹ
បានបញ្ចកិញ្ញាណ អដ្ឋសមា_បត្តិយាភ្ញាន ទៅកើតនាហាន ព្រហ្ម-
លោកសួគ៌នាយ ។ តាំងពីនោះតែង តរាជ្យអង្វែង ជាសុខសប្បាយ
ពុំមានសត្រូវ លំនៅដ៏តឆ្ងាយ អាចទៅមើលងាយ សុខសព្វវិស្ស ។

នានាំនិទាន (ខុកជាលំអាន) អាថ៌អត្ថសេចក្តី ទេសនាប្រាយ ប្រាប់ សណ្តាប់កិក្ខុនី ថេរាថេរី មនុស្សស្រុតនានា ។ ត្រាស់ហៅ កិក្ខុវៃ កិក្ខុអើយបុព្វេ កាលអង្គតថា_ គតកើតទៅនា ប្រមុខ្ញែងសង្ឃរ តែងនឹងទេសនា ខ្ញុំនានមនុស្សយក្ខ ។ ឲ្យកាន់សីលសុទ្ធ មិនឲ្យពុតត្បុត លះលោភអបល័ក្ខណ៍ ចែរចាបបងំនោះ លង់លុះសំណាក់ ត្រៃសរ_ ណៈជាក់ ជាភ្លុងបរិស័ទ ។ កិក្ខុអើយតថា_ គតពុំប្រាថ្នា សម្បត្តិ ចក្រព័ត្តិ ប្រាថ្នាឲ្យបាន ត្រាស់ញាណប្រាកដ ទេសនានាំសត្វ ជាក់ ជលន់និព្វាន ។ ខ្រង់ថ្ងៃឆតបស្រេច ថ្ងៃឆចតុស័ច្ច ជាបរិយោសាន ព្រះ សូរសីហនាទ ក្លុំជាតិនិទាន ដោយនូវសរញ្ញាណ វរលោកុត្តរ ។

រីនន្ទិយក្ខេ វិលជាព្រះទេ_ វេតត្តមោហា យក្ខិនីវិញ វិលវិញជាតិ ជា នាមនាងចិញ្ចា_ មានវិតត្ថិយ៍ ។ ឥន្ទ្រាវិសុទ្ធ ជាព្រះអនុរុទ្ធ ព្រះ ឧបាលី គឺអង្គស្តេចខ្មា .វាឧកឯបតី វិលយកជាតី គឺសិម្ពលិត្ថេរ ។ កុម្ភណ្ឌមួយជា នក្ខត្តត្ថេរ មួយយកជាតេ ជាមហានាមា មួយជានាគ ត្ថេរ មួយយកជាតេ ជាអង្គព្រះកច្ចាយន៍ ។ រីអសង្ខ្យេយ្យ ឥសីសីល សៃយ្យ ប្រាជ្ញប្រុះសព្វសាយ គឺព្រះសារីបុត្ត ប្រាកដកែ្លងឆ្ងាយ កុដន្ត រិទ្ធីសាយ ជាមហាមោគ្គល្លាន ។ រឹងអង្គតា ចាស់ចាំសួនច្បារ ចេរវិល

រីឯបាន ជាកសម្បជត្ថេរ រីឯយាយមាន សម្បាសរីលបាន ជានាងកុ-
មា ។ ព្រះព្រហ្មទត្តសោត ជាព្រះសុទ្ធោទន៍ ព្រះពុទ្ធបិតា រីឯក្សត្រី
ស្រស់ស្រីមលា ជាតិជាមហា_ មាយាទេវី ។ រីនាងបទុមា ជាតិជា
ពន្ធិតា ព្រះយសវតី ចេរីលរឹងមត យោនយកជាតី ជាព្រះថេរី នាម
នាងនន្ទា រីអង្គអភ័យ កុមារីលវៃ យោនយកជាតិជា ព្រះនន្ទជាត់
ច្បាស់ សហស្សសេរកុមារ រីលរឹងជាក_ ហុលត្ថេរប្រាកដ ។ រីអង្គ
អានន្ទ អនុជសោភ័ណ គឺអង្គសមុទ្រ សាគរកុមារ ចន្ទាវិសុទ្ធ ជានាង
ជនប- ទកល្យាណី ។ រីនាងសុវណ្ណ_ បុប្ផាសោភ័ណ រីលយកជាតី ជាតិ
ជាទុប្ផល វណ្ណាថេរី រីបុត្រអសុរី នាមអសុរិន្ទ្រា ។ ចេរីលរឹងយក
ជាតិសន្ទតមក ជានាងខេមា ថេរីប្រាកដ យសវតីមហា_ ក្សត្រក្សត្តិ
ប្រាជ្ញា ព្រះគោណ្ឌាញ្ញាប្រាកដ ។ សេះទ្រង់អំណាច គឺកណ្ឌសារថ
សេះសបរិសុទ្ធ លុះដោយខ្លួនាន ក្សត្រក្សត្តិចក្រវត្តិ ជាពុទ្ធបរិស័ទ
ពាំងអស់ពាល់គ្នា ។ សុវណ្ណកេសរ ថ្លៃថ្នាបវរ រីលយកជាតិជា ជាតិ
ចូលសម្រេច សម្តេចពិម្ពា ជាកន្ទ្រៃសារ ពេជ្ឈរោធិញ្ញាណ ។
ទេវទត្តនរន្ធ្នោ នរុត្តមោ រីសេសថ្លើងឋាន ថ្លើងឋលប្រាជ្ញប្រុះ សាយសុះ
ញេយ្យញ្ញាណ ពុំគឺក្សត្រក្សត្តិ ព្រះថេរជាមែ ។ គឺអង្គព្រះពុទ្ធ ប្រពៃ
បរិសុទ្ធ ខ្លួពាំងតាពៃត្រៃ ស្មោះស្មើនរាទេស រីសេសក្សាថ្លៃ គ្រូគ្រប់សុប

ណ្ឌយ្យ សុបណ្ណនាគា ។ ពាំងកុម្ភណ្ឌយក្ខ មនុស្សទេពសិង្ឃពាក់
សិង្ឃពីងចេស្តា បញ្ចប្រតិស្ត នមស្ការ លុះត្រៃសរណា សរណៈ
គមនាប់ ។

វរទេវន្នោ គឺជាតកោ និដ្ឋិតំចែងចប់ ដោយពាក្យកាព្យកិច្ច
សេចត្រែចសុះសព្វ ចរិបូណ៌គ្រាន់គ្រប់ ប្រការម្ល៉ះហោង ។

(ចប់ខ្សែប្រាំមួយតែប៉ុណ្ណោះ) ។

កណ្ឌទី ៣៣

ឧកញ៉ាបុលរាជសេនា ង្វ-កិន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ធឹងបេះទុបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ខ្ញុំពីក្រខ្សែកយើញក៏ត្រេកអរពន់ប្រមាណ ទើបអធិប្បាយរឿងដែលលំ
បាកគេចវត់មកនោះឲ្យគួនអ្ហ៊ូ, ទៀវហ៊ុយស្ដាប់គ្រប់ប្រការ ហើយក៏នាំគ្នា
ទៅ លុះទៅដល់ស្រុកសុំនអៀហើយ ។ ខ្ញុំពីតំប្រឹក្សានឹងពាហន
ទាំងពួនថា ដែលឈ្មួមីរៈគិតបញ្ឆោតយើងដូច្នោះ ខ្ញុំបៀវឲ្យអញ្ជើញទៅ
ហើយឈ្មួមីគិតធ្វើអន្តរាយយើងទោះ អ្នកទាំងពួនគិតដូចម្ដេចខ្លះ សុន-

ខៀនថ្លែយថា ដែលឈ្លួមិត្តធ្វើអន្តរាយលោកដូច្នេះ នឹងស្ទើរទៅម្តេច បានសូមឲ្យលោកមានសំបុត្រទៅដល់ឡៅប៉ៃ តាមរសេចក្តីឲ្យច្បាស់ ។ ឡៅពីបានស្តាប់ក៏យល់ឃើញត្រូវ ទើបធ្វើសំបុត្រឲ្យស៊ុនខៀនតាន់ចូលទៅដល់ស្រុកគេនដាវ នាយទ្វារក៏នាំស៊ុនខៀន ចូលទៅដំរាបឡៅប៉ៃ ។ សួរថា យើងឲ្យអញ្ជើញឡៅពីទៅខួលនាម៉ឺនមុខមន្ត្រី ឯស្រុកសុងយ៉ុងនោះ កំពុងតែលៀងអាហារមិនទាន់សម្រេច ស្រាប់តែឡៅពីវត់ចេញទៅនោះ តើដោយប្រការហេតុអ្វី ? ។

ស៊ុនខៀនក៏យកសំបុត្រជូនទៅឲ្យឡៅប៉ៃ ក្នុងសំបុត្រនោះ សេចក្តីថា ដែលលោកឲ្យហៅខ្ញុំទៅខួលគំនាប់នាម៉ឺនមុខមន្ត្រីហើយលៀងគោរជនាហារនោះ ខ្ញុំបានទៅដួបក្នុងទីប្រជុំដែលកំពុងលៀងអាហារ ឈ្លួមិត្តប្រទូស្តាយខ្ញុំ នេះហាក់ថា ខ្ញុំវត់ទៅរួច ទើបផុតពីសេចក្តីអន្តរាយជីវិត ហេតុផលដូច្នេះ ខ្ញុំក៏មិនទាន់ទីដំរាបលោកឲ្យជ្រាប គិតតែវត់ឲ្យរួចខ្លួនទៅសិន ។ ឡៅប៉ៃបានឮដូច្នោះក៏ខឹងភ្លាំងណាស់ ឲ្យហៅឈ្លួមិត្តចូលមកដេរប្រទេចថា ឯងនេះពេញជាបង្កាច់គេដោយអំណាចចិត្ត គិតនឹងសម្លាប់ឡៅពីជាប្អូនអញ ឯងមិនមានគោតក្រែងអញជាធំ និយាយហើយក៏បង្គាប់ពាហានឲ្យចាប់ខ្លួនឈ្លួមិត្តទៅសម្លាប់ ខណៈនោះ នាងឈ្លួហ៊ូយិនជាបងឈ្លួមិត្តទៅស្តាប់ពាក្យដូច្នោះ ក៏ចេញមកនិយាយសុំទោសឡៅប៉ៃ

ថា. ដែលឈួមមិនបង្កាច់ធ្វើការ តាមអំណាចចិត្តដូច្នេះ ទោសក៏ខ្ញុំសជាខមួន
ទៅហើយ លោកឲ្យសម្លាប់ចេញនោះក៏គួរ តែខ្ញុំសុំទោសលោកទុកម្តងចុះ ។ ឡៅប៉ៅវិញបាន
ឮតាំយានិយាយលន់តួទោសដូច្នេះ ក៏នៅស្ងៀមដោយកម្ចាំងក្រោធ មិនបានតបថាយ៉ាងម្តេចឡើយ ។

សុនខៀនឃើញឡៅប៉ៅវិងវាំងណាស់ក៏ដំរាបថា ដែលឈួមធ្វើខុស លោកនឹងឲ្យប្រហារជីវិតនោះក៏គួរហើយ តែថាខ្ញុំបានពីគ្រោះឃើញថា បើឈួមស្លាប់ទៅ ឡៅពីនឹងនៅក្នុងដែនស្រុកគេងដីវិតទៅ ក៏មិនបានសេចក្តីសុខ ដែលលោកថាអាណិតឡៅពីនោះ ក៏ដូចជាឥតប្រយោជន៍ ។
ឡៅប៉ៅវិញបានស្តាប់ក៏គិតថា ពាក្យសុនខៀននិយាយនោះ គ្រោះឃើញថាឈួមមានពួកមាកច្រើន ប្រសិនបើអញសម្លាប់ឈួមចេញហើយ មនុស្សពាំងពួនដែលជាស្ម័គ្រព័ទ្ធពួកឈួមនោះ ក៏គង់មានចិត្តគំនុំគំគួនឰយាបាទឡៅពី ដោយសេចក្តីកំហឹងជាប្រាកដមិនខាន ឡៅប៉ៅវិញគិតហើយក៏ឲ្យលើកទោសឈួមមិនសម្លាប់ គ្រាន់តែឰយរទោសទុក ហើយឲ្យឡៅពីជាបុត្រឰយនឹងសុនខៀនទៅសុំទោសឡៅពី ។

ឡៅពីនឹងសុនខៀនក៏លាឡៅប៉ៅវិញចេញទៅស្រុកសុំនអៀ. ចូលទៅគំនាប់ឡៅពីហើយដំរាបថា ឥឡូវបិតាខ្ញុំបានឲ្យមកសំពះសូមទោសលោក ដោយទើបដឹងសេចក្តីថា ឈួមគិតប្រទូស្តព៌ាយលោកនោះ

ទោសខ្ញុំសូមទម្លន់ណាស់ សុំកុំឲ្យលោកប្រកាន់ខឹងតទៅឡើយ ។ ឲ្យពីបានស្តាប់ហើយក៏មានអំណរណាស់ ហៅឲ្យគេបំពេញអាហារ ខណៈកាលឲ្យគេកំពុងសេពសុខនោះក៏សោកាតិលាប ។ ឲ្យពីត្រឡែកឃើញក៏សួរថា ហេតុម្តេចបានជាកូយសោកយំដូច្នេះ ឲ្យគេជំរាបថា ខ្ញុំបាទយំសោកនេះព្រោះគិតអាណិតខ្លួនណាស់ ដោយនាងឈូហ៊ូយិនមានគុណខ្ញុំបាទ មានចិត្តឫស្យាគិតតែនឹងសម្លាប់ខ្ញុំបាទចេញ ខ្ញុំបាទក៏មិនដឹងនឹងការពារក្សាខ្លួនដូចម្តេចសោះ ដើម្បីឲ្យរួចពីសេចក្តីអន្តរាយនោះបាន ហេតុនេះ ខ្ញុំបាទសូមពឹងដម្រេះប្រាប់ជ្រោសដួយអនុគ្រោះណែនាំពន្យល់ខ្ញុំបាទផង ។ ឲ្យគេថា សព្វថ្ងៃនេះបើកូយនឹងរក្សាខ្លួនបានក៏អាស្រ័យដោយប្រើកិរិយានឹងអធ្យាស្រ័យដ៏រៀបរយ កូយចូរទៅស្បាថ្ងៃប្រតិបត្តិតាមទំនងចិត្តនាងឈូហ៊ូយិនកុំឲ្យមានភាស់អធ្យាស្រ័យ ទើបនឹងរួចទោសភ័យអន្តរាយទាំងពួង លុះឲ្យពីពន្យល់ហើយត្រឹកឡើង ឲ្យគេក៏លាវិលទៅវិញ ។ ឲ្យពីក៏ឡើងដំរះសេះដួនដំណើរទៅដល់ក្រៅព្រំស្រុក ហើយត្រឡប់មកវិញ ដួបមនុស្សម្នាក់ដើរធ្វើភ្លេងនៅកណ្តាលផ្លូវថាជាសេចក្តីថា៖

ធម្មជាតិផែនដីបុរេម្យ　　ទឹងទ្រែតរលំដួលក្រឡាប់
ដូចភ្លើងរលត់ផុតសែងអ័ព្ទ　　សូន្យស័ព្ទពុំក្តីពន្ធឡើយ ។
បើមេដំបូលចុតស្រយុត　　យកឈើកំបុតគូចទល់ហើយ
តំទ្រុំឈ្នះជ្រុះជាត្រើយ　　អ្នកអើយនេះគឺចាស់លោកថា ។

អ្នកស្រុកស្រែក្រៅនៅឆ្ងាយក្រុង មានពន្យល់ដាតឆ្ងាតវោហារ
ត្រូវស្នេរកម្ចាស់ចេះណាស់សា នរណាក៏គ្មានស្គាល់យើងសោះ។
ខ្ញៀវពីបានស្តាប់មនុស្សធ្វើភ្លេងដូច្នោះ តំរែកក្តីចិត្តគិតថា ពាក្យ
សំដីសុមាតេកធាក្រាប់ថា ហុកឡុង. ហង់ស្ងួនោះប្រហែលជាឈ្មោះ
នេះទេដឹង ? ខ្ញៀវពីតំចុះពីសេះចូលទៅគំនាប់ ហើយក៏នាំចូលទៅកន្លែ
លំនៅឲ្យអង្គុយក្នុងទីសមគួរហើយសួរថា អ្នកឈ្មោះអ្វី? នៅទីដំបន់ឯណា?។
ឈ្មោះនោះតំឆ្លើយ ខ្ញុំបាទឈ្មោះ តាន់ហុក ស្រុកនៅដំបន់អេងសុង ខ្ញុំ
បានដឹងថា លោកនេះមានចិត្តល្អ ជ្រៀតលាយពោះពាយពាក់ពាន់ធ្ងន់អ្នកពាំង
ភ្លេង តែតនឹងប្រថុយចូលមកតកលោក ក្រែងមិនសមគួរ បានជាខ្ញុំបាទភ្លេង
ធ្វើ ភ្លេងច្រៀងលេងដូច្នេះ ច្រាថ្នាន់ឲ្យលោកដឹងច្បាស់ ។ ខ្ញៀវពីឮដូច្នោះ
តំសោមនស្សត្រេកអរបបួលតាន់ហុកទុកឲ្យទៅជាមួយ ដើម្បីនឹងជួយធ្វើ
ជាទីប្រឹក្សា តាន់ហុកតំយល់ព្រម ហើយនិយាយនឹងខ្ញៀវពីថា សេះដែល
លោកដិះមកអម្បាញ់មិញនេះ ខ្ញុំបាទនឹងសូមមើលលក្ខណៈបន្តិច ។ ខ្ញៀវពី
តំហៅមនុស្សបំរើឲ្យដឹកសេះនោះមកដិត តាន់ហុកតំពីគ្រោះមើលលក្ខណៈ
ឃើញតាច ទើបដំណាច់ខ្ញៀវពីថា សេះនេះលក្ខណៈឈ្មោះតេកខ្ញៀ មាន
តម្លាំងនឹងថ្ងៃដង្ហែរួសពាន់ហ៊ីសណាស់ តែថា រមែងតើតអន្តរាយដល់ម្ចាស់
បើលោកនឹងដិះសេះនេះតទៅ អន្តរាយនឹងមានដល់លោក។ ខ្ញៀវពីថា បើ

ប្រសិនជាសេះនេះ ចង្រៃកើតអន្តរាយដល់ម្ចាស់ដូចអ្នកថាមែន តាលណា
ក៏នឹងនាំយកខ្លួនយើងធ្លាក់ស្ទឹងតាន់ទេមកបាន ។ តាន់ហុកថា ទោះបីសេះ
នេះបាននាំលោកឆ្លងមកចាកអំពីសេចក្តីស្លាប់ក្នុងគ្រានេះក៏មែន តែថា ត
ទៅមុខគង់នឹងឲ្យមានអន្តរាយទៀតជាប្រាកដ ខ្ញុំបានដឹងកិច្ចមួយទៀតទេ
ចេញ ដើម្បីនឹងដោះសេះនេះតទៅមុខកុំឲ្យកើតភ័យអន្តរាយបាន ។ ទៀតសួរថា
ឲ្យបាយរបស់អ្នកប្រការម្តេចបានអន្តរាយ ប្រាប់ចុះ? ។ តាន់ហុកឆ្លើយថា
ដែលមិនឲ្យមានអន្តរាយនោះ នរណាដែលមិនត្រូវចិត្តលោក ។ ត្រូវឲ្យ
សេះនេះទៅអ្នកនោះដោះប្រើទៅចុះ អន្តរាយនោះគង់នឹងមានដល់អ្នកនោះ
ជាមុន រួចសឹមលោកត្រឡប់យកសេះនេះមកវិញ ទើបនឹងមានសេចក្តី
បំរើនតទៅអស់មានអន្តរាយទៀតហើយ ។ ទៀតពោលហើយក៏ឱនលាស
ថាអ្នកនេះមានប្រាជ្ញាមកខ្លាំងណាស់ ។ គិតថានឹងជួយទប្តូរឲ្យយើង
បានសេចក្តីល្អជាបុណ្យដាធម៌ គួរហើយ ឬ មកប្រដៅឲ្យទៅជាអធម៌វិញ
ឲ្យយើងបំផ្លាញអ្នកដទៃឲ្យវិនាសដូច្នេះ យើងមិនសូមចង់ឮ ចង់ស្តាប់តទៅ
ទៀយ ។

តាន់ហុកក៏អស់សំណើចហើយថា ខ្ញុំបាននិយាយដំកបលោកដូច្នេះ
មិនមែននឹងឲ្យលោកធ្វើដូច្នោះក៏ទេ ព្រោះខ្ញុំបានឮគេតិះដៀលយ៉ាង
និយាយគ ។ មកថា លោកជាអ្នកមានចិត្តប្រកបដោយសត្យធម៌ តែ

ខ្ញុំបាទមិនចាន់យើញច្បាស់នឹងក្បែកនៅឡើយ ដែលខ្ញុំបាទក្រែងនិយាយ
ជូរច្នេះ ដើម្បីនឹងពិសោធចិត្តលោកមើលទេតើ តែឥឡូវតំយើញសមប្រកប
នឹងរន្ធឮៗនោះមែន ។ ទៀតពីថា ដែលឮគេនិយាយនោះក៏មែនហើយ តែថា
ខ្លួនខ្ញុំនេះគ្រាន់តែជាប្រមាណនឹងបានដូចពាក្យ គេនិយាយសព្វគ្រប់ជូច្នេះ
ក៏ទេ គ្រានេះ អ្នកមកនៅជាមួយនឹងយើងហើយ ចូរជួយរំលឹកពន្យល់
ជាផ្លូវខ្ញុំកុបំរុងដែលប្រពៃផងចុះ ហើយទៀតពីកំតាំងឲ្យគាន់ហុកធ្វើជា
ធំបង្គាប់បញ្ជាការហានតាំងពួន ។

ឯចូនួ លុះលើកពលយោធាត្រឡប់ទៅពីស្រុកគីជីវហើយ ក៏
ប្រើឲ្យចោយ៉ន, លៀន, លិកង, លិសៀង លើកទាហាន ៣ ម៉ឺនទៅ
តាំងនៅស្រុកហួនសៀ ដែលជាស្រុកចំណុះ បំណងនឹងស្តាប់កិច្ចការស្រុក
ខេសក្ខន្ធ ទ្រគីជីវនោះ លុះលិកង, លិសៀងដឹងក៏និយាយនឹងចោយ៉ន ថា
ទៀតពីលើកទ័ពមកនៅស្រុកសុំនអៀ មុខជានឹងគិតការជាធំឡើងទៀត
ចាំនឹងកំចាត់ចេញឲ្យបាន កុំឲ្យធ្វើការតទៅខាងមុខបាន ឯខ្លួនខ្ញុំបាទ
តាំង ២ នាក់បងប្អូននេះ មកនៅធ្វើកជការនឹងមហាឧបរាជ ក៏មិនចាន់
បានធ្វើសេចក្តីគាប់ប្រសើរដូននៅឡើយ សព្វថ្ងៃក៏តាំងចិត្តគិតធ្វើការតប
ស្នងសងគុណមហាឧបរាជឲ្យដល់ខ្លួន ឥឡូវ ទៀតពីមកតាំងនៅស្រុក
សុំនអៀ ខ្ញុំបាទបងប្អូននឹងសុំអាសាទៅកាត់ក្បាលទៀតពីមកឲ្យបាន

ចោយនឹងលិខៀនពួកដូច្នោះកើត្រូតរាល់ ទើបចាត់ឲ្យហាន ៥៣នាក់ឲ្យ
លិកធ, លិសៀនលើកទៅដល់ដែនចុងស្រុកសុំនអៀ ។

ចំណែកបំរើសេះយើញកងទ័ពលើកមកដូច្នោះ ក៏ស្រូតទៅប្រាប់
ខ្មៅពុ ។ ក៏ហៅតាន់ហុកមកប្រឹក្សាថា ឥឡូវកងទ័ពលើកមកធ្វើអន្តរាយ
ដល់យើងហើយអ្នកនឹងជួយគិតយ៉ាងម្តេច ? តាន់ហុកឆ្លើយថា ដែល
សត្រូវលើកទ័ពមកប្រទូស្តព័យើងដូច្នេះ នឹងបង្អង់ទុកឲ្យកន្លងមកទៀត
មិនគួរទេ ត្រូវតែកំចាត់ចេញពីចម្ងាយ សុំឲ្យលោកប្រើខៀវហ៊ុយលើក
ពលហានវាងទៅស្កាត់ពីក្រោយ ហើយឲ្យគួនអ៊ូលើកពលទៅពួន
បង្កប់ស្កាត់កណ្តាលផ្លូវ ឯខ្លួនលោកនឹងជួឡងចូលលើកទ័ពជាកងហ្មងទៅ
ទល់ចាំងចំមុខបច្ចាមិត្រកណ្តាលផ្លូវ ក៏ទឹងបានដាយដំនះជាប្រាកដ ។ ខ្មៅ
ពីកាយល់យើញត្រូវផង ទើបប្រើគួនអ៊ូនឹងខៀវហ៊ុយលើកពហានទៅតាំង
តាមពាក្យតាន់ហុកថា ។ ឯខ្មៅពីនឹងជួឡងកំលើកពលពីរពាន់ ចេញពី
ស្រុកភៅចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គី) បានជួបនឹងកងទ័ពលិ-
កធ លិសៀនលើកចូលមក ខ្មៅពីឲ្យបញ្ឈប់កងទ័ពហើយចារសេះទៅ
បញ្ជ្រាតមុខពហានទើបសួរថា អ្នកឯងឈ្មោះអ្វី ? ទើបអាចលើកកង
ទ័ពកន្លងចូលមកដល់ដែនរបស់យើង ? លិកធឆ្លើយថា យើងឈ្មោះលិ
កធជាពហានឯករបស់មហាឧបាជ ឥឡូវនឹងមកចាប់ខ្លួនអ្នកឲ្យបាន ។

ខ្ញុំតាំងពីតូចណាស់ ក៏ប្រើដូចឪពុកនឹងលក់ដាច់បាន ៥ ក្បាង ដូចឪពុកយកខ្លួនចាក់ត្រូវលក់ដាច់ភ្លាត់ពីលើសេះស្ទាប់ ខ្ញុំតាំងពីឃើញបានចំណាប់ក៏បរពេលចូលប្រកាប់ប្រចាក់ លុះសឿនឃើញលើសកំឡាំងនឹងទ្រាំតទល់ពុំបាន ក៏ចាក់ចេតវត់ថយទៅក្រោយ គួនអ៊ូក៏ចេញមកដេញបណ្តាយតាសង្ហាង ចូលចាក់គាប់សម្លាប់រហ៍ពលលុះសឿនស្ទាប់ប្រហែល ២ ពាន់ថ្នាយ លុះសឿនឃើញពលខ្លួនស្ទាប់វត់ខ្លាចក៏ថយវត់ចេញទៅ ខ្ញុំវាហ៊ុយដែលនៅចាំស្តាត់ខាងក្រោយផ្លូវឃើញលុះសឿនឆាំពលវត់បែកមក ក៏បរសេះចេញទៅចាំស្តាក់ពីមុខហើយស្រែកថា អញឈ្មោះខ្ញុំវាហ៊ុយ ម៉ែកចាំស្តាក់ឯងនៅទីនេះជាយូរហើយ លុះសឿនក្រឡេកឃើញខ្ញុំវាហ៊ុយក៏ស្តុតស្ទាំងក្នុងចិត្ត ញាក់សេះនឹងវត់ ខ្ញុំវាហ៊ុយក៏ដេញតាមយកខ្លួនចាក់ត្រូវលុះសឿនភ្លាត់ពីលើសេះស្ទាប់ ឆ ហានចាំងពួងក៏បែកភ្លាត់ភ្លាយចេញទៅ ខ្ញុំតាំងពីឲ្យដេញចាប់ឆ ហានបានច្រើនណាស់ ហើយឲ្យលើកកងទ័ពត្រឡប់មកស្រុកសុំនអ្វីវិញ ។

ឯឆ ហានលក់ដែលបែកវត់ទៅបាននោះ ក៏នាំគ្នាមានទៅជ្រាប់ចោយនគ្រប់ប្រការ ចោយនឮហើយក៏តក់ស្លុតខ្លាំងណាស់ ប្រឹក្សានឹងលុះខ្ញុំនឹងឆ ហានចាំងពួងថា ឥឡូវលក់ដាច់លុះសឿនលើកទ័ពទៅក៏បាត់ដាយនឹងខ្ញុំតាំងពីទៅហើយ តើយើងនឹងគិតប្រការម្តេចទៅវិញ ? លុះខ្ញុំនធ្វើយ

ថា លិកនឹ, លើសៀនោះ ដល់ខ្លួវសេចក្តីស្លាប់ក្នុងគ្រានេះ កំព្រោះប្រមាទមើលងាយខ្មៅពី បើយើងនឹងលើកទ័ពបន្ថែមទៅវាយស្រុកសុំនអៀខ្មៅតក៏មិនបាន ឯខ្មៅពីមានជ័យ កំភំរើកចិត្តខ្លាំនខ្មៅត សូមឲ្យលោកគិតកែប្រែបន្ថែមបន្ថឹងឹតាហានខុកសិន ហើយប្តឹងសំបុត្រចូលទៅដល់មហាឧបរាជឲ្យលើកកងទ័ពមកជួយ ។ ចោយិនធ្វើយថា ខ្មៅពីសម្លាប់សេនាយើងហើយ, ចាប់យកពាំងកូនតាហានទៅជាឈ្លើយកំប្រែនឹងស្រួមនៅម្តេចបាន ត្រូវតែយើងលើកកងទ័ពទៅសងសឹកខ្មៅពីវិញ ឯស្រុកសុំនអៀប៉ុនបាតដៃនឹងឲ្យក្តៅក្រហាយ ដល់មហាឧបរាជនោះមិនគួរសោះ សូមឲ្យតែកំឡាំងយើងក៏ល្មមធ្វើបានដែរ លិខៀនថា ឯខ្មៅពីនោះមានជម្រេះប្រជ្ញាជ្រៅឆ្ងាយខ្លាយណាស់ ដែលលើកទ័ពទៅបង្ក្រាប តាមកំឡាំងមិនបានទេ ឲ្យរៃគិតសិន ចោយិនថា អ្នកឋាចាដូច្នេះ មិនអង្គឹងនឹងខ្លាចថ្លើដែខ្មៅពីហើយឬ ? លិខៀនថា ខ្ញុំនិយាយដូច្នេះមិនមែននឹងកោតខ្លាចថ្លើដែខ្មៅពីដូចម្តេចទេ ប្រាថ្នានឹងជាសស្មារតីលោកទេតើ ព្រោះពាក្យបុរាណក៏មានភោលខុកថា បើនឹងធ្វើការសង្គ្រាម គប្បីឲ្យដឹងលក្ខណៈក្នុងកលសឹកជាមុន ទើបមានជ័យដំនះដោយងាយ ហេតុដូច្នេះបានជាខ្ញុំឃាត់ហាមលោក ក្រែងថ្ងៃសំគារនឹងសត្រូវកំនឹងថែមអាក្រក់ទៅខ្មៅត ។

ចោយិនថា: អ្នកនិយាយនេះគឺធ្វើការជាចិត្ត ២ មិនមែនជាកត្តីស្មោះ

ត្រង់ បើដូច្នោះ តែកំឡាំងយើងនឹងលើកទៅចាប់ខ្លួនឡៅពីកំបានដែរ លោ
ខៀនថា ដែលនឹងលើកទ័ពទៅនោះកំតាមសេចក្តីគិតលោកចុះ ខ្ញុំនឹង
សូមអាសាគ្រងតាហានទៅរក្សាស្រុកហ៊ួនសៀ ចោយនឹងឮដូច្នោះក៏ទឹង
ណាស់ថា អ្នកចារចាប្រែចិត្តចេញពីយើងដូច្នេះ យើងយើញថា អ្នកចិត្ត ២
ទៅហើយ ចានជាគ្មានសេចក្តីឈឺចិត្តច្អិតច្អៃមសោះ លោខៀនថា ខ្ញុំនិយាយ
ជាស់តឿនស្មារតីលោកដោយការពិត នឹងបានប្រែចិត្តចេញពីលោកកំខ្លះ
បើជាលោកនៅសង្ស័យនឹងខ្ញុំ ។ សូមទៅជាមួយផង ចោយនឹងលោខៀន
ក៏លើកតាហាន ៦.៤០០០ ស្រួតជម្រង់ទៅស្រុកសុំនអៀ ដោយកំឡាំង
ពោសោ មិនចាំនឈប់សម្រាកកងំពាលើកទៅតំងយប់តំងថ្ងៃ ដោយ
តំនិតនឹងចិត្តចោយិនោះបំងនឹងទៅជាន់សង្កត់ផែនដីស្រុកសុំនអៀឲ្យលិច
ទៅក្នុងមហាសមុទ្រតែម្តង ។

ឯតាន់ហុកចាប់ដើមតាំងពីឡៅពីចានដ៏យដំនះត្រឡប់ចូលទៅស្រុន
សុំនអៀវិញ ក៏និយាយនឹងឡៅពីថា ចោយិនមកតាំងទ័ពនៅស្រុកហ៊ួន
សៀនោះ ឥឡូវខ្លួចសេនាឯកដល់ ២ នាក់ មុខជាមានចិត្តខឹងក្តៅលើក
ទ័ពមកវាយស្រុកយើងខ្លៅតហើយ ។ ឡៅពីឮហើយក៏យល់ថាមែន ទើប
សួរតាន់ហុកថា បើប្រសិនចោយិនលើកទ័ពមកមែន តើយើងនឹងគិត
ការពារប្រការម្តេច ? តាន់ហុកថា បើចោយិនលើកមកគ្រានេះ មុខជា
ប្រមូលចាហានយកមកពាំងអស់ យើងនឹងគិតកលឧបាយលបទៅវាយ

យកស្រុកហ៊ីនសៀឲ្យបាន ។ ឡៅពីសួរថាកល់ទុយអ្នកគិតយ៉ាងម្តេច? តាន់ហុកក៏រៀបប្រាប់ឡៅពីជាសេចក្តីថា ស្រុកហ៊ីនសៀនោះមនុស្សស្តួចស្តើងណាស់ សូមលោកប្រើគួនអ៊ូលើកទាហានលបទៅវាយយកស្រុកហ៊ីនសៀជាកំណាន់ទុក មុខជានឹងបានដោយងាយណាស់ ហើយប្រើខៀវហ៊ុយឲ្យលើកទាហានទៅបង្កប់នៅក្បែរច្រាំងស្ទឹង បើឆ្ងងពីស្រុកហ៊ីនសៀទៅហើយ ឃើញចោយិនបែកទ័ពទៅត្រូវឲ្យចេញស្កាត់វាយពីមុខ ' សឹកសង្គ្រាមគ្រានេះខ្ញុំបាទសំគាល់ថាមុខជាមានជ័យជំនះខ្មែរជាប្រាកដ ។ ឡៅពីឮដូច្នោះក៏ត្រូវចិត្តណាស់ ទើបប្រើគួនអ៊ូ , ខៀវហ៊ុយលើកទាហានទៅធ្វើតាមពាក្យតាន់ហុកថានោះ ហើយឡៅពីក៏ត្រួតត្រាត្រៀមទាហានទុកព្រមស្រេច ។

ខ្លះលំអើសេះម្នាក់ចូលមកប្តឹងឡៅពីថា ចោយិនលើកកងទ័ពមកដល់ប្រទល់ដែន តាន់ហុកឮដូច្នោះក៏នាំឡៅពីលើកទាហានចេញទៅតាំងបន្ទាយតទល់នឹងកងទ័ពចោយិនត្រៀកំពែងស្រុក ឡៅពីក៏ប្រើដូឡុងកំខ្លួនចូលទៅបញ្ជោតចោយិនត្រៀបន្ទាយ ចោយិនឃើញដូច្នោះក៏បណ្តេញឲ្យសៀវទៀនចេញមកតយុទ្ធនឹងដូឡុងបាន ២០ ភ្លេង លិចទៀនឃើញកំឡាំងដូឡុងខ្លាំងលើសលុបនឹងតទល់ពុំបាន ក៏បំផ្លាយសេះរត់ថយក្រោយចូលមកបន្ទាយវិញ ដូឡុងឃើញបានចំណាប់ក៏បរសេះប្រញាប់តាមទៅ ទាហានដែលនៅកងបន្ទាយក៏លើកដួងឡើងបាញ់ស្កាត់ពីមុខ ដូឡុងនឹងពុះ

ពារបួលទៅពុំបាន ក៏បំផ្លាយសេះរំលងមកបួលបន្ទាយវិញ ។

លំខៀនឱយយឧន័ចោយិនថា តាហានឡៅពីមានថ្លីដៃខ្លាំងពូកែណាស់ មុខជាយើងនឹងយកដ័យដំនះមិនបានទេ សូមឲ្យលោកលើកទ័ពត្រឡប់ទៅស្រុកហ៊ួនសៀវិញ នឹងបានរៃគិតការជាថ្មីឡើងទៀត ចោយិនបានឮហើយក៏ខឹងណាស់ទើបថា កាលពីដំបូងយើងរៀបលើកទ័ពមក ខ្លួនធ្វើព្រងើយកន្តើយ យើងក៏យើញចិត្តម្ដងទៅហើយ ដល់មកវេលានេះ យើងឲ្យខ្លួនចេញតយុទ្ធនឹងដូឡុង ខ្លួនក៏បែកថយរត់មកវិញ ឲ្យថ្លស់ការនឹងសត្រូវ បើយើងមិនយកគោសខ្លួនក្នុងគ្រានេះ តាហានចាំងពួងនឹងយកជាតួយ៉ាងតាម ទើបបង្គាប់តាហានឲ្យចាប់ខ្លួនលំខៀនទៅនឹងប្រហារដ៏រឹត ។

នាយទ័ពនាយកកងចាំងអស់គ្នាក៏បួលទៅសូមគោស ចោយិនក៏ព្រមអនុញ្ញាតគោស ហើយចាត់ឲ្យលំខៀនឃុំនាំតាហានជានាយកងក្រោយ សម្រាប់តារពារក្សាស្បៀង លុះវេលាព្រឹកឡើងចោយិនក៏វាយឃ្មោះតងខ្លួនស្ដរឮគិតកងក្នុងបន្ទាយ ហើយរៀបចាត់ចែងពលតាហានតាំងជាកងព្យហៈដោយក្បួនទ័ពឈ្មោះ " ចាំក់ប៊ុនយ៉ាមធោរ៉ុន " ប្រែថា " កូនសោមាស " មានទ្វារ ៨ ទិសស្រែចហើយឲ្យតាហានដឹះសេះចូលទៅស្រែតប្រតាស ក្នុងមុខបន្ទាយឡៅពីថា នាយយើងតាំងតាហានជាព្យហៈទ័ពដូច្នេះ អ្នកឯងដឹងជាកលខុចាយព្យហៈនោះដូចម្ដេចខ្លះ ? ។

តាំងពីឡើងតំណាងហុកឡើងទៅមើលរបៀបទំពាហ៊ះចោយិន ធ្វើឡុងក្លួលវាយបន្ទាយចោយិន ចែក លុះដល់ឡើពីទៅរកខ្មែរបេងមិនដួល ហើយដួលតែតំណែងសុយបេង បបួលសុីយបេងទៅធ្វើ ការ សុីយបេងមិនព្រមទៅ ។

តាន់ហុកបានស្ដាប់ប្បាស់ កំនាំឡៅពីឡើងទៅលើកំពូលភ្នំខ្ពស់ ហើយក្រឡេកមើលចុះមកកំស្គាល់ប្បាស់ក្នុងកល់ព្យហ: ទើបដំរបឡៅ ពីថា ដែលចោយិនតាំងពលតាហានជាព្យហ:ខុកដូច្នេះ ឈ្មោះថា "ប៉ាត់ ប៊ុនយិនធោរិន្ទ" មានទ្វារ ៨ ទិស បើនរណាចូលចេញមិនត្រូវ កំនឹង បរាជ័យចាញ់ បើចូលត្រូវហើយកំនឹងមានជ័យជំនះ ចោយិនធ្វើយ៉ាងនេះ ល្អមែន តែថាមិនទាន់បានជួនលួម សូមឲ្យលោកប្រើតាហានឲ្យចូលពី ទ្វារទិសទក្សិណ រាយទំលាយចេញទៅទាងទិសបស្ចិម តាហានចោយិន តាំងអម្បាលោះកំនឹងបែកជាច្រឡំបល់ទៅឯង ។

ឡៅពីពួកដូច្នោះ កំនាំតាន់ហុកចុះពីលើភ្នំមកវិញ ហើយប្រមូល តាហានឲ្យរក្សាបន្ទាយឲ្យខ្ជាប់ខ្ជួន រួចប្រើដូឡូងលើកពល ៥០០ រាយទំ លាយចូលទៅតាមផ្លូវទ្វារទិសទក្សិណ ឯចោយិនឃើញដូឡូងរាយចូលមក កំឡើងសេះកំជួនចេញបញ្ជាត ចំណងនឹងឲ្យដូឡូងដេញតាមតេញទៅ ទាងទិសទត្តរ ដូឡូងកំមិនដេញតាមទៅប្លាំងពារទំលាយចេញទៅទាង

ទំសុបស្ងួមវិញ. ហើយត្រឡប់ថយក្រោយ វាយត្រឡប់ចូលទៅខៀត ចេញតាមទ្វារទំសុកណ្តែដែល ឯតាហានចាយនក៏ផ្តើលប្រួលប្រួលតាប់សម្លាប់គ្នាឯងជាច្រឡំបល់ ។ ខ្លៅពីយើញថាបានចំណាប់ក៏ប៉ារពលតាហានចូលទ្បែតាប់ចាក់ សម្លាប់តាហានស្លាប់អស់ជាច្រើន ហើយតាហានបែកខ្ចាត់ខ្ចាយចេញទៅ តាន់ហុកក៏នាំខ្លៅពីនឹងដូឡង់លើកទ័ពវិលមកបន្ទាយវិញ ។

ឯចំណែកចាយនដែលចាញ់ប្រៀបនឹងខ្លៅពីដូច្នោះ ក៏នឹកគិតដល់ពាក្យសំដីលៀង រំលឹកពីថ្ងៃមុន ទើបអញ្ជើញលៀងមកប្រឹក្សាថា ក្បួនសឹកគ្រានេះ ក៏រៀបចំយ៉ាងអស់ពីចិត្ត គិតថានឹងយកជ័យជំនះឲ្យបានប្រហែលជាក្នុងកន្លះទាត់ខ្លៅពី មានមនុស្សប្រុសប៉ុនប្រុសបាំមួន ទើបអាចយកជ័យជំនះយើងបានវិញ ។ លៀងតបថា ការពាំងនេះខ្ញុំក៏បាននិយាយរំលឹករលោកពីដំបូងមកហើយ លោកក៏មិនព្រមដឿស្តាប់ពាក្យខ្ញុំសោះ ត្រឡប់ចិត្តខឹងព្រះគោះប្រកាន់មកខ្ញុំវិញថា ខ្ញុំប្រែបែកចិត្ត ឯខ្លួនខ្ញុំមកធ្វើសឹកនឹងលោកគ្រានេះ ចិត្តខ្ញុំចេះតែឲ្យមានគិតវិតក្តព្រួយដល់ស្រុកហ៊ួនសៀកល់ពេលមិនដែលក្តេចសោះ ព្រោះទីនោះនឹងរកនរណានៅគ្រប់គ្រងរក្សាជាមាំមួនក៏គ្មាន ខ្លាចក្រែងមានអន្តរាយជាក្រោយយើង ចោយនតបថា អ្នកនិយាយនេះត្រូវណាស់ តែថាយើងលើកកងទ័ពមកដល់

ប្រទេសដែនស្រុកសុខនអៀហើយ ត្រូវតែចាំចាំឆ្នាំនឹងឡៅពីឱ្យអស់ចិត្ត
សិន ពេលយប់នេះ យើងនឹងលើកទាហានជាកងទ័ពចូលលុកបន្ទាយ
ឡៅពី ប្រសិនបើសមដូចគំនិតយើងគិតនឹងបានធ្វើការឱ្យជាប់តទៅ បើ
មិនបានសម្រេចទេ សឹមយើងលើកទ័ពត្រឡប់ទៅស្រុកហ្លួនសៀវិញ ។
លីខៀនធ្វើយថា ឡៅពីជាមនុស្សមានសតិបញ្ញាណាស់ពោះបីជាមានជ័យ
ជំនះក្តី ក៏គង់មិនប្រមាទ ដែលថ្ងៃនេះ មុខជាគិតការពារក្បាលបន្ទាយជា
មាំមួន ដែលលោកគិតនឹងលើកទៅលុកបន្ទាយឡៅពីនោះ ត្រែងខ្លួច
ទាហានអសារឥតការទេដឹង ? ចាយិនធ្វើយឡើងថា ឯការសង្គ្រាមនេះ
បើចេះតែគិតខ្លាចបារម្ភត្រែងចញ់ដូចពាក្យអ្នកថា ហើយនឹងធ្វើសឹកតទៅ
ម្តេចបាន ចាយិនមិនស្តាប់ក៏ឱ្យត្រៀមទាហានទុកព្រមស្រេចហើយ
បង្គាប់ថា វេលាយាម ២ នឹងលើកចូលលុកបន្ទាយឡៅពី ។

ឯឡៅពីនឹងតាន់ហុកអង្គុយប្រឹក្សាពីការជាមួយគ្នា ទទួលតើត
ឱ្យលំបុតត្បូងកួចឡើងលើបន្ទាយ តាន់ហុកក៏និយាយនឹងឡៅពីថា ឱ្យលំ
ព្យុះនេះអស្ចារ្យណាស់ ប្រហែលយប់នេះចាយិននឹងលើកទ័ពមកលុក
បន្ទាយយើងជាប្រាកដ ឡៅពីតបថា ប្រសិនបើចាយិននឹងលើកទ័ពមក
លុកមែន យើងរិះគិតការពារប្រការម្តេច ? តាន់ហុកអស់សំណើចហើយ
ថា លោកកុំព្រួយរឹតក្តីឡើយ ដែលនឹងស៊ូចាំឆ្នាំនឹងចាយិននោះ ខ្ញុំបាទ
នឹងទទួលធានាជាពុះពារដោយខ្លួនឯង ។

លុះដល់ពេលព្រលប់ គាន់ហុកកុំប្រើដូឡឹងឲ្យលើកតាហានទៅពួនបង្គប់ស្ពាត់នៅកណ្តាលផ្ទះ ហើយឲ្យគរអុសចំបើងទុកជុំវិញបន្ទាយ ចំណែកចោយិនតាលដល់កំណត់ កំលើកតាហានចេញពីបន្ទាយឲ្យលិខៀនជានាយកងក្រោយ លើកទៅដាតបន្ទាយខ្មៅពី លុះឃើញភ្លើងឆេះភ្លឺជុំវិញបន្ទាយ ។ ចោយិនក៏សំគាល់ថា ទេវតាដ៏ធំខ្លួន បានជាការពារការពារបន្ទាយជាមុន ក៏ថយទ័ពត្រឡប់មកនឹងចូលបន្ទាយវិញ ។ ដូឡឹងដែលពួនបង្គប់ស្ពាត់ផ្ទះនោះ លុះឃើញទ័ពចោយិនថយហើយ ក៏ដេញតាហានស្ទុះស្រេចេញមក តាហានចោយិនមិនបានដឹងខ្លួនក៏បែកផ្លែលនាំគ្នារត់ ដូឡឹងបានចំណាប់កំលើកតាហានដេញតាមទៅ ។

ចំណែកចោយិននឹងចូលបន្ទាយមិនបាន ក៏គេចលើកទ័ពត្រឡប់តម្រង់ទៅឯស្រុកហ៊ិនសៀ លុះទៅដល់មាត់ស្ទឹងដែនស្រុកហ៊ិនសៀ ក៏ឈប់តាហានចាត់ឲ្យរកទូកឆ្លង ។ ខៀវហ៊ុយដែលតាំងបង្គប់នៅត្បែរមាត់ច្រាំងឃើញដូច្នោះ ក៏លើកតាហានចេញស្កាត់ពីខ្នងទ្រោមជុំវិញហើយចូលទៅ ចោយិននឹងលិខៀនមិនបានដឹងខ្លួនក៏ស្ទុះស្ទន់ស្មារតី នាំគ្នាចុះទូកចែវរត់ឆ្លងទៅត្រើយម្ខាង ។ ខៀវហ៊ុយក៏ចាក់កាប់សម្លាប់តាហានចោយិនស្លាប់ដោយអាវុធនឹងភ្លាក់លិចលង់ទឹកស្លាប់អស់ជាច្រើន រាប់ប្រមាណប្រហែល ១ ម៉ឺនជ្រាយ ។

ចំណែកចោយិននឹងលិខៀន ឆ្លងទៅដល់ត្រើយម្ខាងហើយ ក៏នាំ

ពាហានប្រមាណមួយហ្មឺនជាយដែលសល់អំពីស្លាប់នោះប្រញាប់ទៅស្រុកហ្លួនសៀ កាលដល់ទើបហៅពាហានក្នុងស្រុកឲ្យបើកទ្វារទទួល គួនអ្ងួដែលចូលទៅតាំងនៅក្នុងស្រុកនោះ ឃើញដូច្នោះក៏ឲ្យអុជដាវដាសញ្ញាឡើង ហើយឲ្យពាហានបើកទ្វារស្រុកចេញមក ចាយិនក្រឡែកឃើញគួនអ្ងួក៏ភ័យស្ទុតស្ទាតើ នាំពាហានរត់គេចទៅតាមដើងកំពែង គួនអ្ងួកំដេញតាប់សម្លាប់ពាហានចាយិនស្លាប់ជាច្រើន ចាយិនក៏លើកទ័ពស្រួតទៅស្រុកហ្លួតោ កាលទៅដល់ពាក់កណ្តាលផ្លូវមានគេប្រាប់ដំណឹងថាឡៅភីធ្វើការសង្គ្រាមមានជ័យជំនះដូច្នេះ ព្រោះគំនិតតាន់ហុក ។

ឯឡៅពីយើញចាយិនចាញ់ដៃ ជួឡង់បែករត់ទៅដូច្នោះក៏នាំតាន់ហុក ទន់ពាហានចាំងពួង លើកតាមទៅដល់ស្រុកហ្លួនសៀ ជាំងរឿងរ៉ាវថាគួនអ្ងួយកទាន់ស្រុកហ្លិនសៀហើយ ចាយិនទន់ងល់ទៀនាំគ្នារត់ទៅស្រុកហ្លួតោវិញ ។ ឡៅពីក៏លើកពាហានទន់ធ្ងន់ចូលទៅស្រុកហ្លិនសៀ ឯឡៅពិតដែលជាអ្នករក្សាស្រុកហ្លិនសៀ ជាពូជព្រះរាជវង្សព្រះចៅហៀនតេ ជាប់សែជាមួយទន់ឡៅពី លុះដឹងថាឡៅពីលើកទ័ពមកក៏មានសោមនស្សណាស់ ទើបចេញមកអញ្ជើញឡៅពីចូលទៅក្នុងស្រុក ហើយក៏រៀបចំតែងតុះលៀងឲ្យឡៅពីនឹងសេនាពាហានបរិភោគ ។ ណៈដែលឡៅភីកំពុងបរិភោគអាហារនោះ ឃើញក្មួយឡៅពិតទៅដំខន់តួបរួបពាងស្រស់ប៉ស់ឈរពីក្រោយឡៅពិត ឡៅពីក៏សួរថា ដែលឈរពី

ក្រោយនោះឈ្មោះអ្វី ? ខ្មៅពិតដំរាបថា ឈ្មោះ " ខៅហង " ជាកូនបងស្រីខ្ញុំចាស កំព្រាអត់អាពុកម្តាយ ខ្ញុំចាសយកមកចិញ្ចឹមតាំងពីតូច ខ្មៅពីថា ខ្ញុំឃើញរូបរាងវ៉ាន់នេះស្រស់បស់ ក៏មានចិត្តអាណិតណាស់ អ្នកអនុញ្ញាតឲ្យខ្ញុំសុំយកខៅចិញ្ចឹមជាកូនធម៌ចុះ មិនជាអ្វីទេ ខ្មៅពិតបានស្តាប់ដូច្នោះ ក៏មានអំណរណាស់ ទើបហៅ " ខៅហង " ឲ្យចូលមកគំនាប់ខ្មៅពី ហើយអនុញ្ញាតឲ្យធ្វើជាកូនចិញ្ចឹមរបស់ខ្មៅពី ។ ក៏ប្រាប់ឈ្មោះ "ខៅហង" នោះចេញ ឲ្យឈ្មោះថា " ខ្មៅហង " វិញ ហើយនាំគ្នាទៅគំនាប់គួនអ៊ូ, ខៀវហ៊ុយឲ្យហៅថាម៉ា ។ គួនអ៊ូនិយាយនឹងខ្មៅពីថា បុត្រប៉ុស្តាន៍ក៏មានដែរ ហេតុម្តេចបើបយកអ្នកដទៃមកធ្វើជាសាច់ខៀត បើដូចគេចិញ្ចឹមកូនឆ្កែញាំង យូរទៅនឹងបានសេចក្តីក្តៅក្រហាយទេដឹង ? ខ្មៅពីតបថា ទោះបីអ្នកដទៃក្រៅសាច់មែន តើយើងស្រឡាញ់ស្មើបុត្រ បានជាយកមកចិញ្ចឹមទុកគង់តែនឹងមានចិត្តកតញ្ញូតទៅ ទោះយ៉ាងណាក៏មិនមានចិត្តនឹងធ្វើអន្តរាយដល់យើង ។ គួនអ៊ូឮដូច្នោះក៏ពាល់គំនិតមិនធ្វើយថាប្រការម្តេចឡើយ ។

ខ្មៅពីនឹងគាន់ហុកក៏ប្រឹក្សាគ្នា ឲ្យដួងឆ្នាំពាហាន ១ ពាន់នៅរក្សាស្រុកហ៊ួនសៀ ហើយខ្មៅពីនឹងគាន់ហុកក៏នាំអ៊ូគួន ខៀវហ៊ុយត្រឡប់លើកទ័ពទៅស្រុកសុំនអៀវិញ ។

ឯថោយនឹងលិខៀនចូលទៅដល់ស្រុកហ៊ូតោក៏នាំគ្នាទៅគំនាប់

ចូចូ អធិប្បាយរឿងពាំនងពួនដំកបចូចូ ហើយកំយំអង្វរសូមទោស ។
ចូចូក៏តបថា អ្នកកុំតែក្តព្រួយឡើយ ឯធម្មតាសង្គ្រាមនឹងចំណង
យកជ័យជំនះតែមួយយ៉ាងក៏មិនបាន រមែងចាញ់ខ្លះឈ្នះខ្លះ ជាធម្មតា
តែយើងគិតសង្ឃឹមថា ទៀតពីធ្វើការបានដល់ត្រឹមណេះយើញលើស
ហួសណាស់ ប្រហែលមានអ្នកឯណាជួយរិះគិតឲ្យ ។ ចាយិនតបថា ខ្ញុំ
បានដឹងដំណឹងថា ទីប្រឹក្សាគិតការពាំនងពួនឲ្យទៀតពីនោះឈ្មោះថា តាន់
ហុក ចាយិនសួរថា តាន់ហុកនោះគឺនរណាអេះ? ពីដើមឈ្មោះសំ
ឡេងមិនប្រាកដ ដៀយ៉ុកបានឮក៏អស់សំណើចហើយថា តាន់ហុកនោះ
ពីដើមឈ្មោះឈើស៊ីនៅស្រុកអេងដីវ៉ា តាលពីកំឡោះនោះជាមនុស្ស មាន
ពួកកៀនច្រើនរៀនវិជ្ជា ក្រោយពីនោះមកបានសម្លាប់គេស្លាប់
ហើយភៀងធ្វើអាការជាឆ្កួត លុះគេចាប់បានយកខ្លួនទៅវាយតិចារណា
ក៏មិនបានធ្វើយប្រាប់ឈ្មោះនឹងហេតុផល ដែលប្រព្រឹត្តដោយតិតភៀងធ្វើ
ស្ងៀមមិនដឹង អ្នកតិចារណាទើបយកខ្លួនទៅចងជាក់លើរទេះបរទៅជុំវិញ
ស្រុក ស្រែកអាក្រាសវ៉ាយតនឹងឈ្មោះសួរពួកឈ្មោះថា នរណាស្គាល់ឈ្មោះ
នេះខ្លះ? បណ្តាអ្នកស្រុកតាមទីផ្សារពាំនងពួន ដែលស្គាល់ឈ្មោះឈើស៊ី
ភ្ញាចមិនហ៊ានប្រាប់ឈ្មោះ លុះបណ្តើរទៅដួចនឹងពួកម៉ាកឈើស៊ី ពួក
ម៉ាកក៏ចូលជណ្តើរយកខ្លួនឈើស៊ីបាន ឈើស៊ីក៏តត់ទៅរៀនវិជ្ជានៅនឹង

សុមាតេតកធោផ្ទាស់ឈ្មោះថាតាន់ហ៊ុកដរាបដល់សព្វថ្ងៃនេះ ។

ចូធូឮដូច្នោះក៏សួរថា ឈីសុីមានប្រាជ្ញាឆ្លាតម្រះរិះគិតស្មុគឆ្លាតអ្នកឬ? ធៀយ៉ុតដំរាបថា ឈីសុីមានបញ្ញាឆ្លាតគំនិតគិតនោះជាជាងខ្ញុំបាទច្រើនណាស់ ។ ចូធូថា ទៀតពីបានអ្នកមានប្រាជ្ញាឆ្លាតគំនិតរិះគិតទៅខុតជាពីប្រឹក្សា ឃើញឆ្លាតមានចិត្តកំរើកធំឡើងទៀត ធ្វើម្តេចយើងនឹងបានខ្លួនឈីសុីមកខុត កុំឲ្យទៀតកំរើកធំឡើងបាន ។ ធៀយ៉ុតធ្វើយថា បើលោកមានសេចក្តីប្រាថ្នាឆ្លាតចង់បានឈីសុីមកខុតនោះឆ្លាត កអ្វីទោះបីឈ្មោះនេះបានជាទៅនៅឆ្លាតទៀតីហើយក្តី ខ្ញុំបាទឆ្លាតរិះគិតកៃឲយកខ្លួនមកជូនលោកបាន ។ ចូធូសួរថា អ្នកឆ្លាតរិះគិតយ៉ាងម្តេច? ធៀយ៉ុតធ្វើយថា ដែលខ្ញុំបាទឆ្លាតយកឈីសុីមកនោះ ព្រោះខ្ញុំបាទដឹងប្តូរគល់ចិត្តឈីសុីថាជាមនុស្សក្រតញ្ញូណាស់ ឯបិតាស្លាប់ហើយទៅតមាតាជាមនុស្សដក ។ ណៈកាលឈីសុីនឹងដើរចេញពីមាតានោះ មានឈឺឆ្ងាំជាប្អូនប្រគល់ចិត្តមាតាជាជំនួស ឥឡូវ ឈឺឆ្ងាំជាប្អូនស្លាប់ទៅទៀត មាតាក៏កំព្រាអនាថាគ្មាននរណានៅបំរើសោះ សូមលោកឲ្យទៅហៅមាតាឈីសុីមកចិញ្ចឹមរក្សាហើយនិយាយលួងលោមថ្នមចិត្ត ឲ្យមានសំបុត្រទៅដល់ឈីសុីជាសំបុត្រឲ្យចូលមក ក៏ឃើញថាឈីសុី មានកតញ្ញូនឹងម៉ាតានឹងលះបង់មិនបាន គន់នឹងមក ។

ចូធូបានឮដូច្នោះក៏មានអំណរត្រេកចិត្ត ទើបប្រើបំរើឲ្យទៅនាំ

មាគាឈើស៊ីមកចិញ្ចឹមជាប្រក្រតី ហើយចូធ្លក់លួងលោមថ្នមចិត្តថា ឥឡូវយើងដឹងថា បុត្រៃបស់អ្នកម្ចាស់មានតម្រេះប្រាជ្ញាណាស់ ទៅខ្មៅនឹងខ្លៅពីដែលជាសត្រូវក្បត់ផែនដីយើញថាមិនគួរសោះ បីដូចគេយកតែមណីទៅចោលទុកក្នុងជ្រាំ សម្រាប់តែអ័បរស្មីទៅ សព្វថ្ងៃយើងគិតស្គាយពេកណាស់ ហើយមានចិត្តអាណិតដល់អ្នកផង ទើបឲ្យទៅទទួលមកប្រាប្តាឲ្យមានសំបុត្រទៅដល់ឈើស៊ីបុត្រអ្នក ឲ្យមកនៅធ្វើការជាមួយនឹងយើងក្នុងស្រុកក្រុង យើងនឹងបានជួយពិតខ្លួលព្រះចៅហៀនតែតាំងឲ្យធ្វើនាម៉ឺនធំតទៅ ហើយចូធ្លក់ឲ្យយកថ្នុះទឹកភ្នែនក្រដាសនឹងពិតមកប្រគល់ឲ្យសរសេរសំបុត្រ មាគាឈើស៊ីក្លែងសួរចូធ្លថា ដែលឈ្មោះថាខ្លៅពីនោះជាបុត្រអ្នកឯណា លោកស្គាល់ច្បាស់ឬទេ ?

ចូធ្លធ្វើយថា ខ្លៅពីនោះជាពួកស្រុកខ្ញុំនគួន ជាមនុស្សអែនាថា ឥតពូជត្រកូល កុហកចរចាឆបញ្ឆោតឲ្យមនុស្សចាំងពួនដើរថា ពូជព្រះពជវង្សព្រះចៅហៀនតេ ក្លែងធ្វើអាការឲ្យយើញថាជាមនុស្សសុភាពត្រឹមត្រូវតែលំនាំខាងក្រៅ ឯចិត្តថ្មើមមិនមែនខៀងត្រង់នឹងអ្នកឯណា ឱគាឈើស៊ីពូជប្លែកគំនឹងណាស់ ស្រែកគំហកឲ្យចូធ្លថា ឯងនេះជាមនុស្សអាក្រក់ណាស់ មិនមានអៀនខ្មាសសោះថែមលើកតោសខ្លៅពីថាជាមនុស្សមិនល្អ ឯខ្លៅពីនោះអញស្គាល់មកយូរហើយ គឺជាពូជព្រះពជ-

វង្សព្រះចៅហៀនតេជ្ញាកជ ពាំងចិត្តថ្លើមគេកំសុចរតេជ្ញត្រង់នឹងផែនដី មានសេចក្តីល្អសុភាពជល់អាណាប្រជានុរាស្ត្រ សូម្បីតែក្មេងចៅដែកំដឹងស្គាល់ថា ខ្លៅពីជាមនុស្សល្អ ឥឡូវកូនអញទៅនៅនឹងខ្លៅពីកំជាខំសំណាក់ដ៏ធំទូលាយណាស់ហើយ ឯខ្លួនឯងដែលថាជាមនុស្សសុចរតេជ្ញត្រង់នឹងដួយទំនុកបំរុងផែនដីព្រះចៅហៀនតេនោះ អញកំដឹងថាឯងជាសត្រូវរាជសម្បត្តិវិញទៀត ដែលនឹងឲ្យកូនអញច្រាសចាកខ្លៅពីមកនៅធ្វើរាជការនឹងឯងវិញនោះ កំប៉ាដូចចេញពីទីភ្នំមកចូលទៅក្នុងទីងងឹតមិនគួរសោះ ថាហើយកំកន្ត្រាក់ថ្នដុះទឹកភ្នែកចោលសំដៅចូឆ្ង ។ ឃើញមាគាឈីស៊ីធ្វើអាការមើលងាយប្រមាថដូច្នោះកំនឹកឱនណាស់ស្រែកបង្គាប់ឲ្យតាហានចាប់យកខ្លួនមាគាឈីស៊ី ទៅសម្លាប់ចេញ ។ ឯយ៉ុកឃើញតាហានយកមាគាឈីស៊ីទៅដូច្នោះ កំចូលទៅឃាត់ហាមតាហានឲ្យបង្អង់ហើយចូលទៅដាំរបចូឆ្ងថា ដែលមាគាឈីស៊ីប្រមាថមើលងាយលោកដូច្នោះ ព្រោះច្រើនឱនចង់ស្លាប់ឲ្យច្រើនដងក្តៅឈ្មោះទុកជាស្រីតាហានអង់អាច ឬនជាមើលងាយប្រមាថមហាឧបរាជ មិនមានកោតក្រែង បើថាលោកនឹងសម្លាប់ចេញគ្រានេះកំនឹងមានសេចក្តីតរហានិន្ទាជាច្រើនថាសម្លាប់ស្រីដូចសម្លាប់កូនក្មេង មិនត្រូវការសោះ មួយទៀតបើ មាគាឈីស៊ីស្លាប់ហើយ ដំនៅដល់ឈីស៊ីកំនឹងមានចិត្តអាឃាតព្យាបាទលោកជា

ខ្ញុំនឹងទៅទៀត នឹងជួយទៅពិគ្រោះធ្វើការជាមាំមួនជាយកវិយោសនឹងសឹក សូមកុំឲ្យលោកសម្លាប់ស្រីនេះឡើយ គួរនឹងចិញ្ចឹមពុកសិន ទោះឈឺស៊ុនឹងធ្វើការជួយទៅពីតទៅមុខក៏ជាការរ៉ាំងដល់មាតា ឃើញថានឹងមិនគិតការពេញដៃ ក្រោយនេះខ្ញុំចុះនឹងគិតកលទុបាយយកប្លុងឈើ-ស៊ុមកឲ្យពាល់តែបាន ។ ចូរគួបានស្តាប់ក៏យល់ត្រូវ ទើបឲ្យលើកលែងមាតាឈើស៊ុចេញទៅ មិនឲ្យសម្លាប់ ទើបចាត់ចែងទីលំនៅតាមសមគួរ ហើយក៏ចិញ្ចឹមព្យាបាលឲ្យនៅជាសុខ ។

ថ្ងៃមួយ ធៀយ៉ុកក៏ចូលទៅសួរសុខទុក្ខមាតាឈើស៊ុហើយប្រាប់ថាបុត្រអុកនឹងខ្ញុំជាមិត្តសំឡាញ់នឹងគ្នាមកពីដើម អ្នកដែលជាមាតាឈើស៊ុក៏ជួបជាមាតាខ្ញុំដែរ មាតាឈើស៊ុពុជឮពោះក៏សំគាល់ថាពិត មានសេចក្តីក្រែងអណាស់ តាំងពីថ្ងៃនោះមក ធៀយ៉ុកក៏ឲ្យយកចំណីអាហារនឹងរបស់គួរសមទៅឲ្យមាតាឈើស៊ុរឿយ ។ ហើយសរសេរសំបុត្រទៅគំនាប់ពាល់ដន មាតាឈើស៊ុក៏សរសេរមកវិញជាសេចក្តីគបគួរសមតាមប្រពៃណី លុះធៀយ៉ុកបានសំបុត្រមកហើយ ក៏ហាត់សរសេរឲ្យចំណាន ដូចលាយដៃមាតាឈើស៊ុ ហើយក៏តាំងសរសេរសំបុត្រសំនួរ ១ ច្បាប់សេចក្តីថាយើងជាមាតាប្រាប់មកឈើស៊ុជាបុត្រឲ្យបានដឹង ដ្បិតឈើខនជាប្អូនរបស់ឯងនោះមានឪម្នាឈើជាខ្លាំងស្លាប់ទៅហើយ ។

(មានត)

៦៦_ អ្នកណាដែលមើលឃើញ គឺ មើលឃើញចំពោះខ្លួនឯងតែ អ្នកណាដែលមើលមិនឃើញ គឺ ជាសត្រូវនឹងខ្លួនឯង ។

៦៧- បើតាមពិត វត្ថុឯណាដែលគេសន្យាថានឹងឲ្យអ្នក គេនឹងឲ្យ ពិតប្រាកដ គេមិនអាចបោកប្រាស់អ្នកទេ ។

៦៨_ ប្រជាជាតិមួយ ។ មានកាលសម័យដែលគេកំណត់ខុសជា មុនស្រេច, ហើយបើកាលវេលានោះដល់ហើយ, ប្រជាជាតិនោះមិនអាច នឹងបន្តយពេលវេលា ឲ្យទៅក្រោយ ឬបង្កើនពេលវេលា ឲ្យលឿនមួយ ម៉ោងទៅមុខបាន ។

៦៩- ប្អូនអ្នកកុំធ្វើដូចអ្នកខ្លះពោលថា: « យើងបានឮ » តែអ្នក នោះមិនដែលឮអ្វីសោះឡើយ ។

៧០_ គ្មានអ្នកណានឹងបានទៅដល់តាមវត្ថុបំណង បើអ្នកនោះគ្មាន ទុន្តី គ្មានជោគវាសនានឹងទទួលសុភមង្គលបានឡើយ ។

៧១_ អ្នកណាដែលដឹងពិតប្រាកដថាត្រូវពោលពាក្យបែបណា ទើប

ចានឮសំឡេងពិរោះពីសា. អ្នកនោះមិនអាចនឹងបញ្ចេញនូវចិត្តទន់ជែងបានឡើយ ។

៧២- មូលដ្ឋាននៃពិភពលោកនេះ គឺការក្តុច, ការថ្នង់ ការស្តិតនៅស្ងៀមនិយាយមិនរួចរេ, ការត្រឡប់ចាត់ស្មារតី ។

៧៣-ព្រះសុរិយាមួយអាចបំភ្លឺ កុំឲ្យក្តែកឯងឃើញស្រមោលមួយហ្នឹងបាន ។

៧៤ មហាសាគរ បើមានរលក តើគំនូសដែលគូសនៅលើទឹកស្តិតនៅម្តេចបាន ។



ស្រី - អ្ហ៊ូ រៀបរៀង

(ត្រង់)

ហេតុដូច្នេះបានជាលោកប្រដៅថា :

ផ្លូវរៀបកុំបាបង់ ផ្លូវណាត្រង់កុំជើរហៅង
ជើរដោយផ្លូវគន្លង តម្រាយអ្នកបាស់បុរាណ ។

ម្យ៉ាងទៀត គួរអធិប្បាយថា: ផ្លូវដើរដោយដើងក្តី ផ្លូវសម្រាប់ឋរនេះក្តី ដែលចេញពីភូមិ១ ទៅភូមិ១, ចេញពីស្រុក១ ទៅស្រុក១, ដែលបាស់បុរាណមុន។ ភ្ជាប់ទៅមក ប្រស្រ័យគាត់ទន្ទឹងគ្នា ដោយការចិញ្ចឹមជីវិតតែផ្លូវនោះរៀបរាល់ គាំទ្រដល់ណើរយូរបន្តិច បានជាផ្លូវនោះរៀបរាល់ ព្រោះគាត់តម្រង់ទៅពុំរួច ដោយមានទុបស័គ្គ គឺអូរ ចិញ្ច្រាំង ថ្កុំ មានតយន្តភាយ ដោយសត្វសាហាវជាដើម បានជាគាត់តំរង់ទៅពុំបាន ហេតុនេះបានជា បាស់បុរាណ ពានផ្លូវរាល់រៀបបន្តិច តែទៅមកបានដោយស្រួល ផ្លូវរាល់បែបនេះ ជាគន្ធទ្ធតម្រាយរបស់អ្នកជាន់មុនបានត្រាយទុកមក កុំឲ្យក្លែនចៅជាន់ក្រាយលះបង់ចោល ។ ផ្លូវត្រង់វិមន តែបើមានតយន្តភាយនៅស្ទះ កុំដើរទៅឲ្យសោះ ត្រែងមានគ្រោះថ្នាក់ ។ ត្រង់នេះ

ហើយដែលលោកថា " ផ្លូវណាត្រង់កុំដើរហាន " មិនមែនហាមយាត់ដល់ផ្លូវដែលត្រង់ហើយសុទ្ធស្រួលនោះទេ ។

២៩- ឆ្កែជាឲ្យបាយធំ ដេកនៅជិតចាំធនជាន គ្រឿងសឹកទុកទាហាន[1] ក្បែគម្ពីរទុកប្រាជ្ញប្រាយ ។

អធិប្បាយ- ត្រង់បទថា ឆ្កែជាឲ្យបាយធំ ដេកនៅជិតចាំធនជាន បានសេចក្តីថា ឆ្កែល្អមានមារយាទត្រឹមត្រូវចេះស្គាល់សត្រូវ គឺសត្វព្រៃចូលមកក្នុងភូមិ ឬ ស្គាល់ចោរចូលមកក្នុងពេលយប់ ហើយព្រុះបង្អើលដេញចាំ មិនឲ្យសត្រូវចូលមកបាន ឆ្កែបែបនេះឈ្មោះថា ឆ្កែជា ត្រូវឲ្យបាយវាបរិភោគ ដើម្បីនឹងជួយការពារទ្រព្យសម្បត្តិយើង ។

ត្រង់បទថា គ្រឿងសឹកទុកទាហាន បានសេចក្តីថា គ្រឿងចម្បាំងដូចយ៉ាងគាំក្តើងតូច-ធំ គ្រាប់-រំសេវជាដើម គេតែងទុកជាក់នៅលើក្រុមទាហាន ព្រោះទាហានជាអ្នកទទួលការៈខាងការពារសន្តិសុខ ។

ត្រង់បទថា ក្បែគម្ពីរទុកប្រាជ្ញប្រាយ បានសេចក្តីថា ក្បួនច្បាប់ គម្ពីរ ជីវិត សៀវភៅផ្សេងៗ ជាសម្ភារៈរបស់អ្នកប្រាជ្ញ, រីឯជនដែលមាននាមថាជាបណ្ឌិតជាអ្នកប្រាជ្ញ តែងមានគម្ពីរក្បួនច្បាប់ជាច្រើន ។

1- សាស្ត្រខ្លះថា គ្រឿងសឹកទុកជាហ៊ាន ។

៣០ យល់តួចកុំអាលទំ ទោះយល់ធំកុំអាលស្រាយ
គិតក្តីកុំគិតដាយ មើលពិនិត្យពិនិស្ស័យ ។

អធិប្បាយ - ពាក្យថា « យល់តួចកុំអាលទំ » គឺយល់ថា ការងារ ឬមុខរបរណា មិនសូវមានប្រយោជន៍ច្រើនទេ ការងារ ឬ មុខរបរនោះ គេតែងបង្អន់មិនប្រញាប់ធ្វើ គេតែងធ្វើចំពោះការងារ ដែលមានប្រយោជន៍ច្រើនសិន, ឬក៏ ឮដំណឹងអ្វីមួយ មិនដាំកុំកួនទេ គេមិនស្ទុះស្ទាវៗភ្លាមឡើយ។ ពាក្យថា យល់ធំកុំអាលស្រាយ បានសេចក្តីថាបើពិចារណាឃើញថាការងារនោះ មានផលប្រយោជន៍ច្រើន មានតំរៃច្រើន គេមិនថ្លង់ច្រាប់គេភ្លាម ។ ទេ ដូចគាសិតមួយថា កុំស្រាយបង្កៀចកណ្តាលធ្យូរ ។ ពាក្យថា គិតក្តីកុំគិតដាយ បានសេចក្តីថា ការគិតត្រិះរិះក្តីកាំ កុំយល់ថា ដំណើរក្តីជាការងាយស្រួលនោះ រឿងក្តីជាការក្រៃបំផុត ដូចគាសិតថា "ធ្ងន់ក្រៃណានឹងឮក្រៃក្រៃណានឹងក្តី" ហេតុនេះបើកើតរឿងក្តី គេតែងពិនិត្យពិចារណាឲ្យហ្មត់ចត់ គេតែងស្មើស្មរយោបល់ច្បាប់តុលាការសិន បើគេឲ្យយោបល់ថាគួរនឹងក្តីបាន ទើបក្តីនោះនឹងបានឈ្នះដូចបំណងបាន ឈ្មោះថា មើលពិនិត្យពិនិស្ស័យ ។

៣១- ក្លួនអើយកើរ្តិមេបា ឬរកឬបាំសឲ្យប្លែ

ទ្រព្យធនទោះហៀកថ្លៃ រួមរក្សាកុំបីឆ្ងោយ ។

អធិប្បាយ_ ម្នាលកូនប្រុសស្រីចាំឆ្លាយ ! ទ្រព្យធនអ្វីៗ ដែលជាកេរ្តិ៍ដំណែលរបស់មាតាបិតាដ៏ជូនដីតា ចែកទុកមក គួររក្សាឲ្យគង់ ឲ្យចាស់ថ្លៃ កុំឲ្យក្ងេច ទោះបីទ្រព្យធននោះ មានដម្លៃតិចក្តី ច្រើនក្តី រួមរក្សាថែទាំប្រមូលទុកឲ្យគង់ កុំបីឆ្ងេសប្រហែសឡើយ ។

៣២- ពាក្យនេះជាត្រកាល ជាខ្លឹមសារទៀងទុកឲ្យ
កូនចៅតៗឯក្រោយ តែងទូន្មានអង្គអាត្ម ។

អធិប្បាយ- ពាក្យបណ្តាំទាំងអស់ ដែលបានពោលហើយនេះ ជាពាក្យមានសារៈ គឺជាពាក្យមានប្រយោជន៍ធំ ឥតមានអ្វីប្រៀបផ្ទឹមបានពាក្យនេះមិនឆ្ងល់ពិបាកទុកជាក់ដែ ជារបស់ស្រាលងាយរក្សា ងាយទុកជាក់ ទៅណាមកណា យកទៅជាមួយបាន មិនបាច់ម៉ៃរែកសែនដែ ។ ពាក្យនេះមេបាទុកឲ្យកូនចៅ កើតជាន់ក្រោយ សម្រាប់ទូន្មានខ្លួនគ្រប់ៗគ្នា ជានិច្ចនិរន្តរ៍តទៅ ។

៣៣- ថែទាំទើបគង់ទ្រព្យ រៀបរណ្តាប់ទុកទើបជា
ចាយវាយក្រៅតម្រា សឹងវិនាសធនជានផង ។

អធិប្បាយ_ គេតែងថែទាំ រក្សាមើលឲ្យគ្រប់សព្វ ទើបគង់សម្បត្តិ ហើយគេចេះរៀបចំទុកជាក់ តាមអណ្តាប់អណ្តោយ ឲ្យរៀបរយត្រឹមត្រូវ

ទើបល្អប្រពៃ ។ ការចាយវាយខុសរបៀប ការចាយវាយខ្ជះខ្ជាយ ការចាយវាយស្រេកត្រមៃ ជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិ ។

៣៤- បានមកទុកឲ្យគង់ កុំឲ្យបង់បាត់ជាម្ដង (១)
រៀនរិះរក្សាគ្រង យកបេញ្ចាយដោយរដ្ឋិវ ។

អធិប្បាយ:- ការស្វះស្វែងរកទ្រព្យសម្បត្តិបានមកនេះ ចាត់ជាការលំបាកណាស់ ហេតុនេះ គួរខិតខំរិះគិត រក្សាទុកឲ្យគង់ កុំឲ្យវិនាសអន្តរាយបាត់បង់ទៅខេ ។ ដោយឥតដំណឹងនោះ កាលបើនឹងត្រូវដកយកទៅប្រើប្រាស់ចាយវាយ គួរចាយវាយដោយការចាំបាច់, មិនគួរចាយ វាយដោយខ្ជះខ្ជាយឡើយ ។

៣៥- ដឹងហាបឲ្យដឹងដុល ភ្នែកឲ្យឃ់ល់ទៀងត្រាដូ
គិតគ្រប់សព្វដោយដ្ឋិវ ក្ដីបន្លោះកុំបីមាន ។

អធិប្បាយ:- គេតែងតែចេះដឹង តែងស្គាល់តម្លឹង, នាឡិ, ហាប, គីឡូ កាលបើគេទិញ ឬលក់របស់អ្វី ។ តែងតែដឹងចំនួនប៉ុន្មានតម្លឹង ប៉ុន្មាននាឡិ ប៉ុន្មានហាប, ប៉ុន្មានគីឡូ. ហើយតែងតែរៀនលៃស្ងួន របស់ចាំងជុំ ចាំងស្រុត តែងតែចេះប្រមាណការចាំងនេះ តែងស្គាល់ក្អែកជញ្ជីង ឲ្យច្បាស់លាស់ កុំឲ្យគេបន្ទំបាន ព្រោះកិច្ចការចាំងនេះ មិនជាការក្រខេ

១- សាស្ត្រខ្លះថា កុំឲ្យបង់បាត់បំណង ។

កើតមកជាមនុស្ស គួរគិតគូរឲ្យគ្រប់សព្វ កុំបណ្តោយឲ្យល្ងង់ខ្លៅ គួរ
ដឹងឲ្យសព្វថ្លូវ សព្វប្រក កុំឲ្យមានក្តីចង្អៀរឡើយ ។
៣៦-ពាក្យនេះស្មើខ្លិនហើយ កូនចៅអើយចាំសព្វប្រាណ[1]
អ៊ីសំអាបិទ្ធរិទាន ជាស្មរេបម្លេះឯងហោង[2] ។

អធិប្បាយ- ម្នាលកូនចៅចាំនឹងឮយ អាថ៌ធម៌ចាំនឹងឮយ ទឹងទុកដាក់ឲ
ជំបូន្មានចាំនឹងអស់នេះ គួរកាន់ទុកកុំឲ្យក្លេច ទុកស្មើខ្លួន គួរចងចាំ
គ្រប់ៗគ្នា កុំបីមានឡើយ ។

ចប់ស្រេចត្រឹមប៉ុណ្ណេះ ។



ទោន្តកេសុ ច យំ សិប្បំ បរមាត្ថេ ច យទ្ធនំ
យថា តិដ្ឋេបិ សម្បន្នេ ឆត្តំ សិប្បំ ឆត្តំ ធនំ
សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្មូតវត ឬសៀវភៅ
ទ្រព្យធនឯណាដែលមាននៅ ជាក់ទៅលើដៃអ្នកដទៃ ។
បើមានកិច្ចការណាដល់មក សិល្បទ្រព្យនោះយកមកអាស្រ័យ
ពុំបានដូចចិត្តដូរតែធ្វើយដៃ សិល្បទ្រព្យនោះនៃហៅគ្នាហោង ។

(លោកឥតិបកវណ៌)

១-សាស្ត្រខ្លះថា កូនចៅអើយចូរភ្ញាក្រាណ ។ ២-សាស្ត្រខ្លះថា ជាស្មរេបណ្តាំហោង ។

តាមឯកសាររបស់ក្រុមដំនុំទំនៀមទម្លាប់

ដើមកំណើតរឿងភមកេរ្តិ៍

លោក ចាប-ពិន រៀបរៀង

ប្រទេសខ្មែរយើងជាប្រទេសពាប់អានរឿងភមកេរ្តិ៍តាំងពីសម័យ ព្រេងនាយរហូតដល់សម័យបច្ចុប្បន្ននេះ ព្រោះខ្មែរបុរាណបានបង្ហាត់ បង្រៀនរឿងនេះតៗគ្នាមក ដោយនិយាយឲ្យស្តាប់ ដោយចារសាស្ត្រាស្តឹកតែត សរសេរគ្រាំងជាភាព្យហ្មាងយ៉ាងពីកេះពិសា ដោយលេងល្ខោន មានល្ខោនខាល នឹងល្ខោនស្បែកជាដើម ដោយផ្ទាត់ប្តូរនៅជញ្ជាំងព្រះវិហារជញ្ជាំងច្រុងសាទឲ្យមើល ។

រឿងភមកេរ្តិ៍ច្បាប់ដើមបំផុតកើតនៅប្រទេសណា ? ក្នុងសម័យណា ? នរណានិពន្ធ ?

តាមការស្រាវជ្រាវរបស់ក្រុមដំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ យើញថា: រឿងភមកេរ្តិ៍ច្បាប់ដើម ហៅថា រឿងភមាយណ: កើតនៅប្រទេសវណ្ឌៀ ក្នុងសម័យពុទ្ធសករាជ ៧៩០ គ្រិស្តសករាជ ២០៩ តាបណ្ឌិតម្នាក់ឈ្មោះ វាល្មីកិ បាននិពន្ធជាមហាភាព្យភាសាសំស្ក្រឹតនិយាយពីរឿងព្រះភម យ៉ាងពិស្តារ ពីកេះពិសាណាស់ ។

តមក ពាក្យភាព្យរឿងភមាយណ: (ភមកេរ្តិ៍) រឿងព្រះភមភាសា

ប៉ុស្តិ៍នោះ គឺផ្ទុយទេញពីខែត្រមួយទៅខែត្រមួយ ពីប្រទេសមួយទៅ
ប្រទេសមួយ ។

ចំណែកគាលគមក នានាប្រទេសបានប្រែពាក្យភាសារឿងនេះពីភា-
សាសំស្ក្រឹតមកជាភាសាជាតិរបស់ខ្លួន ។ ខ្មែរយើងក៏បានប្រែមកជា
ភាសាខ្មែរដែរដាក់ឈ្មោះថា (រឿងពាមក្ដើ) រឿងនេះក៏ទៅជាចេតិយ-
ស្ថានមួយ សម្រាប់អក្សរសាស្ត្រ ទំនៀមសាសនា បញ្ជាក់នូវគំនិត
នឹងការធ្វើសម័យបុរាណរបស់ប្រទេសផ្សេងៗទៅលើនានាប្រទេស ។

ពាក្យភាសារឿងពាមាយណៈភាសាសំស្ក្រឹត នៅប្រទេសផ្សេងៗ
មានបែបបទដូចម្តេច រឿងពាមាយណៈដែលនានាប្រទេសបានប្រែផ្សាយ
ដោយតែងជាពាក្យភាសា តាមភាសារបស់ខ្លួនតៗគ្នាមក តើមានបែបបទ
ដូចគ្នាដែរឬប៉ុន្មានដោយអំណាចទំនៀមទម្លាប់ស្រុក នឹងអំណាចអក្សរសាស្ត្រ
របស់ប្រទេសទីមួយ ។ ចូលទៅផ្នែកផ្សេងផង តើសេចក្តីប្រែនោះទៅជាមិន
សុទ្ធដូចច្បាប់ដើមជាភាសាសំស្ក្រឹតនោះឡើយ ហើយរឿងពាមាយណៈ
នោះក្លាយទៅជាពាក្យភាសាមួយយ៉ាងធំ សម្រាប់ប្រជាជាតិនីមួយ ។
ទៅលើរឿងនេះ ។

[illegible]

ពាក្យកាត្បាវរឿងពាមាយណៈបានចូលមកដល់ប្រទេសខ្មែរយើងតាមផ្លូវណា ? សម័យណា ?

តាមការពិនិត្យនឹងការស្រាវជ្រាវរបស់អ្នកប្រាជ្ញ នៅប្រទេសឥណ្ឌា និងប្រទេសអឺរ៉ុប យើងដឹងថា រឿងពាមាយណៈបានផ្សាយដោយសារសេចក្តីប្រែរបស់ស្រុកប៍ធីត (ឥណ្ឌា) និងដំបន់ឥណ្ឌាបែកខាងត្បូងមកតាមប្រទេសជ្វា និងម៉ាឡេស៊ី ទើបចូលមកដល់ប្រទេសខ្មែរយើងក្នុងសម័យអង្គរ ហៅថា រឿងពមក្តី ហើយផ្សាយពីប្រទេសខ្មែរទៅប្រទេសថៃនិងប្រទេសលាវ ។

សព្វថ្ងៃនេះ នៅប្រទេសជ្វា_ថៃ_លាវ និងខ្មែរ ដនជាតិទាំងនេះនៅនិយមរឿងពមក្តីនៅឡើយ ។ ចំពោះប្រទេសខ្មែរយើង គេតែងយករឿងនេះដោយអន្ទឹ ។ មកលើលោនានា មានលោនសែ្មក និងលោនព្រះពជ្រឲ្យជាដើម ។

ក្នុងថ្ងៃរឿងទាំងមូល រឿងដែលអ្នកស្រុកចូលចិត្តជាងគេ គឺត្រង់កន្ទេងដែលរាពន៍ឆក់ព្រះនាងសិតា ។

រឿងពមក្តី គេមានតួរជាលំអនៅជញ្ជាំងព្រះវិហារជាច្រើនក្នុងប្រទេសខ្មែរ_លាវ និងប្រទេសថៃ ។

ប្រទេសកម្ពុជាយើងមានតួរគំនូររឿងពមក្តីដុំជាតិ នៅដុំវិញជញ្ជាំង

ថ្ងៃ នៃព្រះវិហារព្រះកែវមរកត គួរប្រសើរឡើងវិញ ដែលបានធ្វើបុណ្យឆ្លងព្រះវិហារនេះ នៅឆ្នាំខាលចត្វាស័ក ព.ស. ២៤៤៤ គ.ស. ១៩០៣ ក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណគោដ្ឋ) ។

តាមឯកសារមួយបែបទៀតចែងថា :

សម័យអង្គរ ក្នុងសតវត្សរ៍ទី ១៣ នៃពុទ្ធសករាជ សតវត្សរ៍ទី ១៦ នៃគ្រិស្តសករាជ ព្រះមហាក្សត្រខ្មែរ ព្រះនាមសូរ្យវរ្ម័នទី ២ ទ្រង់បានសាងប្រាសាទនគរវត្ត ទ្រង់ឲ្យធ្វើរឿងរាមកេរ្តិ៍ជាច្រើនអន្ទោ នៅជញ្ជាំងប្រាសាទនគរវត្ត មានរឿងត្រង់ព្រះរាមទ្រង់ថ្វែងសរប្រឡងរំដែលណ្តើមព្រះនាងសីតា ត្រង់ហនុមានយកចិញ្ចៀនព្រះទម្រង់ទៅថ្វាយព្រះនាងសីតា. ត្រង់ព្រះរាមទ្រង់ឲ្យព្រះនាងសីតាចូលភ្លើង ដើម្បីសំដែងសេចក្តីស្មោះត្រង់. ត្រង់ទេវតាទឹងរៈសុរាញព្រ័ត្រប្រឡងទ្វេគ្នា ដែលយកនាគឈ្មោះវាសុកីជាព្រ័ត្រ ទេវតាញាងក្សាលនាគ អសុរាញាងកន្ទុយនាគ . . . ជាដើម (ដែលជាដើមកំណើតនៃល្បែងញាញព្រ័ត្រយើង) ។

អាស័យដោយភស្តុតាងដូចរៀបរាប់ខាងលើនេះ សូមអស់លោកជ្រាបដោយសង្ខេបថា :

រឿងរាមកេរ្តិ៍ មិនមែនជាមរតករបស់បុព្វបុរសខ្មែរយើងទេ ជារឿងកើតដំបូងបំផុតនៅប្រទេសឥណ្ឌា គឺកវីបណ្ឌិតឈ្មោះវាល្មីកីតែង

ឡើង ក្នុងរវាងសតវត្សរ៍ទី ៨ នៃពុទ្ធសកាជ ទី ៣ នៃគ្រិស្តសកាជ ហើយបានផ្សាយចូលមកដល់ប្រទេសខ្មែរយើង ក្នុងរវាងសតវត្សរ៍ទី ១៧ នៃពុទ្ធសកាជ ទី ១២ នៃគ្រិស្តសកាជ គឺសម័យអង្គរ រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ហើយខ្មែរយើងកាប់អានរឿងរាមកេរ្តិ៍នេះ រហូតមកដល់សម័យបច្ចុប្បន្ន ។

តែទោះបីយ៉ាំងណាក៏ដោយ រឿងរាមកេរ្តិ៍ ដែលបានផ្សាយមកជាច្រើនសតវត្សរ៍ហើយ គេកាប់ថាជារឿងសំខាន់ ១ សម្រាប់ជាតិខ្មែរក្នុងចំណោមរឿងផ្សេង ។ ទៀត ។

រឿងរាមកេរ្តិ៍ ជារឿងយោសនាឲ្យដឿសាសនាព្រាហ្មណ៍ ដូចរឿងជាតក មានមហាវេស្សន្តរជាតកជាដើម ជារឿងយោសនាឲ្យដឿសាសនាព្រះពុទ្ធ ។ ពួកព្រាហ្មណ៍គេដឿថា ព្រះរាមជាអវតារ (បែងភាគ) អំពីព្រះនារាយណ៍មកជួយស្រោចស្រង់លោក ដូចគ្នាទឹងព្រះសម្មាសម្ពុទ្ធ ។

រឿងរាមកេរ្តិ៍ ជារឿងពិស្តារឆ្ងាយទូលាយណាស់ តែពេលនេះសូមសន្ទនាពោលអំពីដើមកំណើតរឿងនោះ ដូចតទៅនេះ ថា :

ថ្ងៃមួយឥសីឈ្មោះ វាល្មីកិ សួរឥសីឈ្មោះ នារទៈ ដែលចេះចប់ត្រៃពេទ ច្រើដូចនឹងកេហារ ថា "បពិត្រលោកនារទៈ ! ក្នុងលោក តើនរណាជាវីរបុរស ប្រកបដោយគុណធម៌ យុត្តិធម៌ មានគតិបណ្ឌិតនឹងចរិយោ

ថ្ងៃថ្ងូ មានមុខញញឹមស្រស់ជានិច្ច មានឥន្ទិយុដ្ឋិផ្សាយខ្លួនទៅក្នុងសកល-លោក តោះបើទេវតាក៏មិនអាចបៀតបៀនបាន ?

ឥសីនារទៈ សំឡឹងមើលព្រៃលោក ហើយឆ្លើយថា :

ខ្ញុំ ! ព្រះមុនី ខ្ញុំស្គាល់ហើយ រឿបុរសនោះ គឺព្រះពុទ្ធ ដែលជាបុប្ផានៃវង្សវេស្សភូ (ភាសាបាលីថា "វេស្សភូ:") ព្រះអង្គមានព្រះប្រាជ្ញាណគ្មាហាន មានវិជ្ជាសាស្ត្រ ឧត្តមប្រពៃណាជាងបុរសទូទ្រគ្រាលឥតផ្ទឹមស្មើ មានព្រះហស្តរឹងមាំ ដើមព្រះទពធំ ព្រះនេត្រចេញរស្មីផ្លេកៗ ព្រះទ័យសប្បុរស ព្រះវិចារណញ្ញាណជ្រាលជ្រៅដូចមហាសាគរ ជំហររឹងដូចភ្នំហេមពាន្ត កម្លាំងដូចព្រះវិស្ណុ លំអដូចព្រះចន្ទ វីរៈដូចប្រើថាមឬនាងគន្ធិនធរណី ទ្រង់ចេះចប់ត្រៃវេទ ។

ព្រះបិតាព្រះពុទ្ធ គឺព្រះបាទសុទ្ធោទនៈ សោយរាជសម្បត្តិនៅព្រះនគរកបិលវត្ថុ ទ្រង់មានព្រះបំណងនឹងបង្អែរពាជ្យព្រះពុទ្ធមានព្រះពុទ្ធ ប៉ុន្តែដោយព្រះនាងមែកយ៉ា ព្រះទេពីទីពីរប្រណែន ដោយចង់ឲ្យព្រះតារៈជាទុតៈ ព្រះនាងសោយរាជ្យវិញ តែទ្រង់បំបរបង់ព្រះពុទ្ធចេញចាកព្រះនគរតែព្រះលក្ខ្មណ៍ជាព្រះអនុជ និងព្រះនាងសិវា ជាព្រះអគ្គមហេសីស៊ុំតាមទៅផង ។ ព្រះពុទ្ធព្រះលក្ខ្មណ៍និងព្រះនាងសិវាកំយាងទៅគង់នៅក្នុងព្រៃសីត្រាកុត ក្នុងអាស្រមប្រកបដោយជោគជ័យល្អស្មើនឹងទេវតា ។

ក្នុងកាលជាមានក្រោយមក ដោយហេតុទ្រង់ព្រះវិតក្កភ្លាំងពេក ព្រះបាទសេរថក៏ទ្រង់ព្រះខន្ធតទៅ រាជសម្បត្តិបានដល់ព្រះភរតៈជាព្រះអនុជពីរ ប៉ុន្តែព្រះភរតៈមិនព្រមទទួល ស្តេចទៅអង្វរព្រះរាម ជាព្រះដង្កូឲ្យត្រឡប់មកទទួលម្តងវិញ តែព្រះរាមទ្រង់ប្រកែក ទ្រង់ប្រទានវិតសុពណ៌ិបានដល់ព្រះភរតៈជាកស្តុតាងនៃអំណាច ដែលទ្រង់ព្រះរាជានុញ្ញាតឲ្យគ្រងព្រះនគរជំនួសទ្រង់ រួចទ្រង់ស្តេចចូលកាន់ព្រៃមួយទៀត ឈ្មោះទណ្ឌកៈ ។ ល ។ ល ។

ឥសីនារទៈអានរឿងព្រះរាមតាំងពីដើមដល់ចប់ មានសេចក្តីពិស្តារពីពេះពិសា ដូចជារឿងដែលលោក-អ្នកធ្លាប់បានស្តាប់ ឬអានរួចមកហើយ ។

លុះឥសីនារទៈអានរឿងព្រះរាមចប់ហើយ ឥសីវាល្មីកិក៏ទូន្មានសិរីសោភាគឥសីនារទៈ ហើយថយចេញទាំយ ទៅឈប់នៅទីមួយឈ្មោះតមសៈ ជាទីប្រសព្វមុខទន្លេតាំង ៥ មានទន្លេគង្គាជាដើម និយាយប្រាប់សិស្សម្នាក់ដែលតាមទៅផងថា :

វត្ថុការព្រាជៈ ចូរអ្នកមើលទន្លេជាទីសោភានេះ ដ៏មានពន្លឺ ទៅនឹងថ្ងៃ ដូចអាត្មានេះបង់ណ្តែតម្នាក់ ចូរអ្នកទៅយកសំពត់សម្រាកឈើពីអាស្រមមកឲ្យខ្ញុំ ហើយឲ្យកុណ្ឌីមួយមកខ្ញុំ។ នឹងងូតទឹក ក្នុងទន្លេនេះ ។

ឥសីវាល្មីកិបានឆ្លូតទឹកដ៏ថ្លាវិដ៍ លាងជម្រះបានសម្រេចមគ្គផលហើយ មុននឹងចូលកាន់អាស្រមកណ្តាលព្រៃ ឥសីយោគ្រាមានមាត់ច្រាំងទន្លេបានឃើញព្រានព្រៃម្នាក់ ជាញឹកញាប់សម្លាប់សត្វក្រសាឈ្មោលមួយ ដែលកំពុងដើរជាមួយនឹងក្រសាញីជាគូ ។ ឥសីវាល្មីកិតើតសង្វេគ កំចងជាពាក្យស្មោកគឺពាក្យកាព្យនិយាយពីរឿងក្រសានឹងព្រានព្រៃនោះ ។

កាលឥសីវាល្មីកិទៅដល់អាស្រមភ្លាម ស្រាប់តែឃើញព្រះព្រហ្មមានព្រះភក្ត្រ ៤ ជាព្រះអាទិទេពអ្នកសាងលោក មានមហិទ្ធិឫទ្ធិមកប្រតិស្ឋានចំពោះមុខ ។

ឥសីវាល្មីកិក្រោកឈរបង្ហាញកាយឆ្ពង់អញ្ជលី ហើយថ្វាយទឹកនឹងអាសនៈដល់ព្រះព្រហ្ម រួចអានស្មោករឿងព្រានព្រៃក្រសានោះចំពោះព្រះភក្ត្រព្រះព្រហ្មថា ៖

ឱ!អំពើនេះលាមកពិត បណ្ឌិតពោលថាបាបលើសខ្លួន
ឱ!អ្នកប្រមាញ់ចិត្តប្រមាថ ម្តេចអ្នកពិឃាតសត្វក្រសា ។
សំឡេងពីរោះល្អក្រៃដ ឲ្យព្រាត់ហាតគូសង្សារ
អ្នកអើយ!ខ្លួនអ្នកបានឈ្មោះថា សម្លាប់ក្រសាដែលឥតទោស ។

ព្រះព្រហ្មបានស្តាប់ក៏ញញឹមហើយពោលថា " ឱព្រះមុនី! គ្រាន់តែរឿងព្រានព្រៃបាញ់ក្រសាស្លាប់ លោកអាចចងជាពាក្យស្មោក

ពីរោះពិសាខៅបាន ខ្ញុំយើញថាលោកជាអ្នកច្រើនដូចគ្នាដែរហើយ ដូច្នេះ សូមលោកថ្លែងនូវសារតែនន៍ថ្វាយដៃនៃព្រះពាម តាមដែលលោកបានស្តាប់ ពីសំណាក់ឥសីនារទៈមុកនោះ ជាពាក្យសាឲ្យពិស្តារពីរោះពិសាចុះ សូមលោកកុំក្តេចចរិយាយរឿងខាំងប៉ុន្មាន ដែលលោកបានដឹង មិនអីទេបើលោកក្តេចខ្ញុំនឹងដួយរំលឹកលោក ។ រឿងព្រះពាមយូរខៅនឹង ក្រអូបសាយសព្វក្រឡាមហាប្រើថពី ក្តុំ សមុទ្រ ទន្លេ ឋិតថេរ នៅដរាបរលាយទំនរលាយដី ។ កាលរឿងព្រះពាមបានក្រអូបសាយខៅសព្វទិសាទុទិសហើយ ទ្រនលោកនឹងបានហានៈខ្ពស់បន្តាប់ពីខ្ញុំ" ។

ពោលហើយ ព្រះព្រហ្មក៏ចាត់មួយរំពេចខៅ ។ ដើម្បីតែរពដល់បណ្តាំរបស់ព្រហ្ម, បន្តាប់ពីនោះ ឥសីវាល្មីកិបានសរសេរសាវតារព្រះពាមធ្វើជាគម្ពីរមួយឲ្យឈ្មោះថា " រាមាយណៈ " ជាពាក្យសំស្រ្កឹត មានស្លោកដល់២៤.០០០ ចែកជាវគ្គមាន ៥០០ ជាកណ្ឌមាន ៦ ជាមហាកាព្យដ៏ពីរោះ ជាទីតែរពរបស់មហាជនទូខៅសព្វទិសាទុទិស ។

កាលឥសីវាល្មីកិសរសេរឿងរាមាយណៈរួចហើយ បានបង្រៀនដល់ឥសី ២ នាក់ឈ្មោះកុសៈ ១ លវៈ ១ ជាសិស្សរបស់លោកគ្រប់នៅក្នុងសំណាក់លោកពីដើម ហើយត្រូវជាព្រះនុសាក្មួយរបស់ព្រះពាមនឹងព្រះនាងសីតា ដែលទ្រង់ព្រះសម្ពាតក្នុងវេលាព្រះនាងត្រូវព្រះពាមបំបះបង់

គឺព្រះនេះហើយដែលខ្មែរយើងហៅថា ពាមល័ក្សណ៍ ជប្បល័ក្សណ៍។

កុសៈ នឹង លវៈ កំពុងនាំរឿងព្រះពាមទៅផ្តាយដល់មហាជន នៅព្រៃនគរអយោធ្យា

លុះជ្រាបដល់ព្រះពាមគ្រាស់ឲ្យហៅកុសៈ នឹងលវៈ ទៅឲ្យ និយាយរឿងពាមាយណៈចំពោះព្រះភក្ត្រព្រះអង្គ ។ ចប់រឿងហើយ ទើបព្រះពាមទ្រង់ជ្រាបថា កុសៈ នឹង លវៈ ជាព្រះនេសរបស់ព្រះអង្គកំទ្រង់ខ្លាំងណាស់ លុះហើយទ្រង់សោមនស្សក្រៃពេក ដែលទ្រង់បានជួបនឹងព្រះពាជនេសតាំងពីព្រះអង្គនោះ ។

ដោយហេតុរឿងពាមក្តី ជារឿងពីពេះពិសា ដូចពណ៌នាមកនេះ ហើយជាទីពាប់អាន់របស់ខ្មែរដូន នឹងជាមូលដ្ឋានសម្រាប់អក្សរសាស្ត្រខ្មែរជាតិ បានជាក្រុមពុទ្ធសាសនបណ្ឌិត្យ ទ្រឹះឡែងបោះពុម្ពផ្សាយជាយូរឆ្នាំហើយ ដើម្បីជាជាសាធារណប្រយោជន៍ ប៉ុន្តែដោយរកច្បាប់ដើមមិនទាន់បានគ្រប់គ្រាន់ ទើបបោះពុម្ពបានតែពីខ្សែ ១ ដល់ខ្សែ ១០ នឹងពីខ្សែ ៧៩ ដល់ខ្សែ ៨០ រួមជា ១៦ ខ្សែប៉ុណ្ណោះ ព្រមទាំងបទានុក្រមពាម-ក្តី ១ខ្សែផង ជា ១៧ ខ្សែ ចាំរកច្បាប់ដើមបានសព្វគ្រប់ នឹងចាត់ការបោះពុម្ពតទៅទៀតដរាបដល់ចប់ ។

អំពីប្រវត្តិការណ៍នឹងស្ថកម្មភាព

នៃពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ក្នុងចំណោមក្រុមនាៗ ដែលចាត់ទុងនឹងក្រសួងធម្មការ គេសំគាល់ឃើញក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលជាវិជ្ជាស្ថានមានគោលចំណងមាន ចាត់ការ នឹងសម្រួបសម្រួលនូវការសិក្សាព្រះពុទ្ធសាសនា ថែកមាន ហីនយាន ក្នុងពួកពលរដ្ឋនៃប្រទេសកម្ពុជា នឹងក្រុមជនជាតិខ្មែរនៅស្រុក ប្រទេស ថាជាមជ្ឈមណ្ឌលមួយ មានមុខការងារស្រាវជ្រាវ នឹងពន្រីក នូវវប្បធម៌ខ្មែរ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យនេះ តើតឡើងក្នុងឆ្នាំ ១៩៣០ ចេះតែ មានសេចក្តីចំរើនលូតលាស់ជុះជាលជាលំដាប់រៀងពីបដរបមក តុំដែលតាក់តែងឡើយ ។ ក្នុងសម័យសព្វថ្ងៃ វិជ្ជាស្ថាននេះ ដែលនៅក្នុងវិថីមានផ្នែក នឹងគណៈកម្មការផ្សេងៗ ចានប្រព្រឹត្តមុខការចំរើនលឿនទៅមុខ រៀងពីលំថ្ងៃ ដោយមានបុគ្គលិកបច្ចេកទេស តាន់តាប់កិច្ចការផ្សេងដោយ ឡែកៗ ពីគ្នា ចានក្លាយទៅជាមន្ទីរវិទ្យាសាស្ត្រមួយ ជាស្ថាពរបស់ជាតិ មានសារៈប្រយោជន៍សំខាន់ ពុកដូចជាគ្រឿងប្រដាប់មួយបែប ខាងផ្លូវប្បៈ

ជាមិ សម្រាប់កសាងប្រទេសកម្ពុជានាបច្ចុប្បន្នកាលនេះ ។

ក្រៅអំពីកិច្ចការឯទៀត ។, ពុទ្ធសាសនបណ្ឌិត្យបានបំពេញមុខការសំខាន់ ។ ជាច្រើន ដូចជាការស្រាវជ្រាវរិះរក នឹងការសិក្សានូវក្បួនខ្នាតអក្សរសាស្ត្រ ការរៀបចំឲ្យមានបណ្ណាល័យសិក្សា, ការរិះរកប្រមែលប្រមូល នឹងការរក្សាទុកនូវឯកសារបុរាណ, ការបោះពុម្ពផ្សាយសៀវភៅជាភាសាបាលី សំស្ក្រឹត- ខ្មែរនឹងបរទេស ដែលជាប់ទាក់ទងនឹងភាសាសាស្ត្រ អក្សរសាស្ត្រ សាសនា សិល្បៈ បុរាណវត្ថុ ប្រវត្តិសាស្ត្រ ហើយនឹងចំណៀមទម្លាប់ សម្រាប់ជាវេជ្ជសាស្ត្រថ្មីៗ ដល់បព្វជិតនឹងគ្រហស្ថទូទៅ ក្នុងព្រះរាជអាណាចក្រ ។

ក្នុងរយៈកាលៗឆ្នាំក្រោយនេះ, សកម្មភាពរបស់ពុទ្ធសាសនបណ្ឌិត្យ ផ្នែកខាងនាទីបោះពុម្ពផ្សាយសៀវភៅ ដោយមិនគិតមុខការខាងអំណោយ នឹងបន្តសៀវភៅផ្សេងៗ បានបោះពុម្ពផ្សាយសៀវភៅជាច្រើនមុខ ជាវយកតំរៃជាប្រយោជន៍ដល់ថវិកាជាតិ ដូចតទៅនេះ :

ឆ្នាំ	ចំនួនបោះពុម្ព ស.ភ.	ចំនួនជាលិខិត	ចំនួនប្រាក់
១៩៥៥	៦៤.២០០ ក្បាល	៥៣.០៦៦ ក្បាល	១.១២៣.៨០០$០០
១៩៥៦	៨៣.៦០០ "	៦២.៣២៦ "	១.២៥២.៨០០$០០
១៩៥៣	១០២.៤០០ "	៣១.៥៣១ "	១.០៨៣.៤០០$០០

ក្នុងបណ្តាកិច្ចការបោះពុម្ពសៀវភៅទាំងប៉ុន្មាននោះ គេតែងតែតំ

គាល់ជាពិសេសនូវការចុះពុម្ពសៀវភៅ ព្រះត្រៃបិដក ជាកិច្ចការដ៏ធំធ្ងន់ ដែលរួបរួមចងក្រងជាសៀវភៅធំៗ មានចំនួន ១១០ ភាគ, សៀវភៅវចនានុក្រមខ្មែរ ២ ភាគ ហើយនឹងសង្ឃនាយដ្ឋកម្ពុជសុរិយា ផ្សាយសាសនានឹងអក្សរសោស្ត្រ ចេញរៀងរាល់ខែ ដែលក្នុងមួយខែៗ មានចំនួន ៦០០ ក្បាល ។

បណ្តាមុខការនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលបានបរិយាយមកអំបាញ់មិញនេះ, ខ្ញុំសូមដំរាបថា មានមុខការ ១ ដែលគួរដកស្រង់ពិសេសយកមកបរិយាយឲ្យបានជ្រាបក្នុងពេលនេះដែរ គឺបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដែលជាមុខការដ៏មានសារៈប្រយោជន៍ ដល់អស់លោក-អ្នក ។

បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ដែលប្រព្រឹត្តទៅក្នុងថ្ងៃរបស់វិជ្ជាស្ថាននេះ គឺជាបណ្ណាល័យនេះសិក្សាវប្បធម៌ ខាងបូពាប្រទេស ។

បណ្ណាល័យនេះ បានទទួលមកតាមពីព្រះរាជបណ្ណាល័យកម្ពុជាពីដើម ហើយសព្វថ្ងៃនេះ ពុកជាបណ្ណាល័យវិទ្យាសាស្ត្រាមួយ ក្នុងព្រះរាជអាណាចក្រកម្ពុជា សម្រាប់អ្នកវិនិតគ្រប់ប្រភេទ ខ្មែរ ឬ បរទេស បព្វជិត ឬ គ្រហស្ថ ព្រមទាំងនិស្សិតទាំងឡាយ ។

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃ ដែលមានសៀវ-

(តមក)

ព្រះមហា ប៉ាង--ខាត់ រៀបរៀង

អចារុ គុ. នែលមិនល្អ ។

អចាល្យ គុ. នែលមិនតប្បីកម្រើកបាន ។

អចិត្ត គុ. នែលមិនមានចិត្ត, ពាល ។

អចិត្តនីយ គុ. នែលមិនគប្បីគិត ។

អចិត្តា ស្ត្រី. អចិន្តា, ការិយាមិនគិត ។

អចិន្ត្យ គុ. នែលមិនគប្បីគិត ។

អចិរ គុ. នែលមិនយូរលង់, ភ្លាមៗ ថ្មីៗ ។ *អចិរំ, អចិរាត៑, អចិរេណ* ក្រ. វិ. អស់កាលមួយរំពេច ។ *(–ជុតិ)* ស្ត្រី. ផ្លេកបន្ទោរ ។ *–ប្រភា, –ការិ, –រោចិស៑,* ស្ត្រី. ផ្លេកបន្ទោរ ។ *អចិរំតុ* ប៉ុ. ; *អចិរតា,* ស្ត្រី. ផ្លេកបន្ទោរ ។ *អចិរោជា* ស្ត្រី. ការិយាក្មេង ។

(មានត)

ភ្នំពេញសន្ទេយ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ៣០ លេខ ១២ ខែធ្នូ

ព. ស. ២៥០១ គ. ស. ១៩៥៨

ក្នុង ៣៧

ECOLE FRANÇAISE
D'EXTRÊME-ORIENT



ទស្សនាវដ្តី ធ្វើឲ្យជំនឿជាំងខាងសាសនា និងអក្សរសាស្ត្រ
ប្រោះពុម្ពធ្វើឲ្យអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មាតិកា	ទំព័រ
- ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ (តចប់)	ព្រះមហា ជាំង-ខាត់ រៀបរៀង	១០៤៣
- អត្ថដ្ឋកថាសុទ្ធកថា (តចប់)	ព្រះមហា អ៊ុក-អ៊ុន រៀបរៀង	១០៥៤
- កម្មកថា	ព្រះអាចារ្យ ឈាង-ដែនឆ្ងន រៀបរៀង	១០៦៣
ផ្នែកអក្សរសាស្ត្រ		
- រឿងកំដរសមានភ័ទ្ធ	លោក លាង-ហាប់-អាន រៀបរៀង	១០៧៨
- រឿងសាមកុក (តមក)	ឧកញ៉ា ទូ-កន ប្រែ	១០៨៤
- សុភាសិតហ៊ាល្ហ	លោក ភ័ឃ-ប៊ុក ឯកស្រង់រៀបរៀង	១១១៨
- ដើមកំណើតល្បែងការព្រ័ត្រ	លោក ចាប-ពិន រៀបរៀង	១១២៤
ផ្នែកកំណត់ទំនៀមប្រវត្តិការណ៍		
- ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ		១១៣០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហាជាំង-ខាត់ រៀបរៀង	១១៣៨

មួយឆ្នាំមាន ១២ សៀវភៅ ជំរៀងជាវ ២៣០រៀល

KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE :

— Histoire du Bouddhisme au Cambodge (suite et fin) par Vén. *PANG-KHAT* 1043
— Atthajatasukhakatha par Vén. *OUK-IN* 1054
— Kammakatha par Vén. *CHEANG-CHHAI-NGOUN* . 1063

PARTIE LITTERAIRE :

— Légende du Paresseux chanceux par *LEANG-HAB-AN* 1078
— Histoire de Sam-Kok (suite) traduite par *M.NOU-KAN* 1084
— Proverbes Hindous par *M. RAY-BUC* 1118
— Le jeu de corde par *CHAP-PIN* 1124

NOTES ET CHRONIQUES :

— Annonce de concours institués par la Commission des Mœurs et Coutumes du Cambodge 1130
— Dictionnaire Sanskrit khmèr (suite) par Vén. *PANG-KHAT* 1138

Prix d'abonnement annuel (comprenant 12 numéros) : 280 r 00

ផ្នែកសាសនា

ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ

ព្រះមហា ប.ង-ខាត់ រៀបរៀង

(តចប់)

ពុទ្ធសាសនាធំឯរដ្ឋៈ ដោយចិត្តខ្មែរជាធម៌បែបនេះហើយ បានជាប្រជាជនខ្មែរមិនចូលចិត្តប្រើកម្លាំងអាវុធ ពេញចិត្តទាំប្រទេសខ្លួនទៅដោយសន្តិវិធី ហើយតាំនៅក្នុងអព្យាក្រឹតភាព ស្រឡាញ់មនុស្ស-ជាតិគ្រប់សាសន៍គ្រប់ភាសា ក្នុងសកលលោកមិនរើសមុខ ទុកមនុស្សលោកជាកល្យាណមិត្រសម្រាប់ដើរទៅតាន់ផ្លូវផ្លាយកន្លាវ រួមសុខរួមទុក្ខជាមួយគ្នា ជ្រឹតបានជាកើតមកហើយ ចង់រួមរស់នៅជាមួយគ្នាដោយក្សេមក្សាន្តរហូតតទៅ ដើម្បីសាងក្តីសុខក្តីចំរើនដល់មនុស្សលោក ។ ប្រជា-ជនខ្មែរទាំងប្រទេសប្រកាសខ្លួនជាអព្យាក្រឹតយ៉ាងទឡ្ហរឹត ចំពោះសកល-លោក មិនថាលោកខាងនេះ ឬលោកខាងនោះទេ នេះឯងហើយជាសក្ខី-ភាពឲ្យសកលលោកស្គាល់ចិត្តខ្មែរថាខ្មែរ "ចិត្តធម៌" ។ តែប្រវត្តិសាស្ត្រ ខ្មែរបានប្រាប់ថា ខ្មែរមិនមែនចិត្តធម៌ស្ងប់ស្ងុតនោះទេ ខ្មែរមានសតិ-សម្បជញ្ញៈ មានគំនិតសំរេចវិតិ ចេះតស៊ូព្រមិយកជីវិតខ្លួនជាពលី ដើម្បី

បួជាមាតុប្រទេស បួជាជាតិ សាសនា ព្រះមហាក្សត្រខ្លួនហូតមក ។

ពុទ្ធសាសនាធំជាងប្រជាជនខ្មែរ: ប្រជាជនខ្មែរអប់រំកូនចៅតាមប្រពៃណីបុរាណ គឺឲ្យកូនចៅទៅរៀននៅវត្ត ។ កូនខ្មែរទោះជាព្រះរាជបុត្រក្តី បុត្រមន្ត្រីក្តី កូនចៅប្រជានុរាស្ត្រក្តី ទាំងអស់ទៅរៀននៅវត្ត យកវត្តជាសាលារៀន វត្តមួយ ។ ត្រូវបង្រៀនមុខវិជ្ជាបានត្រប់យ៉ាង បង្រៀនអក្សរ នាឫត្ត ការរចនា ការស្មាធនា ចរាប់សីលធម៌ នឹងធម៌អាថ៌ ពុទ្ធសាសនា ។ កូនខ្មែរដែលបានរៀនសូត្រចេះដឹងគួរសមហើយ ត្រូវបួសជាសាមណេរជាតិក្តី តើតទៅជាទំនៀមថា កូនប្រុសអាយុ ១២ ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា អាយុ ២១ ឆ្នាំ ត្រូវបួសជាតិក្តី សងគុណបិតា, បួសហើយត្រូវរៀនសូត្រវិជ្ជាខ្ពង់ខ្ពស់តទៅទៀត រៀនចាស់រៀនធម៌អាថ៌ពុទ្ធវចនៈ។ល។ កូនចៅខ្មែរ, បើបានបួសជាសាមណេរជាតិក្តីហើយ សឹកមកវិញ ទើបគេរាប់ថាជាមនុស្សពេញអង្គ. សឹកមកវិញភ្លាម គេឲ្យនាមថា បណ្ឌិត ប្រែថា អ្នកប្រាជ្ញ គេលែងហៅ អាមឹង ដូចពីដើមហើយ ។ បើមិនបានបួសទេ គេហៅ អាមឹង មួយជាតិ ហើយគេមិនរាប់ជាគ្រីមុខទេ ។ បើបានបួសហើយ តែខ្ជិលរៀនសូត្រទៀត ចរាប់ក្រមខ្មែរបន្ទោសថា «កំដៃលអៀនប្រៀន បួសហើយមិនរៀន បន្ទោសថាខ្លៅ» ។ អាស្រ័យដោយការអប់រំប្រពៃណីនេះហើយ ទើបបាន

ជាប្រជាជនខ្មែរមានចរិយាសុភាពរាបសាស្លូតត្រង់ ចិត្តថ្លៃមល្អ មិនសូវចេះ
បៀតបៀនគ្នាទេ ។ សព្វថ្ងៃនេះ កូនប្រុសពុំសូវបានបួសជាកិក្ខុជា
សាមណេរដូចដំនាន់មុនទេ ព្រោះមានសាលាគេតនៅកៅវត្តច្រើន តែ
ទោះម្តេចម្តា ព្រះពុទ្ធសាសនាចាំលកំព្យាយាមបង្រឹតសាលាតាមវត្តដូច
បុរាណកាលវិញជាចំផុត ។ សូម្បីមានសាលារៀនក៏ដោយ តែមាន
សិស្សច្រើនគ្នាណាស់ដែលពឹងពាក់អាស្រ័យនៅតាមវត្តអារាម ជាទីសាស
ល្អបានសេពគប់ព្រះសង្ឃ ។ ឯយុវជនដែលអាស្រ័យនៅផ្ទះ ក៏តែងមាន
ទីសាសចូលទៅវត្តអារាម បានធ្វើបុណ្យតាមប្រពៃណីពុទ្ធសាសនា
បានភ្ជាប់ទំនៃរវាងខ្លួនឯងពុទ្ធសាសនា ចេះខ្ចាចខ្ចាប ចេះចង់បានបុណ្យ
ចេះយល់ព្រះពុទ្ធសាសនា ហើយប្រកាសខ្លួនជាពុទ្ធសាសនិក ព្រោះហេតុ
តែបានទទួលពន្លឺព្រះពុទ្ធសាសនាតាំងពីកុមារមក ។

ពុទ្ធសាសនាធំឯសង្គមខ្មែរ : បុណ្យទានជាន់ពុទ្ធសាសនាក្តី
បុណ្យប្រពៃណីប្រទេសក្តី ប្រជាជនខ្មែរតែងប្រមូលគ្នាទៅធ្វើនៅតាមវត្ត
អារាម ។ ការប្រមូលគ្នាទៅវត្តនេះមានប្រយោជន៍ណាស់ ព្រោះជាទីសាស
ល្អនាំឲ្យបានស្គាល់គ្នា ឲ្យពាប់រកគ្នា ឲ្យបានប្រស្រ័យទូវគ្នាខ្ជិតគ្នា ឲ្យ
យោគយល់គ្នា ឲ្យចេះរួបរួមគ្នា ដើម្បីបំពេញកុសល ឬសម្រេចកិច្ចការ
សង្គមអ្វីនីមួយ ។ ការសមាទានសីលជាកិច្ចការសង្គមមួយដ៏ប្រសើរ ព្រោះ

បានជួសជាត់សង្គមឲ្យស្អាតបរិសុទ្ធ ឲ្យមានចរិយាប្រសើរ មានសីលធម៌ខ្ពស់ ។ ឯការបំពេញទានថ្វាយសង្ឃ ក៏ជាការសង្គមមួយប្រសើរទៀត ព្រោះជាការដម្រេះសេចក្តីកំណាញ់គឺតតែប្រយោជន៍ផ្ទាល់ខ្លួន ទើជាការបង្ហាត់ខ្លួនឲ្យចេះធ្វើចិត្តធូរធ្ងូលាយ ចេះគិតផ្តល់ប្រយោជន៍នឹងសេចក្តីសុខនៃគ្នីគ្នាទៅវិញទៅមក មិនតែប៉ុណ្ណោះទេ ការប្រមូលគ្នាទៅវត្តជាឧកាសមួយប្រសើរដោយឡែកទៀត ព្រោះអាចយកពេលជួបគ្នានេះសម្រាប់ដាដែកគ្នា ពិគ្រោះ ពិភាក្សាគ្នា អំពីកិច្ចការសង្គមជាប្រក្រតីថែមទៀតផង ។ ហេតុដូច្នេះ ប្រស្នាអ្វីមួយជាកិច្ចការសង្គម ដែលបានប្រឹក្សាគ្នានៅវត្តអារាម តែងតែជាប់លាយដោយគំនិតពុទ្ធសាសនា ជាសន្តិធម៌នាំឲ្យកើតសេចក្តីសុខក្សេមក្សាន្តជាដរាប ។

ចាស់ទុំបរមបុរាណខ្មែរបានបង្កើតបុណ្យទំនៀមច្រើន ដើម្បីអប់រំនិស្ស័យសង្គមឲ្យជាប់នឹងពុទ្ធសាសនា ដូចបុណ្យកាន់បិណ្ឌ បុណ្យស្រង់ព្រះ បុណ្យស្រោចស្រពមាតាបិតាចាស់ទុំ បុណ្យបុំបួសនាគ បុណ្យកឋិនទាន ជាដើម ។ ឯបុណ្យភ្ជុំ តាំងរៀបមង្គលកូនប្រុសស្រីជាស្វាមីភរិយា បុណ្យចូលឆ្នាំ ។ល។ ក៏ចាស់ទុំបញ្ចូលលទ្ធិពុទ្ធសាសនាជាមង្គលទាំងអស់ ។ ដោយជាតិយើងចូលចិត្តធ្វើបុណ្យដូច្នេះហើយបានជាមានពាក្យអ្នកបរទេសថ្លែងសរសើរយើងថា "ខ្មែរបានជាក្រ មកពីធ្វើបុណ្យ

ច្រើនពេក" ។ ជនជាតិខ្មែរពេញចិត្តធ្វើបុណ្យយ៉ាងនេះ មកពីយល់ថា "ក្រកិក្រចុះ ឲ្យតែមាន គឺមានអាយុវែង" ។

បុណ្យសំខាន់មួយទៀតសម្រាប់អប់រំចរិយាសង្គមឲ្យរីសេសរីសាលគឺ បុណ្យទេសនាទេសជាតក ។ ការទេសនាទេសជាតក គឺសំដែងពីចរិយាព្រះបរមពោធិសត្វដែលព្រះអង្គខំប្រឹងប្រតិបត្តិ ក្នុងអតីតជាតិឲ្យបានត្រាស់ដឹងធម៌ឲ្យប្រជាជនស្តាប់ ហើយឲ្យយកជាគតិខុតជាពន្លឺក្នុងជីវិតខ្លួនគ្រប់ ៗ គ្នា សម្រាប់ប្រតិបត្តិយកសេចក្តីសុខ នៅនាលោកនេះនឹងបរលោក ។ អាស្រ័យដោយការអប់រំដ៏ប្រសើរនេះ ប្រជាជនខ្មែរបានចេះដឹងពុទ្ធចរិយាដែលព្រះបរមពោធិសត្វកាលព្រះអង្គបានបំពេញទេសចារិ ហើយប្រព្រឹត្តតាមពុទ្ធចរិយា យកពុទ្ធចរិយានេះជាគតិប្រចាំជីវិត ដើម្បីខ្លួនានខ្លួនឲ្យប្រព្រឹត្តល្អ ឲ្យមានសីលធម៌ខ្ពង់ខ្ពស់ ឲ្យមានចិត្តតាំងនៅក្នុងធម៌ ។

ពុទ្ធសាសនាយុកាល ២៥០០វស្សា - ព្រះពុទ្ធសាសនាគ្រប់ជា ២៥០០ វស្សាហើយ ប្រជាជនខ្មែរពាំងប្រទេស បានរៀបចំធ្វើបុណ្យរំលឹកពុទ្ធសាសនាគម្រប់ ២៥០០ វស្សានេះយ៉ាងទូលាំទូលាក ដូចប្រជាជនរួមសាសនានៃប្រទេសនានាដែរ ។ ដោយហេតុអ្វី ? ហើយព្រោះហេតុអ្វីបានជាប្រជាជនពុទ្ធសាសនិកសកលលោក ធ្វើបុណ្យរំលឹកឆ្នាំនេះខុតជាបុណ្យយ៉ាងធំមួយ ក្នុងព្រះពុទ្ធសាសនា ? នេះជាប្រស្នាគួរដញ្ជឹងគិត ។

ចំណែកប្រជាជនខ្មែរតែងរង់ចាំខ្លាអកិលក្លិតសម័យនេះយូរយារ
ណាស់ហើយដោយសោមនស្សជាបំផុត ព្រោះចាស់ទុំរមែងជាស់តឿន
ប្រដៅកូនចៅវុតតាគ្នាថា "តាចាស់ហើយចៅអើយ ! ទំធ្វើបុណ្យទាន
រក្សាសីលចៅ ឲ្យបានចាន់សាសនា២៥០០វស្សាទើតែង" ប្រដៅកូនចៅ
ហើយ ក៏ទំបព្រឹត្តធ្វើល្អខ្លួនឯងផង ព្រោះខ្លួនដល់រយៈចាស់ជរាណាស់ទៅ
ហើយ ក្រែងពុំបានចាន់ពេលវេលាដ៏ប្រសើរនឹងគេ ព្រោះទំនៀម
ចាត់ពុកថាជាអត្ថមួយយ៉ាងធំក្រៃលែង ។ អាស្រ័យដោយហេតុនេះ
ហើយ បានជាប្រជាជនខ្មែរចាំងក្នុងចាំងចាស់ខ្នុងរង់ចាំវាវេកាសនេះ
ណាស់ ព្រោះក្នុងទំនាយនានាដែលអាចារ្យជាន់ដើម បានព្យាករពុកមក
នោះ មានសេចក្តីបញ្ជាក់ថា លុះដាតដល់ ២៥០០ វស្សាហើយ ប្រទេស
ខ្មែរនឹងកើតតលិយុគវិតវៃខ្លាំងណាស់ រហូតដល់សាសនាគ្រប់បរិបូណ៌ជា
២៥០០ វស្សា ទើបព្រះបាទធម្មិកមកលើកពុទ្ធសាសនា បានសេចក្តីសុខ
សប្បាយគ្រប់គ្រងក្សត្រខ្លួនៅចាំងប្រទេស ឥតមានទុក្ខសោកពេតភ័យអ្វីមួយ
បៀតបៀនឡើយ ប្រទេសកម្ពុជានឹងសម្បូណ៌សប្បាយហាក់ប៉ដូចជា
ហាន្ទសួគ៌ ។

ទំនាយចាំងនេះកើតក្នុងពេលវេលាទុក្ខវេទនានៃពង្សវតារខ្មែរ បានធ្វើ
ចិត្តខេមរជនគ្រប់ប្រហឲ្យមានសេចក្តីសង្ឃឹមជានិច្ច មិនឲ្យលះបង់សេចក្តី

ប្រឹងប្រែង ឲ្យចេះអត់ធ្មត់តស៊ូចំពោះរឿងលំបាកគ្រប់ប្រការ ហើយឲ្យ
ស៊ុះសម្លឹងទៅរកអនាគតដ៏រុងរឿងច្បាស់ ពុំមែនឲ្យដេកចាំព្រឹងសំណាងដោយ
ខឹកស្រមៃរើរៃយដល់ដោគវាសនាដ៏ថ្លៃថ្នូនោះទេ គឺត្រូវឲ្យខិតខំព្យាយាម
កសាងអនាគតនោះ ឲ្យកើតជារូបរាងច្បាស់ឡើង ព្រោះ
ពុទ្ធសាសនាជាសាសនាឋាមវន្ត មិនមែនឲ្យដេកចាំវាសនាទេ ។ រូបរាង
កាយឬ ទ្រព្យសម្បត្តិយើង ជាវត្ថុអាចភ្ជាក់ផៅកន្លងទាសភាពបាន តែចិត្ត
គំនិតភ្ជាក់ផៅពុំបានទេ តែងតែអណ្តែតខ្ពស់ផុតពីទាសភាពជាដរាប ចឹក
ចិត្តបែបនេះ បានសំដែងឲ្យឃើញជាក់ច្បាស់ក្នុងពង្សាវតារខ្មែរច្រើនលើក
ច្រើនគ្រាណាស់មកហើយ ។ ចឹកចិត្តប្រសើរនេះហើយដែលអាចញ៉ាំង
ប្រជាជននៃប្រទេសនីមួយៗ ឲ្យមានខ្ទឹមសារ មិនឲ្យសាបសូន្យឲ្យទៅតាម
កាលវិបត្តិឡើយ ។

បើពិនិត្យមើលទៅតាមទំនាយនឹងតាមស្ថានការណ៍ក្នុងសកលលោក
បច្ចុប្បន្ន កំយើងឃើញថា ទំនាយខ្មែរនេះ ហាក់ដូចជាមិនឃ្លាតពីសេចក្តី
ពិតប៉ុន្មានទេ ប្រទេសខ្មែរបានបំរុងចំរើនក្នុងពេលនេះមែន ឯពុទ្ធសាសនា
ទៀត កំដ្រុតជ្រាបពេញទាំងប្រទេសភ្ញាំងជាងសម័យមុន ដោយការផ្សាយ
ព្រះបរមតុទ្ធាភិនេញទំហឹងតាមការទេសនា ការបង្រៀនធម៌វិន័យ
ការបង្រៀនភាសាភ្លើ ការផ្សាយសៀវភៅធម៌របស់ពុទ្ធសាសនបណ្ឌិត្យ

ន៍ឯការបង្កើតពុទ្ធិកមហាវិទ្យាល័យ ។

បើតាមគោលការណ៍នានាប្រទេសវិញ យើងឃើញថាទំនាយរបស់ខ្មែរកើមានចំនួនស្របគ្នានឹងទំនាយនៃប្រទេសពុទ្ធសាសនានានាក្នុងសកលលោក ដែរបានជាមានការធ្វើបុណ្យរំលឹកពុទ្ធសាសទាគម្រប់ ២៥០០វស្សាដូចគ្នា ។ ឯស្ថានការណ៍ក្នុងសកលលោក យើងសង្កេតឃើញមានការប្រែប្រួលច្រើន គឺប្រព័ន្ធសាសនតឹងតែង ។ បែរវេទៀតសាសនធ្លាស្រួលមិនសូវនាំឲ្យកើតក្តាក់ផ្ទើលពីការតំរើញសង្គ្រាមថ្មី នឹងផលអាក្រក់ពាំនាំឲ្យនៃសង្គ្រាមនេះពេក ។ យើងសង្កេតឃើញម្ល៉ាយទៀតថា វិវឌ្ឍនភាពខាងសម្ភារៈយ៉ាមកក្នុងយុគបរមាណូ ពុំអាចនឹងបន្ទរបន្ទុយនូវស្ថានការណ៍តឹងតែងអន្តរជាតិបានដោយងាយទេ គឺមានតែពាំនាំឲ្យកើតចំរ៉ាម្តេតក់ស្លុតរន្ធត់ចំពោះអាវុធថ្មីនេះវិញទេ បានជាប្រទេសទាំងឡាយបបួលគ្នាត្រែះរែះរកមធ្យោបាយស្វែងរកសន្តិភាពខាងចិត្តនិយមវិញ ហើយកំពុងនឹងរកប្រមន្តថ្មីមួយ ដើម្បីប្រមូលគ្នាជាមិត្តភក្តិ ជួយគ្នាទៅវិញទៅមក ឲ្យរួចផុតទុក្ខវេទនា ឲ្យរួចផុតពីការព្យាបាទគ្នា “ រូបមន្តថ្មីនេះពិតប្រាកដជាស្មារក្ខាតធម៌នៃព្រះពុទ្ធសាសនាឥតសង្ស័យទ្បើយ ” ។

ដូចេ្នះ យើងអាចសន្និដ្ឋានបានថា ធម្មិកក្នុងព្យាករណ៍ពាំងឡាយពុំមែនជាតួបុគ្គលមានបុណ្យឈានមួយចុះមករៀបចំប្រទេសនានា ក្នុងសកល

លោកឲ្យបានសុខសប្បាយឲ្យបានសាន្តត្រាណនោះទេគឺជាទង្វើមិត្តភាពនៃការ
ស្រុះស្រួលគ្នាក្នុងលោក ដោយការរកពីធម៌ ដើម្បីសន្តិសុខ នឹងការ
រួមចិត្តគំនិតមូលតែមួយ ដើម្បីធ្វើបុណ្យគោរពព្រះពុទ្ធសាសនាយូរកាលគម្រប់
២៥០០វស្សា រំលឹកដល់ពាក្យទុកដាក់នៃព្រះបរមគ្រូដែលជាអាវុធដ៏មុតថា
អាចកាប់ផ្តាច់នូវមហាមោហន្ធការក្នុងលោក ចំណាយបង់នូវអំពើបៀតបៀន
កំពេលយោរយៅ នូវឥស្សាឈ្នានីសាហាវយង់ឃ្នង នូវអំពើចង្រៃ
ព្យាបាទគំនុំគុំគួនដែលជាគំនរភ្លើងអសន្តិសុខឲ្យប្រែក្លាយសភាពអស្ចរៀ
ជាសភាពសិរីផ្កាន ហើយផ្សាយប្រគល់នូវសន្តិសុខដែលជាទឹកអម្រឹតចិត្ត
វិសេសស្រោចស្រង់ប្រជាជនសកលលោកឥតរើសមុខ រើសពូជពង្សរើស
ព័ណ៌សម្បុរឡើយ ។ បរិយាកាសប្រពៃដែលបានអប់រំប្រជាតិរាល់ពី
២៥០០ឆ្នាំ កន្លងមកហើយនោះ កំដូចជាមកប្រមូកមាំងគ្នាតោងឡើងថ្កុំថ្កើង
ពេលនេះ ម្តងនេះពុំមែនមានទេត្តខ្លាំងត្រឹមតែត្រាំប្រទល់មធ្យមប្រទេស
ប៉ុណ្ណោះទេ អាចរាតសាសន្ធឹងផ្សព្វផ្សាយទូទៅគ្រប់ទ្វីបក្នុងភពលោក
ពិតពន្លោក ដែលមានពុទ្ធបរិស័ទចំនួនប្រមាណ ៥ រយលាននាក់ កំពុង
សោមនស្សរីករាយគោរពបូជាព្រះសម្មាសម្ពុទ្ធ ផ្សាយនូវមេត្តាធម៌គ្រប់
ទិសដំបន់ ត្រូវការទត្តមគតិតែមួយគឺ "សន្តិសុខ" តែប៉ុណ្ណោះ ។

ប្រជាជនខ្មែរទុកជាមានកត្តព្យប្រសើរណាស់ ដោយបានទទួលពន្លឺពុទ្ធ-
សាសនាតាំងពីបុព្វកាលរៀងមក ហើយទំនៀមទុកមិនឲ្យបាត់បង់ទៅ

វិញ ពន្លឺនេះប៉ុន្តែរឿងចំណាចចំពោះតែក្នុងបច្ចុប្បន្នកាលនេះ ជាគំរូមួយឲ្យ
សកលលោកមើល ទុកដូចជាព្រះពុទ្ធសាសនាមានជីវិតនៅរស់រវើកក្នុង
ដែនដីខ្មែរ ហាក់ដូចសម័យពុទ្ធកាល ។ ប្រទេសខ្មែរដែលបានរក្សាព្រះ
ពុទ្ធសាសនាតុមកដោយប្រពៃដូច្នេះ ទុកជាបានរក្សាទុកនូវចិត្តអធិដ្ឋាន
វិសេស សម្រាប់ជួយរំលត់ភ្លើងទុក្ខសកលលោកឲ្យរលត់ ហើយឲ្យបាន
សេចក្តីសុខពិត ឈ្មោះថាបានបូជាដោយពិសេសចំពោះអង្គព្រះសម្មា-
សម្ពុទ្ធបរមគ្រូដោយបដិបត្តិបូជាដ៏ខ្ពង់ខ្ពស់ ។

ចំណែកតំកុសាមណេរនៅប្រទេសខ្មែរ ទ្រទ្រង់ធុរៈពាំងពីរក្នុង
ពុទ្ធសាសនាព្រមទាំងផ្សាយពុទ្ធសាសនាឲ្យបានជ្រួតជ្រាបទូទៅឥតគំណត់
កាលវេលាឡើយ មានបំណងតែមួយចង់ឲ្យតែសាសនាព្រះសម្មាសម្ពុទ្ធ
បិតថេរចៅកោសអង្វែងតទៅ តែងតែនមស្ការគុណព្រះរតនត្រ័យពុំលំអៀ-
ងត្រីស្វាធ្យាយពុទ្ធកាសិគោវាទ រួចហើយសូត្រលើកពុទ្ធសាសនាថា ៖

"សូមគោរពំលើកដល់កាលដែលព្រះសក្យមុនីសព្វញ្ញាពុទ្ធ ព្រះអង្គ
ចូលនិព្វានទៅដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយអនុ-
រាធនក្ខត្តឫក្ស នាយាមអង្គារថ្ងៃអង្គារ ១៥ កើតខែពិសាខ តម្រូវដូវឆ្នាំម្សាញ់
ក្រោមចន្ទោះមែកសាលព្រឹក្សពាំងគួ ដិតក្រុងកុសិនារកុដបច្ចសសម័យ ។
រាប់ចាប់ដើមតាំងពីថ្ងៃ ខែ ឆ្នាំនោះមកដល់ថ្ងៃចន្ទ ១៤ កើតខែពិសាខ ឆ្នាំរកា
នព្វស័កនេះ ពុទ្ធសករាជកន្លងទៅបាន ២៤០០ ឆ្នាំហើយ ។

សូត្រនេះលើកពុទ្ធសាសនាដោយជ្រះថ្លា ព្រោះបានទ្រទ្រង់ធុរៈក្នុងពុទ្ធសាសនាឲ្យគង់វង្សបីតរយៈចំរើនអស់ផែ្នងមួយថៃ្ងហើយមួយថៃ្ងទៀតជាប់ជានិច្ចមិនជាប់ដូច្នេះរួចហើយ ក៏ស្វាធ្យាយបច្ចុមពុទ្ធវចនៈបញ្ចប់ថា ៖

"ម្នាលអានន្ទ ធម៌ក្តី វិន័យក្តីដែលតថាគតបានទេសនាហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ធម៌នឹងវិន័យនោះ ឥតអំពីតថាគតទៅទេ ឯងជាគ្រូអាចារ្យនៃអ្នកទាំងឡាយ;

"អ្នកណាមួយ ជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី បើបានប្រតិបត្តិធម៌សមគួរដល់ធម៌ហើយ អ្នកនោះឈ្មោះថាបានធ្វើសក្ការៈគោរព រាប់អានបូជាតថាគត ដោយការបូជាដ៏ខ្ពង់ខ្ពស់;

"ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតជាសំគ្រឹនអ្នកទាំងឡាយ រាល់គ្នាថា "សង្ខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរបំពេញកិច្ចទាំងពួងរបស់អ្នកឲ្យបានពេញបរិបូណ៌ដោយសេចក្តីមិនប្រមាទចុះ" ។

ក្នុងអភិលក្ខិតសម័យ ២៥០០ នេះ ខ្ញុំសូមនមស្ការ ឯកា ចិត្តក្រាបថ្វាយបង្គំចំពោះព្រះសោណកត្ថេរ ព្រះឧត្តរត្ថេរ ដែលបានទាំព្រះពុទ្ធសាសនាមកប្រតិស្ឋាននៅក្នុងដែនដីសុវណ្ណភូមិនេះ ចំពោះព្រះមហាថេរានត្ថេរទាំងឡាយ ដែលបានទំប្រាំងរក្សាព្រះពុទ្ធសាសនាទុកមកដោយសេចក្តីគោរព ។

សូមព្រះពុទ្ធសាសនា "សាសនាទំពកអម្រឹត" រីកដុះទូលំទូលាយត្រួតត្រាបដ្បិទ្ធរដ្ឋាយទូទៅពេញសកលលោក ញ៉ាំងលោកសន្ធំវាសនេះឲ្យបានត្រជាក់ត្រជំក្បែរមក្បាន្តជានិច្ចនិរន្តរំអស់កាលជាអង្វែងតទៅហោង ។

"ការពោលអំពីកិច្ចត្រូវការ ធ្វើឱ្យអ្នកដួយឱ្យបានសុខ"

ព្រះមហា អ៊ុក-អ៊ីង រៀបរៀង

(តទៅ)

ព្រោះហេតុនោះ, កិត្តិសព្ទក៏ចេះតែតិចចុះតាមលំដាប់ ។ លុះទ្រង់ជ្រាបហេតុនុ៎ះ, ដើម្បីឱ្យកិត្តិសព្ទមានសុខភាពផង ដើម្បីអនុគ្រោះដល់អ្នកត្រូវការបុណ្យផង ដើម្បីអនុគ្រោះដល់បរិយត្តិសាសនៈនឹងមគ្គព្រហ្មចរិយ-សាសនៈផង, ទើបព្រះអង្គអនុញ្ញាតឱ្យកិត្តិឈឺចាំធ្វើមិនឈឺ ខន្ធលុក បរិភោគក្នុងកាលនឹងវិកាលអស់ប្រាំពីរថ្ងៃបាន នូវភេសជ្ជៈប្រាំគឺ សប្បិ-ទឹកដោះពស់, នវនីត-ទឹកដោះខាប់, តេលៈ ប្រេង, មធុ-ទឹកឃ្មុំ ផាណិត-ស្ករ ។ ពួកកិត្តិ, កាលបានបរិភោគភេសជ្ជៈគ្រប់គ្រាន់, ក៏មានសុខភាពបរិបូណ៌ ។

បន្ទាប់មក, ពួកអ្នកជ្រះថ្លា មានវេជ្ជបណ្ឌិតអាជីវកៈគោមារ័ត្យជាដើម បានបវារណាកិត្តិការព្យាបាលកិត្តិឈឺ, សង់គិលានសាលាសម្រាប់ព្យាបាលពេលកិត្តិឈឺនៅក្រុងវេសាលីជាដើម ។

នៅគិលានសាលា, ព្រះសម្ពុទ្ធតែងតែទ្រង់ធ្វើតទុកាសយាងទៅសួរដំណឹង ធ្វើគិលានុបដ្ឋានផ្ទាល់ព្រះអង្គ ដោយឥតសំគាល់ថា «តថាគតជាព្រះពុទ្ធខ្ញុំបំផុតលើលោក" ទេ ព្រោះដាក់ណីយកិច្ចដែលព្រះពុទ្ធ

ពាំងឡាយតែងតែទ្រង់ធ្វើ ហើយទ្រង់ប្រទានធម្មទេសថាដល់ភិក្ខុឈ្មោះថា ភិក្ខុឈ្មោះ គួរធ្វើអាសវៈឲ្យអស់ដោយធម៌ ៥ គឺ

១- ការយេ អសុភានុបស្សនៈ ការឃើញរឿយៗ ក្នុងកាយថា មិនស្អាត,

២- អាហារេ បដិក្កូលសញ្ញា សេចក្តីសំគាល់ក្នុងអាហារថា គួរខ្ពើម,

៣- សព្វលោកេ អនភិរតសញ្ញា សេចក្តីសំគាល់ក្នុងលោកពាំងអស់ថា មិនគួរត្រេកអរ,

៤- សព្វសង្ខារេសុ អនិច្ចានុបស្សនៈ ការឃើញរឿយៗ ក្នុងសង្ខារពាំងអស់ថា មិនទៀង,

៥- អដ្ឋត្តំមរណសញ្ញា សុប្បតិដ្ឋានៈ ការដំកល់សិប់នៅខាងក្នុង នូវមរណសញ្ញា ។

ដើម្បីឲ្យបដ្ឋានកិច្ច ប្រព្រឹត្តទៅបានស្រួលផង ដើម្បីឲ្យគិលានុបដ្ឋាកមានចិត្តចង់ព្យាបាល យកចិត្តទុកជាក់ខ្ជាប់ផង, ព្រះអង្គទ្រង់ដាក់បទបញ្ជាចំពោះគិលានភិក្ខុ ឲ្យប្រព្រឹត្តតាមហានៈខ្លួនជាអ្នកឈឺថា គិលានភិក្ខុ ត្រូវធ្វើខ្លួនឲ្យគិលានុបដ្ឋាក ដោយបំរើដោយធម៌ ៥ គឺ

១- សប្បាយការី បេរធ្វើខ្លួនឲ្យសប្បាយ (មិនសន្សំទោស),

๒- សប្បាយមត្តញ្ញូ ស្គាល់នូវប្រមាណក្នុងសប្បាយ ។

๓- កេសជ្ជបដិសេវិតា ទទួលកាន់កេសជ្ជៈ (ជាអ្នកពន្ធុំ) ។

๔- អាពាធាវិកត្តា ប្រាប់អាពាធឲ្យច្បាស់ ដល់គិលានុបដ្ឋាក ។

๕- អធិវាសិកជាតិកៈ ចេះអត់ទ្រាំនឹងអាពាធ ឆ្ងន់ស្រាល ។

ដើម្បីឲ្យស្រួលដល់គិលានតិក្ខុផង ដើម្បីឲ្យជម្ងឺជាសះស្បើយដោយឆាប់ហ័សផង, ព្រះអង្គទ្រង់ជាក់បទបញ្ជាឲ្យគិលានុបដ្ឋាកប្រតិបត្តិតាមហាន:ថ្នូនថា :

គិលានុបដ្ឋាកគួរប្រកបដោយធម៌ ៥ គឺ

๑- ជាអ្នកដំនាញក្នុងការចាត់ចែងផ្សំកេសជ្ជៈ (តម្រូវតាមសម្ដីជ្ឈនពេត) ,

๒- ជាអ្នកស្គាល់សប្បាយនឹងមិនសប្បាយ មិននាំឲ្យអ្នកឈឺអផ្សុកខ្សឹកខ្សួល ,

๓- ជាអ្នកមានចិត្តមេត្តាអ្នកឈឺ បំរើអ្នកឈឺមិនរំពៃអាម៉ាស: (កំរៃលោក) ,

๔- ជាអ្នកមិនខ្ពើមក្នុងការនាំចេញនូវទុច្ចារៈបស្សាវៈ កំអួត ទឹកមាត់ ,

๕- ជាអ្នកឈ្លាសដើម្បីញ៉ាំងអ្នកឈឺ ឲ្យយល់ ឲ្យចូលចិត្ត ឲ្យអង់អាចឲ្យរីករាយ ដោយធម្មីកថាមួយដងមួយគាល ។

ពីរសិស្សពីនេះ, គួរធ្វើគិលានតិក្ខុឲ្យរីករាយដោយសប្បាយ ๓ គឺ

๑- បច្ចុយសប្បាយ ការត្រូវចំណុចចិត្តដោយបច្ច័យគឺ ដោយសំពត់ស្បែកដណ្ដប់ សំពត់ដូតកម្រាលស្អាត ប្រាសចាកក្លិនមន្ទិលញើសក្អែល

សត្វល្អិត; ដោយអាហារចំណីមានរសត្រូវចំណង់ មិនខំនាស់ដល់រោគ ដល់បទបញ្ជាពេទ្យ; ដោយទីដេក ទីអង្គុយស្អុត ស្រឡះ មានអាកាសល្អ ប្រាសចាកធូលីស្មៅគ្រាគអព័ត្តអ្វ; ដោយកេសដ្ឋ: ៥ គ្រប់គ្រាន់នឹងនូសថំនើបពិសេស ។ ពួកែសត្តិសិទ្ធិ;

២- បុគ្គលសប្បាយ ការត្រូវចំណុចចិត្តដោយបុគ្គល គឺមានបុគ្គលជាសភាគមានធន្លះត្រូវគ្នា ជាទីពប់អាន ជាពហុស្សូតចេះនិយាយឲ្យសប្បាយ និយាយបន្ទោបង់ទុក្ខ ចេះប្រកបអារម្មណ៍ឲ្យត្រូវចិត្ត ប្រកបដោយធម៌ ៥ យ៉ាង;

៣- ធម្មសប្បាយ ការត្រូវចំណុចចិត្តដោយធម៌ គឺសប្បាយដោយមានបុគ្គលអ្នកឈ្លាសវៃ អាចណែនាំពន្យល់ សំដែងធម៌ដែលនាំឲ្យចិត្តដកអំពីការសោយអារម្មណ៍ជាទុក្ខ ព្រោះអាពាធ មកកាន់ឯកគ្គតារម្មណ៍ដែលអាចរម្ងាប់ទុក្ខវេទនា ចាន់ស្រាន្តចាកដម្មី ដូចព្រះអានន្ទសំដែងធម៌ដល់ព្រះគិរីមានន្ទជា ដើម ។

គិលានភិក្ខុ នឹងគិលានុបដ្ឋាក, កាលបើបានប្រតិបត្តិតាមបទបញ្ជារឿង ។ ខ្លួន យ៉ាងនេះហើយ, អាការៈពេតុអាពាធ នឹងអាចធាប់ជាបានដោយងាយ, ឈ្មោះថាបានស្រួលពាំងពីរខាង ភិក្ខុឈឺបានទទួលនូវសេចក្តីសុខអំពីការជាសះស្បើយចាកពេតុអាពាធ, អ្នកបំរើដែរឈ្មោះថា

ប្រទេសស្រុកស្រួលដល់អ្នកឈឺ ថែមទាំងបានសេចក្តីសរសើរ កេរ្តិ៍ឈ្មោះ
ល្អ ក្នុងហានៈរបស់ខ្លួនផង ។

ការព្យាបាលគិលានកិច្ចនេះ ជាការណីយកិច្ចមួយ ដែលព្រះពុទ្ធ
តែងតែទ្រង់ធ្វើដោយផ្ទាល់ព្រះអង្គ ឥតរើសអើងព្រោះពុទ្ធកាព ដូចទ្រង់
គក់បោកចីវរផ្ទុតទឹក ដុះលាងដំបៅ ចំរើដម្បីនៃព្រះបូតិគត្តតិស្សត្ថេរជា
ដើម ។

នេះជាទត្តមចរិយា ដែលពុទ្ធបរិស័ទបានប្រព្រឹត្តត ។ គ្នាមក ដល់
បច្ចុប្បន្ននេះ ដែលយើងជាពុទ្ធបរិស័ទជាន់ក្រោយផ្ទាប់បានធ្វើតាមដោយ
គោរពមកហើយ ។ ឥឡូវនេះ យើងបានទាំងបង្កើតឲ្យមានសមាគម
មានមន្ទីរព្យាបាលព្រះសង្ឃមានអាពាធជាដើម នេះជាឫស្តុតាងនៃការ
ប្រព្រឹត្តតាមទត្តមចរិយានៃព្រះសម្ពុទ្ធ ដែលព្រះអង្គជាព្រះពុទ្ធផង ធ្លាប់ជា
ទត្តមជាតិផង ប្រព្រឹត្តធ្វើមកហើយនោះ ។

សមាគមគិលានុបដ្ឋាន ចំពោះព្រះសង្ឃពុទ្ធសាសនិក

ឥឡូវនេះ នៅប្រទេសយើង ដែលជាប្រទេសពុទ្ធសាសនិកដ៏ល្បី
ក្នុងសកលលោក មានសមាគមមួយសម្រាប់ដួយព្យាបាលព្រះសង្ឃមាន
អាពាធ ហៅថា "សមាគមគិលានុបដ្ឋាន ចំពោះព្រះសង្ឃពុទ្ធសាសនិក" ។

សមាគមនេះមាន ឯកឧត្តម ឃួន-ណា ជាប្រធាន, សម្តេចព្រះសង្ឃនាយកតំណាងជាទីប្រឹក្សា ទទឹងបព្វជិតគ្រហិស្ថខួរទៅជាសមាជិក ហើយបិតនៅក្រោមព្រះពុទ្ធបត្ថម្ភក៍ដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រតំណាងព្រះអង្គ នៃសម្តេចព្រះបិតាឯករាជ្យជាតិ ទទឹងក្រោមការឧបត្ថម្ភនៃព្រះពុទ្ធរដ្ឋាភិបាល, ចានស្ថាបនាគិលានសាលាមួយហៅថា "មន្ទីរពេទ្យព្រះសង្ឃភុទ្ធ-សាសនិក" ចានបើកភ្ជាវខួលព្រះសង្ឃ មានអាពាធឲ្យចូលសំនខួលការព្យាបាលអស់ចំនួន ៣ ឆ្នាំមកហើយ ។

ព្រះសង្ឃមានអាពាធ ដែលចានខួលការព្យាបាលចានជាសះស្បើយ ហើយចេញទៅកំច្រើន ។ ចំណែកព្រះសង្ឃមានអាពាធ ដែលត្រូវការចូលទៅឲ្យព្យាបាលពេត មានច្រើនណាស់ទៅទៀត; តែព្រះសង្ឃទាំងនោះ, អង្គខ្លះដែលមានដម្ងូចន្ទំ កំចានចូលទៅសំនព្យាបាល, ឯអង្គដែលមានអាពាធល្មម។ កំគ្រាន់តែនៅខួលការពិសោធន៍ ចាក់ថ្នាំតាមពេលធ្លើការ ។

សកម្មភាពរបស់សមាគម ចានដើរសន្សឹមៗទៅតាមកំលាំងនឹងការអាចធ្លើទៅចានតាំងពីដើមរហូតមក ។ ប៉ុន្តែឥឡូវនេះ សមាគមមិនអាចនឹងខួលព្រះសង្ឃមានអាពាធឲ្យចូលសំនឲ្យហួសអំពី ៥០ រូបទៅ

ចាន ព្រោះថវិការបស់ខ្ញុំនមិនត្រូវអនុញ្ញាតឲ្យខ្ញុំទទួលបាន ។ ចំពោះ
ដំណើរនេះ សមាគមមានសេចក្តីស្តាយ ហើយអាណាចអធ្មមដល់ព្រះ
សង្ឃមានអាពាធ ដែលមិនបានចូលមកសឹងជាទីបំផុតហួសចិត្ត ។

សមាគមទទួលបំពេញសេចក្តីត្រូវការ របស់ព្រះសង្ឃមានអាពាធ
ឥឡូវនេះសេចក្តីត្រូវការរបស់ខ្ញុំនឲ្យគ្រប់គ្រាន់ ដោយមូលនិធិតាត់តជាក់ផ្ទុះចេញ
ប៉ុន្តែសេចក្តីត្រូវការនោះ នឹងដើរទៅដល់ទីដៅរបស់ខ្ញុំនបាន លុះត្រាតែ
ថវិការបស់ខ្ញុំ មានកំលាំងរឹងប៉ឹង ។ ប៉ុន្តែបើពុកជាយ៉ាងណាក៏ដោយ ក៏
សមាគមចេះតែទុំឲ្យអស់កំលាំងកាយ-ចិត្តបំពេញសេចក្តីត្រូវការនឹងគោល
បំណងរបស់ខ្ញុំនគឺ

១- ជួយព្រះសង្ឃមានអាពាធឲ្យស្រួលដល់ការប្រព្រឹត្តធម្មវិនយ,

២- អនុគ្រោះព្រះពុទ្ធសាសនាដែលព្រះសង្ឃកាន់ផ្ទាល់ ឲ្យឋិតនៅក្នុង
លោកវែងឆ្ងាយ,

៣- ប្រព្រឹត្តតាមពុទ្ធចរិយា នឹងទត្តមគតិនៃមនុស្សធម៌ គឺ ព្រហ្មវិហារ-
ធម៌,

៤- សំដែងឲ្យឃើញនូវពុទ្ធសាសនីកភាពរបស់ខ្ញុំន,

៥- ដើម្បីសុខ-ចំរើនសម្រាប់ខ្ញុំនផង អ្នកដទៃផង កុងឥឡូកធាតុនិង
បរលោក,

៦- ដើម្បីកត្តិនាមជាពីរោះ នៃជាតិ ប្រទេស សាសនា ព្រះមហា-
ក្សត្រ ។

គោលបំណងនេះ ឋិតនៅលើជីវិតរបស់សមាគម ។ ជីវិតរបស់
សមាគមចងជាប់នៅលើ ព្រះហឫទ័យ ព្រះទ័យសន្តោនចិត្តសប្បុរស
នៃសម្តេច ទ្រង់ ឯកទត្តម ព្រះតេជព្រះគុណ អស់លោក-អ្នក ដែលតែង
តែជួយផ្តល់ដល់សមាគមនូវខេយ្យធម៌ ទុស ប ច្ចយ ទបតរណ៍ផ្សេង។
ដើម្បីឲ្យសមាគមមានកំលាំងជីវិតធរមាននៅ ដើម្បីបំរើព្រះពុទ្ធសាសនា
ផ្នែកខាងការជួយព្យាបាលព្រះសង្ឃ មានអាពាធឲ្យអស់ចំណង់ ។
សមាគមមានប្រាមោទ្យយ៉ាងក្រៃលែង ចំពោះខេយ្យធម៌ដ៏ប្រសើរនោះ
ព្រោះថា សមាគមខ្លួនឯង ផ្តើតរវើរដើរតាម សកម្មភាពរបស់ខ្លួន ទៅលើ
សព្វាខេយ្យនៃសប្បុរសទូទៅ ឥតរើសសញ្ជាតិ ។ សមាគមមានសេចក្តី
សង្ឃឹមមាំ ចំពោះការទបត្ថម្ភជាដរាប អំពីចិត្តប្រកបដោយករុណា ចំពោះ
ព្រះសង្ឃមានអាពាធ សព្វទិសទី ។

ពោលដោយរួបរួមយើញថា សមាគមនេះ ជារបស់ពុទ្ធបរិស័ទ
ទាំងអស់ ទាំងពុទ្ធបរិស័ទឈ្មោះថា មាតាបិតារបស់សមាគម ព្រោះថា
សមាគមកើតឡើងអាស្រ័យនឹងពុទ្ធបរិស័ទ ។ ករណីនេះ ពុទ្ធបរិស័ទ
ហ្នឹងហើយ ជាអ្នកចិញ្ចឹមទំនុកដោះដល់សមាគម តាមការគាបជ្រើបានន៏ទំ

លាំង ។ គោលបំណងរបស់សមាគមនឹងដល់ទូវទីបំផុតបាន លុះតែសមាគមបានទទួលទានទឹកដោះរបស់សម្តេច ទ្រង់ ឯកទគ្គម ព្រះតេជព្រះគុណអស់លោក-អ្នក បានបរិបូណ៌ ។

សូមជ្រាបថា សមាគមដាឈ្មោះរួមដោយបុគ្គល ជនជាន ការ-ណ៍យកច្ចុ ។ ហេតុដូច្នោះ អ្នកដែលបានចូលកន្លងនាមពាំងបីនោះឈ្មោះថា សមាជិក ឬ សមាគមិក ។ រួបរួមទៅពុទ្ធបរិស័ទកំដូចសមាគមដែរ ឈ្មោះថា ជាទីទូវការមិនមានភេគ, អាយុវែង, សម្បុរកាយល្អ, សេចក្តីសុខ, កំលាំង, បញ្ញា, លាភ ដល់ព្រះសង្ឃ ដែលបានជាសះស្បើយភេគ ។

តាំងបច្ចុប្បន្ននេះ នឹងកន្លងលោកគត ។ ទៅ, ពុទ្ធបរិស័ទកំដូចសមាគម នឹងបានទូវអានិសង្សគឺ ការមិនមានភេគ, អាយុយឺនយូរ តាមកាលរូបសម្បត្តិល្អ, សេចក្តីសុខ, មានកំលាំងកាយច្រើន, បរិបូណ៌ដោយបដិភាណៈ, បញ្ញាមុតថ្លៃ, ជាទីស្រឡាញ់, ពេញចិត្តនៃមនុស្សទេពតា មានកិត្តិសព្ទពីពេះខ្លួរភ្លាយ, ដល់ទំលាយកាយស្លាប់ទៅនឹងបានទៅកើតក្នុងតំនូនល្អ ។ តទៅទៀត, ទៅទីណា ។ គេគោរពបូជាកន្លងនោះ ។ ដល់ទីបំផុតជាតិ នឹងបានសំរេចអរហត្តភាតំកិលេសទុក្ខសោកភេគភ័យប្រល័យជាតិ ជរ ព្យាធិ មរណៈ ទៅកាន់អមតនិព្វាន គ្មានវិលមកកន្លងវិលវៃបែបនេះទៀត » ។ ចប់ ។

កម្មកថា

របស់ព្រះអាចារ្យ ឈាង-ឆៃជ្លីង វត្តលង្កា

ទេសនាតាមវិទ្យុជាតិនៅថ្ងៃទី ១៩-១១-៥៨

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

សូមនមស្ការចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ដ៏ព្រះអរិយសង្ឃ ដោយសេចក្តីគោរព)។

អស់លោក-អ្នកស្តាប់ទាំងឡាយ វេលានេះ ជាថ្ងៃទីបួសថសីល ដែលអស់លោក អ្នកខំបំពេញធម៌បានសមាទានរួចស្រេចបាច់ហើយ; លំដាប់តទៅនេះ អាត្មាភាពសូមសំដែងធម្មទេសនា ពណ៌នាអំពីពាក្យថា "កម្ម" ព្រមទាំងអធិប្បាយពន្យ័តសេចក្តី ដើម្បីដួយបណ្តុះបុណ្យកុសល, សម្រាប់ត្រិះរិះពិចារណានឹងជាវត្ថុប្រតិបត្តិ នៃពុទ្ធសាសនិកជនទូទៅ តាមលំអានបាលីពុទ្ធភាសិត ដែលមានប្រាកដក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ត្រង់ពាលវគ្គថា :

តញ្ហ កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។

កម្មណាដែលគេធ្វើហើយ មិនក្តៅក្រហល់, នាំឱ្យគេពិតប្រាកដ ទទួលផល (ជាសុខ) ក្នុងកាលខាងក្រោយ

កម្មនោះឯង គេធ្វើហើយជាការគាប់ប្រសើរ ។

សេចក្តីអធិប្បាយ :

ក្នុងផ្នែពុទ្ធភាសិតខាងលើនេះ មានពាក្យមួយម៉ាត់គឺ " កម្ម " ដែលគួរដកស្រង់យកមកប្រែ ហើយអធិប្បាយតទៅ :

ពាក្យថា " កម្ម " ក្នុងទីនេះ ប្រែថា អំពើ, ការងារ ឬកិច្ចការ; សំដៅយកកម្ម ដែលបុគ្គលបានធ្វើហើយ ឥឡូវអតីតជាតិមកក៏មាន សំដៅយកកសិកម្ម, ទំនៀមទម្លាប់ជាដើម ជាអំពើដែលបុគ្គលត្រូវប្រកប, ត្រូវធ្វើក្នុងបច្ចុប្បន្នលោកនេះក៏មាន ។

ម៉្យាងទៀត, ពាក្យនេះ ជាតំយើងច្រើនឱ្យយល់សំដៅរកសេចក្តីអាក្រក់, ការខូចលេងខុសទោស, គ្រោះថ្នាក់, ការបង្កើតចង្អល់តានតឹងក្នុងចិត្ត លំបាកកាយជាដើម តែម៉្យាង; ដូចពាក្យគេប្រាប់និយាយថា " ខ្ញុំខ្ជិលធ្វើកម្មជាប់តាំងពីដើមឆ្នាំ រហូតមកដល់ចុងឆ្នាំ ពុំសូវបានធ្ងន់ខ្លួនឡើយ សប្បាយក្នុងចិត្តសោះ " ប៉ុណ្ណេះជាដើម; ប៉ុន្តែបើតាមសេចក្តីពិត ពាក្យនេះជាកណ្តាលមិនខាន់ប្រាកដជាល្អ ឬ អាក្រក់នៅឡើយ លុះតែមានសព្ទគឺ កុសលៈ ឬ អកុសលៈ ឬក៏ បុញ្ញៈ ឬនិងបាបៈ ភ្ជាប់ពីខាងដើម ទើបមានសេចក្តីប្រាកដថា ល្អ ឬ អាក្រក់ទៅបាន ដូចពាក្យថា សុលកម្ម ឬ អកុសលកម្ម ។

កម្មនេះ បើចែកតាមថ្នាក់ខ្ពស់ទាប ឬ ល្អអាក្រក់នោះ មានពីរយ៉ាង គឺ កុសលកម្ម ១, អកុសលកម្ម ១ ។

កុសលកម្ម ប្រែថា អំពើល្អ, អំពើដែលកំចាត់បង់នូវអំពើអាក្រក់ សំដៅយកអំពើឬការងារទាំងអស់ ក្នុងលោកនេះ ដែលមិនខុសនឹងពុទ្ធប្បញ្ញត្តិ ឬ ច្បាប់សម្រាប់រដ្ឋ ជាអំពើដែលអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងសរសើរ, តែងពាប់អាន ។ ឯពាក្យជាវេវចនៈនឹងកុសលកម្មនោះគឺ បុញ្ញកម្ម ប្រែថា អំពើជាបុណ្យ. អំពើដែលបណ្ឌិតគួរបំពេញបាន; កល្យាណកម្ម ប្រែថា អំពើដែលបណ្ឌិតគួរពាប់រក, គួរសរសើរ ។

អកុសលកម្ម ប្រែថា អំពើអាក្រក់, អំពើរបស់បុគ្គលអ្នកមិនឈ្លាសសំដៅយកអំពើដែលខុសនឹងពុទ្ធប្បញ្ញត្តិ ដែលពួកពាលជនតែងប្រព្រឹត្តធ្វើ ជាអំពើដែលព្រះពុទ្ធទ្រង់តិះដៀល ។ ឯពាក្យជាវេវចនៈនឹងអកុសលកម្មនោះគឺ បាបកម្ម ប្រែថា អំពើបាប អំពើលាមក; អធម្មកម្ម ប្រែថា អំពើមិនមែនជាធម៌, អករណីយកិច្ច ប្រែថា កិច្ចមិនគួរធ្វើ; អធម្មចរិយៈ ឬ វិសមចរិយៈ ការប្រព្រឹត្តិមិនជាធម៌, ការប្រព្រឹត្តិមិនសមរម្យ ។

បណ្តាកម្មទាំងពីរយ៉ាងនេះ ចំណែកអកុសលកម្ម ជាអំពើដែល

ព្រះពុទ្ធទ្រង់ហាម ឬគួលមិនគួរធ្វើដោយជាប់ខាត ព្រោះជាអំពើនាំមក
នូវទុក្ខទោសតែប៉ុណ្ណោះ ក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។

ក្នុងពិភពលោកនេះ មានសាស្ដាច្រើនជាច្រើន ដែលជាអ្នកបង្កើត
លទ្ធិសាសនាផ្សេងៗ មានពុទ្ធសាសនា, ព្រហ្មញ្ញសាសនា និងគ្រិស្ត
សាសនាជាដើម ។ បណ្ដាសាស្ដាចារ្យទាំងអម្បាលនោះ ព្រះបរមសម្ពុទ្ធ
របស់យើងជាអ្នកបង្កើតលទ្ធិពុទ្ធសាសនា ។ ព្រះអង្គទ្រង់ទេសប្បវត្តិផ្សេង
ក្នុងលោក ក្នុងចំណោមសាសនាផ្សេងៗ ដែលពួកមនុស្សក្នុងសម័យ
នោះកំពុងប្រកាន់ទិដ្ឋិលទ្ធិទីទៃពីគ្នា ជាអនេកប្បការ ពួកខ្លះប្រកាន់ថា កម្ម
ល្អ-អាក្រក់ដែលមនុស្សសត្វគ្រប់ប្រភេទធ្វើហើយ គ្មានផលប្រយោជន៍ ពាក់ព័ន្ធ
ក្នុងអតីតភពជាតិ ស្មោចគ្មានឃើញថា កម្ម ឬ អំពើដែលគេធ្វើហើយ
នឹងអំពើមិនបានផលល្អ-អាក្រក់អ្វីទេ, យ៉ាងនេះ ហៅថា អតីតភាវៈ ប្រែ
ថា អ្នកពោលប្រកាន់ថា មិនមានអំពើ គឺពួកអ្នកបដិសេធផល ។ ពួក
ខ្លះប្រកាន់ថា អ្នកបានល្អ, បានអាក្រក់, បានសុខ, បានទុក្ខ បានមក
ឯង។ គ្មាននរណាចាត់ចែង បែងចែកទេ មិនមែនបានមកពីកម្មអ្វីទេពាក់
ព័ន្ធក្នុងអហេតុកទិដ្ឋិ ស្មោចគ្មានឃើញថា ការល្អឬអាក្រក់ដែលមនុស្ស
សត្វបានមក ដោយមិនមានហេតុ-បច្ច័យទេ ស្រេចហើយតែជួបជួន,
ប៉ះប្រទះ យ៉ាងនេះ ហៅថា អហេតុកភាវៈ ប្រែថា អ្នកពោលប្រកាន់ថា

មិនមានហេតុ គឺពួកអ្នកបដិសេធហេតុ; សំដៅសេចក្តីថា ពួកអ្នកបដិ-
សេធកម្មជាអតីត ដែលជាហេតុឲ្យផលក្នុងបច្ចុប្បន្ន ។ ពួកខ្លះប្រកាន់
ថា គ្មានចាំងហេតុចាំងផល គឺប្រកាន់ថា អ្នកបានល្អ; បានអាក្រក់ក្នុង
បច្ចុប្បន្ននេះ មិនមានអ្វីឲ្យល្អ, ឲ្យអាក្រក់ទេ, អ្នកធ្វើល្អ-អាក្រក់បច្ចុប្បន្ន
នេះ ក៏មិនបានផលប្រយោជន៍អ្វីទៅក្នុងអនាគតដែរ ពាប់ចូលក្នុងនត្ថិកទិដ្ឋិ
សេចក្តីយល់ឃើញថា មិនមានហេតុមិនមានផល; យ៉ាងនេះហៅថា នត្ថិ-
កវាទី ប្រែថា អ្នកពោលប្រកាន់ថា មិនមានហេតុ-ផល គឺពួកអ្នកបដិ-
សេធផលដែលត្រូវបានមកពីកម្មចាស់, បដិសេធផលដែលនឹងត្រូវបាន
ក្នុងខាងមុខ ។ ពួកខ្លះពាប់ចូលក្នុងសស្សតទិដ្ឋិ សេចក្តីយល់ឃើញថា
លោកនេះទៀងពាក់ព័ន្ធថេរ គឺជាតិនេះឆាប់តើតជាសត្វ ទៅលោកខាង
មុខក៏តើតជាសត្វទៀតមិនប្រែប្រួល ។ ពួកខ្លះពាប់ចូលក្នុងឧច្ឆេទទិដ្ឋិ
សេចក្តីយល់ឃើញថា ពួកមនុស្សសត្វប្រតាកអត្តភាពនេះហើយ ដាច់
សូន្យសោះ មិនត្រឡប់មកតើតទៀតទេ ។ ទិដ្ឋិខាងក្រៅពុទ្ធសាសនា
មានប្រភេទផ្សេង ។ គ្មានច្រើនណាស់ ដូចយ៉ាងអន្តគ្គាហិកទិដ្ឋិ ១០ យ៉ាងគឺ
សេចក្តីយល់ឃើញថា លោកទៀង, លោកមិនទៀង, លោកមានទីបំ
ផុត, លោកមិនមានទីបំផុត ប៉ុណ្ណោះដោយ ។

ក្នុងព្រហ្មជាលសូត្រទីឃនិកាយ មានសំដែងអំពីរឿងទិដ្ឋិប្លែកគ្នា
នេះ មានចំនួន ៦២ យ៉ាង; ទិដ្ឋិទាំងនេះ មានមកតាំងពីបរមបុរាណ

មុនពុទ្ធកាលយូរអង្វែងណាស់, ជាទំដុំកំពុំដ៏ហួសកំឡាំង ប្រាជ្ញាមនុស្ស
សាមញ្ញ នឹងអាចចាក់ធ្លុះធ្លុះយល់បាន ។

អ្នកមេប្រកាសសាសនា ឬ មេលទ្ធិនីមួយ ។ សុទ្ធតែជាអ្នកមានសំដី
ថ្នឹមាត់ពូកែ អាចនិយាយតទល់ណែនាំពួកមនុស្ស អ្នកមានប្រាជ្ញាអន់
ខន់ឲ្យយល់ឲ្យចូលចិត្តដឿ ប្រព្រឹត្តកាន់តាមមតិទំដ្ឋរបស់ខ្លួន; ដូចយ៉ាង
ពួកខ្លះនិយាយថា គាំបិតជាបថវីធាតុ, សាច់របស់សត្វកំសង្គ្រោះចូលក្នុង
បថវីធាតុដែរ, មនុស្សយកគាំបិតទៅសម្លាប់សត្វ ប្រហែលគ្នានឹងយកគាំ
បិតទៅគាប់ដី តើនឹងឲ្យមានទោស ឬ មានបាបដូចម្តេចបាន ? ព្រោះគ្រាន់
តជាតុខាងក្រៅ ទៅប៉ះនឹងជាតុខាងក្នុង គឺសាច់សត្វប៉ុណ្ណោះ គិតមារ
យកបុណ្យបាបពីគ្នា ដូចជាហួសប្រមាណពេកណាស់ ដូចភ្លើងជាអាបោ
ធាតុ (ធាតុទឹក) បង្អើរបុះស្រោចស្រប់ព្រឹក្សាលតាវល្លិ ដែលជាបថវី-
ធាតុ ឲ្យជុះស្រស់បស់លូតលាស់ល្អ តើទឹកភ្លើងនឹងគិតមារយកគុណ
បំណាច់ដែរឬ ? ភ្លើងឆេះព្រៃត្រូវពិន័យធ្វើទោសភ្លើងឲ្យបានបាបដែរឬ ?
ប៉ុណ្ណោះជាដើម ។ នេះជាវោហារអាចដឹកនាំចាញ់ពួកមនុស្សឲ្យចូល
កន្លង់ផ្លូវដែលទ្ធិរបស់ខ្លួនបាន; បានជាមានមេលទ្ធិ, មានទំនៀមទម្លាប់
ប្រពៃណី, មានសាសនាផ្សេង ។ គ្នា ជាប់រហូតមកដល់សព្វថ្ងៃនេះ ។
ពួកខ្លះចូលចិត្តប្រកាន់ដឿគោរពបូជា ធម្មជាតិគឺ ដី, ទឹក, ភ្លើង, ឈើ,

ព្រៃ ក្តុំជាដើម ថាជាសរណៈត្តុដ៏ស័ក្តិសិទ្ធិ សម្រាប់ខ្លីពីនឹងផ្លាស់ខ្លួនស្លេ
ដោយដាវិត, កាលបើមានភ័យអាសន្នអន្តរាយតែងឡើងហើយ, មនុស្ស
ពាំនឹងឃ្លាយ តែងរត់បន់ស្រន់ធម្មជាតិពាំងនេះ សុំឲ្យរួចពីកុក្តភ័យជា
ដើម ។ សេចក្តីនេះ គួរឲ្យសន្និដ្ឋានបានថា ក្នុងសម័យនោះ ពួក
មនុស្សច្រើនតែយកធម្មជាតិពាំងអស់នេះ ជាទីពឹងទីរលឹកស្លេដោយដាវិត,
ឯធម្មជាតិពាំងនេះ ក៏ត្រឡប់ទៅជាព្រះរបស់មនុស្សលោកខ្លួនៅ សម្រាប់
ជាទីបន់ស្រន់បួងសួងសុំសុខសប្បាយ ម្ល៉ោះហើយបានជាមានពាក្យហៅ
ថា «ព្រះឆរណី, ព្រះអគ្គិ, ព្រះពាយ, ព្រះពិរុណ, ព្រះអាទិត្យ, ព្រះចន្ទ
ជាដើម ជាប់ហូតមកដល់សព្វថ្ងៃនេះ» ។ នេះ ជាដំនៀរបស់ពួកជន
អ្នកកាន់ព្រហ្មញ្ញាសាសនា ។

វត្តបំណងរបស់ព្រះសម្ពុទ្ធបរមគ្រូជាម្ចាស់ ក្នុងការប្រកាសលទ្ធិ
ពុទ្ធសាសនា ដើម្បីបដិសេធ ឬ រំលុបរំលាយចោលនូវសេចក្តីប្រកាន់
ខឹងទំនៀមទម្លាប់ប្រពៃណីពាំងអស់នេះ ។ ក្នុងចំណោមសាស្តាចារ្យក្នុង
លោកនេះ ព្រះសម្ពុទ្ធបរមគ្រូយើង ជាសាស្តាមួយយ៉ាងឯក ខាងប្រកាស
លទ្ធិពុទ្ធសាសនា ព្រះអង្គទ្រង់ជាកម្មវាទី ជាអ្នកសំដែងអាងកម្ម ទ្រង់
លើកយកកម្មឡើងជាធំ ជាកត្តុតាង ឬ ជាគោលចារឹកក្នុងការប្រកាស
លោសនា ឬ ការសំដែងធម៌ខ្លួនៅ, ទ្រង់សំដែងបំភ្លឺ, ពន្យល់ណែនាំពួក

វេនេយ្យសត្វឲ្យអាងប្រកាន់ដឿកម្មនឹងផលរបស់កម្មតែម្យ៉ាង គឺថា កម្មល្អ
ឲ្យផលល្អ, កម្មជាអាក្រក់ឲ្យផលអាក្រក់ ។ អ្នកបានល្អអាក្រក់, សុខទុក្ខ
ចំរើនវិនាស, មានក្រជាដើម ស្រេចហើយតែអំពើ ឬ កិច្ចការរបស់ខ្លួន
ម្នាក់ៗ បានធ្វើទុកក្នុងអតីតជាតិ ឬក្នុងជាតិបច្ចុប្បន្ននេះ. ឥតមានឧបាយ
ជួយឲ្យរួចចាកកម្មនឹងផលនៃកម្មបានឡើយ ។ សមដូចព្រះពុទ្ធកាសិកភារទ្វាជ
ព្រះអគ្គទ្រង់ត្រាស់នឹងមាណពម្នាក់ថា :

កម្មស្សកា មាណវ សត្តា កម្មទាយា
កម្មយោនិ កម្មពន្ធូ កម្មប្បដិសរណា កម្មំ
សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ ។

ម្នាលមាណព, ពួកសត្វមានកម្មជារបស់ខ្លួន, មានកម្មជាទ្រព្យ
មរតក មានកម្មជាកំណើត មានកម្មជាញាតិសន្ដាន
មានកម្មជាទីពឹងអាស្រ័យ កម្មចែករំលែកពួកសត្វឲ្យថោកថាប ខ្ពង់ខ្ពស់ ។

ម្យ៉ាងទៀត បុរសស្ត្រីក្នុងលោកនេះ អ្នកប្រាថ្នាកេរ្តិ៍ឈ្មោះល្អ យស
ស័ក្តិដ៏ធំខ្ពង់ខ្ពស់នឹងសេចក្តីសរសើរ អំពីសំណាក់នៃជនដទៃគួរប្រព្រឹត្ត
ធ្វើអំពើល្អ អំពើសុចរិត ដែលជាប្រយោជន៍ដល់ប្រទេសជាតិសាសនា
ពិត ។ មិនគួរលះបង់ប្រព្រឹត្តធ្វើអំពើថាប, លាមក, ទុច្ចរិតដោយស្វាត់
កំបាំងតែម្នាក់ឯង ឬ ក្នុងទីវាលវើយ ដែលជាហេតុនាំឲ្យវិនាសសាប

សូន្យប្រយោជន៍ប្រទេសជាតិផង នាំឲ្យអាប់ទុនហោកខាបដល់សាសនារបស់ខ្លួនផង ព្រោះព្រះពុទ្ធទ្រង់ត្រាស់ថា :

កម្មេន កិត្តិ លភតិ បសំសំ
កម្មេន ជាឯញ្ច វធញ្ច ពន្ធំ
តំ កម្មជាជាករណាំ វិទិត្វា
កស្មា វាទេ ឧត្តិ កម្មន្តិ លោកេ ។

បុគ្គលបានកិត្តិស័ព្ទ សេចក្តីសរសើរ ព្រោះអំពើ (ល្អ) បាន សេចក្តីវិនាសសាបសូន្យនឹងការសម្លាប់ចាប់ចង ព្រោះអំពើអាក្រក់ បើដឹងថា អំពើឬកម្មជាហេតុធ្វើឲ្យមនុស្សផ្សេងគ្នាយ៉ាងនេះហើយ ម្តេចឡើយគឺពោលថា "កម្មគ្មាន" ក្នុងលោក ។

ព្រះសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់ថា របស់អ្វីៗក្នុងលោកនេះ ប្លុងសង្ខតប្រកបដោយហេតុផល គឺថា ទើបវត្ថុនេះកើតមាន ព្រោះកើតឡើងពីវត្ថុនោះ ព្រោះតែមានវត្ថុនោះ បើមានវត្ថុនេះ បើវត្ថុនោះមិនមានទេ វត្ថុនេះក៏មិនអាចកើតមានដែរ ព្រោះតែវត្ថុនោះវិនាស ទើបវត្ថុនេះលាយសៅដែរ ។ នេះជាទ្រឹស្តីរបស់ព្រះពុទ្ធសាសនាដែលស្តីអំពីកម្មជាធំ គ្មានលំណាំជាំដណាំអ្វីក្នុងលោកនេះ បុគ្គលនោះនឹងត្រូវច្រូតកាត់យកផលណានោះវិញមិនខាន ។ អំពើណាមួយរបស់មនុស្សក្នុងលោកនេះពោះ

ល្អក្តី អាក្រក់ក្តី អាចនឹងឲ្យផលក្នុងបច្ចុប្បន្ននឹងអនាគតមិនខាន ។
ឥតមាននរណាមួយគេចឲ្យផុតពីផលកម្ម ដែលខ្លួនបានធ្វើនោះឡើយ ។
សមដូចព្រះពុទ្ធភាសិត ក្នុងធម្មបទខុទ្ទកនិកាយ ត្រង់ថាបាឡីគាថា :

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ
ន បព្ពតានំ វិវរំ បវិស្ស
ន វិជ្ជតេ សោ ជគតិប្បទេសោ
យត្រដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។

ពុំឃើញថាមានបុគ្គលរត់ទៅពួនឮជ័អាកាស ក្នុងកណ្តាលសមុទ្រ ឬចូលទៅសម្ងំនៅក្នុងចន្លោះភ្នំ ឬក៏ផ្នែប្រទេសលើផែនដីណាក៏ដោយ ក៏មិនអាចគេចឲ្យផុតពីអំពើអាក្រក់របស់ខ្លួនបានទេ ; ។ ព្រះពុទ្ធភាសិតនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា ការទទួលយកនូវបុណ្យនឹងបាប តាមផលនៃអំពើល្អនឹងអាក្រក់ដែលខ្លួនបានធ្វើពុំខុសមក ព្រោះផលហុចឲ្យមិនហួសពីអំពើរបស់ខ្លួនទេ ។

ពួកពុទ្ធបរិស័ទបានជឿជាក់ច្បាស់ហើយថា ព្រះពុទ្ធជាម្ចាស់ទ្រង់មិនយល់ត្រមថា ក្នុងពិភពលោកនេះ មានអាទិទេពណាមួយមានឫទ្ធិអំណាចអាចបង្កើតផែនដីនឹងសត្វលោកហើយដួយឲ្យបានសុខចំរើន ខ្ពស់ខ្ពស់នោះទេ ។ ព្រះអង្គទ្រង់ពិចារណាឃើញច្បាស់ នូវដីវិភាពរបស់លោកលើផែនដីនេះ សុទ្ធតែអាស្រ័យនូវកម្ម អំពើប្រកបរៀងៗខ្លួនអស់ ។ បើជនណា

មួយមិនធ្វើការងារ ដើម្បីជីវិតទេ ជននោះមុខជានឹងស្លាប់ដោយពិត ។

ប្រទេស ឬ ស្រុកណា សង្គមណា ដែលមានការងារសម្រាប់ឲ្យមនុស្សធ្វើមិនគ្រប់គ្រាន់ មិនពេញលេញ ឬជា មានមនុស្សអ្នកធ្វើការតិចគ្នា ប្រទេស ស្រុកសង្គមនោះ ។ នឹងធ្លាក់ទៅជាវិបត្តិ, សាបសូន្យ, អាប់ឧនឬកំព្រារហោមរហាមមិនខាន់ឡើយ ។

សេចក្តីនេះ គួរយើញថា លោកពាំនមូលមានលេស្យាំនៅមុខហើយតាំងនៅបិតថែរបាន ដោយអាស្រ័យការងារ ទើបព្រះពុទ្ធទ្រង់បែងចែកការងារតាមលំដាប់ថ្នាក់ពាប កណ្តាល ខ្ពស់ មាន ៣ ថ្នាក់ ដើម្បីកុំឲ្យមនុស្សខ្វិលច្រអូសនៅទំនេរ ឲ្យមានព្យាយាមប្រកបការងារធ្វើគ្រប់ជាតិកុំណើត ។

ឯការងារជាន់ពាប សម្រាប់បុគ្គលណាមួយមានចំណង់ចង់រស់នៅក្នុងលោកនេះ ត្រូវថ្នាចង់បានកេរ្តិ៍ឈ្មោះយសស័ក្តិ ទ្រព្យសម្បត្តិធនធានត្រូវធ្វើតាមកម្មវិធីសម្បទា ៤ យ៉ាងគឺ :

-១- ការគ្រាក់ត្រេះ , ការសុះសាម្ភីម្ភា ការរៀសរៀប្រញាប់ប្រញាល់ចាប់ការងារតាមមុខត្រួសួន , មុខងារនៅទីរៀង ។ ខ្លួន , តាមវ័យតាមកាលៈទេសៈរបស់លោក ផ្លាស់ប្តូរប្រែប្រួល ដោយមិនអាងដល់ហេតុ ៦ យ៉ាងថា ក្តៅពេក , ត្រជាក់ពេក, ព្រឹកណាស់ , ល្ងាចណាស់ជា

ដើមហៅថា «ទុដ្ឋានសម្បទា» ។

๒- ការចេះប្រមែប្រមូលទ្រព្យសម្បត្តិឲ្យគង់វង្សល្អ. មិនឲ្យវិនាស អន្តរាយ ប្លន់បង់ដោយហេតុណាមួយ មានចោរលួចឬភ្លើងឆេះជាដើមនឹងការរៀរចាកការប្រព្រឹត្តអបាយមុខទាំង ๔ មានលេងស្ត្រីនឹងជក់សុរាជាដើម ដែលជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិហៅថា «អារក្ខសម្បទា» ។

๓- ភាពជាអ្នករៀរចាកបាបមិត្រហើយ សេពគប់. កប់ប្រសព្វតែនឹងកល្យាណមិត្រ គឺមិត្រល្អមានសីលធម៌ មានមធ្យាបាយល្អចេះនិយាយដឹកនាំទៅកន្លែងត្រូវ, ផ្លូវសុខចំរើន ហៅថា «កល្យាណមិត្តតា» ។

๔ ការចេះចាយវាយទ្រព្យសម្បត្តិក្នុងការចិញ្ចឹមជីវិត. បេះសំចៃលៃលកឲ្យស្មើ ឲ្យសមរម្យនឹងកំឡាំងធនធានរបស់ខ្លួន, បេះបែកុរលៃលកឲ្យដល់ដន់អ្នកអត់ឃ្លាន, បេះស្គាល់ប្រមាណក្នុងការស្វែងរក, ការចេះចួលការប្រើប្រាស់ចាយវាយផ្សែង ។ យ៉ាងនេះហៅថា «សមជីវិតា» ។

សម្បទាទាំង ๔ យ៉ាងនេះ ឧកញ៉ាការងារឬជាការណ៍យកចិត្ត សម្រាប់បុរសស្ត្រីអ្នករស់នៅក្នុងបច្ចុប្បន្ននេះ ?

ការងារថ្នាក់កណ្តាល សម្រាប់បុរសស្ត្រីណា មានសេចក្តីធុញទ្រាន់នឿយណាយ មិនចង់នៅក្នុងលោកនេះ មានប្រាថ្នាចង់ទៅកើតលោកខាងមុខ ត្រូវធ្វើតាមសម្បទាបរលោក ๔ យ៉ាងគឺ

๑—ការបរិបូណ៌ដោយការជឿកម្មនិងផលរបស់កម្ម គឺជឿថា កម្ម
ល្អនិងឲ្យផលល្អ, កម្មអាក្រក់និងឲ្យផលអាក្រក់ ឬ ជឿថា ចុះបុណ្យ,
គុណពេស កើតមកពីខ្លួនឯងទាំងអស់ប៉ុណ្ណោះជាដើម យ៉ាងនេះហៅថា
"សទ្ធាសម្បទា" ។

๒- ការពេញលេញដោយការក្សារៀបរយ ប្រុងប្រយ័តតាយ រាថា
ចិត្តរបស់ខ្លួនឲ្យមានរបៀបរៀបរយ សណ្តាប់ធ្នាប់ល្អ បានដល់ការក្សា
និច្ចសីលនិង ๑ ចោសថសីលជាដើម យ៉ាងនេះហៅថា "សីលសម្បទា"។

๓- ការលះសេចក្តីកំណាញ់ស្វិតស្វាញ ដើម្បីចំណាយធនធានតាម
តិច—ច្រើន សម្រាប់សាងសាលារៀន, មន្ទីរពេទ្យ, ស្ពាន ផ្លូវថ្នល់
កុដិ, សាលា, និងព្រះវិហារជាដើម ទុកជាប្រយោជន៍ប្រទេសជាតិ
សាសនា យ៉ាងនេះហៅថា "ចាគសម្បទា" ។

๔- ការខំប្រឹងប្រែងសិក្សារៀនសូត្រចំណេះវិជ្ជា ផ្លូវលោកផ្លូវធម៌
ដើម្បីឲ្យបានចេះដឹង ពិចារណាឲ្យស្គាល់គុណពេស, ទុសត្រូវ ល្អ
អាក្រក់ បុណ្យបាប, សុខទុក្ខ ជាដើម ឬ ការពិសោធន៍ រាវរកនូវប្លែសគល់
នៃសង្ខារទាំងពួង ឲ្យឃើញថាជារបស់មិនទៀង, ជាទុក្ខ, មិនមែនខ្លួន
ប្រាណ, មិនមែនយើងគេជាដើម យ៉ាងនេះ ហៅថា "បញ្ញាសម្បទា"។

សម្បទាទាំង ๔ យ៉ាងនេះ ទុកជាការងារ, កិច្ចការ ជាប្រយោជន៍

ជាទ្រព្យសម្បត្តិ ឬ ជាសម្បឹងអាហារ សម្រាប់បុគ្គលម្នាក់ ។ ដែលមានដំណើរត្រូវចេញចាកលោកនេះ ទៅតាន់លោកខាងនាយដោយពិត ។

ការងារថ្នាក់ខ្ពស់បំផុត សម្រាប់ពពួកជនដែលមានសេចក្តីធុញទ្រាន់ខឹងការលើសើត រើសឆ្ងាប់ញឹកញាប់រកទីបំផុតគ្មាន មានទ្រាថ្នាត្រង់កន្លែងផុតកើតស្លាប់ ផុតទុក្ខ ពោលគឺព្រះនិព្វាន ត្រូវធ្វើការងារឬបំពេញប្រយោជន៍ពីរខាងដើម ឲ្យបានជិតដល់ ឬ ពេញលេញគ្រប់គ្រាន់ ។ ព្រះនិព្វាននេះ ជាទីបំផុតនៃពុទ្ធសាសនា ជាកន្លែងរំលត់ទុក្ខ ជាកន្លែងខេមក្ខេមជាកន្លែងបញ្ឈប់ដំណើរបរបស់ជាតិ ។ ពួជនៃតិរ៍ស័តណ្ហាតូច ។ មានអនុសយក្លេសនឹងតិរ៍ស័តធំ ។ មានពាគ:ទោស: មោហ:ជាដើម ដែលជាហេតុនាំឲ្យបន្តជាតិជរាព្យាធិនឹងមរណ: កន្លងវាលវដ្តសង្សារ ឥត មានសេសសល់អ្វីក្នុងព្រះនិព្វាននោះទេ ។ និយាយយ៉ាងខ្លីមកថា ព្រះនិព្វានជាកន្លែងបញ្ឈប់ ឬ បញ្ចប់កំណើតថ្មីរបស់សត្វ យ៉ាងនេះ ហៅថា "បរមត្ថប្រយោជន៍" ឬ «ឧត្តមប្រយោជន៍» ។

បើនិយាយអំពីប្រយោជន៍វិញ ព្រះពុទ្ធសាសនា ជាសាសនាមួយមានប្រយោជន៍ សម្រាប់ហុចឲ្យឬផ្តល់ឲ្យដល់ជនអ្នកដឿស្តាប់តាមកាន់តាមមាន តាមជាន់ តាមថ្នាក់ ពាប តណ្ហាលនឹងខ្ពស់បំផុត ដូចសេចក្តី

ដែលបានពណ៌នាមកនេះ ។ ពុទ្ធបរិស័ទចាំងឡាយ គួរសន្និដ្ឋានថា ព្រះពុទ្ធសាសនាដែលយើងកាន់សព្វថ្ងៃនេះ ជាតួប្រយោជន៍មួយដ៏ខ្ពង់ខ្ពស់អស្ចារ្យ, រកប្រយោជន៍ណាក្នុងលោកនេះមកប្រៀបផ្ទឹមឲ្យត្រឹមស្មើនឹងប្រយោជន៍គឺ ពុទ្ធសាសនានេះ ពុំមានឡើយ ។

ហេតុនេះ ពុទ្ធមាមកជនចាំងឡាយ អ្នកប្រាថ្នាប្រយោជន៍ សេចក្តីសុខ, ចម្រើន-កើតឡើងល្អ យសស័ក្តិដ៏ខ្ពង់ខ្ពស់នឹងសេចក្តីសរសើរជាដើម ក្នុងបច្ចុប្បន្ននឹងបរលោក គួរបព្រឹត្តធ្វើអំពើ ឬ កិច្ចកម្មការងារណាល្អ ដែលជាប្រយោជន៍សុខ ចំពោះ ដល់ប្រទេសជាតិ នឹងសាសនារបស់ខ្លួនតាមន័យដែលបានរៀបរាប់មកហើយ ។

ពណ៌នាក្នុងធម្មកថាមកនេះ អំពីពាក្យថា "តម្ម" ចប់ដោយសន្ទុតត្រឹមប៉ុណ្ណេះ ។

ដោយតេជៈនៃព្រះរតនត្រ័យនឹងកុសលនៃធម្មទេសនានេះ សូមឲ្យប្រជាជនចាំងឡាយ ក្នុងសកលកម្មដដ្ឋ នឹងពិភពលោកចាំងមល ដល់នូវការលុតលាស់ដុះដាលចំពោះឡើង នឹងសន្តិភាព កុំបីឃ្លៀតកាយទៅជាប្រការដទៃឡើយ ។

រឿងកំដិលមានភ័ព្វ

លោក លាង – ហាប– អាន

រៀបរៀង

ក្នុងសម័យកន្លងទៅហើយ, មានបុរសស្វាមីភរិយា ប្រកបដោយភាព
នៅក្នុងភូមិភាគ នាជនបទមួយ ។ បុរសប្តីជាមនុស្សខ្ជិលច្រអូស
សំដីរកមនុស្សឯទៀតប្រដូចគ្នាន ។ ពាល់ព្រឹក បុរសតែងក្រោកពីដេក
នៅពេលអ្នុណារះផុតស្រឡះ ។ បុរសពុំមានធ្វើការអ្វី ហួសពីអង្គុយ
ត្រចោមក្បាលជង្គង់, កេះក្បាត, ស្ទាបហួមៗ ទេ្បីយ ។

ថ្ងៃមួយ, ក្នុងរដូវដែលផុតពេលក្លៀវស់ហើយ បុរសបានដឹកគោ
មួយនឹម យកទៅឃ្វាលឯភ្លឺស្រែ ។ កាលបើបានទៅដល់ទីវាលដ៏មាន
ស្មៅខ្ចីៗ បុរសក៏ដើរចុះទៅដែ មើលនាយ_អាយហើយត្រូចស្មៅមួយ
គុម្ព ចង់ខែ្វគោចាំងពីរនៅនោះ ។ ស្រែចហើយ បុរសក៏ដើរចូលទៅ
ក្រាលក្រមាចំរេតខ្នងក្រោមដើមឈើ ។

រីគោ កាលបើបរិភោគស្មៅនៅដុំវិញខ្លួនអស់ហើយ ក៏តម្រែ្លល
ចាល់តែរបើកដីមួយផ្ទាំងធំ ។ ឃើញដូច្នោះ បុរសក៏ដើរមកចាប់គោ ។

បុរសងាកទៅមុខ ឃើញត្រង់ផ្នែងរបើកដីនោះ មានក្រហូងមួយកន្លែង បុរសដើរទៅមើល ទៅដឹងហើយ ខ្នងមើលទៅស្រាប់តែឃើញមានកំណប់ពាងស្ពរមួយ ពេញទៅដោយមាសក្រហមផ្លេ ។ ឃើញយ៉ាងនោះ បុរសគិតខ្លួនឯងថា: "ហ៊ឹ:! ចានប្រយោជន៍អ្វីបែបនេះ!" ។ ថាដូច្នោះហើយ, បុរសក៏យកគុម្ពស្មៅរបើកមកគ្រប់មាត់រណ្តៅដដែលទៅវិញ ។ ត្រឡប់មក, បុរសក៏ដឹកគោមកផ្ទះវិញ ។

ថ្ងៃនោះ, ភរិយាចានរៀបកោជនាហារយ៉ាង ឆ្ងាញ់ពិសាជូនស្វាមីៗ កាលបើអាស្រ័យឆ្អែតហើយ, បុរសទៅអង្គុយពិភាក្សាលេងនឹងភរិយានៅលើផ្ទះកណ្តាល ។ ខ្នងហួសចិត្តពេក, បុរសអស់សំណើចតែម្តងឯង ។ ភរិយាឃើញដូច្នោះ ក៏សួរទៅថា: "អ្នកបងសើចរឿងអ្វី?" ។ បុរសតាំរ៉ាយរ៉ាប់ទៅភរិយាវិញថា: "ឯងអើយ! បងនឹកទៅចង់តែសើច ពីថ្ងៃមិញ, បងយកគោទៅចងនៅនឹងគុម្ពស្មៅមួយ, ស្រាប់តែវាទាញរួរបើក, លេចឯកំណប់មាសមួយពាងធំ" ។ ពុំតែប៉ុណ្ណោះ, នាងស្រីនឹកខ្មាស ដញ្ជក់មាត់ថា: "អើ: ម៉េចអ្នកបងមិនយកមក!" ។ បុរសគបាំងស្នាមញញឹម ទៅថា: "ហ៊ឹ:! យកមកនាំឲ្យតែធ្ងន់! បងយកដីគបដដែលទៅវិញហើយ!" ។ នាងភរិយាក៏គបញាប់មាត់ទៅវិញភ្លាមថា: "យី! បើយ៉ាងហ្នឹង ជូនខ្ញុំទៅឥឡូវចុះ ខ្ញុំនឹងដឹក

ទូលយកមកទុក" ។ កាលបើគិរយោនយាយឲ្យដូនៗ, បុរសក៏ចាន
ហាមយាត់ថា "ចាំស្អុក" ។

គាប់ជួនជាពេលនោះ មានអាចារកំណាចម្នាក់ ដែលវាតែងតែ
ដើរលួចរកតគ្រាតគេគ្រប់ផ្ទះ, ក៏ចានចូលមកពួនស្ដាប់ដើងការ ។ ចោរ
នោះបានឮវាចារសុន្ទរនាគ្នា រវាងបុរសនឹងភរិយា ក៏ទុកអត្រួច ព្រមចាំង
កាត់ដុំយួយដើងកន្ទេងស្រាប់ ។ រួលបដើរចេញពីក្រោមផ្ទះ ប្រញាប់
ប្រញាល់ទៅរកចប, ចន្ទុះ ដើរទៅដល់កន្លែងកំណប់ភ្លាម ។ ចោរចាន
ឃើញគុម្ពស្មៅរបើកជាក់ ។ រាំដុតចន្ទុះគ្រាលមើលទៅ ក៏ឃើញពាង
មួយប្រាកដមែន ។ ប៉ុន្តែចោរនោះ ពុំចានឃើញមាសមួយដុំសោះ, បែរ
ជាប្រទះសុទ្ធតែសត្វអាស៊ីរពិស កំពុងរាប្រចាក់បើកពាការនៅក្នុងនោះ ។
ចោរមានសេចក្ដីភ័យតក្កមាមហិមា ព្រមទាំងនឹកខឹងជាអនេក ក៏ស្ទុះ
យកឈើមួយបន្ទុះគ្រប់មាត់ពាងដាត ។ ចោរចាញចប ខំដកលុងយក
ពាងនោះចានមកក្រៅ ហើយនឹកក្នុងចិត្តថា នេងឈ្មោះសបុរសនោះឲ្យ
ខានតែចាន ។ ចោរលីពាងមកដល់ផ្ទះបុរសវិញមួយរំពេច ។ ពេលនោះ
ជាពេលកណ្ដាលអធ្រាត្រ, អ្នកផងចូលនិទ្រាលក់ស្កប់អស់ទៅហើយ ។
ចោរចាញយកដណ្ដើរផ្ដួកជាក់ឡើងលប ។ ទៅលើដំបូលផ្ទះបុរសនោះ
ហើយក៏តត់ស្ទឹកចំហរ ផ្ងើងគូថពាងចាក់ពស់មកខាងក្នុងបន្ទប់ផ្ទះ ។ រីង

ពស់កាលបើឆ្ងាត់ចេញពីក្នុងពាងទៅក្រោម ក៏ប្រែក្លាយទៅជាដុំមាសឆ្ងាត់
រពុកខ្លួនភ្លាមទៅលើក្តារក្រាល ធ្វើឲ្យបុរសនឹងភរិយាភ្ញាក់ ក្រោកឡើង
ភ័យស្រឡាំងកាំង រត់យកចង្កៀងមកបំភ្លឺមើល ឃើញសុទ្ធតែដុំមាស
ហើយគឺមានសេចក្តីត្រេកអរឥតឧបមា ។ ចំណែកឯពោរ កាលបើដឹង
ថា ម្ចាស់ផ្ទះក្លាក់ដឹងខ្លួនហើយ , ក៏ស្ទុះចុះម្ទីមារត់ចេញទៅវិញ ដោយ
គិតក្នុងចិត្តថា « ពស់ពាងនេះ នឹងលួនទៅចឹកប្រពន្ធមនុស្សអស់ជ្រុះនេះ
ជាពុំខាន » ប៉ុន្តែ បែរជាពុំដូច្នោះសោះ នាយបុរសក៏ត្រឡប់ជា បាន
ទទួលលាភឥតប្រៀប ពុំចាំបាច់ទៅបង់កំឡាំងដល់បន្តិចបន្តួចផង ។

រំលងកាលពីនោះមក, ដំណឹងនេះ បានឮសុះសាយទៅពេញពាង
តីក្លូម ។ ពោរនោះ នឹកក្តៅចិត្តថា នឹងទៅឈ្នានីសបូនយកប្រពន្ធបុរស
នោះឲ្យអន្តរាយអស់ ។

ថ្ងៃមួយ, ក្រោយដែលបានចំពេញកិច្ចការក្នុងផ្ទះរួចស្រេចហើយ
បុរសក៏ដើរចូលទៅដេកលេង នៅក្រោមដើមស្តៅខាងក្រោយផ្ទះ ។
បុរសបានពិនិត្យ ឆ្លៀងឃើញស្រមោចមួយរន្ធ ដែលមានមេមួយក្រុម
ចេះតែនាំគ្នាវារចេញ វារចូល ធ្វើឲ្យបុរសភ្ញាក់ផ្អើលរៀបរាប់ថា « ហ៊ឹះ !
អាឯងចេញប៉ុន្មានក៏អញដឹង ចូលប៉ុន្មានក៏អញដឹង , » ។ បុរសនិយាយ
ពាក្យនេះ ចាស់តែក្រោកមកផ្ទះវិញ ។

ក្នុងវេលាយប់នោះ, បុរសចូលទៅនៅជ្រាជាមួយភរិយាក្នុងបន្ទប់ ។ គាប់ដួងជាយប់នោះ នាយចោរដែលបំរុងនឹងឈានទីសបុរស ក៏បានប្រមូលគ្នាគ្នា បានប្រាំមួយប្រាំពីរនាក់ លបចូលទៅក្រោមផ្ទះ ដើម្បីស្តាប់ដើងការ ក្រែងមានមនុស្សច្រើនហួសពីនោះ ។ បុរស, កាលបើខ្លួនឮពាក្យពាំងនេះចាំស្ងាត់ពីសេលាថ្ងៃ លុះនិយាលក់ទៅ ក៏យល់សប្តិឃើញអ្វីពុំដឹង, ក៏នៅតែនិយាយប៉ាច់ប៉ាច់ថា: "ហ៊ឺវើយ គ្នាឯងប៉ុន្មាននាក់ ក៏អញជឿន អាឯងចូលប៉ុន្មាន ក៏អញជឿន ចេញប៉ុន្មានក៏អញជឿន . . . ." ។ គ្រាន់តែពាក្យប៉ុណ្ណោះ ពួកចោរសំគាំងមើលមុខគ្នាផ្សេកៗ ហើយនាំគ្នាវាលបរគេចេញទៅលំទៅវិញ រៀងហ៊ានមកបៀត ។

តាំងពីនោះមក, ចោរកំណាចចង់ផ្តន្ទាបុរស បានប្តេជ្ញាក្នុងចិត្តថានឹងរៀងចង់គំនុំនឹងបុរសនេះខ្លាំងហើយ, ព្រោះគេនេះជាមនុស្សមានឫទ្ធិណាស់ ។

ចោរក៏បានទៅប្រគបរបរលក់ដូរទៅវិញ ។ រាល់ៗ ថ្ងៃ ចោរនេះតែងតែរកសាច់ផ្តួលដើរលក់គ្រប់ដំបន់ ។ មានមួយថ្ងៃ, វេលាម៉ោង៩ ព្រឹក, បុរសពុំបានទៅណាទេ ។ បុរសបានឃាំភរិយាមកអង្គុយនៅមាត់ទ្វារស្រាប់ ។ ដោយរមាស់ក្បាលតេក, នាងភរិយាក៏បានពីនស្វាមីឲ្យរកសក់រកចៃឲ្យនាង ។ បុរសជាប្តីបានខ្នះខ្នែងធ្វើតាមបង្គាប់នាង ដោយ

មេត្រី ។ ជាទេសកាលអាក្រក់ ពេលនោះ នាយចោរបានរែកសាច់ជ្រូក មកដល់ចំមុខផ្ទះនាយបុរស ហើយពាយនាយថា " សាច់ជ្រូកអើយ សាច់ជ្រូក " ។ ខ្មៅមួយរំពេចនោះ បុរសមានភ័ព្ទ ចាប់បានមៀច មួយធំ ហើយអស់សំណើចបញ្ចេញវាចាយ៉ាងខ្លាំងថា « អើរើយ អញ រកតែមុខអាចោរឯងទេតើ ឥឡូវ ឃើញស្រេចអាចោរចង្រៃ ។ គ្រាន់តែឮប៉ុណ្ណោះ ក្មេកលក់សាច់ជ្រូក ដែលមានខ្លួនស្រាប់ ក៏ធ្វើមុខមើលឡើង ឡើង មើលនាយអាយ ឆ្កែអស្ចារ្យ គេស្គាល់ខ្លួនពិតហើយ " ។ ចំណាស់ស្រែកចោល ហើយស្ទុះរត់យកតែអាយុ លែងមើលក្រោយ ខ្លុកសាច់ជ្រូកទាំងភ្លៀងនាយបុរសនឹងកំរោ ។ ចុះមករើសយកទៅ ចែកចាយញាតិផង ជាតទាំងបរិភោគជាសុខសាន្តហោង ។

x

x x

កណ្ដាទី ៣៤

ឧកញ៉ាវិបុលរាជសេដ្ឋា ស្ងួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ធំងបេះទុបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ខ្ញុំនម៉ែកំគាន់តែជព នឹងរកអ្នកឯណាមកចិញ្ចឹមព្យាបាលក្បាម៉ែកំគ្មាន ចូរឆ្ងាយកម៉ែទៅធ្វើទោសហ៊ាយនឹងឲ្យយកទៅសម្លាប់ថា ពីព្រោះកូនមកទៅនឹងខ្លៅពីគ្រប់ខ្លួសព្រាយចូរឆ្ងាយ នេះហាក់តែធឿយុកមេត្តាម៉ែដោយឃើញជរាអនាថា ដួយនិយាយឲ្យលើកទោសទើបម៉ែមិនស្លាប់ ប្រសិនបើកូនទៅមានកតញ្ញូគុណិតម៉ែមកវិតចូរឆ្ងាយហ៊ាយ ជីវិតម៉ែកំមិនមានអន្តរាយ បើចូរឆ្ងាមិនរោលោះអាល័យដល់ម៉ែ មិនបានទៅតាមសំបុត្រនេះទេ ម៉ែកំនឹងស្លាប់ដោយអាជ្ញាចូរឆ្ងាប្រាកដ កាលធឿយុកតែងឮ

សំបុត្រហើយ កំពុងតែបំរើឲ្យនាំទៅឲ្យឈើស៊ុងស្រុកស៊ុនអៀ ប្រាប់ថាម្ដាយ
ជួលឲ្យកាន់សំបុត្រនេះមកឲ្យឈើស៊ុ លុះបំរើទៅដល់ហើយក៏ឲ្យសំបុត្រ-
ទៅឈើស៊ុតាមបណ្ដាំសព្វគ្រប់ ។

ឈើស៊ុទទួលយកសំបុត្រមកលាមើលឃើញសេចក្ដីនឹងអក្សរប្រាកដ
ជាលាយដៃមាតាចំពោះបញ្ជាសំដួច្នោះ ក៏សោកាតិលាប ទើបនាំយកដើម
សំបុត្រនោះចូលទៅបង្ហាញឲ្យពីរហើយដំកបថា សព្វថ្ងៃនេះខ្ញុំពុំតាំង
ចិត្តស្វាមីកក្ដី មកពីនឹងពាក់ជួយធ្វើរាជការលោកក៏យូរហើយ ខ្ញុំពុំមិន
ពាន់បានសំដែងរឿងរ៉ាវពីដើមឲ្យលោកជ្រាប ហើយឈើស៊ុកិច្ចានឲ្យ
ឲ្យពីស្ដាប់គ្រប់ប្រការ ហើយខ្ញុំពុំមកនៅធ្វើរាជការនឹងលោក ។
ក៏មានសេចក្ដីមេត្តាករុណាខ្ញុំពុំ ។ ក៏តែងថានឹងតបស្នងសងគុណឲ្យអស់-
ជម្រះប្រាជ្ញា ឥឡូវ មានកម្មតាមកម្មផល ចូរធ្វើដឹងថា ខ្ញុំពុំមកនៅនឹង
លោកក៏រករឿងនឹងចាប់យកមាតាខ្ញុំពុំទៅធ្វើទោសហើយ នឹងឲ្យសម្លាប់
ចោញ មាតាខ្ញុំពុំដួលមនុស្សឲ្យនាំសំបុត្រនេះមកឲ្យខ្ញុំពុំថា ឲ្យទៅនៅ
នឹងចូរធ្វើ បើខ្ញុំពុំមិនទៅឥឡូវនេះទេ មុខជាចូរធ្វើនឹងសម្លាប់មាតា
ពុំខាន ទោសក៏នឹងមានដល់ខ្ញុំពុំទៅអនាគតជាច្រើន មាតាបង្កើតមក
រក្សាបីបាច់នៅមិនពាន់បានតបគុណលោកសោះ មកថែមនាំឲ្យមានទោស
ព្រោះខ្លួនទៅទៀតមិនគួរសោះ សូមលោកមានសេចក្ដីអនុគ្រោះឲ្យខ្ញុំពុំ

ចាន់ទៅដួបនឹងចូនធ្លុះ ដូចចាន់តបគុណមាតាកុំឲ្យលោកអន្តរាយដល់ជីវិតទើយ បើខ្ញុំចាទទៅហើយចាន់នេះគិតឲ្យស្រួលវិលាណានឹងរកទាយវិលមកវិញ ដើម្បីនឹងតបស្នងសងគុណលោកតទៅ ។

ឡៅពីចាន់ស្តាប់ក៏ស្រាលក្នុងខ្លួនដូចគ្មានព្រលឹងវិញ្ញាណ មានសេចក្តីស្តាយនឹងអាណិតឈើស៊ីពន់ប្រមាណ ក្នុងប្រាណឡៅពីកំអាក់អួលក្តួលសោកាហើយថា ធម្មតាកើតមកជាម្តាយនឹងកូន កំដូចដាវិតជាមួយគ្នា បើមានហេតុកេទដូច្នេះហើយ កំជាប្រវេណីនៃបុត្រនឹងសង្រ្គោះមាតា នរណាក៏នឹងអាចចោលមាតាចាន ដែលអ្នកនឹងទៅរកចូនធ្លុនោះកំតាមចិត្តចុះ តែថាបើមាតាអ្នកចាន់រួចពីទុក្ខភ័យហើយ ចូរអ្នកនេះគិតត្រឡប់ជួយណែនាំពន្យល់យើងតទៅទៀត ឥឡូវខ្លួនអ្នកនឹងយើងត្រូវនិរាសច្រាសចាកគ្នាទៅហើយ អ្នកអើយ សូមឲ្យអ្នកនៅបង្អង់មួយរាត្រីនឹងយើងចុះ រៀលព្រឹកស្អែកនេះ យើងនឹងរៀបលៀងអាហារ ឲ្យអ្នកបរិភោគជាទីកំសាន្តចិត្តរួចសឹមទៅ។ ឈើស៊ីខ្លួលពាក្យហើយក៏លាទៅគាន់គេហដ្ឋាន។ ក្រោយនោះ ស៊ីនវៀនក៏និយាយនឹងឡៅពីថា ឈើស៊ីនេះជាមនុស្សមានសតិបញ្ញាច្រើនណាស់ ហើយក៏ចាន់មកនៅនឹងលោកក្នុងស្រុកស៊ីនអៀ ជិនជាក់តិចពាក់ជ្រៅធ្ងន់នឹងស្រាលគ្រប់ប្រការ បើជាលោកបើកឲ្យទៅនៅនឹងចូនធ្លុគ្រានេះ ចូនធ្លុក៏នឹងមានសេចក្តីត្រេកអរ ខ្លួលចិញ្ចឹមព្យាលរក្សាជា

ឃាងវែក្រពេក ការពក់ជ្រៅធ្ងន់ធ្ងន់ស្រាលយ៉ាងម្តេចនោះ ឈើស៊ុកធ្ងន់ណែនាំពន្យល់ចូរឆ្ងួយឲ្យល់ក្តីចាំងអស់ អំណើះទៅមុខគង់ធ្ងន់មានភ័យអន្តរាយមកដល់លោកជាប្រាកដ ការនេះសូមឲ្យលោកយាត់ខ្លួនឈើស៊ុកកុំបើកឲ្យទៅឡើយ ។ ឯចូរបើឃើញថា ឈើស៊ុមិនទៅហើយក៏ធ្ងន់សម្ងាប់មាតាចេញ ឈើស៊ុក៏គង់ធ្ងន់មានចិត្តខ្មោចក្តៅក្រហាយរកបាយធ្ងន់សងសឹកដោយសេចក្តីព្យាបាទចូរ តាំងចិត្តធ្ងន់ជួយធ្វើការលោកពេញដៃដោយសុចរិត ។ ឧត្តរតបថា អ្នកនិយាយនោះយើងមិនយល់ឃើញផងសោះ ព្រោះធ្ងន់ឲ្យគេព្រាត់ប្រាសម្តាយធ្ងន់កូនមិនឲ្យទៅមករកគ្នា ឲ្យមាតាចាំស្លាប់ ពីព្រោះកូននោះក៏ធ្ងន់មានបាបកម្មទៅខាងអនាគតមួយទៀត យើងក៏បានចេញសំដីអនុញ្ញាតបើកឲ្យគេទៅហើយ ខ្មោះបីខ្លួនយើងធ្ងន់ធ្ងន់ស្លាប់ពីព្រោះឆ្មាយគំនិត ត្រង់រឿងនេះក៏មិនជាអ្វី ត្រូវរក្សាតែសេចក្តីស័ត្យតតាំងខុសជាបង្អាលចារឹក យើងមិនយកប្រាថ្នាពាក្យសំដីដែលអ្នកនាំមកអធិប្បាយនោះទេ ព្រោះមិនមែនជាសេចក្តីសត្យានុស័ត្យពិតត្រង់ល្អ បណ្តាសេនាគហានបានឮពាក្យឧត្តរតបន័យយ៉ាងដូច្នោះ ក៏បង្កើតចិត្តបីតិជាមោទ្ធត្រេចត្រឹកមនាំគ្នាសរសើរ ឧត្តរតបានសេចក្តីស័ត្យសុចរិតមាំមួនណាស់ ។

លុះវេលាព្រឹកឡើង ឧត្តរតក៏ឲ្យទៅអញ្ជើញឈើស៊ុមកបរិភោគអាហារ

ខណៈកាលឈើស៊ុលើកពែងស្រាឡើងផឹកនោះ ក៏និយាយទៅឡៅពីថា ខ្ញុំ
បាទដឹងថា ចូរឲ្យចាប់មាត់ទៅធ្វើទោសយ៉ាត់ឃុំខ្លួកនោះ ចំណែកខ្ញុំបាទ
ក្តៅដូចភ្លើងឆេះឆិក្នុងទុក នោះបើលោកនឹងយកអាហារដែលមានឧជារស
ស្មើរបស់ទិព្យមកបញ្ចុក ក៏លេបទៅមុខជាមិនចូលដល់ចំពង់ក្នុងឡើយ ឡៅ
ពីតបថា ដែលអ្នកកើតខ្លួនក៏ដល់មាត់ដូច្នោះហើយ ក៏ជាប្រវៃណីមាន
មកដូច្នេះ តែខ្លួរបស់យើងដែលនិងសង្ឃាសចាកអំពីអ្នកទាំងណោះតាំង
ពីថ្ងៃនេះទៅ ក៏រមែងក្តៅក្តួលឆួលឆេះស្មើរនឹងប្រេះប្រមាត់ដូចគ្នា បើនរ
ណានឹងយកថ្មើមហង្សនឹងថ្មើមមក ជាមានឧជារសទិព្យមកឲ្យបរិភោគ
ក៏មិនអាចនឹងដឹងថា មានឧជារសនោះដូចម្តេចឡើយ ។

ឡៅពីនឹងឈើស៊ុនិយាយគ្នាទៅវិញទៅមកដូច្នេះហើយ ក៏តាំងតែ
យំសោកអាឡោះអាល័យគ្នា លុះបរិភោគរួចហើយ ឈើស៊ុក៏គំនាប់ឈា
ឡៅពី ។ ក៏ឲ្យរៀបចងសេះ ១ ដោយប្រដាប់ស្រេចហើយ ក៏ឡើងជិះ
សេះដួនដំណើរបរទើមគ្នាចេញទៅ លុះទៅផុតមាត់ព្រៃស្រុក ឈើស៊ុក៏ចុះពី
លើសេះគំនាប់ឡៅពីថាលោកចេញមកដួនដំណើរខ្ញុំបាទដល់ទីនេះអរព្រះ
គុណ-គុណជាទីបំផុត អញ្ជើញលោកវិលទៅទៀសុខសំពានចុះ ។ ឡៅពីក៏
ចុះពីលើសេះខ្លួលគំនាប់ឈើស៊ុ ចាប់ដៃទុប ហើយឡៅពីថា ខ្លួនខ្ញុំវេលា
នេះឃើញថាជាមនុស្សមានកំសត្តាតិចណាស់ ទើបមិនបានអ្នកខ្លួកជាគ្នា

នឹងបានណែនាំពន្យល់ធ្វើការតទៅ ។ ឈើស៊ុយហើយតបថា ខ្ញុំនឹងបានកំ
មានតម្លៃតាមមកផ្តល់ ឲ្យព្រាត់ប្រាសនិងសេចក្តីពីលោកកណ្តាលការ
ព្រោះមានតាជា ១ ធំ ទោះបីបងធ្លុនឹងបានខ្ញុំនឹងបានទៅនៅផងក្តីខ្ញុំនឹង
កំសូមស្បថស្បែងកុនឹងលោកថា . បើខ្ញុំនឹងធ្វើការអ្វីតទៅមុខ ខ្ញុំនឹង
កំមិនបានតតកល់ទុយអ្វីមួយ ឲ្យបងធ្លុធ្វើអន្តរាយដល់លោកបាន
ឡើយ ។

ឡៅពីថា ខ្ញុំនអ្នកមានសតិបញ្ញាណាស់ បានជួយណែនាំយើងមក
តីថ្ងៃមុន ឥឡូវអ្នកនៅឃ្លាតពីយើងហើយ ខ្ញុំនយើងម្នាក់ឯងរកអ្នកណា
ជួយទំនុកបំរុងគ្មាន កំនឹងស្មែងទៅលាក់ខ្លួនពួននៅក្នុងព្រៃ មិនមានតាំង
ចិត្តនឹងតតធ្វើការអ្វីតទៅទៀតទេ ។ ឈើស៊ុតបថា លោកនឹងមកតូចចិត្តតត
ល់បងរំសេចក្តីពិព្យាយាមនោះមិនគួរសោះឡើយ ទោះបីខ្ញុំនឹងនឹង
ឃ្លាតចេញពីលោកសោត កំមិនមែននឹងអស់ផុតអ្នកមានជម្រះប្រាជ្ញា
នោះទេ ចូរទស្សាហ៍ស្មែងរកតទៅទៀត គង់ជួបប្រទះនឹងអ្នកមានជម្រះ
ប្រាជ្ញា ហើយឈើស៊ុតក្រឡេកមើលទៅក្រោយ ឃ្លែងឃាំនឹងតាហានតាំងពួន
ថា អ្នកតាំងឮយទៅធ្វើកជការ ត្រូវទំយកចិត្តទុកជាត់ស្មាម៉ាត់ក្តីនឹងទៅ
ហ្វាយនាយ ដោយសុចរិតកុំគិតនឿយហត់ឡើយ បើបានសម្រេចការជួប
ប្រាថ្នាហើយ គង់នឹងបានចំរើនទូរសេចក្តីសុខសប្បាយកល់គ្នា ព្រោះទៅ

ហ្វាយនាយនេះគង់ធំធ្ងន់ជាងពីរនាក់ដល់មនុស្សពាំងពួន អ្នកកាលគ្នាកុំ
បីយកយើងជាតួយ៉ាង ដែលធ្វើការមិនបានហួតដូច្នេះឡើយ ។ ចាហាន
ពាំងពួនបានឮពាក្យឈើស៊ុនិយាយដូច្នោះមើយ ក៏នាំគ្នាយំសោកវិយោគ
ពាំងអស់គ្នា ។

ខ្លៅពីក៏មិនអាចត្រឡប់ចូលទៅក្នុងស្រុកបាន ឲ្យមានតែចិត្តល្អិត
ល្អៃអាល័យអាលោះពុំអស់ហើយ ក៏បរសេះដួនជំណើរឈើស៊ុទៅទៀត ។
ឈើស៊ុក៏និយាយនឹងខ្លៅពីថា លោកទស្សាហ៍មកដួនជំណើរខ្ញុំបាទក៏ធ្ងាយ
ណាស់ហើយ ចូរនាំចាហានអញ្ជើញវិលទៅវិញចុះ ខ្ញុំបាទសូមលាលោក
ហើយ ។ ខ្លៅពីក៏បរសេះស្រួតទៅរឹមចាប់ដៃឈើស៊ុហើយថា អ្នកនឹងខ្ញុំ
ពីថ្ងៃនេះទៅនឹងត្រូវក្បត់តែថ្ងៃ-ទៀ-ឆ្នាំ ឆ្ងាយពីគ្នាណាស់ហើយ កាលណា
ទៀបនឹងបានវិលមកជួបឃើញមុខគ្នាទៀត និយាយហើយក៏យំសោក-
ល័យជ្រប់លើខ្នងសេះ ។ ឈើស៊ុឃើញខ្លៅពីយំជ្រប់ដូច្នោះក៏អត់ខឹកភ្នែកពុំ
បានញាក់សេះគំនាប់ហើយក៏បំផាយសេះលឿនទៅ ខ្លៅពីឃើញឈើស៊ុ
បំផាយសេះទៅក្រឡេកទៅចាំនឹងតុម្ពឈើមើលមិនឃើញ ក៏យកសៀ
សេះចង្កុលឲ្យចាហានកាប់រំលំតុម្ពឈើនោះចេញ ។ ចាហានពាំងពួនសួរថា
លោកឲ្យកាប់តុម្ពឈើធ្វើអ្វី ? ខ្លៅពីប្រាប់ទៅវិញថា ព្រោះកំពុងនឹងយើង
មើលឈើស៊ុមិនឃើញ ។

ឯណៈដែលឡៅតីកំពុងឲ្យថាហ៊ានកាប់គុម្ពឈើនោះ ទទួលយើញឈើស៊ុបំផាយសេះរំលត្រឡប់មកវិញ ឡៅតីត្រេកអរណាស់ គិតខុកក្នុងចិត្តថា ប្រហែលឈើស៊ុមានចិត្តគាល់យើងនឹងមិនទៀវដឹង បានជាត្រឡប់មកវិញ? លុះឈើស៊ុមកដល់ជិត ក៏ស្រែកសួរថា អ្នកត្រឡប់មកវិញធ្វើអ្វី ? ឈើស៊ុបំបៀតសេះចូលមកជិតហើយថា ខ្ញុំបានប្រុងនឹងដំរាបសេចក្តីដល់លោក ក៏នៅមិនទាន់បានចរចាដោយសារមានខ្មុក្រាសចាកគ្នា ថ្មីមប្រមាត់ខ្ញុំបានចាំដូចគេលឺងលាជ ក៏ភ្លេចអស់ទៅ ឥឡូវនឹកឃើញបានជាវិលត្រឡប់មកវិញបំណងនឹងដំរាបលោក ព្រោះមានមនុស្សម្នាក់នៅត្រើស្រុកសុងយ៉ុង មានបញ្ញានឹងជម្រិះរិះគិតជ្រៅខ្លាយជាងវៃណាស់ សូមឲ្យលោកទៅអញ្ជើញខ្លួនអ្នកនោះមក នឹងបានជួយគិតការគ្រប់ទៀត ។

ឡៅតីក្តៅហើយសួរថា បើដូច្នោះអ្នកអាណិតដូនយើងទៅឲ្យស្គាល់ខ្លួនបន្តិចសិនចុះ ។ ឈើស៊ុតបថា ដែលលោកនឹងឲ្យទាំទៅនោះក៏បាន តែថាដែលនឹងទៅកដោយការរួសរាន់នោះមិនបានទេ ត្រូវលោកទៅតំនាំដោយសុចរិតយ៉ាងសុភាពទើបគួរ បើបានអ្នកនោះមកហើយ ក៏ដូចព្រះចៅហាន់គោចោ បានទៀវលៀងដ៏មានប្រាជ្ញាមកជាទីប្រឹក្សា ។ ឡៅតីសួរថា ដែលថាមនុស្សនោះនឹងមានសតិបញ្ញាស្មើប្រហែលនឹងអ្នកដែរឬ ?

ឈើស៊ុតបថា ដែលនឹងយកគំនិតគិតនឹងប្រាជ្ញាខ្ញុំបាទទៅប្រៀបផ្ទឹមនោះ ធ្វើយពីគ្នាណាស់ ខ្លួនខ្ញុំបាទឧបមាដូចក្អែក នឹងយកទៅផ្ទឹមនឹងស្តេច-ហង្សមិនគួរ មួយទៀតសេះអាជានេយ្យមានកម្លាំងដ៏តិច នឹងយកទៅប្រៀបនឹងស្តេចពាជសីហ៍មិនបាន ឯមនុស្សដែលមានប្រាជ្ញាប្រៀបលោកនោះ អាចប្រទ្រង់នឹងញ៉ាំងឲ្យដឹងក្រមផែនដី នឹងលើអាកាសជាឯកម្ចាត់ឯង នឹងកេអ្នកឯណាប្រៀបផ្ទឹមឲ្យស្មើជា ២ នោះគ្មាន ។ ឮពាក្យដូច្នោះ ក៏មានអំណរណាស់ទើបសួរថា អ្នកនោះឈ្មោះអ្វី ? ឈើស៊ុបប្រាប់ថា ឈ្មោះខុងហេង(១) សែដូគាត់ , ឥឡូវអត់ពីបិតាមាតា នៅជាមួយគ្នានឹងដូគាត់កន ជាប្អូនប្រុស ធ្វើស្រែចំការចិញ្ចឹមជីវិតនៅលើភ្នំនៅឡាំកាំង ឯជំបន់ឡុង-សៀ អ្នកស្រុកខាំងពួងហៅឈ្មោះខុងហេងជាអាចារ្យហុកឡុង ប្រសិនបើលោកទស្សាហ៍ទៅអញ្ជើញខុងហេង មកទុកឲ្យជួយរៃគិតការលោក នឹងប្រាប្រាមស្រុកទេសខាំងពួងឲ្យ ពាបាបជាសុខសាន្តបាន ។

ឮពាក្យថា កាលយើងទៅឈប់សំណាក់ នឹងសុមាតេកនោះ សុមាតេកនោកំបានដំណាលប្រាប់យើងថា ហុកឡុង, ហង្សូ ២ នាក់នេះមានសតិបញ្ញាវាងវៃណាស់ ប្រសិនបើបានអ្នកឯណាមួយមកជួយធ្វើរាជការ កំនឹងប្រាប្រាមស្រុកទេស ឲ្យពាបាបបាន ដែលអ្នកថានេះនឹងជាហុកឡុង ឬ ហង្សូ ? ដែលសុមាតេកនោប្រាប់យើងនោះឬ មិនមែន ?

១- ហៅថា កុងម៉ុងកំបាង ។

ឈើស៊ីឆ្វើយថា អ្នកនោះឈ្មោះហុកឡុងនោះឯង ឯហង្សនោះគឺចាំងថង
នៅស្រុកសុងយ៉ុង ខ្ញុំពីក៏មានសោមនស្សពេកណាស់ ខះដែរសើចហើយ
ថា មនុស្សល្អនៅដាតបង្កើយ ដូចជាឃើញនឹងក្អែក បើងក៏មិនអាចដឹង
សោះ ហាក់តែអ្នកមកនិយាយប្រាប់ ទើបបានដឹងច្បាស់ថា ហុកឡុង ហង
ស្ងួ នៅដំចន់នេះ ។ ឈើស៊ីពន្យល់សេចក្តីឲ្យខ្ញុំពីដឹងដូច្នោះហើយ ក៏គំ
នាប់លាខ្ញុំពីចំដាយសេះចេញទៅ ។

ឯខ្ញុំពីបានស្តាប់ពាក្យដែលឈើស៊ីប្រាប់ត្រូវគ្នានឹងពាក្យសុមាតេកនៅ
ដូច្នោះ រួចក៏នាំទាហានចាំងពួនត្រឡប់ទៅស្រុកសិនអឿរញ ។ ឯឈើស៊ីក៏
លាខ្ញុំពីទៅ ហើយក៏នឹងគិតដល់គុណបការ ដែលខ្ញុំពីអាណិតស្រ-
ឡាញ់ ដោយស្មោះត្រង់ ហើយគិតបរិតក្តថា ខ្ញុំពីនឹងទៅអញ្ជើញទុង-
បេង ។ នឹងមិនមកធ្វើការផងផង ក៏នឹងបូចសេចក្តីប្រាថ្នា ទើបបំផាយសេះ
គេចចូលទៅត្រង់ភ្នំដើរឡំ កាំង ចូលទៅគំនាប់ទុងបេង ។ ក៏សួរសាកថា
អ្នកមកដោយធុរៈអ្វី ? ។ ឈើស៊ីក៏ដំរាបតាមដំណើរដើមរហូតដល់ចុងឲ្យ
ស្តាប់គ្រប់ប្រការ ហើយថា កាលខ្ញុំលាខ្ញុំពីមកនេះ បានផ្តាំទុកថា អ្នក
ជាមនុស្សមានជម្រិះប្រាជ្ញានៅក្នុងទីនេះ ខ្ញុំពីមានសេចក្តីត្រេកអរ-
ណាស់ ប្រសិនបើខ្ញុំពីមកអញ្ជើញអ្នក ។ កុំព្រងើយកន្តើយ ចូរទៅ
ជួយខ្ញុំពីជាទីបក្ខពួកណែនាំពន្យល់ឲ្យធ្វើការបានសម្រេចប្រយោជន៍ គឺ

ដួយច្រាបច្រាមសឹកសត្រូវ ក្នុងដែនដី ឲ្យរាបទាបជាសុខក្សេមក្សាន្ត ដោយដម្រិះប្រាជ្ញារបស់អ្នកផងចុះ កុំឲ្យខូចប្រយោជន៍ចំណាច់បានរឿង សូត្រវិជ្ជាសិស្សាស្ត្រចេះដឹងមក ។ ខុងបេងបានស្តាប់ឮដូច្នោះ ក៏ខឹងណាស់ ធ្វើយតបទៅឈីស៊ីវិញថា ខ្ញុំនឹងអ្នកឯងដើរចេញពីឡៅពីទៅហើយ មិនមានរបស់អ្វីនឹងទុកកំជាប់ចិត្តឲ្យឡៅពីឬ? បានជាមកយកយើងទៅធ្វើជាគ្រឿងសំណែនឲ្យឡៅពីវិញ ? ខុងបេងថាតែប៉ុណ្ណោះហើយ ក៏ចូលដើរចូលទៅក្នុងផ្ទះ។ ឈីស៊ីឃើញខុងបេងថាស់ចិត្តក៏នឹកអៀនខ្មាសពន់ប្រមាណ ទើបឡើងសេះស្រូតទៅស្រុកហួតោ ។

ចូធួឮថា ឈីស៊ីមកដល់ក៏សោមនស្សក្នុងចិត្តពន់ពេកណាស់ ប្រើឲ្យដៀយុកនឹងសុនហុក ចេញទៅទួលដល់ត្រៃស្រុក សុនហុកនឹងដៀយុកក៏នាំឈីស៊ីចូលទៅគាំទាប់ចូធួ ។ ក៏សួរថា ខ្ញុំនឹងជាមនុស្សមានសតិបញ្ញា ហេតុម្តេចបានជាទៅនៅនឹងឡៅពី ដែលជាមនុស្សគ្មានបណ្ដាសត្តិវិញ ។ ឈីស៊ីក៏ធ្វើយតបថា ដែលខ្ញុំបានទៅនៅនឹងឡៅពីនោះ ព្រោះពីដើមខ្ញុំបានប្រព្រឹត្តសេចក្តីខុសជាខ្លាំង ខ្លាចក្រែងគេចាប់បាន ទើបផ្សាស់ឈ្មោះចេញ ហើយស្វែងរកទៅជ្រកពួនទៅក្នុងស្រុកសុនអៀ ទួលជួបនឹងឡៅពី បាននិយាយត្រូវពាក្យសំដីគ្នា ព្រោះជាមិត្តភ័ក្តិមកពីដើម ខ្ញុំបានតាំងនៅធ្វើការជាមួយ ឥឡូវខ្ញុំបានដឹងថា មហាឧបាជ្ឈាយគាខ្ញុំ

ចាទមកខ្លួន ខ្ញុំចាទក៏មានសេចក្តីត្រេកអរណាស់ ចានជាចូលមកគំនាប់
លោក ។ ចូឆូថា យើងក៏គាប់ចិត្តនឹងអ្នកដែលមានសេចក្តីតតញ្ញូ ហើយ
មកក្នុងសម័យនេះក៏ជាហើយ នឹងបានថែរក្សាមាតាបង្កើតរបស់អ្នកតាមប្រពៃណី
យើងក៏នឹងជួយចំនុកបំរុងតទៅ ។ លីស៊ីគំនាប់ហើយក៏លាចូឆូចេញទៅ
រកមាតា លុះទៅដល់ក៏លុតជង្គង់គំនាប់ហើយយំសោកចំពោះមុខមាតា ។

ឯមាតាលុះឃើញលីស៊ីមកដល់ក៏តក់ស្លុតក្នុងចិត្ត ទើបសួរថា ហេតុ
ម្តេចបានជាឯងមកដូច្នេះ លីស៊ីឮមាតាថាដូច្នោះក៏ភ្ញាក់ខ្លួន ទើបនាំសេចក្តី
មកអធិប្បាយដំណមាតាតាមដំណើរ ដែលទៅនៅនឹងឡៅពី ចាលំតែ
ត្រឡប់មកឲ្យមាតាស្តាប់គ្រប់ប្រការ ។ មាតាបានស្តាប់សព្វសេចក្តីក៏ទំនឹង
ញ័រអស់ពាំនឹងខ្លួន យកដៃតប់ទះតុហើយដេរថា អាចារចង្រៃឆោតអប្បវត
ច្រាជ្ញាណាស់ ទំនៀមមានមកពីណា កើតមកជាប្រុសមិនចេះគិតពិគ្រោះ
ពិចារណា ឃើញសំបុត្រហើយ ក៏ប្រញាប់ដឿស្តាប់បង់ក៏ឡាំងដែលអញ
បានបង្កើតឯងមក ហើយដើររៀនវិជ្ជាចំណេះតាំងពីតូចចាលំធំ អញគិត
ថា នឹងល្អគ្រាន់បើស្មើមនុស្សនឹងគេ មិនដឹងជាត្រឡប់មកធ្វើជាមនុស្ស
ខូចដូច្នេះសោះ អញនឹងទៅឲ្យឃើញមុខគេពាល់ភ្នាក់អៀនខ្មាសមិនដឹង
នឹងយកមុខទៅលាក់ទុកឯណា ដេរដូច្នេះហើយ ក៏គ្រាតចូលទៅចង្ក-
ស្តាប់ខាងក្នុងផ្ទះ ។ លីស៊ីគ្រាបក្រាបមុខទៅទ័ពោះមិនបានដឹង មនុស្សបំរើ

ក្នុងដំណះក៏តាំងចេញមកប្រាប់ឈ្មោះស៊ុថា មាតាអ្នកចង់កស្លាប់ទៅហើយ ឈ្មោះ
ស៊ុកយស្តេតក៏តាំងចូលទៅនឹងស្រាយ កំមិនទាន់ទទួលជាច់ៗរល់ស្លាប់ ឈ្មោះ-
ស៊ុកយំដួលសន្លប់នៅទីនោះ លុះឈ្មោះស៊ុក្លាក់ដឹងខ្លួនឡើងក៏រៀបចាត់ចែង
ការសពដែលនឹងកប់មាតា ។

ចូធូដឹងដំណើរថា មាតាឈ្មោះស៊ុស្លាប់ហើយ ក៏ឲ្យរៀបរបស់គួរ
សមនាំទៅដួយការសព ។ ឈ្មោះស៊ុកំមិនព្រមទទួលយក បង្គិលរបស់ទាំង
នោះឲ្យយកទៅដូនចូធូវិញ ដោយមិនបានតាំងចិត្តកក្តីដែលនឹងនៅ
ធ្វើការជាមួយនឹងចូធូដោយសុចរិត ឈ្មោះស៊ុក៏រៀបចំចៃសពមាតាទៅ
បញ្ចុះទុកខាងទិសទក្សិណស្រែ ស្រុកហ៊ូគោហើយ ក៏ទៅនៅក្បែរ
សពមាតាក្នុងទិនោះជានិរន្តរ៍ ក្រោយពីនោះមក ចូធូលើកទ័ពទៅវាយ
អាណាខ្វែត្រខាងទិសទក្សិណ ស៊ុនហុកដឹងការណ៍ ក៏ចូលទៅដាំរាបចូធូថា
ដែលលោកនឹងលើកទ័ពទៅច្បាំងគ្រានេះ ជាទេសកាលត្រូវលើរដូវរងា
ខាហានខាំងពួងនឹងឃ្លានសេចក្តីលំបាកណាស់ សូមឲ្យលោកបង្អង់ឈប់
កងទ័ពសិនចុះ ចើដល់រដូវប្រាំងវេលាណាសឹមលើកទ័ពទៅ នឹងស្រួល ។
ចូធូឃ្លានឮដូច្នោះក៏យល់ឃើញផង ទើបឲ្យបង្អង់កងទ័ពតាំងតែហ៊ុកហាត់
សេនាខាហានឲ្យស្គាត់ស្គាញក្នុងក្បួនទ័ពខ្លួន ។

ឯខ្មៅពីកាលដូនដំណើរឈ្មោះស៊ុទៅហើយក៏វិលមកក្នុងស្រុកវិញ ទើប

ចាត់ចែងរបស់ទ្រព្យដែលនឹងយកទៅគំនាប់ខ្លួនបេង ។ ណ:នោះទើបលួច
អ្នកចាំគ្រូវចូលមកដំរាបឡើងពីថា ឥឡូវមានអាចារ្យម្នាក់មានរូបរាងធំស្អាត
ចាត តែងខ្លួនជាមនុស្សសុភាពមករកលោក ។ ឡើងពីពួកជូរចោះតំណាល
ថា ប្រហែលខ្លួនបេងទេដឹងតែអរណាស់ ក៏រលះរលាំងចេញទៅ
ទើបលួចឃើញសុមាតេកធោ ។ ឡើងពីអរណាស់ក៏អញ្ជើញឡើងទៅលើផ្ទះ
ហើយគំនាប់សួរថា តាំងពីខ្ញុំបែកចាកលោកពីថ្ងៃនោះមក តើមានចិត្ត
នឹករលឹកដល់លោកជារឿយៗគ្មាននឹងទៅសួរ ដែលលោកអញ្ជើញមក
វេលានេះដោយកិច្ចធុរៈអ្វី ? ។ សុមាតេកធោឆ្លើយថា ខ្ញុំមកនេះនឹងមាន
ទុក្ខធុរៈរឿងអ្វីក៏ទេ ព្រោះដឹងឮថា ឈើស៊ីបានមកនៅធ្វើការងារជាមួយ
នឹងលោក មានចិត្តនឹករលឹកក៏មកសួរលេង ឡើងពីក៏អធិប្បាយសេចក្តី
ដែលឈើស៊ីមកនៅ ហើយបែកទៅឲ្យសុមាតេកធោស្តាប់គ្រប់បការ ។

សុមាតេកធោឮដូច្នោះក៏ថា ដែលឈើស៊ីទៅសួរម្តាយឯស្រុកហ៊ូគោ
នោះ ព្រោះមិនដឹងកល់របស់ចូលួច ឯម្តាយឈើស៊ីជាមនុស្សប្រកប-
ដោយស័ត្យសុចរិតមាំមួនណាស់ ទោះបីចូលួចនឹងចាប់ខ្លួនយកទៅយាត់
ឃុំធ្វើទោសប្រការម្តេច ក៏ឃើញថាមិនឲ្យដឹងដំណឹងអ្វីមកដល់កូន នឹងស៊ូ
ស្តាប់តែម្នាក់ឯង ដែលមានសំបុត្រមកនោះ ប្រហែលជាគលទុយាយរបស់
ចូលួចទេ ដែលឈើស៊ីទៅកន្លែងនេះ ប៉ុដូចជាទៅសម្លាប់មាគាឲ្យស្លាប់

បើឈើស៊ីមិនទៅស្រុកហ្ន៎ះគ្មា តាមសំបុត្រនោះទេ ម្ដាយឈើស៊ីកំទៅមានអាយុដីវិតទៅទៀត ។ ទ្បៀតីឮសុមាតេកតនោថាដូច្នេះ កំតក់ស្ដុតស្មារតី ហើយសួរថា ហេតុម្ដេចបានជាលោកនិយាយដូច្នេះ ។

សុមាតេកតនោឆ្លើយថា ដែលខ្ញុំនិយាយដូច្នេះ ព្រោះសំឡឹងឃើញចិត្តម្ដាយឈើស៊ីនោះស្រឡាញ់ ចង់ឲ្យកូនបាន់នៅនឹងលោកតទៅ ដែលឥឡូវកូនត្រឡប់ទៅនៅនឹងចូធ្លូវិញ កំមិនតេញចិត្តទេ ទើបសម្ងាប់ខ្លួនដួចខ្ញុំស្មានមិនខុសទេ ។ ទ្បៀតីថា លោកនិយាយកំគួរហើយតែថាបើខ្ញុំមិនឲ្យឈើស៊ីទៅដួចនឹងម្ដាយ កំឃើញមិនគួរ កាលបើឈើស៊ីនឹងទៅនោះបាន់ផ្ដាំពុកនឹងខ្ញុំថា មានមនុស្សម្នាក់ឈ្មោះអាចារ្យ ខុនបេង នៅប្រុបស្រុកលុងយ៉ុង មានដម្រិះប្រាជ្ញាវាងវៃណាស់ លោកបានជ្រាបឬទេ ? សុមាតេតនោទ្បៀតីថាដូច្នេះកំថា ឈើស៊ីនឹងទៅតែខ្លួនម្ដេចមិនបាន ចាំនាំពាក្យមានដល់រូបខុនបេង ឲ្យខុនបេងរំខានចិត្តទៀត មុខជាកូតឈាមនឹងមានមកជាក្រោយ មិនគួរសោះ ។ ទ្បៀតីសួរថា ហេតុម្ដេចបានជាលោកមានប្រសាសន៍ដូច្នេះ ? ។

សុមាតេកតនោឆ្លើយតបថា ខ្ញុំនឹងយល់ថាបើខុនបេងមកនៅធ្វើការនឹងលោកនោះជាការធំពន្ធឹកក្រៃពេក មុខជាត្រូតែតតែវៃដោយដម្រិះប្រាជ្ញាគ្រប់លៀនឹងក្រុងដើមទ្រូងជាមិនខាន បានជាខ្ញុំថាដូច្នេះ ព្រោះខុន-

បេន៍នោះ មានប្រាជ្ញាច្រើនណាស់ ប៉ដូច ខ្វាន់គុន, ង៉ាកយើ ដែលបាន
ចំនុកបំរុងផែនដីកាលត្រាសុនស៊ីនោះឯង ។

គួនអ៊ូបានឮសុមាតេតធោសរសើរខុង់បេង៍ជូរប្នោះតំធ្វើយថា លោត
មានប្រសាសន៍នោះ ខ្ញុំមិនពន់យល់យើញផង់សោះ ព្រោះខ្វាន់គុន, ង៉ាក
យើ ២ នាក់នេះ មានជម្រិះប្រាជ្ញាន៍ង៉ាកនណាស្មើគ្នាន ដែលន៍ង៉ាក
ខុង់បេង៍ទៅប្រៀបធៀបនោះយើញថាលើសណាស់ សុមាតេតធោអស់សំ
ណើចហើយថា ខ្ញុំនិយាយនេះគ្រាន់តែជាការប្រមាណទេ យើង៍ន៍ង៉ាត-
ត្រោះមើលជម្រិះប្រាជ្ញាខុង់បេង៍នោះ ន៍ង៍ប្រៀបបាន់ស្មើន៍ង៍តេង៍សុង៍ដែល
ជាអ្នកចំនុកបំរុង់ផែនដីព្រះចៅដ៏វប៊ុនអង ដែលសោយរាជសម្បត្តិតមក
បានដល់ ៨០០ ឆ្នាំនោះទៀត សុមាតេតធោនិយាយតែប៉ុណ្ណោះហើយ
ក៏លាទៀតីត្រាតដើរចេញទៅ ទៀតីយាត់ក៏ពុំស្តាប់ លុះដើរ
ទៅដល់មាត់ទ្វាររបង៍ភូមិ ក៏ឆើយមើលលើចាំយសើចថា ហុកឡង៍ន៍ង៍បាន
រៀបរាយនាយជូរប្នោះតំសមគួរហើយ តែមុខគួរទ្រីស្តាយពេតណាស់
ព្រោះជាមនុស្សអ័ភព្វគ្នានបុណ្យ ថាហើយក៏ដើរចេញទៅ ។

លុះវិលាព្រឹតទៀង៍ ទៀតីត៏នាំគួនអ៊ូ,ទៀហ៊ុយ ចេញចាតស្រុក
ស៊ុនអៀង៍ន៍ទៅតខុង់បេង៍ឯភ្នំដោ"ឡុកាង៍ លុះទៅដល់បានជួបន៍មនុស្ស
៩ នាក់ ធ្វើចំការនៅដើង៍ភ្នំមួយ ទៀតីត៏សួរថា អាចារ្យម្នាក់ឈ្មោះថា

ហុកឡុងនោះនៅដំបន់ឯណា? អ្នកចាំនឹងឆ្លើយដឹងដែរឬទេ? ។ ពួកអ្នកចំការក៏ឆ្លើយថា កាលៗហុកឡុងនៅត្រង់ប្រឡុះក្នុងដ៏ទំសេកស្ងាំណា មានព្រៃឈើដុះជាសំគាល់ខាងមុខផ្ទះ ។ ខ្ញុំពីបានឮដូច្នោះ ក៏ត្រេកអរពន់ប្រមាណ នាំគ្នាអូសខ្ញុំវាហ៊ុយ ដើរកាត់ចូលទៅចម្ងាយផ្លូវប្រហែល ៣០សិន (១.២០០ម.) ដល់ឈើដុះពីមុខផ្ទះពុងបេង ឯពុងបេងលុះដឹងថា ខ្ញុំពីនឹងចូលមករកកំទឹកក្នុងចិត្តថា ឮល្បីគេនិយាយថា ខ្ញុំពីនេះ មានសតិបញ្ញាប្រកបដោយអធ្យាស្រ័យនឹងសេចក្តីព្យាយាមជាច្រើន នឹងពិតឬ ប្រការម្តេច? តាលនឹងឲ្យដួបខ្លួនគ្រានេះ កំមិនច្បាស់ថា ខ្ញុំពីមានសេចក្តីព្យាយាមយ៉ាងណា ដែលយើងនឹងទៅនៅផងនោះ ក៏នឹងត្រូវជួយគិតការជាធំពេកណាស់ មិនដឹងជាមានប្រយោជន៍ ឬ មិនជាប្រយោជន៍តទៅ ត្រូវតែពិសោធន៍ឲ្យដឹងជួនចិត្តខ្ញុំពីសិន គិតហើយក៏បង្គាប់ក្មេងទុកថា បើឃើញមាននរណាមកសួរកអញ ចូរប្រាប់ថា អញមិននៅទេ ផ្តាំហើយពុងបេងក៏ចូលទៅជួនក្នុងផ្ទះ ។

ឯខ្ញុំពីគួនអ្ងូ ខ្ញុំវាហ៊ុយ ក៏ចុះពីលើសេះដើរចូលទៅដល់ទ្វារបងផ្ទះ ខ្ញុំពីក៏ពិគ្រោះមើលភូមិឋានផ្ទះសម្បែង ឃើញរៀបចំស្អាតបាត គួរជាអ្នកមានរបៀបត្រឹមត្រូវ ប្រសិនបើដល់ដូវក្តៅក៏មិនបានក្តៅព្រោះមានចន្ទោះខ្យល់បក់ចូលមកបាន តាលបើដល់ដូវភ្លៀងក៏ជាទីមួយ

បិទបាំងមិនឲ្យក្មេងទាំង បើដល់រដូវងារក៏មិនបានជាងារណាស់ ព្រោះមានទីបាំងមិនឲ្យឯកសន្សឹមបក់ចូលបាន គួរសមជាទីលំនៅនៃអ្នកដ៏មានជម្រិះប្រាជ្ញាមែន ។

ខ្លៅពីឃើញដូច្នោះ ក៏តែងមានចិត្តសោមនស្សត្រេកអរជាច្រើន ហើយក៏ដើរចូលទៅដល់ដើងដណ្តើរផ្ទះ ។ មានក្មេងម្នាក់ដែលនៅចាំផ្ទះ នោះក៏សាកសួរមកថា លោកឈ្មោះអ្វី ? មកពីណាទៅណា ? ។ ខ្លៅពីឆ្លើយថា យើងឈ្មោះ ហួនបុងកុនយីសេងតេងហោ-ខ្លៅពី ជាពូជព្រះកដវង្សព្រះចៅហៀនតេ ទើងមកគំនាប់អាចារ្យអ្នកឯង ។ ក្មេងនោះក៏ឆ្លើយថា លោកប្រាប់ឈ្មោះនោះច្រើនណាស់ ខ្ញុំចាំមិនបានទេ ។ ខ្លៅពីឆ្លើយថា បើចាំឈ្មោះយើងមិនបាន ចូរទៅដំរាបអាចារ្យអ្នកឯងថាតែខ្លៅពីមកវាកប់ ។ ក្មេងនោះក៏ឆ្លើយថា ឥឡូវអាចារ្យខ្ញុំចាទមិនទៅ ទើងទៅឯណាខ្ញុំចាទក៏មិនដឹង ។ ខ្លៅពីថា កាលណាទើងត្រឡប់មកវិញ ។ ក្មេងនោះក៏ដំរាបថា អាចារ្យខ្ញុំចាទទៅនោះទើងកំណត់ថាមកធាប់ឬយូរមិនបានទេ ដូនតាល ៣ ថ្ងៃ ដូនតាល ៥ ថ្ងៃ ដូនតាល ១០ ថ្ងៃក៏មានទើបបានត្រឡប់មកវិញ ។

ខ្លៅពីបានឮដូច្នោះក៏ទឹកភ្លូចចិត្តណាស់ គួនអ្វី ទៀវហ៊ុយក៏និយាយទើងខ្លៅពីថា ឥឡូវអាចារ្យមិននៅហើយ យើងត្រូវត្រឡប់ទៅវិញសិន

ចុះ សឹមប្រើឲ្យមនុស្សមកចាំស្តាប់មើល ប៉ើដឹងថាវិលមកវិលាណា សឹម
យើងមកវិលានោះ ។ ឡៅតាយល់យើញត្រូវ ទើបផ្តាំនឹងក្មេងនោះថុក
ថា បើប្រសិនអាចារ្យអ្នកឯងមកវិញចូរដំណឹងថា យើងឈ្មោះឡៅតាមកចាំ
គំនាប់មិនបានជួប ឥឡូវយើងត្រឡប់ទៅសិនហើយ ឡៅតាក៏នាំគ្នាត្រឡប់
មកវិញ ហើយឡើងដំរះសេះចេញពីទីនោះទៅចម្ងាយផ្លូវប្រហែល ៣០
សិន (១.៦០០ម), ទទួលជួបនឹង ស៊ុយបេងដើរមក ឡៅតាយើញរូបកាន
កិរិយាសមគួរជាអាចារ្យក៏សំគាល់ថា ពុនបេង ទើបចុះពីលើសេះទៅគំនាប់
ហើយសួរថា លោកនេះឬ ឈ្មោះអាចារ្យហុកឡុង ? ស៊ុយបេងក៏ឆ្លើយ
ថា ខ្ញុំចាទមិនមែនឈ្មោះហុកឡុងទេ ខ្ញុំចាទឈ្មោះស៊ុយបេង ជាកឿន
របស់ពុនបេងដែរ អ្នកមកពីណា? ឈ្មោះអ្វី? ឡៅតាឆ្លើយថា ខ្ញុំឈ្មោះឡៅ
តានឹងមកពីពុនបេងក៏មិនជួបប្រទះ ដែលមកជួបប្រទះនឹងអ្នកក្នុងថ្ងៃនេះកំជា
បុណ្យរបស់ខ្ញុំខ្លាំងណាស់ អញ្ជើញអ្នកឡើងអង្គុយលើទីសមគួរនឹងបាននិ
ន្តាផង ស៊ុយបេងអង្គុយចុះហើយសួរថា លោកមកពីពុនបេងគ្រានេះដោយ
តិចួនុះអ្វី? ឡៅតាឆ្លើយថា ខ្ញុំមកពីគ្រានេះ ព្រោះផែនដីកើតចលាចលមិន
បានជាប្រក្រតី ច្រាថ្នាំនឹងអញ្ជើញពុនបេង ទៅជួយធ្វើរាជការជាមួយនឹងខ្ញុំ
ដើម្បីនឹងទំនុកបំរុងផែនដីឲ្យជាសុខតទៅ ។ ស៊ុយបេងអស់សំណើចហើយ
ឆ្លើយថា ដែលផែនដីកើតចលាចលហើយមកពីពុនបេងទៅជួយទំនុកបំរុង

ឲ្យជាសុខនោះយើញថា លោកមានចិត្តសុចរិតខ្លាំងត្រង់ល្អហើយ តែថា ប្រវេណីផែនដីនេះ រមែងកើតចលាចលហើយក៏ជាសុខ ។ ហើយក៏កើតកលិយុគទៀតវិញ នេះជាធម្មតាមកពីដើមដូច្នេះ ដែលលោកនឹងរិះគិតច្រាបផែនដីដល់កំណត់ចលាចលគ្រានេះ ឲ្យត្រឡប់ជាសុខនោះ ភ្លាចត្រង់មិនសមនឹងជម្រិះគិតតាមច្រាថ្នា ក៏នឹងនាំឲ្យខូចការទេ ឯដែលកើតជាមនុស្សស្រួលពីថ្ងៃនេះ ក៏បំផុតហើយនៅបុណ្យនឹងកម្មនឹងសំគាល់ថាអ្វីក្រៅពីវាសនានេះមិនបានទេ ។

ខ្លៅពីតបថា អ្នកនិយាយដូច្នេះត្រូវហើយ តែថាខ្លួនខ្ញុំនេះបានជាព្ធជព្រះពុជវង្សព្រះចៅហៀនតេមកហើយ នឹងព្រងើយកន្តើយស្ងៀមនៅមិនដួយឈឺឆ្អាលទុក្ខបំបុងមិនបាន ដូចជាមិនមានកតញ្ញូ សូម្បីវាសនាខ្ញុំតិច ក៏ស្រេចហើយនៅភ្យាយាមយកចិត្តទុកជាក់ទំនុកដាក់ធ្វើកុសលកាតបស្នងសងព្រះគុណព្រះចៅហៀនតេ តាមសតិកំឡាំង ។ ស៊ុយបេងតបថា បើដូច្នោះចូរលោកឯរិះគិតទៅចុះ ។ ខ្លៅពីតបថា ដែលអ្នកបានជាសង្គ្រៀនស្នាវតីពន្យល់ខ្ញុំដូច្នេះ ខ្ញុំមិនមែនរលុបគុណអ្នកក៏ទេ តែថាខ្ញុំខំសង្ឃឹមតមគ្រានេះ ច្រាថ្នាឲ្យដួបនឹងឧដបេង អ្នកចូរអនុគ្រោះឲ្យដំណឹងផងចុះ ។ ស៊ុយបេងតបថា ឧដបេងនឹងទៅតែនៃឯណាខ្ញុំក៏មិនបានដឹង ខ្ញុំមកគ្រានេះ តែតាំងចិត្តចង់ដួបនឹងឧដបេងដែរ ខ្លៅពីថាបើដូច្នោះ សូមអ្នកអញ្ជើញទៅ

ជាមួយនឹងខ្ញុំនៅឯស្រុកស៊ុនអៀចុះ ។ ស៊ុយបេងតបថា ខ្លួនខ្ញុំជាមនុស្ស
ស្រុកស្រែចំការ ប្រាថ្នាតែសេចក្តីសប្បាយដោយទំលាប់ពស្ត្រកេស៊ុតធ្វើការ
នឹងទៅនៅធ្វើការពាជការជាមួយនឹងលោក ប្រាថ្នាយកយសហានន្តរសក្តិ
នោះ ចិត្តក៏មិនសូវត្រេកអរ បើវេលាណាខ្ញុំបានទំនេរសឹមឈៀងចូលទៅ
លេងនឹងលោក ហើយស៊ុយបេងក៏លាទៅ ។

ឯខ្មៅពី គួនអ្ហួ ខ្មៀវហ៊ុយ ក៏ឰ្យនឹងសេះនាំគ្នាទៅស្រុកស៊ុនទៀ
នៅ ៤-៥ ថ្ងៃ ខ្មៅពីក៏ប្រើចំរើឲ្យទៅមើលខុងបេង លុះបំរើត្រឡប់មក
វិញក៏ប្រាប់ថា ខុងបេងត្រឡប់មកលំនៅវិញហើយ ។ ខ្មៅពីក៏ចាត់ចែង
ទ្រព្យរបស់នឹងយកទៅគំនាប់ខុងបេង ។ ខ្មៀវហ៊ុយឆ្លើយថា លោកនឹងមក
វិញ្ញើរាប់អានថា ខុងបេងជាមនុស្សមានសតិបញ្ញា ហើយទំនុកហ៊ាស្មើន
ទៅរកដោយធ្វើកាយឲ្យលំបាកនោះមិនគួរសោះ ព្រោះខុងបេងជាមនុស្ស
អ្នកស្រុកស្រែចំការនៅស្រុកក្រៅ បើនឹងឲ្យតែបាននៅហៅយកមកក៏
បាន ខ្មៅពីបានឮដូច្នោះក៏ងឿងណាស់ ឆ្លើយទៀនថា ខុងបេងជាមនុស្ស
មានសតិបញ្ញា ។ ខ្លួនមកមើលងាយប្រមាថដូច្នេះមិនគួរសោះ ថាហើយក៏

ឡើងដំរេះចេញទៅនឹងមនុស្សបំរើគួនអ្ងូ, ខៀវហ៊ុយឃើញដូច្នោះកំឡើង
សេះបរតាមទៅចម្ងាយផ្លូវប្រវែល ៣០ សិន (១៦០០ ម) មានទឹក
សន្សើមធ្លាក់ជោកអស់ពាំនូនរងាំងំណាស់ ខៀវហ៊ុយនិយាយថា
ខេសកាលនេះជារដូវរងា បើប្រសិនមានសឹកសង្រ្គាមក្នុងរដូវរងាគង់តែត
សម្រេកឈប់បាន ចុះនេះគួរហើយឬមកវាប់អានខ្លួនបេងដែលជាអ្នកស្រែ
លើសការអាសន្នទៅខៀតនឹងប្រយោជន៍អ្វី? សូមឲ្យលោកត្រឡប់វិលទៅ
ស្រុកសិនចុះ ។

ខ្មៅពីតបថា ធម្មតាអ្នកនឹងប្រាថ្នារកបស់ល្អ ក៏រមែងប្រកបទៅ
ដោយសេចក្តីទុស្សាហ៍ ទើបនឹងរកបស់នោះបាន ដែលយើងខ្ញុំមាន
កាយមកពាំនម្ងុះ ក៏ប្រយោជន៍ប្រាថ្នានឹងរកខ្លួនបេងឲ្យបាន មួយទៀត
ដើម្បីឲ្យខ្លួនបេងដឹងថា យើងមានសេចក្តីស្រឡាញ់ដោយស្មោះត្រង់ ទើប
ព្យាយាមទៅរកពាំនម្ងុះ បើខ្លួនភ្ញាចនឿយព្រួយលំបាកដោយធនំរងាមិន
បានតំឲ្យវិលត្រឡប់ទៅស្រុកវិញចុះ ខៀវហ៊ុយឆ្លើយថា ខ្ញុំបាទគិតឃើញ
លោកនឿយលំបាកថាខ្ញុំឯងតាសដូច្នេះ ។ ខ្មៅពីឆ្លើយថា ពីថ្ងៃនេះទៅ
យើងហាមកុំឲ្យខ្លួននិយាយដូច្នេះទៀតឡើយ ហើយក៏បរសេះទៅ ។

លុះទៅដល់ខៀមលក់ស្រាមួយដងកូមិ ដែលខ្លួនបេងនៅនោះក៏ជួន
ញុសឡើងមនុស្សនិយាយគ្នា មុនពេលធីកស្រាខាងក្នុងផ្ទះ ឆ្លើយឆ្លងគ្នា

២នាក់ ទៀតពីឮសូរសំដីប្លែកក៏ចាញ់សេះឈប់ស្តាប់ ឮពាក្យដោះសា
វាងវៃណាស់ ក៏សំគាល់ថាខុនបេង ទើបចុះពីលើសេះដើរទៅអែបស្តាប់
ប្រុមាត់ទ្វារ ឃើញមនុស្សម្នាក់មុខមាត់ស្អាតបាតសង្រែះ ពុកមាត់វែង ម្នាក់
ទៀតមុខមាត់មានស្នាហាប់ រូបរាងក៏ស្រស់ចំណាប់ធំដំបង ទៀតពីក៏ចូល
ទៅគំនាប់ហើយសួរថា លោកចាំងពីរ នេះជាអាចារ្យហុកឡុងឬ?
ចោះកុងជួន ឆ្លើយតបថា ខ្ញុំមិនមែនខុនបេងទេ ខ្ញុំឈ្មោះចោះកុងជួនផ្សែង
ទេតើ ម្នាក់ទៀតឈ្មោះបេងគង់អ៊ុយ យើងីចាំងពីរនាក់នេះជាមិត្រ
សំឡាញ់នឹងខុនបេង ។ ទៀតពីបានឮដូច្នោះ ក៏នឹកអឿនឮសណាស់ លា
ត្រឡប់ទៅទៀត លុះទៅដល់ផ្ទះខុនបេងហើយចុះពីលើសេះ ដើរចូល
ទៅសួរក្មេងថា ថ្ងៃនេះអាចារ្យអ្នកឯងនៅទេឬ? ក្មេងនោះប្រាប់ថា អាចារ្យ
ខ្ញុំចាត់តំពូនសម្រាន្តមើលសំបុត្រឯក្នុង ទៀតពីឲ្យក្មេងនោះនាំចូលទៅ បាន
ឃើញមនុស្សកំឡោះម្នាក់ដើរចេញមកពីខាងក្នុង ទៀតពីសំគាល់ថា ខុន
បេងមានសេចក្តីត្រេកអរណាស់ ក៏ចូលទៅគំនាប់ហើយដំកបថា ខ្ញុំបាទនេះ
ឈ្មោះទៀតី តាំងពីបានឮគេនិយាយតមកជាយូរហើយ ខ្ញុំបាទជាមនុស្ស
វាសនាតិច តាំងចិត្តនឹងមកគំនាប់លោកក៏មិនដឹងពីលំនៅ តមកឈឺស៊ី
ណែទាំបង្អាញ ទើបដឹងដំរួយខ្លះ ទំស្រុះស្រួងមកតេលោកម្តងរួចហើយ

មិនបានជួប វ៉ែថ្ងៃនេះដាប់ណាត៍ភ្លុំលុ ខំលុយកាត់ទឹកសន្សើមខ្លះជាក
អស់ពាន់ខ្លួន កំបានមកជួបនឹងលោកមានចិត្តត្រេកអរណាស់ ។

ដូកាត់កិនបានឮដូច្នេះ ក៏ឆ្លើយថា លោកនេះឈ្មោះ ខ្លៅពី ជាតួជ
ព្រះពជវង្សព្រះចៅហៀនគេឬ? ឯខ្លួនខ្ញុំឈ្មោះដូកាត់កិនប្អូនខុនបង់ទេ បង
ប្អូនខ្ញុំពាន់អស់ ៣ នាក់ ម្នាក់ទៀតក៏ឈ្មោះដូកាត់កិនដូចខ្ញុំដែរ ជាបង
បង្អស់ តែចៅធ្វើពជការនៅនឹងស៊ុនគួនចៅហ្វាយស្រុកគាំងតាំង ។ ខ្លៅពី
បានឮដូច្នេះក៏អៀនខ្មាសណាស់ ទើបភ្លុយសួរថា ឥឡូវខុនបង់បងអ្នកនៅ
ឯណា? ដូកាត់កិនឆ្លើយថា បងខ្ញុំមិននៅទេ គឿនសំឡាញ់មកបបួល
ចៅដើរលេងតាំងពីព្រឹក ។ ខ្លៅពីក៏សួរទៀតថា បងអ្នកចៅលេងឯណា?
ដូកាត់កិនឆ្លើយថា ដួនតាលចៅខ្លួក ដួនតាលចៅគោក ទឹងកំណាត់ថាចៅ
ជោយអ្វី ចៅរកនរណាក៏មិនច្បាស់ច្រាកដ ។ ខ្លៅពីថា ខ្ញុំពេញជាអភ័ព្វពាន់
ប្រមាណណាស់ ព្រោះវាសនាតិច បានមករកបងអ្នកដល់ ២ ដងនេះហើយ
មិនបានជួបប្រទះសោះ ។

ខ្លៅវ៉ាហ៊ុយក៏និយាយទឹងខ្លៅពីថា លោកទស្សាហ៍ព្យាយាមមករក
ខុនបង់មិនចេះជួប ទឹងនៅធ្វើឲ្យយូរសោត ពេលក៏កាន់តែល្ងាចណាស់
ហើយ ត្រែងត្រៀងខ្យល់ភ្លាក់មកងាខ្លាំងណាស់ សូមអញ្ជើញត្រឡប់
វិលទៅវិញជាប្រញាប់ចុះ ។ ខ្លៅពីតបថា យើងមកនេះ មិនទាន់បានចរចា

ពាក្យ ១ ម៉ាត់ ២ ម៉ាត់សោះ ខ្ញុំមកបង្ហើយប្រញាប់វិលទៅវិញនោះនឹង
មានប្រយោជន៍អ្វី ហើយក៏សួរដូគាត់កន្ទុយថា ខ្ញុំបានឮគេនិយាយថា
បងអ្នកមានជម្រិះប្រាជ្ញា ដោយបានរៀនវិជ្ជាសិល្បសាស្ត្រចេះចំណាប់
ណាស់ ខ្ញុំនឹកជាប្អូន ម្តេចក៏មិនដឹងថា សព្វថ្ងៃនេះ បងអ្នកចេះដឹងអ្វីខ្លះ ?
ដូគាត់កន្ទុយធ្វើយថា បងខ្ញុំមានជម្រិះប្រាជ្ញាក៏មែនហើយ តែខ្ញុំនឹងបានដឹង
ច្បាស់ថា បងខ្ញុំរៀនវិជ្ជាអ្វីខ្លះនោះ ខ្ញុំមិនអាចដឹងដល់ទេ ។

ទៀតទីនិយាយថា ខ្ញុំមកដល់ទីនេះពីរដងហើយមិនជួបសោះ លុះ
នឹងនៅឲ្យយូរហួសវេលា ពេលក៏ល្ងាចណាស់ទៅហើយ ខ្ញុំសូមលាអ្នក
ទៅ.បាន តែខ្ញុំសូមក្រងាសនឹងពិតមកសរសេរកំណត់គំនាប់ខុកជូនបង
អ្នក តែឈ្មួលជ្រាបថា ខ្ញុំបានទុស្សាហ៍មករកលោកអាចារ្យហុងឡុង
ព្រោះខ្ញុំដឹងដំណឹងថា លោកជាអ្នកមានជម្រិះប្រាជ្ញាវិជ្ជាគុណជំប្រសើរ
នឹងរកអ្នកឯណាផ្ទឹមស្មើគ្មាន ខ្ញុំមានសេចក្តីប្រាថ្នាច្រាំនឿយហត់ ដោយ
សេចក្តីលំបាកមករកលោកដល់ពីរដងហើយ មិនបានជួបសោះ ខ្ញុំនេះ
ជាមនុស្សអកុសលក្រអប្បឥតវាសនាណាស់ សូមឲ្យលោកមានសេចក្តីមេត្តា
ករុណាដល់ខ្ញុំនឹងខ្ញុំផង កុំឲ្យសូន្យសេចក្តីប្រាថ្នាឡើយ បើលោកអនុ-
គ្រោះខ្ញុំហើយ សូមឲ្យខ្ញុំបានមកជួបចំពោះមុខតែម្តងចុះ ដែលមកក្នុង
គ្រានេះ ប្រាថ្នានឹងពឹងប្រាជ្ញាវិជ្ជាគុណរបស់លោក សូមអញ្ជើញលោក

ទៅជួយធ្វើការពាជការខំនុតបំរុងផែនដីដែលចលាចល ឲ្យបានរៀបរយ
ជាសុខក្សេមក្សាន្តតទៅ នឹងបានច្រាកដក្តីឈ្មោះ ដោយកំឡាំងជម្រុះ
ច្រាជ្ញានឹងគំនិតគតិគួរបស់លោក លុះចប់ហើយក៏ប្រគល់ឲ្យដូគាត់កិន រួច
ក៏គំនាប់លាវិលមកវិញ ខ្លួលឡើងលើខ្នងសេះភ្លាមសំឡេងក្មេងស្រែក
ថា លោកតាអាចារ្យមកពីនោះហើយ ។ ខ្មៅពីក្រឡេកទៅឃើញអាពុក
ក្មេកខ្នងបេងដំនុដ្ឋ . មានក្មេងគួចម្នាក់ដើរតាមឆ្ងងស្ពានមក ក៏សប្បាយ
រោះរាយក្នុងចិត្តសំគាល់ថា ខ្នងបេង ខ្មៅពីក៏ចុះពីសេះចូលទៅគំនាប់ថា
អាចារ្យខ្ញុំមានការយ៉ាំការត់ខំសង្វែម អញ្ជើញមកពីណា ខ្ញុំទស្សាវ
ស្ទុះស្វែងមករក ទើបនឹងបានជួបថ្ងៃនេះ ដូគាត់កិនក្រឡេកឃើញខ្មៅពី
គំនាប់ដូច្នោះ ក៏ស្រែកប្រាប់ពីក្រោយថា មិនមែនខ្នងបេងទេ អ្នកនេះគឺ
ឈ្មោះអុយស៊ីង៉ាន ជាអាពុកក្មេកខ្នងបេងទេតើ ។

ខ្មៅពីបានឮដូច្នោះក៏ត្រាំតែអឿនខ្ញាសក្នុងចិត្ត គំនាប់ហើយក៏ឡើង
សេះបរទៅ លុះទៅដល់ស្រុកសិនអៀ ខ្មៅពីមានសេចក្តីខ្វល់ខ្វាយមនស្ស
ដែលគិតនឹងរកខ្នងបេងនោះ មិនមានជាប់មួយវេលា ខ្លួលចូលឆ្ងាំថ្មីក៏
ដួតខឹងដំរះកាយ រួចតែងខ្លួនស្លៀកពាក់ដោយសមគួរសន្ទ្រួមកាយគ្រប់
៣ ថ្ងៃហើយ ក៏រៀបចាត់ចែងរបស់ទ្រព្យដែលនឹងយកទៅគំនាប់ខ្នងបេង ។
គួនអ៊ូឃើញដូច្នោះក៏និយាយនឹងខ្មៅពីហ៊ុយថា : អ្នកបងនេះមានសេចក្តី

កន្លស់កាប់ពាន់ខុនបេនដូច្នេះ អាចារ្យនេះឫកធំពេកណាស់ យើងទុស្សាហ៍
ទៅមានតាយសែងទៅរក ២ ដងហើយមិនចេះដួប ឥឡូវនឹងទៅធ្វើអ្វីទៀត
នាំឲ្យព្រួយលំបាក ពោះបើយ៉ាងណាក៏គួរឲ្យដួបតែម្តងចុះ នេះប្រហែលគ្រាន់
តែភ្លេចខ្លួនទេ ទេ បើខុនបេននោះជាអ្នកមានជម្រះប្រាជ្ញាមែន ដូចពាក្យ
គេថា ក៏គន់នឹងទៅរកបានដួបខ្លះ នឹងដឿថាពិតជាចេះដូចជាមិនមែន
សោះ។ ខៀវហ៊ុយបានឮដូច្នោះក៏ធ្វើយឡែនទៀតថា ដែលបងគួនអ៊ូស្មាន
នោះក៏ដូចគំនិតខ្ញុំតែដែរ បើប្រាថ្នាបងចង់ជួបខុនបេនឲ្យបាន ខ្ញុំនឹងខ្ចួល
ជាធុរៈគ្រាន់តែប្រើបំរើឲ្យទៅហៅខ្លួនយកមកក៏បាន បើប្រសិនខុនបេន
មិនព្រមមក ខ្ញុំនឹងយកក្ប ១ ទៅទៅបងដឹកយកមកជូនលោក ។ កុំបាច់
ទៅឲ្យព្រួយឡើយ ។

ឡៅតីបានស្តាប់ក៏ចិត្តណាស់ ស្រែកតំហកឲ្យខៀវហ៊ុយថា ចៅ
ចរចានេះជាមនុស្សគ្មានអធ្យាស្រ័យអ្វីសោះ រំលុបរំលាងកេរ្តិ៍ឈ្មោះខុន-
បេន ដូចជាគេគ្មានជម្រះប្រាជ្ញា ចៅមិនជំនឿទេឬ អម្បាលដល់ព្រះចៅ
ដ៏វិបុនអង្គលោកដាក្យត្រដឹប្រសើរ ម្តេចទៅទ្រង់ព្រះទុស្សាហ៍យាងខ្ចួល
កេងសុងដល់ក្រៅព្រះនគរឯខ្លួនយើងប៉ុណ្ណោះក៏គួរតែនឹងទៅចំណុះខុនបេន
បើខ្លួនមិនយល់ឃើញថាសមគួរនឹងទៅក៏នៅតាមចិត្តចុះ ខ្លួនយើងគួនអ៊ូ
ត្រូវតែស៊ូព្យាយាមទៅម្តងទៀត ។ ខៀវហ៊ុយឆ្លើយថា ខ្ញុំបាទនឹងចោលបង

ម្តេចបានត្រូវតែទៅដែរ ។ ខ្ញុំពីថា បើទៅជាមួយនឹងយើងក៏តាមចិត្ត តែសេចក្តីអ្វីដែលយើងបានហាមប្រាមហើយ មិនត្រូវចរចាទៀតឡើយ ថា ហើយខ្ញុំពីក៏នាំគ្នាចេញទៅ លុះដំតន់ដល់ទីលំនៅខុនបេង ប្រហែល ២០ ម៉ិន (៨០០ ម.) ជួបនឹងជូកាត់កិនដើរមក ខ្ញុំពីគំនាប់ហើយ សួរថា បងអ្នកនៅទេឬ ? ជូកាត់កិនគំនាប់ហើយឆ្លើយថា បងខ្ញុំត្រឡប់ មកពីមរ្យែលមិញហើយ ថ្ងៃនេះមុខជាបានជួប លោកអញ្ជើញទៅចុះ ថា តែប៉ុណ្ណោះហើយក៏ដើរហួសទៅ ។ ខ្ញុំពីមានសេចក្តីត្រេកអរទ្រួតដើរ ចូលទៅ លុះទៅដល់ទ្វារផ្ទះកិនិយាយនឹងក្មេងតូចឲ្យនាំសេចក្តីចូលទៅ ប្រាប់ខុនបេងថា ខ្ញុំពីមកពីក្មេងនោះក៏ចូលទៅដំរាបថា ដូរ៉តខ្ញុំពីមកពីក ខុនបេងពន្យល់ហើយក៏ឲ្យក្មេងនោះចេញមកវិញប្រាប់ថា អាចារ្យ ខ្ញុំបានទៅផ្ទះកំមែន តែថាកំពុងសំពះលក់នៅឡើយ ខ្ញុំមិនហ៊ានជាស់ ទេ ។ ខ្ញុំពីថា អាចារ្យអ្នកឯងសំពះក៏កុំអាលទៅរំខានឡើយ ហើយក៏ បង្គាប់គួនអ៊ូ ឲ្យរៀបហ៊ុយឲ្យនៅចំខាងក្រៅផ្ទះ ខ្ញុំពីក៏លបដើរចូលទៅ ខាងក្នុង ឃើញខុនបេងដេកបែរមុខទៅខាងជញ្ជាំង ខ្ញុំពីក៏ឈរនៅពី ជ្រុងតាប ឲ្យរៀបហ៊ុយឃើញខ្ញុំពីចូលទៅយូរណាស់ មិនបានឮសំឡេង និយាយគ្នាថាអ្វីសោះ ក៏ខឹងណាស់ ត្រឡប់ចេញទៅប្រាប់គួនអ៊ូថា ខុនបេង នេះអាក្រក់ណាស់ គ្មានសេចក្តីគួរសមនឹងបងយើងសោះ ថែមធ្លាប់ដេក

លក់ទៅទៀត ខ្ញុំចង់យកក្តៅទៅដុតផ្ទះពីខាងក្រោយឲ្យភ័យក្លាក់ឡើង
ឲ្យបាន គួនអ្នកគិតយើញទុសក៏និយាយហាមឃាត់ទៀតហ៊ុយ ។

ឯទុងបេនដឹងដែរ តែធ្វើជាដេកលក់នៅប្រហែល៤មោង ក៏ក្រោក
ក្លាក់ឡើងធ្វើអាការៈបីដូចជាខើបនឹងក្លាក់ពីដេក ហើយត្រឡប់ធ្វើជាដេក
ទៅវិញ ។ ក្មេងបំរើយើញឡៅពីឈរខ្មាមានការយូរណាស់ ក៏កើតវេទនា
ក្នុងចិត្តនឹងចង់ចូលទៅជាស់ទុងបេនឲ្យក្លាក់ឡើង។ ឡៅពីឃាត់ថា កុំគាល
ទៅធ្វើវាឲ្យអាចារ្យសំកន្តឲ្យសប្បាយចុះ ឯទុងបេនធ្វើជាដេកកន្លងថ្ងៃ
នោះយូរណាស់ ទាល់តែរសៀលមោង៥ ហើយខើបប្រែខ្លួនក្លាក់ឡើង
និយាយជាពាក្យឃ្លោង៤បទ សេចក្តីថា :

ធម្មតាជាមនុស្សនោះដេកស្ងប់ ស៊ីឯលក់ចាំងចិត្តចាំងសញ្ញា
លក់ចាំងរូបរស់អស់កាយា លក់ចាំងនេត្រាមាត្រាផង ។
ទីលែងដំណេកដែលដេកនេះ គួចតែបើរៈឲ្យម៉ត់ហ្មង
គួរដេកសប្បាយកាយកន្ធង ចានរិះត្រិះត្រងជាង៥ផ្លុះធំ ។
ទោះបីរដូវត្រូវក្តៀងផ្គរ ឲ្យលំព្យុះបក់មកលើដុំ
មិនឲ្យព្រួយចិត្តគិតទុក្ខទំ និយមតែសោយជោយសុខា ។
ឧត្រះអាទិត្យមានរិទ្ធិរុង កុំគាលចាត់វង់ចាំងបព្វតា
ចូរនៅចាំងចែងសែងសុរិយា ឲ្យយើងសេយ្យនាជាសុខអីយ ។

លុះថាឃ្លោងចប់ហើយ ក៏ហៅក្មេងតូចនោះចូលទៅសួរថា មាន នរណាមកវាសយើងខ្លះឬទេ ? ។ ក្មេងតូចនោះដាក់បថា ឥឡូវ ឡៅតីមក រកលោកឈរចាំនៅខាងក្រៅជាយូរហើយ ខ្ញុំបេងក៏ធ្វើជាខឹងកំហែងក្មេង នោះថា ហេតុម្តេចបានជាមិនប្រាប់អំពីដំបូង ចេះតែនៅស្ងៀមចាស់តែថ្ងៃ ល្ងាចដូច្នេះ ថាដូច្នោះហើយ ក៏ក្រោកដើរចូលទៅលែងក្តី សិតសក់ ស្ទឹកពាក់នោងអាវរៀបខ្លួនហើយក៏ចេញមក ។

ឡៅតីក្រឡេកឃើញខ្ញុំបេង មានរូបរាងធំខ្ពស់ប្រហែល ៦ ហត្ថ មុខមាត់ស្អាតជាតិសម្បុរស ដូចបណ្តាលចេក តែងខ្លួនស្រស់បស់ បែបជាអាចារ្យអ្នកធំ ក៏ចូលទៅគាប់ហើយថា ខ្ញុំបាទតាំងចិត្តមករក លោកវេលានេះ ព្រោះមានសេចក្តីប្រាថ្នាខ្លាំងសុំដម្រិះប្រាជ្ញាលោកឲ្យ ជួយ ដោយដែនដីសព្វថ្ងៃនេះ កើតចលាចលដាតខ្លាំងសាបសូន្យទៅហើយ ខ្លួនខ្ញុំបាទនេះជាពួជព្រះរាជវង្សព្រះចៅហៀនតេ តែថាមានសត្រូវ តិចណាស់ ហើយក៏ជាអ្នកស្រែកស្រែរត្រៅនៅស្រុកខ្លួនក្លួន ដ៏ធំថា លោក ជាមនុស្សត្រឹមត្រូវមានជម្រិះប្រាជ្ញាដ៏សំខាន់ លាន់ឮល្បីចប់ដែនដីគ្រប់ កន្លែង ដូចសំឡេងផ្គរនេះ ខ្ញុំបាទគ្រែងអរណាស់ ទើសស្វែងមកគាប់ លោកដល់ ២ ដងហើយ តែមិនដែលបានជួបប្រទះសោះ បានជាសរ- សេរកំរោតខ្លួកដាក់បថ្វាយលោកឲ្យបានជ្រាប ។ ខ្ញុំបេងតបថា ខ្ញុំបាទ

បានយើញក្នុងសេចក្តីកំណត់ក៏ដឹងអស់ហើយ តែខ្ញុំបាទគិតថា ខ្លួនខ្ញុំ
បាទនៅក្មេងសេចក្តីខ្ចីគំនិតណាស់ ទាំងជម្រិះប្រាជ្ញានឹងរិះគិតក៏នៅខ្លះ
ថយ បើនឹងទៅនៅធ្វើពាណិជ្ជការជាមួយនឹងលោក ក៏ខ្លាចក្រែងខូចបង់ការ
ជាអសារបស់លោកទៅ ។ ឝ្លៅព័ន្ធបានឮពុនឝេនិយាយបន្ទាបខ្លួនដូច្នោះ
ក៏ថាដែលលោកមានប្រសាសន៍ថា ជម្រិះប្រាជ្ញាខ្លះថយនោះ ខ្ញុំបាទក៏
យល់ហើយដោយសុភាតែការនោះនឹងឈើស្មុ បានឲ្យដំណឹងពីថ្ងៃមុនគ្រប់ប្រ-
ការ សូមលោកកុំបោះបង់ឲ្យខ្ញុំខូចបំណងប្រាថ្នាឡើយ ចូរជួយយកអាសា
ដែនដីផងចុះ ។ ពុនឝេនឮដូច្នោះក៏តបថា ដែលលោកនឹងឲ្យខ្ញុំបាទទៅជួយ
រិះគិតធ្វើពាណិជ្ជការនោះ គំនិតរបស់លោកនឹងចង់គិតដូចម្តេចខ្លះ ? ចូរ
បំភ្លឺឲ្យខ្ញុំបាទដឹងច្បាស់សិន ។ ឝ្លៅព័ន្ធក៏កិលចូលទៅដិតពុនឝេនហើយ
ថា សព្វថ្ងៃនេះ ព្រះចៅហៀនតេគ្រងពាណិជ្ជសម្បត្តិជាក្សត្រាធិពាណិជ្ជ តែទ្រង់
សាបសូន្យអំណាច ព្រោះមានពាណិជ្ជត្រូវទៅបៀតបៀនធ្វើឲ្យព្រួយព្រះ
ពាណិជ្ជហ័យក្រៃពេក ខ្ញុំបាទមានចិត្តឈឺក្តៅជាអនេក ដោយការដែនដីនោះ
ឬ ណាស់ បានជាខំស្វះស្វែងរកអ្នកមានជម្រិះប្រាជ្ញា ដែលល្មមនឹងជួយ
គិតការកំចាត់សត្រូវពាណិជ្ជសម្បត្តិនោះចេញបាន ក៏នៅមិនទាន់សម្រេច
សេចក្តីប្រាថ្នានៅឡើយ តែឥឡូវយោធាក៏បានប្រុងប្រៀបខ្លួនហើយ
ទើបមករកលោកគ្រានេះ ប្រាថ្នានឹងចង់ឲ្យជួយរំនុកបំប៉ន លោកគួរ
មានសេចក្តីអាណិតខ្ញុំបាទផងចុះ ។

ខ្ញុំដែនតបថា ឯដែនដីដែលកើតចលាចល ដរាបមកដល់
វេលានេះ ក៏ព្រោះតាំងតុះជាដើមហេតុ ឯបួនសោតក៏បានប្រុងប្រៀប
ពលពាហនចាំងពួង លើកទៅកំចាត់អ្នកសៀវបានខោះមិនមែន នឹង
សម្រេចដោយកំឡាំងពាហនច្រើន ក៏ឥតអង្គឺមាន គឺពាហនបួនតូចជាង
ពាហនអ្នកសៀវទៀត ដែលនឹងអាចធ្វើការដ៏ធំពន្ធឹក ឲ្យសម្រេចបាន
ខោះ ក៏ព្រោះបញ្ញានឹងគំនិតរិះគិតរបស់ខ្ញុំ ខោះបើបើបួនអាក្រក់
មិនមានសេចក្តីកតញ្ញូនឹងព្រះចៅហៀនតេ · គិតតែធ្វើការបៀតបៀន
ដោយចិត្តប្រទូសព៌យយ៉ាងណាក្តី ក៏កម្រនឹងកំចាត់បួនបានដោយងាយ ។

ឯស៊ុនគួនចៅហ្វាយស្រុកកាំងតាំងសោត សូម្បីមានកំឡាំងតិច
ក៏បីដូចជាមានកំឡាំងច្រើន ព្រោះអាណាប្រជានុកស្ត្រគាំងពួង មាន
សេចក្តីពប់អានស្រឡាញ់ បីដូចជាចិត្តមួយ ខ្លួនមួយនឹងគ្នា លោក
កុំគប្បីមើលងាយប្រមាទស៊ុនគួនឡើយ គួរហើយតែនឹងស្រឡាញ់ពប់
អានឲ្យបានជាមេត្រីនឹងគ្នា ឯស្រុកកេងដីវ៉ាខោះសោត ក៏ជាស្រុក
មុខសឹកដូចសត្រូវមានទៅដុំគាំង ៤ ទិស បើអ្នកឯណាមានដម្រិះ
ប្រាជ្ញាអាចនឹងរក្សាការពារយ៉ាងម្តេច អំណោះទៅមុខក៏គង់នឹងបានជា
របស់លោក ដូចយ៉ាងស្រុកសែឈួនជាក៏ស្រុកធំមាំមួន ប្រកបដោយ
ទ្រព្យសម្បត្តិជាច្រើននោះ តាលគ្រាព្រះចៅហាន់តោចក៏តាំងខ្លួន

ក្នុងស្រុកនោះជាមុន ឥឡូវ ខ្លៅដៀរចៅហ្វាយស្រុកសែឈួនកំជាមនុស្ស
លេះលោះនឹងយកជាការមិនបាន ហើយកំគ្មានមេត្រីពប់អាន បណ្តា
ពួកពលខាហានទាំងពួង កំចាំពេលតែនឹងប្រែបែកចិត្តចេញ ខ្លួនលោកកំ
ជាពូជព្រះពជវង្សព្រះចៅហៀនតេ ហើយប្រកបចៅដោយសតិបញ្ញាកំ
ឆ្លៀវឆ្លាត បើនឹងគិតសង្ឃឹតយកស្រុកតេងដីវហើយ ស្រុកសែឈួនកំនឹង
បានដោយងាយ តែថាបើបានហើយ ចូរធ្វើមេត្រីឲ្យកេះកយចៅជល់បណ្តា
អាណាខ្មែត្រទាំងពួង ឯស៊ុនគួននោះ កំនឹងបានជាទីពុំនាក់របស់លោក
តៅ នឹងបានតាំងទុកបំរុងសេនាខាហានឲ្យត្រមត្រៀង បើឃើញ
ថាវែនដីវៀរកេយចៅកាលណា កំនឹងបានរៃគិតធ្វើការចៅបានស្រួល
ឯអាណាប្រជានុកស្តេចទាំងពួង កំនឹងមានចិត្តស្រឡាញ់លោកជាច្រើន
ដែលលោកមានសេចក្តីប្រាថ្នា នឹងឲ្យជួយទុកបំរុងនោះ ខ្ញុំបាទកំនឹង
បានណែនាំពន្យល់ឲ្យលោកបានផ្លូវចំរើនជម្រះប្រាជ្ញាតែប៉ុណ្ណោះ ប្រសិន
បើលោកមានសេចក្តីទុស្សាហ៍ធ្វើតាមពាក្យសំដីខ្ញុំបាទហើយ កំនឹងបាន
សម្រេចដូចសេចក្តីប្រាថ្នាជាមិនខាន ។

ឧកញ៉ាបេនសន្ធានឹងខ្លៅពីដូច្នោះហើយ កំហៅឲ្យក្មួនលើតយក
វែនទីដំបន់ស្រុកសែឈួន ដែលមានស្រុកឡើង ៩០ មណ្ឌលមកសាឲ្យ
មើល ហើយឧកញ៉ាបេនសន្ធានិយាយថា បើលោកមានសេចក្តីទុស្សាហ៍ព្យាយាម

រៃគិតធ្វើការបានស្រុកសែឈួននេះកាលណាហើយ ក៏នឹងបានជាធំសមដូច
សេចក្តីប្រាថ្នាកាលណោះ ឡៅពីបានស្តាប់ពុនរបងប្រាប់ដូច្នោះក៏និយាយ
ថា ដែលលោកមានសេចក្តីមេត្តាណែនាំពន្យល់ឲ្យខ្ញុំបានយល់ដូច្នេះ
ខ្ញុំបានក៏មានសេចក្តីត្រេកអរណាស់ បានក្តីស្វាងជ្រះក្នុងដួងចិត្ត បីដូច
ព្រះអាទិត្យដ៏មានបរមណ្ឌល ប្រាសចាកពពកចំពាំង ចែងចាំងខ្ពង់ៗ
ក្នុងលោកចាំងពួង តែថាស្រុកសែឈួននឹងស្រុកកងដីវានោះ សុទ្ធតែ
ជាបក្រតែសែលោហិតព្រះបរមរាជវង្ស នៃព្រះចៅហៀនតេ ធ្លើចៅហ្វាយ
ស្រុកចាំងអស់ បើខ្ញុំបានក៏គិតធ្វើការយកស្រុកចាំង ២ នោះ កំហាក់
បីដូចជាក្បត់ផែនដី ជាមនុស្សអកតញ្ញូនឹងព្រះមហាក្សត្រិយ៍ ។

ពុនបេងឆ្លើយថា លោកមានប្រសាសន៍នោះក៏គួរហើយ តែ
ខ្ញុំបានពិគ្រោះមើលឃើញថា ឡៅប៉ៅវានោះជាមនុស្សអាយុមិនយឺន
យូរអង្វែងទេ ឯឡៅប៉ៅវានោះសោត ក៏ជាមនុស្សលេះលោះមិននឹងនួន
ក្នុងកាយ សូម្បីតែអាណាប្រជានុករស្តេចចាំងឡាយ ក៏មិនសូវមានចិត្ត
ស្រឡាញ់ ទោះបីលោកនឹងមានចិត្តកតញ្ញូ ដល់ព្រះចៅហៀនតេពិត
ក៏មិនបានតាំងចិត្តប្រទូសរ៉ាយអ្នកចាំង ២ នោះឡើយ លុះយូរៗទៅ
ហើយក៏នឹងកើតអន្តរាយៗឯង ស្រុកចាំង ២ នោះក៏នឹងបានដល់លោក
ជាប្រាកដ ។

(មានត)

សុភាសិតហិណ្ឌូ

ណោក រ៉ាយ-ប៊ីក ជាស្រែង់ រៀបរៀង

១-ដើម្បីឲ្យចម្រើនចំពោះការដើរតាមសេសវិសាលខ្លួន គឺត្រូវហាត់សរសៃដុំ នៃដើងរបស់យើង មិនត្រូវប្រើដើងឈើរបស់ជនបរទេសសោះឡើយ ។

២ បង្កឿនឆ្មាមិនអាចធ្វើឲ្យបង្កឿនមួយទៀតឆេះបាន, បើបង្កឿនឆោះមិនអាចកក្រុំទុកនូវអណ្តាតភ្លើងរបស់ខ្លួន ។

៣-គ្រូមិនអាចនឹងបង្ហាត់បង្ហាញគេបានដោយពិត, បើខ្លួនមិនបានសិក្សារៀនសូត្រខ្លួនឯងតទៅទៀត ។

៤-សច្ចធម៌មិនគ្រាន់តែជូនពរមានទេ ត្រូវញុំាងចិត្តឲ្យមានគំនិតថ្មីៗតទៅទៀត ។

៥-សុភមង្គលប្រៃប្រួលដូចដំណក់ទឹក ។

៦-បាត់ញាតិដោយមិនបានទៅញឹកញាយ, បាត់បំណុលដោយយើងមិនបានទារច្រាក់ដំពាក់, បាត់ជីដោយយើងមិនអកិបាលរក្សា ។

៧-មនុស្សម្នាក់អាចសម្លាប់មនុស្សម្នាក់បាន, តែលំអរូបកាយនៃនារីពាំងឡាយ អាចសម្លាប់មនុស្សដែលទៅជាប់ទាក់ ។

៨-ដៃក្តាប់នាំឲ្យអត់ចាយ ។

៩-ថ្នាំដ៏វិសេសយ៉ាងណា ក៏មិនអាចបំភ្លឺមនុស្ស ដែលមានស្ថានការណ៍ ដ៏តដល់សេចក្តីវិនាស; ទុសច្រគេពេទ្យពូកែយ៉ាងណា ក៏មិនអាចជួយយោងជីវិតមនុស្ស ដែលសេចក្តីស្លាប់ដ៏តមកដល់ ។

១០-ការសិក្សាច្រើនហួសប្រមាណការងារមិនស្អាត ។

១១-បើកូនប្រុសរៀបរាប់ហាមឆ្ងល់ការពីក្មេងពេក, ប្រពន្ធកូនប្រុសនោះ នឹងរងទុក្ខលំបាកគ្រប់យ៉ាង ។

១២-បើការយោយើងសប្បាយចិត្ត គឺជានាងទេវធីតា, បើការយោយើងអាក់អន់ស្រពន់ចិត្ត គឺជាបិសាច ។

១៣-គ្មានប្រសើរ ជាងមានវត្តុដែលមិនល្អ ។

១៤-គោរពព្រះគាថាទេពតែមួយអង្គ ប្រសើរជាងគោរពបិសាចមួយពាន់រូប ។

១៥-សេចក្តីខ្មាសគេ ដោយហេតុមកពីលួចស្វាមួយ, បើទុកជាធ្វើអំណាយទូវដ៏រមួយ ក៏មិនអាចរលុបរលាង នូវកំហុសនោះបានឡើយ ។

១៦-ដៃមួយ មិនអាចទះព្រមេ ។

១៧-ផ្ទះព្រួសរស់ពួកខ្លឹងជាងក្តៀង ។

១៨-កូនក្មេងដែលគេថែរក្សាដោយល្អ, កូនក្មេងនោះតែងឃ្លានអាហារ ។

១៨_ខ្លួនជាទំនាំង អ្នកឯទៀតជាឆ្កែសរ៉ី ។

២០_ដីកព្រែកឲ្យត្រង់តើហែលទឹក ។

២១_ផ្លូវនៃសច្ចធម៌នាំទៅកាន់ព្រះអាទិទេពតែមួយ ។

២២_អ្នកឯងឆ្ងាយយ៉ាងណា ទីដែប្រៃទៅយ៉ាងនោះ ។

២៣_ពោលអំពីសាសនា ជាការងាយ, ប្រព្រឹត្តប្រតិបត្តិតាមសាសនានោះជាការលំបាក ។

២៤-ធ្នាំងស្ពានដែលគេមិនបានជុសខាត់ពលាំថ្ម មានសម្បុរស្រអាប់ចិត្តដែលគ្មានសមាធិពលាំថ្ម ទៅជាកកស្អុក ។

២៥ - មនុស្សណាមានកោតទ្រព្យហើយមិនចេះប្រើប្រាស់ គេមិនខុកជាមនុស្សទេ ។

២៦- វាយោតែងបក់នាំកូនចន្ទន៍ក្រអូប ទីងកូនស្មូយ តែកូនពាំងពីរនេះ មិនអាចលាយឡំគ្នាបាន ។

២៧_ ឆាងជូងជ្រុះធ្លាក់, តែខុកស្មាមនៅលើដើមជូង ។

២៨- ពស់មានពិសនៅក្នុងធ្មេញ, តែពិសនោះ មិនអាចសម្លាប់ពស់ទេ, ជាពិសសម្រាប់សម្លាប់ជនដទៃ ។

២៩_ បើពាក់ស្បែកជើងហើយភ្ជាចអ្នកស្ងួនឯងបន្ទា, បើមានវិជ្ជាពេញបរិបូណ៌ហើយ ភ្ជាចអ្នកស្ងួនឯងទុក្ខ ។

៣០- ព្រះអាទិត្យ, ព្រះចន្ទមិនអាចបំភ្លឺពិភពកកស្អុកបាន ។

៣១- ការក្រឡេកឃើញមនុស្សច្បាប់ នាំឲ្យយើងនឹកឃើញដល់ក្តី សាលាតុលាការ; ការក្រឡេកឃើញគ្រូពេទ្យ នាំឲ្យយើងនឹកដល់ពេត, ព្យាធិ, ទុស្ស ។

៣២- កម្លាំងធំ កើតពីទឹបសគ្គធំ ។

៣៣- តាមគុណជាពស់មានក្បាលមួយពាន់ ដែលត្រូវយកកែងដើងជាន់ក្បាលស្លាប់ ។

៣៤- ពេលសប្បាយបំផុត គឺពេលណាដែលយើងក្មេច១ន ។

៣៥- មនុស្សកើតមក ដើម្បីតស៊ូនឹងធម្មជាតិ ។

៣៦- មនុស្សធំគឺមនុស្សណា ដែលអ្នកដទៃសរសើរ នូវគុណសម្បត្តិ ។

៣៧- ស្មៅវែញប្រមូលគ្នាអាចទប់ទឹកភ្លៀងបាន, ស្មៅដដែលពត់រាយគ្នា មិនអាចទប់ទឹកភ្លៀងបាន, ទឹកភ្លៀងអាចធ្វើឲ្យដាប់ស្មៅនោះបាន។

៣៨- ខន្ធធំ, រុក្ខជាតិធំ, ដើមឈើទុស្ស, មនុស្សសប្បុរស កើតមកមិនមែន ដើម្បីខ្លួនឯងទេ, ដើម្បីធ្វើការជូនអ្នកដទៃ ។

៣៩- គេស្គាល់មាសដោយថ្មសំលៀង, គេស្គាល់មនុស្សដោយសំដី, គេស្គាល់គោដោយទឹមរនេះ, តែមិនមានវិធានការអី ដើម្បីឲ្យស្គាល់ធម្មជាតិ របស់ស្ត្រីសោះឡើយ ។

៤០- គេមិនដែលធ្វើអន្ទឹងមុនក្មេងកើត ហើយគេមិនដែលពាយក្មេង មុនដែលគេឃើញក្មេងនោះឡើយ ។

៤១- អ្នកណាសាបព្រោះពូជល្អ នឹងបានគ្រាប់ស្រូវល្អ ។

៤២- បុត្រម្នាក់មានប្រាជ្ញាប្រសើរជាងបុត្រល្ងង់មួយរយនាក់ ; ព្រោះបន្តែតមួយ អាចបំបាត់ខ្លួងងឹតបាន ប្រសើរជាងផ្កាយពាន់ហ្មឺន ។

៤៣- បក្សាតែងឃើញចំណីរៀងៗខ្លួន ចម្ងាយមួយរយយោជន៍ , បើពេលវេលាដល់ហើយ , មិនឃើញអង្គប់ដែលគេជាក់ក្នុងទីចំពោះមុខទេ ។

៤៤- បក្សាដែលហើរលើអាកាស មិនអាចផុតពីគ្រោះថ្នាក់ , ម្ចាស់ហៅថាគ្មានត្រូវ មិនអាចផុតពីកណ្តាប់ដៃអ្នកនេសាទ ។

៤៥- ធ្យូងឈើ , កាលណាក្តៅឆេះ , កាលណាត្រជាក់ប្រឡាក់ដៃ ។

៤៦- ស្មៅស្ងួតត្រឹមមួយសំណុំឆេះ មិនអាចធ្វើឲ្យក្តៅទឹកសមុទ្របានទេ ។

៤៧- កុំខុកចិត្តធ្មា, ក្របី, ដៀម, ក្អែក, មនុស្សពាល ។

៤៨. មនុស្សពាលដូចជាក្អមដីដែលបែក ហើយមិនងាយនឹងយកអំបែងមករួបរួមឲ្យទៅជាភ្នក្អមល្អវិញបាន. មនុស្សប្រាជ្ញដូចក្អមមាសដែលបែកហើយងាយរួបរួមជាក្អមមាសដដែលវិញបាន ។

៤៩- វាយោ មិនមែនធ្វើឲ្យស្មៅប្តូដើមឈើតូចៗរលំទេ, វាអាចធ្វើឲ្យរលំដើមឈើធំៗ ។

៥០- ចូរអ្នកយកភ្ញាញ់ ទៅលាបកន្ទុយឆ្កែ ហើយយកកំណាត់រុចធ្វើឲ្យជាប់ជល់ ១៦ ឆ្នាំ, ហើយស្រាយចំណងចេញ, កន្ទុយនោះស្តិតទៅដដែលវិញ មិនប្រែប្រួល ។

៥១- បើខុកជាយកទឹកអម្រឹតមកស្រោចដើមឈើពុលផង, ក៏ដើមឈើនោះមិនអាចឲ្យផ្លែបរិភោគបាន ។

៥២- ចូរអ្នកឲ្យពស់ផឹកទឹកដោះ, ពស់នោះគាន់តែមានពិសច្រើនឡើងទៀត ។

៥៣ សត្រូវបុត្រគឺបិតាមានបំណុល, សត្រូវស្វាមីគឺប្រពន្ធផឹកស្រវឹង, សត្រូវបិតាគឺបុត្រល្ងីល្ងើ ។

៥៤- វត្តបីយ៉ាងនាំឲ្យខូចមេត្រីភាពគឺ ចូលទៅរកគូនញឹកញាយ១, ខ្ចីប្រាក់មិត្រញឹកញាយ១, ចូលទៅប្រាស្រ័យនឹងប្រពន្ធមិត្រ ពេលមិត្រមិននៅ១ ។

តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

ដើមកំណើតល្បែងនាញព្រ័ត្រ

បាប-ពិន រៀបរៀង

ប្រទេសខ្មែរយើងមានល្បែងពាប់រយមុខ ជាល្បែងប្រចាំជាតិ ។ ល្បែងពាំងនោះ ខ្លះជាល្បែងសម្រាប់មនុស្សក្មេង ខ្លះជាល្បែងសម្រាប់មនុស្សចាស់ ជាល្បែងកំសាន្តចិត្តក៏មាន ជាល្បែងហាត់ប្រាណឲ្យពុងកាយមានសុខភាពរឹងប៉ឹងក៏មាន ជាល្បែងហាត់ចិត្ត ហាត់គំនិតឲ្យមានសេចក្តីវាងវៃ ឲ្យចេះពេលល្បិចក៏មាន ដែលគួរចាប់អារម្មណ៍ គួរពាប់បញ្ចូលក្នុងពួកកីឡាអត្តពលកម្មបាន ។

ក្នុងទីនេះ សូមពណ៌នាតែល្បែងនាញព្រ័ត្រ ១ មុខ ជាល្បែងពាប់ចូលក្នុងពួកកីឡាអត្តពលកម្ម ដែលខ្មែរយើងធ្លាប់លេងនាដូវខែចេត្រក្នុងពេលដែលគេដួបជុំគ្នា ធ្វើបុណ្យចូលឆ្នាំក្នុងទីវត្តអារាម នៅតាមភូមិស្រុកកំមានលេងដែរ តែដោយតិច ។

ល្បែងនាញព្រ័ត្រមានរបៀបដូចរៀបរាប់តទៅនេះ :

- គេជ្រើសរកឈើណាមួយជាទំព័រលំនៅរស្អាតល្អធំទូលាយ ហើយគេគូសប្តូលកដីបំពេញក្តាលទី ១ ណ្ឌជាទីសំគាល់ ។

_ គេយកពួរដក់ជូន ឬ ពួរផ្លៅ ១ ធំប៉ុនកដៃក្មេង ឬ កំព្រ័ត្រសែ្បក ប្រវែង ២០ ឬ ៣០ ម៉ែត្រ មកលាតសន្ធឹងកណ្តាលទី ហើយគេយកកន្ទៃរ ឬ កំណាត់សំពត់ចងចំពាក់កណ្តាលពួរឬព្រ័ត្រនោះ សំគាល់ពាក់កណ្តាលម្ខាងម្ខាក់ ។

_ គេជ្រើសយកមនុស្សប្រុស_ស្រី មានមាឌធំៗ ម៉ាំៗប៉ុនគ្នា តែដោយគេទុកកេរស្រីជាកេរខ្សោយជាងប្រុស គេជាក់ចំនួនខាងប្រុស ៨ នាក់ ខាងស្រី ១០ នាក់ បើខាងប្រុសឡើងចំនួនដល់ ១៨ នាក់ ខាងស្រីត្រូវឡើងចំនួនដល់ ២០ គឺឲ្យស្រីលើសពីរៗនាក់ជាដរាប តែការពន្ធឹសចំនួនខាងស្រីនេះស្រេចនៅស្ម័គ្រចិត្តទេ ស្រុកខ្លះចូនតាល ស្រីៗចូលចិត្តលឿងកម្ទាំងទំងប្រុសៗ គេជាក់ចំនួនស្មើគ្នាក៏មាន ។

_ គេជ្រើសយកមនុស្ស ២ នាក់ ខាងប្រុស ២ នាក់ ខាងស្រីដែលមានស្មាគាងរូបរាងធាត់ធំមានកម្លាំងច្រើន ជាក់ឲ្យគាន់ដើមព្រ័ត្រម្នាក់ប្តូនព្រ័ត្រម្នាក់ ពាំងពីរខាង មនុស្សស្គមៗគេឲ្យឈរគាន់កណ្តាលព្រ័ត្រប្រុងចាំពាញយកថ្លៃដៃតែរឿងខ្លួន ។

_ គេជ្រើសយកមនុស្សខាងប្រុសម្នាក់ ខាងស្រីម្នាក់ ឲ្យឈរចំកណ្តាលទីត្រង់ប្រទល់មុខគ្នា ហើយប្រុសម្នាក់តាំងវែកបន្ទុំ ដែលគេហៅធាកកុម្មាឡើងថា " យក្សអែរ " ដោយសំឡេងខ្លាំងវែង ។ រលាក់រលែក ។

ពួកអ្នកគាន់ព្រ័ត្រនឹងអ្នកឈរមើលចាំងប៉ុន្មាន ដួយស្រែកទួលព្រមគ្នា ទៀនថា ហ៊ោរ៉ឺ! ហ៊ោរ៉ឺ! ៣ ដង ។ ពេលធាកកុម្ភ ៣ ដងនោះ មានមនុស្សម្ភាក់ទះសម្ភោរពេញ ៣ បទ តាមចង្វាក់សម្រែក ។

ចប់លើកទី១ ហើយ បើគេចង់លេងលើកទី ២ ទី ៣ ទៀត ស្រែចទៅសន្ធតគ្នា ហើយគេរៀបដូចមុន ក្នុង ១ លើក ។ មានថ្នាក់វេលាពី ៦ នាទីទៅ ១០ នាទី នាឡិកា អាចដើរចាញ់ឈ្នះបាន ។

តីឡាចាញ់ព្រ័ត្រ មានរបៀបលេងប្លែកគ្នាបន្តិចបន្តួចដោយស្រុក គឺស្រុកខ្លះមានស្រែកធាកកុម្ភ យកស្អែរ បន្ទុំ ទឹងទះសម្ភោរបញ្ចើតទៅពេលលេង, ស្រុកខ្លះមិនមានទេ គេចាប់លេងតែម្តង តែរបៀបក្រៅពីនេះ ដូចគ្នាគ្រប់ស្រុក ។

លេងចាញ់ព្រ័ត្រមានដើមកំណើតដំបូងមកអំពីពួកយក្ស ទឹងពួកទៅតាប្រឡងកម្លាំងគ្នា មានក្នុងរឿងកមាយណៈ «កមាស្តិ» ថា:

មានតាលមួយថ្ងៃ ពួកយក្សច្រណែនទឹងពួកទៅតាថា ពួកនេះគ្មានខ្លៃខ្លាំងពូកែជាងពួកយើងជាយក្សប៉ុន្មានទេ ប៉ុន្តែបានជាពួកនេះមានហានៈខ្ពស់ជាងយើងដោយសារព្រះឥសូរទ្រង់ប្រោសប្រាណ បើលេងកម្លាំងគ្នា មុខជាពួកនេះចាញ់ពួកយើងពុំខាន ។ ពួកទៅតាបានឮក៏អៀនខ្មាសនាំគ្នាទៅនិយាយអួតជាតំយក្សវិញថា « យើងមិនខ្លាចទេមានត្រឹម

យក្ស . បើប្រសិនជាចង់ប្រកួតកម្ចាំងគ្នា យើងក៏ហ៊ានដែរ រៀវលែងតែប្រើយុទ្ធពិធី " ។ ពួកយក្សទើងពួកទេវតា ក៏ព្រមព្រៀងគ្នាយកពិធីភាញព្រត្រក្នាល់ល្បងកម្ចាំងគ្នា ថាបើពួកយក្សភាញឈ្នះពួកទេវតា ពួកយក្សត្រូវបានហាន:ខ្ពស់ជាង ពោះបើចូលទៅកាន់ទីគាល់ព្រះឥសូរក្តី ទៅកាន់ទីប្រជុំជាទៃក្តី ត្រូវពួកយក្សបានទីអង្គុយខ្ពស់ជាងទេវតាជាដាប ។ គាលព្រមព្រៀងគ្នាកំណត់រៀលាថា ទីធភាញព្រត្រក្នុងថ្ងៃស្អែកហើយ ពួកទេវតាក៏នាំគ្នា ដើរស្រចុះស្រឡើងជាពួកៗទៅមុខព្រះលានព្រះឥសូរ ។ ពេលនោះគាប់ចួនជាស្តេចភាលីបានទ្រង់ជ្រាប ទង់ត្រាស់ប្រាប់ទៅយថា "ឲ្យយកនាគធ្វើព្រត្រ ឲ្យពួកទេវតាភាញខាងក្បាលនាគ ឲ្យពួកយក្សភាញខាងកន្ទុយនាគ ដល់ពេលកំពុងភាញឲ្យទេវតាខអង្គុយកម្រាមដៃចុចត្រង់ផ្តួតនាគ នាគមុខជាទើរសើប ហើយវាទើងវាត់កន្ទុយឲ្យរបូតពីដៃយក្ស ស្ទុះទៅខាងទីទេវតា ទេវតាមុខជាឈ្នះយក្សជាពុំខាន" ។ ដល់ពេលភាញព្រត្រពួកទេវតាសុំភាញខាងក្បាលនាគ ពួកយក្សក៏យល់ព្រម ហើយទើបយកនាគឈ្មោះវាសុកីជាព្រត្រ ។ លុះភាញទៅ ពួកទេវតាក៏បានឈ្នះពួកយក្សមែន ។

តាមការស្រាវជ្រាវរបស់ក្រុមដំនុំទំរៀមទម្ងាប់ខ្មែរយើញថា:
ប្រទេសខ្មែរយើងមានទំរៀមលេងកីឡាភាញព្រត្រតាំងពីសម័យ

អង្គរ ក្នុងសតវត្សទី ១៧ នៃពុទ្ធសកពាជ ទី ១២ នៃគ្រិស្តសកពាជ
នោះមក ដោយយើញ ព្រះកេរ្តិ៍នៃព្រះមហាក្សត្រខ្មែរព្រះនាមព្រះបាទ
សុរ្យវរ្ម័នទី ២ ដែលទ្រង់បានសាងប្រាសាទនគរវត្ត ហើយទ្រង់ឲ្យឆ្លាក់
លើជញ្ជាំងក្រាសាទនោះ នូវរឿងពួកទេវតានឹងពួកអសុរយកនាគឈ្មោះ
វាសុកីធ្វើព្រំត្រែតាញប្រឡងនឹងគ្នា ជាកស្តុតាង ។

បើយើងធ្វើដំណើរទៅទស្សនាប្រាសាទនគរវត្ត យើងនឹងឃើញ
ចម្ងាក់ប្លែនាគ ១ វែងសន្ធឹង នៅជញ្ជាំងប្រាសាទនោះ ខាងក្បាលនាគ
សុទ្ធតែពួកទេវតា ខាងកន្ទុយនាគសុទ្ធតែពួកយក្ស តាញព្រំត្រែប្រជែងគ្នា
ដូចរបៀបតាញព្រំត្រែយើងសព្វថ្ងៃ ប៉ុន្តែតែយើងយកពួរធ្វើពីដក់ជូង ពីផ្លៅ
ឬពីស្បែក ធ្វើជាព្រំត្រែទៅវិញប៉ុណ្ណោះ ។

ល្បែងតាញព្រំត្រែ ជាកីឡាសំដែងឥទ្ធិពលនៃកម្លាំងកាយនឹងកម្លាំង
ប្រាជ្ញា គឺអ្នកលេងកីឡានេះដែលនឹងមានជ័យជំនះទៅបាន អាស្រ័យ
ដោយកម្លាំងកាយដែលសាមគ្គីព្រមព្រៀងគ្នាផង ដោយកម្លាំងល្បិចដែល
កីឡានេះប្រាប់ដល់អ្នកលេងក្នុងពេលកំពុងលេងផង ដូចជាទេវតាជាអ្នក
ឈ្នះយក្ស តែដោយសារស្តាប់ល្បិចអំពីស្តេចពាលី ហើយបាន
បបួលយក្សយកនាគធ្វើព្រំត្រែ បានតាញខាងក្បាលនាគ បានចាក់ផ្តិតនាគ
ខ្សែរសើប ទើបនាគដួយកម្លាំងទេវតា ទេវតាកំឈ្នះយក្សទៅបាន ។

និពន្ធនេះ ជាទំនាក់ទំនងមួយយ៉ាង គឺជាការអ្វីៗ ទោះជាការងារផ្លូវធម៌ក្តី ការងារផ្លូវលោកក្តី ត្រូវអាស្រ័យដោយកម្លាំងកាយដែលប្រកបដោយសាមគ្គី ទើបកម្លាំងចំណេះវិជ្ជារៀងៗពួកអ្នកប្រតិបត្តិការនោះៗ ទើបអាចសម្រេចប្រយោជន៍ដ៏ធំធេលាយទៅបាន ។

បរិយាយតែប៉ុណ្ណេះ ចប់ត្រឹមប៉ុណ្ណេះ ។

ផ្នែកកាំណត់ជំនួយប្រវត្តិសាស្ត្រ

ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្នុងធមាសទី ១ ឆ្នាំ ១៩៥៩

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ១ មុខ ស្តីអំពីជីវភាពរបស់ខេមរជន ។

អត្ថបទសម្រាប់ប្រឡងប្រជែងនេះ សម្រេចយកនៅធមាសទី ១ គឺតាំងពីខែមករាដល់ដាច់ខែមិថុនា ឆ្នាំ ១៩៥៩ ។

ដូច្នេះ អស់លោកពេះដ៏ឆ្ងាយ ទោះជាស្ត្រី បុរស គ្រហស្ថ ឬបព្វជិត ដែលស្ម័គ្រចិត្តធ្វើជាបេក្ខជនប្រឡង សូមសរសេរតែងអត្ថបទស្តីអំពីជីវភាពរបស់ខេមរជន តាមគោលសំខ្លះដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅដល់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែមិថុនា ឆ្នាំ ១៩៥៩ ។

បេក្ខជនឆ្ងាយអាចយកអត្ថបទប្រឡងប្រជែងទៅឲ្យផ្ទាល់ខ្លួនក៏បាន ផ្ញើតាមប៉ុស្តិ៍ទៅក៏បាន យកទៅដួនសាលាឃុំ ឬ សាលាស្រុក-ខែត្រ ស៊ុំ

ទ្បៃផ្ញើទៅឲ្យកំបាន ដោយការឧដ្ឋសំបុត្រថា :

"ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ"

អត្ថបទដែលប្រឡងជាប់ ត្រូវបានរង្វាន់ជា ៤ ថ្នាក់ :

រង្វាន់លេខ ១	៣០០រៀល
រង្វាន់លេខ ២	៥០០រៀល
រង្វាន់លេខ ៣	៤០០រៀល
រង្វាន់លេខ ៤	២០០រៀល

បេក្ខជនមួយរូប ។ ដែលសរសេរអត្ថបទទៅដាក់ប្រឡង សូមសរសេរនាម ព្រមទាំងលំនៅរបស់ខ្លួនឲ្យច្បាស់ដលើអត្ថបទនោះ ។

ឯសំនួរខាងមុខនេះពុំសូវគ្រប់ខេ បើបេក្ខជនណាជ្រាបការណ៍ឯ-ទៀតក្រៅអំពីសំនួរនេះ ហើយអាចសរសេរឲ្យការណ៍ទៅបាន នោះក្រុមជំនុំអរគុណណាស់ ពីព្រោះសំនួរទាំងប៉ុន្មាននេះគ្រាន់តែជាលំនាំក្បាយផ្លូវតែប៉ុណ្ណោះ ឯការធំបំផុត គឺក្រុមជំនុំចង់ជ្រាបឯកសាររបស់បេក្ខជនណាដែលឲ្យការណ៍ពិស្តារ ហើយនឹងមានតម្លៃតម្រឹមត្រូវល្អសូវគ្រប់, តែបើមិនអាចតែងពិស្តារ តែងតែសង្ខេប តាមដែលចេះចាំក៏ក្រុមជំនុំត្រូវការដែរឲ្យតែអាងគោលច្បាស់លាស់ ហើយនឹងជ្រាបដើមកំណើតត្រឹមត្រូវល្អ។

គោលបញ្ជានៃការប្រឡងប្រជែង

អំពីជីវភាពរបស់ខេមរជន

ខាងក្រោមនេះ សូមជូនសំនួរជាលំនាំដល់លោកអ្នក ដើម្បីឲ្យទឹកយើញការដែលត្រូវសរសេរតែងអំពីជីវភាពរបស់ខេមរជន:

សូមចែកជីវភាពរបស់ខេមរជនជា ៣ ភាគ:

ទី ១ ភាគបឋមវ័យ :

ក) ជីវភាពរបស់កូនប្រុសស្រីនៃខេមរជនតាំងពីថ្ងៃកើតមក រហូតដល់ចេះសើច ចេះក្រឡាប់ ចេះអង្គុយ ចេះដើរ ចេះរត់ ។ល។ មានបែបបទដូចម្តេចខ្លះ? សូមរៀបរាប់អំពីរបៀបចិញ្ចឹម របៀបបំបៅ, របៀបការពារ, របៀបព្យាបាល, របៀបអប់រំកូន ព្រមទាំងទំនៀម ត្រណម ជំនឿ តាមដំណាក់របស់ក្មេង ដែលតែងតែរស់នៅដោយសារអ្នកព្យាបាល ។

ខ) គេកោរសក់ព្រៃឲ្យកូននៅពេលណា ? ពេលនោះ គេមើលពេលដែរឬ ? ហើយគេធ្វើពិធីដូចម្តេចខ្លះនៅពេលនោះ ?

គ) គេបង្ហាត់ដូចម្តេចខ្លះ ដើម្បីឲ្យកូនចេះសម្អាតខ្លួន, ចេះប៉ះពាល់ចំណីត្រឹមត្រូវ, ចេះនិយាយស្តី, ចេះគួរសម, ចេះសុភាសិតបម្រៀនល្បែង

លេង, ចេះតែរៀនសាសនា, ជំនួសអាក្រក់បុណ្យច្បាប, រឿងព្រៃនពាក់-
ព័ន្ធដោយសាសនា ? ហើយគេតែងបង្ហាត់នៅពេលណា គេតែងបង្ហាត់
នៅពេលចាយ ពេលខំនេរល្ងាចៗ យប់ៗ មុនចូលដំណេកឬ?

ឃ) គេផ្តន្ទាទោសក្មេងនៅពេលណា ?

ង) ពាក្យៈការដុតនិងពាក្យសោកាន្ត ប្រែថាម្តេច ? ត្រូវគ្នាឬ
ផ្សេងគ្នា? បើផ្សេងតើពិធីការដុតគេតែងធ្វើដល់កុមារពួកណា? សោកាន្ត
ដល់កុមារពួកណា? គេធ្វើពិធីការដុតឬសោកាន្តនៅពេលណា? គេមើល
ពេលាដែរឬ? ពិធីនោះៗ ដូចម្តេចខ្លះ? គេធ្វើដើម្បីអ្វី?

ច) គេបង្រៀនអក្សរកូននៅវេលាដែលកូនមានអាយុប៉ុន្មានឆ្នាំ ?
ពេលដែលគេឱ្យកូនទៅនៅវត្ត ឬទៅរៀននៅសាលារៀន គេមើលពេលា
ដែរឬ? ហើយនៅពេលនោះ គេតែងធ្វើកិច្ចដូចម្តេច?

ឆ) ចំណែកកូនប្រុស អាយុប៉ុន្មានឆ្នាំដែលគេតែងឱ្យបួសជា
សាមណេរ? គេឱ្យកូនបួសសាមណេរដើម្បីអ្វី? ពេលបួសគេមើលពេលា
ដែរឬ ហើយគេតែងធ្វើពិធីដូចម្តេចខ្លះនៅពេលនោះ ?

ជ) លុះកូនបួសជាសាមណេរហើយ មាតាបិតាតែងខំទុកបម្រុង
យ៉ាងណាខ្លះ ? គេនៅចិញ្ចឹមដែរឬឈប់ចិញ្ចឹមហើយ ?

ឈ) កុលបុត្របិតានៅក្នុងសាមណេរភាពតែងមានដំណើរការយ៉ាងណា?

ជ) តើតែងបួសសាមណេរប៉ុន្មានវស្សាបានសឹក ? ពេលសឹកអំពី
សាមណេរគេមើលពេលាដែរឬទេ ? គេតែងធ្វើពិធីអ្វីខ្លះនៅពេលសឹក
នោះ ? សឹកព័សាមណេរគេហៅថាអ្វី? សឹកប៉ុន្មានថ្ងៃបានទៅនៅផ្ទះបាន?

ឈ) ជីវភាពរបស់ជនដែលសឹកចាកសាមណេរភាគមកមានប្រ-
ការដូចម្តេចខ្លះ ? ហើយពេលនោះទៅក្នុងការទប់ត្នុម្ភរបស់ជនណា ?

ញ) អាយុប៉ុន្មានបានគេឲ្យកូនបួសកឋិន ? គេឲ្យកូនបួសកឋិន
ដើម្បីអ្វី ? ពេលចូលបួសកឋិនគេមើលពេលាដែរឬទេ ? មុនពេលចូល
បួសកឋិន មាតាបិតាតែងរៀតឲ្យកូនទាក់ទងនឹងពួកញាតិសន្តានដូចម្តេច
ខ្លះដែរឬ ?

ដ) រៀបបួសកឋិនតែគ្នាឬនឹងសាមណេរដែរឬបែកគ្នា ? មាន
មានពិធីដូចម្តេចខ្លះ ?

ឋ) កាលបួសជាកឋិនហើយ តើមាតាបិតាតែងទប់ត្នុម្ភដូចម្តេចខ្លះ?
គេនៅចំពាំមដែរ ឬឈប់ចំពាំមហើយ ?

ឍ) កុលបុត្រដែលបិតានៅក្នុងកឋិនភាពតែងមានជីវភាពយ៉ាងណាខ្លះ?

ណ) តើតែងបួសកឋិនប៉ុន្មានវស្សាបានសឹក ? ពេលសឹកចាក
កឋិនភាពតើតែងធ្វើពិធីដូចម្តេចខ្លះ ? ពេលដែលផ្ទាស់ស្បង់ចីពរក្តាម ។
តើគេតែងស្បែកពាក់ដូចម្តេច ? សឹកមកហើយមានការពាក់ទងនឹងទប់-

សកដើងវាត្តជួបម្តេចខ្លះដែរឬទេ ? សឹកឥតិកុគេហៅថាអ្វី ? សឹកប៉ុន្មានថ្ងៃ
ទើបទៅនៅផ្ទះបាន ?

ណ) ដីវាតារបស់ជនដែលសឹកចាកតិក្ខុភាពមកមានប្រការជួប
ម្តេចខ្លះ ? តែងនៅក្នុងការទបត្ថម្ភរបស់ជនណា ? អ្នកទបត្ថម្ភនោះគេតែង
ចែកមតិកឲ្យដោយរបៀបជួចម្តេចខ្លះ ?

ត) កូនប្រុសអាយុប៉ុន្មានបានគេរកកសិយាឲ្យ ? ការរកកសិយា
នោះគេតែងរកដោយបែបបទជួចម្តេចខ្លះ ?

ថ) កូនស្រីអាយុប៉ុន្មានបានគេឲ្យចូលមួប ? គេឲ្យចូលមួបដើម្បីអ្វី ?
ពេលចូលមួបគេតែងធ្វើពិធីជួចម្តេចខ្លះ ? កូននៅក្នុងមួបគេតែងឲ្យបរិភោគ
រហារយ៉ាងណា ? ចូលប៉ុន្មានថ្ងៃ-ខែ-ឆ្នាំបានគេឲ្យចេញ ? ពេលចេញ
មានធ្វើពិធីជួចម្តេចខ្លះ ? ពិធីចូលមួបនិងចេញមួបមានណាធំជាង ?

ទ) កូនស្រីអាយុប៉ុន្មានបានគេឲ្យមានប្តី ?

ធ) មុននឹងឲ្យមានប្តីមាតាបិតាតែងបង្ហាត់ឲ្យកូនចេះដឹងអ្វីខ្លះ?
ដើម្បីឲ្យបានទៅជាមេផ្ទះស្រួលបួលល្អតាមប្រពៃណីខ្មែរ ?

ន) នៅក្នុងគ្រួសារមានការអប់រំក្នុងក្នុងការរួមដំណេកដែរឬ ?
បើមានតើគេអប់រំជួចម្តេចខ្លះ ?

ប) ការអប់រំកូនចៅ ស្រៅពីមាតាបិតា តើមានមីន ។ ល ។ គេ

ជួយអប់រំដែរឬ ? បើជួយតើជួយបែបណាខ្លះ ?

ឆ) ការអប់រំក្មេងក្នុងគ្រួសារតើគេជាស់ប្លែរៅតាមសម័យដែរឬទេ ? បើជាស់តើសម័យបុរាណគេអប់រំដូចម្តេច ? សម័យបច្ចុប្បន្នគេអប់រំដូចម្តេច ?

ទី ២ ភាគមជ្ឈិមវ័យ .

ក) ពេលណាដែលកូនប្រុស ស្ត្រីរៀបការចេញពីផ្ទះមកអាស្រ័យនៅជាមួយឪពុកម្តាយ ? ហើយពេលដែលកូនកាំកន្ទាំនោះគេតែងឆក ជាយការណ៍យកចិត្តដូចម្តេចខ្លះ ?

ខ) មូលហេតុអ្វីខ្លះ ដែលទេមរជនជាន់ក្រោយតែងប្រកបជាអាជីវកម្មយ៉ាងដុំកំភួនជាងគេ ?

គ) ក្នុងភាគមជ្ឈិមវ័យ តើទេមរជនគេតែងចាត់ទុកនូវព្រះពុទ្ធសាសនាដោយកិច្ចដូចម្តេចខ្លះ ដើម្បីឲ្យបានសេចក្តីសុខក្នុងសង្គម នាលោកនេះ ?

ដើរភាពទេមរជនក្នុងភាគនេះ លោកអ្នកអាចមានការសរសើរតែងបានច្រើនណាស់ ប៉ុន្តែដើម្បីឲ្យការនេះមានដុំកំភួនល្អ សូមលោកអ្នកប្រឹងកុំខានរៀបរាប់គោលធំ ។ តាមដែលលោកអ្នកបានធ្លើជ្រាលជ្រៅនូវឬបានយើញការចិញ្ចឹមដើរតធម្មតារបស់ខ្មែរនូវជាន់ប្រទេស ដែលគេធ្លាប់ប្រកបជាន់សម័យបុរាណ ជាន់សម័យបច្ចុប្បន្ន ។

ទី ៣ ភាគបច្ចឹមរឿយ :

ក) ក្នុងភាគនេះបច្ចឹមរឿយ ៗ ខ្ញុំមានគោលបំណងប្រកបអាជីវកម្មដើម្បី ជីវភាពរបស់ខ្លួនដូចម្តេចខ្លះ ?

ខ) ខ្ញុំមានគោលបំណងសម្រេចក្តីក្តៅល់របស់ខ្លួនដោយចរិយោ ដូចម្តេចនៅពេលចាស់ជរា? ហើយពេលនោះគេចាត់ទុកធនធានព្រះពុទ្ធសាសនាដោយកិច្ចយ៉ាងណាខ្លះ ដើម្បីឱ្យខ្លួនគេបានសុខក្នុងលោកខាងមុខ ?

អត្ថបទដែលធើទៅដោយប្រឹងប្រែង លួបលេងអ្នកប្រឡងសរសេរលើសៀវភៅយ៉ាងល្អត្រឹមត្រូវ ដើម្បីយកទៅជាក់ក្នុងចិត្តទុកជាឯកសារនៅមន្ទីរក្រុមជំនុំទៀមទម្លាប់ ឱ្យបានបិត លើរបេរកាលតទៅ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(តមក)

ព្រះមហា ប៉ាំ--ទាត់ រៀបរៀង

អបេតន គុ. នែលមិនមានចេតនា ។

អបេតិត គុ. នែលមិនរវល់គិត ។

អបេម្ហមិ ក្រ. វិ. ដោយតឹតកម្រើក ។

អបៃតន្យ នបុ. អចេតន្យ ។

អប្ប គុ. ភ្លឹះ, ថ្លា, បរិសុទ្ធ ។ -ហ្វាយ គុ. នែលមានចិត្តបរិសុទ្ធ ។ **អប្ផាខ** នបុ. ឈ្មោះស្រះមួយនៅភ្នំហិមាល័យ ។

អប្បទ្វិតិ នបុ. ការយោមិនមាន ។

អប្បភល្ល ចុំ. ខ្លាឃ្មុំ ។

អប្បល នបុ. ការយោមិនកុហក ។

(មានតទៀត)